#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

## ៦. ការចូលរួមជាសាធារណ:

តាមការពិគ្រោះយោបល់ និងការសំភាសន៍ដែលមានការចូលពីសាលាខេត្តព្រះសីហនុ មន្ទីរបរិស្ថានខេត្តព្រះសីហនុ មន្ទីរដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាជនបានឲ្យដឹងថា មានការគាំទ្រទាំងស្រុងទៅលើគម្រោង **អភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី** នៅក្នុងតំបន់កោះក្របីនេះ។ មូលហេតុដែលគាត់ធ្វើការគាំទ្រព្រោះពួកគាត់ចង់ឱ្យតំបន់នេះមានការរីកចំរើនរុងរឿង តាមរយៈការបង្កើតរមណីយដ្ឋានទំនើបបែបលក្ខណៈធម្មជាតិ ដែលធ្វើឱ្យមានកំនើននៃទេសចរណ៍នៅក្នុងតំបន់នេះ។ ទន្ទឹមនឹងការគាំទ្រលើការអភិវឌ្ឍន៍នេះ ពួកគាត់ក៏មានសំណូមពរមួយចំនួនទៅម្ចាស់គម្រោងអភិវឌ្ឍន៍ ដែលមានដូចជា ផ្តល់ឱកាសការងារដល់ប្រជាជននៅក្នុងតំបន់ អនុវត្តការសាងសង់ដោយស្របតាមប្លង់មេជាអាទិភាពដែលបានកំណត់សាងសង់ប្រព័ន្ធបង្ហូរសំណល់រាវ អាងប្រព្រឹត្តិកម្មសំណល់រាវ និងការគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវ។ ចំពោះសំណូមពរ និងកិច្ចការពារបរិស្ថាន សូមឱ្យក្រុមធ្វើការពិនិត្យឱ្យបានទៀងទាត់នូវការបំពុលទឹក ដី និងខ្យល់នៅក្នុងតំបន់អភិវឌ្ឍន៍ ព្រោះដើម្បីធានាថាការអភិវឌ្ឍន៍មិនប៉ះពាល់ដល់ជីវចម្រុះនៅក្នុងតំបន់កោះក្របីនេះឡើយ។

## ៧. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

ការអភិវឌ្ឍន៍គម្រោងរមណីយដ្ឋានកោះក្របី អាចមានហេតុប៉ះពាល់បរិស្ថានមួយចំនួនដូចជា៖ ធនធានព្រៃឈើ សត្វព្រៃ ការបំពុលខ្យល់ ការរំខានដោយសំលេង គុណភាពទឹកលើដី និងក្រោមដី សុខភាព និងសុខមាលភាពសាធារណៈ ។ ទន្ទឹមនឹងមានហេតុប៉ះពាល់បរិស្ថានទាំងនេះ ក្រុមហ៊ុនមានវិធានការកាត់បន្ថយមួយចំនួនដូចខាងក្រោម៖

### ក. ដំណាក់កាលមុនប្រតិបត្តិគម្រោង៖

**សណ្ឋានដី:**

- ឈូសឆាយដីទៅតាមលក្ខណៈសណ្ឋានដី
- សិក្សាពីប្លង់គម្រោងលំអិតជាមុនសិន មុននឹងធ្វើការឈូសឆាយ
- ជៀសវាងការបំបែកយកថ្មច្រើនពេក ឬការជីកយកដីជ្រៅហួសហេតុពេក
- ប្រមូលអាចម៍ដីទៅចាក់បំពេញនៅតំបន់ទំនាប ឬកន្លែងគ្រលុក។

**ការហូរច្រោះដី និងការខូចគុណភាពដី:**

- ការកិនបង្ហាប់ដី
- ការដាំរុក្ខជាតិនៅជុំវិញតំបន់អភិវឌ្ឍន៍ និងរៀបថ្ម ទប់ការបាក់ដី និងហូរច្រោះដី
- មានផែនការគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទ។

**ការបំពុលទឹក:**

- ឈូសឆាយដីនៅរដូវប្រាំង
- ធ្វើការអប់រំដល់បុគ្គលិក-កម្មករឲ្យយល់ដឹងអំពីអនាម័យដោយត្រូវវេចខ្ចប់រាល់សំណល់ផ្ទះបាយរបស់ខ្លួន និងទុកដាក់ឱ្យបានត្រឹមត្រូវ
- សាងសង់ប្រព័ន្ធបង្ហូរសំណល់រាវ

គុណភាពខ្យល់:

- សំណល់ចេញពីសំណង់ត្រូវប្រែកចូលទៅក្នុងការ៉ុង/បាវរូចចងឱ្យជិត មុននឹងធ្វើការដឹកជញ្ជូនយកទៅចោលទៅតាមការកំណត់របស់ ក្រសួងបរិស្ថាន
- បាញ់ស្រោចទឹកនៅក្នុងតំបន់សាងសង់
- ប្រើប្រាស់រថយន្តដឹកជញ្ជូន និងគ្រឿងចក្រថ្មីៗ ព្រមទាំងធ្វើការត្រួតពិនិត្យ និងថែទាំជាទៀងទាត់នូវគុណភាពរបស់វា

**ការរំខានដោយសំលេង និង រំញ័រ:**

-កំណត់ម៉ោងធ្វើការសាងសង់គឺចាប់ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៥:០០ល្ងាច
-បំពាក់ឧបករណ៍ទប់សំឡេងដល់បុគ្គលិក-កម្មករដែលនៅជាមួយគ្រឿងម៉ាស៊ីន
-ប្រើប្រាស់គ្រឿងចក្រ និងម៉ាស៊ីនភ្លើងធុនទំនើបដែលបញ្ចេញសំលេងតិច

**ធនធានព្រៃឈើ និងទីជំរក:**

- កំណត់កន្លែងដែលត្រូវឈូសឆាយដីព្រៃ
- ដាំដើមឈើ និងរុក្ខជាតិឡើងវិញ
- សហការជាមួយស្ថាប័នមានសមត្ថកិច្ច មុននឹងធ្វើការឈូសឆាយ
- ដាក់ពិន័យដល់កម្មករដែលកាប់ព្រៃឈើដោយមិនមានការអនុញ្ញាត
- អប់រំដល់កម្មករឲ្យប្រយ័ត្នពីភ្លើងឆេះព្រៃ។
- តំបន់ដែលគ្មានព្រៃ ក្រុមហ៊ុននឹងធ្វើការដាំបន្ថែម ដើម្បីបង្កើនគម្របព្រៃឈើ និង ប្រែក្លាយទៅជាតំបន់បៃតង។

**ពពួកសត្វព្រៃ:**

- ក្រុមហ៊ុនបានយកសត្វព្រៃមកចិញ្ចឹមនៅលើកោះ នេះបន្ថែមដូចជាសត្វស្វាជាដើម
- ដាំដើមឈើ និងរុក្ខជាតិឡើងវិញ
- ដាក់ពិន័យដល់កម្មករដែលបរបាញ់សត្វព្រៃ។

**ជីវចំរុះក្នុងទឹក:**

- ការឈូសឆាយដីសំរាប់សាងសង់ដៃទេសចរណ៍មានទំហំតូច ហើយអ្នកមៅការរកទីតាំង ណាដែលពុំមានផ្កាថ្ម ដោយជៀសវាងមិនឲ្យមាន ការប៉ះពាល់ដល់ផ្កាថ្មឡើយ។
- ចូលរួមថែទាំនូវគុណភាពទឹកសមុទ្រ និងការពារការហូរច្រោះដី
- គ្រប់គ្រងសំណល់រឹង-រាវឲ្យបានត្រឹមត្រូវ

- ក្រុមហ៊ុនរក្សាព្រៃឈើធម្មជាតិនៅតាមទីជម្រាល ដើម្បីជួយថែរក្សាគុណភាពទឹក និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់គម្រោង។

មុខរបរ និងប្រាក់ចំណូល:

- អនុញ្ញាតិឲ្យប្រជាជននេសាទនៅចម្ងាយ ២៥០ម៉ែត្រពីមាត់ទឹកកោះក្របី ដោយដាក់ពោងបណ្តែតជាសញ្ញានៅជុំវិញកោះ
- ផ្តល់អាទិភាពដល់ប្រជាជនដែលធ្វើការនេសាទនៅជុំវិញកោះក្របីនោះ ចូលបម្រើការងារជាបុគ្គលិក/កម្មករនៅក្នុងដំណាក់កាលសាងសង់

សុខភាព និងសុខាមាលភាពសាធារណ:

- ផ្តល់កន្លែងស្នាក់សមស្របដល់កម្មករ
- សង់បង្គន់ ផ្តល់ទឹកស្អាតប្រើប្រាស់ឱ្យបានគ្រប់គ្រាន់
- ធ្វើការអប់រំសុខភាពដល់កម្មករអំពីអនាម័យទូទៅ និងការបង្ការឆ្លងរោគផ្សេងៗ ជាពិសេស ជំងឺកាមរោគ (មេរោគអេដស៍/ជំងឺអេដស៍)
- ជ្រើសរើសគ្រូពេទ្យប្រចាំការនៅការដ្ឋានសំរាប់ពិគ្រោះព្យាបាល និងសង្គ្រោះបន្ទាន់
- ប្រកាន់យកសុវត្ថិភាពជាចំបងនៅការដ្ឋានសាងសង់។

**ខ. ដំណាក់កាលប្រតិបត្តិគម្រោង៖**

ការបំពុលខ្យល់:

- ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ដើម្បីកាត់បន្ថយការបំពុលខ្យល់
- បង្កើតកន្លែងស្តុកសំរាមនៅលើកោះក្របី និងមានផែនការគ្រប់គ្រងត្រឹមត្រូវ
- អាងចំរោះ តាមអគារនីមួយៗត្រូវមានគំរបបិទជិត
- ដាំដើមឈើនៅតាមប្លុកផ្ទះលំហែកាយនីមួយៗ និងរក្សាទុកតំបន់បៃតងឱ្យបានច្រើន។

ការរំខានដោយសំលេង:

- ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ កាត់បន្ថយប្រើប្រាស់ម៉ាស៊ីនភ្លើង
- ក្រុមហ៊ុនមានផែនការរៀបចំដាំដើមឈើបន្ថែមនៅលើកោះដើម្បីកាត់បន្ថយសំលេងពីទូកនេសាទ និងទូកទេសចរណ៍
- ក្រុមហ៊ុនមានផែនការរៀបចំដាក់ស្លាកសញ្ញា ពោងបណ្តែតទឹក ដើម្បីកំណត់កន្លែងនេសាទ និងជិះទូកទេសចរណ៍។

គុណភាពទឹក:

- បង្កើតកន្លែងស្តុកសំរាមនៅក្នុងកោះក្របី ហើយយកទៅទុកដាក់នៅលើដីគោកតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច
- សាងសង់អាងចំរោះ និងប្រព័ន្ធលូឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមបទដ្ឋាននៃការបញ្ចេញសំណល់រាវទៅក្នុងប្រភពទឹកសាធារណៈរបស់ក្រសួងបរិស្ថាន។

ធនធានព្រៃឈើនិងសត្វព្រៃ:
- ដាំដើមឈើ និងរុក្ខជាតិឡើងវិញ
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីប្រលែងសត្វបន្ថែមនៅលើកោះ
- អប់រំដល់កម្មករ និងអ្នកទេសចរណ៍ឲ្យប្រយ័ត្នពីភ្លើងឆេះព្រៃ។

ជីវចំរុះក្នុងទឹក:
- រក្សាទុកព្រៃនៅតាមមាត់សមុទ្រ ព្រមទាំងដាំដើមឈើឡើងវិញនៅតំបន់ណាដែលគ្មានគម្របព្រៃឈើ
- ចូលរួមថែទាំនូវគុណភាពទឹកសមុទ្រ និងផ្កាថ្ម
- ការពារការហូរច្រោះដី
- គ្រប់គ្រងសំណល់រឹង-រាវឲ្យបានត្រឹមត្រូវ
- ហាមការនេសាទខុសច្បាប់។

មុខរបរ និងប្រាក់ចំណូលះ
- អនុញ្ញាតប្រជាជននេសាទនៅចម្ងាយ ២៥០ម៉ែត្រពីមាត់ទឹក
- ផ្តល់អាទិភាពដល់ប្រជាជន ដែលធ្វើការនេសាទនៅជុំវិញកោះ ចូលបម្រើការងារជាបុគ្គលិក/កម្មករនៅក្នុងដំណាក់កាលដំណើរការគម្រោង
- រៀបចំមូលនិធិបរិស្ថាន-សង្គម សម្រាប់បណ្តុះបណ្តាលប្រជាជនឲ្យមានជំនាញអាចធ្វើការនៅក្នុងតំបន់អភិវឌ្ឍន៍បានជាដើម។

សុខភាព និងសុខមាលភាព សាធារណ:
- រមណីយដ្ឋានទេសចរណ៍ដ៏ប្រណិត សម្រាប់ទាក់ទាញអ្នកទេសចរណ៍មកស្នាក់នៅលំហែកាយ ងូតទឹកសមុទ្រ និងការចុះទស្សនាផ្កាថ្មបាតសមុទ្រ។
-ដាក់ផ្លាកសញ្ញាពោងបណ្តែតទឹកនៅតំបន់មានទឹកជ្រៅ ឬតំបន់ដែលអាចងូតទឹកបាន ឬតំបន់អាចជិះទូក ឬម៉ូតូលើទឹកបាន។
- ត្រូវបំពាក់សម្ភារៈការពារខ្លួនដូចជាអាវពោង វ៉ែនតា និងសម្ភារៈផ្សេងៗទៀតនៅពេលចុះលេងទឹក។
- ត្រៀមឧបករណ៍ មធ្យោបាយ សម្ភារៈសង្គ្រោះបន្ទាន់ និងគ្រូពេទ្យប្រចាំការ។

ការប្រើប្រាស់ទឹកស្អាត និងអគ្គិសនី:
- ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ
- រៀបចំអាងស្តុកទឹកភ្លៀង
- រៀបចំប្រព័ន្ធប្រើប្រាស់ទឹក និងអគ្គិសនីដោយមានលក្ខណ:សន្សំសំចៃ
- ជូនដំណឹងដល់អ្នកទេសចរឱ្យយល់ដឹងពីការប្រើប្រាស់ទឹក និងភ្លើង ដោយសន្សំសំចៃ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- ក្រុមហ៊ុនរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹក និងអគ្គិសនីសំរាប់បំរើការនៅក្នុងកោះក្របី នេះឲ្យគ្រប់គ្រាន់។

គ្រោះថ្នាក់ដោយគ្រោះធម្មជាតិ:

- បំពាក់ឧបករណ៍ការពាររន្ទះ Lightning System នៅក្នុងប្លុកផ្ទះវីឡានីមួយៗនេះ ដើម្បីការពាររន្ទះបាញ់
- បំពាក់ប្រព័ន្ធគ្រប់គ្រងអគ្គីភ័យយ៉ាងគ្រប់គ្រាន់ និងមានប្រសិទ្ធិភាពខ្ពស់
- បណ្តាញអគ្គិសនីនៅក្នុងអគារត្រូវបានរៀបចំ ឡើងដោយវិស្វករមកពីបរទេស និងជំនាញក្នុងស្រុកដើម្បីធានាអោយបាននូវសុវត្ថិភាព។

## គ. ដំណាក់កាលបញ្ចប់គម្រោង

ការបំពុលខ្យល់:

- ក្រុមហ៊ុនបានរក្សាទុកព្រៃធម្មជាតិដែលមានស្រាប់នៅលើកោះបាន៨០% ដើម្បីរក្សាលំនឹងធម្មជាតិ និងកាត់បន្ថយការបំពុល។
- ក្រុមហ៊ុននឹងបំពាក់ឧបករណ៍ផលិតកម្មស្អាត នៅតាមបំពង់បញ្ចេញផ្សែងរបស់ទូកកប៉ាល់ និងគ្រឿងម៉ាស៊ីនផ្សេងៗ។
- រាល់សម្ភារៈ និងឧបករណ៍ផ្សេងៗក្នុងតំបន់គម្រោង ក្រុមហ៊ុនមិនយកចេញទេ។

ការរំខានដោយសំលេង និងរំញ័រ:

- ក្រុមហ៊ុនមានផែនការរៀបចំដាំដើមឈើនៅតាមផ្លូវសំខាន់ៗមួយចំនួន និងនៅតាមសួនសាធារណៈ ដើម្បីជួសជុលនូវព្រៃឈើដែលបាត់បង់ និងជួយកាត់បន្ថយការរំខានដោយសំលេងពីទូកនេសាទ ទូកទេសចរណ៍ និងមាស៊ីននានាទៀត។
- ក្រុមហ៊ុនបានរៀបចំដាក់ផ្លាកសញ្ញាចរាចរណ៍នៅជុំវិញកោះ ដើម្បីកំណត់កន្លែងសម្រាប់ទូកនេសាទ និងទូកទេសចរណ៍។
- រាល់សម្ភារៈ និងឧបករណ៍ផ្សេងៗក្នុងតំបន់គម្រោង ក្រុមហ៊ុនមិនយកចេញទេ។

គុណភាពទឹក:

-សហការជាមួយមន្ទីរសាធារណៈការខេត្តព្រះសីហនុ ដើម្បីសំអាតភក់នៅក្នុងអាងសិបទិក។

-ការដេកជញ្ជូនចេញត្រូវបានធ្វើឡើងដោយមានការបំរ៉ុងប្រយ័ត្នចំពោះការកំពប់រំលេចជ្រាប។

- សម្ភារៈចាស់ៗ និងដឹងជញ្ជូនចេញ ហើយចែកចាយជូនប្រជាជននូវសម្ភារៈដែលអាចប្រើប្រាស់បាន។ ចំណែកសម្ភារៈប្រើប្រាស់មិនបានក្រុមហ៊ុនសហការជាមួយក្រុមហ៊ុនប្រមូលសំរាមដើម្បីយកទៅបោះចោលនៅទីលានចាក់សំរាមខេត្តព្រះសីហនុ។

**ជីវៈចម្រុះក្នុងទឹកសមុទ្រ:**

- ក្រុមហ៊ុនត្រូវរក្សាទុកព្រៃនៅតាមតំបន់ឆ្នេរជុំវិញកោះ ទៅតាមការកំណត់របស់ក្រសួង/ស្ថាប័នពាក់ព័ន្ធ ព្រមទាំងធ្វើការដាំដើមឈើនៅតាមឆ្នេរណាដែលគ្មានគំរបព្រៃ ឬមានព្រៃរេចរឹល។

-សំណល់ភក់ដែលនៅសេសសល់ក្រុមហ៊ុន នឹងសហការជាមួយមន្ទីរសាធារណៈការ និងដឹកជញ្ជូន ដើម្បីដឹកជញ្ជូនចេញទៅចោលនៅទីតាំងដែលមន្ទីរសាធារណៈការ បរិស្ថាន និងអាជ្ញធរខេត្តអនុញ្ញាត។

-ការដឹកជញ្ជូនសំណល់ភក់ចេញ គឺ ត្រឹមត្រូវតាមបច្ចេកទេសកុំឲ្យមានការកំពប់ ឬលេចជ្រាប។

**មុខរបរ និងប្រាក់ចំណូល:**

-ម្ចាស់គម្រោងនឹងផ្តល់វគ្គអប់រំបណ្តុះបណ្តាលបុគ្គលិក ទាំងអស់ឲ្យមានជំនាញកាន់តែច្បាស់លាស់ និងពិតប្រាកដ ដែលពួកគាត់អាចរកការងារបានធ្វើនៅពេលបញ្ចប់គម្រោង។

-ផ្តល់ពត៌មានជូនបុគ្គលិក នៅពេលវេលាបញ្ចប់គម្រោងឲ្យបានច្បាស់លាស់ ដែលពួកគាត់អាចរកការងារនៅកន្លែងទៀតបានធ្វើនៅពេលបញ្ចប់គម្រោង។

-នៅពេលបញ្ចប់ក្រុមហ៊ុន នឹងសហការជាមួយរដ្ឋាភិបាល ដើម្បីអនុញ្ញាតឲ្យបុគ្គិលិកទាំងអស់អាចបន្តការងារធ្វើដូចធម្មតា។

## ៨. ផែនការគ្រប់គ្រងបរិស្ថាន

កម្មវិធីអង្កេតតាមដានគម្រោង គឺជាកម្មវិធីមួយសម្រាប់ធ្វើការត្រួតពិនិត្យ និងតាមដាននូវរាល់ហេតុប៉ះពាល់បរិស្ថានទាំងឡាយ ដែលអាចនឹងកើតមានឡើងដោយសារសកម្មភាពរបស់គម្រោងនៅក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិគម្រោង និងប្រតិបត្តិគម្រោងដើម្បីផ្តល់ភាពងាយស្រួលឲ្យម្ចាស់គម្រោងរិះរកវិធានការកាត់បន្ថយនូវហេតុប៉ះពាល់ទាំងនោះ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ។

ការត្រួតពិនិត្យបញ្ហាបរិស្ថាននឹងត្រូវអនុវត្ត ដោយម្ចាស់គម្រោងនៅគ្រប់ដំណាក់កាលនៃគម្រោង។ លទ្ធផលនៃការត្រួតពិនិត្យនេះ ក្រុមហ៊ុននឹងធ្វើរបាយការណ៍ផ្ញើជូនក្រសួងបរិស្ថានរៀងរាល់ ០៦ ខែម្តង ដើម្បីចុះពិនិត្យ និងអង្កេតតាមដានសម្រាប់កែលំអក្នុងកិច្ចដំណើរការរបស់

#322P, St.271Z, Sk.Terk Tla, Khan Resey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

គម្រោង ស្របតាមពិសោធន៍និងបច្ចេកទេស និងបញ្ចៀសបាននូវហេតុប៉ះពាល់បរិស្ថានអវិជ្ជមានធ្ងន់ធ្ងរឲ្យដល់កម្រិតអប្បបរមា។ ចំណែកហេតុប៉ះពាល់វិជ្ជមាន ក្រុមហ៊ុននឹងខិតខំធ្វើឲ្យប្រសើរឡើងដល់កម្រិតអតិបរមា។

## ៩. ការវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន

ការវិនិយោគលើគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី (កោះចន្លុះ) ពិតជាការ អភិវឌ្ឍមួយ ដែលអាចចូលរួមចំណែកដល់ការរីកចម្រើនលើវិស័យទេសចរណ៍ទាំងនៅក្នុងតំបន់ដីសម្បទាន ទាំងនៅក្នុងប្រទេសកម្ពុជាទាំងមូល។ ការអភិវឌ្ឍនេះក៏ជាផ្នែកមួយដែលបានចូលរួមជួយអភិវឌ្ឍន៍សង្គម ដោយបានផ្តល់នូវឱកាសការងារជូនដល់ប្រជាជនដែលរស់ក្បែរ ឬក្រៅតំបន់នោះផងដែរ តាមរយៈការផ្តល់ការងារជាកម្មករសំណង់ក្នុងដំណាក់កាលសាងសង ផ្តល់ការងារជាបុគ្គលិកបម្រើក្នុងរមណីយដ្ឋានក្នុងដំណាក់កាលប្រតិបត្តិគម្រោង និងថែមទាំងផ្តល់ឱកាសការងារផ្សេងទៀតដូចជាការលក់ដូរវត្ថុអនុស្សាវរីយ៍។ ការផ្តល់នូវឱកាសការងារនេះ ហាក់បីដូចជាជួយដល់ស្ថានភាពសេដ្ឋកិច្ចសង្គមក្នុងតំបន់នោះឱ្យមានដំណើរការ នៃចរន្តសាច់ប្រាក់ក្នុងតំបន់នោះថែមទៀតផង។

ក្រៅពីការចូលរួមអភិវឌ្ឍន៍សង្គម គម្រោងវិនិយោគនេះក៏បានរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិតាមរយៈការបង់ពន្ធអាករចូលរដ្ឋថែមទៀតផង។ តាមរយៈការអភិវឌ្ឍគម្រោងនេះ រដ្ឋាភិបាលអាចនឹងទទួលបានប្រាក់ចំណូលក្នុងរូបភាពជាការបង់ពន្ធអាករ ប្រមាណ **៩២.៩០០ ដុល្លាសហរដ្ឋអាមេរិក** ក្នុងមួយឆ្នាំ ដែលស្មើនឹង៣%នៃប្រាក់ចំណូលដុលរបស់ក្រុមហ៊ុន។ ក្រៅពីការបង់ពន្ធពីការកាត់ពន្ធប្រាក់ចំណូលដុលរបស់ក្រុមហ៊ុន រដ្ឋាភិបាលក៏នឹងអាចទទួលបានចំណូលផ្សេងទៀតដូចជាការកាត់ពន្ធប្រាក់បៀវត្តន៍របស់បុគ្គលិកក្រុមហ៊ុន។

លើសពីនេះ គម្រោងអភិវឌ្ឍន៍គឺជាប្រភេទអភិវឌ្ឍលើវិស័យទេសចរណ៍ ដោយផ្តោតលើការសាងសង់ និងប្រតិបត្តិលើរមណីយដ្ឋានលំហែកាយលើកោះ។ ហេតុនេះ ការអភិវឌ្ឍនេះពុំមានសកម្មភាពណាមួយដែលគំរាមកំហែងដល់ធនធានបរិស្ថាននៅក្នុងតំបន់នោះទេ។ តែផ្ទុយទៅវិញ គម្រោងនេះ នឹងមានផែនការដាំដើមឈើលម្អរបន្ថែមទៀតដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ ឱ្យចូលទស្សនា និងសម្រាក់កម្សាន្តនៅទីនោះ។

ក្រលែកមកមើលពីផលចំណេញរបស់ក្រុមហ៊ុនវិញ យើងអាចសន្និដ្ឋានបានថាការវិនិយោគនេះ ក៏អាចផ្តល់នូវផលចំណេញច្រើនគួរសមដល់អ្នកវិនិយោគ ហើយដោយផ្អែកលើវិធីសាស្ត្រវិភាគហានិភ័យនៃស្ថានភាពហិរញ្ញវត្ថុនៃគម្រោងអភិវឌ្ឍនេះ យើងបានរកឃើញថាពុំមានហានិភ័យណាមួយនឹងអាចកើតឡើងចំពោះគម្រោងនេះ ក្នុងកំឡុងពេលប្រតិបត្តិដំណើរការជាផ្លូវការឡើយ។ ជាក់ស្តែងតាមលទ្ធផលវិភាគស្ថានភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចរបស់

គម្រោងបានបង្ហាញថាជាមធ្យមការវិនិយោគនេះនឹងអាចទទួលបានផលចំណេញសុទ្ធ (net benefit) ប្រមាណជាង**២,៥លានដុល្លា**ក្នុងមួយឆ្នាំ។ បន្ថែមពីនេះទៀត តាមការវិភាគការប្រៀបធៀបសន្ទស្សន៍ផលចំណេញខាត (Benefit-cost ratio) នៅករណីធម្មតា (base-case scenario) បានបង្ហាញថាស្មើនឹង១,៥ ដែលជាតួលេខធំជាង១ នោះមានន័យថាការវិនិយោគនេះគឺទទួលបានផលចំណេញច្រើន។ ដូចនេះការវិនិយោគនេះគួរតែមានការគាំទ្រពីភាគីរដ្ឋាភិបាលដើម្បីអនុញ្ញាតឱ្យការប្រតិបត្តិគម្រោងនេះដំណើរការទៅបានដោយរលូន ដែលវាជាការអភិវឌ្ឍលើវិស័យទេសចរណ៍ ក៏ដូចជាជួយដល់សង្គម និងសេដ្ឋកិច្ចជាតិផងដែរ។

## ១០. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

គម្រោងអភិវឌ្ឍន៍**រមណីយដ្ឋានកោះក្របី** របស់ក្រុមហ៊ុន RPB Investment Co., LTD. ដែលមានទីតាំង ស្ថិតនៅលើតំបន់ កោះក្របី ខេត្តព្រះសីហនុ ត្រូវបានរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានសំរេចជាចុងក្រោយដោយចេញអនុក្រឹត្យលេខ ១៦១ អនក្រ.បក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការធ្វើអនុបយោគប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទៅជាទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋក្នុងតំបន់ កោះក្របី ដោយជួលដីនេះទៅឲ្យក្រុមហ៊ុនតាមកិច្ចសន្យារវាងរាជរដ្ឋាភិបាល និងក្រុមហ៊ុនចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៨។ គម្រោងនេះគឺឆ្លើយតបនឹងផែនការអភិវឌ្ឍន៍ទេសចរណ៍ដែលជាមាសបៃតង ដែលកំពុងមានកំណើនអ្នកទេសចរជារៀងរាល់ឆ្នាំ និងដើម្បីកែប្រែមុខមាត់ខេត្តព្រះសីហនុ ឲ្យក្លាយទៅជាទីក្រុងស្អាតបរិស្ថានបៃតង និងសាកសមជាតំបន់អេកូទេសចរណ៍ដ៏ប្រណិត។

តាមលទ្ធផលនៃការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងបានបង្ហាញឲ្យឃើញថា ទីតាំងគម្រោងស្ថិតនៅក្នុងតំបន់កោះក្របីដែលមានវត្តមានធនធានព្រៃឈើ និងសត្វព្រៃ ឬតំបន់អេកូឡូស៊ីក្នុងទឹក ប៉ុន្តែពុំមានវត្តមានរបស់ប្រជាពលរដ្ឋរស់នៅតំបន់នេះទេ។

លើសពីនេះទៀត សកម្មភាពឈូសឆាយដី ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការសាងសង់អគារផ្ទះលំហែកាយ និងការដាក់ឲ្យប្រើប្រាស់គម្រោងនេះនឹងមានហេតុប៉ះពាល់អវិជ្ជមានមួយចំនួនទៀតដូចជា ការបំពុលទឹក ការបំពុលខ្យល់ ការរំខានដោយសំលេងនិងរំញ័រ ធនធានព្រៃឈើ សត្វព្រៃ ជីវៈចំរុះក្នុងទឹក មុខរបរ និងប៉ះដល់សុខភាពសាធារណៈ។

ទោះបីជាមានហេតុប៉ះពាល់អវិជ្ជមានយ៉ាងណាក៏ដោយ ការសិក្សាបានបង្ហាញឲ្យឃើញថា ការប៉ះពាល់ទាំងអស់នេះអាចគ្រប់គ្រង និងកាត់បន្ថយបានមួយចំនួនធំតាមរយៈការអនុវត្តឲ្យបានត្រឹមត្រូវនូវវិធានការកាត់បន្ថយនានា។

អនុសាសន៍មួយចំនួនដែលក្រុមហ៊ុនវិនិយោគត្រូវអនុវត្ត នៅក្នុងដំណាក់កាលមុនសាងសង់ សាងសង់ និងប្រតិបត្តិគម្រោង ដូចមានរៀបរាប់ដូចខាងក្រោម៖

→ រាល់លក្ខខណ្ឌក្នុងការរៀបចំគម្រោង និងការសាងសង់ត្រូវគោរពតាមគោលការណ៍ ណែនាំ និងបទដ្ឋានបច្ចេកទេសសំណង់របស់ប្រទេសកម្ពុជា ឬអន្តរជាតិ។

→ ត្រូវមានការសហការល្អជាមួយគ្រប់ក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធនានានៅគ្រប់ដំណាក់កាលសាងសង់ និងការដាក់ឲ្យ ដំណើរការ ដូចជា ការជូនដំណឹង ការផ្សព្វផ្សាយស្តីពីកម្មវិធីសាងសង់ សុវត្ថិភាព ការពារគ្រោះថ្នាក់ទៅដល់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

→ ម្ចាស់គម្រោង ក្រុមហ៊ុនទីប្រឹក្សាសាងសង់ អ្នករៀបចំគម្រោងប្លង់ និងអ្នកម៉ៅការ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមវិធានការកាត់បន្ថយហេតុប៉ះពាល់ និងកម្មវិធីត្រួតពិនិត្យដូចដែលបានកំណត់ក្នុងផែនការគ្រប់គ្រងបរិស្ថាន កិច្ចសន្យាការពារបរិស្ថាន កិច្ចសន្យាសាងសង់ និងឯកសារបច្ចេកទេសផ្សេងៗទៀតដែលទាក់ទងនឹងគម្រោងវិនិយោគទាំងមូល។

ជាចុងបញ្ចប់ ក្រុមហ៊ុន RPB Investment Co., LTD. ដែលជាក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី មានឱកាសក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជាឲ្យមានការរីកចំរើនយ៉ាងឆាប់រហ័ស។

ដូចនេះ ក្រុមហ៊ុនសូមសំណូមពរដល់ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធនានា មេត្តាអនុញ្ញាតជួយជ្រោមជ្រែង និងបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុន RPB Investment Co., LTD. ដើម្បីអនុវត្តគម្រោងសាងសង់រមណីយដ្ឋានកោះក្របីនេះឲ្យបានសមស្របនឹង ច្បាប់ស្តីពីវិនិយោគ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី១៖
# សេចក្តីផ្តើម

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូក១៖ សេចក្តីផ្តើម

## ១.១ សាវតា

ព្រះរាជាណាចក្រកម្ពុជាក្នុងពេលបច្ចុប្បន្នមានសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់ល្អប្រសើរ និងមានការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្នុងនោះមានវិស័យកសិកម្ម វិស័យកាត់ដេរ វិស័យសំណង់ និងវិស័យទេសចរណ៍មានការរីកចំរើនខ្លាំង ហើយបានរួមចំណែកក្លាយជាសសរទ្រូងទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចកម្ពុជា។ ដោយឡែក ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធកាន់តែទទួលបាននូវការអភិវឌ្ឍន៍ដ៏ល្អប្រសើរគួរឲ្យកត់សម្គាល់ផងដែរ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ ជាមួយនឹងការរីកចំរើនឥតឈប់ឈរនេះ រាជរដ្ឋាភិបាលបានប្រកាន់ខ្ជាប់នូវគោលនយោបាយនៃការជំរុញនូវកំណើនសេដ្ឋកិច្ចក្នុងដំណើរឆ្ពោះទៅរកការអភិវឌ្ឍន៍ **សេដ្ឋកិច្ចបៃតង** នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក្នុងស្មារតីឆ្លើយតបទៅនឹងនិន្នាការអភិវឌ្ឍន៍ថ្មីនេះ កម្ពុជាបានដាក់ចេញនូវយុទ្ធនាការ **ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ** ដែលជាជម្រើសយុទ្ធសាស្ត្រមួយដ៏សមស្របបំផុតក្នុងការចូលរួមអភិវឌ្ឍទេសចរណ៍បៃតង និងការធ្វើឲ្យកម្ពុជាឆ្ពោះទៅរកភាពស្អាត និងបៃតង។

ការរីកចំរើននៃវិស័យទេសចរណ៍កម្ពុជា បានឆ្លុះបញ្ចាំងយ៉ាងប្រត្យក្ស អំពីសារៈសំខាន់នៃកត្តាសន្តិសុខ សុវត្ថិភាព ស្ថេរភាពនយោបាយ ដែលជាកត្តាកំណត់ និងជាមូលដ្ឋានសម្រាប់ធានាចីរភាព កំណើននៃវិស័យទេសចរណ៍។ ជាការពិត ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា វិស័យទេសចរណ៍កម្ពុជាមានការរីកចំរើនគួរឲ្យកត់សំគាល់ និងទទួលបានសមិទ្ធផលធំៗ ហើយវិស័យទេសចរណ៍ត្រូវបានចាត់ទុកជាវិស័យអាទិភាពដ៏សំខាន់មួយក្នុងការកសាងសេដ្ឋកិច្ច-សង្គម ដោយបាននាំមកនូវចំណូលជូនជាតិ ផ្តល់ឱកាសការងារ និងចូលរួមដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។ [1]ជាក់ស្តែងក្នុងឆ្នាំ២០១៣ កម្ពុជាទទួលបានទេសចរអន្តរជាតិចំនួន**៤.២១០.១៦៥នាក់** ក្នុងកំណើន**១៧,៥%** (បើប្រៀបធៀបនឹងឆ្នាំ២០១២) ក្នុងនោះមកពីតំបន់អាស៊ីប៉ាស៊ីហ្វិក ៧៦% មកពីអឺរ៉ុប ១៦% និងមកពីអាមេរិក។ ក្នុងចំណោមទីផ្សារសំខាន់ទាំង១០របស់កម្ពុជាមាន វៀតណាម ចិន កូរ៉េ ឡាវ ថៃ ជប៉ុន អាមេរិច

---

[1] សុន្ទរកថារបស់ឯកឧត្តមថោងខុនក្នុងឱកាសសន្និបាតបូកសរុបសភាពការណ៍អនុវត្តការងារទេសចរណ៍ឆ្នាំ២០១២-២០១៣

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

អូស្ត្រាលី រុស្ស៊ី បារាំង ជាមួយនឹងកំណើនទេសចរក្នុងស្រុកប្រមាណ**៧លាននាក់** (ដែលមានកំណើនប្រមាណ៣%) ដោយបាននាំមកនូវចំណូលប្រមាណ២.៥៤៧លានដុល្លា ចាក់បញ្ចូលក្នុងសេដ្ឋកិច្ចកម្ពុជា (ស្មើនឹង ១៥,៥% នៃទិន្នផលសរុបក្នុងស្រុកGDP) និងបង្កើតការងារដោយផ្ទាល់ប្រមាណ **៦២ម៉ឺននាក់** និងដោយប្រយោលរាប់ម៉ឺននាក់ទៀត។ តាមការព្យាករណ៍របស់ក្រសួងទេសចរណ៍ឆ្នាំ២០១៤នេះ កម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណ **៤.៧លាននាក់** ហើយនៅឆ្នាំ២០១៥ ប្រមាណ**៥លាននាក់** ហើយនៅឆ្នាំ២០២០ កម្ពុជានឹងអាចទទួលភ្ញៀវទេសចរអន្តរជាតិប្រមាណ **៧,៥-៨លាននាក់** ជាមួយនឹងចំណូលជាតិសរុបប្រមាណ **៥ពាន់លានដុល្លា** និងបង្កើតការងារដោយផ្ទាល់ប្រមាណ **៨៥លាននាក់**។

តាមរបាយការណ៍ទេសចរណ៍ក្នុងរយៈពេលកន្លងមកនេះ ទេសចរណ៍ប្រទេសកម្ពុជាបានក្លាយទៅជាគោលដៅទស្សនាដ៏សំខាន់របស់ភ្ញៀវទេសចរ ដែលភ្ញៀវភាគច្រើនមកលេងកំសាន្តទស្សនារមណីយដ្ឋាន វប្បធម៌-ប្រវត្តិសាស្ត្រ ធម្មជាតិ និងមកសម្រាកលំហែកាយនៅតាមតំបន់ឆ្នេរដ៏ច្រើនបន្ថែមទៀត។ ដើម្បីលើកស្ទួយនូវវិស័យទេសចរណ៍នេះ **ក្រុមហ៊ុន អភីប៊ី អ៊ិនវេសមេន ខូអិលធីឌី** (RPB Investment Co. Ltd) បានចូលរួមចំណែក ក្នុងការក៏សាងហេដ្ឋារចនាសម្ព័ន្ធដោយសាងសង់តំបន់អេកូទេសចរណ៍ផងដែរ ហើយបច្ចុប្បន្ននេះក្រុមហ៊ុនកំពុងបានសាងសង់គម្រោងអភិវឌ្ឍន៍បង្កើតនូវ **រមណីយដ្ឋានកោះក្របី** ដែលមានទីតាំងស្ថិតនៅ ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ក្រុមហ៊ុន **អភីប៊ី អ៊ិនវេសមេន ខូអិលធីឌី** នេះគឺជាក្រុមហ៊ុនមានឈ្មោះល្អដ៏ល្បីនៅប្រទេសរុស្ស៊ី ផ្នែកអភិវឌ្ឍន៍រមណីយដ្ឋាន អចលទ្រព្យ និងបានអភិវឌ្ឍន៍យ៉ាងជោគជ័យជាមួយគម្រោងរមណីយដ្ឋានជាច្រើននៅក្នុងប្រទេសរុស្ស៊ី។

គម្រោងអភិវឌ្ឍន៍ **រមណីយដ្ឋានកោះក្របី** ត្រូវបានគេរំពឹងថានឹងរៀបចំឲ្យមានលក្ខណៈស្តង់ដារថ្មីមួយសម្រាប់ក្រុងព្រះសីហនុ ឲ្យទៅជាតំបន់ទាក់ទាញភ្ញៀវទេសចរថ្មីមួយនៅលើផែនទីរមណីយដ្ឋានទាំងអស់លើពិភពលោក ដើម្បីទាក់ទាញដល់ភ្ញៀវទេសចរដែលបានទស្សនារតនៈសម្បត្តិអង្គរ និងបន្តស្នាក់នៅកាន់តែយូរថែមទៀតតាមរយៈដំណើរកំសាន្តតំបន់ឆ្នេរនៃប្រទេសកម្ពុជា។ បន្ថែមពីនេះទៅទៀត ការអភិវឌ្ឍន៍នឹងរំពឹងថា នឹងមានកំនើនភ្ញៀវទេសចរ ការផ្តល់នូវការងារថ្មីដែលមានស្តង់ដារ ដល់ប្រជាជននៅក្នុងតំបន់ ឲ្យមានលក្ខណៈល្អប្រសើរជាងមុន រួមមាន ការផ្តល់ជូននូវកន្លែងស្នាក់នៅ អាហារ កម្មវិធីកំសាន្តផ្សេងៗ សកម្មភាពពេលទំនេរ កម្មវិធីបណ្តុះបណ្តាល និងទេពកោសល្យបន្ថែមទៀតដល់ពួកគាត់។ ចំពោះអ្នកទេសចរវិញ នឹងត្រូវបានទទួលបានការអប់រំ ខាងផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រទំនៀមទំលាប់ប្រពៃណី សិល្បៈជាដើម។ លើសពីនេះទៅទៀតគម្រោងអភិវឌ្ឍន៍ នឹងបញ្ចូលនូវសកម្មភាពមនុស្សធម៌សម្រាប់ជួយដល់សង្គមខ្មែរផងដែរ។ គម្រោងនេះនឹងផ្តល់នូវអត្ថប្រយោជន៍ដល់ប្រជាជននៅក្នុងតំបន់ និងភ្ញៀវទេសចរណ៍ ក្រុមហ៊ុននឹងរៀបចំអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធទាំងមូល ឲ្យមានលក្ខណៈល្អប្រសើរឡើងនឹងចូលរួមលើក

កម្ពស់វិស័យទេសចរណ៍ ការអភិវឌ្ឍន៍សង្គម និងការធ្វើឲ្យមានកំណើនសេដ្ឋកិច្ចជាតិជាដើម។ ទន្ទឹមនឹងផលប្រយោជន៍ដ៏ច្រើនដែលកើតចេញពីគម្រោងអភិវឌ្ឍន៍កោះក្របីនេះ វាក៏អាចបង្កើតឲ្យមាននូវផលប៉ះពាល់បរិស្ថានមួយចំនួន នៅក្នុងតំបន់នោះផងដែរ។

ដូចនេះ ដើម្បីស្វែងរកនូវចំនុចអវិជ្ជមាននានាដែលកើតចេញពីគម្រោងអភិវឌ្ឍន៍ ក៏ដូចជាដំណោះស្រាយ និងវិធានការនៃការកាត់បន្ថយនូវហានិភ័យនានា ការអភិវឌ្ឍន៍នេះតម្រូវឲ្យមានការសិក្សាអំពី ហេតុប៉ះពាល់បរិស្ថាន និងសង្គមជាមុនសិន ដែលស្របទៅនឹងគោលការណ៍នៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ អនុក្រឹត្យស្តីពីការគ្រប់គ្រងការបំពុលផ្សេងៗ និងស្របទៅតាមគោលការណ៍ផ្សេងៗដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

## ១.២ សេចក្តីថ្លែងបញ្ហា

ប្រទេសកម្ពុជាសម្បូរទៅដោយធនធានធម្មជាតិ និងតំបន់ទេសភាពជាច្រើន តំបន់ធម្មជាតិ និងតំបន់ទេសភាពមួយចំនួន ត្រូវបានយកចិត្តទុកដាក់យ៉ាងជិតដល់ពីសំណាក់រាជរដ្ឋាភិបាល ក្នុងការការពារ និងដាក់ជាតំបន់អភិរក្ស។ ទន្ទឹមនឹងនោះតំបន់ធម្មជាតិ និងទេសភាពមួយចំនួនត្រូវបានរងការគម្រាមកំហែងពីសំណាក់ជនឱកាសនិយមផងដែរ ដូចជាការកាប់បំផ្លាញព្រៃឈើ ការជួញដូរសត្វព្រៃ និងការនេសាទខុសច្បាប់ជាដើម។ តំបន់ទេសភាពខ្លះទៀតត្រូវបានទុកចោល ដោយមិនបានផ្តល់ផលចំណេញសេដ្ឋកិច្ចដល់តំបន់ ឬប្រទេសជាតិឡើយ ជាក់ស្តែងកោះក្របីដែលមានទីតាំងស្ថិតនៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជានៃខេត្តព្រះសីហនុ ដែលជាកោះត្រូវបានទុកចោលដោយមិនមានសកម្មភាពអភិវឌ្ឍន៍អ្វីបន្តិចសោះ ហើយក៏មិនមានសកម្មភាពទាញយកផលចំណេញពីសក្តានុពលរបស់កោះនេះឡើយ។

ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឲ្យប្រទេសកម្ពុជា ឆ្ពោះទៅមុខយ៉ាងរឹងមាំប្រកបដោយភាពសុទិដ្ឋិនិយម និងការប្តេជ្ញាខ្ពស់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ដើម្បីកែប្រែមុខមាត់ និងលើកស្ទួយកិត្តិស័ព្ទប្រទេសកម្ពុជាឲ្យបានល្អប្រពៃ ដូចសម័យអង្គរដ៏រុងរឿង ដែលកូនខ្មែរគ្រប់ៗរូបមិនអាចបំភ្លេចបាន។ [2]ដើម្បីជំរុញការអភិវឌ្ឍន៍ប្រទេសឲ្យបានឿនលឿន ប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញនូវ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣** សំដៅលើការលើកទឹកចិត្ត ដល់វិស័យឯកជនក្នុងការទាក់ទាញវិនិយោគទាំងក្នុងនិង ក្រៅប្រទេស ដែលរាជរដ្ឋាភិបាលបានកំណត់ថា **វិស័យឯកជនគឺជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។**

---

[2] យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ពីឆ្នាំ២០១៣ដល់២០១៨

ដោយឃើញស្ថានភាពអំណោយផល ខាងផ្នែកសេដ្ឋកិច្ច រួមទាំងគោលនយោបាយបើកទូលាយទីផ្សារសេរី **ក្រុមហ៊ុន អភីប៊ី អ៊ិនវេសមេន ខូអិលធីឌី** បានដាក់ទុនវិនិយោគទៅលើគម្រោងដីសម្បទាននៅក្នុង **តំបន់កោះក្របី** មានទីតាំងស្ថិតក្នុង ខេត្តព្រះសីហនុដែលមានផ្ទៃដីសរុបទំហំ **១០ហិកតា** ក្នុងរយៈពេល៩៩ឆ្នាំ ក្រោមការទទួលស្គាល់ និងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា។ ការវិនិយោគនៅក្នុងតំបន់នេះ គឺអាចប្រែក្លាយតំបន់នេះឲ្យទៅជាកន្លែងរមណីយដ្ឋានកោះក្របី ដ៏ល្បីមួយក្នុងប្រទេសកម្ពុជា។ ការបង្កើតឲ្យមានតំបន់រមណីយដ្ឋាននៅក្នុងតំបន់នេះ គឺមានគោលបំណង ដើម្បីចូលរួមចំណែកលើការបង្កើននូវភ្ញៀវទេសចរទាំងក្នុងស្រុកនិងក្រៅស្រុក ដើម្បីផ្តល់ការងារដល់ប្រជាពលរដ្ឋរស់នៅជុំវិញតំបន់នេះ ដើម្បីបង្កើននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលអាចរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា ដោយស្របទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រដ្ឋាភិបាល។

ដើម្បីធានានូវនិរន្តភាពនៃការអភិវឌ្ឍន៍នេះ គម្រោងបង្កើតឲ្យមាន **រមណីយដ្ឋានកោះក្របី** ត្រូវរៀបចំផែនការនៃការប្រើប្រាស់ និងគ្រប់គ្រងដីឲ្យបានសមស្រប ហើយនឹងការយកចិត្តទុកដាក់ចំពោះបញ្ហាប្រជាជននៅក្នុងតំបន់ ប្រកបដោយតម្លាភាព និងគណនីយភាពត្រឹមត្រូវច្បាស់លាស់។ លើសពីនេះទៅទៀត គម្រោងត្រូវយកចិត្តទុកដាក់ទៅវិធានការការពារបរិស្ថាន ដោយតម្រូវឲ្យធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេលេញនៃគម្រោងជាមុន ដើម្បីបង្ហាញអំពីហេតុប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានរបស់គម្រោងព្រមទាំងផ្តល់នូវអនុសាសន៍ជូនដល់រាជរដ្ឋាភិបាល និងម្ចាស់គម្រោង ហើយនឹងត្រូវធ្វើការផ្សព្វផ្សាយដល់សាធារណៈជនឲ្យបានដឹងលឺផងដែរ។ ការវាយតំលៃនេះ ត្រូវបានរៀបចំឡើងដោយ **ក្រុមហ៊ុន អភីប៊ី អ៊ិនវេសមេន ខូអិលធីឌី** សហការជាមួយក្រុមហ៊ុន **គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ** ក្រោមការត្រួតពិនិត្យយ៉ាងត្រឹមត្រូវពីក្រសួងបរិស្ថាន និងបណ្តាក្រសួងដែលពាក់ព័ន្ធមួយចំនួន។

## ១.៣ គោលបំណងនៃការសិក្សា

គោលបំណងជាក់លាក់នៃការសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញទៅលើគម្រោងអភិវឌ្ឍន៍ **រមណីយដ្ឋាន កោះក្របី** គឺៈ

1. សិក្សាលើធនធានបរិស្ថានជីវៈសាស្ត្រដែលមានស្រាប់ក្នុងតំបន់ (ធនធានព្រៃឈើ សត្វព្រៃ ធនធានជលផល ផ្កាថ្ម និងជីវៈចំរុះ)។
2. សិក្សាលើធនធានបរិស្ថានរូបសាស្ត្រក្នុងតំបន់គម្រោង (ទឹក ដី និងលក្ខណៈអាកាសធាតុ)។
3. សិក្សាលើធនធានបរិស្ថានសង្គម-សេដ្ឋកិច្ចនៅក្បែរតំបន់គម្រោង។
4. សិក្សាលើគម្រោងប្លង់មេផ្ទះលំហែរកាយ ផែ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។
5. វិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថានរបស់គម្រោងអភិវឌ្ឍន៍។

6. វិភាគ និងវាយតំលៃចំពោះហេតុប៉ះពាល់ទៅលើធនធានធម្មជាតិ និងសង្គម ដែលបណ្តាលមកពីសកម្មភាពគម្រោង។
7. កំណត់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ឲ្យនៅកម្រិតអប្បបរមា និងស្របទៅតាមផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោង។

## ១.៤ វិសាលភាព និងដែនកំណត់នៃការសិក្សា

ទំហំនៃការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានលើគម្រោងលំហែកាយ **កោះក្របី** ត្រូវបានកំណត់ដូចខាងក្រោមៈ

→ ទីតាំងនៃការសិក្សាកោះក្របី (កោះច្រឡុស) ស្ថិតនៅក្នុងភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានចំងាយ ៦គីឡូម៉ែត្រពីឆ្នេរសមុទ្ររាម។
→ ការសិក្សា និងវិភាគអំពីធនធានបរិស្ថានដែលមានស្រាប់ក្នុងតំបន់គម្រោងទាំងធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសង្គមសាស្ត្រ។
→ សិក្សា និងវិភាគលើការសាងសង់រមណីយដ្ឋានលើកោះក្របី និងសាងសង់ផែដីគោក (ឆ្នេរសមុទ្ររាម)។
→ ពិភាក្សា និងពិគ្រោះយោបល់បន្ថែមជាមួយមន្ទីរពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ។
→ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះ ត្រូវបានធ្វើឡើងក្នុងរយៈពេល០៧ខែ គឺចាប់ពីខែតុលា ឆ្នាំ២០១៤ ដល់ ខែមិថុនា ឆ្នាំ២០១៥ ដោយ **ក្រុមហ៊ុន អភីប៊ី អ៊ិនវេសមេន ខូអិលធីឌី** សហការជាមួយ ក្រុមហ៊ុនឯករាជ្យ **គ្រីអេធីវ គ្រីន ឌីហ្សាញ** ដែលមានបទពិសោធន៍ក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

## ១.៥ មាតិកាសង្ខេប

របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លើគម្រោងអភិវឌ្ឍន៍ "**រមណីយដ្ឋាន កោះក្របី**" មានចំនួន ៩ជំពូកគឺៈ

១. សេចក្តីផ្តើម
២. វិធីសាស្ត្រសិក្សាស្រាវជ្រាវ
៣. ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ
៤. ការពិពណ៌នាអំពីគម្រោងអភិវឌ្ឍន៍

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

៥. ការពិពណ៌នាអំពីធនធានបរិស្ថានដែលមានស្រាប់
៦. ការចូលរួមពីសាធារណៈជន និងកិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ
៧. ហេតុប៉ះពាល់បរិស្ថានដែលអាចកើតមាន និងវិធានការកាត់បន្ថយ
៨. ផែនការគ្រប់គ្រងបរិស្ថាន
៩. ការវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន
១០. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី២៖
# វិធីសាស្ត្រស្រាវជ្រាវ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូក២៖ វិធីសាស្ត្រស្រាវជ្រាវ

## ២.១ សេចក្តីផ្តើម

ជំពូកនេះគឺជា ជំពូកនៃវិធីសាស្ត្រស្រាវជ្រាវដែលត្រូវបានរៀបចំឡើង ដើម្បីបង្ហាញពីវិធីសាស្ត្រស្រាវជ្រាវទាំងមូលក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញរបស់គម្រោង **រមណីយដ្ឋានកោះក្របី** របស់ក្រុមហ៊ុន **អនុគីប៊ី**។ ជំពូកនេះបានរៀបរាប់អំពីវិធីសាស្ត្រស្រាវជ្រាវទៅលើធនធាន រូបសាស្ត្រ ជីវសាស្ត្រ ស្ថានភាពសង្គមសេដ្ឋកិច្ច វិធីសាស្ត្រការចូលរួមជាសាធារណៈ វិធីសាស្ត្រវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន វិធីសាស្ត្រកំណត់ហេតុប៉ះពាល់បរិស្ថាន ជាដើម។

## ២.២ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ

ការដើម្បីទទួលបានពត៌មានជាក់លាក់ ពិតប្រាកដ និងត្រឹមត្រូវការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញនៃគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីបានប្រមូលទិន្នន័យជា២ប្រភពគឺ ទិន្នន័យបឋម (Primary Data) និងទិន្នន័យបន្ទាប់បន្សំ (Secondary Data)។

### ក. ទិន្នន័យបឋម (Primary Data)

ទិន្នន័យបឋម គឺជាពត៌មានដែលបានមកពីការសម្ភាសន៍ ការសិក្សា និងការអង្កេតផ្ទាល់នៅក្នុង និងជុំវិញតំបន់គម្រោងអភិវឌ្ឍន៍។ ទិន្នន័យបឋមទាំងនោះមានដូចជា៖

- ការសម្ភាសន៍ផ្ទាល់ជាមួយមន្ទីរដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាជនមូលដ្ឋាន
- សម្ភាសន៍ ជាមួយម្ចាស់គម្រោង និងមន្ត្រីជំនាញបច្ចេកទេសរបស់ម្ចាស់គម្រោង
- សិក្សាធនធានសត្វព្រៃ ព្រៃឈើ ជលផល និងផ្កាថ្មក្នុង និងជុំវិញតំបន់គម្រោង
- ពិនិត្យ និងថតយករូបភាពជាក់ស្តែង

ខ. ទិន្នន័យបន្ទាប់បន្សំ (Secondary Data)

ទិន្នន័យបឋម គឺជាពត៌មានដែលមានស្រាប់ទាក់ទងនឹងលក្ខណៈបច្ចេកទេស ច្បាប់ពាក់ព័ន្ធ គោលនយោបាយ បទបញ្ញត្តិ ផែនការអភិវឌ្ឍន៍ ស្ថិតិ និងវិធីសាស្ត្រផ្សេងៗដែលទាក់ទងនឹងគម្រោងអភិវឌ្ឍន៍។ ទិន្នន័យបន្ទាប់បន្សំទាំងនោះមានដូចជា៖

- ស្នើរសុំទិន្នន័យដែលមានស្រាប់មួយចំនួនពីម្ចាស់គម្រោង
- ស្នើរសុំទិន្នន័យដែលមានស្រាប់ពីមន្ទីរ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន
- ឯកសារនៅតាមបណ្ណាល័យ ការសែត ទស្សនាវដ្តី និងបណ្ណាគារផ្សេងៗ
- ការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណែត។ល។

## ២.៣ វិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវ

### ២.៣.១ វិធីសាស្ត្រក្នុងការសិក្សាធនធានរូបសាស្ត្រ

#### ២.៣.១.១ ការសិក្សាលើគុណភាពទឹក

ក. វិធីសាស្ត្រយកសំណាកទឹក

- ការបើកគំរបដបដើម្បីសំលាប់មេរោគ៖ យកគំរបដកចេញ ហើយមិនមូលចូលវិញ ឬ ទាញចេញក្រៅទេ។
- កាន់ដបគៀកទៅក្រោម ហើយដាក់ចូលក្នុងទឹកដែលមានជំរៅប្រហែល ២០ស.ម ដោយបើកមាត់ដបឲ្យដើបត្រង់បន្តិច។ ប្រសិនបើមានទឹកហូរ នោះមាត់ដបគួរតែបែរទៅរកទឹកហូរ។ បន្ទាប់មកដបគួរតែគ្រប ឬចុកដូចដែលបានអធិប្បាយពីមុនមកនោះ(WHO,1997)។

ខ. ទីតាំងយកចំណាកទឹក

ជ្រើសរើសសំណាក (Sample) ដើម្បីវិភាគគុណភាពទឹកត្រូវបាន ជ្រើសរើសចំនួន ៤ប្រភពផ្សេងៗគ្នា បន្ថែមលើសំណាកចាស់ក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមដំបូង។ ចំណុច និងទីតាំងយកសំណាកត្រូវបានកំណត់ដូចខាងក្រោម៖

→ ចំណុចទី១៖ ជាសំណាកទឹកសមុទ្រជាប់កោះក្របី ស្ថិតនៅចំណុចទីតាំង (X=០៣៤៧៩៥០, Y=១១៦៣៧៧៧) ។ ប្រភពទឹកនេះត្រូវបានក្រុមហ៊ុនជ្រើសរើស និងបូមយកមកចំរាញ់ដើម្បីប្រើប្រាស់ នៅលើកោះ។

→ ចំណុចទី២៖ ជាសំណាកដែលយកចេញពីម៉ាស៊ីនចំរ៉ាញ់ទឹកប្រៃ ស្ថិតនៅត្រង់ចំណុចទីតាំង (X=០៣៤២៧៩៥,Y=១១៦២១០៥) ។

→ ចំណុចទី៣៖ ជាសំណាកទឹកដែលយកមកពីទឹកអណ្តូងក្បែរឆ្នេរសមុទ្ររាម ស្ថិតនៅត្រង់ចំណុចទីតាំង (X=០៣៤៣២១៧, Y=១១៦២១៥២)។

→ ចំណុចទី៤៖ ជាសំណាកទឹកសមុទ្រជាប់ឆ្នេរសមុទ្រ ជាទីតាំងសាងសង់ផែដីគោគ ស្ថិតនៅចំណុចទីតាំង (X=០៣៤៣០៥៨, Y=១១៦១៩៩២)។

តារាង២.១៖ ទីតាំងដែលជ្រើសរើសសំណាកទឹក

| សំណាកទឹក | ប្រភេទសំណាក | ទីតាំង | ចំណុចនិយាមការ | |
|---|---|---|---|---|
| | | | X | Y |
| ទី១ | ទឹកសមុទ្រ | ទីតាំងសាង់សង់ផែ (ជាប់ឆ្នេរសមុទ្ររាម) | ០៣៤៧៩៥០ | ១១៦៣៧៧៧ |
| ទី២ | ទឹកសមុទ្រ | ទីតាំងភាគខាងលិចនៃកោះ | ០៣៤២៧៩៥ | ១១៦២១០៥ |
| ទី៣ | ទឹកអណ្តូង | ទឹកអណ្តូង (ក្បែរឆ្នេរសមុទ្ររាម) | ០៣៤៣២១៧ | ១១៦២១៥២ |
| ទី៤ | ទឹកស្អាត | ទឹកដែលចេញពីម៉ាស៊ីនទឹកប្រៃ | ០៣៤៣០៥៨ | ១១៦១៩៩២ |

គ.ប៉ារ៉ាម៉ែត្រដែលជ្រើសរើសសម្រាប់វិភាគគុណភាពទឹក

ការវិភាគគុណភាពទឹកនេះត្រូវបានជ្រើសរើសប៉ារ៉ាម៉ែត្រចំនួន ២៣ប៉ារ៉ាម៉ែត្រដើម្បីវិភាគ ដែលមានបង្ហាញឈ្មោះប៉ារ៉ាម៉ែត្រ និងវិធីសាស្ត្រវិភាគដូចខាងក្រោម៖

តារាង២.២៖ ប៉ារ៉ាម៉ែត្រ និងវិធីសាស្ត្រសម្រាប់វិភាគគុណភាពទឹក

| ល.រ | ប៉ារ៉ាម៉ែត្រ | វិធីសាស្ត្រវិភាគ | ល.រ | ប៉ារ៉ាម៉ែត្រ | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| ១ | pH | Method MAJI Meter | ១៣ | Chemical Oxygen Demand | Method JIS K 0102 |
| ២ | Turbidity | Method MAJI Meter | ១៤ | Total Nitrogen | Method JIS K 0102 45 |
| ៣ | Total Dissolved Solid | Method MAJI Meter | ១៥ | Total Phosphorus | Method JIS K 0102 46 |
| ៤ | Dissolved Oxygen | Method MAJI Meter | ១៦ | Arsenic | Method 3500-As D |
| ៥ | Salinity | Method MAJI Meter | ១៧ | Copper | Method 3500-Cu C |
| ៦ | Total Suspended Solid | Method 2540 D | ១៨ | Iron | Method 3500-Fe C |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ល.រ | ប៉ារ៉ាម៉ែត្រ | វិធីសាស្ត្រវិភាគ | ល.រ | ប៉ារ៉ាម៉ែត្រ | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| ៧ | Ammonium | Method ICs 90 | ១៩ | Lead | Method 3500-Pb C |
| ៨ | Chloride | Method4500-Cl F | ២០ | Mercury | Method ICP-MS |
| ៩ | Nitrade | Method 4500-NO3 C | ២១ | Zinc | Method 3500-Zn C |
| ១០ | Phosphate | Method ICs 90 | ២២ | Total Coliform | Method NF T90-413 (37 $^{0}$C) |
| ១១ | Sulphate | Method 4500-$SO4^{2-}$ B | ២៣ | E-Coli | Method NF T90-413 (44 $^{0}$C) |
| ១២ | Biochemical Oxygen Demand | Method 5210 B | | | |

ប្រភព: តារាងប៉ារ៉ាម៉ែត្រគុណភាពទឹករបស់ក្រសួងបរិស្ថាន

## ២.៣.២ វិធីសាស្ត្រក្នុងការសិក្សាបរិស្ថានជីវសាស្ត្រ

### ២.៣.២.១ វិធីសាស្ត្រសិក្សាអំពីសត្វ

#### ក. ការសម្ភាស

ការសិក្សាលើវត្តមានសត្វព្រៃ គឺធ្វើតាមរយៈការសម្ភាស ជាមួយប្រជាពលរដ្ឋមូលដ្ឋាន និងអ្នកបរបាញ់ ឬអ្នកដាក់អន្ទាក់ដែលធ្លាប់ចូលទៅប្រើប្រាស់ ផល-អនុផលព្រៃឈើ បរបាញ់ និង ដាក់អន្ទាក់ក្នុងទីតាំងគម្រោង។ ការសម្ភាសគឺធ្វើឡើង ដោយគ្រាន់តែពិភាក្សា ឬសាកសួរព័ត៌មានវត្តមានសត្វព្រៃក្នុងតំបន់របស់គាត់ ក្នុងកំឡុងពេល ១០ឆ្នាំចុងក្រោយ។

#### ខ. ការដាក់តាំងត្រង់ស៊ិក

បន្ថែមលើព័ត៌មាន ដែលទទួលបានពីការសម្ភាសប្រជាពលរដ្ឋ នៅក្នុងតំបន់គម្រោង ក្រុមការងារសិក្សាវត្តមាន សត្វព្រៃនឹងធ្វើការអង្កេតវត្តមានសត្វព្រៃនៅតាមបន្ទាត់ត្រងស៊ិក ចំនួន៣ ដែលចាប់ផ្តើមពីចំណុចដើមកោះដល់ចុងកោះ។ នៅតាមបណ្តោយ និងសងខាង បន្ទាត់ត្រង់ស៊ិក ក្រុមការងារអង្កេត និងកត់ត្រាលើសម្លេង ដានជើង លាមក រោម ឬស្លាកស្នាមផ្សេងៗដែលបានលឺ ឬជួបនៅទីវាល។

ការសិក្សាស្រាវជ្រាវ និងការកត់ត្រាទិន្នន័យ គឺធ្វើឡើងនៅក្នុងកំឡុងពេលនៃការដើរអង្កេតនៅលើបន្ទាត់ត្រង់ស៊ិក តាមរយៈការពិនិត្យមើលដោយភ្នែកផ្ទាល់ទៅលើវត្តមានសត្វសងខាង (ទាំងខាងឆ្វេង និងស្តាំនៃ បន្ទាត់ត្រង់ស៊ិក) សម្លេង ដានជើង លាមក រោម ឬសញ្ញានៃក្រញ៉ៅលើសំបកឈើ ឬសញ្ញាណផ្សេងៗ ដែលអាចកំណត់ពីវត្តមានរបស់សត្វ ដែលត្រូវកត់ត្រាបញ្ចូលទៅក្នុងតារាងទិន្នន័យ

(Worksheet)។ ការសិក្សាអំពីសត្វព្រៃនេះ ក្រុមការងារបានសិក្សាចំនួន ២ថ្ងៃ១១-១២ ខែ វិច្ឆិកាឆ្នាំ ២០១៤។

គ. ការអង្កេតផ្ទាល់

ការអង្កេតផ្ទាល់នៅទីវាលជាក់ស្តែងត្រូវបានប្រើវិធីសាស្ត្រដូចខាងក្រោម៖

- ថនិកសត្វ៖ អង្កេតលើដាន សម្លេង លាមក ដានជើង (លើដី ស្លឹកឈើ រឺ លើសំបកឈើ) រន្ធនៅលើ ដើមឈើជាដើម ស្ថានភាពជម្រកនិងការបរបាញ់ រឺ ការដាក់អន្ទាក់
- បក្សី ៖ សិក្សាពេលព្រឹក និងពេលល្ងាច វាយតម្លៃលើជម្រក និងការសង្កេតផ្សេងៗទៀត
- ឧរង្គសត្វរីល្លូន៖ ស្លាកស្នាមបន្សល់ទុកលើសំបកឈើ ដាន រឺភស្តុតាងផ្សេងៗទៀតដែលបន្សល់

ការអង្កេតត្រូវបានធ្វើឡើង នៅក្នុងទីតាំងដែលបានដាក់តាំងឡូត៍-អនុឡូត៍គំរូសិក្សាវាយតម្លៃធនធានដើមឈើ និងការដើរអង្កេត ដោយលៃយ៉ាងណាឲ្យគ្របដណ្តប់ទូទាំងតំបន់សិក្សាស្រាវជ្រាវ។

ប្រភព៖ (Alan Rabinowitz, 2000, ឯកសារបណ្តុះបណ្តាលការអភិរក្ស និងស្រាវជ្រាវសត្វព្រៃនៅលើភូមិសាស្ត្រ)។

ឃ. ក្រុមសិក្សាវត្តមានសត្វព្រៃ

ការសិក្សាវត្តមានសត្វនៅលើកោះក្របីនេះ មានសមាជិកចំនួន ៥នាក់ ដែលមានដូចខាងក្រោម៖

- ១នាក់ (អ្នកបច្ចេកទេស) ប្រធានក្រុមដឹកនាំក្រុម និងកត់ត្រាលទ្ធផល។
- ២នាក់ (ជំនួយការអ្នកបច្ចេកទេស) ស្តាប់សម្លេងសត្វ ផ្ទៀងផ្ទាត់ដាន និងកំណត់អត្តសញ្ញាណសត្វ។
- ២នាក់ (អ្នកភូមិ) ជំនួយការនាំផ្លូវ ស្តាប់សម្លេងសត្វ ផ្ទៀងផ្ទាត់ដាន (ជាអ្នកស្គាល់ឈ្មោះសត្វ)។

## ២.៣.២.២ វិធីសាស្ត្រសិក្សាអំពីព្រៃឈើ

### ក.១ ការកំណត់ប្រភេទព្រៃ

តាមការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) បានបង្ហាញថាតំបន់អភិវឌ្ឍន៍កោះក្របីមានទំហំផ្ទៃដី១០ហិកតា។ ក្នុងការសិក្សានេះក្រុមការងារចុះវាយតម្លៃបានប្រើប្រាស់ផែនទីគម្របព្រៃឈើឆ្នាំ២០១០ដើម្បីកំណត់ទំហំប្រភេទព្រៃ និងទំហំផ្ទៃដីទំនេរសម្រាប់ជាមូលដ្ឋានក្នុងការគណនាចំនួនឡូត៍-អនុឡូត៍គំរូ។ ប្រព័ន្ធព័ត៌មានភូមិសាស្ត្របានបង្ហាញថាក្នុងតំបន់សិក្សាផ្ទៃចំនួន៨ហិកតាជាព្រៃស្រោង និង២ហិកតាជាដីគ្មានគម្របព្រៃឈើ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- ព្រៃស្រោង ចំនួន ៨ហិកតា
- ដីគ្មានគម្របព្រៃឈើ ចំនួន ២ ហិកតា

សរុប ១០ ហិកតា

ការសិក្សាលើសារព័ន្ធរុក្ខជាតិក្នុងតំបន់គម្រោងនេះ បានកំណត់យកឡូត៍-អនុឡូត៍គំរូចំនួន១០ ឡូត៍មកសិក្សាក្នុងកម្រិតលម្អៀង ១០% ដែលនឹងដាក់តាំងទៅតាមប្រភេទព្រៃ។

ការសិក្សានេះ ធ្វើឡើងក្នុងរយៈពេល២ថ្ងៃគឺថ្ងៃទី១១-១២ ខែ វិច្ឆិកាឆ្នាំ២០១៤។

### ក.២ កំណត់ប្រភេទប្លង់ជំរើស

ក្នុងការគណនាចំនួនឡូត៍-អនុឡូត៍គំរូសម្រាប់ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មាន ធនធានព្រៃឈើគឺ ផ្អែកលើគោលការណ៍ណែនាំសម្រាប់ធ្វើសារពើភ័ណ្ឌរបស់រដ្ឋបាលព្រៃឈើ។ ឡូត៍ និងអនុឡូត៍គំរូសម្រាប់ធ្វើសារពើភ័ណ្ឌវាយតម្លៃ ប៉ាន់ស្មានធនធានព្រៃឈើ នៅលើកោះក្របី ដោយសារផ្ទៃដីមានទំហំត្រឹមតែ១០ហិកតា ដែលគ្របដណ្តប់ដោយព្រៃស្រោង ដូចនេះក្រុមការងារធ្វើសម្រេចដាក់តាំងឡូត៍អនុឡូត៍គំរូសិក្សាតាមលំដាប់ថ្នាក់អង្កត់ផ្ចិតដូចខាងក្រោម៖

- អង្កត់ផ្ចិតកំពស់(១.៣០ម) ចាប់ពី ៥-១៤សម សិក្សាចំនួន ១០ឡូត៍គំរូ
- អង្កត់ផ្ចិតកំពស់(១.៣០ម)ចាប់ពី១៥-៣០សម សិក្សាចំនួន ១០ឡូត៍គំរូ
- អង្កត់ផ្ចិតកំពស់(១.៣០ម)ធំជាង៣០សម សិក្សាចំនួន ១០ឡូត៍គំរូ

ចំពោះឡូត៍-អនុឡូត៍គំរូ ដែលបានដាក់តាំងសម្រាប់ការសិក្សាវាយតម្លៃធនធានព្រៃឈើនិងសត្វព្រៃនៅក្នុងតំបន់កោះក្របីរបស់ក្រុមហ៊ុន **អគីឌី អ៊ិនវេសមេន ខូអិលធីឌី** គឺបានដាក់តាំងលក្ខណៈជាប្រព័ន្ធ ដែលរាប់ពីខ្សែវាស់មួយទៅខ្សែវាស់រាប់មួយទៀតមានគំលាត ១០០ម៉ែត្រស្មើៗគ្នា។ ដោយឡែកចន្លោះឡូត៍មួយទៅឡូត៍មួយទៀតមាន គំលាត១០០ម៉ែត្រ (ដូចរូបទី៥.៧)។ មុននឹងដាក់តាំងឡូត៍-អនុឡូត៍គំរូសិក្សានេះក្រុមការងារធ្វើការ ជ្រើសរើសទីតាំង សមស្របមួយសម្រាប់ដាក់តាំងឡូត៍គំរូសិក្សាវាយតំលៃ ដោយធ្វើយ៉ាងណាឲ្យឡូត៍-អនុឡូត៍គំរូគ្របដណ្តប់បានគ្រប់ប្រភេទព្រៃដែលមាននៅក្នុងតំបន់គម្រោង។

តារាង២.៣៖ ទំហំឡូត៍ និង អនុឡូត៍គំរូ

| ថ្នាក់អង្កត់ផ្ចិត | ទំហំឡូត៍ | ផ្ទៃដី | ចំនួនឡូត៍គំរូ |
|---|---|---|---|
| ០៥ទៅ ១៤ស.ម | ៣០ម X ២៥ម | ០.០៧៥ ហិកតា | ១០ |
| ១៥ទៅ ៣០ស.ម | ៣០ម X ៥០ម | ០.១៥០ ហិកតា | ១០ |

| | | | |
|---|---|---|---|
| ធំជាង ៣០ស.ម ឡើងទៅ | ៣០ X ១០០ម | ០.៣០០ ហិកតា | ១០ |




រូបភាព២.១៖ គំនូសតាមឡូតិ៍ អនុតំបន់ឡូតិ៍




| ថ្នាក់អង្កត់ផ្ចិត | ទំហំឡូតិ៍-អនុឡូតិ៍ |
|---|---|
| - 05-14ស.ម | 30ម*25ម = 0.075 ហ.ត |
| - 15-30ស.ម | 30ម*50ម = 0.15 ហ.ត |
| - >30ស.ម | 30ម*100ម = 0.300 ហ.ត |

រូបភាព២.២៖ ទំហំឡូតិ៍ និងអនុតំបន់




រូបភាព២.៣៖ ទីតាំងឡូតិ៍គំរូ និងអនុឡូតិ៍គំរូសម្រាប់ធ្វើសារពើភ័ណ្ឌធនធានព្រៃឈើក្នុងតំបន់គម្រោង

### ក.៣ ការគណនាចំនួនឡូត៍គំរូត្រូវដាក់តាំង

ការគណនាចំនួនឡូត៍គំរូត្រូវដាក់តាំងក្នុងតំបន់សារពើភ័ណ្ឌ តាមរូបមន្តដូចខាងក្រោម:

$$N = \frac{S \times SI}{s}$$

ដែល: - S: ផ្ទៃដីសរុបតាមស្រទាប់ព្រៃនីមួយៗ គិតជាហិកតា
- SI: កំរិតជម្រើសតាមថ្នាក់អង្កត់ផ្ចិតនីមួយៗ
- s: ទំហំឡូត៍ អនុឡូត៍គំរូនីមួយៗ គិតជាហិកតា

### ក.៤ ការគណនាគំលាតរវាងខ្សែរាប់

ការគណនាគំលាតរវាងខ្សែវាស់រាប់ តាមរូបមន្តដូចខាងក្រោម:

$$D = \frac{30}{SI} = \frac{30}{0.3} = 100 \text{ ម}$$

ដែល: - D : ចំងាយរវាងខ្សែរាប់ គិតជាម៉ែត្រ
- SI : កំរិតជម្រើស ដែលកំណត់យក 30%
- 30ម : ជាទទឹងឡូត៍គំរូ

### ក.៥ ការគណនាគំលាតរវាងអនុឡូត៍គំរូ

ការគណនាគំលាតរវាងអនុឡូត៍គំរូ (អនុឡូត៍គំរូដែលមានទំហំ៣០ម៉ែត្រx២៥ម៉ែត្រ ៣០ម៉ែត្រx៥០ម៉ែត្រ)តាមរូបមន្តដូចខាងក្រោម:

$$IG = \sqrt{S/N}$$

ដែល: - IG : ចន្លោះរវាងក្រឡាចក្រត្រង្គ (គិតជាម៉ែត្រ)
- S : ជាផ្ទៃដីសរុបតាមស្រទាប់ព្រៃនីមួយៗ (គិតជាម៉ែត្រការេ)
- N : ចំនួនអនុឡូត៍គំរូ

ក.៦ ការរៀបចំការងារសារពើភ័ណ្ឌ

- ការរៀបចំព្រំប្រទល់អនុតំបន់៖ លាបថ្នាំពណ៌ក្រហមតាមបណ្តោយព្រំប្រទល់ដែលបានកាប់ឆ្ការ ឬ មាន ដោយធម្មជាតិ។
- ការរៀបចំខ្សែប្រលោះព្រៃ៖ ត្រៀមបើកប្រលោះព្រៃដែលមានទទឹងពី១ ឬ២ម៉ែត្រ និង បោះបង្គោល ពីមួយទៅមួយប្រវែង ២៥ម៉ែត្រ ដោយមានការបាញ់ថ្នាំពណ៌ ក្រហមទៅបង្គោល ឬដើមឈើនៅក្បែរនោះ។ ចំងាយពីខ្សែប្រលោះព្រៃមួយទៅខ្សែមួយទៀតប្រវែង ៣០០ម៉ែត្រ និងធ្វើអត្តសញ្ញាណនៅនឹងគល់ខ្សែ ដោយ ដាក់ជាលេខសំរាប់សំគាល់តាមលំដាប់លំដោយ។

ក.៧ វិធីសាស្ត្រវាស់វែង

❖ កំណត់ប៉ារ៉ាម៉ែត្រវាស់វែង

ប៉ារ៉ាម៉ែត្រត្រូវវាស់វែងក្នុងការងារសារពើភ័ណ្ឌរួមមាន: អង្កត់ផ្ចិត($D_{1,30ម}$), កំពស់ ($H_{មែកទី1}$), និងរាប់ចំនួនដើមឈើ។

❖ គោលការណ៍វាស់រាប់

- ប្រភេទឈើ: រាប់ដើមឈើគ្រប់ប្រភេទដែលមានអង្កត់ផ្ចិតកំពស់ទ្រូង (១.៣០ម) ចាប់ពី៥សង់ទីម៉ែត្រឡើងទៅ និងចំណាត់ថ្នាក់ប្រភេទ ត្រូវអនុវត្តន៍តាមប្រកាសលេខ ០៨៩ ប្រក.កសក ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០០៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក្នុងឧបសម្ព័ន្ធ ៥) ស្តីពីប្រភេទឈើជាប់ក្នុងលំដាប់ថ្នាក់។
- អង្កត់ផ្ចិត: វាស់ទំហំអង្កត់ផ្ចិតកំពស់ស្មើទ្រូង (១.៣០ម) ឬលើព្រឹង០.៦៥ម ពីនីវ៉ូដីលើសំបកដើមឈើគ្រប់ប្រភេទមានអង្កត់ផ្ចិតចាប់ពី៥សង់ទីម៉ែត្រឡើងទៅ។
- កំពស់: ប៉ាន់ស្មានកំពស់ដើមឈើត្រឹមមែកទី១ គ្រប់ប្រភេទឈើមានអង្កត់ផ្ចិតចាប់ពី ៥ស.ម ឡើងទៅ។

❖ ការប្រើប្រាស់ឧបករណ៍វាស់វែង

- វាស់ទំហំអង្កត់ផ្ចិត៖ ប្រើខ្សែម៉ែត្រវាស់អង្កត់ផ្ចិត (Diameter tap)
- វាស់កំពស់៖ ប៉ាន់ស្មានដោយភ្នែកទទេ។

## ក.៨ ការកំណត់គុណភាពឈើឈរ

ការវាយតំលៃគុណភាពឈើសំរាប់ដើមឈើនីមួយៗ ត្រូវបានផ្តល់ជាចំណាត់ថ្នាក់ដូចខាងក្រោម:

គុណភាព A : ដើមឈើដែលអាចផ្តល់ឈើហ៊ុបដោយគ្មានការខូចខាត។

គុណភាព B : ដើមឈើដែលអាចផ្តល់ឈើហ៊ុបមានការខូចខាតតិចតួចដែលអាចយកទៅប្រើប្រាស់បាន។

គុណភាព C : ដើមឈើមិនអាចផ្តល់ឈើហ៊ុប ដែលប្រើប្រាស់បាននៅក្នុងរោងចក្រ អារឈើ ឬឧស្សាហកម្មក្តារបន្ទះពីព្រោះមានការខូចខាតច្រើន។

រូបភាពទី២.៤៖ ការវាស់អង្កត់ផ្ចិតដើមឈើ




រូបភាពទី២.៥៖ករណីដើមឈើដុះនៅលើទីជម្រាលខ្លាំង ចំណុចវាស់អង្កត់ផ្ចិតត្រូវឈរវាស់នូវផ្នែកខាងលើទីទួល




រូបភាពទី២.៦៖ ករណីដើមចំពាម




- ករណីដើមចំពាម ប្រសិនបើចំណុចវាស់អង្កត់ផ្ចិតនូវកំពស់ ១.៣ម៉ែត្រ ពីនីវូដី ចំពាម ហើយមានទំរង់ដើមធំជាងនោះ ការវាស់វែងអង្កត់ផ្ចិតត្រូវរំកិលចុះក្រោម ប្រមាណ៣០សង់ទីម៉ែត្រ គឺវាស់ត្រង់ចំណុច១ម៉ែត្រពីនីវូដី និងគិតជាឈើមួយដើម។
- ករណីចំណុចវាស់អង្កត់ផ្ចិតនូវកំពស់ ១.៣ម៉ែត្រពីនីវូដីនៅពីលើចំពាមនោះ ចំណុចវាស់អង្កត់ផ្ចិតត្រូវធ្វើការវាស់វែងចំនួន ០២លើក និងគិតជាឈើចំនួន ០២ដើម។

រូបភាពទី២.៧៖ ករណីដើមឈើមានព្រឹងចំណុចវាស់
អង្កត់ផ្ចិតត្រូវរំកិលទៅផ្នែកខាងលើ
ព្រឹង ៦៥សង់ទីម៉ែត្រ




រូបភាពទី២.៨៖ ករណីចំណុចវាស់អង្កត់ផ្ចិត
ប៉ះចំពក ប្រហោង ស្អុយ
មែកជាដើម ចំណុចវាស់អង្កត់
ផ្ចិតត្រូវអនិយ័ត




រូបភាពទី២.៩៖ ករណីដើមឈើឫសអាកាសចំណុច
វាស់អង្កត់ផ្ចិត ត្រូវគិតចាប់ពីចុងឫស
ទៅផ្នែកខាងលើ ១.៣ម៉ែត្រ




រូបភាពទី២.១០៖ ករណីដើមទ្រេត ចំណុច
វាស់អង្កត់ផ្ចិត ១.៣ម៉ែត្រពីនីវ៉ូដី
ត្រូវវាស់ផ្នែកខាងក្រោមទម្រេតដើម




### ក.៩ ការកត់ត្រាទិន្នន័យ

ក្នុងការកត់ត្រាទិន្នន័យដើមឈើ គឺក្រុមការងារនឹងប្រើប្រាស់ក្រដាស់កត់ត្រាទិន្នន័យដែលបានរៀបចំរួចជាស្រេច ដែលមានកំណត់នូវប៉ារ៉ាម៉ែត្រឈើ ទៅតាមទំហំឡូត៍អនុឡូត៍គំរូរួចជាស្រេច ដូចជាប្រភេទឈើ ចំនួនដើមឈើ និង អង្កត់ផ្ចិតឈើ (ករណីរអង្កត់ផ្ចិតធំជាង ៥ស.ម)។ ដោយឡែកកំពស់ឈើឈរ ក្រុមការងារពុំបានវាស់នោះទេដោយសារ ក្នុងព្រៃក្រាស់ដូចជាស្រោង និងពាក់កណ្តាលស្រោងមានភាពលំបាកក្នុងការប្រើប្រាស់ឧបករណ៍វាស់។ សារព័ន្ធរុក្ខជាតិ ដែលនឹងត្រូវកត់ត្រារួមមានចុល្លព្រឹក្ស តិណទេស បណ្តុងជាតិ គុម្ពព្រឹក្ស និងដើមឈើរាប់បញ្ចូលទាំងឈើពាណិជ្ជកម្ម និងឈើមិនមែនពាណិជ្ជកម្ម។

ក.១០ ចាត់តាំងការងារអនុវត្តន៍ជាក់ស្តែងលើទីវាល

❖ សមាសភាពក្រុមរៀបចំព្រំប្រទល់ និង ប្រឡោះព្រៃសារពើភ័ណ្ឌ
មានសមាជិកចំនួន ៥នាក់ ក្នុងនោះ៖

- ២នាក់(អ្នកបច្ចេកទេស) ប្រធានក្រុមជាអ្នកប្រើឧបករណ៍ GPS និងកាន់ត្រី វិស័យតំរង់ទិស
- ២នាក់(កម្មករ) ជាអ្នកត្រាយបើកប្រឡោះព្រៃ
- ២នាក់(កម្មករ) ជាអ្នកទាញខ្សែម៉ែត្រវាស់ចំងាយរត់បង្គោល វាយស្លាក និង លាបថ្នាំពណ៌

❖ សមាសភាពក្រុមវាស់រាប់

មានសមាជិកចំនួន ៧នាក់ ក្នុងនោះ៖

- ១នាក់(អ្នកបច្ចេកទេស) ប្រធានក្រុមដឹកនាំក្រុម និងកត់ត្រាលទ្ធផលវាស់រាប់
- ២នាក់ (អ្នកបច្ចេកទេស) វាស់អង្កត់ផ្ចិត ប៉ាន់ស្មានកំពស់ កំណត់គុណភាព និងហៅឈ្មោះឈើ
- ២នាក់(កម្មករ) ត្រាយព្រៃ លាបថ្នាំសំគាល់ ធ្វើព្រំប្រទល់ឡូត៍ និង អនុឡូត៍គំរូ
- ២នាក់(កម្មករ) ជំនួយការវាស់អង្កត់ផ្ចិត ប៉ាន់ស្មានកំពស់ កំណត់គុណភាព និងហៅឈ្មោះឈើ(ជាអ្នកស្គាល់ឈ្មោះឈើច្បាស់លាស់

## ខ. ដំណើរការវិភាគទិន្នន័យ

### ខ.១ វិធានការគណនាមាឌឈើ

ការកំណត់មាឌឈើឈរដោយប្រើសមីការមាឌ តាមលំដាប់ថ្នាក់អង្កត់ផ្ចិតតាមប្រភេទព្រៃដូចខាងក្រោម:

**ប្រភេទព្រៃស្រោង**

ប្រភេទឈើ Dipterocarp

<15ស.ម មាឌ $= 0.022 + 3.4\ D^2$

15ស.ម⁺ មាឌ $= 0.015 + 2.137\ D^2 + 0.513\ D^2L$

ប្រភេទឈើ Non-dipterocarp

<30ស.ម មាឌ $= 0.03 + 2.8\ D^2$

30ស.ម⁺ មាឌ = $-0.0023 + 2.947D^2 + 0.262D^{2*}L$

ប្រភេទព្រៃល្បោះ

ប្រភេទឈើ Dipterocarp

<15ស.ម មាឌ = $0.00849 + 4.097 D^2$

15ស.ម⁺ មាឌ = $-0.031 + 4.637D^2 + 0.135 D^{2*}L$

ប្រភេទឈើ Non-dipterocarp

<15ស.ម មាឌ = $0.03 + 3.3 D^2$

15-30ស.ម មាឌ = $0.03 + 3.55 D^2$

30ស.ម⁺ មាឌ = $-0.285 + 4.782 D^2 + 0.269 D^{2*}L$

(ប្រភព៖ រដ្ឋបាលព្រៃឈើ, ២០១០)

### ខ.២ ការប៉ាន់ស្មានជីវម៉ាស់នៅលើដី និងកាបូនស្តុក

❖ ការប៉ាន់ស្មានជីវម៉ាស់

ការប៉ាន់ស្មានជីវម៉ាស់នៅលើដី (Above Ground Biomass)គឺអនុវត្តតាមរូបមន្តរបស់លោក Brown ឆ្នាំ ១៩៩៧ ដែលបង្ហាញដូចខាងក្រោម៖

$$AGB = VOB \times WD \times BEF$$

ដែល
- AGB ជាជីវម៉ាស់លើដី (Above Ground Biomass)
- VOB មាឌឈើគិតទាំងសំបក
- WD ដង់ស៊ីតេឈើ WD = 0.57 (UNFCCC)
- BEF មេគុណពង្រីក

ចំពោះមេគុណពង្រីក មានរបៀបគណនាដូចខាងក្រោម៖

$$BEF = \mathrm{Exp}\{3.213 - 0.506 \times \mathrm{Ln}(BV)\} \text{ for } BV < 190 \text{ t/ha}$$

$$= 1.74 \text{ for } BV >= 190 \text{t/ha}$$

(ដែល BV ជាជីវម៉ាស់របស់មាឌឈើ បានមកពីការធ្វើសារពើភ័ណ្ឌព្រៃឈើគិតជា t/ha)

តាមឯកសាររបស់លោក Sakasi Nophear បានបង្ហាញថា ជីវម៉ាសក្រោមដី (Bellow Ground Biomass) ស្មើនឹង ៣០% នៃជីវម៉ាស់លើដី។

❖ ការប៉ាន់ស្មានកាបូនស្តុក

- ការគណនាបរិមាណកាបូនស្តុកនៅលើដើមឈើ ឬកំណើនកាបូននៅក្នុងព្រៃឈើ គេប្រើប្រាស់រូបមន្តៈ

$C_{(above\ ground)} = AGB \times r_c$

- បរិមាណកាបូនស្តុកក្នុងដើមឈើ (ផ្នែកខាងលើដី និងផ្នែកឫស)

$C_{(hold\ tree)} = HTB \times r_c$ (ដែល HTB ជាជីវម៉ាស់ដើមឈើទាំងមូល)

- បរិមាណនៃ $CO_2$ គណនាដោយរូបមន្ត (Kakada K., 2006)៖

$CO_2 = 44/12 \times AGB \times r_c$

## ២.៣.២.៣ វិធីសាស្ត្រសិក្សាធនធានជលផល

### ក. វិធីសាស្ត្រវាយតម្លៃសកម្មភាពនេសាទ និងធនធានជលផល

ការវាយតម្លៃពីសកម្មភាពនេសាទនិង ធនធានជលផលដែលប្រមូលបាននៅក្នុងតំបន់អភិវឌ្ឍន៍ **កោះក្របី** នេះ គឺមានសារសំខាន់និងជាជំហានដំបូងក្នុងដំណើរការតាមដានការសាងសង់គម្រោង។ ការសិក្សាទាំងនេះ អាចឲ្យយើងដឹងថាតើប្រជាពលរដ្ឋបានពឹងផ្អែកលើធនធានជលផលក្នុងតំបន់នេះយ៉ាងដូចម្តេច ហើយថាតើត្រូវកាត់បន្ថយផលប៉ះពាល់ទៅលើសកម្មភាពនេសាទ និងធនធានជលផលយ៉ាងណា ព្រមទាំងអាចឲ្យយើងដឹងថាតើអ្នកនេសាទអាចទទួលបានអ្វីខ្លះពីគម្រោងនេះ។ ជារួម ទិដ្ឋភាពទាំងនេះអាចជួយកាត់បន្ថយជម្លោះរវាងអ្នកនេសាទ និងក្រុមហ៊ុនអភិវឌ្ឍន៍ ព្រមទាំងអាចធានាបានសកម្មភាពនេសាទ និងធនធានជលផលនៅក្នុងតំបន់អភិវឌ្ឍន៍ប្រកបដោយចីរភាព។ យ៉ាងណាមិញប្រជានេសាទ មិនបាននេសាទតែនៅជុំវិញកោះក្របីទេ តែគាត់នេសាទនៅក្នុងប្រជុំកោះតាកៀវតែម្តង ដែលមានចំងាយចេញពីកោះក្របីប្រមានពី៥ ទៅ១០គីឡូម៉ែត្រ ទើបសំបូរធនធានជលផល។

### ខ. ការសិក្សាអង្កេតសកម្មភាពនេសាទ និងធនធានជលផលដែលប្រមូលបាន

នៅក្នុងដំណើរការនៃការប្រមូលព័ត៌មាននេះ ក្រុមការងារចំនួន ០៤រូប ត្រូវបានជ្រើសរើសឲ្យចុះសិក្សាវាយតម្លៃពីបស្ថានភាពនេសាទ និងធនធានជលផលដែលប្រមូលបាន នៅក្នុងតំបន់កោះក្របីនេះ។ តាមគ្រោង ការចុះសិក្សាត្រូវប្រើរយៈពេលត្រឹម៥ថ្ងៃប៉ុណ្ណោះ ប៉ុន្តែដោយសារ អាកាសធាតុពុំអំណោយផល (ភ្លៀងធ្លាក់ស្ទើររាល់ថ្ងៃ) ធ្វើឲ្យសកម្មភាពស្រាវជ្រាវបានពន្យាពេលរហូតដល់ ១០ថ្ងៃ គឺចាប់ពីចាប់ពីថ្ងៃទី០១ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៣។ នៅក្នុងដំណើរការប្រមូលព័ត៌មាន

នេះ ក្រុមការងារបានរៀបចំជាបញ្ជីសំណួរ ដោយបែងចែកជាជំពូកផ្សេងៗ ជាពិសេសគឺផ្តោតទៅលើមេគ្រួសារ មុខរបរប្រចាំគ្រួសារ ប្រាក់ចំណូល សកម្មភាពនេសាទ ប្រភេទធនធានជលផលដែលចាប់បានឧបករណ៍ នេសាទដែលបានប្រើប្រាស់ និងចំណូលបានពីការនេសាទ។

### គ. ដំណើរការនៃការប្រមូលព័ត៌មាន

នៅក្នុងដំណើរនៃការប្រមូលព័ត៌មាន ក្រុមការងារបានធ្វើការសម្ភាសន៍ជាមួយប្រជាពលរដ្ឋដែលជា អ្នកនេសាទចំនួន៣០គ្រួសារ ស្ថិតក្នុងឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ហើយបន្ទាប់មក ក្រុមការងារ បានពិនិត្យស្រង់យកព័ត៌មានពីគ្រួសារអ្នកនេសាទណាដែលបាននិងកំពុងធ្វើនេសាទនៅក្នុងតំបន់ប្រជុំកោះតាគៀវ ជាពិសេសនៅជុំវិញកោះក្របី។ ជាលទ្ធផល គឺក្រុមការងារបានចម្រាញ់យកព័ត៌មានពីគ្រួសារអ្នក នេសាទត្រឹម១៧គ្រួសារតែប៉ុណ្ណោះដែលបានធ្វើនេសាទក្នុងតំបន់នេះ ដើម្បីជៀសវាងនូវភាពលំអៀងច្រើន។

ការប្រមូលព័ត៌មានត្រូវបានធ្វើនៅចន្លោះម៉ោង៣ទៅ៥ល្ងាច ប៉ុណ្ណោះ ពីព្រោះពេលវេលានេះគឺពួក អ្នកនេសាទទើបបានត្រឡប់ពីការនេសាទភ្លាមៗ ហើយពេលវេលានេះអាចឲ្យយើងពិនិត្យមើលប្រភេទត្រី ផលត្រីដែលចាប់បាននិងឧបករណ៍នេសាទដែលពួកគេបានប្រើប្រាស់។ ការស្រង់យកព័ត៌មានត្រូវបានធ្វើ តាមរយៈការសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកនេសាទនីមួយៗ ព្រមទាំងបានថតយករូបភាពត្រីនិងធនធានជលផលដទៃទៀតដែលពួកគេប្រមូលបានពីក្នុងតំបន់អភិវឌ្ឍន៍។ ចំពោះប្រភេទត្រីដែលចាប់បានត្រូវបាន កំណត់អត្តសញ្ញាណតាមសៀវភៅអត្តទេសក៍ អំពីប្រភេទធនធានជលផលសមុទ្រក្នុងព្រះរាជាណាចក្រកម្ពុជា ផលិតដោយរដ្ឋបាលជលផលក្នុងឆ្នាំ២០០៨។

### ឃ. ការវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបានត្រូវបានត្រួតពិនិត្យដោយប្រុងប្រយ័ត្ន ហើយបញ្ចូលទៅក្នុងកំព្យូទ័រដោយ ប្រើកម្មវិធី Microsoft Excel ដើម្បីវិភាគនិងវាយតម្លៃ។ លទ្ធផលនៃការវិភាពនេះត្រូវបានយកមកបកស្រាយតាមរយៈតារាងនិងក្រាហ្វិក។

ចំណែកតម្លៃឬប្រាក់ចំណូលដែលទទួលបានជាប្រាក់រៀល ត្រូវបានគណនាជាប្រាក់ដុល្លាអាមេរិក ដោយគិតក្នុងអត្រា១ដុល្លាស្មើនឹង៤.១០០រៀល។

## ២.៣.២.៤ វិធីសាស្ត្រក្នុងការសិក្សាផ្កាថ្ម

ការសិក្សា និងវាយតម្លៃធនធានស្រទាប់បាត សម្រាប់គម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីនេះត្រូវបានបែងចែកជា២ ទីតាំង គឺទីតាំងទី១ ស្ថិតនៅជុំវិញកោះក្របី និងទីតាំងទី២ ស្ថិតក្បែរឆ្នេរសមុទ្ររាម ដែលជាទីតាំងសាងសង់ផែដីគោក។

### ក. វិធីសាស្ត្រវាយតម្លៃប្រព័ន្ធអេកូឡូស៊ីស្រទាប់បាតនៅជុំវិញកោះក្របី

នៅក្នុងសកម្មភាពសិក្សាដើម្បីវាយតម្លៃប្រព័ន្ធអេកូឡូស៊ីស្រទាប់បាតនៅជុំវិញ កោះក្របី ត្រូវបានធ្វើ ឡើងដោយមន្ត្រីជំនាញរបស់នាយកដ្ឋានអភិរក្សជលផលចំនួន០៨រូប ដែលមានជំនាញGIS ជំនាញមុជ ទឹក និងជំនាញកំណត់ពីស្ថានភាពផ្កាថ្ម និងជំនាញកំណត់អត្តសញ្ញាណជីវសាស្ត្រសមុទ្រ។ ការសិក្សានេះ ត្រូវបានធ្វើនៅតាមទីតាំងចំនួន២០ទីតាំង នៅជុំវិញកោះក្របីដែលបានជ្រើសរើសដោយចៃដន្យ និងដោយគិតទៅលើស្ថានភាពចរន្តទឹក និងសុវត្ថិភាពជាចម្បង។ ខាងក្រោមនេះ ជាចំណុចទាំង២០ទីតាំង ដែលត្រូវ បានកំណត់ក្នុងសកម្មភាពស្រាវជ្រាវ៖

តារាង២.៤៖ ទីតាំងស្រាវជ្រាវប្រព័ន្ធអេកូឡូស៊ីបាតសមុទ្រនៅជុំវិញកោះក្របី

| ទីតាំងស្រាវជ្រាវ | UTM (Y) | 48P (X) | ទីតាំងស្រាវជ្រាវ | UTM (Y) | 48P (X) |
|---|---|---|---|---|---|
| 1 | 1161696 | 0343600 | 11 | 1161633 | 0343176 |
| 2 | 1161573 | 0343589 | 12 | 1161778 | 0343152 |
| 3 | 1161493 | 0343570 | 13 | 1161897 | 0343174 |
| 4 | 1161416 | 0343555 | 14 | 1161929 | 0343194 |
| 5 | 1161479 | 0343684 | 15 | 1162055 | 0343211 |
| 6 | 1161586 | 0343691 | 16 | 1162048 | 0343322 |
| 7 | 1161470 | 0343444 | 17 | 1162015 | 0343436 |
| 8 | 1161492 | 0343325 | 18 | 1161936 | 343538 |
| 9 | 1161547 | 0343242 | 19 | 1161816 | 343593 |
| 10 | 1161625 | 0343228 | 20 | 1161757 | 343594 |




រូបភាព២.១១ ៖ ផែនទីទីតាំងស្រាវជ្រាវធនធានស្រទាប់បាតនៅជុំវិញកោះក្របី

ខ. វិធីសាស្ត្រវាយតម្លៃប្រព័ន្ធអេកូឡូស៊ីស្រទាប់បាតនៅទីតាំងសាងសង់ផែ (ដីគោក)

នៅក្នុងសកម្មភាពសិក្សាដើម្បីវាយតម្លៃប្រព័ន្ធអេកូឡូស៊ីស្រទាប់បាត នៅក្នុងតំបន់សំណង់ផែទេសចរណ៍ ត្រូវបានធ្វើឡើងដោយមន្ត្រីជំនាញរបស់នាយកដ្ឋានអភិរក្សជលផលចំនួន០៤រូប ដែល មានជំនាញGIS ជំនាញមុជទឹក ជំនាញកំណត់ពីស្ថានភាពផ្កាថ្ម និងជំនាញកំណត់អត្តសញ្ញាណជីវសាស្ត្រសមុទ្រ។ ការសិក្សានេះ ត្រូវបានធ្វើនៅតាមទីតាំងចំនួន១០ទីតាំង ដែលបានជ្រើសរើសដោយចៃដន្យ និងដោយគិតទៅលើស្ថានភាពចរន្តទឹក និងសុវត្ថិភាពជាចម្បង។ ខាងក្រោមនេះ ជាចំណុចទាំង១០ទីតាំង ដែលត្រូវបានកំណត់ក្នុងសកម្មភាពស្រាវជ្រាវ៖

តារាង២.៥៖ ទីតាំងស្រាវជ្រាវប្រព័ន្ធអេកូឡូស៊ីបាតសមុទ្រ

| ទីតាំងស្រាវជ្រាវ | ចំណុចនិយាមការ | |
|---|---|---|
| | X | Y |

| | | |
|---|---|---|
| A01 | 0347954 | 1163562 |
| A02 | 0347943 | 1163610 |
| A03 | 0347897 | 1163612 |
| A04 | 0347916 | 1163584 |
| A05 | 0347924 | 1163706 |
| A06 | 0347962 | 1163696 |
| A07 | 0347953 | 1163658 |
| A08 | 0347914 | 1163651 |
| A09 | 0347861 | 1163631 |
| A10 | 0347911 | 1163633 |




រូបភាព២.១២៖ ផែនទីទីតាំងស្រាវស្រាវធនធានស្រទាប់បាតនៅតំបន់ផែដីគោក

### ២.៣.៣ វិធីសាស្ត្រក្នុងការសិក្សាបរិស្ថានសង្គម-សេដ្ឋកិច្ច

ដោយសារនៅលើកោះក្របីនេះមិនមានប្រជាជនរស់នៅ ដូចនេះគម្រោងអភិវឌ្ឍន៍នេះមិនប៉ះពាល់ដល់ដីធ្លីប្រជាជនឡើយ តែទោះជាយ៉ាងណាក៏ដោយ សំណាករបស់ប្រជាជនក៏ត្រូវបានជ្រើសរើសដើម្បីយកមកសិក្សាពីសង្គម សេដ្ឋកិច្ច និងបរិស្ថានប្រជាជនដែលរស់នៅក្បែរតំបន់គម្រោង ថាតើមុនចាប់ផ្តើមគម្រោងអភិវឌ្ឍន៍ស្ថានភាពមានលក្ខណៈដូចម្តេច និងក្រោយប្រតិបត្តិគម្រោងមានស្ថានភាពដូចម្តេច។ ដើម្បីប្រមូលព័ត៌មានពីប្រជាជនឲ្យមានប្រសិទ្ធភាព និងគ្រប់គ្រាន់ វិធីសាស្ត្រគំរូសំណាកចៃដន្យ (Random Sampling) ត្រូវបានអនុវត្តក្នុងការសិក្សាស្រាវជ្រាវនេះ។ ការជ្រើសរើសចំនួនសំណាកប្រជាជនត្រូវបានប្រើរូបមន្ត ថារ៉ូ (Taro Yamane) ដែលកំណត់យកកំរិតលំអៀង១០%។ សំណាកប្រជាជន ត្រូវបានជ្រើសរើសយកស្ថិតក្នុងឃុំរាម ស្រុកព្រៃនប់ ដោយប្រជាជនសរុបក្នុងឃុំរាមមានចំនួន ២,០៦៩គ្រួសារ (ឃុំរាម ឆ្នាំ២០១២) ដូចនេះតាមការគណនាខាងក្រោមចំនួនសំណាកដែលត្រូវជ្រើសរើសសរុបមានចំនួន៩៥គ្រួសារ។

រូបមន្តថារ៉ូ:

$$n = \frac{N}{1 + Ne^2}$$

ដែល:

- n: ចំនួនសំណាកគំរូ
- N: ចំនួនគ្រួសារសរុប
- e: ចន្លោះជឿជាក់ ១០%

$$n = \frac{២០៦៩}{១ + ២០៦៩(០.១)^២} \cong ៩៥ \text{ សំណាក}$$

ការគណនាសំណាកតាមភូមិនីមួយៗ

តាមរូបមន្ត:

$$nx = \frac{N}{n} dx$$

ដែលៈ

- nx ជាចំនួនសំណាកដែលត្រូវរក
- N ជាចំនួនគ្រួសារតាមភូមិ
- n ជាចំនួនគ្រួសារសរុប
- dx ជាចំនួនសំណាកដែលត្រូវយកសរុប

តារាង២.៦: ការជ្រើសរើសសំណាកតាមភូមិប្រជាជន

| ឈ្មោះភូមិ | គ្រួសារសរុប | ចំនួនសំណាក |
|---|---|---|
| ស្នាច់ដែក | ៧០៣ | ៣២ |
| រាម | ៣៧៩ | ១៨ |
| ថ្មធំ | ៣១៦ | ១៥ |
| អុង | ៦៧១ | ៣០ |
| សរុប | ២០៦៩ | ៩៥ |

## ២.៣.៤ វិធីសាស្ត្រចូលរួមជាសាធារណៈ

ការចូលរួមជាសាធារណៈត្រូវបានចែងចែកជាបីផ្នែក គឺទី១ការពិគ្រោះយោបល់ជាមួយ សាលាខេត្តព្រះសីហានុ និងស្ថាប័នដែលពាក់ព័ន្ធ។ ផ្នែកទី២គឺការពិគ្រោះយោបល់នៅសាលាឃុំរាម ដែលមានការចូលរួមពីមេឃុំរាម និងមេភូមិដែលនៅក្បែរតំបន់គម្រោង។ ផ្នែកទី៣គឺ ក្រសួងបរិស្ថានបានអនុញ្ញាតដល់ក្រុមហ៊ុនគ្រីអេធីវ ហ្គ្រីនឌីហ្សាញ ក្នុងការចុះសិក្សា និងពិគ្រោះយោបល់ជាសាធាណៈជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញលើគម្រោងអភិវឌ្ឍន៍កោះក្របី កាលពីថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៤។ ដោយមានការអនុញាតិនេះ ក្រុមការងារ គ្រីអេធីវ ហ្គ្រីនឌីហ្សាញ បានជ្រើសរើសវិធីសាស្ត្រក្នុងការពិភាក្សា និង

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ពិគ្រោះយោបល់ពីមន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធ ដោយប្រើប្រាស់កម្រងសំនួរសម្រាប់សម្ភាសន៍ផ្ទាល់ជាមួយប្រធានមន្ទីរ និងមន្ត្រីជំនាញពាក់ព័ន្ធមួយចំនួន។ ចំណែកអាជ្ញាធរ ប្រើប្រាស់វិធីសាស្ត្រប្រជុំពិភាក្សា និងពិគ្រោះយល់បល់ ដែលមានការចូលរួមសំណាក់ប្រធានឃុំ និងមេភូមិទាំង៨ក្នុងឃុំរាម។ រីឯប្រជាពលរដ្ឋក្នុងមូលដ្ឋានត្រូវបានប្រើប្រាស់វិធីសាស្ត្រការពិគ្រោះយោបល់ ដោយជ្រើសរើសជាជនតំណាងដើម្បីធ្វើការសម្ភាសន៍ចំនួន៩៥គ្រួសារ និងធ្វើការពិភាក្សាក្រុមចំនួន១៥គ្រួសារ។ មន្ទីរ-ស្ថាប័ន្ធពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងចំនួនប្រជាជនដែលចូលរួមមានដូចខាងក្រោម៖

តារាង ២.៧៖ វិធីសាស្ត្រក្នុងការពិគ្រោះយោបល់ជាសាធារណៈ

| វិធីសាស្ត្រ | ស្ថាប័នដែលបានសម្ភាសន៍ | ថ្ងៃ និងម៉ោងសម្ភាសន៍ | អ្នកចូលរួម |
|---|---|---|---|
| ស្នើរសុំពិគ្រោះយោបល់ផ្ទាល់ | សាលាខេត្តព្រះសីហនុ | ៣១ តុលា២០១៤<br>ម៉ោង៨:០០-៩:០០ព្រឹក | - ក្រុមហ៊ុនទីប្រឹក្សា: ៣នាក់<br>- អភិបាលខេត្ត និងជំនួយការ |
| | មន្ទីរបរិស្ថានខេត្តព្រះសីហនុ | ៣១ តុលា២០១៤<br>ម៉ោង២:០០-៣:០០ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា: ៣នាក់<br>- អនុប្រធានមន្ទីរ |
| | មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ | ៣១ តុលា២០១៤<br>ម៉ោង៩:៣០-១០:៣០ព្រឹក | - ក្រុមហ៊ុនទីប្រឹក្សា: ៣នាក់<br>-អនុប្រធានមន្ទីរ និង<br>ប្រធានការិយាល័យ: ៣នាក់ |
| | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តព្រះសីហនុ | ៣១ តុលា២០១៤<br>ម៉ោង២:០០-៣:១០ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា: ៣នាក់<br>- ប្រធានការិយារៀបចំដែនដី<br>និងជំនួយការ: ២នាក់ |
| ស្នើរសុំពិគ្រោះយោបល់ និងសម្ភាសន៍ផ្ទាល់ | មន្ទីរសាធារណៈ និងដឹកជញ្ជូនខេត្តព្រះសីហនុ | ៣១ តុលា២០១៤<br>ម៉ោង៣:៣០-៤:៣០ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា: ៣នាក់<br>- អនុប្រធានមន្ទីរ |
| | ខណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ | ៣០ តុលា២០១៤<br>ម៉ោង២:០០-៣:០០ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា: ៣នាក់<br>- អភិបាលរងខណ្ឌ |
| | ខណ្ឌរដ្ឋបាលព្រៃឈើ | ៣០ តុលា២០១៤ | - ក្រុមហ៊ុនទីប្រឹក្សា: ៣នាក់ |

| វិធីសាស្ត្រ | ស្ថាប័នដែលបានសម្ភាសន៍ | ថ្ងៃ និងម៉ោងសម្ភាសន៍ | អ្នកចូលរួម |
|---|---|---|---|
| | ខេត្តព្រះសីហនុ | ម៉ោង២:០០-៣:០០ល្ងាច | - អភិបាលរងខណ្ឌ |
| ស្នើរសុំពិគ្រោះយោបល់ និងប្រជុំនៅសាលាឃុំរាម | - ប្រធានឃុំរាម<br>- មេភូមិរាម<br>- មេភូមិស្មាច់ដែង<br>- មេភូមិថ្មធំ<br>- មេភូមិអុង | ០១ វិច្ឆិកា២០១៤<br>ម៉ោង៩:០០-១១:០០ព្រឹក | - ក្រុមហ៊ុនទីប្រឹក្សា: ៨នាក់<br>- មេឃុំរាម: ១នាក់<br>- មេភូមិរាម: ១នាក់<br>- មេភូមិស្មាច់ដែង: ១នាក់<br>- មេភូមិថ្មធំ: ១នាក់<br>- មេភូមិអុង: ១នាក់ |
| ស្នើរសុំពិភាក្សាក្រុមនៅសាលាឃុំរាម | ប្រជាជនមូលដ្ឋាន | ០១ វិច្ឆិកា២០១៤<br>ម៉ោង៣:០០-៥:០០ល្ងាច | - ក្រុមហ៊ុនទីប្រឹក្សា: ៨នាក់<br>- តំណាងប្រជាជនក្នុងឃុំរាម: ១៨នាក់ |
| ការសម្ភាសន៍ | ប្រជាជនមូលដ្ឋាន | ០៩ កក្កដា ២០១២ | - ក្រុមហ៊ុនទីប្រឹក្សា: ៨នាក់<br>- តំណាងប្រជាជនក្នុងឃុំរាម: ៩៥នាក់ |

## ២.៣.៩ វិធីសាស្ត្រវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន

ការវិភាគប្រសិទ្ធិភាពសេដ្ឋកិច្ចគឺផ្តោតលើកត្តាពីរសំខាន់ៗគឺ ការវិភាគហិរញ្ញវត្ថុ (Financial analysis) និងការវិភាគសេដ្ឋកិច្ច (Economic analysis) នៃគម្រោងអភិវឌ្ឍន៍នីមួយៗ។ ការវិភាគសេដ្ឋកិច្ចនៃគម្រោងវិនិយោគ គឺស្រដៀងគ្នានឹងការវិភាគហិរញ្ញវត្ថុ ដែលការវិភាគទាំងពីរនេះ ក្នុងគោលបំណងកំណត់អំពីកម្រិតនៃផលចំណេញរបស់គម្រោង។ ប៉ុន្តែគំនិតសំខាន់នៃផលចំណេញផ្នែកហិរញ្ញវត្ថុរបស់គម្រោងមិនដូចគ្នានឹងផលចំណេញ ផ្នែកសេដ្ឋកិច្ចរបស់គម្រោងទេ។ ការវិភាគហិរញ្ញវត្ថុ(Financial analysis)របស់គម្រោង គឺធ្វើឡើងដើម្បីប៉ាន់ស្មានផលចំណេញ ដែលទទួលបានពីការប្រតិបត្តិគម្រោងរបស់ក្រុមហ៊ុនវិនិយោគ។ ដោយឡែក ការវិភាគសេដ្ឋកិច្ច (Economic analysis) របស់គម្រោងគឺដើម្បីវាស់វែងផលប៉ះពាល់នានានៃគម្រោងលើសេដ្ឋកិច្ចជាតិ។ គម្រោងមួយដែលអាចដំណើរការទៅបាន គឺត្រូវមាននិរន្តរភាពហិរញ្ញវត្ថុរបស់ខ្លួន ផ្ទុយផ្សំនឹងប្រសិទ្ធិភាពផ្នែកសេដ្ឋកិច្ចនៃការប្រតិបត្តិគម្រោង។ ផ្ទុយទៅវិញ ប្រសិនបើគម្រោងនោះពុំមាននិរន្តរភាពហិរញ្ញវត្ថុទេ នោះផលចំណេញផ្នែកសេដ្ឋកិច្ចនៃសង្គមជាតិក៏មិនអាចកើតមានផងដែរ។ ដូចនេះ ការវិភាគហិរញ្ញ

វត្ថុ (Financial analysis) និងសេដ្ឋកិច្ច (Economic analysis) ប្រៀបបាននឹងកាក់មួយមានមុខពីរ ដែលជួយបំពេញឱ្យគ្នាទៅវិញទៅមក។

បន្ទាប់ពីធ្វើការកំណត់អថេរចំណាយ និងចំណូល ដើម្បីធ្វើការវិភាគផ្នែកហិរញ្ញវត្ថុ និងការវិភាគផ្នែកសេដ្ឋកិច្ចរួចរាល់មក យើងនឹងប្រើប្រាស់វិធីសាស្ត្រវិភាគប្រៀបធៀបផលចំណេញ-ខាត (Cost-Benefit Analysis) ដើម្បីវាស់វែង ថាតើការវិនិយោគរបស់គម្រោងមួយអាចមានប្រសិទ្ធិភាពសេដ្ឋកិច្ចកម្រិតណា។ វិធីសាស្ត្រវិភាគប្រៀបធៀបផលចំណេញ-ខាត (Cost-Benefit Analysis) គឺជាសេដ្ឋម៉ែត្រដ៏សាមញ្ញមួយ ត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីវិភាគលើប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនៃគម្រោងអភិវឌ្ឍន៍ ហើយត្រូវបានគេប្រើប្រាស់ដើម្បីធ្វើការសម្រេចចិត្តទៅលើគម្រោងណាមួយដើម្បីស្វែងយល់ឱ្យច្បាស់ថាតើគម្រោងវិនិយោគនោះអាចប្រព្រឹត្តិទៅបាន ឬក៏យ៉ាងណាដោយផ្អែកលើផលចំណេញផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ចជាតិដែលអាចទទួលបានពីសកម្មភាពគម្រោង។

នៅក្នុងការសិក្សាហេតុប៉ះពាល់បរិស្ថាន (EIA) នេះ យើងក៏ប្រើប្រាស់វិធីសាស្ត្រវិភាគប្រៀបធៀបផលចំណេញ-ខាតផងដែរ ដើម្បីកំណត់ឱ្យឃើញ ថាតើការវិនិយោគរបស់ ក្រុមហ៊ុនអភីបី ផ្តល់ផលចំណេញសេដ្ឋកិច្ច និងជួយលើកកំពស់សេដ្ឋកិច្ចជាតិក្នុងកម្រិតណា។ លើសពីនេះទៀត យើងក៏ប្រើប្រាស់វិធីសាស្ត្រវិភាគរកតម្លៃនៃអត្រាចំណូលវិនិយោគខាងក្នុង (IRR) ដែលជាវិធីសាស្ត្រមួយ បង្ហាញឱ្យយើងឃើញពីអត្រានៃការទទួលបានផលចំណេញមកវិញ ដោយធៀបនឹងអត្រាការប្រាក់ ឬអត្រាអប្បហារ។

ការវិភាគផលចំណេញ-ខាត (CBA) គឺជាផលធៀបនៃផលបូកសរុបនៃតម្លៃចំណេញបច្ចុប្បន្ន (Total Present Value benefit) និងផលបូកសរុបនៃតម្លៃចំណាយបច្ចុប្បន្ន (Total Present Value cost)។ បច្ចុប្បន្ន អត្រាការប្រាក់ ឬអត្រាអប្បហារ ប្រែប្រួលពី១០% ទៅ១៥%ក្នុងមួយឆ្នាំ ដោយអាស្រ័យទៅតាមប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ ដូចនេះ ការជ្រើសរើសយកអត្រាការប្រាក់ ឬអត្រាអប្បហារ គឺជាចំនុចដ៏សំខាន់ក្នុងការវិភាគផលចំណេញ-ខាត (CBA) របស់គម្រោង ដោយសារតែការប្រែប្រួលនៃតម្លៃបច្ចុប្បន្ន (Present Value) របស់ចំណាយ និងចំណូលនៃការវិនិយោគ គឺអាស្រ័យលើអត្រាអប្បហារ (Discout rate)។

## ២.៣.៦ វិធីសាស្ត្រកំណត់ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

វិធីសាស្ត្រសម្រាប់ប្រើក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គម គឺអាចប្រែប្រួលទៅតាមប្រភេទគម្រោងនីមួយៗ និងផ្អែកទៅលើបទពិសោធន៍ឬទៅលើឯកសារ ដែលមានស្រាប់

(Existing literatures or past experiences) ចំពោះគម្រោងដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ វិធីសាស្ត្រដែលគេធ្លាប់ប្រើជាញឹកញាប់រួមមាន៖

ក. វិធីសាស្ត្រតាមបញ្ជីផ្ទៀងផ្ទាត់ (Checklist)

គឺជាបញ្ជីស្តង់ដារនៃប្រភេទហេតុប៉ះពាល់ ដែលទាក់ទងទៅនឹងប្រភេទនៃគម្រោងមួយជាក់លាក់ (Impact associated with a particular type of project)។ វិធីសាស្ត្រដោយប្រើបញ្ជីផ្ទៀងផ្ទាត់នេះគេប្រើវាជាចំបងសំរាប់រៀបចំព័ត៌មាន (Organizing information) ឬក៏ធានាឲ្យបានថាមិនមានហេតុប៉ះពាល់ណាមួយ ដែលអាចកើតមានឡើងត្រូវបានមើលរំលងឬធ្វេសប្រហែសឡើយ (No potential impact is overlooked)។ ចំពោះបញ្ជីផ្ទៀងផ្ទាត់នេះគេក៏អាចប្រើបញ្ជីផ្ទៀងផ្ទាត់ដែលមានលក្ខណៈសាមញ្ញ (Simple Checklist) ដែលជាបញ្ជីកំណត់នូវប៉ារ៉ាម៉ែត្របរិស្ថានដោយមិនទាមទារឲ្យមានការប្រើសេចក្តីណែនាំ (Guideline) ថាតើប៉ារ៉ាម៉ែត្រទាំងនោះត្រូវបានវាស់យ៉ាងដូចម្តេចឡើយ។

ខ. វិធីសាស្ត្រម៉ាទ្រីកហ្វីនីកផាល់មីល (Matrix Phoenic Pulp Mill Method)

នេះគឺជាម៉ាទ្រីកសំរាប់កំណត់ភាពប្រទាក់គ្នា (interactions) រវាងសកម្មភាពនានារបស់គម្រោងទៅនឹងហេតុប៉ះពាល់ នៃសមាសធាតុបរិស្ថានដែលអាចកើតមាន។ ម៉ាទ្រីកដែលមានភាពងាយស្រួល ហើយដែលគេនិយមប្រើគឺ នីកផាល់មីល (Phoenic Pulp Mill) ដែលបង្ហាញអំពីភាពប្រទាក់គ្នារវាងសមាសភាគបរិស្ថាន (Environmental components) ជាមួយនឹងសកម្មភាពនានារបស់គម្រោង។

គ. ប្រើប្រាស់សេចក្តីណែនាំ (Sectorial guideline)

ការវាយតំលៃហេតុប៉ះពាល់នៃបរិស្ថានត្រូវផ្អែកទៅលើឯកសារ ឬសេចក្តីណែនាំដែលមានស្រាប់ព្រោះវាជួយបង្កើនល្បឿននៃការសិក្សាដោយផ្អែកលើបទពិសោធន៍ និងមេរៀនដែលទទួលបានចំពោះគម្រោងដែលមានលក្ខណៈស្រដៀងគ្នា ឧទាហរណ៍ដូចជាសេចក្តីណែនាំដែលបានបង្កើតឡើងដោយក្រសួងបរិស្ថាន។

## ២.៣.៧ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យក្នុងការសិក្សានេះត្រូវបានបែងចែកជា២ប្រភេទគឺ តាមបែបគុណវិស័យ (Qualitative Data) និងតាមបែបបរិមាណវិស័យ (Quantitative Data)។ ការសិក្សាបានប្រើប្រាស់នូវកម្មវិធី SPSS និង Microsoft Office Excel 2010 ដើម្បីធ្វើការវិភាគ និងបកស្រាយទិន្នន័យ។ ការវិភាគទិន្នន័យនេះនឹងបកស្រាយជាតារាង ក្រាបសរសេរ ក្រាបផ្លិត ដ្យាក្រាម និងរូបភាពជាដើម។

## ២.៤ ដ្យាក្រាមសង្ខេបពីវិធីសាស្ត្រស្រាវជ្រាវ



# ជំពូកទី៣៖
# ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី៣៖ ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ

ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ហើយនិងរបាយការណ៍ដែលត្រូវចងក្រង នឹងធ្វើឡើងដោយគោរពទៅតាម និងមានសុពលភាពក្របខ័ណ្ឌច្បាប់ និងអនុក្រឹត្យនានាដែលពាក់ព័ន្ធទៅនឹងការការពារបរិស្ថាន ធនធានធម្មជាតិ និងគម្រោងអភិវឌ្ឍន៍ ដែលមានបរិយាយដូចខាងក្រោមនេះ៖

## ៣.១ ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (ឆ្នាំ១៩៩៦)

ច្បាប់ស្ដីអំពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិត្រូវបានអនុម័តដោយរដ្ឋសភាជាតិ ហើយត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយ ព្រះរាជក្រមលេខ នស,រកម១២៩៦,៣៦ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ច្បាប់នេះមានគោលដៅ៖

- ការពារលើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋ ដោយធ្វើការទប់ស្កាត់កាត់បន្ថយ និងការត្រួតពិនិត្យការបំពុល។
- វាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញនូវសេចក្ដីសំរេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គម្រោងដែលបានស្នើឡើង។
- ធានាឲ្យមានការអភិរក្ស ការអភិវឌ្ឍន៍ ការគ្រប់គ្រងនិងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
- លើកទឹកចិត្ត និងផ្ដល់លទ្ធភាពឲ្យសាធារណៈជនចូលរួមក្នុងកិច្ចការពារបរិស្ថាននិងការគ្រប់គ្រង ធនធានធម្មជាតិ។
- បង្ក្រាបរាល់អំពើទាំងឡាយ ដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន។

ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់នេះបានតំរូវឲ្យបណ្ដាក្រុមហ៊ុនទាំងអស់ ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA)។ ផ្អែកលើច្បាប់នេះបានចែងនៅក្នុងមាត្រាទី៦និង៧ នៃជំពូកទី៣ ដែលមានសេចក្ដីដូចខាងក្រោម៖

**មាត្រា៦៖** ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើគម្រោង និងសកម្មភាពរបស់ឯកជនឬសាធារណៈ ហើយត្រូវបានត្រួតពិនិត្យនិងវាយតំលៃដោយក្រសួងបរិស្ថាន មុននឹងដាក់ជូនរាជរដ្ឋា

ភិបាលសំរេច។ ការវាយតំលៃនេះត្រូវអនុវត្តផងដែរចំពោះសកម្មភាព ដែលមានស្រាប់និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។ ប្រភេទទំហំគម្រោងនិងសកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

<u>**មាត្រា៧៖**</u> ចំពោះពាក្យស្នើសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតំលៃហេតុប៉ះពាល់ បរិស្ថានដំបូង (IEIA)ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ(EIA)ដូចមានចែងក្នុងមាត្រា៦ នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវត្រួតពិនិត្យ និងផ្តល់យោបល់លើ IEIA ឬ EIA ទៅអង្គភាពមានសមត្ថកិច្ចក្នុងរយៈពេលដូចបានកំណត់ ក្នុងច្បាប់ស្តីពីវិនិ យោគនៃព្រះរាជាណាចក្រកម្ពុជា។

## ៣.២ ច្បាប់ស្តីពីព្រៃឈើ (ឆ្នាំ២០០២)

ច្បាប់ស្តីពីព្រៃឈើត្រូវបានអនុម័តដោយរដ្ឋសភាជាតិ និងប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខនស/រកម/០៨០២/០១៦/៣១ អនុម័តនៅថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០០២។ មាត្រាដែលពាក់ព័ន្ធនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថានៃគម្រោងវិនិយោគនេះមានដូចខាងក្រោម៖

ច្បាប់ស្តីពីព្រៃឈើត្រូវបានអនុម័តដោយរដ្ឋសភាជាតិនិងប្រកាស ឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៨០២/០១៦/៣១អនុម័តនៅថ្ងៃទី៣០ខែកក្កដាឆ្នាំ២០០២។ មាត្រាដែលពាក់ព័ន្ធនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថានៃគម្រោងវិនិយោគនេះមានដូចខាងក្រោម៖

<u>**មាត្រា១៖**</u>

- ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនៃការគ្រប់គ្រងការប្រមូលផលការប្រើប្រាស់ ការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោល បំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាពដើម្បីផលប្រយោជន៍សង្គម-សេដ្ឋកិច្ចនិងបរិស្ថានរួមទាំងការអភិរក្សជីវៈចំរុះនិងមរតកវប្បធម៌។

<u>**មាត្រា៣៖**</u>

- ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅ នៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។ ការគ្រប់គ្រងព្រៃលិចទឹកស្ថិតនៅក្រោមច្បាប់មួយដោយឡែក។ រដ្ឋផ្តល់សិទ្ធគ្រប់គ្រង

តំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថានក្រោមបទបញ្ញាតិទាំងឡាយ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធម្មជាតិចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើតនិងកំណត់តំបន់ការពារធម្មជាតិចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ និងលិខិតបទដ្ឋានច្បាប់ផ្សេងៗទៀត។

➢ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ចំពោះរាល់បទល្មើសព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការសំរបសំរួលជាមួយក្រសួងបរិស្ថាន ស្របតាមបទបញ្ញតិ ដូចមានចែងនៅក្នុងជំពូកទី១៤ នៃច្បាប់នេះ។

➢ សកម្មភាពនេះមិនធ្វើឱ្យប៉ះពាល់ដែលសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

<u>**មាត្រា៦៖**</u>

➢ ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសំរេចរបស់រដ្ឋាភិបាល ដែលមានសក្តានុភាពចំពោះហេតុប៉ះពាល់ធ្ងន់ធ្ងរទៅលើសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការចូលរួមជាសាធារណៈ។

➢ សកម្មភាពចំបងៗ ដែលពាក់ព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលឱ្យមានការប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងហេតុប៉ះពាល់ សង្គម ដោយផ្អែកលើក្រុមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

➢ ឯកសារវាយតំលៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈរាល់ការសម្រេចចុងក្រោយលើសកម្មភាពចំបងៗពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាល ត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ការសំរេចចុងក្រោយ ណាមួយក្រោមមាត្រានេះរាជរដ្ឋាភិបាលអាចជូនដំណឹងជាសាធារណៈ។

<u>**មាត្រា៧៖**</u>

➢ សហគមន៍មូលដ្ឋានដែលប្រកបរបរចំការពនេរចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិសហគមន៍ជនជាតិភាគតិចដែលបានចុះបញ្ជីការួចហើយជាមួយរដ្ឋ។ ផ្នែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាននេះត្រូវផ្តល់ការអនុញ្ញាតិការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះ ដែលជាផ្នែកមួយនៃ ផែនការគ្រប់គ្រងព្រៃសហគមន៍នោះ។ ការអនុវត្តន៍ចំការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃ

ធម្មជាតិមិនទាន់ប៉ះពាល់ក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍។ ដីព្រៃឈើដែលរៀបចំសម្រាប់ចំការពនេចរ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៩៖**

➢ គ្មានរូបវន្តបុគ្គលណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីឲ្យកាន់កាប់ដីក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះឡើយ។

**មាត្រា៩៤៖**

➢ បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើ ធ្វើឲ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើត្រូវចេញថ្លៃស្តារ ឬជូសជុលការខូចខាតមានលក្ខខណ្ឌដូចដើមឡើងវិញ។

## ៣.៣ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៧)

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋភាលើកទី៦ នីតិកាលទី៣។

**មាត្រា១៖**

ច្បាប់នេះមានគោលដៅជុំរុញ ឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធិភាព និងនិរន្តភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសំរេចបាននូវការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះកំណត់អំពី:

- សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក
- គោលការណ៍គ្រឹះសំខាន់ៗ សម្រាប់ការគ្រប់គ្រងធនធានទឹក
- ការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹក ក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តភាព។

**មាត្រា២៖**

ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានន័យថា៖

- ទឹក គឺទឹកលើដី ទឹកក្រោមដី និងទឹកក្នុងអាកាស។
- ធនធានទឹកគឺទឹកសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងជងអូរ បឹងបួ ត្រពាំង ថ្លុក អាងទឹក

- ទឹកក្រោមដី គឺទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែង មួយទៅកន្លែងមួយទៀត។
- ល្អាងទឹកក្រោមដី គឺទឹកក្រោមដីដែលស្ថិតនៅជាអចិន្ត្រៃយ៍ក្នុងល្អាងធម្មជាតិក្រោមដី។
- អាងទន្លេ គឺតំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរ ដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។
- អាងទន្លេរង គឺផ្នែកមួយនៃអាងទន្លេ។
- ទន្លអន្តរជាតិ គឺទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹកដីប្រទេសចាប់ពីពីរឡើងទៅ។
- ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺចំណែកដីដែលធម្មតាលិចដោយទឹក នៅក្នុងទន្លេ ស្ទឹង ព្រែក អូរ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬអង្គធាតុដទៃទៀតដែលនៅឆ្ងាយពីច្រាំង និងលិចទឹកម្តងម្កាលនោះ។
- ឆ្នេរសមុទ្រ ទន្លេ ស្ទឹង គឺចំណែកដី ឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល
- បាតទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺផ្នែកមួយនៃដីដែលកំណត់ដោយច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាតទឹកដែលគ្របដណ្តប់ដោយទឹក។
- តម្រូវការសាធារណៈ គឺការផ្គត់ផ្គង់ទឹកនៅតាមទីក្រុងនិងជនបទ ការផលិតស្បៀង ការផលិតថាមពលវារីអគ្គីសនី ការបំរើវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យនាវាចរ និងការរក្សាឲ្យមានជារាទឹកអប្បរមា ដើម្បីថែរក្សាបរិស្ថាន ជីវិតមនុស្សជីវិតមច្ឆាជាតិ និងរុក្ខជាតិនានា។
- ការងារទឹក គឺសំណង់ទំនប់ធំ តូច ទំនប់បង្វៀរ ទំនប់បញ្ជាល់ទឹក ទំនប់ទឹកការពារទឹកជំនន់ ប្រឡាយដោះទឹកធំ តូច ប្រព័ន្ធស្រោចស្រព អាងទឹកតូចធំ ប្រឡាយនាំទឹក អណ្តូងទឹកគ្រប់ប្រភេទ ទំនប់វារីអគ្គីសនី និងសំណង់ដទៃទៀត ដែលបានសាងសង់ក្នុងគោលបំណងបង្វែរទឹក រក្សាទឹកទុក នាំទឹកយកទៅប្រើប្រាស់ អភិរក្សការពារធនធានទឹក ដោះទឹកចេញពីតំបន់ដីលិចទឹកការពារកាត់បន្ថយនូវឥទ្ធិពលទឹកជំនន់ និងសង្គ្រោះបន្ទាន់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងទឹក។
- អាជ្ញាប័ណ្ណទឹក · គឺប័ណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ទឹក និងធនធានទឹកឲ្យបុគ្គលគ្រប់រូបដើម្បីធ្វើអាជីវកម្ម និងអភិវឌ្ឍន៍។
- បុគ្គល គឺរូបវន្តបុគ្គល ឬនីតិបុគ្គលទោះក្នុងន័យជាឯកជន ឬសាធារណៈក៏ដោយ។

**<u>មាត្រា៣៖</u>** ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ។

- ទឹកក្រោមដី គឺទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែង មួយទៅកន្លែងមួយទៀត។
- ល្អាងទឹកក្រោមដី គឺទឹកក្រោមដីដែលស្ថិតនៅជាអចិន្ត្រៃយ៍ក្នុងល្អាងធម្មជាតិក្រោមដី។
- អាងទន្លេ គឺតំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទឹជម្រាលនៃប្រព័ន្ធទឹកហូរ ដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។
- អាងទន្លេរង គឺផ្នែកមួយនៃអាងទន្លេ។
- ទន្លអន្តរជាតិ គឺទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹកដីប្រទេសចាប់ពីពីរឡើងទៅ។
- ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺចំណែកដីដែលធម្មតាលិចដោយទឹក នៅក្នុងទន្លេ ស្ទឹង ព្រែក អូរ បឹងបួ និងអាងទឹក ដោយរាបើបញ្ចូលទាំងដី ថ្ម ឬអង្គធាតុដទៃទៀតដែលនៅឆ្ងាយពីច្រាំង និងលិចទឹកម្តងម្កាលនោះ។
- ឆ្នេរសមុទ្រ ទន្លេ ស្ទឹង គឺចំណែកដី ឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល
- បាតទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺផ្នែកមួយនៃដីដែលកំណត់ដោយច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាតទឹកដែលគ្របដណ្តប់ដោយទឹក។
- តម្រូវការសាធារណៈ គឺការផ្គត់ផ្គង់ទឹកនៅតាមទីក្រុងនិងជនបទ ការផលិតស្បៀង ការផលិតថាមពលវារីអគ្គីសនី ការបំរើវិស័យកកសិកម្ម វិស័យឧស្សាហាកម្ម វិស័យនាវាចរ និងការរក្សាឲ្យមានជាវទឹកអប្បរមា ដើម្បីថែរក្សាបរិស្ថាន ជីវិតមនុស្សជីវិតមច្ឆាជាតិ និងរុក្ខជាតិនានា។
- ការងារទឹក គឺសំណង់ទំនប់ធំ តូច ទំនប់បង្វៀរ ទំនប់បញ្ចាល់ទឹក ទំនប់ទឹកការពារទឹកជំនន់ ប្រឡាយដោះទឹកធំ តូច ប្រព័ន្ធស្រោចស្រព អាងទឹកតូចធំ ប្រឡាយនាំទឹក អណ្តូងទឹកគ្រប់ប្រភេទ ទំនប់វារីអគ្គីសនី និងសំណង់ដទៃទៀត ដែលបានសាងសង់ក្នុងគោលបំណងបង្វែរទឹក រក្សាទឹកទុក នាំទឹកយកទៅប្រើប្រាស់ អភិរក្សការពារធនធានទឹក ដោះទឹកចេញពីតំបន់ដីលិចទឹកការពារកាត់បន្ថយនូវឥទ្ធិពលទឹកជំនន់ និងសង្គ្រោះបន្ទាន់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងទឹក។
- អាជ្ញាប័ណ្ណទឹក · គឺប័ណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ទឹក និងធនធានទឹកឲ្យបុគ្គលគ្រប់រូបដើម្បីធ្វើអាជីវកម្ម និងអភិវឌ្ឍន៍។
- បុគ្គល គឺរូបវន្តបុគ្គល ឬនីតិបុគ្គលទោះក្នុងន័យជាឯកជន ឬសាធារណៈក៏ដោយ។

**<u>មាត្រា៣៖</u>** ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ។

**មាត្រា១១៖**

បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយ មិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និនងតម្រូវការផ្សេងៗ រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និងដំណាំ ដោយចៀសវាងមិនឲ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ។ តម្រូវការខាងលើនេះ មិនតម្រូវឲ្យសុំអាជ្ញាប័ណ្ណឡើយ។

**មាត្រា១២៖**

ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្មលើសពីកំរិតដែលមានចែងក្នុងមាត្រា១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធ តម្រូវឲ្យមានការសុំ ជាអាជ្ញាប័ណ្ណទឹក ឬលិចិតអនុញ្ញត។ បែបបទនៃការសុំនេះ មិនមានចែងក្នុអនុក្រិត្យ។ ការយកខ្សាច់ដី ឬគ្រួសប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរ សមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួតម្រូវឲ្យមានការសុអាជ្ញាប័ណ្ណទឹក។ បែបបទបច្ចេកទេសជលសាស្ត្រដែលពាក់ព័ន្ធនឹងការងារនេះ នឹងមានចែងលំអិតនៅក្នុង អនុក្រិត្យ។ ការលប់ទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ អាងទឹក និងអាងធម្មជាតិតម្រូវឲ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាតិ។ បែបបទនៃការសុំនេះនឹងមានចែងនៅក្នុងអននុក្រឹត្យ។ ការសាងសង់ ស្ពានតូចធំ កាត់ទន្លេ ស្ទឹង កំពង់ផែ ឬសំណង់អាគារតូចធំ លើច្រាំង និងឆ្នេរទន្លេតម្រូវឲ្យមានការឯភាពផ្នែកបច្ចេកទេសជាមុនពីក្រសួងធនធានទឹក និងឧតុនិយម។ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការអនុញ្ញាតិ និងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានការអនុម័តយល់ព្រមពិស្ថាប័ននីតិបញ្ញតិ។

**មាត្រា១៤៖**

មុនពេលផ្តល់អាជ្ញាប័ណ្ណទឹកដល់បុគ្គលណាមួយ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើការប្រើប្រាស់ទឹក និងការសាងសង់ សំណង់ការងារទឹកដែលបុគ្គលនោះស្នើឡើង។

**មាត្រា២២៖**

រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិ ត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការ អនុញ្ញតិ។ ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដារបច្ចេកទេសនៃការបញ្ចេញ

ទឹក សំណល់នឹងមានកំណត់ដោយអនុក្រឹត្យ។ រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

<u>មាត្រា២៣៖</u>

ក្រសួងធនធានទឹក និងឧតុនិយម អាចប្រកាសទុកជាតំបន់អាសន្ន ឬជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹកក្នុងករណីដែល:

- ទឹកលើដី ឬទឹកក្រោមដីត្រូវនបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬតុល្យភាពអេកូឡូស៊ី។
- ទឹកលើទីជំរាលដែលកំពុងរងការគំរាមកំហែងដោយសកម្មភាពមនុស្ស ឬធម្មជាតិ។
- ទឹកដែលបណ្តាលឲ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ។

ដែនភូមិសាស្ត្រនៃតំបន់អាសន្ន ឬតំបន់ហាមឃាត់នោះ ត្រូវកំណត់តាមករណីនិមួយៗដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម។

<u>មាត្រា៣២៖</u>

រាល់វិវាទដែលពាក់ព័ន្ធនឹងការបង្កើត និងដំណើការសេវាក្នុងការប្រើប្រាស់ទឹកត្រូវ សម្រួលដោះស្រាយដោយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងពាក់ព័ន្ធ និងអាជ្ញាធរ មូលដ្ឋាន។

<u>មាត្រា៣៨៖</u>

រាជរដ្ឋាភិបាលអាចផ្តល់រង្វាន់លើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗដល់បុគ្គលទាំងឡាយដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ ការបង្កើតបច្ចេកវិទ្យាថ្មីៗ ឬការដំឡើងឧករណ៍ទំនើបដែលជួយ កាត់បន្ថយកាកសំណល់ និងជួយបង្កើនគុណភាពទឹក ដើម្បីឲ្យការប្រើប្រាស់ទឹកមានប្រសិទ្ធភាពខ្ពស់។ លក្ខណៈវិនិច្ឆ័យ និងបែបបទសម្រាប់ការផ្តល់រង្វាំលើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម។

## ៣.៤ ច្បាប់ស្តីពីជលផល (ឆ្នាំ២០០៦)

ច្បាប់ស្តីពីជលផល ត្រូវបានអនុម័តដោយរដ្ឋសភាជាតិដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម ០៥០៦/ ០១១ ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៦។

<u>ប្រការ១៖</u> បានចែងថា "ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្មជលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋក្នុង

សហាគមន៍មូលដ្ឋាន ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះផង ទាំងមរតកវប្បធម៌ធម្មជាតិផង ប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។”

<u>ប្រការ៣៖</u> បានចែងថា “ការគ្រប់គ្រងជលផល ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅ នៃក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ។ ការគ្រប់គ្រង ព្រៃលិចទឹក និងព្រៃកោងកាងដែលពាក់ព័ន្ធនឹងវដ្តជីវិតធនធាន ជលផលត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់នេះ។

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទបញ្ញតិទាំងឡាយនៃច្បាប់ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹកការអនុវត្តច្បាប់ ចំពោះរាល់បទល្មើសជលផលដែលកើតមានចែងក្នុងជំពូកទី១៨នៃច្បាប់នេះ។ សកម្មភាពនេសាទនេះនឹងមិនធ្វើឲ្យប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ”។

<u>ប្រការ២២៖</u> បានចែងថា “ហាមឃាត់ ការចាក់ចោល ការបោះចោល ការបង្ហូរ ឬការបាចពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬរាវ ឬសារធាតុពុលដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តិសកម្មភាពដែលធ្វើឲ្យពុល ឬការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ។”

## ៣.៥ ច្បាប់ភូមិបាល (ឆ្នាំ២០០១)

ច្បាប់ភូមិបាលនេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តនៅថ្ងៃទី២០ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី២។ មាត្រាសំខាន់ៗដែលពាក់ព័ន្ធទៅនឹងគម្រោង គឺមានសេចក្តី ដូចខាងក្រោម៖

<u>មាត្រា១៖</u> ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយ នៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជា។

<u>មាត្រា៣៖</u> ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ។ ការគ្រប់គ្រងផ្នែក រដ្ឋបាលសុរិយោដីលើអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ និងការចេញប័ណ្ណ

កម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បទបញ្ញា និងនីតិវិធី នៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋនឹងត្រូវកំណត់ដោយអនុក្រឹត្យ។

**<u>មាត្រា៧៖</u>** របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់។

**<u>មាត្រា៨៖</u>** មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកមានឧបនិស្ស័យជាកម្មសិទ្ធិលើដីនៅកម្ពុជា គឺពលរដ្ឋខ្មែរទាំងអស់ សមូហភាព ដែនដី សាធារណៈ គ្រឹះស្ថានសាធារណៈ សហគមន៍ឬសមាគមកម្ពុជាសហគ្រាសសាធារណៈ និងក្រុមហ៊ុនស៊ីវិល ឬ ពាណិជ្ជកម្មកម្ពុជា និងគ្រប់អង្គការកម្ពុជា ដែលបានទទួលស្គាល់ដោយច្បាប់ថាជានីតិបុគ្គល។ ជនបរទេសដែលបានក្លែងបន្លំប័ណ្ណសញ្ជាតិដើម្បីឲ្យក្លាយជាកម្មសិទ្ធិករលើដីនៅកម្ពុជានឹងត្រូវផ្តន្ទាទោស ដូចចែង ក្នុងមាត្រា២៥១ នៃច្បាប់នេះ។ ទ្រព្យដែលបានមកក្នុងលក្ខខណ្ឌនេះ ត្រូវរឹបអូសយកទុកជាសម្បត្តិរដ្ឋ ដោយរដ្ឋ មិនចេញសំណងឲ្យឡើយ។

**<u>មាត្រា១២៖</u>** រដ្ឋជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិទាំងឡាយក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងក្នុងមាត្រា ៥៨ នៃ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងទ្រព្យនិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឲ្យរដ្ឋ ដោយស្ម័គ្រចិត្ត ឬទ្រព្យ ដែលមិនមែនជាកម្មវត្ថុនៃការយកធ្វើជារបស់ឯកជនតាមច្បាប់ ឬមិនមែនជាទ្រព្យ ដែលកំពុងកាន់កាប់ជារបស់ឯកជនស្របតាមបទបញ្ញត្តិនៃជំពូកទី៤ នៃច្បាប់នេះ។

**<u>មាត្រា១៥៖</u>** រាប់ចូលក្នុងសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ៖

- ទ្រព្យទាំងឡាយដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹកដែលនាវា ឬក្បូន ចេញចូលបានបណ្តែត បឹងធម្មជាតិ ច្រាំងទន្លេដែលនាវាឬក្បូនចេញចូលបានបណ្តែតបាន និងត្រើយសមុទ្រ។
- ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេស សម្រាប់ប្រយោជន៍ទូទៅ ដូចជាទីឋានកំពង់ផែ ផ្លូវដែក ស្ថានីយ៍រថភ្លើង និងព្រលានយន្តហោះ។
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឲ្យប្រើជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំដូចជា ផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងឧទ្យានសាធារណៈ និងដីចំណី។
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឲ្យដំណើរការ សម្រាប់សេវាសាធារណៈ ដូចជា សាលារៀនឬអគារសិក្សា សាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ។

- ទ្រព្យទាំងឡាយដែលបង្កើតជាដែនបំរុងធម្មជាតិការពារដោយច្បាប់
- បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ។
- អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស។
- អចលនវត្ថុជាព្រះរាជទ្រព្យត្រូវបានចាត់ចែងដោយព្រះមហាក្សត្រកំពុងគ្រងរាជ្យ។

**មាត្រា១៦៖** ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ ហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះ មិនអាចកំណត់អាយុកាលបានទេ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចបិតនៅក្រោមការកាន់កាប់ដោយ លទ្ធកម្មពិសេសនៃ ជំពូកទី៤ នៃច្បាប់នេះបានទេ។ ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ អាចជាកម្មវត្ថុនៃការអនុញ្ញាតឲ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្នមិនទៀង ហើយអាចដកហូតវិញបាន បើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ លើកលែងតែបានអនុញ្ញាតតាម ជំពូកទី៣នៃច្បាប់នេះ។ ការអនុញ្ញាតទាំងនេះមិនអាចប្រែក្លាយទៅជាកម្មសិទ្ធិ ឬជាសិទ្ធភណ្ឌិកជាប្រយោជន៍ដល់ អ្នកកាន់កាប់ទ្រព្យទាំងនេះបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវបានចាត់បញ្ចូលជាទ្រព្យ សម្បត្តិឯកជនរបស់រដ្ឋតាមរយៈច្បាប់អនុប្រយោគ។

**មាត្រា១៨៖** ត្រូវទុកជាមោឃៈនិងគ្មានអានុភាព ហើយមិនអាចត្រូវបានធ្វើនិយ័តកម្ម ទោះតាមរូបភាពណាក៏ដោយនូវ៖

- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធាណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ និងរាល់ការបំប្លែងការកាន់កាប់ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទៅជាសិទ្ធិកម្មសិទ្ធិ ទោះបីការកាន់កាប់និងការបំប្លែងនេះ កើតឡើងនៅពេលណាក៏ដោយ ដែលមិនសមស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក។
- រាល់ការបំប្លែងទៅជាសិទ្ធិកម្មសិទ្ធិនៃដីសម្បទាន ទោះជាការបំប្លែងនោះកើតឡើងមុនពេលច្បាប់នេះ ចូលជាធរមានក៏ដោយ លើកលែងតែសម្បទានដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គម។
- រាល់សម្បទានមិនស្របនឹងបញ្ញត្តិទាំងឡាយនៃជំពូកទី៥។
- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋ ទោះជាតាមរូបភាពណាក៏ដោយដែលបានកើតឡើងក្រោយច្បាប់នេះចូលជាធរមាន។

**មាត្រា៣០៖** បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈ ដោយសន្តិវិធីនិងមិនមានការជំទាស់ចាប់ពី ៥(ប្រាំ)ឆ្នាំយ៉ាងតិច គិតមកដល់ការបរិច្ឆេទនៃការប្រកាសឲ្យ ប្រើច្បាប់នេះលើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុង ការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិ

ស្ថាពរ។ ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថាខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈ ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥(ប្រាំ) ឆ្នាំនៅលើអចលនវត្ថុដែលមានទំនាស់ ឬយកភស្តុតាង ដែលថាខ្លួនបានទិញ អចលនវត្ថុនោះពីភាគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ឬអ្នកទទួលផ្ទេរកម្មសិទ្ធិពីសន្តតិជនរបស់ខ្លួន។

**<u>មាត្រា៣៣</u>៖** ក្នុងករណីមានការដកហូតអចលនវត្ថុដោយហឹង្សា រឺដោយប្រើអំណាចរំលោភរបស់អាជ្ញាធរ អចលនវត្ថុនោះត្រូវបានបង្វិលមករដ្ឋវិញ ហើយមិនអាចជាកម្មវត្ថុនៃការកាន់កាប់ថ្មីបានឡើយ ប្រសិនបើគ្មានបណ្តឹងទាមទារពីភាគី ស្របច្បាប់នៃអចលនវត្ថុ ដែលត្រូវបានដកហូត។ បណ្តឹងទាមទារនេះមានរយៈពេល ០៣ ឆ្នាំ ចាប់ពីថ្ងៃដែលរដ្ឋប្រកាសដកហូត។

**<u>មាត្រា៣៤</u>៖** អ្នកកាន់កាប់ថ្មីលើអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ ឬរបស់បុគ្គលឯកជនដោយគ្មានប័ណ្ណ ក្រោយច្បាប់នេះចូលជាធរមានត្រូវចាត់ទុកជាអ្នកកាន់កាប់ដោយខុសច្បាប់ ហើយត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ២៥៩ នៃច្បាប់នេះ។

**<u>មាត្រា៣៥</u>៖** មានតែអាជ្ញាធរមានសមត្ថកិច្ចក្នុងនាមរដ្ឋ និងនីតិបុគ្គលសាធារណៈប៉ុណ្ណោះ ដែលអាចឲ្យអ្នកកាន់កាប់អចលនវត្ថុ គ្មានប័ណ្ណ ឬមានប័ណ្ណមិនគ្រប់គ្រាន់ចាកចេញពីទីតាំងអចលនវត្ថុនោះ។ សាមញ្ញជន ឬ អាជ្ញាធរដែលមិនតាងនាម រដ្ឋ ឬនីតិបុគ្គលសាធារណៈគ្មានសមត្ថកិច្ចដេញអ្នកកាន់កាប់ដោយសន្តិភាព មានប័ណ្ណត្រឹមត្រូវដោយប្រើកម្លាំងបានឡើយ។ ការដេញអាចធ្វើបានតាមការបង្គាប់របស់តុលាការ យោងតាមបណ្តឹងរបស់បុគ្គលដែលបានប្តឹងទាមទារទ្រព្យ។ តុលាការត្រូវពិនិត្យបញ្ជាក់រូបភាព ប្រភព កាលបរិច្ឆេទ និងលក្ខខណ្ឌទាំងឡាយនៃប័ណ្ណដែលបានបង្ហាញ។ តុលាការមិនអាចប្រកែកក្នុងការបង្គាប់ឲ្យចាកចេញ ដើម្បីជាប្រយោជន៍ដល់បុគ្គល ដែលបង្ហាញប័ណ្ណត្រឹមត្រូវ និង ពេញលេញរបស់សុវិយោជីបានឡើយ។

**<u>មាត្រា៣៨</u>៖** ក្នុងការរង់ចាំដើម្បីឲ្យបានទៅជាកម្មសិទ្ធិពេញលេញ ភោគៈដែលស្របតាមបញ្ញាតិនៃច្បាប់នេះ បង្កើតបានជាសិទ្ធិភណ្ឌិកលើអចលនវត្ថុ។ ភោគៈនេះអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរផ្ទេរសិទ្ធិ ឬជាកម្មវត្ថុនៃកិច្ចការជំនួយ។

**<u>មាត្រា៤២</u>៖** បុគ្គលទាំងឡាយណាដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួនដោយហេតុមិនបានដឹង ឬដោយធ្វេសប្រហែស អ្នកនោះនៅតែមានសិទ្ធិត្រូវបានការពារតាមអំណាចនៃមាត្រា២៩ មាត្រា៣០ និង មាត្រា ៣១ នៃច្បាប់នេះ។

<u>**មាត្រា៤៦៖**</u>ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចមិនព្រមចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ អ្នកកាន់កាប់អចលនវត្ថុ នោះអាចធ្វើពាក្យប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

<u>**មាត្រា៤៧៖**</u> វិវាទរវាងភាគីចំពោះអចលនវត្ថុមួយ នឹងត្រូវដាក់ឲ្យធ្វើការស៊ើបអង្កេតនិងដោះស្រាយ តាមនីតិវិធីកំណត់។ លទ្ធផលនៃការស៊ើបអង្កេតត្រូវដាក់ជូនគណៈកម្មាការសុរិយោដីដែលបង្កើត ឡើង នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មាការនេះត្រូវធ្វើសេចក្តី សំរេចលើបដិវាទកម្មនោះ។ ក្នុងករណីមិនសុខចិត្ត គូវិវាទអាចប្តឹងទៅតុលាការបាន។ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះដោយអនុក្រឹត្យ។

<u>**មាត្រា៦៦៖**</u> បុគ្គលដែលមានសញ្ជាតិខ្មែរ និងមានសមត្ថភាពចុះកិច្ចសន្យាអាចលក់ ឬទិញទ្រព្យជា អចលនវត្ថុបាន។ បុគ្គលដែលមិនអាចលក់បានគឺ៖

- បុគ្គលដែលមិនមែនជាកម្មសិទ្ធករនៃទ្រព្យដែលត្រូវលក់
- កម្មសិទ្ធករនៃទ្រព្យអវិភាគដោយគ្មានការយល់ព្រមពីកម្មសិទ្ធករអវិភាគផ្សេងទៀត
- បុគ្គលដែលមានអចលនវត្ថុជាកម្មវត្ថុនៃការរឹបអូស។

បុគ្គលដែលមិនអាចទិញបានគឺ ៖

- អាណាព្យាបាលមិនអាចទិញទ្រព្យរបស់បាលិតខ្លួន
- ហិតូបត្ថម្ភកៈមិនអាចទិញទ្រព្យដែលខ្លួនគ្រប់គ្រង
- ចៅក្រម ឬភ្នាក់ងាររដ្ឋបាលមិនអាចទិញទ្រព្យដែលយុត្តាធិការរបស់ខ្លួន ឬដែលខ្លួនមាន បេសកម្មលក់
- បុគ្គលដែលមានទ្រព្យត្រូវរឹបអូសមិនអាចទិញទ្រព្យនោះវិញបានទេ។

<u>**មាត្រា៨៦៖**</u> កម្មសិទ្ធិករនៃទ្រព្យមិនអាចប្រើប្រាស់ទ្រព្យនោះក្នុងគោលដៅព្យាបាទ រំខានដល់តតិយ ជន និងជាពិសេសដល់ អ្នកជិតខាងរបស់ខ្លួនបានឡើយ។ ការប្រើប្រាស់ទ្រព្យជាធម្មតាដែលមាន ចរិកធម្មានុរូបមិនអាចចាត់ទុកជាការរំខាន ដែលបណ្តាលឲ្យរាំងស្ទះដល់ការប្រើប្រាស់ទ្រព្យនោះ បានឡើយ។

<u>**មាត្រា៨៧៖**</u> កម្មសិទ្ធិករនៃដីអាចធ្វើនៅលើដី រាល់ការដាំដុះ ការរៀបចំ និងការសាងសង់តាមបំណង របស់ខ្លួនលើកលែង តែមានច្បាប់ហាមឃាត់។ ការរៀបចំឬការសាងសង់ទាំងនោះជាកម្មសិទ្ធិរបស់ ខ្លួនទាំងអស់ ស្របតាមបញ្ញត្តិនៃ ផ្នែកទី៣នៃជំពូកនេះ។

**<u>មាត្រា១១៤៖</u>** បែបបទសំណង់ និងលក្ខខណ្ឌទាំងឡាយនៃការរៀបចំដែនដី និងនគរោបនីយកម្មចំពោះកម្មសិទ្ធិករ នឹងកំណត់ ដោយអនុក្រឹត្យ។

**<u>មាត្រា១៧៥៖</u>** សហកម្មសិទ្ធិ គឺជាកម្មសិទ្ធិលើទ្រព្យជាអចលនវត្ថុរបស់បុគ្គលច្រើននាក់ បែងចែកតាមឡូត៍ ដែលម្នាក់ៗបានមួយចំណែកជាឯកជន ហើយមួយចំណែកទៀតជាផ្នែកនៃទ្រព្យរួម។

**<u>មាត្រា១៧៦៖</u>** សហកម្មសិទ្ធិករទាំងឡាយ អាចរៀបចំបទបញ្ជាផ្ទៃក្នុងដែលកំណត់របៀបគ្រប់គ្រងនិងវិធានការនៃការថែទាំព្រម ទាំងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករ ជាពិសេសចំពោះផ្នែករួមដោយគោរពតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ។ ក្នុងករណីដែលគ្មានបទបញ្ជាផ្ទៃក្នុងនេះទេសហកម្មសិទ្ធិត្រូវស្ថិតនៅក្រោមបទបញ្ញត្តិទាំងឡាយដែលបានកំណត់ពីមាត្រា ១៧៧ ដល់មាត្រា១៨៥ នៃច្បាប់នេះ។

**<u>មាត្រា១៧៩៖</u>** រាល់ចំណែកនៃអាគារ ឬដីសម្រាប់ការប្រើប្រាស់ ឬជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងឡាយ ឬសហកម្មសិទ្ធិករ ខ្លះក្នុងចំណោមនោះបង្កើតបានជាចំណែករួម។ ទ្រព្យរួមមានជាអាទិ៖

- ដី ទីធ្លា ឧទ្យាន និងសួនច្បារ ផ្លូវ ច្រកចេញចូល
- ជញ្ជាំងសសរទ្រទ្រង់សំខាន់ៗនៃអគារ ឧបករណ៍រួមរាប់បញ្ចូលចំណែកនៃបណ្តាញទឹក ភ្លើង បណ្តាញ ឧស្ម័នដែលអាច ឆ្លងកាត់ចំណែកឯកជន
- ទូរួម បំពង់ និងក្បាលបំពង់ផ្សែង
- ទីកន្លែងនៃសេវារួម។

សិទ្ធិបន្តបន្ទាប់ខាងក្រោមនេះក៏ត្រូវទុកជាកម្មសិទ្ធិរួមដែរ៖

- សិទ្ធិជីករុករកវត្ថុធាតុដែលមានក្នុងដី
- សិទ្ធិស្ថាបនាអគារថ្មីក្នុងទីធ្លា ឧទ្យានឬសួនច្បារដែលជាចំណែករួម
- សិទ្ធិជីករុករកក្នុងទីធ្លា ឧទ្យានឬសួនច្បារទាំងនេះ
- សិទ្ធិនៃអឌ្ឍសិទ្ធិភាពដែលជាប់ទៅនឹងចំណែករួមទាំងឡាយ
- សិទ្ធិលើកបន្តឲ្យខ្ពស់នូវអគារសម្រាប់ប្រើប្រាស់រួម ឬដែលមានកន្លែងច្រើន បង្កើតបានជាចំណែកឯកជនផ្សេងគ្នា។ គ្មានករណីណាមួយដែលកម្មសិទ្ធិករនៃអគារសហកម្មសិទ្ធិជាន់លើបំផុត អាចលើកបន្តសម្រាប់តែខ្លួនឯងផ្ទាល់ ឬលក់សិទ្ធិនៃការលើកនេះឡើយ។
- បទបញ្ញត្តិនេះមានលក្ខណៈជាសណ្តាប់ធ្នាប់សាធារណៈ។

**<u>មាត្រា១៨៤៖</u>** អាជ្ញាធរមានសមត្ថកិច្ច អាចដាក់វិធានការឲ្យសហកម្មសិទ្ធិករ រ៉ាប់រងការថែទាំឲ្យល្អលើចំណែករួម។ សោហ៊ុយនៃការថែទាំជាបន្ទុកនៃសហកម្មសិទ្ធករ ដោយគិតតាមសមាមាត្រទៅនឹង

តំលៃនៃចំណែករៀងៗខ្លួន។ សហកម្មសិទ្ធិករដែលមិនព្រមរួមទទួលបន្ទុកនេះ ឬមិនគោរពតាមលក្ខខណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈ ត្រូវទទួលទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា២៥៨ នៃច្បាប់នេះ។

**មាត្រា២៤៨៖** ត្រូវចាត់ទុកជាការប៉ះពាល់កម្មសិទ្ធិ និងសិទ្ធិស្របច្បាប់ផ្សេងៗទៀតលើអចលនវត្ថុជាបទល្មើសព្រហ្មទណ្ឌក្នុងន័យ នៃច្បាប់នេះមាន៖

- រាល់អំពើប្រព្រឹត្តដោយជាក់ស្តែង រំលោភកាន់កាប់អចលនវត្ថុដោយចេតនា ដោយមិនទទួលស្គាល់ប័ណ្ណចេញដោយរដ្ឋបាលសុរិយោដី។
- រាល់អំពើប្រព្រឹត្តដោយជាក់ស្តែង រារាំងអ្នកកាន់កាប់ដោយសន្តិភាព ឬភាគីនៃទ្រព្យមួយនៅក្នុងតំបន់ មិនទាន់មានប្លង់សុរិយោដី ដែលរបបកម្មសិទ្ធិមិនទាន់បានពង្រឹងជាស្ថាពរ តាមបញ្ញត្តិនៃច្បាប់នេះ។
- រាល់ការចូលកាន់កាប់មិនត្រឹមត្រូវតាមច្បាប់ ឬមិនប្រក្រតីលើអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលមិនស្របតាមមាត្រា ១៧ មាត្រា១៨ និងមាត្រា១៩ នៃច្បាប់នេះ។
- រាល់ការបំប្លែងពីសម្បទានមកជាកម្មសិទ្ធិ លើកលែងសម្បទានឆ្លើយតបទៅនឹងប្រយោជន៍សង្គម។

**មាត្រា២៤៩៖** ការប៉ះពាល់កម្មសិទ្ធិក្នុងន័យនៃមាត្រាខាងលើ អាចជាទង្វើរបស់អាជ្ញាធរមានសមត្ថកិច្ច ឬទង្វើរបស់សាមញ្ញជន ដែលធ្វើដោយម្នាក់ឯង ឬដោយឃុបឃិតជាមួយភ្នាក់ងាររបស់អាជ្ញាធរ។

**មាត្រា២៥០៖** មន្ត្រី ឬអាជ្ញាធរមានសមត្ថកិច្ច ដែលបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិស្របច្បាប់លើអចលនវត្ថុត្រូវទទួលទោសរដ្ឋបាល បន្ថែមលើទោសព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី។

**មាត្រា២៥១៖** ជនណាដែលបានក្លែងប័ណ្ណក្នុងគោលបំណងយកទៅប្រើប្រាស់ជាផ្លូវការ ទោះជាក្នុងរូបភាពអ្វីក៏ដោយ ត្រូវផ្តន្ទាទោសដាក់ព័ន្ធនាគារពី ០១ (មួយ) ឆ្នាំ ដល់ ០៥ (ប្រាំ) ឆ្នាំ។

**មាត្រា២៥៣៖** ជនណាដែលប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ទោះជាមិនទាន់ធ្វើប័ណ្ណ ឬកំពុងមានទំនាស់ក៏ដោយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ១.៥០០.០០០ (មួយលានប្រាំសែន) រៀលដល់ ២៥.០០០.០០០ (ម្ភៃប្រាំលាន)រៀល ឬដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ដល់២ (ពីរ) ឆ្នាំដោយពុំទាន់គិតបញ្ចូលនូវទោស ប្រព្រឹត្តអំពើហិង្សាប្រឆាំងនិងមនុស្ស។ បន្ថែមលើទោសខាងលើ អ្នកប្រព្រឹត្តអំពើហឹង្សាត្រូវទទួលខុសត្រូវចំពោះ សំណងរដ្ឋប្បវេណីដល់ជនរងគ្រោះដែលបណ្តាលមកពីអំពើហិង្សារបស់ខ្លួន។ បើអំពើហិង្សាខាងលើត្រូវបញ្ជាពីជនដទៃទៀតក្រៅ

ពីអ្នកបង្ក ហើយជននោះមិនបានចូលរួមផ្ទាល់ក្តី អ្នកបញ្ជានោះក៏ត្រូវទទួលការផ្តន្ទាទោសដូច អ្នកប្រព្រឹត្តអំពើហិង្សាផ្ទាល់ដែរ។

**មាត្រា២៥៨៖** សហកម្មសិទ្ធិករ ដែលមិនព្រមចូលរួមទទួលបន្ទុកថែទាំចំណែករួម នៃសហកម្មសិទ្ធិខ្លួន ឬ មិនគោរពតាមលក្ខខណ្ឌ នៃសណ្តាប់ធ្នាប់សាធារណៈដូចមានចែងនៅក្នុងមាត្រា១៨៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន)ដល់ ៣.០០០.០០០ (បីលាន)រៀល។

**មាត្រា២៦១៖** មន្ត្រីឬអាជ្ញាធរដែលបានប្រើអំណាចដោយរំលោភ ទោះមានបញ្ជាក្តីឬគ្មានបញ្ជាក្តីដើម្បីដកហូតអចលនវត្ថុពី អ្នកកាន់កាប់ដោយសន្តិភាព ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០.០០០.០០០ (ដប់លាន)រៀល ដល់ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត។ ចាត់ទុកជាការរំលោភ មានការក្លែងបន្លំ ការកសាងប័ណ្ណដោយបំពានការរៀបសង្កត់ ឬវិធានការសម្ពារៈ ដើម្បីបណ្តេញចេញធ្វើឡើង ចំពោះអ្នកកាន់កាប់អចលនវត្ថុ។ បើការដកហូតអចលនវត្ថុបានប្រព្រឹត្តទៅដោយអំពើហិង្សាចារីត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់២ (ពីរ) ឆ្នាំថែមទៀត។ អ្នកបញ្ជាដោយរំលោភត្រូវផ្តន្ទាទោសដូចគ្នានឹង អ្នកប្រព្រឹត្តផ្ទាល់ដែរ។

**មាត្រា២៦៣៖** អាជ្ញាធរមានសមត្ថកិច្ចដែលព្រងើយកន្តើយ ឬបណ្តោយឲ្យសាមញ្ញជនប្រព្រឹត្តដោយរំលោភសិទ្ធិរបស់កម្មសិទ្ធិកររបស់ភាគី ឬរបស់អ្នកកាន់កាប់ដោយសន្តិភាពត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១,០០០,០០០(មួយលាន)រៀលដល់ ១០,០០០,០០០(ដប់លាន)រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត។

## ៣.៦ ច្បាប់ការងារ (ឆ្នាំ២០០១)

ច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលមានន័យសេចក្តីពាក់ព័ន្ធទៅនឹងគម្រោងមានបង្ហាញដូចខាងក្រោម៖

**មាត្រា១៖** ច្បាប់នេះគ្រប់គ្រងរាល់ទំនាក់ទំនង ដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជកនិងកម្មករនិយោជិត ដើម្បីយកមកអនុវត្តលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីកិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ដោយ ទោះមានសញ្ជាតិជាអ្វីហើយស្នាក់នៅទីណាក៏ដោយ។ ច្បាប់នេះអនុវត្តចំពោះសហគ្រាស ឬគ្រឹះស្ថានឧស្សាហកម្មរ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវាកម្មដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹកទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅ

សាសនា ឬក្នុងសាសនាក៏ដោយ ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬជាការកុសលក៏ដោយ ព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគម ឬក្រុមប្រភេទណាក៏ដោយ។

**មាត្រា៣៖** កម្មករនិយោជិកតាមន័យនៃច្បាប់នេះគឺ ជនគ្រប់ប្រភេទ និងគ្រប់សញ្ជាតិដែលបានចុះកិច្ចសន្យាធ្វើការយកកំរៃ ក្រោមការដឹកនាំ និងគ្រប់គ្រងរបស់បុគ្គលម្នាក់ទៀតជារូបវន្តបុគ្គល ឬនីតិបុគ្គល ជាសាធារណៈ ឬឯកជន។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីលក្ខន្តិកៈ គតិយុត្តិនៃកម្មករនិយោជិកព្រមទាំងមិនត្រូវ គិតពីចំនួនប្រាក់ឈ្នួលតិច ឬច្រើនទេ។

**មាត្រា៤៖** និយោជិក ឬអ្នកជួយ គឺជនដែលមានកិច្ចសន្យាជួយធ្វើការបុគ្គលណាម្នាក់ដោយយកកំរៃ ប៉ុន្តែគ្មានធ្វើហត្ថកម្មពេញទី ឬក៏គ្រាន់តែជួយធ្វើហត្ថកម្មជាបន្ទាប់បន្សំប៉ុណ្ណោះ។

**មាត្រា៦៖** កម្មករ គឺជាអ្នកធ្វើការយកឈ្នួល ក្រៅពីអ្នកបំរើនៅក្នុងផ្ទះ និងនិយោជិក ពោលគឺជនដែលធ្វើការភាគច្រើន ខាងហត្ថកម្មយកកំរៃក្រោមការដឹកនាំនៃនិយោគជក ឬតំណាងនៃជននេះ។

**មាត្រា ១១៖** តាមរបៀបបើកប្រាក់ឈ្នួល កម្មករនិយោជិកត្រូវបែងចែកដូចតទៅនេះ៖

- កម្មករនិយោជិក ធ្វើការយកប្រាក់ឈ្នួលតាមពេល "ប្រចាំខែ ប្រចាំថ្ងៃ ប្រចាំម៉ោង" ដែលគេត្រូវ បើកប្រាក់ឈ្នួលឲ្យរាល់ថ្ងៃ ឬរាប់ពេលមិនហួសពីដប់ថ្ងៃ ឬមួយខែ
- កម្មករនិយោជិក ធ្វើការយកប្រាក់ឈ្នួលតាមបរិមាណផលិតផល ឬម៉ៅការ
- កម្មករនិយោជិក ធ្វើការយកកំរៃជើងសា។

**មាត្រា១៤៖** និយោជកត្រូវតែមានច្បាប់ការងារយ៉ាងហោចណាស់ មួយច្បាប់សម្រាប់សេចក្តីត្រូវការនៃកម្មករនិយោជិករបស់ខ្លួន ហើយជាពិសេសសម្រាប់តំណាងនៃកម្មករនិយោជិក នៅគ្រប់សហគ្រាសគ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់នេះ។

**មាត្រា១៥៖** ការងារដោយបង្ខំ ឬជាកាតព្វកិច្ច ត្រូវហាមឃាត់ជាដាច់ខាត ដោយអនុលោមតាមអនុសញ្ញាលេខ២៩ ស្តីពី ការងារដោយបង្ខំ ឬដោយកាតព្វកិច្ច អនុម័តនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៣០ ដោយអង្គការការងារអន្តរជាតិ ហើយព្រះរាជាណាចក្រកម្ពុជា បានឲ្យសច្ចាប័ននៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩។ មាត្រានេះត្រូវអនុវត្តលើបុគ្គលទាំងអស់ គិតទាំងអ្នកបំរើក្នុងផ្ទះហើយនិងកម្មករនិយោជិកក្នុងសហគ្រាស កសិដ្ឋានទាំងឡាយ។

**មាត្រា១៦៖** ការជួលមនុស្សឲ្យធ្វើការងារ ដើម្បីកាត់ជំពាក់ត្រូវហាមឃាត់។

**មាត្រា១៧៖** និយោជកទាំងអស់ដែលត្រូវអនុវត្តច្បាប់ការងារនេះ ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារ នៅពេលបើកសហគ្រាសគ្រឹះស្ថាន។ សេចក្តីប្រកាសជូនដំណឹង

នេះហៅថា សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថាន ដែលត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងដាក់ជូនក្រសួងទទួលបន្ទុកវិស័យការងារ នៅមុនពេលបើកសហគ្រាសគ្រឹះស្ថានជាស្ថាពរ។

**មាត្រា១៨៖** ចំពោះការបិទសហគ្រាស និយោជកក៏ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យការងារដែរ ក្នុងរយៈពេលសាមសិបថ្ងៃ បន្ទាប់ពីថ្ងៃបិទសហគ្រាសនោះ។

**មាត្រា១៩៖** ប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ កំណត់អំពីបែបបទ និងនីតិវិធីនៃការធ្វើសេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាសតាមករណីនីមួយៗ។

**មាត្រា២១៖** នៅរាល់ពេលដែលទទួលឲ្យធ្វើការ ឬបញ្ឈប់កម្មករនិយោជិកណាម្នាក់ និយោជកត្រូវធ្វើសេចក្តីប្រកាសជូនដំណឹង ទៅក្រសួងទទួលបន្ទុកវិស័យការងារ។ សេចក្តីប្រកាសជូនដំណឹងនេះត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលដប់ប្រាំថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលឲ្យធ្វើការ ឬបញ្ឈប់ឲ្យធ្វើការ។

**មាត្រា២២៖** និយោជកនៃសហគ្រាស ឬគ្រឹះស្ថានដែលមានចែងក្នុងមាត្រា ១៧ ខាងលើនេះ ហើយដែលមានកម្មករនិយោជិក យ៉ាងតិចប្រាំបីនាក់ត្រូវតែរៀបចំឲ្យមានបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសមួយជាដរាប។

**មាត្រា៣២៖** ជនដែលមានសញ្ជាតិខ្មែរ ធ្វើការយកឈ្នួលពីនិយោជកណាមួយត្រូវតែមានសៀវភៅការងារ។ ជនណាក៏ដោយ មិនអាចប្រើកម្មករនិយោជិក ដែលមិនប្រតិបត្តិតាមបទបញ្ញត្តិ នៃកថាខ័ណ្ឌខាងលើនេះបានទេ។

**មាត្រា៣៩៖** និយោជកដែលមានរៀបរាប់ក្នុងមាត្រា ១៧ខាងលើ ត្រូវប្រកាន់ដោយទៀងទាត់ដរាបនូវសៀវភៅបើកប្រាក់មួយ ដែលមានគំរូ និងកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ។ មុននឹងយកទៅប្រើសៀវភៅបើកប្រាក់ ត្រូវមានចុះលេខគ្រប់ទំព័រ និងចុះហត្ថលេខាសង្ខេបដោយអធិការការងារ។ សៀវភៅបើកប្រាក់នេះត្រូវទុកនៅ ក្នុងការិយាល័យបេឡា ឬទីចាត់ការនៃសហគ្រាស ដើម្បីនឹងបានងាយស្រួលក្នុងការត្រួតពិនិត្យ។ កាលណាប្រើសៀវភៅ នេះទំព័រទាំងអស់ និយោជកត្រូវទុកឲ្យគង់ក្នុងរយៈពេល៣ឆ្នាំ។ អធិការការងារអាចទាររកសៀវភៅនេះនៅគ្រប់ពេលវេលា។

**មាត្រា៤១៖** សហគ្រាសណាដែលចង់ធ្វើសៀវភៅបើកប្រាក់តាមរបៀបផ្សេងពីនេះ ប៉ុន្តែមានការចុះព័ត៌មាន និងបែបត្រួតពិនិត្យដូចគ្នា នោះអាចធ្វើពាក្យសុំទៅអធិការដ្ឋានការងារបាន។

**មាត្រា៦៥៖** កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឲ្យមានការទាក់ទងផ្នែកការងាររវាងកម្មករ និយោជិក និងនិយោជក។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទំរង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា។

**មាត្រា១៣៧៖** ក្នុងគ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីជាគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសល ព្រមទាំងនៅក្នុងវិជ្ជាជីវៈសេរីក៏ដោយ ថេរវេលាធ្វើការពេញលេញនៃកម្មករនិយោជិកទាំងពីរភេទ មិនត្រូវឲ្យលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោងក្នុងមួយអាទិត្យឡើយ។

**មាត្រា១៧២៖** និយោជក និងនាយកគ្រឹះស្ថានដែលមានប្រើកម្មករជាក្មេង ឬកូនជាងអាយុតិចជាង ១៨ ឆ្នាំ ឬស្ត្រីឲ្យធ្វើការក្នុង នោះត្រូវមើលឲ្យមានកិរិយាមារយាទល្អ ហើយនិងរក្សាការសមរម្យចំពោះសាធារណៈជនផង។ ត្រូវហាមឃាត់ យ៉ាងតឹងរឹងចំពោះការរំលោភខាងផ្លូវភេទគ្រប់ទ្រង់ទ្រាយទាំងអស់។

**មាត្រា១៨២៖** ក្នុងសហគ្រាសទាំងអស់ដែលមានរាប់ក្នុងមាត្រា១ នៃច្បាប់នេះ ស្ត្រីទាំងឡាយត្រូវមានសិទ្ធិឈប់សំរាកកៅសិបថ្ងៃដើម្បីសំរាលកូន។ ក្រោយពីឈប់សំរាលកូនមកក្នុងរយៈពេលពីរខែដែលបានចូលធ្វើការត្រូវឲ្យស្ត្រីនោះធ្វើ ការងារណាស្រាលៗ។ ត្រូវហាមឃាត់មិនឲ្យនិយោជកបញ្ឈប់ស្ត្រីសំរាលកូននៅពេលឈប់ឆ្លងទន្លេ ឬនៅថ្ងៃណា មួយក្នុងពេលសំរាលកូននេះ ទោះដោយវិធីឲ្យដំណឹងមុនក៏ដោយ។

**មាត្រា២២៩៖** គ្រប់គ្រឹះស្ថាន និងទីកន្លែងធ្វើការត្រូវរក្សាឲ្យបានស្អាត ហើយបង្ហាញថាមានល័ក្ខខ័ណ្ឌអនាម័យ និងសភាពសុខសប្បាយជានិច្ច ឬជាទូទៅត្រូវឲ្យមានល័ក្ខខ័ណ្ឌការងារចាំបាច់សម្រាប់សុខភាពរបស់កម្មករនិយោជិក។

**មាត្រា២៤៨៖** ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលដែលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសមកពីកម្មករនិយោជិកឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករ និយោជិកក្នុងពេលធ្វើការឲ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វីនៅទីកន្លែងណាក៏ដោយ។ ម៉្យាងវិញទៀត ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែល ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករ និយោជិកក្នុងពេលដែលសាម៉ីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានទៅកន្លែងផ្សេង ជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតំរូវឲ្យទៅ។

**មាត្រា២៨៣៖** ក្នុងករណីដែលមានគ្រោះថ្នាក់ដល់ស្លាប់ ឬគ្រោះថ្នាក់ដែលបណ្តាលឲ្យបាត់បង់សមត្ថភាពពលកម្ម ជាអចិន្ត្រៃយ៍ ប្រាក់បំណាច់ត្រូវបើកឲ្យជនរងគ្រោះ ឬអ្នកសិទ្ធិវន្តជាធនលាភ។ ត្រូវឲ្យប្រាក់បំណាច់បន្ថែមដល់អ្នករងគ្រោះណា ដែលតំរូវឲ្យមានមនុស្សដទៃម្នាក់នៅថែទាំខ្លួនជានិច្ច។

**មាត្រា២៨៤៖** អ្នករងគ្រោះថ្នាក់ការងារត្រូវមានសិទ្ធិទទួលការពិនិត្យជំងឺ (ការផ្តល់ជាវត្ថុ ការព្យាបាលជំងឺ និងការផ្តល់ថ្នាំព្រមទាំងកន្លែងសំរាកព្យាបាលជាដើម) និងការព្យាបាលខាងវះកាត់ និងផ្តល់បន្ថែមវត្ថុណាដែលចាំបាច់បន្ទាប់ពីគ្រោះថ្នាក់ទាំងនោះ។

**មាត្រា៣៨៥៖** អ្នកប្រព្រឹត្តល្មើស នឹងបទបញ្ញាតិនៃមាត្រាទាំងឡាយដូចមានចែងក្នុងជំពូក១៦ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យ ជាប្រាក់ ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬក៏ត្រូវទទួលទោសទាំងពីរ។ ការពិន័យជាប្រាក់ត្រូវដាក់បង្ខំដោយអធិការការងារ ឬអភិបាលការងារ។

## ៣.៧ ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**មាត្រា១៖** ច្បាប់ស្តីពីការរៀបចំដែនដី នគរោបនីយកម្ម និងសំណង់ មានកម្មវត្ថុជំរុញឲ្យមានការរៀបចំកែលំអទីក្រុង និងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍន៍សុខដុមនៃប្រទេសក្នុងស្មារតី៖

- គោរពប្រយោជន៍រួម និងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបទបញ្ញាច្បាប់ផង និងត្រួតពិនិត្យការសាងសង់ផង។
- ធានាការអភិវឌ្ឍន៍សំដៅរកលំនឹងរវាងទីក្រុង និងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រ និងលក្ខណៈពិសេសនៃជនបទនីមួយៗ។
- ធានាលើតំលៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ និងធានាការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍ និងរក្សាបាននូវគុណភាពបរិស្ថាន។

**មាត្រា២៖** ច្បាប់រៀបចំទឹកដី នគរោបនីយកម្ម និងសំណង់នេះ ត្រូវសំអាងទៅលើកម្មសិទ្ធិដែលអនុលោមទៅតាមច្បាប់ភូមិបាលបច្ចុប្បន្ន។ ក្នុងករណីដែលច្បាប់ភូមិបាលត្រូវកែប្រែ ឬផ្លាស់ប្តូរច្បាប់ស្តីពីការរៀបចំទឹកដី នគរោបនីយកម្ម និងសំណង់ នឹងត្រូវកែច្នៃឲ្យស្របទៅតាមច្បាប់ភូមិបាលនេះដែរ។

**មាត្រា៣៖** ដើម្បីសំរេចនូវបំណងដែលបានចែងខាងលើនេះ ត្រូវបង្កើតឲ្យមានគណៈកម្មាធិការជាតិរៀបចំដែនដី នគរោបនីយកម្ម និងសំណង់ដែលមានសមាជិក និងសំណើរការតែងតាំងនឹងរៀបចំដោយអនុក្រឹត្យ។ ចំពោះរាជធានីភ្នំពេញ គណៈកម្មាធិការរៀបចំទឹកដី នគរោនីយកម្ម និងសំណង់

ហើយដែលមានប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ ឬអភិបាល អភិបាលរង ព្រមទាំងអង្គភាពបច្ចេកទេស ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផងដែរ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការនៃគណៈកម្មាធិការរៀបចំដែនដី នគរោបនីយកម្ម និងសំណង់ សម្រាប់ក្រុងភ្នំពេញត្រូវកម្រិតដោយអនុក្រឹត្យ។

**មាត្រា៤៖** ឯកសារទាំងឡាយដែលទាក់ទងនឹងការរៀបចំទឹកដី នគរោបនីយកម្ម និងសំណង់ ត្រូវរៀបចំទឹកដីនគរោបនីយកម្ម និងសំណង់ត្រូវរៀបចំតាមករណីនីមួយៗឲ្យសមស្របទៅតាមស្ថានភាពលក្ខណៈពិសេសនៃទឹកដីខេត្ត-ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ ដល់បរិស្ថានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច។

**មាត្រា៥៖** គណៈកម្មាធិការរៀបចំដែនដី នគរោបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរោបនីយកម្ម សំណង់ខេត្ត-ក្រុងនីមួយៗ ត្រូវគូសប្លង់គោលដើម្បីរៀបចំ និងអភិវឌ្ឍន៍រាជធានី ខេត្ត-ក្រុងរបស់ខ្លួន។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរោបនីយកម្ម និងសំណង់ នឹងកំណត់ដោយអនុក្រឹត្យ។ ដើម្បីការពារនូវបេតិកភណ្ឌការពារបរិស្ថាន និងដើម្បីធានាអភិវឌ្ឍសេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយ ដែល គណៈរដ្ឋមន្ត្រីបានកំណត់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរោបនីយកម្ម និងសំណង់ មានភារកិច្ចរៀបចំប្លង់ គោលសម្រាប់តំបន់ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត។

**មាត្រា៦៖** ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវរៀបចំឡើងសម្រាប់រាជធានី ខេត្ត ក្រុង។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន។

**មាត្រា៧៖** ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់ អំពីតំបន់ដែលត្រូវប្រើប្រាស់សម្រាប់ការពារជាតិ សម្រាប់កសិកម្ម សម្រាប់ពាណិជ្ជកម្ម សម្រាប់ឧស្សាហកម្មសម្រាប់សិប្បកម្ម សម្រាប់វប្បធម៌ សម្រាប់ទេសចរណ៍ សម្រាប់សាសនា ព្រមទាំងសម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខារសាធារណៈ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាព សម្រាប់សាងសង់។

**មាត្រា៨៖** ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវគោរពតាមប្លង់គោល ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ។

**មាត្រា៩៖** ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់សម្រាប់រាជធានី និងខេត្ត ក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត ក្រុងរួចត្រូវមានការយល់ព្រមពីគណៈកម្មាធិកាជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ទៀត។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈទាំងពួងផង។

**មាត្រា១០៖** រាជរដ្ឋាភិបាលរៀបចំបទបញ្ញត្តិពិសេស និងសេវាភាពនគរូបនីយកម្មដើម្បីការពារ និងលើកតំលៃរមណីយដ្ឋាន ឬអចលនវត្ថុណាដែលនឹងផ្តល់នូវអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព ឬបច្ចេកទេស។ បញ្ជីអចលនវត្ថុ ឬរមណីយដ្ឋានទាំងនោះ នឹងកំណត់ដោយអនុក្រឹត្យ។ ការរុះរើការផ្លាស់ប្តូរទ្រទ្រង់ និងការគ្រប់គ្រងអចលនវត្ថុ និងរមណីយដ្ឋានទាំងនោះ ត្រូវកំណត់ដោយច្បាប់ស្តីពីការការពារបេតិកភណ្ឌ។

បទបញ្ញត្តិពិសេស និងសេវាភាពនគរូបនីយកម្ម ដើម្បីការពារនិងលើកតំលៃរមណីយដ្ឋាន ឬអចលនវត្ថុ ដែលផ្តល់ប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព ឬបច្ចេកទេសត្រូវចារឹកក្នុងប្លង់គោលរៀបចំទឹកដី នគរូបនីយកម្ម និងអភិវឌ្ឍន៍នឹងចារឹកក្នុងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់។

**មាត្រា១១៖** រាល់ការកកាយរុករក ឬការស្ទង់ដែលមានការប៉ះពាល់ដល់ខាងផ្នែកបុរាណវិទ្យាចាំបាច់ត្រូវការអនុញ្ញាតពីរាជរដ្ឋាភិបាល។ រាល់ការសាងសង់ ក្នុងករណីជួបប្រទះនូវវត្ថុអ្វីមួយដែលមានអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ឬ ប្រវត្តិសាស្ត្រ អ្នកទទួលខុសត្រូវការដ្ឋាន ត្រូវមានកាតព្វកិច្ចរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចឲ្យបានជ្រាបភ្លាមៗ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ឈប់សំណង់ជាបន្ទាន់។

**មាត្រា១២៖** រាល់បុគ្គល ឬស្ថាប័នឯកជនក៏ដូចជាអាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនឲ្យសាងសង់លើទីធ្លា ដែលមានលក្ខណៈជាសាធារណៈដូចតទៅ៖

- ទីបំរុងទុកទឹក និងទំនប់ទឹក
- ទីបំរុងជីករ៉ែ និងតំបន់ព្រៃឈើ
- រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រ
- សួនច្បារ ឧទ្យានសាធារណៈ និងតំបន់អភិវឌ្ឍន៍
- ដីបំរុងទុកសម្រាប់ផ្លូវ បំរុងសម្រាប់ចំណីផ្លូវ និងដីបំរុងទុកសម្រាប់ផ្លូវរថភ្លើង និងអាកាសយានដ្ឋាន
- ទន្លេ សមុទ្រ ព្រែក ស្ទឹង ព្រមទាំងឆ្នេរ ច្រាំង
- ជាទូទៅនៅលើដីទាំងឡាយណាដែលបញ្ញត្តិច្បាប់កំណត់មិនឲ្យសង់។

លក្ខខណ្ឌនៃការគ្រប់គ្រងតំបន់ទាំងនោះ លក្ខខ័ណ្ឌសំណង់ទីតាំងលំនៅធុនស្រាលបណ្តោះអាសន្នអនុញ្ញាតបានដោយអនុក្រឹត្យ។

**<u>មាត្រា១៣៖</u>** ការងារសាងសង់ និងការតាំងទីត្រូវធ្វើឡើងដោយគោរពតាមឯកសារ ដែលទាក់ទងនិងការរៀបចំទឹកដី នគរោបនីយកម្ម និងសំណង់ គោរពតាមប្លង់គោល ដែលមានចែងក្នុងមាត្រា៤ និង៥នៃច្បាប់នេះ។

**<u>មាត្រា១៤៖</u>** រាល់ការសាងសង់ រាល់ការកែប្រែទិដ្ឋភាព ឬកែប្រែការប្រើប្រាស់ណាមួយ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

ពាក្យស្នើសុំអនុញ្ញាតសាងសង់ត្រូបមានឯកសារ និងប្លង់ចាំបាច់។ នីតិវិធីក្នុងការអនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**<u>មាត្រា១៥៖</u>** ឯកសារ និងប្លង់ចាំបាច់សម្រាប់ភ្ជាប់ពាក្យសុំអនុញ្ញាតសាងសង់ធំៗ ត្រូវរៀបចំឡើងដោយស្ថាបត្យករខ្មែរ មានសញ្ញាប័ត្រ ឬជនណាដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច។

លក្ខខ័ណ្ឌដែលទាមទារអំពីសញ្ញប័ត្រ និងទាមទារការទទួលស្គាល់ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**<u>មាត្រា១៦៖</u>** ពាក្យសុំអនុញ្ញាតសាងសង់ ត្រូវយកមកដាក់សុំដោយម្ចាស់កម្មសិទ្ធិដី ឬអ្នកទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ។ ពាក្យសុំអនុញ្ញាតនេះត្រូវមានភ្ជាប់មកជាមួយផង នូវឯកសារបញ្ជាក់ពីកម្មសិទ្ធិរបស់ម្ចាស់ដី។

**<u>មាត្រា១៧៖</u>** មិនអនុញ្ញាតឲ្យសាងសង់នូវសំណង់ ក្នុងលក្ខណៈដែលមិនសមស្របនឹងប្លង់គោលឬប្លង់ប្រើប្រាស់ដីធ្លី និងសំណង់។ មិនអនុញ្ញាតឲ្យសាងសង់ បើគម្រោងសាងសង់នោះមានការប៉ះពាល់ដល់សន្តិសុខសាធារណៈ ប៉ះពាល់ដល់បរិស្ថាន ប៉ះពាល់ដល់អនាម័យសាធារណៈសំណង់ ឬអចលនវត្ថុដែលមានសារប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិ-សាស្ត្រ វប្បធម៌ សោភណ្ឌភាព បច្ចេកទេស ឬប៉ះពាល់ដល់តំបន់ដែលមានធនធានធម្មជាតិ។ មិនអនុញ្ញាតឲ្យ សាងសង់ បើសិនជាពុំមានការរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធ ឬបរិក្ខារសាធារណៈឲ្យបានគ្រប់គ្រាន់ និងគម្រោងសំណង់ដែលសុំ។

**<u>មាត្រា១៨៖</u>** ក្នុងករណីពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ អាជ្ញាធរខេត្ត ក្រុង ត្រូវបង្កើតគណៈកម្មាធិការ ដើម្បីពិនិត្យពាក្យសុំ និងចេញលិខិតអនុញ្ញាសាងសង់។

**<u>មាត្រា១៩៖</u>** ចំពោះគម្រោងសំណង់រដ្ឋបាល អង្គភាពដែលស្នើសុំសាងសង់ ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច។ ការអនុញ្ញាតនោះអាចផ្តល់បានតែចំពោះសំណង់ណា ដែលមានលក្ខណៈចាំបាច់សម្រាប់សំណើរការផ្នែករដ្ឋបាល។ ការអនុញ្ញាតនេះមិនអាចនាំឲ្យមានការផ្លាស់ប្តូរ

នូវការប្រើប្រាស់ដីធ្លីដែលបានកំណត់មកហើយ ហើយក៏មិនអាចកែប្រែនូវលក្ខណៈសាធារណៈ និងអត្ថប្រយោជន៍ទូទៅនៃតំបន់នេះឡើយ។

**មាត្រា២០៖** សំណង់ទាំងឡាយណា ដែលអ្នកវិនិយោគទុនឯកជន បានសាងសង់នៅលើដីរបស់រដ្ឋស្របតាមកិច្ចសន្យាណាមួយ ត្រូវប្រគល់មកឲ្យរដ្ឋវិញពេលផុតកំណត់ចែងក្នុងកិច្ចសន្យានោះ។

**មាត្រា២១៖** បើគ្មានមូលហេតុត្រឹមត្រូវ ដែលបានបញ្ជាក់ក្នុងច្បាប់នេះ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យពាក្យសុំសាងសង់ ឬចេញលិខិតអនុញ្ញាតសាងសង់ ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ ៤៥ថ្ងៃទេនោះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់។

ក៏ត្រូវផ្តន្ទាទោសផងដែរ ចំពោះភ្នាក់ងារណាដែលបានពិនិត្យគម្រោងសាងសង់ និងចេញលិខិតអនុញ្ញាតសាងសង់ ដែលមិនស្របនិងបទបញ្ញត្តិ។

ភ្នាក់ងារត្រួតពិនិត្យលើសំណង់ដែលពុំបានជំទាស់ ពេលដែលខ្លួនឃើញសំណង់លើការដ្ឋានណាមួយ មិនគោរពតាមគម្រោងដែលអនុញ្ញាត ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់។

ទណ្ឌកម្មផ្នែករដ្ឋបាលដែលត្រូវយកមកអនុវត្តចំពោះភ្នាក់ងារ ដែលមានកំហុស ដូចបានរៀបរាប់ខាងលើនេះ ត្រូវកំណត់ដោយច្បាប់រដ្ឋបាល។

ចំណែកឯអ្នកសាងសាង់ដែលមិនគោរពលិខិតអនុញ្ញាតសាងសង់ទេនោះ នឹងត្រូវទទួលបង្គាប់ឲ្យរុះរើកែសំណង់ឲ្យស្រប តាមលិខិត អនុញ្ញាតសាងសង់ក្នុងរយៈពេល៣០ថ្ងៃយ៉ាងយូរ គឺចាប់ពីថ្ងៃទទួលលិខិតបញ្ជាផ្លូវការ។

មន្ត្រីរាជការណាដែលរួមគំនិត នឹងត្រូវដាក់បទចោទប្រកាន់ចំពោះមុខតុលាការ។

នៅពេលពិនិត្យឃើញមានសំណង់ខុសឆ្គង ការដ្ឋានត្រូវបញ្ឈប់ ហើយជាយថាហេតុ សម្ភារៈនិងឧបករណ៍សំណង់នៅទីនោះត្រូវទទួលរឹបអូសតាមបង្គាប់តុលាការ។ ក្នុងករណីដែលអ្នកសាងសង់ទទួលរងគ្រោះដោយមិនមែនជាកំហុសរបស់ខ្លួន អ្នករងគ្រោះអាចប្រើសិទ្ធរបស់ខ្លួនដើម្បីប្តឹងទៅតុលារទាជំងឺចិត្ត។

**មាត្រា២២៖** ម្ចាស់សំណង់មុនពេលវាយកំទេចសំណង់របស់ខ្លួនដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាត រុះរើពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន។ បែបបទនៃការរុះរើវាយកំទេចសំណង់អាចត្រូវបដិសេធបានក្នុងលក្ខណៈដែលការរុះរើ វាយកំទេចសំណង់នោះមាន ទាក់ទងបញ្ហាសង្គមកិច្ច បច្ចេកទេស និងបេតិកភណ្ឌដែលរដ្ឋបានកត់ត្រា។

**មាត្រា២៣៖** បទបញ្ញត្តិទាំងឡាយណា ដែលមាននៅក្នុងច្បាប់ពីមុន ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

## ៣.៨ ច្បាប់ស្តីពីទេសចរណ៍ (ឆ្នាំ ២០០៩)

ច្បាប់ស្តីពីទេសចរណ៍ ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៤ ដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីដូចតទៅ៖

<u>មាត្រា១៖</u> ច្បាប់នេះមានគោលដៅកំណត់វិធាន និងយន្តការសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍នៃព្រះរាជាណាក្រកម្ពុជា។

<u>មាត្រា២៖</u> ច្បាប់នេះមានគោលបំណងដូចតទៅ៖

- គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ
- រួមចំណែកការពារ និងថែរក្សាធនធានធម្មជាតិ វប្បធម៌ និងទំនៀមទំលាប់ដែលជាមូលដ្ឋានបម្រើឲ្យវិស័យទេសចរណ៍
- ធានា និងលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតប្រព័ន្ធធានាគុណភាពដោយផ្តល់សន្តិសុខ សុវត្ថិភាព ផាសុកភាព និងបង្កើនការពេញចិត្តដល់ទេសចរ
- ទាញយកផលប្រយោជន៍ក្នុងវិស័យទេសចរណ៍ ឲ្យបានជាអតិបរមា ធានាការបែងចែកប្រកបដោយសមធម៌ និងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាន នៃវិស័យទេសចរណ៍
- លើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយ រកទីផ្សា និងជំរុញការផ្សព្វផ្សាយទេសចរណ៍កម្ពុជាឲ្យកាន់តែមានប្រសិទ្ធភាព ដោយមានការចូលរួមពីផ្នែកសាធារណៈ និងផ្នែកឯកជន
- អភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍
- រួមចំណែកកសាងមិត្តភាព និងការយោគយល់ជាអន្តរជាតិ តាមរយៈឧស្សាហកម្មទេសចរណ៍។

<u>មាត្រា៣៖</u> ច្បាប់នេះមានវិសាលភាពគ្រប់គ្រង និងគ្របដណ្តប់លើរាល់សកម្មភាព ទេសចរណ៍នៅក្នុងព្រះរាជាណាក្រកម្ពុជា។

<u>មាត្រា៤៖</u> ក្រសួងទេសរណ៍ ត្រូវរៀបចំគោលនយោបាយ និងផែនការអភិវឌ្ឍទេសចរណ៍សម្រាប់ព្រះរាជាណាក្រកម្ពុជា ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សមាគមឧស្សាហកម្មទេសចរណ៍ និងផ្នែកឯកជន ដែលមានការពាក់ព័ន្ធ។

ផែនការអភិវឌ្ឍន៍ទេសចរណ៍ រួមមាន ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់ និងផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការអភិវឌ្ឍទេសចរណ៍ សម្រាប់មូលដ្ឋានរបស់ខ្លួន។

**មាត្រា៦៖** ផែនការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់ជាតិត្រូវ៖

ក. កំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិសម្រាប់ការអភិវឌ្ឍន៍ និងផ្សព្វផ្សាយអំពីវិស័យទេសចរណ៍។

ខ. លើកឡើងរាល់វិធានការ ដើម្បីកាត់បន្ថយភាពក្រីក្រ និងធានាឲ្យបាននូវនិរន្តរភាព នៃការអភិវឌ្ឍន៍វិស័យទេសចរណ៍ថ្នាក់ជាតិ។

គ. ធ្វើសមាហរណកម្មជាមួយផែនការទេសចរណ៍អាស៊ាន និងផែនការទេសចរណ៍អន្តរជាតិនានា។

**មាត្រា៧៖** ផែនការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់តំបន់ និងផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ៖

ក. កំណត់យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍តាមតំបន់ និងនៅថ្នាក់រដ្ឋបាលរបស់ខ្លួន។

ខ. លើកឡើងនូវវិធានការនានាដើម្បីកាត់បន្ថយភាពក្រីក្រ និងដើម្បីធានាឲ្យបាននូវនិរន្តភាពនៃការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យទេសរណ៍នៅតាមតំបន់ និងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ។

ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់ ត្រូវរៀបចំឡើងឲ្យស្របទៅតាម ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ។ ផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាល ថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងឲ្យស្របទៅតាមផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់។

**មាត្រា៨៖** ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ និងថ្នាក់តំបន់ត្រូវដាក់ជូនរាជរដ្ឋាភិបាល ដើម្បីអនុម័ត និងបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ដើម្បីឲ្យក្លាយទៅជាគោលនយោបាយ និងយុទ្ធសាស្ត្រទូទៅរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា។

ផែនការអភិវឌ្ឍទេសចរណ៍ត្រូវពិនិត្យ និងកែប្រែឡើងវិញតាមភាពចាំបាច់យ៉ាងហោចណាស់មួយដងរៀងរាល់រយៈពេល ០៥ (ប្រាំ) ឆ្នាំ។

**មាត្រា៩៖** ក្រសួងទេសចរណ៍មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងការងារវិស័យទេសចរណ៍ និងបំពេញភារកិច្ចផ្សេងៗទៀត ឲ្យមានប្រសិទ្ធភាពស្របទៅតាមការអនុវត្តជាលក្ខណៈជាតិ និងអន្តរជាតិ។

ក្រសួងទេសចរណ៍ត្រូវដឹកនាំ និងត្រួតពិនិត្យការអនុវត្តផែនការអភិវឌ្ឍទេសចរណ៍។ ដោយវិស័យទេសរណ៍ប៉ះពាល់ទៅលើ និងទទួលរងការប៉ះពាល់ពីការងារ និងសមត្ថកិច្ចរបស់ក្រសួង

ស្ថប័ន និងអាជ្ញាធរជាច្រើនទៀត ការបែងចែក តួនាទី របស់ក្រសួងទេសចរណ៍ជាទូទៅ ត្រូវធ្វើឡើងស្របទៅតាមគោលការណ៍ដែលបានគូសបញ្ជាក់នៅក្នុងមាត្រានានានៃជំពូកនេះ។

**មាត្រា១០៖** ក្រសួងទេសចរណ៍ ត្រូវទទួលខុសត្រូវជាចម្បងក្នុងការចេញបទប្បញ្ញត្តិសំខាន់ៗផ្នែកឧស្សាហកម្មទេសចរណ៍ ដើម្បីជំរុញការអនុវត្តផែនការអភិវឌ្ឍទេសចរណ៍ឲ្យមានប្រសិទ្ធភាព។ ផ្នែកសំខាន់ៗទាំងនោះរួមមាន៖

- ការផ្សព្វផ្សាយវិស័យទេសចរណ៍ក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា
- ការធានាគុណភាពនៅក្នុងវិស័យទេសចរណ៍
- ស្តង់ដារនានានៃវិស័យទេសចរណ៍
- អាជ្ញាបណ្ណទេសរណ៍
- សកម្មភាពអាជីវកម្មទេសចរណ៍
- ការគ្រប់គ្រង និងការត្រួតពិនិត្យព័ត៌មានទេសចរណ៍
- សហប្រតិបត្តិការអន្តរជាតិក្នុងវិស័យទេសរណ៍ ជាមួយប្រទេសជិតខាង និងពិភពលោក។

ក្រសួងទេសចរណ៍ត្រូវពិគ្រោះយោបល់ ជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ក្នុងករណីដែលក្រសួង ស្ថាប័ន ឬអាជ្ញាធរណាមួយនោះ មានចំណាប់អារម្មណ៍ ប្រឹក្សាយោបល់លើផ្នែកណាមួយនៃឧស្សាហកម្មទេសចរណ៍។

**មាត្រា១១៖** ក្រសួងទេសចរណ៍ ត្រូវមានការទទួលខុសត្រូវរួមគ្នាជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតក្នុងការចេញបទបញ្ញត្តិសំខាន់ៗ ដែលប៉ះពាល់ទៅលើ ឬទទួលរងការប៉ះពាល់ដោយឧស្សាកម្មទេសចរណ៍។ ផ្នែកសំខាន់ៗទាំងនោះរួមមាន៖

- សមាគមឧស្សាហកម្មទេសចរណ៍
- ការការពារបរិស្ថាន
- ការការពារ និងការបង្ហាញពីមរតកវប្បធម៌
- ការវិនិយោគវិស័យទេសចរណ៍ និងការលើកទឹកចិត្ត
- ការគ្រប់គ្រង និងឯកជនភាវូបនីយកម្ម នៃសហគ្រាសទេសចរណ៍របស់រដ្ឋ
- ការគ្រប់គ្រងដីធ្លីរបស់រដ្ឋ ដែលបានជូលសម្រាប់គោលបំណងទេសចរណ៍
- ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ
- ការអភិវឌ្ឍន៍ផលិតផលទេសចរណ៍
- អេកូទេសចរណ៍

- សហគមន៍ទេសចរណ៍មូលដ្ឋាន
- ការកាត់បន្ថយភាពក្រីក្រ
- អនាម័យ និងសុវត្ថិភាពចំណីអាហារ
- សន្តិសុខ និងសុវត្ថិភាពទេសចរ
- នគរបាលទេសចរណ៍។

ក្រសួងទេសចរណ៍ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវសហការគ្នា ដើម្បីធានាថាផ្នែកនានានៅក្នុងឧស្សាហកម្មទេសចរណ៍ត្រូវបានចាត់ចែង និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបទៅតាមផែនការអភិវឌ្ឍន៍ទេសចរណ៍។

**មាត្រា១២៖** ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដែលការងាររបស់ខ្លួន ប៉ះពាល់ទៅដល់ឧស្សាហកម្មទេសចរណ៍ និងផែនការអភិវឌ្ឍន៍ ត្រូវពិគ្រោះយោបល់ ផ្នែកជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍។ ផ្នែកដែលប៉ះពាល់ទៅលើ ឬទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍អាចរួមមាន៖

- ផែនការប្រើប្រាស់ដីធ្លី
- ផែនការវប្បធម៌ និងផែនការអភិវឌ្ឍន៍
- ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសាធារណៈ
- ការផ្តល់ឲ្យភាពជាម្ចាស់កម្មសិទ្ធ ភតិសន្យា ឬសម្រាប់គោលបំណងទេសចរណ៍
- ការកសាងគោលនយោបាយពន្ធដារ លើអាជីវកម្មទេសចរណ៍
- ទិដ្ឋាការ
- គោលនយោបាយអាកាសចរណ៍។

ដើម្បីធានាការអនុវត្តឲ្យមានប្រសិទ្ធភាព រាល់គម្រោងសាងសង់សំណង់បម្រើឲ្យសកម្មភាពទេសចរណ៍ ត្រូវធ្វើឡើងឲ្យស្របតាមផែនការអភិវឌ្ឍទេសចរណ៍ និងត្រូវមានការជួយយោបល់ផ្នែកជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍។

ក្រសួងទេសចរណ៍ ជួយផ្តល់ដំបូន្មានបច្ចេកទេស ទៅដល់គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍រាជធានី ខេត្ត និងថ្នាក់មូលដ្ឋាន ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សា និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា សមាគមឧស្សាហកម្មទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍។

**មាត្រា១៣៖** ក្នុងករណីចាំបាច់ ក្រសួងទេសចរណ៍ព្រមទាំងក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធអាចចេញបទប្បញ្ញត្តិផ្សេងៗរួមគ្នា ដើម្បីចាត់ចែង និងគ្រប់គ្រងការងារដូចមានចែងក្នុងមាត្រា ១១ និងមាត្រា១២ នៃច្បាប់នេះឲ្យមានប្រសិទ្ធភាព។

<u>**មាត្រា១៤៖**</u> ក្រសួងទេសចរណ៍ត្រូវពង្រឹង និងពង្រីករចនាសម្ព័ន្ធចាត់តាំងរបស់ខ្លួនឲ្យឆ្លើយតបតាមផែនការអភិវឌ្ឍទេសចរណ៍។

<u>**មាត្រា១៥៖**</u> ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតវិទ្យាស្ថានជាតិទេសចរណ៍។ វិទ្យានស្ថានជាតិទេសចរណ៍ជាមណ្ឌលសិក្សា និងស្រាវជ្រាវអំពីវិស័យទេសចរណ៍ក្នុងគោលបំណងបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍទេសចរណ៍ប្រកបដោយ ប្រសិទ្ធភាព គុណភាព និងនិរន្តរភាព។ ការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិទេសចរណ៍នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

<u>**មាត្រា១៦៖**</u> ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតសាលាវិជ្ជាជីវៈទេសចរណ៍។ សាលាវិជ្ជាជីវៈទេសចរណ៍នេះមានបេសកកម្មអប់រំបណ្តុះបណ្តាល អ្នកឯកទេសវិជ្ជាជីវៈផ្នែក ទេសចរណ៍សណ្ឋាគារ និងបដិសណ្ឋារកិច្ចសំដៅបម្រើឲ្យឧស្សាហកម្មទេសចរណ៍។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាវិជ្ជាជីវៈទេសចរណ៍នេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

<u>**មាត្រា១៧៖**</u> ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតសកលវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច។ សាកលវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ចជាគ្រឹស្ថានឧត្តមសិក្សា ដែលមានការអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សលើគ្រប់ជំនាញ នៃវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចត្រូវកំណត់ដោយអនុក្រឹត្យ។

<u>**មាត្រា១៨៖**</u> ក្រសួងទេសចរណ៍សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវទទួលស្គាល់តួនាទីដ៏មានតម្លៃរបស់ផ្នែកឯកជនក្នុងការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋាគារកិច្ចដូចបានកំណត់ក្នុងបទប្បញ្ញត្តិនានាដែលមានចែងក្នុងជំពូកទី៥ នៃច្បាប់នេះ។

<u>**មាត្រា១៩៖**</u> ក្រសួងទេសចរណ៍ជួយសម្រួលការងារទាំងឡាយក្នុងការបង្កើតធម្មនុញ្ញ និង/ឬ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងត្រួតពិនិត្យសកម្មភាពរបស់សមាគមឧស្សាហកម្មទេសចរណ៍។

សមាគមឧស្សាហកម្មទេសចរណ៍ត្រូវមានធម្មនុញ្ញ និង/ឬលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងឲ្យស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗជាធរមាន។

<u>**មាត្រា២០៖**</u> ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជាមានអក្សរកាត់ថា "ក.ផ.ផ" ក្នុងលក្ខណៈជាដៃគូជាមួយផ្នែកឯកជន និងផ្នែកសាធារណៈ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជាត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២១៖** ហិរញ្ញប្បទានទ្រទ្រង់ការអភិវឌ្ឍ និងគ្រប់គ្រងវិស័យទេសចរណ៍បានមកពី:

- ថវិកាជាតិប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍
- ហិរញ្ញប្បទានសហប្រតិបត្តិការ របស់ដៃគូអភិវឌ្ឍនានា
- ការបរិច្ចាគរបស់សប្បុរសជន អតិថិជន និងសមាគមឧស្សាហកម្មទេសចរណ៍
- ការបរិច្ចាគរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា
- ការបរិច្ចាគរបស់ប្រតិបត្តិករទេសចរណ៍
- ប្រភពហិរញ្ញប្បទាន ឬចំណូលស្របច្បាប់ផ្សេងៗ។

ការគ្រប់គ្រង និងការប្រើប្រាស់ថវិកាសម្រាប់អភិវឌ្ឍវិស័យទេសរណ៍ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២២៖** ក្រសួងទេសចរណ៍ត្រូវត្រួតពិនិត្យលើការចាត់ចែងរាល់អាជីវកម្ម និងសកម្មភាពទេសចរណ៍តាមរយៈការផ្តល់អាជ្ញាប័ណ្ណ ការបង្កើតប្រព័ន្ធចំណាត់ថ្នាក់ កំណត់ស្តង់ដារអប្បបរមា និងប្រព័ន្ធអនុវត្តនានា ដើម្បីបង្កើត កែលម្អ និងរក្សាគុណភាពសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៣៖** ក្រសួងទេសចរណ៍ត្រូវកំណត់ស្តង់ដារ និងការតម្រូវលើបញ្ហាបច្ចេកទេស សេវាកម្មទេសចរណ៍ឲ្យស្របទៅនឹងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវអនុវត្តទៅតាមស្តង់ដារ និងការតម្រូវដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា២៤៖** ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត ស្របទៅតាមស្តង់ដារអន្តរជាតិ និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៅក្នុងព្រះរាជាណាក្រកម្ពុជា។ ប្រព័ន្ធចំណាត់ថ្នាក់សម្រាប់សេវាកម្មទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា២៥៖** ក្រោយពេលប្រព័ន្ធចំណាត់ថ្នាក់ ត្រូវបង្កើតឡើងសម្រាប់សកម្មភាពអាជីវកម្មទេសចរណ៍ណាមួយនោះ អាជ្ញាបណ្ណទេសចរណ៍ដែលចេញក្រោមច្បាប់នេះត្រូវបញ្ជាក់ពីកម្រិតថ្នាក់របស់អាជីវកម្មនោះ។

**មាត្រា២៦៖** ក្រសួងទេសចរណ៍ត្រូវណែនាំវិធានការ សម្រាប់បង្កើនការធានាគុណភាព សេវាកម្មទេសចរណ៍ផ្សេងទៀត ដូចជា ស្លាកសញ្ញាពិសេស ស្លាកសញ្ញាបញ្ជាក់គុណភាពការទទួលស្គាល់គុណភាព រង្វាន់ និងការលើកទឹកចិត្ត។

ក្រសួងទេសចរណ៍ ត្រូវពិគ្រោះយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ និងក្រុមអ្នកពាក់ព័ន្ធផ្សេងៗ ក្នុងការរៀបចំគំនូសប្លង់ ការអភិវឌ្ឍ និងការអនុវត្តវិធានការទាំងនោះ។

លក្ខណៈពិសេសនៃស្លាកសញ្ញាពិសេស ស្លាកសញ្ញាបញ្ជាក់គុណភាព ការទទួលស្គាល់គុណភាព រង្វាន់ និងការលើកទឹកចិត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា២៧៖** ដើម្បីលើកទឹកចិត្តចំពោះការធានាគុណភាពផលិតផល និងសេវាកម្មក្នុងឧស្សាហកម្មទេសចរណ៍ ក្រសួងទេសចរណ៍ត្រូវបង្កើតស្លាកសញ្ញាបរិស្ថានពិសេសមួយហៅថា "អេកូឡាបិល" ទុកជូនរង្វាន់លើកទឹកចិត្តដល់ប្រតិបត្តិករទេសចរណ៍ ណាដែលបានអនុវត្តត្រឹមត្រូវតាមស្តង់ដាបរិស្ថាន របស់ក្រសួងបរិស្ថាន។ មានតែប្រតិបត្តិករទេសចរណ៍ ដែលជាអ្នកបានទទួលរង្វាន់សញ្ញាបរិស្ថានពិសេសទេ ទើបអាចប្រើប្រាស់ស្លាកនេះសម្រាប់បិទនៅលើផលិតផល និងសេវាកម្មបម្រើឲ្យសាធារណជន និងអតិថិជនរបស់គេបាន។

**មាត្រា២៨៖** ប្រតិបត្តិករទេសចរណ៍ដែលជាម្ចាស់ស្លាកសញ្ញាបរិស្ថានពិសេស ដែលផ្តល់ដោយក្រសួងទេសចរណ៍ អាចទទួលបានអត្ថប្រយោជន៍ និងការលើកទឹកចិត្ត ជាអាទិភាពពីរាជរដ្ឋាភិបាលមុនប្រតិបត្តិករទេសចរណ៍ដទៃទៀត។ ក្នុងចំណោម អត្ថប្រយោជន៍ និងការលើកទឹកចិត្តទាំងនោះមាន៖

- សិទ្ធក្នុងការធ្វើអាជីវកម្មក្នុងតំបន់ពិសេសមួយចំនួន
- ការកាត់បន្ថយថ្លៃចេញអាជ្ញាបណ្ណទេសចរណ៍
- ការផ្សព្វផ្សាយនៅក្នុងប្រព័ន្ធគេហទំព័រអ្នកទទួលរង្វាន់ពិសេស
- ការផ្សព្វផ្សាយនៅក្នុងសៀវភៅអ្នកទទួលរង្វាន់ពិសេស
- ការទទួលអាទិភាពនៅក្នុងយុទ្ធនាការផ្សព្វផ្សាយ។

**មាត្រា៣០៖** សកម្មភាពអាជីវកម្មទេសចរណ៍ ដូចចែងក្នុងជំពូកទី៣ នៃច្បាប់នេះ ត្រូវបានចាត់ទៅតាមប្រភេទ និងការទទួលខុសត្រូវរបស់ក្រសួងទេសចរណ៍ដូចតទៅ៖

ក. សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវ ជាចម្បង ដូចមានចែងក្នុងមាត្រា១០នៃច្បាប់នេះមានជាអាទិ៍ដូចតទៅ៖

- មគ្គុទេសក៍ទេសចរណ៍
- ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍
- ព័ត៌មាន និងការផ្សព្វផ្សាយទេសចរណ៍

- សេវាកម្មស្នាក់នៅទេសចរណ៍
- រមណីរដ្ឋានទេសចរណ៍
- គោលដៅទាក់ទាញទេសចរណ៍
- សេវាកម្មដឹកជញ្ជូនទេសចរណ៍
- អាហារដ្ឋាន និងភោជនីយដ្ឋានទេសចរណ៍
- សាលាវិជ្ជាជីវៈទេសរណ៍
- មណ្ឌលកម្សាន្តទេសចរណ៍
- មណ្ឌលកំសាន្តទេសចរណ៍មនុស្សពេញវ័យ
- សកម្មភាពកីឡាទេសចរណ៍
- ព្រឹត្តការណ៍ និងពិព័រណ៍ទេសចរណ៍។

ខ. សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវរួមគ្នា ដូចមានចែងក្នុងមាត្រា១១ នៃច្បាប់នេះមានជាអាទិ៍ដូចតទៅៈ

- អាហាដ្ឋាន និងភោជនីយដ្ឋានទទួលបម្រើភ្ញៀវក្នុងស្រុក
- សេវាកម្មដឹកញ្ជូនអ្នកធ្វើដំណើរក្នុងស្រុក
- តំបន់ការពារធម្មជាតិ
- តំបន់សត្វជ្រោតទន្លេមេគង្គ
- សកម្មភាពអេកូទេសចរណ៍
- សកម្មភាពសហគមន៍ទេសចរណ៍មូលដ្ឋាន
- សេវាកម្មលក់ដូរវត្ថុអនុស្សាវរីយ៍
- គ្រឹះស្ថានសិក្សាទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច។

គ. សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងដែលមានការទទួលខុសត្រូវដោយការប្រឹក្សាយោបល់ ដូចមានចែងក្នុងមាត្រា១២នៃច្បាប់នេះ មានជាអាទិ៍ដូចតទៅៈ

- ការដឹកជញ្ជូនអ្នកធ្វើដំណើរតាមផ្លូវអាកាស
- ទីតាំងបេតិកភណ្ឌវប្បធម៌របស់ជាតិ
- ទីតាំងបេតិកភណ្ឌធម្មជាតិរបស់ជាតិ
- សេវាកម្មរៀបចំសន្និសីទ ពិព័រណ៍ ព្រឹត្តិការណ៍ និងបុណ្យជាតិ អន្តរជាតិ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ក្រសួងទេសចរណ៍អាចធ្វើការកែសម្រួលប្រភេទនៃសកម្មភាពអាជីវកម្មទេសចរណ៍ និងការទទួលខុសត្រូវរបស់ខ្លួន បានស្របតាមការចាំបាច់ ឬការតម្រូវដែលមានកំណត់នៅក្នុងផែនការអភិវឌ្ឍទេសចរណ៍។

**មាត្រា៣៨៖** ក្រសួងទេសចរណ៍ ដោយមានការពិគ្រោះយោបល់ ជាមួយផ្នែកឯកជន ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវកំណត់ស្តង់ដារអប្បបរមា និងលក្ខណវិនិច្ឆ័យដទៃទៀត សម្រាប់ប្រភេទនីមួយៗនៃអាជ្ញាបណ្ណទេសចរណ៍ ដែលរៀបចំឡើងដើម្បីបង្កើត កែលម្អ និងរក្សាគុណភាពសេវាកម្មទេសចរណ៍។

លក្ខណវិនិច្ឆ័យទាំងនោះត្រូវស្របទៅតាមប្រភេទនីមួយៗ នៃអាជ្ញាបណ្ណទេសចរណ៍ និងត្រូវមានទំនាក់ទំនងជាមួយកម្មវត្ថុមួយចំនួន ឬទាំងអស់ក្នុងចំណោមកម្មវត្ថុទាំងឡាយ ដូចខាងក្រោម:

ក. សញ្ជាតិ គុណវុឌ្ឍ បទពិសោធ ចំណេះដឹង និងអត្តចរិតរបស់ប្រតិបត្តិករ និងបុគ្គលិកសំខាន់ៗ។

ខ. ទីតាំង អគារ បរិក្ខារ ការចុះបញ្ជី និងសមត្ថភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិករ។

លក្ខណវិនិច្ឆ័យសម្រាប់ប្រភេទនៃអាជ្ញាបណ្ណទេសចរណ៍នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា៣៩៖** លក្ខណវិនិច្ឆ័យសម្រាប់ការចេញអាជ្ញាបណ្ណទេសចរណ៍ឲ្យមគ្គុទេសក៍ ទេសចរណ៍ត្រូវមានជាអាទិ៍ដូចខាងក្រោម៖

ក. ត្រូវតែជាបុគ្គលដែលមានសញ្ជាតិខ្មែរ និងមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។

ខ. មានវិញ្ញាបនបត្រជំនាញមគ្គុទេសក៍ទេសចរណ៍ ដែលការបណ្តុះបណ្តាលត្រូវមានទទួលស្គាល់ដោយក្រសួងទេសចរណ៍។

**មាត្រា៤៨៖** ប្រតិបត្តិករទេសចរណ៍ រួមទាំងភ្នាក់ងារ និយោជិក និងអ្នកជាប់កិច្ចសន្យាទាំងអស់ ត្រូវមានកាតព្វកិច្ចដូចតទៅ៖

→ អនុវត្តតាមច្បាប់ និងបទបញ្ញត្តិជាធរមាន ដែលពាក់ព័ន្ធនឹងស្តង់ដារក្រមប្រតិបត្តិវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ និងលក្ខខណ្ឌនានានៃអាជ្ញាប័ណ្ណទេសចរណ៍។

→ អនុវត្តតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយ ដែលប៉ះពាល់ទៅលើ ឬទទួលរងការប៉ះពាល់ដោយវិស័យទេសចរណ៍ដូចជា ការកំណត់នគរូបនីយកម្ម ការសាងសង់អគារ សុវត្ថិភាពអគ្គីភ័យ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន សុខភាព អនាម័យ ម្ហូបអាហារ ការងារកាតព្វកិច្ចពន្ធ គណនេយ្យ និងហិរញ្ញវត្ថុ ការការពារមរតកវប្បធម៌ មរតកធម្មជាតិ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

→ ការពារប្រយោជន៍ជាតិ និងប្រយោជន៍ទេសចរ និងចូលរួមចំណែកនៅក្នុងការថែរក្សាធនធានធម្មជាតិ មិនបំពុល ឬមិនបំផ្លាញបរិស្ថាន ការពារនិងអភិរក្ស មរតកវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទំលាប់របស់ប្រជាពលរដ្ឋខ្មែរក្នុងរាល់សកម្មភាពទេសចរណ៍របស់ខ្លួន។

→ ផ្តល់ដល់ទេសចរណ៍នូវព័ត៌មានពិតច្បាស់លាស់ និងទទួលខុសត្រូវផ្តល់សេវាកម្ម ដូចដែលបានសន្យា ព្រមទាំងមានវិធានការសមស្រប ដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពដល់ទេសចរ ក្នុងពេលដែលទេសចរស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។

→ ប្តឹង ឬរាយការណ៍ជាបន្ទាន់ទៅនគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬសមត្ថកិច្ចទេសចរណ៍ដែលនៅជិតបំផុត ក្នុងករណីដឹងឬមានការសង្ស័យថា មានការប្រព្រឹត្តបទល្មើស ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការជួញដូរ និងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និងសម្ភារៈអាសអាភាស ឬប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត។

→ អ្នកគ្រប់គ្រងសណ្ឋាគារ ឬសេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវកត់ត្រាទុកអត្តសញ្ញាណអតិថិជន និងព័ត៌មានផ្សេងៗទៀតនៅពេលចូលស្នាក់នៅ។

→ សហការនៅក្នុងកិច្ចការអធិការកិច្ច ដូចមានចែងក្នុងមាត្រា៦០ នៃច្បាប់នេះ។

→ ប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឲ្យបានល្អ។

→ អនុវត្តឲ្យបានខ្ជាប់ខ្ជួននូវលក្ខខណ្ឌដែលមានចែង ក្នុងមាត្រា៣៩ និងលក្ខខណ្ឌដទៃផ្សេងទៀតដែលមានចែងក្នុងជំពូកទី៥នៃច្បាប់នេះ។

<u>មាត្រា៤៩៖</u> មន្ត្រីមានសមត្ថកិច្ចដែលពាក់ព័ន្ធ នឹងវិស័យទេសចរណ៍ ត្រូវមានកាតព្វកិច្ចដូចតទៅ៖

ក. ផ្តល់ដល់ទេសចរនូវព័ត៌មានឥតលាក់លៀម និងមិនលំអៀង។

ខ. ជួយយកអាសារដោយភាពស្មោះត្រង់ និងផ្តល់ភាពពាក់ទាក់ក្នុងនាមជាម្ចាស់ផ្ទះ។

គ. សម្រួលការធ្វើដំណើរដល់ទេសចរ សម្រួលកិច្ចការលិខិតស្នាម និងបែបបទនានាឲ្យសាមញ្ញ។

ឃ. មិនរើសអើងសញ្ជាតិ ពូជសាសន៍ ពណ៌សម្បុរ និងសាសនា។

ង. ចាត់វិធានការចាំបាច់ ដើម្បីការពារថែរក្សាទ្រព្យសម្បត្តិរបស់ទេសចរ និងរក្សាសន្តិសុខសុវត្ថិភាព។

ច. ប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈ របស់អង្គការទេសចរណ៍ ពិភពលោកឲ្យបានល្អ។

<u>មាត្រា៥០៖</u> ទេសចរណ៍ ឬអ្នកដំណើរកម្សាន្តត្រូវមានកាតព្វកិច្ចដូចតទៅ៖

→ គោរពច្បាប់ និងបទបញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា

→ គោរពប្រពៃណី ទំនៀមទំលាប់ និងវប្បធម៌ខ្មែរ និងមិនត្រូវចូលរួមក្នុងសកម្មភាពណាមួយ ដែលបំពាន ឬធ្វើឲ្យខូចខាតដល់វប្បធម៌ខ្មែរ។

→ មិនត្រូវធ្វើឲ្យខូចខាតដល់បរិស្ថាន ឬមរតកវប្បធម៌ និងមរតកធម្មជាតិ។

→ មិនត្រូវចូលរួមក្នុងសកម្មភាពណាមួយ ដែលពាក់ព័ន្ធដល់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការជួញដូរ និងការបង្ខាំងមនុស្សការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និងសម្ភារៈអាសអាភាស ការលាងលុយកខ្វក់ និងការបង្កឲ្យមានអសន្តិសុខក្នុងសង្គម។

→ មិនធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងសុខុមាលភាពជាទូទៅ។

→ មិនត្រូវគំរាមកំហែងដល់សន្តិសុខ ឬជាប់ពាក់ព័ន្ធដល់ក្រុមភេរវកម្ម។

→ អនុវត្តឲ្យបានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ ដែលចេញដោយក្រសួងទេសចរណ៍ ឬដែលបង្កើតឡើងដោយសមាគម ឧស្សាហកម្មទេសចរណ៍ ហើយយល់ព្រមដោយក្រសួងទេសចរណ៍។

→ ប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈ របស់អង្គការទេសចរណ៍ពិភពលោកឲ្យបានល្អ។

→ ចំពោះទេសចរ ឬអ្នកធ្វើដំណើរកម្សាន្តជាជនបរទេសមិនត្រូវប្រើប្រាស់ទិសដៅទេសចរណ៍ជាឱកាសដើម្បីស្វែងរកការងារ ឬការតាំងលំនៅដ្ឋាន។

**មាត្រា៥៦៖** អនីតិជនមិនត្រូវបានអនុញ្ញា ឲ្យចូលទៅកាន់ទីបរិវេណមណ្ឌលកំសាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យឡើយ។

**មាត្រា៥៧៖** អ្នកគ្រប់គ្រង និងម្ចាស់អាជ្ញាបណ្ណនៃមណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ ត្រូវហាមឃាត់ និងចាត់វិធានការសមស្របដើម្បីធានាថា មិនមានវត្តមានអនីតិជន នៅក្នុងទីបរិវេណនោះ និងត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណបណ្ណអតិថិជនវ័យក្មេងទាំងអស់ដើម្បីធានាឲ្យមានការប្រតិបត្តិតាមកាតព្វកិច្ចក្រោមមាត្រានេះ។

បែបបទនៃការអនុវត្តមាត្រា៥៦ និងមាត្រា៥៧ នៃច្បាប់នេះត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៨៖** ក្រសួងទេសចរណ៍ត្រូវដឹកនាំការងារអធិការកិច្ច៖

→ បញ្ជូនមន្ត្រីចុះត្រួតពិនិត្យ ធ្វើអធិការកិច្ចលើទីកន្លែងប្រកបអាជីវកម្មលើទីបរិវេណ ឬ សម្ភារៈដែលបានប្រើប្រាស់ ឬសង្ស័យថាបានប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្មទេសចរណ៍ និងដែលបានប្រើប្រាស់ ឬដែលបានសង្ស័យថាបានប្រើប្រាស់ផ្ទុយនឹងច្បាប់។ ក្នុងការធ្វើ

អធិការកិច្ចក្រសួងទេសចរណ៍អាចសហការ និងសម្របសម្រួលជាមួយមន្ត្រីពីក្រសួងស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត។

→ ប្រសិនបើទីបរិវេណប្រកបអាជីវកម្មនោះ ត្រូវបានប្រើប្រាស់ជាលំនៅដ្ឋានផងដែរ ការធ្វើអធិការកិច្ចអាចប្រព្រឹត្តទៅបានតែក្នុងអំឡុងម៉ោងអាជីវកម្មប៉ុណ្ណោះ។

**មាត្រា៥៩៖** មន្ត្រីអធិការកិច្ចត្រូវបង្ហាញអត្តសញ្ញាបណ្ណមុខងារ និងបណ្ណបេសកកម្មឬលិខិតអនុញ្ញាតឲ្យបំពេញបេសកម្មមុនចាប់ផ្ដើមធ្វើអធិការកិច្ច។ មន្ត្រីអធិការកិច្ចទេសចរណ៍ ត្រូវមាននីតិសម្បទាជានគរបាលយុត្តិធម៌។

**មាត្រា៦០៖** ម្ចាស់អាជ្ញាបណ្ណ ប្រតិបត្តិករទេសចរណ៍ និងបុគ្គលដែលកាន់កាប់ទីកន្លែង ប្រកបអាជីវកម្ម ទីបរិវេណ ឬសម្ភារៈបរិក្ខារជាកម្មវត្ថុនៃអធិការកិច្ច ត្រូវសហការជាមួយមន្ត្រីអធិការកិច្ចទេសចរណ៍ ដោយផ្ដល់ព័ត៌មានត្រឹមត្រូវពិតប្រាកដ គ្រប់គ្រាន់ និងការពន្យល់មកស្រាយរាល់ការចោទសួរណាមួយ ដើម្បីជានាឲ្យមន្ត្រីអធិការកិច្ច អាចអនុវត្តភារកិច្ចបាន។ គ្មានបុគ្គលណាម្នាក់អាចរារាំង បង្អាក់ ឬជ្រៀតជ្រែក ក្នុងការងារអធិការកិច្ចដែលមានចែងក្នុងច្បាប់នេះឡើយ។

**មាត្រា៦១៖** ប្រសិនបើមន្ត្រីអធិការកិច្ចពិនិត្យឃើញថា មានការរំលោភបទប្បញ្ញត្តិនៃច្បាប់នេះ មន្ត្រីអធិការកិច្ចនោះអាចចាត់វិធានការតាមច្បាប់នេះ និងក្នុងករណីចាំបាច់ត្រូវស្នើសុំឲ្យមានកិច្ចសហការពីសមត្ថកិច្ចពាក់ព័ន្ធ។ បើជាករណីធ្ងន់ធ្ងរត្រូវរាយការណ៍ជាបន្ទាន់ ជូនក្រសួងទេសចរណ៍ ដើម្បីចាត់វិធានការតាមច្បាប់។

ក្នុងករណីដែលពិនិត្យឃើញ ឬមានហេតុផលជាមូលដ្ឋានអាចជឿជាក់ថាមានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មន្ត្រីអធិការកិច្ចនោះត្រូវរាយការណ៍ជាបន្ទាន់ជូនព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៃតំបន់ពាក់ព័ន្ធនោះ ដើម្បីចាត់វិធាមការតាមនីតិវិធីនៃច្បាប់។

**មាត្រា៦២៖** ក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធចាត់វិធានការចាំបាច់ដើម្បីបញ្ឈប់ជាបន្ទាន់ និងបិទអាជីវកម្មណាដែលអាជ្ញាបណ្ណរបស់អាជីវកម្មនោះ ត្រូវបានលុបចោល ឬព្យួរ ឬអាជីវកម្មណាដែលគ្មានអាជ្ញាបណ្ណទេសចរណ៍។

**មាត្រា៦៣៖** ការពិន័យអន្តរការណ៍ ដែលកំណត់ដោយច្បាប់នេះ ត្រូវធ្វើដោយមន្ត្រីអធិការកិច្ចទេសចរណ៍ និង/ឬ នគរបាលទេសចរណ៍។ នីតិវិធី និងលក្ខខណ្ឌក្នុងការពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ការបែងចែកសមត្ថកិច្ចរវាងមន្ត្រីអធិការកិច្ចទេសចរណ៍ និងនគរបាលទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

**មាត្រា៦៤៖** ការដាក់ពិន័យអន្តរការណ៍ មិនធ្វើឲ្យអ្នកប្រព្រឹត្តអំពើនោះរួចផុតពីការទទួលខុសត្រូវ ខាងរដ្ឋប្បវេណី និង/ឬ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលមានចែងដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៦៥៖** បុគ្គលណាដែលប្រកបអាជីវកម្មទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដែលអប្បបរមាស្មើនឹង២.០០០.០០០ (ពីរលាន) រៀល និងអតិបរមាមិនលើសពី២០.០០០.០០០ (ម្ភៃលាន) រៀល។ ទំហំទឹកប្រាក់ នៃការពិន័យអន្តរការណ៍សម្រាប់ប្រភេទអាជីវកម្មទេសចរណ៍នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា៦៦៖** ការប្រព្រឹត្តិរំលោភលើកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា៤៨ នៃច្បាប់នេះអាចជាកម្មវត្ថុនៃការពិន័យអន្តរការណ៍។ អំពើដែលជាកម្មវត្ថុ និងទំហំទឹកប្រាក់នៃការពិន័យអន្តរការណ៍នេះ ត្រូវកំណត់លំអិតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា៦៧៖** មន្ត្រីមានសមត្ថកិច្ចដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាល ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ។

**មាត្រា៦៨៖** ទេសចរ ឬអ្នកដំណើរកម្សាន្តដែលប្រព្រឹត្តល្មើសនឹងមាត្រា៥០ នៃច្បាប់នេះ អាចត្រូវបានលុបចោលទិដ្ឋាការទេសចរណ៍ ហើយបណ្តេញចេញ ឬហាមឃាត់វត្តមានក្នុងតំបន់គោលដៅទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលកំណត់ណាមួយ ដែលមិនលើសពី០៥ ឆ្នាំ ឬជាអចិន្ត្រៃយ៍។

**មាត្រា៦៩៖** ទេសចរ ឬអ្នកធ្វើដំណើរកម្សាន្ត ដែលធ្វើឲ្យខូចខាតដល់បរិស្ថាន មរតកវប្បធម៌ ឬមរតកធម្មជាតិត្រូវទទួលខុសត្រូវតាមច្បាប់ និងបទបញ្ញត្តិជាធរមាន។

**មាត្រា៧០៖** អ្នកគ្រប់គ្រង ឬម្ចាស់មណ្ឌលកម្សាន្តទេសចរណ៍ សម្រាប់មនុស្សពេញវ័យ ដែលប្រព្រឹត្តល្មើសនឹងមាត្រា ៥៧ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី១.០០០.០០០ (មួយលាន) រៀលដល់ ១០.០០០.០០០ (ដប់លាន) រៀល ដោយមិនទាន់គិតដល់វិធានការរដ្ឋបាលផ្សេងទៀត ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ទ្វេដង។

**មាត្រា៧១៖** ប្រតិបត្តិករទេសចរណ៍ដែលមិនអនុញ្ញាត ឬរារាំងមន្ត្រីអធិការកិច្ចទេសចរណ៍បំពេញការងាររបស់ខ្លួនដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ ជាប្រាក់ពី១,០០០,០០០ (មួយលាន)រៀល ដល់ ១០,០០០,០០០(ដប់លាន)រៀល ដោយមិនទាន់គិតដល់វិធានការរដ្ឋបាលផ្សេងទៀត ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ទ្វេដង។

**មាត្រា៧២៖** ជនណាដែលបង្កឲ្យមានការប្រព្រឹត្តល្មើស ឬការពារអាជីវកម្មទេសចរណ៍ដែលប្រព្រឹត្តរំលោភនឹងបទបញ្ញត្តិនៃច្បាប់នេះ ត្រូវប្រឈមនឹងទណ្ឌកម្មខាងរដ្ឋបាល ឬការទទួលខុសត្រូវខាងព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណីដែលមានចែងដោយច្បាប់ និងបទបញ្ញត្តិជាធរមានផ្សេងទៀត។

**មាត្រា៧៣៖** ជនណាដែលបន្លំ ឬបោកបញ្ឆោតក្នុងការលក់ផលិតផល ឬសេវាកម្មទេសចរណ៍ក្លែងក្លាយដល់ភ្ញៀវ ត្រូវទទួលពិន័យអន្តរការណ៍ដែលមានចំនួនទ្វេដងនៃថ្លៃលក់ផលិតផល ឬសេវាកម្មទេសចរណ៍។ ប្រសិនបើអំពើនោះបង្កើតជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។ ក្នុងករណីនេះ ក្រសួងទេសចរណ៍អាចលុបចោល ឬព្យួរ ឬបញ្ចុះថ្នាក់អាជ្ញាប័ណ្ណទេសចរណ៍មកជាអាជ្ញាប័ណ្ណបណ្តោះអាសន្ន។

**មាត្រា៧៤៖** ជនណាដែលក្លែងអាជ្ញាបណ្ណទេសចរណ៍ ឬឯកសារសាធារណៈផ្សេងៗ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

**មាត្រា៧៥៖** អាជ្ញាបណ្ណទេសចរណ៍ ដែលចេញដោយក្រសួងទេសចរណ៍ មុនច្បាប់នេះចូលជាធរមាន នៅតែមានសុពលភាព និងប្រសិទ្ធភាពរហូតដល់ថ្ងៃអស់សុពលភាពដូចដែលបានកំណត់នៅលើអាជ្ញាបណ្ណទេសចរណ៍នោះ។

ប្រតិបត្តិករទេសចរណ៍ទាំងឡាយណា ដែលបើកដំណើរការអាជីវកម្មបម្រើ សេវាកម្មទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសរណ៍ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ក្នុងរយៈពេល០៣ (បី) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន។

**មាត្រា៧៦៖** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

## ៣.៩ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (ឆ្នាំ២០០៧)

អនុក្រឹត្យលេខ ២៤ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអនុម័តនៅថ្ងៃទី១៩ មីនាឆ្នាំ២០០៧។

**មាត្រា២១៖**

→ លើកទឹកចិត្តរាល់សកម្មភាពវប្បធម៌ ព្រមទាំងរៀបចំចាត់តាំងបណ្តាការសម្តែងសិល្បៈវប្បធម៌ ពិពណ៌សំដៅធ្វើឲ្យមហាជនចាប់អារម្មណ៍ និងវប្បធម៌របស់ខ្លួន

→ បំផុស និងសម្រួលដល់សមាគមន៍វិជ្ជាជីវៈផ្សេងៗក្នុងវិស័យវប្បធម៌ សំដៅលើកម្ពស់មនសិការវិជ្ជាជីវៈ ព្រមទាំងការពារផលប្រយោជន៍ស្របច្បាប់របស់គេ

→ លើកទឹកចិត្ត និងត្រួតពិនិត្យចំពោះការថែរក្សារាល់សកម្មភាពវប្បធម៌ល្អៗ របស់ប្រជាពលរដ្ឋតាមតំបន់ទូទាំងប្រទេស។

**មាត្រា២៩៖**

→ គ្រប់គ្រងការអភិរក្ស ការថែរក្សា ការជួលជុល ការសិក្សា និងការធ្វើឲ្យសំបូរបែបនៃសមុច្ច័យសាធារណៈ

→ ធានាការផ្សព្វផ្សាយ និងការតាំងបង្ហាញសមុច្ច័យទាំងឡាយចំពោះសាធារណៈជន ព្រមទាំងត្រួតពិនិត្យតាមលក្ខណៈវិទ្យាសាស្ត្របច្ចេកទេស បណ្តាយសមុច្ច័យទាំងនេះ

→ គ្រប់គ្រងលើសារមន្ទីររដ្ឋ និងសារមន្ទីរគ្រប់ប្រភេទទូទាំងប្រទេស

→ ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន

→ ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន

**មាត្រា៣០៖**

→ គ្រប់គ្រង និងសិក្សាស្រាវជ្រាវ ដើម្បីអនុវត្តកិច្ចការការពារបេតិកភណ្ឌវប្បធម៌ ដូចមានចែកនៅក្នុងច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ

→ រៀបចំ ស្ថាបនាអភិរក្សដ្ឋាន នៅតាមបណ្តាក្រុមប្រាសាទ និងរមណីដ្ឋានវប្បធម៌នានា ដោយមានអភិរក្សករ និងអ្នកជំនាញផ្សេងៗធ្វើការនៅទីនេះ

→ សិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រ នូវបណ្តាលប្រាសាទបុរាណ រមណីដ្ឋានវប្បធម៌ និងសំណង់បុរាណ ដែលទើបរកឃើញថ្មីពុំទាន់បោះពុម្ពផ្សព្វផ្សាយ

**មាត្រា៣១៖**

→ ស្រាវជ្រាវ រុករកកំណត់ទីតាំង និងចុះបញ្ជីទីតាំងនៃស្ថានីយបុរេប្រវត្តិ និងប្រវត្តិសាស្ត្រ ដែលកប់ក្នុងដី និងក្រោមទឹក

→ ធ្វើកំណាយស្របច្បាប់លើស្ថានីយមួយចំនួន ដែលមានសារសំខាន់ក្នុងការយល់ដឹងពីសង្គម និងវប្បធម៌ សម័យបុរាណ

→ ធ្វើការវិភាគរាល់វត្ថុបុរាណដែលជីកបានពីស្ថានីយដែលមានប្រភពច្បាស់លាស់

→ ផ្សព្វផ្សាយនូវពត៌មាន ដែលស្រាវជ្រាវរកឃើញ ពីកំណាយស្របច្បាប់ ដើម្បីចែករំលែកចំនេះដឹងដល់មន្ត្រីក្រសួង និងបញ្ញវ័ន្តទូទៅ

## ៣.១០ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (ឆ្នាំ ១៩៩៩)

អនុក្រឹត្យលេខ ៧២អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បាន អនុម័តនៅ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩។

**មាត្រា១៖**

អនុក្រឹត្យនេះមានគោលបំណង៖

- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជនឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថាន មុននឹងដាក់ជូនរដ្ឋាភិបាលសំរេច។
- កំណត់ប្រភេទ និងទំហំនៃគម្រោងសកម្មភាព ដែលបានស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន។
- បំផុសឲ្យមានការចូលរួម ពីសាធារណៈជន ក្នុងកិច្ច ដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគម្រោង។

**មាត្រា២៖**

អនុក្រឹត្យនេះមានវិសាលភាព អនុវត្តចំពោះគម្រោងដែលស្នើរឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ជាក្រសួង-ស្ថាប័នរដ្ឋ លើកលែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែឡសំរេចដោយរាជរដ្ឋាភិបាល។

**មាត្រា៣៖**

ក្រសួងបរិស្ថានមានភារៈកិច្ច៖

ក. ពិនិត្យ និងវាយតំលៃលើ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ

ខ. តាមដាន ឃ្លាំមើល និងចាត់វិធានការឲ្យម្ចាស់គម្រោងប្រតិបត្តិតាម ផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង ដូចមានចែងក្នុងរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តរួច។

**មាត្រា៤៖**

ស្ថាប័ន និងក្រសួងដែលមានសិទ្ធអនុម័តលើគម្រោង មានភារៈកិច្ច ពិនិត្យ និងសំរេចលើគម្រោង ដែលក្រសួងបរិស្ថានបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

**មាត្រា៥៖**

អាជ្ញាធរខេត្ត-ក្រុង ដែលមានសិទ្ធិអនុម័តលើគម្រោង ខេត្ត-ក្រុងមានភារៈកិច្ច

- បញ្ជូននូវរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃគម្រោងដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ទៅមន្ទីរបរិស្ថានខេត្ត-ក្រុង
- ពិនិត្យ និងសម្រេចលើគម្រោង បន្ទាប់ពីបានពិចារណាលើយោបល់របស់មន្ទីរបរិស្ថានថ្នាក់ខេត្ត-ក្រុង ដែលក្រសួងបរិស្ថានបានប្រគល់សិទ្ធជូន ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា៦៖**

ម្ចាស់គម្រោងត្រូវធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ចំពោះគម្រោងដែលតម្រូវឲ្យ មានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

**មាត្រា៧៖**

ម្ចាស់គម្រោង ត្រូវដាក់ពាក់សុំពិនិត្យ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍បុរេលិទ្ធភាពទៅក្រសួងបរិស្ថាន។

**មាត្រា៨៖**

ម្ចាស់គម្រោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការសិក្សាលទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគម្រោងដែលអាចបង្ករហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ដល់ធនធានធម្មជាតិ អេកូស៊ីស្តែម សុខភាព និងសុខមាលភាពសាធារណៈ។

**មាត្រា៩៖**

ម្ចាស់គម្រោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុង មាត្រាទី ៧ និងមាត្រាទី ៨ ទៅមន្ទីរបរិស្ថាន ខេត្ត-ក្រុង គម្រោងថ្នាក់ ខេត្ត-ក្រុង។

**មាត្រា១០៖**

គោលការណ៍ណែនាំ ស្តីពីការធ្វើរបាយការ វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា១១៖**

ម្ចាស់គម្រោងត្រូវបង់ថ្លៃសេវាការងារ សំរាប់ការពិនិត្យលើរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងតាមដាន ឃ្លាំមើលការអនុវត្តគម្រោង។ តំលៃសេវាការងារនេះ ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើររបស់ក្រសួងបរិស្ថាន ដែលត្រូវបញ្ចូលក្នុងថវិកាជាតិ។

**មាត្រា១២៖**

ម្ចាស់គម្រោងត្រូវបង់វិភាគទាន ចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថាន សំរាប់កិច្ចការពារបរិស្ថាន ដូចមានចែងក្នុងមាត្រា ១៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

**មាត្រា១៣៖**

ពាក្យសុំត្រូវបំពេញដោយម្ចាស់គម្រោង និងត្រូវផ្តល់ជូនដោយក្រសួងបរិស្ថាន ចំពោះគម្រោង ថ្នាក់ក្រសួង-ស្ថាប័ន និងត្រូវផ្តល់ជូនដោយមន្ទីរបរិស្ថានខេត្ត-ក្រុង ចំពោះគម្រោងថ្នាក់ខេត្ត-ក្រុង។

**មាត្រា១៤៖**

ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៧ ទៅក្រសួងបរិស្ថាន និងផ្តល់លិខិតចំលង ទៅស្ថាប័នអនុម័តគម្រោង។

**មាត្រា១៥៖**

ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៤ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើរទៅម្ចាស់គម្រោង និងស្ថាប័នអនុម័តគម្រោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាបុរេលទ្ធភាព និងរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ពីម្ចាស់គម្រោង។

**មាត្រា១៦៖**

ក្នុងករណីដែលក្រសួងបរិស្ថាន តម្រូវឲ្យមានរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៨ ទៅក្រសួងបរិស្ថាន ជាមួយនឹងការដាក់ពាក្យសុំវិនិយោគទៅស្ថាប័នអនុម័តគម្រោង។

**មាត្រា១៧៖**

ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៦ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើរទៅម្ចាស់គម្រោង និងស្ថាប័នអនុម័តគម្រោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាបុរេលទ្ធភាព និងរបាយការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ពីម្ចាស់គម្រោង។

**មាត្រា១៨៖**

ក្នុងករណីដែលក្រសួងបរិស្ថានខកខាន មិនបានបញ្ជូនយោបល់ និងសំណើដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា ១៧ នោះ ស្ថាប័នអនុម័តគម្រោងអាចកំណត់ថា គម្រោងនោះត្រូវបានបំពេញតាម តម្រូវការនៃអនុក្រឹត្យនេះ។

**មាត្រា១៩៖**

ក្នុងសមត្ថកិច្ច ជាស្ថាប័នអនុម័តគម្រោងផង និងជាម្ចាស់គម្រោងផងនោះ ម្ចាស់គម្រោងត្រូវមានភារៈកិច្ច អនុវត្តតាមកិច្ចដំណើរការ ដូចដែលបានចែងខាងលើ។

**មាត្រា២០៖**

មុនចាប់ដំណើរការអនុវត្តគម្រោង ម្ចាស់គម្រោងត្រូវទទួលយោបល់ឯកភាពពីក្រសួងបរិស្ថាន លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

**មាត្រា២១៖**

ក្នុងរយៈពេលយ៉ាងយូរ ០១ ឆ្នាំ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យរបាយការណ៍នេះ មកក្រសួងបរិស្ថាន ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការដែលមានទទួលការអនុម័ត ពីថ្នាក់ក្រសួង-ស្ថាប័ន។

**មាត្រា២២៖**

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ យ៉ាងយូរ ០៦ ខែ ទៅតាមតម្រូវការដែលមានចែង ក្នុងករណីដែលក្រសួងបរិស្ថាន បានពិនិត្យឃើញថា សកម្មភាពដែលមានស្រាប់ និងគំពុងដំណើរការ តម្រូវឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

**<u>មាត្រា២៣៖</u>**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ក្នុងរយៈពេល ០៦ ខែ គិតចាប់តាំងពីថ្ងៃ ដែលក្រសួងបរិស្ថាន បានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាមតម្រូវការ នៃអនុក្រឹត្យនេះ។

**<u>មាត្រា២៤៖</u>**

ក្នុងរយៈពេលយ៉ាងយូរ ០២ ឆ្នាំ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យ របាយការណ៍នេះ មកមន្ទីរបរិស្ថាន ខេត្ត- ក្រុង ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការដែលបានទទួលការអនុម័តពីថ្នាក់ ខេត្ត- ក្រុង។

**<u>មាត្រា២៥៖</u>**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ យ៉ាងយូរ ០៦ ខែ ទៅតាមតម្រូវការដែលមានចែងកន្លងមក ក្នុងករណីដែលមន្ទីរបរិស្ថាន ខេត្ត- ក្រុង ពិនិត្យឃើញថា សកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការតម្រូវ ឲ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

**<u>មាត្រា២៦៖</u>**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននោះ ក្នុងរយៈពេល ០៦ ខែ គិតចាប់ពីថ្ងៃដែលមន្ទីរបរិស្ថាន ខេត្ត- ក្រុងបានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាម តម្រូវការនៃអនុក្រឹត្យនេះ។

**<u>មាត្រា២៧៖</u>**

ស្ថាប័នអនុម័តគម្រោង ត្រូវណែនាំម្ចាស់គម្រោង ឬម្ចាស់កម្មសិទ្ធ ឲ្យអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ដូចបានរៀបចំក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តដោយក្រសួងបរិស្ថាន។

**មាត្រា២៨៖**

ក្រសួងបរិស្ថាន ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ចេញបញ្ជាឲ្យផ្អាកសកម្មភាព ចំពោះម្ចាស់គម្រោង ឬម្ចាស់កម្មសិទ្ធណា ដែលពុំបានអនុវត្តតាម ផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ដូចបានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានឯកភាពរួចហើយ។

**មាត្រា២៩៖**

ម្ចាស់គម្រោង ឬម្ចាស់កម្មសិទ្ធដែលខកខានមិនបានផ្តល់ ឬបកស្រាយខុសនូវពត៌មាន ឬមិនបានអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាន ដូចបានពិពណ៌នានៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬបំពាននឹងបទប្បញ្ញត្តិណាមួយ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោស ដូចមានចែងក្នុងមាត្រា ២០ ២១ ២២ ២៣ និង ២៥ នៃជំពូកទី ៩ នៃច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

**មាត្រា៣០៖**

កំណត់ហេតុ និងការធ្វើបណ្តឹងចំពោះជនទាំងឡាយណា ដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយ នៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

**មាត្រា៣១៖**

មន្ត្រីបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិត នឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោស ផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ។

**មាត្រា៣២៖**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារៈកិច្ចរៀងៗខ្លួនៗ។

**មាត្រា៣៤៖**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

## ៣.១១ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក (ឆ្នាំ ១៩៩៩)

អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក បានអនុម័តនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ អនុក្រឹត្យនេះមានចែងដូចតទៅ ៖

**មាត្រា១៖**

អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ។

**មាត្រា២៖**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយណាដែលបង្កឲ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ។

**មាត្រា៣៖**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ៖

ក. តំបន់ទឹកសាធារណៈ : គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា៖ ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូល ទាំងប្រព័ន្ធប្រលាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី។

ខ. ប្រភពបំពុលៈ គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុបំពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ។

គ. សំណល់រាវៈ គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្ម ក្តី។

ឃ. ទឹកលូ : គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ។

ង. សំណល់រឹងៈ គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបាន បញ្ចេញចោលពីប្រភពបំពុល។

ច. សំរាម : គឺសំដៅលើសារធាតុ ឬរបស់រឹងដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោល ពីលំនៅស្ថាន និងអាគារសាធារណៈ។

ឆ. សារធាតុបំពុល : គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទ ដែលធ្វើឲ្យមាន ការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ៖ ធ្វើឲ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬ លក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចូលទៅក្នុងទឹកដោយចេតនាក្តី ឬអចេតនាក្តី។

ជ. បរិមាណសារធាតុបំពុល : គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅ ដែលមាន នៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬ ប្រព័ន្ធលូសាធារណៈ។

ឈ. **សារធាតុប្រកបដោយគ្រោះថ្នាក់** : គឺសំដៅទៅសារធាតុ ដែលបណ្តាលឲ្យមានគ្រោះថ្នាក់ ទៅ ដល់សរីរាង្គមានជីវិត ឬធ្វើឲ្យខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលឲ្យ ប៉ះពាល់ ឬមហន្តរាយ ដល់បរិស្ថាន។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃ អនុក្រឹត្យនេះ។

**មាត្រា៤៖**

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុង តារាងឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យនេះ។

**មាត្រា៥៖**

ក្នុងករណីចំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការ អភិរក្សជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដោយ ឡែកសំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ។

កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយក្រសួងបរិស្ថាន។

**មាត្រា៦៖**

ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ណាមួយ ដែលមិនអនុវត្តតាមកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុង មាត្រា ៤ និង មាត្រា ៥ នៃអនុក្រិត្យនេះ ។

**មាត្រា៧៖**

ក្រសួងបរិស្ថានត្រូវរៀបចំកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតឲ្យបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ។

**មាត្រា៨៖**

ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ទៅក្នុងតំបន់ទឹកសារធារណៈ ឬប្រព័ន្ធលូសាធារណៈ ដែលនាំឲ្យមានការបំពុលទឹក នៅតំបន់ទឹកសាធារណៈ។

**មាត្រា៩៖**

ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធប្រោះសំអាតនានា។

**មាត្រា១០៖**

ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុល ទៅកន្លែងដ៏ទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវធ្វើសេចក្តីចំលង នៃពាក្យស្នើសុំនោះ ទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ។

**មាត្រា១១៖**

ប្រភេទនៃប្រភពបំពុល ដែលតំរូវឲ្យសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដ៏ទៃ ដូចម្មានចែងក្នុងមាត្រាទី ១០ នៃអនុក្រឹត្យនេះ ហើយបានបែងចែកជា ២ ប្រភេទ៖

ក. ប្រភពបំពុលប្រភេទថ្នាក់ទី ១ : តំរូវឲ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុល នោះមានចំនួនច្រើនជាង ១០ ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សំរាប់ប្រព័ន្ធត្រជាក់នៃគ្រឿងចក្រ។
ខ. ប្រភពបំពុលប្រភេទថ្នាក់ទី ២ : ចាំបាច់តំរូវឲ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន។

**មាត្រា១២៖**

ការសុំអនុញ្ញាតលើការបញ្ចេញសំណល់ ឬការដឹកសំណល់រាវ ចេញពីប្រភពបំពុលទៅកន្លែងដទៃ ដូចមានចែងនៅក្នុងមាត្រាទី ១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគម្រោងថ្មី និងទាំងគម្រោងកំពុងដំណើរការ លើកលែងតែគម្រោងប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងនោះត្រូវបានអនុម័ត នឹងត្រូវបានរួចផុត ពីការតំរូវឲ្យសុំការអនុញ្ញាត លើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ។

**មាត្រា១៣៖**

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ ដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដទៃ ត្រូវដាក់សុំការអនុញ្ញាតមកក្រសួងបរិស្ថាន៖

- អោយបានមុន ៩០ ថ្ងៃ សំរាប់គម្រោងនៅភ្នំពេញ និង ៦០ ថ្ងៃសំរាប់គម្រោងនៅតាមខេត្តក្រុង នៃការចាប់ផ្តើមដំណើរការ សំរាប់ប្រភពបំពុលដែលជាគម្រោងថ្មី។
- អោយបានក្នុងរយៈពេល ៣០ ថ្ងៃ សំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៥០ ថ្ងៃសំរាប់គម្រោងនៅតាមខេត្តក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ។

**មាត្រា១៤៖**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់ចេញពីប្រភពបំពុលទៅកាន់កន្លែងដទៃ នឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះ ត្រូវបានបំពេញទៅតាមគោលការណ៍ ណែនាំបច្ចេកទេស ដែលកំណត់ដោយក្រសួងបរិស្ថាន។

**មាត្រា១៥៖**

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដែលទទួលបានការអនុញ្ញាតពីក្រសួងបរិស្ថាន អោយបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ហើយមានបំណងចងធ្វើការផ្លាស់ប្តូរប្រព័ន្ធ បញ្ចេញសំណល់រាវរបស់ខ្លួន ត្រូវដាក់ពាក្យសុំការអនុញ្ញាតថ្មី ទៅក្រសួងបរិស្ថានឲ្យបានមុន ៣០ ថ្ងៃ នៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូរ។

**មាត្រា១៦៖**

បុគ្គលដែលជួល ឬអ្នកកាន់កាប់បន្តប្រភពបំពុលពីម្ចាស់កម្មសិទ្ធដើម ឬអ្នកទទួលខុសត្រូវដើម ដែលបានទទួលការអនុញ្ញាតពីក្រសួងបរិស្ថាន ឲ្យបញ្ចេញ ឬដឹកសំណល់រាវរបស់ខ្លួនទៅទី

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ដំទៃត្រូវអនុវត្តបន្តឲ្យបានត្រឹមត្រូវនូវចំណុច ដែលបានកំណត់នៅក្នុងពាក្យសុំការអនុញ្ញាត ដែលម្ចាស់កម្មសិទ្ធដើម ឬអ្នកទទួលខុសត្រូវដើម បានដាក់ជូនទៅក្រសួងបរិស្ថាន។

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវថ្មីនៃប្រភពបំពុល ត្រូវផ្តល់សេចក្តីជូនដំណឹងពីការជួល ឬការកាន់កាប់បន្តរបស់ខ្លួនទៅក្រសួងបរិស្ថាន ក្នុងរយៈពេល ៣០ ថ្ងៃយ៉ាងយូរ ក្រោយពីបានការជួល ឬកាន់កាប់បន្តនោះ។

**មាត្រា១៧៖**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុល ដែលបានផ្តល់ជូនទៅឲ្យម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាសន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវ ប្រភពបំពុលនោះ ប្រព្រឹត្តល្មើសធ្ងន់ធ្ងរ ទៅនឹងមាត្រាណាមួយនៃមាត្រា ១៤ និង១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ។

**មាត្រា១៨៖**

ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

**មាត្រា១៩៖**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល។

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស។

**មាត្រា២០៖**

ការវិភាគគំរូតាងសំណល់រាវ ដែលយកបានមកពីប្រភពបំពុលក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ត្រូវធ្វើនៅក្នុង មន្ទីរពិសោធន៍ក្រសួងបរិស្ថាន។

**មាត្រា២១៖**

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវបង់ថ្លៃវិភាគសំណល់រាវរបស់ខ្លួនតាមបញ្ជីចំនួនទឹកប្រាក់ ដែលបានកំណត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ចំណូលនេះ ត្រូវបញ្ចូលទៅក្នុងថវិការជាតិ ដើម្បីផ្តល់ជយនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន។

**មាត្រា២២៖**

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសំណល់រាវរបស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដ៏ទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរ ពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធរបស់ក្រសួងបរិស្ថាន។

<u>មាត្រា២៣៖</u>

ចំពោះប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវ៖

ក. ទទួលខុសត្រូវក្នុងការកំណត់យកនូវវិធីសាស្ត្រធ្វើប្រព្រឹត្តកម្មសំអាត និងបញ្ចេញសំណល់រាវរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹង កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និង មាត្រា ៥ នៃអនុក្រឹត្យនេះ និងកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមាន ចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ។

ខ. មានសំភារៈ និងមធ្យោបាយគ្រប់គ្រាន់សំរាប់រារាំង ឬទប់ស្កាត់ការបំពុល តំបន់ទឹកសាធារណៈ នៅពេលដែលមានគ្រោះថ្នាក់ដោយចៃដន្យបង្កឡើងពីប្រភពបំពុលរបស់ខ្លួន។

គ. ទទួលខុសត្រូវក្នុងការដំឡើងឧបករណ៍ សំរាប់ធ្វើការវាស់នូវចរន្តហូរ កំហាប់ និងបរិមាណសារធាតុបំពុល ដែលមាននៅក្នុងសំណល់រាវរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ។ លទ្ធផលនៃការវាស់ស្ទង់ ត្រូវផ្ញើជារបាយការណ៍មកកាន់ក្រសួងបរិស្ថានរៀងរាល់ ៣ ខែម្តង។

<u>មាត្រា២៤៖</u>

ក្នុងករណីដែលរកឃើញថា ការបញ្ចេញសំណល់រាវពីប្រភពណាមួយ ពុំបានឆ្លើយតបទៅនឹងកំរិតកំណត់ ស្តង់ដារនៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ ឬពុំឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ក្រសួងបរិស្ថានត្រូវ ៖

ក. ចេញបញ្ជាជាលាយល័ក្ខអក្សរ តម្រូវឲ្យម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ប្រភពបំពុលនោះ ធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ ប្រសិនបើសកម្មភាពល្មើសនោះ មិនទាន់បង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក។

<u>មាត្រា២៥៖</u>

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក និងសំរាប់សុខភាពសាធារណៈមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ នៃអនុក្រឹត្យនេះ។

**មាត្រា២៦៖**

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធាការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ។

**មាត្រា២៧៖**

ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងប្រទេសកម្ពុជា។

**មាត្រា២៨៖**

ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់តឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៩៖**

ក្នុងករណីរកឃើញថា តំបន់ទឹកសាធារណៈត្រូវទទួលរងការបំពុល ដែលបង្កឲ្យមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវៈចំរុះ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់នេះ និងត្រូវចាត់វិធានការទប់ស្កាត់ការបំពុលទឹក និងស្តារនូវគុណភាពទឹកតំបន់ទឹកសាធារណៈ។

**មាត្រា៣០ ៖**

នៅពេលចុះធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តតាមនិតិវិធី ដូចមានចែងខាងក្រោម៖

ក. បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្ម របស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងប្រភពបំពុល ដើម្បីធ្វើអធិការកិច្ច យកគំរូតាង ឬពិនិត្យកំណត់ត្រា

ខ. កំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់

គ. មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឲ្យម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុ សំរាប់ប្រើប្រាស់ជាវត្ថុតាង

ឃ. របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន។

**មាត្រា៣១ ៖**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបង្ហូរបញ្ចេញនូវសំណល់រាវ ដែលមានផ្ទុកសារធាតុពុល បង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កឲ្យមានការបំពុលដល់តំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធចូលរួមអធិការកិច្ច នៅក្នុងបរិវេទប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ។

**មាត្រា៣២ ៖**

ក្នុងករណីមានឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយ នៃការបំពុលទឹកនៅតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថាន ត្រូវចុះធ្វអធិការកិច្ចជាបន្ទាន់លើបញ្ហាឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនោះ និងត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

**មាត្រា៣៣ ៖**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កឲ្យមានការបំពុលទឹក មន្រ្តីអធិការកិច្ចក្រសួងបរិស្ថានត្រូវ ៖

ក. ធ្វើកំណត់ហេតុ ប្រមូល ឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនទាន់បង្កឲ្យមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់ សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ។

ខ. ប្រមូល និងឃាត់ទុកភស្តុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហោតុ និងបញ្ជូនសំណុំរឿង ទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កឲ្យមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ។

**មាត្រា៣៤ ៖**

ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

**មាត្រា៣៥ ៖**

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

កំណត់ហេតុចោទប្រកាន់បទល្មើស ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តន៍តាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ។

**មាត្រា៣៦ ៖**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកដែលប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ។

**មាត្រា៣៧ ៖**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣៨ ៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**តារាងឧបសម្ព័ន្ធ១៖ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់**

1. សមាសធាតុសរីរាង្គអាឡូសែន និង សារធាតុដែលអាចបង្កើតបានជាសមាសធាតុសរីរាង្គអាឡូសែនទាំងនោះនៅក្នុងបរិស្ថានទឹក
2. សមាសធាតុសរីរាង្គផូស្វរ
3. សមាសធាតុសរីរាង្គទីន
4. សារធាតុដែលបង្កឲ្យមានជម្ងឺមហារីក
5. បារត និង សមាសធាតុរបស់វា
6. កាត់ម្ញូម និង សមាសធាតុរបស់វា
7. សមាសធាតុប្រេងសរីរាង្គដែលមិនបំបែកធាតុ និង ពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងនៅ

8. សមាសធាតុសំយោគដែលមិនបំបែកធាតុ ដែលអាចអណ្តែតលើផ្ទៃទឹក ឬលិចក្នុងទឹកហើយដែលអាចជ្រាបចូលទៅក្នុងការប្រើប្រាស់ទឹក
9. សារធាតុវិទ្យុសកម្ម
10. លោហៈ និងសមាសធាតុរបស់វាដូចជា:

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យ៉ូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម (Be) | តាល់ស្យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (Br) | តេលុយរីយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |

11. សមាសធាតុសរីរាង្គពុលមិនបំបែកធាតុស៊ីលីស្យ៉ូម
12. សមាសធាតុអសរីរាង្គផូស្វរ
13. សមាសធាតុប្រេងជាសរីរាង្គមិនបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ
14. សមាសធាតុ ស៊ីអានីត និង ក្លួយអរ
15. សារធាតុដែលមានឥទ្ធិពលលើអុកស៊ីសែនដូចជា អាម៉ូញ៉ាក់ នីទ្រីត។ល។

<u>តារាងឧបសម្ព័ន្ធ៣.១៖</u> កម្រិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សម្រាប់អភិរក្សជីវៈចម្រុះនៅក្នុងទឹក

1- <u>សម្រាប់ទន្លេ</u>

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | $BOD_5$ . | mg/l | 1-10 |
| 3 | សារធាតុរឹងអណ្តែតក្នុងទឹក (SS) | mg/l | 25-100 |
| 4 | កម្រិតរលាយអុកស៊ីសែន (DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម (Coliform) | MPN/100ml | <5000 |

2- <u>សម្រាប់បឹង និងអាងស្តុកទឹក</u>

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |

| | | | |
|---|---|---|---|
| 2 | COD | mg/l | 1-8 |
| 3 | សារធាតុសរីរាង្គអណ្តែតក្នុងទឹក(SS) | mg/l | 1-15 |
| 4 | កម្រិតរលាយអុកស៊ីសែន (DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម (Coliform) | MPN/100ml | <1000 |
| 6 | អាសូតសរុប (Total Nitrogen) | mg/l | 0,1-0,6 |
| 7 | ផូស្វរសរុប (Total Phosphorus) | mg/l | 0,005-0,05 |

3- <u>សម្រាប់ទឹកសមុទ្រ</u>

| <u>ល.រ</u> | <u>ប៉ារ៉ាម៉ែត្រ</u> | <u>ខ្នាត</u> | <u>កម្រិតស្តង់ដារ</u> |
|---|---|---|---|
| 1 | pH | | 7,0-8,3 |
| 2 | COD | mg/l | 2-8 |
| 3 | កម្រិតរលាយអុកស៊ីសែន (DO) | mg/l | 7,5-2,0 |
| 4 | កូលីហ្វម (Coliform) | MPN/100ml | <1000 |
| 5 | សមាសធាតុប្រេង (Oil Content) | mg/l | 0 |
| 6 | អាសូតសរុប (Total Nitrogen) | mg/l | 0,2-1,0 |
| 7 | ផូស្វរសរុប (Total Phosphorus) | mg/l | 0,02-0,09 |

## ៣.១២ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (ឆ្នាំ១៩៩៩)

អនុក្រឹត្យលេខ៣៦អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹងបានអនុម័តនៅថ្ងៃទី២៧ខែមេសា ឆ្នាំ ១៩៩៩។ អនុក្រឹត្យនេះ៖

- មានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹងប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកប ដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ។
- មានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូលដឹកជញ្ជូន កែច្នៃ និងបញ្ចោញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់។
- មានភ្ជាប់ជាមួយនូវឧបសម្ព័ន្ធ ដែលកំណត់នូវប្រភេទសំណល់ ប្រកបដោយគ្រោះថ្នាក់។

<u>មាត្រា១ ៖</u>

មានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹងប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកប ដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ។

**មាត្រា២ ៖**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់។

**មាត្រា៤៖**

ក្រសួងបរិស្ថានត្រូវរៀបចំប្រកាសស្តីពី គោលការណ៍ណែនាំលើការបោះចោល ប្រមូល ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តា ខេត្ត -ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត -ក្រុង របស់ខ្លួន សំរាប់ រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។

**មាត្រា៥៖**

ការអនុវត្តន៍ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោល សំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង។

ការអនុវត្តន៍វាក្យខ័ណ្ឌទី ១ នៃមាត្រា ៥នេះ ត្រូវអនុលោមទៅតាមគោលការណែនាំ លើការ គ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន។

**មាត្រា៦៖**

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង។

**មាត្រា៧៖**

ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅទីសាធារណៈ ឬការចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៨៖**

ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមាន ការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន។

**មាត្រា៩៖**

ការនាំចេញសំរាមពីប្រទេសកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានលុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្មព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់ម្ចាស់ប្រទេស ជាមុនសិន។

**មាត្រា១០៖**

ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកប្រទេសកម្ពុជា។

**មាត្រា១១៖**

ក្រសួងបរិស្ថានត្រូវរៀបចំប្រកាស ស្តីពីគោលការណែនាំ លើករគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថភាព។

**មាត្រា១២៖**

ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពី កំរិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ នៅក្នុងសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលអាចអនុញ្ញាតឲ្យបោះចោល ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស ការការពារគុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ។

**មាត្រា១៣៖**

ម្ចាស់សំណល់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្រប និងមានសុវត្ថិភាព។

**មាត្រា១៤៖**

ម្ចាស់សំណល់ ត្រូវធ្វើនិងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទង់នឹងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន៖

ក. ប្រភេទ និងបរិមាណសំណល់

ខ. វិធីសាស្រ្តក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ. វិធីសាស្រ្តក្នុងការសំអាតសំណល់ ឬបំបាត់សំណល់។

**មាត្រ ១៥៖**

ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុវត្តដាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន។

ហាមឃាត់ជាដាច់ខាត ការបោះចោល ឬការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភពឬបណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ។

**មាត្រា១៦៖**

ការប្រមូល ដឹកជញ្ជូន ស្តុក និងការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ តាមលំនៅស្ថាន ទីផ្សារ គ្លីនិក សម្ភព មន្ទីរពេទ្យ សណ្ឋាគារ ភោជនីយដ្ឋាន និងអាគារសាធារណៈ គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង។

**មាត្រា១៧៖**

ការដឹកជញ្ជូន ឬសាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ដែលមានប្រភពពីរោងចក្រសហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន។

**មាត្រា១៨៖**

ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវធ្វើ និងផ្ញើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ ដែលទាក់ទងទៅនឹងសំណល់ដែលបានដឹកមកចាក់ចោល ឬស្តុកនៅកន្លែងរបស់ខ្លួន រួមមាន៖

ក. ប្រភេទ និងបរិមាណសំណល់

ខ. ប្រភពដើមរបស់សំណល់

គ. ការដឹកជញ្ជូន និងមធ្យោបាយវេចខ្ចប់

ឃ. ដំណើរការ និងការគ្រប់គ្រងសំណល់នៅក្នុងទីកន្លែងរបស់ខ្លួន

**មាត្រា១៩៖**

ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសំអាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវមានការឯកភាពពីក្រសួងបរិស្ថាន ជាមុនសិន។

## ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

1. សំណល់សរសៃអំបោះ និងកំទេចកំណាត់ដែលមានពណ៌ (ក្នុងករណីយកទៅដុត)
2. សំណល់កំទេចក្រដាស ដែលសល់ពីការផលិតម្សៅក្រដាស
3. សំណល់ភក់ ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តិកម្មសម្អាតសំណល់រាវ និងទឹកល្វ
4. សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡូឧស្សាហកម្ម

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

5. សំណល់ផ្លាស្ទិក "ប៉ូលីវីនីលក្លរ"
6. សំណល់សារធាតុជ័រប៉ូលីវីក្លរីណេតទីបប៊ីផេនីល (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ។ល។
7. សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុប៉ូលីមែរប៊ុយទីលីន
8. សំណល់ប្រេងឥន្ទនៈ និងប្រេងម៉ាស៊ីន
9. សំណល់ដែលមានផ្ទុកជាតិអាស៊ីត
10. សំណល់ដែលមានផ្ទុកជាតិបាស
11. សំណល់លោហៈ និងសមាសធាតុរបស់វា រួមមាន:

| | | | |
|---|---|---|---|
| សង្កសី (ZN) | សេនីលីញ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យ៉ូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | ប៉ារីយ៉ូម (Ba) | កូប៉ាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម (Be) | តាលយ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរីយ៉ូម (Te) |
| សំណ (Pb) | ទីតានីញ៉ូម (Ti) | អ៊ុយរ៉ានីញ៉ូម (U) | ប្រាក់ (Ag) |
| បារត (Hg) | កាត់ម៉្យូម (Cd) | ដែក (Fe) | |

12. លំអងផ្សែង និងធូលីដែឡកើតមានក្នុងករណីសម្អាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម
13. សំណល់អំពូលអគ្គីសនី និងបន្ទះគ្រឿងអេឡិចត្រូនិចអគ្គីសនី
14. សំណល់អាគុយ និងថ្មពិល
15. សំណល់ថ្នាំលាប និង ថ្នាំជ្រលក់ពណ៌ និងសម្ភារៈវិចខ្ចប់ថ្នាំពណ៌
16. សំណល់បានមកពីការផលិត និងការប្រើប្រាសើទឹកថ្នាំបោះពុម្ព
17. សំណល់គ្រឿងផ្ទុះ
18. សំណល់ដែលនាំឲ្យមានការចម្លងមេរោគ ឬជម្ងឺ
19. សំណល់ដែលសល់ពីការផលិតថ្នាំពុលកសិកម្ម និងសម្ភារៈវិចខ្ចប់
20. សំណល់ផេះនៃឡដុតសំរាម សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់
21. ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់
22. សំណល់ហ្វីល ដូចជាហ្វីលភាពយន្ត វីដេអូ ហ្វីលកាសែតចំរៀង ហ្វីលថតរូប និង ហ្វីលថតសរីរាង្គមនុស្សតាមមន្ទីរពេទ្យ
23. សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសម្អាតដីកខ្វក់ ឬដីខូចគុណភាព
24. សំណល់ដែលបានមកពីការផលិតឱសថ និងឱសថដែលខូចគុណភាព

25. សំណល់ដែលជាសមាសធាតុភ្លុយអរីន
26. សំណល់ដែលជាសមាសធាតុស៊ីអានីត
27. សំណល់ដែលជាសមាសធាតុ អាសបេតូស
28. សំណល់ដែលជាសមាសធាតុផេណុល ($C_6H_5OH$)
29. សំណល់ដែលជាសមាសធាតុ អេទែ ( $R\text{-}COO\text{-}R_1$)
30. សំណល់ដែលសារធាតុសរីរាង្គរំលាយដែលមានអាឡូសែន និងគ្មានអាឡូសែន
31. សំណល់ដែលជាសមាសធាតុ ឌីអុកស៊ីសែន និងហ្វូរ៉ាន
32. សំណល់ធាតុវិទ្យុសកម្ម
33. សំណល់ដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តិកម្មសម្អាតសំណល់ ដែលមានចែង ពីចំនុចទី1 ដល់ចំនុចទី 32។

## ៣.១៣ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង (ឆ្នាំ ២០០០)

អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង ត្រូវបាន អនុម័តនៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០០។ អនុក្រឹត្យនេះគោលដៅ៖

**មាត្រា១៖**

កំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង ដើម្បីទប់ស្កាត់និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសម្លេងក្នុងបរិយាកាស សំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ។

**មាត្រា២៖**

មានវិសាលភាពអនុវត្តនិងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងឡាយណាដែលបង្កឲ្យមានការបំពុលខ្យល់ និងការរំខានដោយសម្លេងនៅក្នុងបរិយាកាស។

**មាត្រា៤៖**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតឲ្យមាននៅក្នុងខ្យល់មានបែងចែកនៅក្នុងឧបសម្ព័ន្ធ ២។

**មាត្រា៥៖**

កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតឲ្យបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងឧបសម្ព័ន្ធ ៣ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤។

**មាត្រា៦៖**

ក្នុងករណីចាំបាច់ កំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យ និងត្រូវពិនិត្យកែសំរួលរៀងរាល់ ៥ឆ្នាំម្តងតាមសំណើររបស់ក្រសួងបរិស្ថាន។

**មាត្រា៧៖**

កំរិតកំណត់ស្តង់ដារបញ្ចេញសំលេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតកំណត់ ស្តង់ដារសំលេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ៦ និង ៧។

**មាត្រា៨៖**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុពុលចូលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងឧបសម្ព័ន្ធ ៤។

**មាត្រា៩៖**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសំលេង ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧។

**មាត្រា១០៖**

ការនាំចូល និងផលិតនូវសារធាតុឆេះ ដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាបួប្រហើរ ត្រូវឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៨ ។

**មាត្រា១១៖**

ហាមឃាត់ដាច់ខាតនូវការនាំចូល ប្រើប្រាស់ ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទនៅប្រទេសកម្ពុជា ដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំលេងមិនឆ្លើយតបទៅនឹងកំរិតស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និង ៥ ។

**មាត្រា១២៖**

ហាមដាច់ខាតការបង្ហូរ ឬការធ្វើអោយលេចធ្លាយសារធាតុឆេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី។

**មាត្រា១៣៖**

ការបញ្ចេញសារធាតុបំពុល និងសំលេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ។

**មាត្រា១៤៖**

ការសុំអនុញ្ញាតនាំចូលនូវសារធាតុឆេះ ត្រូវមានភ្ជាប់នូវលទ្ធផលវិភាគ ដែលបញ្ជាក់ពីបរិមាណជាតិពុលស្ពាន់ធ័រ សំណ បង់សែន ឬអ៊ីដ្រូកាប៊ួប្រហើរពីប្រភេទដើម នៃការនាំចូល និងការផលិត។

**មាត្រា១៥៖**

ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំលេងមានដូចចែងនៅក្នុងមាត្រាទី ១៣ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគម្រោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ លើកលែងតែគម្រោងដែលមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ។

**មាត្រា១៦៖**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវប្រភពបំពុលដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន ៖

- អោយបានមុន ៥០ ថ្ងៃ នៃការចាប់ផ្តើមដំណើរការ សំរាប់គម្រោងនៅភ្នំពេញ
- អោយបានមុន ៦០ ថ្ងៃ នៃការចាប់ផ្តើមដំណើរការ សំរាប់គម្រោងនៅតាមខេត្ត-ក្រុង

**មាត្រា១៧៖**

ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុឆេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពអចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

**មាត្រា១៨៖**

ការត្រួតពិនិត្យនៃការបញ្ចេញឧស្ម័ន និងសំលេងពីប្រភពចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួង និងស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង។

**មាត្រា១៩៖**

ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្តីពីវិធីសាស្រ្តត្រួតពិនិត្យប្រភពបំពុលវិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសំលេង។

<u>មាត្រា២០៖</u>

ក្រសួងបរិស្ថានត្រូវចុះយកគំរូតាង នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល។ ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្ករលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស។

<u>មាត្រា២១៖</u>

នៅពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីបរិស្ថានអាចធ្វើការវិភាគគំរូតាងនៅនឹងកន្លែង ឬយកមកធ្វើនៅមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។

<u>មាត្រា២២៖</u>

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវប្រភពបំពុលត្រូវបង់ថ្លៃសំរាប់វិភាគតាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិការជាតិដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន។

<u>មាត្រា២៣៖</u>

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសារធាតុបំពុលរបស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដ៏ទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្រ្តវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន។

<u>មាត្រា២៤៖</u>

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវ៖

- ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និងឧបករណ៍កាត់បន្ថយសំលេង ដើម្បីឲ្យឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ
- ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុលដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជា ឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ ខែម្តង។
- ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថាន ក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ។

**មាត្រា២៥៖**

ក្នុងករណីដែលរកឃើញថាការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពណាមួយពុំបានឆ្លើយតបទៅនឹង កំរិតស្តង់ដារដូចមានចែងនៅក្នុងមាត្រា ៥ និងមាត្រា ៧ នៃអនុក្រឹត្យនេះ ក្រសួងបរិស្ថានត្រូវ៖

ក. ចេញបញ្ជាជាលាយល័ក្ខណ៍អក្សរតំរូវឲ្យម្ចាស់កម្មសិទ្ធ និងម្ចាស់ទទួលខុសត្រូវប្រភពបំពុលនោះ ធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ។

ខ. ចេញបញ្ជាជាលាយល័ក្ខណ៍អក្សរតំរូវឲ្យម្ចាស់កម្មសិទ្ធ និងម្ចាស់ទទួលខុសត្រូវប្រភពបំពុលនោះ ផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្នរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កអោយមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬប៉ះពាល់ដល់គុណភាពបរិស្ថាន។

**មាត្រា២៦៖**

ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងប្រទេសកម្ពុជាដើម្បីមានវិធានការទប់ស្កាត់ និងការត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា។

**មាត្រា២៧៖**

ក្រសួងបរិស្ថានត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាព និងវាយតំលៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាព និងការបំពុលខ្យល់នៅទូទាំងប្រទេសកម្ពុជា។

**មាត្រា២៨៖**

ក្នុងករណីរកឃើញថាតំបន់ណាមួយត្រូវទទួលរងការបំពុលខ្យល់ ដែលបង្កអោយមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬគុណភាពបរិស្ថាន ក្រសួងបរិស្ថានត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវស៊ើបអង្កេតរកប្រភពដែលបង្កឲ្យមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារនូវគុណភាពខ្យល់អោយបានប្រសើរឡើងវិញ។

**មាត្រ ២៩៖**

នៅពេលចុះធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តតាមនិតិវិធី ដូចមានចែងខាងក្រោម៖

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ក. បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្ម របស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬទីកន្លែងប្រភពបំពុល ដើម្បីធ្វើអធិការកិច្ចយកគំរូតាង ឬពិនិត្យកំណត់ត្រា។

ខ. កំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ត្រូវធ្វើនៅនឹង កន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់។

គ. មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឲ្យម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុ សំរាប់ប្រើប្រាស់ជាវត្ថុតាង។

ឃ. របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន។

**មាត្រា៣០ ៖**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបញ្ចេញនូវសារធាតុបំពុលខ្យល់ ឬសំលេង ឬរំញ័រ ដែលបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្សសត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កឲ្យមានការបំពុលដល់តំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធចូលរួមអធិការកិច្ច នៅក្នុងបរិវេទប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ។

**មាត្រា៣១៖**

ក្នុងករណីមានឧប្បទ្វហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយ នៃការបំពុលខ្យល់ ឬការរំខានដោយសូរសំលេង ក្រសួងបរិស្ថាន ត្រូវចុះធ្វអធិការកិច្ចជាបន្ទាន់លើបញ្ហាឧប្បទ្វហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនោះ និងត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

**មាត្រា៣២៖**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កឲ្យមានការបំពុលខ្យល់ ឬការរំខានដោយសូរសំលេង មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ ៖

ក. ធ្វើកំណត់ហេតុ ប្រមូល ឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនទាន់បង្កឲ្យមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់ សុខភាពមនុស្សសត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ។

ខ. ប្រមូល និងឃាត់ទុកភស្តុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿង ទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កឲ្យមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពសាធារណៈ។

**មាត្រា៣៣៖**

ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

**មាត្រា៣៤៖**

កំណត់ហេតុចោទប្រកាន់បទល្មើស ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តន៍តាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ។

**មាត្រា៣៥៖**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកដែលប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ។

**តារាងឧបសម្ព័ន្ធ៣.២៖ កម្រិតស្តង់ដារគុណភាពខ្យល់**

| ល.រ | ប៉ារ៉ាម៉ែត្រ | រយៈពេល៨ម៉ោងជាមធ្យម mg/m$^3$ | រយៈពេល៨ម៉ោងជាមធ្យម mg/m$^3$ | រយៈពេល២៤ម៉ោងជាមធ្យម mg/m$^3$ | រយៈពេល១ឆ្នាំជាមធ្យម mg/m$^3$ |
|---|---|---|---|---|---|
| 1 | កាបូនឌីអុកស៊ីត$CO$ | 40 | 20 | | |
| 2 | អាសូតឌីអុកស៊ីត $NO_2$ | 0,3 | | 0;10 | |
| 3 | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 0,5 | | 0,30 | 0,10 |
| 4 | អូសូន $O_3$ | 0,2 | | | |
| 5 | សំណ Pb | | | 0,005 | |
| 6 | សារធាតុរឹងអណ្តែតក្នុងខ្យល់ | | | 0,33 | 0,10 |

| | | | | | |
|---|---|---|---|---|---|
| | TSP | | | | |

កំណត់សម្គាល់៖

- កម្រិតស្តង់ដារនេះអនុវត្តសម្រាប់ធ្វើការវាយតម្លៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់។
- វិធិសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន។
- TSP – Total Suspended Particulate

**តារាងឧបសម្ព័ន្ធ៣.៣៖ កម្រិតស្តង់ដារសម្រាប់ត្រួតពិនិត្យសម្លេង ក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម**

| កម្រិតសម្លេង (dB (A)) | រយៈពេលអតិបរមា (ម៉ោង) | កំណត់បង្ហាញ |
|---|---|---|
| 75 | 32 | ត្រូវផ្តល់ឧបករណ៍ការពារ |
| 80 | 16 | ត្រចៀកដល់អ្នកបម្រើការដែលធ្វើការនៅកន្លែងមានសម្លេងលើសពី |
| 85 | 8 | 80dB (A) |
| 90 | 4 | |
| 95 | 2 | |
| 100 | 1 | |
| 105 | 0,5 | |
| 110 | 0,25 | |
| 115 | 0,125 | |

កំណត់សម្គាល់៖ កម្រិតសស្តង់ដារនេះអនុវត្តសម្រាប់ការត្រួតពិនិត្យកម្រិតសម្លេងនៅក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម។

## ៣.១៤ អនុក្រឹត្យចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ (ឆ្នាំ២០០៤)

អនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ត្រូវបានអនុម័តនៅថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៤។ មាត្រាសំខាន់ៗនៃអនុក្រឹត្យនេះមានចែងដូចខាងក្រោម៖

**មាត្រា១៖** អនុក្រឹត្យនេះមានគោលបំណងផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ សំដៅបញ្ជាក់អំពីកម្រិត គុណភាព សេវាកម្ម សំភារៈ និងគ្រឿងបំពាក់នៅតាមសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ឲ្យបានសមស្របតាមនិយាមអន្តរជាតិ។

**មាត្រា៧៖** គោលការណ៍សម្រាប់វិនិច្ឆ័យផ្តល់ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍មាន៖

→ ទីតាំង ស្ថាបត្យកម្ម និងទិដ្ឋភាពទូទៅ ដោយរាប់បញ្ចូលទាំងគុណភាព និងល័ក្ខខ័ណ្ឌផ្នែកខាងក្រៅ អាគារ ទស្សនីយភាព ទីសាធារណៈក្នុងអាគារ និងបន្ទប់ភ្ញៀវ
→ ការបំពាក់សំភារៈបរិក្ខារ ដោយរាប់បញ្ចូលផ្នែកម្រាល និងជញ្ជាំង រាំងនន អគ្គិសនីបំភ្លឺ ប្រព័ន្ធប្រើប្រាស់ អគ្គិសនី គ្រឿងសង្ហារឹម ព័ត៌មាន និងទូរគមនាគមន៍
→ អនាម័យ និងការថែទាំដោយរាប់បញ្ចូលបន្ទប់ភ្ញៀវ បន្ទប់ទឹក កន្លែងសាធារណៈកន្លែងកំសាន្ត
→ សេវា និងគុណភាពសេវា ដោយរាប់បញ្ចូលឯកសណ្ឋាន អាកប្បកិរិយារបស់បុគ្គលិកចំពោះភ្ញៀវ ការគ្រប់គ្រង និងទំនាក់ទំនងរវាងបុគ្គលិក និងភ្ញៀវ សុវត្ថិភាព និងសន្តិសុខភ្ញៀវ
→ សេវាកម្មផ្តល់ម្ហូបអាហារ ដោយប្រើប្រាស់ផលិតផលក្នុងស្រុកដែលមានគុណភាពនិងអនាម័យរាប់បញ្ចូលភោជនីយដ្ឋានការបំរើអាហារដល់បន្ទប់ គុណភាពម្ហូបអាហារ ចំនួនមុខម្ហូប ការរៀបចំតុ និងពិធីផ្សេងៗ ភ្លេងប្រពៃណីនិងរបាំបុរាណខ្មែរ។

**មាត្រា៨៖** សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ ដែលទទួលចំណាត់ថ្នាក់បាន លុះត្រាតែមានអាជ្ញាបណ្ណទេសចរណ៍ស្ថិតក្នុងសុពលភាព និងល័ក្ខខ័ណ្ឌតម្រូវដូចតទៅ៖

- ត្រូវមានការចុះបញ្ជីពាណិជ្ជកម្ម
- អាគារសំណង់ត្រូវមានលិខិតអនុញ្ញាត និងការទទួលស្គាល់ជាផ្លូវការ
- មានវិញ្ញាបនប័ត្រធានារ៉ាប់រង
- អាគារស្នាក់នៅត្រូវធានាសន្តិសុខ សុវត្ថិភាព បង្ការអគ្គីភ័យ
- ការពារបរិស្ថាន
- មានអនាម័យល្អ
- អនុវត្តតាមច្បាប់ និងបទបញ្ញត្តិផ្សេងៗទៀតរបស់រដ្ឋ។

## ៣.១៥ គោលនយោបាយចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល

យុទ្ធសាស្ត្រចតុកោណ ត្រូវបានរៀបចំឡើងទៅតាមរចនាសម្ព័ន្ធជាមុំបួន នៃចតុកោណ ដែលប្រទាក់ក្រឡាគ្នាហើយផ្សាភ្ជាប់នៅគ្រប់ជ្រុងទាំងអស់។ ជារួម សមាសធាតុនៃយុទ្ធសាស្ត្រចតុកោណជំណាក់កាលទី២នេះមានដូចតទៅៈ ចតុកោណយុទ្ធសាស្ត្រទាំងបួនសំរាប់ជំរុញកំណើនរួមមានៈ

<u>ចតុកោណទី១</u>ៈ ការលើកស្ទួយវិស័យកសិកម្ម

មុំទី១ ៈ ការលើកកំពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម

មុំទី២ ៈ ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម

មុំទី៣ ៈ កំណែទម្រង់ដីធ្លី ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

មុំទី៤ ៈ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

<u>ចតុកោណទី២</u>ៈ ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

មុំទី១ ៈ ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង

មុំទី២ ៈ ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ

មុំទី៣ ៈ ការអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនី

មុំទី៤ ៈ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។

<u>ចតុកោណទី៣</u>ៈ ការអភិវឌ្ឍវិស័យឯកជន និងការងារ

មុំទី១ ៈ ការពង្រឹងវិស័យឯកជន និងការជំរុញការវិនិយោគ និងធុរកិច្ច

មុំទី២ ៈ ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធនតូច និងមធ្យម

មុំទី៣ ៈ ការអភិវឌ្ឍទីផ្សារការងារ

មុំទី៤ ៈ ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ

<u>ចតុកោណទី៤</u>ៈ ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស

មុំទី១ ៈ ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំ, វិទ្យាសាស្ត្រ, បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស

មុំទី២ ៈ ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ

មុំទី៣ ៈ ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម

មុំទី៤ ៈ ការអនុវត្តគោលនយោបាយជាតិប្រជាជន និងសមភាពយេនឌ័រ។

ក្នុងកថាខណ្ឌទី៧៥ៈ ក្នុងគោលដៅនេះ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** បានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់នូវរបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចរបស់កម្ពុជាសម្រាប់រយៈពេល ៥ឆ្នាំ ខាងមុខ ដែលផ្តោតទៅលើ "គោលដៅជាយុទ្ធសាស្ត្រ ៤" និង "អាទិភាព ៤" ដូច

បានគូសបញ្ជាក់ពីខាងដើម។ ដូច្នេះ ក្នុងរយៈពេល៥ឆ្នាំខាងមុខ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** នឹងនាំកម្ពុជាឱ្យបន្តដំណើរឈានឡើងរបស់ខ្លួនយ៉ាងស្វាហាប់តទៅទៀត ដោយឆ្លងកាត់នូវដំណើរការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រ នៅក្នុងទិដ្ឋភាពប្រទាក់ក្រឡាគ្នាចំនួនបួនសំខាន់ៗគឺ៖

ទី១- ដំណើរការនៃការផ្លាស់ប្តូរពីបរិមាណទៅគុណភាពនៅក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈកំណែទម្រង់រចនាសម្ព័ន្ធ ការបង្កើនផលិតភាព និងការធ្វើពិពិធភាវូបនីយកម្មសេដ្ឋកិច្ច សំដៅលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា បង្កើនបរិយាប័ន្ន ឬ ការចូលរួមរបស់ប្រជាជន ព្រមទាំងលើកស្ទួយសមធម៌សង្គម។ ដំណើរការផ្លាស់ប្តូរនេះ នឹងត្រូវបានឆ្លុះបញ្ចាំងតាមរយៈ (១). ការបន្តជំរុញអនុវត្តកំណែទម្រង់ដ៏ស៊ីជម្រៅទាំងឡាយ ពិសេសកំណែទម្រងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រងវិមជ្ឍការ និងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌ និង(២). ការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម និងបរិស្ថានវិនិយោគ។

ទី២- ដំណើរការនៃការអភិវឌ្ឍឧស្សាហកម្ម តាមរយៈការដាក់ចេញ និងជំរុញអនុវត្ត " **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម**" និងការធ្វើពាណិជ្ជកម្មូបនីយកម្មវិស័យកសិកម្ម ដើម្បីបង្កើនតម្លៃបន្ថែម ពោលគឺការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា ពីកសិកម្មបែបវិបុលកម្ម មានផលិតផលទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯង ទៅជាកសិកម្មបែបប្រពលកម្ម មានផលិតភាពខ្ពស់ និងផលិតសម្រាប់ធ្វើពាណិជ្ជកម្ម។

ទី៣- ដំណើរការនៃការផ្លាស់ប្តូរពីការសង្កត់ធ្ងន់លើការវិនិយោគលើ "មូលធនរូបវន្ត" ទៅរកការផ្តល់សារៈសំខាន់កាន់តែខ្លាំងឡើងលើការវិនិយោគលើ "មូលធនពុទ្ធិ" ពោលគឺការអភិវឌ្ឍ "មូលធនមនុស្ស" ពិសេស តាមរយៈការបង្កើនការវិនិយោគលើយុវជន និងការលើកកម្ពស់តួនាទីរបស់យុវជននៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ព្រមទាំងការលើកស្ទួយសុខមាលភាពរបស់ប្រជាជនដោយផ្តោតជាសំខាន់លើស្ត្រី ទារក និងកុមារ។

ទី៤- ដំណើរការនៃការធ្វើសមាហរណកម្មកាន់តែស៊ីជម្រៅទៅក្នុងសហគមន៍តំបន់ និងពិភពលោក ពិសេសការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន នៅឆ្នាំ២០១៥ ខាងមុខ ដោយខិតខំប្រើប្រាស់ឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត នូវបណ្តាកាលានុវត្តភាព និងលក្ខខណ្ឌអំណោយផលទាំងឡាយ ដែលកើតចេញមកពីកិច្ចដំណើរការសមាហរណកម្មក្នុងតំបន់នេះ សំដៅទាក់ទាញប្រយោជន៍ជាអតិបរមាសម្រាប់កម្ពុជា ពិសេសតាមរយៈការតភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹងបណ្តាញផលិតកម្មតំបន់ និងខ្សែសង្វាក់តម្លៃសកល។

## ៣.១៦ សារាចរណ៍ណែនាំស្តីពីការអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

ការបង្កើតសារាចរណ៍ណែនាំស្តីពីការអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងចីរភាព ដើម្បីជៀសវាងនិងទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍន៍ទេសចរណ៍ សេដ្ឋកិច្ចសង្គម បរិស្ថាន វប្បធម៌ និងប្រពៃណីតំបន់ឆ្នេរ។ ការដាក់សារាចរនេះ ដើម្បីណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តនូវគោលការណ៍គ្រប់គ្រង ប្រើប្រាស់ ថែរក្សា ការពារ និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រព្រះរាជាណាចក្រកម្ពុជា ដែលរួមមានដែនគោក កោះ និងដែនទឹកដូចខាងក្រោម៖

### ១. ឆ្នេរសមុទ្រ

ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ ឬសាងសង់នានាជាថ្មី ដី ឬ ខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

→ ឆ្នេរជម្រាល ត្រូវកំណត់យ៉ាងតិច៣០ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ខ្ពស់បំផុតទៅខាងដីគោក

→ ឆ្នេរចោទត្រូវកំណត់យ៉ាងតិច២០ម៉ែត្រ ចាប់ពីចំណុចកំពូលនៃផ្ទៃចោទមកខាងដីគោកក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែង នៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃឬពង្រីកបន្ថែម ដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកំសាន្ត។

នៅលើឆ្នេរសមុទ្រ អាចអនុញ្ញាតឲ្យដាក់ឆ័ត្រ កៅអី និងតុតូចៗតាមចំនួនសមស្របដែលអាចផ្លាស់ប្តូរទីតាំងបាន សម្រាប់គោលដៅសម្រាកលំហែកាយ និងត្រូវរៀបចំដាក់តួបផ្ទាំសមុទ្រ ដោយបំពាក់សម្ភារៈ និងឧបករណ៍ចាំបាច់តាមតម្រូវការ ដើម្បីឃ្លាំមើល និងការពារសុវត្ថិភាពជូនសាធារណៈជន និងអ្នកទេសចរ។

### ២. ដីចំណីឆ្នេរសមុទ្រ និងការប្រើប្រាស់

ដីចំណីឆ្នេរសមុទ្រ ជាទូទៅប្រើប្រាស់សម្រាប់ជាសួនបៃតង និងចណ្តាញទេសភាពឬសម្រាប់ដាំដើមឈើសម្គាល់ព្រំឆ្នេរ និងចំណីឆ្នេរដោយបន្តទៅជាប់នឹងផ្លូវសាធារណៈដែលស្ថិតក្នុងទិសខាងដីគោក។

### ២.១ ដីចំណីឆ្នេរសមុទ្រ

ដីចំណីឆ្នេរសមុទ្រ គឺជាផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។ ប្រវែងឬទំហំដីចំណីឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- → ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់យ៉ាងតិច ៥០ម៉ែត្រ ពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក
- → ក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រ មានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

### ២.២ ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ

ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រមានលក្ខណៈពិសេសដោយឡែកៗពីគ្នា តាមស្ថានភាពទីតាំងនីមួយៗ៖

ដីចំណីឆ្នេរសមុទ្រ ដែលមានប្រជាជនរស់នៅច្រើន និងមានលក្ខណៈជាទីប្រជុំជន ឬមានសកម្មភាពទេសចរណ៍ ការប្រើប្រាស់ ត្រូវបានកំណត់ដូចខាងក្រោម៖

- → អាចអនុញ្ញាតឲ្យសាងសង់ជាសំណង់តូបតូចៗ សម្រាប់បម្រើដល់សេវាកម្មទេសចរណ៍នៅចន្លោះដើមឈើ ដែលមានចម្ងាយពីតូបមួយ ទៅតូបមួយទៀតយ៉ាងតិច១៥ម៉ែត្រ ដើម្បីសម្រួលដល់ការឆ្លងកាត់របស់សាធារណជន និងអ្នកទេសចរ និងរក្សាគំហើញទៅលំហសមុទ្រ។ សំណង់តូបតូចៗនេះត្រូវរៀបចំឲ្យបានត្រឹមត្រូវ តាមបទដ្ឋានបច្ចេកទេសភាពបៃតង
- → អាចអនុញ្ញាតឲ្យមានសំណង់ជានិមិត្តរូបផ្សេងៗ ជាលក្ខណៈរូបចម្លាក់ស្តូប ឬសិល្បៈសាធារណៈ
- → អាចអនុញ្ញាតឲ្យមានចំណតយានយន្តទេសចរណ៍គ្រប់ប្រភេទ ចូលក្នុងបរិវេណដីចំណីឆ្នេរសមុទ្រ ដែលមិនប៉ះពាល់ដល់សួនច្បារ និងទេសភាពបៃតងអាចអនុញ្ញាតឲ្យសាងសង់ជាបង្គន់អនាម័យសាធារណៈ ដែលមានលក្ខណៈសោភណភាព និងចំនួនសមស្រប សម្រាប់បម្រើដល់សាធារណជន និងអ្នកទេសចរ ដោយស្ថិតនៅតាមទីតាំងសមស្រប និងមិនប៉ះពាល់ដល់ទស្សនីយភាពតំបន់
- → មិនអាចអនុញ្ញាតឲ្យមានសំណង់រឹងមាំនៅលើដីចំណីឆ្នេរសមុទ្រ លើកលែងតែសំណង់នៅត្រូវសាងសង់ឡើង ក្នុងគោលបំណងបម្រើប្រយោជន៍សាធារណៈ និងទេសចរណ៍ដូចជា៖
    - ច្រកចូលឬស្ពានសម្រាប់ភ្ជាប់ទៅកំពង់ផែរ ដែលមានទូកទេសចរណ៍ឬទូកម៉ាស៊ីនតូចៗសម្រាប់ភ្ញៀវទេសចរ ឬសាធារណជនប្រើប្រាស់។ កំពង់ផែទាំងនេះ ត្រូវមានទីតាំងសមស្រប និងមិនរំខានដល់សកម្មភាពឆ្លងកាត់ឆ្នេរសមុទ្រ

- សារមន្ទីរជីវៈមន្ទីរចម្រុះ រុក្ខជាតិសមុទ្រ ត្រីសមុទ្រ ដែលនៅផ្នែកខាងមុខសំណង់ស្ថាបត្យកម្មនេះអាចឲ្យភ្ញៀវទេសចរ ឬសាធារណជនអាចឆ្លងកាត់បាន

### ៣. កោះជាផ្ទៃដីហ៊ុមព័ទ្ធដោយទឹកសមុទ្រ

ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរអតិបរមាឡើងលើ។ កោះអាចមានទំហំតូចធំខុសៗគ្នា ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ លើកលែងតែមានការកំណត់ដោយឡែក។ កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅនិងការអភិវឌ្ឍន៍ ស្របតាមគោលដៅនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងទេសចរណ៍។

### ៣.១ ការប្រើប្រាស់និងការអភិវឌ្ឍន៍កោះក្នុងកម្មវត្ថុសម្រាប់ការរស់នៅ

លើកលែងតែមានការហាមឃាត់ដោយច្បាប់ កោះមួយចំនួនអាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ជាបណ្តោះអសន្ន និងមិនទៀងតាមរយៈកិច្ចសន្យាច្បាស់លាស់។ ការអភិវឌ្ឍន៍កោះក្នុងកម្មវត្ថុនេះ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីព្រមទាំងបទបញ្ញត្តិ ជាធរមាន ឬតាមផែនការអភិវឌ្ឍន៍ដែលរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នមានសមត្ថកិច្ចបានអនុញ្ញាត។

ចំពោះកោះដែលអនុញ្ញាតឲ្យប្រើប្រាស់ក្នុងកម្មវត្ថុនេះ តែពុំទាន់មានប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់ការអនុវត្ត ស្របតាមស្ថានភាពជាក់ស្តែង និងគោរពតាមគោលការណ៍ដូចខាងក្រោម៖

- → ត្រូវរក្សា និងការធនធានធម្មជាតិ ព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%
- → ត្រូវមានសន្ទស្សន៍ទាប ដោយមានផលធៀបក្រឡាផ្ទៃបាតសំណង់ទាបជាង៣៥% ហើយផ្ទៃដីដែលនៅសល់ត្រូវរៀបចំដាំដើមឈើ និងធ្វើយ៉ាងតិច៥០%
- → ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ
- → ត្រូវរៀបចំឲ្យមានលំហសាធារណៈ និងតំបន់កម្សាន្តនានាឲ្យបានច្រើនជាអតិបរមា ដើម្បីជំរុញការមកលេងកំសាន្តរបស់សាធារណជន និងអ្នកទេសចរ
- → ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូច ឬកំពង់ផែទេសចរណ៍ ដែលអាចអនុញ្ញាត ឲ្យសាធារណជនទូទៅ ឬអ្នកទេសចរចេញចូលបាន
- → ត្រូវរៀបចំតំបន់កំសាន្តនានាក្នុងករណីមានឆ្នេរខ្សាច់ និងរៀបចំកសាងផ្លូវសាធារណៈ នៅក្បែរឆ្នេរនេះ ស្របតាមស្ថានភាពនៃទីតាំងរបស់កោះ។ ក្រសួង ស្ថាប័ន និងអាជ្ញាធរ ពាក់ព័ន្ធត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះ និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយ និងបទដ្ឋានបច្ចេកទេសរៀប

ចំដែនដីនិងនគរូបនីយកម្ម។ ផ្លូវសាធារណៈត្រូវមានទំហំសមស្របតាមបទដ្ឋានបច្ចេកទេស និងតម្រូវការនៃការប្រើប្រាស់ដ៏យូរអង្វែង

→ ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹងនិងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងការប៉ះពាល់ដល់បរិស្ថាន

→ ត្រូវធ្វើការថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះគ្រប់ប្រភេទ ដូចជាផ្កាថ្ម ត្រី និងរុក្ខជាតិសមុទ្រជាដើម ដែលមាននៅជុំវិញកោះសម្រាប់គោលដៅទេសចរណ៍។

### ៣.២ ការអភិវឌ្ឍន៍ និងការសាងសង់នៅលើកោះក្នុងកម្មវត្ថុផ្សេងក្រៅពីការរស់នៅ

រាជរដ្ឋាភិបាលកម្ពុជាអាចធ្វើការអភិវឌ្ឍន៍កោះដោយផ្ទាល់ ឬសហការជាមួយវិស័យឯកជន ឬផ្តល់សិទ្ធិឲ្យឯកជនធ្វើការអភិវឌ្ឍន៍ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។ បន្ទាប់ពីមានការសម្រេចពីរាជរដ្ឋាភិបាល បុគ្គលដែលទទួលបានសិទ្ធិត្រូវរៀបចំផែនការអភិវឌ្ឍន៍កោះ ជាលក្ខណៈរួបវន្តឲ្យបានសមស្រប និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពិនិត្យភាពសមស្របតាមគោលនយោបាយ និងបច្ចេកទេសរៀបចំដែនដី នគរូបណីយកម្ម និងសំណង់។ ការអភិវឌ្ឍន៍នេះ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

→ ត្រូវមានសន្ទស្សន៍ទាប ឬមធ្យម

→ ត្រូវការពារធនធានធម្មជាតិ និងរក្សាព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%

→ ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ

→ ត្រូវរៀបចំប្លង់អភិវឌ្ឍន៍រួបវន្ត ដែលបង្ហាញពីការប្រើប្រាស់ដីតំបន់សាធារណៈ សួនច្បារសួនឧទ្យាន បណ្តាញបៃតង ប្រព័ន្ធហេដ្ឋានរចនាសម្ព័ន្ធដូចជាផ្លូវសាធារណៈ ផ្លូវថ្មើរជើង ប្រព័ន្ធចម្រោះ ទឹកកខ្វក់ជាដើម ឲ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស និងស្ថានភាពភូមិសាស្រ្តត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូច ឬកំពង់ផែទេសចរណ៍ ដែលអាចឲ្យអ្នកដំណើរ និងសាធារណៈជនអាចចេញចូលបាន តាមស្ថានភាពជាក់ស្តែង និងមានទីតាំងសមស្រប

→ ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹង និងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីជៀសវាងការបោះសំរាម និងការបង្ហូរទឹកកខ្វក់ចូលក្នុងសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះគ្រប់ប្រភេទដូចជាថ្ម ត្រី និងរុក្ខជាតិសមុទ្រ ដែលមាននៅជុំវិញកោះដើម្បីគោលដៅទេសចរណ៍។

រាល់ការអភិវឌ្ឍន៍ក្នុងតំបន់ឆ្នេរសមុទ្រ និងកោះនិងការធ្វើសកម្មភាពសេដ្ឋកិច្ច និងទេសចរណ៍ត្រូវធានាដល់សុវត្ថិភាពសាធារណៈ សង្គម និងបរិស្ថាន ដោយត្រូវគោរពតាមច្បាប់ បទដ្ឋានគតិយុត្តិ និងបទដ្ឋានបច្ចេកទេសជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ៣.១៧ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាការជាតិគ្រប់គ្រងនិង អភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

**មាត្រា១៖**

អនុក្រឹត្យនេះកំនត់អំពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការនៃគណៈកម្មាធិការជាតិគ្រប់គ្រងនិង អភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលហៅកាត់ថា អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក**។

**មាត្រា២ថ្មី៖**

គ.អ.ធ.ក មានសមាសភាពដូចខាងក្រោម

| | | |
|---|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | ប្រធាន |
| - រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | អនុប្រធានអចិន្ត្រៃ |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងការពារជាតិ | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួង ឧស្សាហកម្មនិងសិប្បកម្ម | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងផែនការ | ១រូប | សមាជិក |
| - រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១រូប | សមាជិក |

| | | |
|---|---|---|
| - អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១រូប | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | ១រូប | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ១រូប | សមាជិក |
| - អភិបាលនៃគណៈអភិបាលខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤ | ១រូប | សមាជិក |
| - តំណាងគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ | ១រូប | សមាជិក |
| - តំណាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | ១រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងបរិស្ថាន | ១រូប | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១រូប | សមាជិក |
| - អគ្គលេខាធិការ គ.អ.ធ.ក | ១រូប | សមាជិក |

**មាត្រា៣៖**

អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក**.ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។

អគ្គលេខាធិការរងបំពេញភារកិច្ចតាមសេចក្តីសម្រេចស្តីពីការបែងចែកភារកិច្ចរបស់អគ្គលេខាធិការ។

**មាត្រា៤៖**

អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក**. មានរចនាសម្ពន្ធដូចតទៅ៖

- ផ្នែករៀបចំដែនដី និងនគរូបនីយកម្ម
- ផ្នែកគ្រប់គ្រងបរិស្ថាននិង ធនធានធម្មជាតិ
- ផ្នែកគ្រប់គ្រងនិង អភិវឌ្ឍទេសចរណ៍
- ផ្នែកអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយនិង ព័ត៌មានវិទ្យា
- ផ្នែកនីតិកម្មនិង ដោះស្រាយវិវាទ
- ផ្នែកទំនាក់ទំនងសាធារណៈ និង សហប្រតិបត្តិការ
- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក**. ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។ អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក**. អាចលើកសំណើកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក**. តាមការចាំបាច់។

**មាត្រា៥៖**

ផ្នែកនីមួយៗដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។ ប្រធានផ្នែកមានឋានៈស្មើប្រធាននាយកដ្ឋាន និងអនុប្រធានផ្នែកមានឋានៈស្មើរអនុប្រធាននាយកដ្ឋាន ផ្នែកនីមួយៗមានការិយាល័យចំនុះមួយចំនួនតាមការចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗត្រូវកំនត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដែលជាប្រធាន **គ.អ.ឆ.ក.**

**មាត្រា៦៖**

អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** មានមន្ត្រីបម្រើការមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ និងមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈផ្សេងៗទៀត។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាដើម្បីជួយបំពេញការងារ។

**មាត្រា៧៖**

អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** មានសិទ្ធប្រើត្រាដោយឡែករបស់ខ្លួន។

**មាត្រា៨៖**

ផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម មានតួនាទីនិងភារកិច្ចដូចខាងក្រោម

រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍ ប្លង់គោល និងផែនការប្រើប្រាស់ដី ដែលទាក់ទងនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីដាក់ជូន **គ.អ.ឆ.ក.** ពិនិត្យនិង សម្រេច

- ពិនិត្យនិង ផ្តល់ **គ.អ.ឆ.ក.** លើរាល់គម្រោងអភិវឌ្ឍនិង ការអនុវត្តគម្រោងដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រកម្ពុជា លើទិដ្ឋភាពរៀបចំដែនដីនិង នគរូបនីយកម្ម
- រៀបចំនិង ចូលរួមសិក្សាស្រាវជ្រាវនិងលើកកម្ពស់វិស័យរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ និងផ្តល់ប្រឹក្សាបច្ចេកទេស ដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំ គ្រប់គ្រង និងធ្វើសមាហរណកម្មទិន្នន័យរូបវន្តដែលទទួលបានពីគ្រប់អង្គភាពពាក់ព័ន្ធ
- រៀបចំបទដ្ឋានបច្ចេកទេសពាក់ព័ន្ធនឹងវិស័យ រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីឲ្យមានការឯកភាពនៅតំបន់ឆ្នេរសមុទ្រកម្ពុជា

- សិក្សាស្រាវជ្រាវគោលនយោបាយ បទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ និងផែនការរបស់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដែលទាក់ទងនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន គ.ស.ឆ.ក. ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ចំពោះការងាររៀបចំដែនដីនិងនគរូបនីយកម្មនៃតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំផែនការសកម្មភាព និងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងាររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ តំបន់ឆ្នេរសមុទ្រកម្ពុជាតាមការកំណត់

**<u>មាត្រា៩៖</u>**

ផ្នែកគ្រប់គ្រងបរិស្ថាននិង ធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំបទដ្ឋានគតិយុត្ត និងគោលគោលការណ៍ចាំបាច់នានា ដើម្បីធានាបាននូវការគ្រប់គ្រង ការអភិរក្សនិងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា ប្រកបដោយតម្លាភាព សមធម៌ និង និរន្តរភាពបរិស្ថាន
- រៀបចំលក្ខខណ្ឌ និងចាត់ថ្នាក់ធនធានធម្មជាតិដែលត្រូវអភិរក្សនៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា
- សិក្សា ស្រាវជ្រាវ ប្រមូលនិង ចងក្រងទិន្នន័យពាក់ព័ន្ធនិង បរិស្ថានសេដ្ឋកិច្ច និង សង្គម
- រៀបចំវិធានការនានាសម្រាប់បង្ការ ទប់ស្កាត់កម្មភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រកម្ពុជា
- តាមដានការអនុវត្តកម្មវិធី គម្រោងអភិវឌ្ឍ និងសកម្មភាពនានានៅតំបន់ឆ្នេរសមុទ្រកម្ពុជា ដោយផ្តោតសំខាន់លើទិដ្ឋភាពនៃកិច្ចការពារបរិស្ថាន និង អភិរក្សធនធានធម្ម ជាតិតំបន់ឆ្នេរសមុទ្រកម្ពុជា
- ត្រួតពិនិត្យនិង វាយតម្លៃផលប៉ះពាល់បរិស្ថានពីគម្រោង វិនិយោគនិងអភិវឌ្ឍទាំងឡាយក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗ របស់អគ្គលេខាធិការដ្ឋាន គ.ស.ឆ.ក. ដើម្បី ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិង អន្តរជាតិ ចំពោះកិច្ចការពារបរិស្ថាននិង ធនធានធម្មជាតិ និងរៀបចំផែនការអភិវឌ្ឍន៍បៃតងនៃតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបទដ្ឋានបច្ចេកទេសនិងផ្តល់ប្រឹក្សាពាក់ព័ន្ធនឹង វិស័យបរិស្ថាន និងធនធានធម្មជាតិនៅតំបន់ឆ្នេរសមុទ្រកម្ពុជា

- រៀបចំផែនការយុទ្ធសាស្ត្រ កម្មវិធីសកម្មភាព និងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារគ្រប់គ្រងបរិស្ថាន និង ធនធានធម្មជាតិតំបន់ឆ្នេរសមុទ្រកម្ពុជាតាមការកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.អ.ឆ.ក.** ប្រគល់ជូន។

**<u>មាត្រា១០៖</u>**

ផ្នែកគ្រប់គ្រងនិង អភិវឌ្ឍទេសចរណ៍ មានតួនាទីនិង ភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយអំពីអត្តសញ្ញាណនិង គំរូល្អនៃការអភិវឌ្ឍនិង ការអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបទដ្ឋានបច្ចេកទេសទេសចរណ៍តំបន់ឆ្នេរ សម្រាប់ការអនុញ្ញាត និង ការអនុវត្តសកម្មភាពទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា មានជាអាទិ៍ ឆ្នាំសមុទ្រ ទេសចរណ៍ក្នុងទឹកសមុទ្រ ខ្សែទស្សនកិច្ចតំបន់ឆ្នេរទេសចរណ៍តាមនាវា ដើម្បីជានាការគ្រប់គ្រងតំបន់ទេសចរណ៍តំបន់ឆ្នេរឲ្យបានល្អប្រសើរ
- ពិនិត្យ និងផ្តល់មតិទៅលើសកម្មភាពអភិវឌ្ឍទេសចរណ៍តមបន់ឆ្នេរសមុទ្រកម្ពុជា មានជាអាទិ៍ ការរៀបចំគម្រោងឆ្នេរគំរូ សកម្មភាពផ្ទះឆ្នេរ ប្រភេទទេសចរណ៍ផ្ទះទី២
- ពិនិត្យនិងវាយតម្លៃ លើពាក្យស្នើសុំអនុវត្តសកម្មភាពទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- តាមដាននិង ត្រួតពិនិត្យសកម្មភាពទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំលក្ខណវិនិច្ឆ័យសម្រាប់គ្រប់គ្រងអាជីវករនិង ប្រតិបត្តិករនៅតំបន់ឆ្នេរសមុទ្រកម្ពុជានិង ផ្តល់យោបល់លើពាក្យស្នើសុំធ្វើជាប្រតិបត្តិករទេសចរណ៍
- ពិនិត្យនិង ផ្តល់យោបល់ ដើម្បីចាត់វិធានការបង្ការ និងទប់ស្កាត់រាល់សកម្មភាពទាំងឡាយដែលអាចប៉ះពាល់ដល់ការគ្រប់គ្រង ការអភិរក្ស និង ការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- សម្រុះសម្រួលនិង ដោះស្រាយវិវាទពាក់ព័ន្ធ នឹងការអនុវត្តសកម្មភាពទេសរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបទដ្ឋានបច្ចេកទេសនិង ផ្តល់ប្រឹក្សាពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍទេសចរណ៍នៅតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិង អន្តរជាតិចំពោះការងារគ្រប់គ្រងនិង អភិវឌ្ឍទេសចរណ៍នៃតំបន់ឆ្នេរសមុទ្រកម្ពុជា

- រៀបចំផែនការយុត្តសាស្ត្រ កម្មវិធីសកម្មភាព និងធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងារទេសចរណ៍តំបន់ឆ្នេរសមុទ្រកម្ពុជាតាមការកំណត់

<u>មាត្រា១១៖</u>

ផ្នែកអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ និងព័ត៌មានវិទ្យាមានតួនាទីនិង ភារកិច្ចដូចខាងក្រោម

- ផ្សព្វផ្សាយដល់ថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងគ្រប់ភាគីពាក់ព័ន្ធឲ្យយល់ដឹងអំពីការគ្រប់គ្រង ការអភិរក្ស និង ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- អប់រំ បណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងការគ្រប់គ្រង ការអភិរក្ស និង ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបណ្តុះបណ្តាលបំពេញបន្ថែម សិក្ខាសាលា វគ្គបំប៉នខ្លីៗ ដល់មន្ត្រី បុគ្គលិក ដែលកំពុងបម្រើការងារនៅក្នុងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ស្រាវជ្រាវចងក្រង បោះពុម្ព និង ផ្សព្វផ្សាយព័ត៌មាននិង ទិន្នន័យដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្សនិង ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំ គ្រប់គ្រងប្រព័ន្ធព័ត៌មានកម្ពុជានិង ធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់ **គ.អ.ឆ.ក.**
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិង អន្តរជាតិ ចំពោះការងារអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ និងព័ត៌មានវិទ្យា
- រៀបចំផែនការសកម្មភាពនិង បូកសរុបរបាយការណ៍សំរាប់កិច្ចការអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយនិង ព័ត៌មានវិទ្យា
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.អ.ឆ.ក.** ប្រគល់ជូន។

<u>មាត្រា១២៖</u>

ផ្នែកនីតិកម្ម និងដោះស្រាយវិវាទ មានតួនាទីនិង ភារកិច្ចដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវ រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត និងគោលការណ៍ចាំបាច់នានាពាក់ព័ន្ធនឹងការ គ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដាក់ជូន **គ.អ.ឆ.ក.** ដើម្បីពិនិត្យនិងសម្រេច
- ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត និង បទដ្ឋានបច្ចេកទេស ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបទបញ្ញាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋាន**គ.អ.ឆ.ក.**

- ទទួលពាក្យបណ្តឹងតវ៉ា ធ្វើការស៊ើបអង្កេត និងសម្របសម្រួល ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងបណ្តឹងតវ៉ាទាំងនោះ ស្របតាមច្បាប់ បទប្បញ្ញត្តិ និង នីតិវិធីជាធរមាន
- ពិនិត្យនិង ផ្តល់មតិលើកិច្ចព្រមព្រៀងអន្តរជាតិនិង លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗ របស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិង អន្តរជាតិ ចំពោះការងារនីតិកម្មនិងដោះស្រាយវិវាទ
- រៀបចំផែនការសកម្មភាព និងរបាយការណ៍សម្រាប់កិច្ចការនីតិកម្មនិងដោះស្រាយវិវាទ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.អ.ឆ.ក.** ប្រគល់ជូន។

**<u>មាត្រា១៣៖</u>**

ផ្នែកទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការមានតួនាទីនិង ភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌជាតិ តំបន់និងអន្តរជាតិ នូវរាល់សកម្មភាពដែលទាក់ទងនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- សម្របសម្រួលនឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសាកលលោក
- ធ្វើការផ្សព្វផ្សាយ និងរៀបចំដំណើរការប្រឡងប្រណាំឆ្នេរស្អាតតាមដាននិង វាយតម្លៃលើរាល់សកម្មភាពដែលមានចែងក្នុងកំនត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាជូនថ្នាក់ដឹកនាំពិនិត្យ សម្រេច ដើម្បីរិះរកវិធានការបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រង ការអភិរក្ស និង ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ធ្វើទំនាក់ទំនងសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់និង អន្តរជាតិ ដើម្បីបញ្ជូនមន្ត្រី បុគ្គលិកទៅធ្វើការសិក្សាដលបទពិសោធការងារពាក់ព័ន្ធនឹងការគ្រប់គ្រង ការអភិរក្ស និង ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិង អន្តរជាតិចំពោះការងារទំនាក់ទំនងសាធារណៈនិង សហប្រតិបត្តិការធ្វើកិច្ចការឆ្លើយព័ត៌មានជាសាធារណៈ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.អ.ឆ.ក.**ប្រគល់ជូន

**មាត្រា១៤៖**

ផ្នែករដ្ឋបាលនិងហិញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.** ឲ្យមានភាពរលូន និងមានប្រសិទ្ធភាព
- គ្រប់គ្រងការងាររដ្ឋបាលទូទៅ និងការងារបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.**
- រៀបចំសន្និបាត កិច្ចប្រជុំ សិក្ខាសាលា និង ពិធីការនានា
- សម្របសម្រួលនិង រៀបចំផែនការសកម្មភាពនិង ថវិការបស់ **គ.អ.ឆ.ក.**
- គ្រប់គ្រងថវិកានិង ធ្វើរបាយការណ៍អំពីស្ថានភាពចំណូលចំណាយរបស់ **គ.អ.ឆ.ក.**
- ធ្វើលទ្ធកម្មក្នុងការផ្គត់ផ្គង់ និងបែងចែកសម្ភារៈបរិក្ខា និងធ្វើបញ្ជីសារពើភណ្ឌ ទ្រព្យសម្បត្តិរបស់**គ.អ.ឆ.ក.**
- សហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន **គ.អ.ឆ.ក.**ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិង អន្តរជាតិ ចំពោះការងាររដ្ឋបាល និងហិរញ្ញវត្ថុ
- បូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស និង ប្រចាំឆ្នាំរបស់**គ.អ.ឆ.ក.**

ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ **គ.អ.ឆ.ក.** ប្រគល់ជូន។

**មាត្រា១៥៖**

បទបញ្ញត្តិទាំងឡាយទាំងឡាយណាដែលផ្ទុយនឹង អនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៦៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ និងប្រធាន **គ.អ.ឆ.ក** រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធីការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តតំបន់ឆ្នេរសមុទ្រទាំង៤ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ។

# ជំពូកទី៤៖
# ការពិពណ៌នាអំពីគម្រោង

# ជំពូកទី៤៖ការពិពណ៌នាអំពីគម្រោង

## ៤.១ សេចក្តីផ្តើម

ដោយមើលឃើញពីសក្តានុពលវិស័យទេសចរណ៍ដ៏សំបូរបែបនៅកម្ពុជា ជាពិសេស រមណីយដ្ឋានដែលមានលក្ខណៈវប្បធម៌ និងធម្មជាតិទើប ក្រុមហ៊ុន **អរ៉ភីប៊ី អ៊ិនវេសមេន ខូអិលធីឌី** (RPB Investment Co.Ltd)ដែលជាវិនិយោគគិនមកពីប្រទេសរុស្ស៊ីបានរៀបចំ គម្រោងអភិវឌ្ឍន៍ជារមណីយដ្ឋានធម្មជាតិដែលមានទីតាំងនៅលើ**កោះក្របី** (**កោះច្រឡុស**) **ខេត្តព្រះសីហនុ**។ប្លង់មេអភិវឌ្ឍន៍នៃ **រមណីយដ្ឋានកោះក្របី**រួមមានគម្រោងអភិវឌ្ឍន៍ សំខាន់ៗដូចជាគម្រោងសាងសង់ផ្ទះលំហែកាយ ភោជនីយដ្ឋាន អាងហែលទឹក-កន្លែងហាត់ប្រាណ- ស្ប៉ារ កំពុងផែទេសចរណ៍ និងកន្លែងកំសាន្តផ្សេងៗទៀត។

ការអភិវឌ្ឍន៍នេះមានផ្ទៃដីសរុប **១០ហិកតា**នៅលើកោះក្របីនិង០.១៥ហិកតា នៅលើដីគោក(ឆ្នេរសមុទ្ររាម)។ ផ្ទៃដីនៅលើកោះត្រូវបានបែងចែកជា៣តំបន់គឺ តំបន់ទី១(**៧,៥ហិកតា**) តំបន់ទី២(**១ហិកតា**) តំបន់ទី៣(**១,៥ហិកតា**)និងដីនៅត្រើយម្ខាងនៃដីគោក ត្រូវបានបែងចែកជា២តំបន់ទៀតគឺតំបន់ទី៤(**0,0៥ហិកតា**)និងតំបន់ទី៥(**0,១ហិកតា**)។ គម្រោងអភិវឌ្ឍន៍នេះមានទុនវិនិយោគសរុបចំនួន**១០,00៩,000**USD(**ដប់លាន ប្រាំបួនពាន់ ដុល្លារអាមេរិក**) ដោយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាលតាមរយៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍នៃកម្ពុជា (CDC) ដោយមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី០១។




រូបភាព៤.១៖ គម្រោងប្លង់មេកោះក្របី(កោះច្រឡុស)

## ៤.២ សាវតាក្រុមហ៊ុន

ក្រុមហ៊ុន**អរភីប៊ី អ៊ិនវេសមេន ខូអិលធីឌី** (RPB Investment Co.,Ltd) គឺជាក្រុមហ៊ុនមួយក្រៅស្រុកដោយធ្លាប់មានបទពិសោធន៍ និងមានឈ្មោះល្អ។ គម្រោងទាំងអស់នេះ រៀបចំគូសវាសឡើងស្របតាមស្តង់ដារជាតិ និងអន្តរជាតិ ក្រោមការត្រួតពិនិត្យបច្ចេកទេសយ៉ាងត្រឹមត្រូវ និងប្រកបដោយគុណភាព។ក្រុមហ៊ុន**អរភីប៊ី អ៊ិនវេសមេន ខូអិលធីឌី** (RPB Investment Co.,Ltd)មានទីស្នាក់ការនៅដីឡូត៍លេខ៧ ផ្លូវមិត្តភាពកម្ពុជា សូវៀត ភូមិលេខ៣ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនឯកជន ទទួលខុសត្រូវលើការវិនិយោគនៃការអភិវឌ្ឍន៍ដែលមានដើមទុនវិនិយោគជាង**១០,០០៩,០០០**USD (**ដប់លាន ប្រាំបួនពាន់ ដុល្លារអាមេរិក**)ដែលមានលោក**ហ្វីតដូរ៉ូ វីតាលី**(FEDOROV VITALY) ជាប្រធានក្រុមហ៊ុន។

## ៤.៣លិខិតបទដ្ឋានរបស់ក្រុមហ៊ុនពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍

ឯកសារគោលការណ៍ច្បាប់ដែលក្រុមហ៊ុន **អរភីប៊ី** បានទទួលទាក់ទងនឹងគម្រោងអភិវឌ្ឍន៍តំបន់លំហែកាយកោះក្របី មានដូចខាងក្រោម៖

☞លិខិតលេខ១១១/០៧អនុដេ៣.ឧស្សា ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៧របស់ **ក្រសួងទេសចរណ៍** បានឯកភាពជាគោលការណ៍ក្នុងការវិនិយោគលើ **កោះក្របី** (**ហៅកោះច្រឡុស**) ក្រុងព្រះសីហនុ របស់ក្រុមហ៊ុនRPB Investment Co.,Ltd។

☞លិខិតលេខ ២៩៥៣/០៧ គ.វ.ក ចុះថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ ២០០៧ របស់ **គណៈកម្មាធិការវិនិយោគកម្ពុជា**បានចេញសេចក្តីជូនដំណឹងដល់ក្រសួង/ស្ថាប័នពាក់ព័ន្ធឲ្យបានជ្រាបថា: ក្រុមហ៊ុន RPB Investment Co.,Ltdបានបង់ថ្លៃចុះបញ្ជីវិនិយោគ លើគម្រោងអភិវឌ្ឍន៍កោះក្របី (ហៅកោះច្រឡុស)ចំនួន៧.០០០.០០០(ប្រាំពីរលាន)រៀលនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។

☞អនុក្រឹត្យលេខ១៦១អនក្រ.បក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**បានធ្វើអនុបយោគទីតាំងកោះស្រមោច កោះប្រើស កោះក្របី និងកោះគ្រេះ ត្រូវបានបញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

☞លិខិតលេខ៧៧៦/០៨អគ.វ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៨របស់**រាជរដ្ឋាភិបាល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**(CDC)ស្តីពីការសម្រេចចេញវិញ្ញាបនប័ត្រចុះបញ្ជីរជាស្ថាពរ លើគម្រោងអភិវឌ្ឍន៍ **កោះក្របី** (**ហៅកោះច្រឡុស**) ខេត្តព្រះសីហនុ។

## ៤.៤ ទីតាំង និងព្រំប្រទល់ដីនៃគម្រោងអភិវឌ្ឍន៍

### ៤.៤.១សាវតាទីតាំងគម្រោង

កោះក្របី ស្ថិតនៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចំងាយ៦គីឡូម៉ែត្រពីឆ្នេរសមុទ្ររាម។ កោះនេះត្រូវបាន**ក្រុមហ៊ុន អឌីធី** មកដាក់ទុនវិនិយោគធ្វើជារមណីយដ្ឋានសម្រាប់ទាក់ទាញភ្ញៀវទេសចរមកកំសាន្តក្នុងតំបន់នេះ ក៏ដូចជាក្នុងខេត្តព្រះសីហនុ។ នៅជុំវិញកោះក្របីនេះមានកោះឬស្សី កោះតាកៀវ កោះព្រះ ឆ្នេរសមុទ្ររាម ដែលជាទីប្រជុំនៃទេសចរណ៍ធម្មជាតិសម្រាប់ភ្ញៀវទេសចរអាចដើរកំសាន្តបានគ្រប់ទីតាំងទាំងនេះ។




រូបភាព៤.២៖ទីប្រជុំកោះរួមទាំងកោះក្របីមើលពីឆ្នេរសមុទ្ររាម

ផែនទីបង្ហាញពីតាំងទីនិយោគកោះក្របី ខេត្តព្រះសីហនុ




រូបភាព៤.៣៖ រយៈចំងាយនៃកោះក្របីធៀបទៅនឹងកោះឬតំបន់ដែលនៅជុំវិញ

## ៤.៤.២ ព្រំប្រទល់នៃគម្រោងអភិវឌ្ឍន៍

គម្រោងអភិវឌ្ឍន៍ផ្ទះលំហែកាយកោះក្របី មានទីតាំងស្ថិតក្នុងភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលមានព្រំប្រទល់ខាងជើងជាប់សមុទ្រ ខាងកើតជាប់សមុទ្រ ខាងត្បូងជាប់សមុទ្រ និងខាងលិចជាប់សមុទ្រ។



រូបភាព៤.៤៖ ទិដ្ឋភាពកោះក្របីពីទិសខាងត្បូង

#322P, St.271Z, Sk.Terk Tla, Khan Rasey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៤.៥៖ទិដ្ឋភាពកោះក្របីពីទិសខាងជើង



រូបភាព៤.៦៖ ទិដ្ឋភាពកោះក្របីពីទិសខាងលិច



រូបភាព៤.៧៖ទិដ្ឋភាពកោះក្របីពីទិសខាងកើត

## ៤.៥ គោលបំណង នៃការអនុវត្តគម្រោង

ការបង្កើតគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី ក្នុងតំបន់កោះក្របីមានគោលបំណង៖

→ បង្កើនការវិនិយោគ លើវិស័យទេសចរណ៍សម្រាប់ខេត្តព្រះសីហនុ និងប្រទេសជាតិទាំងមូល

→ បង្កើនប្រាក់ចំណូលចូលរដ្ឋ តាមរយៈការយកពន្ធពីគម្រោងវិនិយោគ និងផ្នែកផ្សេងៗទៀតដែលពាក់ព័ន្ធ

→ ផ្តល់ជូននូវកាលានុវត្តន៍ការងារដល់ប្រជាពលរដ្ឋក្នុងតំបន់ ក្នុងគោលបំណងចូលរួមក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

## ៤.៦ គោលការណ៍ នៃការអភិវឌ្ឍន៍គម្រោង

→ កាត់បន្ថយការប៉ះពាល់ជាអប្បបរមា ទៅដល់ទេសភាពធម្មជាតិនៃកោះក្របី

→ រាល់អគារ និងសំណង់ផ្សេងៗ មានលក្ខណៈធម្មជាតិ និងស៊ីគ្នាជាមួយទេសភាពជុំវិញ ដោយមិនធ្វើឲ្យប៉ះពាល់ចំពោះសោភ័ណ្ឌភាពធម្មជាតិនៃកោះឡើយ។

→ ទាញយកសក្តានុពលធម្មជាតិដែលមានស្រាប់ ដើម្បីធ្វើជាកន្លែងកំសាន្ត ដូចជា ថ្មផ្ទាំងសីលាធំៗ ល្អាង ដើមឈើ ឆកសមុទ្រ ។ល។

→ តំបន់សាធារណៈ និងតំបន់ឯកជន គួរតែបែងចែកផ្សេងពីគ្នាអោយបានច្បាស់លាស់។

→ ផ្តល់អោយភ្ញៀវនូវភាពឯកជនដាច់ដោយឡែកតាមផ្ទះលំហែកាយនីមួយៗ ដែលអាច មានពេលវេលាច្រើន សម្រាប់ការស្នាក់នៅផ្ទាល់ខ្លួន ដោយមិនមានការរំខានជាមួយ បុគ្គលិក និងភ្ញៀវផ្សេងទៀត។

→ ការស្នាក់នៅក្នុងផ្ទះលំហែកាយនេះ មិនដូចការស្នាក់នៅតាមសណ្ឋាគារធម្មតាទេ ដោយ តាមផ្ទះលំហែកាយនីមួយៗមិនគួរមានការចេញចូលដោយគ្មានការអនុញ្ញាតទេ។

→ រក្សាទុកនូវទេសភាពធម្មជាតិអោយបានច្រើនជាអតិបរមា។ កន្លែងទាំងឡាយដែលនៅ ក្បែរអាងហែលទឹក និងភោជនីយដ្ឋាន គួរតែមានហ៊ុំព័ទ្ធទៅដោយវាលស្មៅពណ៌បៃតង ស្រស់ស្អាត និងទីធ្លាក្រាលក្តារ ដើម្បីអោយភ្ញៀវអាចមានឱកាសដើរដោយជើងទទេរ បាន។

→ ការបំរើសេវា គួរតែមិនមានការរំខាន ប៉ុន្តែអោយរហ័សទាន់ចិត្ត ហើយមានប្រសិទ្ធិភាព។ បើសិនជាភ្ញៀវត្រូវការអ្វីមួយ សេវាកម្មនឹងយកទៅដល់ភ្លាម មិនឲ្យទាស់ចិត្ត។

## ៤.៧ ការប្រើប្រាស់ដីនៅក្នុងតំបន់គម្រោងអភិវឌ្ឍន៍

ការប្រើប្រាស់ដីសម្រាប់អភិវឌ្ឍគម្រោងនេះ ត្រូវបានធ្វើឡើងស្របទៅតាមបទដ្ឋាន បច្ចេកទេសស្ថាបត្យកម្ម និងវិស្វកម្មផ្តល់ជំនួយបច្ចេកទេសរបស់ក្រុមហ៊ុនសិក្សាគំរូប្លង់ដែលមាន បទពិសោធន៍ខ្ពស់ក្នុងការគូសប្លង់អភិវឌ្ឍគម្រោងធំៗជាច្រើន។ **រមណីយដ្ឋានកោះក្របី** មាន ទំហំដីសរុបសម្រាប់អភិវឌ្ឍន៍ចំនួន **១០ហិកតា** ដែលបានបែងចែកជា៣តំបន់សំខាន់ៗគឺ តំបន់ទី១: គម្រោងសាងសង់ផ្ទះលំហែកាយ(៧៥.០០០ម$^2$) តំបន់ទី២: គឺជាតំបន់គម្រោងសេវាកម្ម (១០.០០០ម$^2$)តំបន់ទី៣: គឺជាទីកន្លែងសម្រាប់ដាក់សម្ភារៈផ្សេងៗ (១៥.០០០ម$^2$) ។ ចំណែកឯ ត្រើយម្ខាងនៅឆ្នេរសមុទ្ររាម គឺជាតំបន់ទី៤ និងទី៥ មានក្រឡាផ្ទៃសរុប ១៥០០ម$^2$ (៦០ម ×២៥ម) ដែលតំបន់ទី៤ មានផ្ទៃក្រឡាសរុប (១.០០០ម$^2$)ជាទីតាំងសម្រាប់គម្រោងចំណតឡាន និងកំពង់ផែ ដើម្បីរង់ចាំការមកដល់របស់ភ្ញៀវ។ ចំណែកឯតំបន់ទី៥មានផ្ទៃក្រឡាសរុប៥០០ ម៉ែត្រការ៉េ ដែលនឹងសាងសង់កន្លែងដាក់សម្ភារៈ/កន្លែងបច្ចេកទេស។

តារាង៤.១៖ ការបែងចែកដីសម្រាប់ប្រើប្រាស់ក្នុងតំបន់គម្រោងទាំង៥

| តំបន់ | ទីតាំង | ឈ្មោះគម្រោង | ចំនួន | ក្រឡាផ្ទៃដី | ប្រើប្រាស់ដី% |
|---|---|---|---|---|---|
| ទី១ | លើកោះក្របី | ផ្ទះលំហែកាយ | ៤០ | - ក្រឡាផ្ទៃសរុប៖ ៧៥.០០០ម២<br>- ក្រឡាផ្ទៃប្រើប្រាស់សម្រាប់អគារ៖ ៦.៤៦៤ម២ | ៧៥% |
| ទី២ | | **តំបន់សាធារណ:៖**<br>- ភោជនីយដ្ឋាន២<br>- អាងហែលទឹក១<br>- ស្ប៉ា/កន្លែងហាត់ប្រាណ ១<br>- ហាងលក់ទំនិញ ១<br>- កន្លែងទទួលភ្ញៀវ១<br>- សួនច្បារ និងកន្លែងសកម្មភាពផ្សេងៗ | | -ក្រឡាផ្ទៃសរុប៖១០.០០០ម២<br>- ក្រឡាផ្ទៃប្រើប្រាស់សម្រាប់អគារ៖ ២.០៦០ម២ | ១០% |
| ទី៣ | | **តំបន់សេវាកម្ម(លើកោះ)៖**<br>- បន្ទប់បុគ្គលិកប្រុសស្រី<br>- ឃ្លាំងសម្ភារ:<br>- ផ្ទះបាយ បន្ទប់ទឹក<br>- កន្លែងធ្វើជីកំប៉ុស<br>- អាងប្រព្រឹត្តិកម្មសំណល់រាវ<br>- កន្លែងផ្សេងៗ)<br>-កន្លែងដាក់ម៉ាស៊ីនភ្លើង | | - ក្រឡាផ្ទៃសរុប៖១៥.០០០ម២<br>- ក្រឡាផ្ទៃប្រើប្រាស់សម្រាប់អគារ៖ ១.៦២០ម២ | ១៥% |
| **សរុប** | | | | **១០០.០០០ម២=១០ហិកតា**<br>**ក្រឡាផ្ទៃប្រើប្រាស់សម្រាប់អគារ:**<br>**១០.១៤៤ម២≈ ១.១ហិកតា** | **១០០%** |
| ទី៤ | ដីគោក (ជាប់ឆ្នេរសមុទ្រភាម) | **កំពង់ផែ និងចំណតឡាន៖**<br>- កន្លែងទទួលភ្ញៀវ កន្លែងផ្ញើសម្ភារ:<br>- កំពង់ផែ<br>- ចំណតឡាន | | -ក្រឡាផ្ទៃសរុប៖១.០០០ម២<br>- ក្រឡាផ្ទៃប្រើប្រាស់សម្រាប់អគារ៖ ១.០០០ម២ | ៣៣,៣៣% |
| ទី៥ | | **កន្លែងដាក់សម្ភារ:/កន្លែងបច្ចេកទេស៖**<br>- បន្ទន់អនាម័យ<br>- ឃ្លាំងសម្ភារ:<br>- បន្ទប់បណ្តុះបណ្តាលបុគ្គលិក<br>- ចំណតម៉ូតូបុគ្គលិក | | -ក្រឡាផ្ទៃសរុប៖៥០០ម២<br>- ក្រឡាផ្ទៃប្រើប្រាស់សម្រាប់អគារ៖ ៤០០ម២ | ៦៦,៧៧% |

| | | | | | |
|---|---|---|---|---|---|
| | | - ការិយាល័យគណនេយ្យ<br>- រោងជាងជួសជុលកាណូត<br>- ទូរទឹកកក ទូរត្លាសេ<br>- កន្លែងដាក់សម្រាម | | | |
| | | សរុប | | ក្រឡាផ្ទៃសរុប៖ ១.៨០០ម² | ១០០% |




ក្រហ្វិក៩.១៖ការបែងចែកដីសម្រាប់ប្រើប្រាស់ក្នុងតំបន់លើកោះ




ក្រហ្វិក៩.២៖ ការបែងចែកដីសម្រាប់ប្រើប្រាស់ក្នុងតំបន់ដីគោក (ឆ្នេរសមុទ្ររាម)

#322P, St.271Z, Sk.Terk Tla, Khan Resey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com




រូបភាព៩.៨៖ ការបែងចែកប្រើប្រាស់ដីក្នុងតំបន់គម្រោងទាំង៥ទីតាំង

#322P, St.271Z, Sk.Terk Tla, Khan Resey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# គម្រោងប្លង់អភិវឌ្ឍន៍លើកោះ

## ៤.៨ គម្រោងប្លង់មេនៃតំបន់អភិវឌ្ឍន៍លើកោះ

ការរៀបចំគម្រោងប្លង់មេនៃតំបន់អភិវឌ្ឍន៍គឺផ្អែកទៅលើលក្ខណៈធម្មជាតិដែលមានស្រាប់នៅលើកោះ។ តាមទិន្នន័យនៃការសិក្សា លក្ខណៈភូមិសាស្ត្រ និងសណ្ឋានដីគឺតំបន់កោះទាំងមូលមានលក្ខណៈទីទួលខ្ពស់ មិនរាបស្មើរ ចំណែកឯមាត់ច្រាំងនៃឆ្នេរជុំវិញកោះមានទឹកជ្រៅ សំបូរដុំថ្មច្រើន និងមិនមានខ្សាច់លេង។ ដូច្នេះ ការរៀបចំអភិវឌ្ឍន៍តំបន់កោះក្របីឲ្យបានល្អ ត្រូវតែចាំបាច់រៀបចំសិក្សាដី នីវ៉ូ ភូមិសាស្ត្រ និងលក្ខណៈធម្មជាតិ ដែលមាននៅលើកោះនេះលំអិតជាមុនសិន ទើបចាប់ផ្តើមកំណត់បែងចែកគម្រោងប្លង់ទៅតាមតំបន់នីមួយៗ។

ក្រុមហ៊ុន **អតីប៊ី** បានបែងចែកផ្ទៃកោះជាបីតំបន់សំខាន់ៗ ដោយមានផ្ទៃដីសរុប១០ហិកតា។ តំបន់ទី១មានផ្ទៃដីសរុបចំនួន **៧,៥ហិកតា** ជាតំបន់សំបូរទៅដោយព្រៃធម្មជាតិ ដែលមានមុខកាត់ឈើមិនលើសពី៣០ស.ម គម្រោងអភិវឌ្ឍន៍បានកំណត់តំបន់នេះរក្សាទុកអភិវឌ្ឍន៍ជាផ្ទះសំណាក់លំហែកាយបែបធម្មជាតិ។ តំបន់ទី២ មានផ្ទៃសរុប **១ហិកតា** ជាតំបន់មាត់ច្រាំងនៃកោះ ដែលមានផ្ទៃជំរាលទាបល្មម គឺរក្សាទុកជាតំបន់សាធារណៈ ដែលមានអគារភោជនីយដ្ឋានបណ្ណាល័យ កន្លែងឈប់សម្រាករបស់ភ្ញៀវ។ល។ ចំណែកឯ តំបន់ទី៣មានផ្ទៃសរុប **១,៥ហិកតា** ទុកសម្រាប់អភិវឌ្ឍន៍ជាតំបន់រដ្ឋបាល និងសេវាកម្ម ដែលមានគម្រោងអគារប៉ូលីស សន្តិសុខ រោងម៉ាស៊ីនភ្លើង កន្លែងចំរោះទឹកស្អុយ កន្លែងផ្គត់ផ្គង់ទឹកស្អាត រួមទាំងផែមួយកន្លែងសម្រាប់ទទួលភ្ញៀវដែលមកស្នាក់នៅលើកោះនេះ។

### ៤.៨.១ គម្រោងសាងសង់ផ្ទះលំហែកាយធម្មជាតិ

គម្រោងរៀបចំផ្ទះលំហែកាយចំនួន **៤០ខ្នង** (40Villas) ស្ថិតនៅក្នុងកំពស់នីវ៉ូផ្សេងៗគ្នាធៀបទៅនឹងនីវ៉ូទឹកសមុទ្រ ដែលអាចមើលឃើញទេសភាពផ្ទៃសមុទ្រយ៉ាងស្រស់ស្អាត។ផ្ទៃក្រឡាសម្រាប់សាងសង់អគារនីមួយៗនៃផ្ទះលំហែកាយមានចំនួន**១៦១,៦ម៉ែត្រការ៉េ** ដែលត្រូវបែងចែកជា២គឺ តួផ្ទះមានក្រឡាផ្ទៃសរុប**៩៦,៦ម៉ែត្រការ៉េ** និងកន្លែងហែលទឹក**៦៥ម៉ែត្រការ៉េ**។ ផ្ទះលំហែកាយនីមួយៗទាំងអស់នេះ ស្ថិតនៅទីតាំងមួយដាច់ពីគ្នាដើម្បីផ្តល់ភាពឯកជន និងដាច់ដោយឡែកពីគ្នា។ ផ្ទះលំហែកាយទាំងអស់ នឹងហ៊ុំព័ទ្ធដោយទេសភាពធម្មជាតិដូចជា ដើមឈើ ទេសភាពព្រៃបៃតង ផ្ទាំងថ្ម និងទិដ្ឋភាពសមុទ្រ។ ផ្ទះលំហែកាយទាំងអស់នឹងមានសាងសង់បន្ទប់ដេក បន្ទប់ទឹកក្នុង អាងហែលទឹកមុខផ្ទះ និងកន្លែងសម្រាប់សំរាកលំហែកាយដែលអាចមើលឃើញទិដ្ឋភាពជុំវិញ។ ជំបូលផ្ទះលំហែកាយនឹងសាងសង់ឲ្យមានលក្ខណៈរាបស្មើដើម្បីដាំផ្កា និងរុក្ខជាតិលំអរនៅតាមដំបូលផ្ទះលំហែនីមួយៗ។ ផ្ទះទាំងនេះត្រូវបានរៀបចំតាមលក្ខណៈលំអិតខាងក្រោមៈ

- ចំនួនផ្ទះដែលត្រូវសាងសង់ :៤០ខ្នងផ្ទះ (40Villas)
- ក្រឡាផ្ទៃសាងសង់ផ្ទះ : ៩៦,៦ម៉ែត្រការ៉េ
- កំពស់ផ្ទះ : ជាន់ផ្ទាល់ដី
- ផ្ទៃក្រឡាបន្ទប់ដេក : ២២,៥ម៉ែត្រការ៉េ
- ផ្ទៃក្រឡាបន្ទប់ទទួលភ្ញៀវ : ១៩,៣ម៉ែត្រការ៉េ
- ផ្ទៃក្រឡាបន្ទប់ទឹក : ១៨,៩ម៉ែត្រការ៉េ
- ផ្ទៃក្រឡាបាយនីយដ្ឋាន : ២៨,៩ម៉ែត្រការ៉េ
- ផ្ទៃក្រឡាសរុបកន្លែងហែលទឹក :នៅខាងមុខផ្ទះ (៦៥ម៉ែត្រការ៉េ)
- ផ្ទៃក្រឡាអាងហែលទឹក : ២៨ម៉ែត្រការ៉េ
- ការស្នាក់នៅ : លក្ខណៈគ្រួសារ មិត្តភក្តិនិងគូរស្នេហ៍ដែល ទើបរៀបអាពាហ៍ពិពាហ៍រួច
- ចំនួនមនុស្សស្នាក់នៅ : ២ទៅ៤នាក់
- ការរក្សាទុកព្រៃ : ៨០% ព្រៃព័ទ្ធជុំវិញ (ព្រៃដែលមានស្រាប់)
- ផ្ទៃដំបូល : រាបស្មើដែលអាចចាប់បន្ទះស្រូបពន្លឺព្រះអាទិត្យបាន។ ដាក់ទរ ដើម្បីប្រមូលទឹកភ្លៀងសម្រាប់ ប្រើប្រាស់។
- រចនាបទខាងក្នុង : ប្រើប្រាស់សម្ភារៈទំនើប
- ទិដ្ឋភាពជុំវិញផ្ទះ : មិនមានការរំខាន ផ្តល់នូវអារម្មណ៍ស្ងប់ស្ងាត់ អាចមើលឃើញទេសភាពធម្មជាតិព្រៃព័ទ្ធជុំវិញ ថ្មាំងថ្ម និងទិដ្ឋភាពសមុទ្រដ៏ធំល្វឹងល្វើយ។

построено | проект завершен | в работе | перспектива




| RPB-investment Co., Ltd | KOH KRABEY | GENPLAN | Схема размещения объектов с перспективой 11-12.2012 г. | Прежежецкий | | 20.12.2012 |
|---|---|---|---|---|---|---|




រូបភាព៤.១០៖ គម្រោងប្លង់នៃគំរូផ្ទះលំហែកាយ



រូបភាព៤.១១៖ គំរូផ្ទះលំហែកាយមើលពីមុខ (រូប3D)

#322P, St.271Z, Sk.Terk Tla, Khan Rosey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៤.១២៖ គំរូផ្ទះលំហែកាយមើលពីលើ(រូប3D)



រូបភាព៤.១៣៖ គំរូផ្ទះលំហែកាយមើលពីចំហៀង(រូប3D)



រូបភាព៤.១៤៖ គំរូផ្ទះលំហែកាយមើលពីក្រោយ(រូប3D)



រូបភាព៤.១៥៖ គំរូផ្ទះលំហែកាយមើលពីក្នុង(រូប3D)



រូបភាព៤.១៦៖គំរូផ្ទះលំហែកាយដែលបានសង់រួច



រូបភាព៤.១៧៖ការដាំរុក្ខជាតិលំអរនៅលើដំបូលផ្ទះលំហែកាយ

ក. ការពិពណ៌នាអំពីបន្ទប់ដេក

បន្ទប់ដេកត្រូវបានសាងសង់លើផ្ទៃក្រឡា**២២,៥ម៉ែត្រការ៉េ**ដែលមានទីតាំងជាប់បន្ទប់ទឹក។ សម្ភារៈក្នុងបន្ទប់ដេកមាន គ្រែមានទំហំ**១៥,១ម៉ែត្រការ៉េ**កន្លែងផ្លាស់សំលៀកបំពាក់ និងទូដាក់សំលៀកបំពាក់**៧,៤ម៉ែត្រការ៉េ** មានទូរទស្សន៍ខ្សែកាប៊ និងបំពាក់ម៉ាស៊ីនត្រជាក់។ រាល់សម្ភារៈដែលប្រើប្រាស់ក្នុងបន្ទប់ដេកនឹងប្រើប្រាស់សម្ភារៈមានអនាម័យ និងទំនើប ដែលមានតម្រូវការថាមពលតិច។ សម្រាប់បន្ទប់ដេកនេះ គឺយកខ្យល់ធម្មជាតិក៏បាន ប្រើម៉ាស៊ីនត្រជាក់ក៏បាន (AC)។



រូបភាព៤.១៨៖បន្ទប់គេងគំរូដែលបានសង់រួច

ខ. ការពិពណ៌នាអំពីបន្ទប់ទទួលភ្ញៀវ

បន្ទប់ទទួលភ្ញៀវនឹងសាងសង់ជាប់បន្ទប់ដេក ដែលមានផ្ទៃសាងសង់សរុប**១៩,៣ម៉ែត្រការ៉េ**។ ក្នុងបន្ទប់ទទួលភ្ញៀវនឹងរៀបចំ ដាក់សាឡុង តុ ទូរទស្សន៍ខ្សែរកាប។ បន្ទប់ទទួលភ្ញៀវនេះ គឺជាកន្លែងដែលអាចអង្គុយលេង ជជែកពិភាក្សា មើលទូរទស្សន៍ ឆែកអ៊ីនធឺណែត មុនពេលចូលសម្រាក។

#322P, St.271Z, Sk.Terk Tla, Khan Rosey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៤.១៩៖បន្ទប់ទទួលភ្ញៀវគំរូដែលបានសង់រួច

គ. ការពិពណ៌នាអំពីបន្ទប់ទទួលទានអាហារ

កន្លែងទទួលទានអាហារនឹងសាងសង់នៅលើរានហាលខាងមុខផ្ទះ ដែលមានផ្ទៃក្រឡាសរុប**២៨,៩ម៉ែត្រការ៉េ**។ បន្ទប់ញ៉ាំអាហារ មានដាក់ទូទឹកកកដែលមានភេសជ្ជៈគ្រប់ប្រភេទ កាហ្វេ តែ និងអាហារសំរ៉ន់ផ្សេងៗទៀត។ ម្យ៉ាងទៀតកន្លែងញ៉ាំអាហារនេះ មានតុ និងកៅអីដែលភ្ញៀវទេសចរណ៍អាចអង្គុយញ៉ាំអាហារ ពិសាកាហ្វេ ជជែកពិភាក្សា គយគន់ទេសភាពព្រៃព្រឹក្សា ទិដ្ឋភាពសមុទ្រ និងស្រូបខ្យល់អាកាសបរិសុទ្ធ។ ម្យ៉ាងទៀតភ្ញៀវទេសចរណ៍ ក៏អាចកុម៉ង់អាហារទាំងបីពេលសម្រាប់ញ៉ាំនៅទីនេះ ដោយមិនចាំបាច់ទៅញ៉ាំនៅភោជនីយដ្ឋានក៏បានដែរ។



រូបភាព៨.២០៖គំរូកន្លែងអង្គុយលំហែខាងមុខផ្ទះលំហែកាយដែលបានសង់រួច

### ឃ. ការពិពណ៌នាអំពីបន្ទប់ទឹក

ក្រៅពីការរៀបចំខាងលើ ក៏មានការរៀបចំបន្ទប់ទឹកប្រកបដោយអនាម័យផងដែរ ដែលមានផ្ទៃក្រឡាសរុប**១៨,៩ម៉ែត្រការ៉េ**។ នៅក្នុងបន្ទប់ទឹកនេះមានបំពាក់នូវសម្ភារៈទំនើបដែលគិតគូរទៅលើផលិតកម្មស្អាត (Cleaner Production) មានសម្ភារៈដូចជា ម៉ាស៊ីនទឹកក្ដៅ-ទឹកត្រជាក់ អាងមុជទឹក ហ្សាក់កូហ្ស៊ី កន្លែងលាងដៃ អាងងូតទឹក ឡាវ៉ាបូចំនួនពីរបង្គន់មួយ ស្នូរហាលសំលៀកបំពាក់កញ្ចក់ តុសំអាងជាដើម។បន្ទប់ទឹកនេះនឹងសាងសង់ជាប់បន្ទប់ដេក ដើម្បីងាយស្រួលប្រើប្រាស់នាពេលរាត្រី។



រូបភាព៤.២១៖គំរូបន្ទប់ទឹកដែលបានរៀបចំរួច

### ង. ការពិពណ៌នាអំពីអាងហែលទឹក

ដើម្បីឲ្យការស្នាក់នៅកាន់តែសប្បាយរីករាយ គម្រោងនឹងសាងសង់អាងហែលទឹកនៅខាងមុខផ្ទះដែលមានផ្ទៃក្រឡាសរុប **៦៥ម៉ែត្រការ៉េ**ក្នុងនោះផ្ទៃក្រឡារបស់អាងផ្ទុកទឹកមាន ២៨ ម៉ែត្រការ៉េ (៨×៣,៥ម)។ នៅលើទីតាំងអាងហែលទឹកនេះមាន កន្លែងលាងជំរះកាយបន្ទាប់ពីហែលទឹករួច និងគ្រែដេក ដែលអាចដេកហាលថ្ងៃ អានសៀវភៅ គយគន់ទេសភាព ស្រូបខ្យល់អាកាសបរិសុទ្ធហើយថែមទាំងអាចបរិភោគអាហារបានទៀត។




រូបភាព៤.២២៖ ប្លង់បាត នៃអាងហែលទឹកជាប់ផ្ទះលំហែកាយ



រូបភាព៤.២៣៖គំរូអាងហែលទឹកខាងមុខផ្ទះលំហែកាយដែលបានសង់រួច

៣.៨.២ គម្រោងប្លង់មេនៃតំបន់ទី២ (តំបន់សាធារណៈលើកោះ)

តំបន់សាធារណៈ មានន័យថាជាតំបន់ដែលរៀបចំឡើងដើម្បីបម្រើសេវាសាធារណៈដល់ភ្ញៀវទេសចរដែលមកកំសាន្ត ឬស្នាក់នៅក្នុងសណ្ឋាគារនៅលើរមណីយដ្ឋានកោះក្របីនេះ។ តំបន់នេះនឹងរៀបចំឡើងនៅក្នុងភាគខាងជើងនៃកោះ។តំបន់សាធារណៈនេះរួមមានសាងសង់ភោជនីយដ្ឋាន បានីយដ្ឋាន ស្ប៉ា អាងហែលទឹក បណ្ណាល័យ កន្លែងសិល្បៈឬសម្តែងផ្សេងៗ កន្លែងហាត់ប្រាណ ហាងលក់សំលៀកបំពាក់ជាដើម។

ក. ការប្រើប្រាស់ដីក្នុងតំបន់ទី២

តំបន់ទី២មានផ្ទៃដីសរុប**១០,០០០ម៉ែត្រការ៉េ** (១ហិកតា) ប៉ុន្តែផ្ទៃដីប្រើប្រាស់សម្រាប់សាងសង់អគារមានត្រឹមតែ **២,០៦០ម៉ែត្រការ៉េ**ប៉ុណ្ណោះ។ ក្រៅពីផ្ទៃដីប្រើប្រាស់សម្រាប់សាងសង់អគារ គម្រោងអភិវឌ្ឍន៍នឹងរក្សាធនធានបរិស្ថានដែលមានស្រាប់ទាំងនោះ ដើម្បីឲ្យបរិស្ថានក្នុងតំបន់គម្រោងមានលក្ខណៈធម្មជាតិពិតៗដែលអាចទាក់ទាញភ្ញៀវទេសចរមកលំហែកាយ។ ផ្ទៃក្រឡាដែលនឹងសាងសង់សម្រាប់គម្រោងនីមួយៗរួមមាន៖

តារាង៤.២៖ ការបែងចែកដីប្រើប្រាស់ក្នុងតំបន់ទី២ (លើដីកោះ)

| | |
|---|---|
| ភោជនីយដ្ឋានអាហារបីពេល | ៣០០ម$^{២}$ |
| ភោជនីយដ្ឋានសម្រាប់អាហារពេលល្ងាច | ២០០ម$^{២}$ |
| អាងហែលទឹករួម | ៣៦០ម$^{២}$ |
| ស្ប៉ា/កន្លែងហាត់ប្រាណ | ៣០០ម$^{២}$ |
| បណ្ណាល័យ/កន្លែងសិល្បៈ/កន្លែងសម្តែងសកម្មភាពផ្សេងៗ | ២០០ម$^{២}$ |
| កន្លែងស្រូបយកខ្យល់អាកាស | ២០០ម$^{២}$ |
| សួនផ្កា | ៥០០ម$^{២}$ |
| សរុប | ២.០៦០ម$^{២}$ |

## ខ. ការពិពណ៌នាលំអិតអំពីគម្រោងសាងសង់ក្នុងតំបន់ទី២

### ខ.១ គម្រោងសាងសង់ភោជនីយដ្ឋាន

នៅលើដីកោះគម្រោងភោជនីយដ្ឋានត្រូវបានសាងសង់២កន្លែងដាច់ដោយឡែកពីគ្នា៖

**គម្រោងភោជនីយដ្ឋានទី១៖** ជាភោជនីយដ្ឋានខ្នាតធំមានក្រឡាផ្ទៃសរុប ៣០០ម៉ែត្រការ៉េ ដែលមានសេវាកម្មបានីយដ្ឋានក្នុងនោះផងដែរ។ ភោជនីយដ្ឋាននេះ មានសេវាកម្មបម្រើជូននូវអាហារបីពេល សម្រាប់ភ្ញៀវដែលមកកំសាន្តនៅទីនេះ។ ម៉្យាងទៀតភ្ញៀវទេសចរអាចកុម៉ង់អាហារសមុទ្រស្រស់ៗ ម្ហូបក្តៅៗ ដែលអាចទទួលទានក្នុងភោជនីយដ្ឋានក៏បាន ឬទទួលទាននៅតាមផ្ទះលំហែកាយក៏បាន។ក្រៅពីបំរើនូវសេវាកម្មដ៏សម្បូរបែបខាងលើ គម្រោងភោជនីយដ្ឋានទី១នេះ ក៏មានរក្សាទុកទីធ្លាសម្រាប់រាំលេងកំសាន្តថែមទៀតផង។



រូបភាព៤.២៤៖ គម្រោងប្លង់មេសាងសង់ភោជនីយដ្ឋាន



រូបភាព៤.២៥៖ គម្រោងប្លង់រៀបចំផ្នែកខាងក្នុងនៃភោជនីយដ្ឋាន



រូបភាព៤.២៦៖ភោជនីយដ្ឋានទី១ ដែលកំពុងសាងសង់

**គម្រោងភោជនីយដ្ឋានទី២៖** ជាភោជនីយដ្ឋានសម្រាប់បំរើសេវាអាហារពេលល្ងាច ដែលសាងសង់ក្នុងក្រឡាផ្ទៃត្រឹមតែ២០០ម៉ែត្រការ៉េប៉ុណ្ណោះ។ ភោជនីយដ្ឋាននេះនឹងសាងសង់នៅលើច្រាំងថ្ម២ផ្ទាំងធំៗ ចំពីលើឆ្នេរ ដែលប្រកបដោយទេសភាពល្អបំផុត។ ការសាងសង់ភោជនីយដ្ឋាននេះមានលក្ខណៈពិសេស ដែលភ្ញៀវអាចបរិភោគអាហារពេលល្ងាចថែមទាំងអាចគយគន់ទិដ្ឋភាពសមុទ្រ និងស្រូបយកជំនោរសមុទ្រធ្វើឲ្យអារម្មណ៍ស្រស់ស្រាយ។



រូបភាព៤.២៧៖គម្រោងប្លង់មេសាងសង់ភោជនីយដ្ឋានទី២ (ទិដ្ឋភាពពីខាងមុខ)

#322P, St.271Z, Sk.Terk Tla, Khan Resey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com




រូបភាព៤.២៨៖គម្រោងប្លង់មេសាងសង់ភោជនីយដ្ឋានទី២ (ទិដ្ឋភាពពីខាងក្រោយ)



រូបភាព៤.២៩៖គម្រោងប្លង់មេសាងសង់ភោជនីយដ្ឋានទី២ (ទិដ្ឋភាពពីចំហៀង)



រូបភាព៤.៣០៖គម្រោងប្លង់សាងសង់លក្ខណៈខាងក្នុងនៃភោជនីយដ្ឋានទី២





រូបភាព៨.៣១៖សកម្មភាពសាងសង់ភោជនីយដ្ឋានទី២

## ខ.២ គម្រោងអាងហែលទឹករួម

អាងហែលទឹកនឹងសាងសង់នៅជិតនឹងគម្រោងភោជនីយដ្ឋានហើយនៅជាប់នឹងសមុទ្រ ដែលមានក្រឡាផ្ទៃសរុប ៣៦០ម៉ែត្រការ៉េ។ គម្រោងនេះក៏មានសាងសង់បន្ទប់ទឹក១ និងបន្ទប់ផ្លាស់សំលៀកបំពាក់១ សម្រាប់ផ្តល់សេវាដល់ភ្ញៀវមកហែលទឹកកំសាន្តទីនេះ។ គម្រោងអាងហែលទឹកនឹងសាងសង់នៅក្បែរមាត់សមុទ្រមានភូមិសាស្ត្រជាទេសភាពធម្មជាតិដ៏ល្អ។ ចំពោះមាត់អាងហែលទឹក នឹងរៀបចំឲ្យស៊ីគ្នាជាមួយផ្ទៃសមុទ្រ ដែលលក្ខណៈនេះអាចរំលេចដោយការហៀរទឹក ដូច្នេះវាបង្កើតជាអារម្មណ៍ដូចស្ថិតក្នុងសមុទ្រដ៏ធំទូលាយ។ អាងហែលទឹកនេះ បម្រើសេវាកម្ម២៤ម៉ោង។



រូបភាព៤.៣២៖ប្លង់សាងសង់អាងហែលទឹករួម



រូបភាព៤.៣៣៖អាងហែលទឹករួមកំពុងសាងសង់

## ខ.៣ កន្លែងស្ប៉ា និងកន្លែងហាត់ប្រាណ

កន្លែងស្ប៉ា និងកន្លែងហាត់ប្រាណត្រូវបានរៀបចំរួមគ្នា ដែលមានផ្ទៃក្រឡា ៣០០ម៉ែត្រការ៉េ។ គម្រោងស្ប៉ានេះមានរៀបចំកន្លែងទទួលភ្ញៀវ កន្លែងរង់ចាំ កន្លែងលក់ឥវ៉ាន់ កន្លែងផ្លាស់រួម បន្ទប់ស្ទីម អាងទឹកក្ដៅទឹកត្រជាក់ បន្ទប់ព្យាបាលចំនួន៩(គ្រែមួយ ឬគ្រែពីរ) ដែលនីមួយៗមានហ្សាក់គូហ្ស៊ី បន្ទប់ផ្លាស់សំលៀកបំពាក់ និងបង្គន់អនាម័យ។ ចំណែកឯកន្លែងហាត់ប្រាណ មានបំពាក់នូវម៉ាស៊ីនមួយចំនួនដូចជា ម៉ាស៊ីនរត់ ម៉ាស៊ីនទាក់កង់ លើកដុំដែកជាដើម។




រូបភាព៤.៣៤៖គម្រោងប្លង់សាងសង់អគារស្ប៉ា និងម៉ាស្សា



រូបភាព៤.៣៥៖រូបភាពដែលបានសាងសង់អគារស្ប៉ា និងម៉ាស្សា

### ខ.៨បណ្ណាល័យ/កន្លែងសិល្បៈ/កន្លែងសម្រាប់សកម្មភាពអ្វីមួយ

កន្លែងនេះសាងសង់ក្នុងទំហំ ២០០ម៉ែត្រការ៉េ ដែលសាងសង់ឡើងសម្រាប់ការអានសៀវភៅ សំរាក កន្លែងហាត់យ៉ូហ្គា ថៃឈីជាដើម។ កន្លែងនេះក៏មានរៀបចំថ្នាក់បង្រៀនផ្សេងៗ ដូចជាសិល្បៈ គូររូប និងសកម្មភាពវប្បធម៌ដទៃទៀត។ អគារនេះមានទីតាំងជាប់គ្នាជាមួយអគារស្ប៉ា និងម៉ាស្សា ផ្នែកខាងក្រោយ។



រូបភាព៤.៣៦៖រូបភាពដែលបានសាងសង់អគារបណ្ណាល័យ និងកន្លែងសិល្បៈ

### ខ.៩ កន្លែងលំហែកាយស្រូបយកខ្យល់អាកាស

ដើម្បីឲ្យការកំសាន្តនៅលើកោះ កាន់តែមានភាពសប្បាយរីករាយគម្រោងមានការរៀបចំកន្លែងសម្រាប់ភ្ញៀវទេសចរអង្គុយមើលទេសភាព និងស្រូបយកខ្យល់អាកាសបរិសុទ្ធ និងជាពិសេសគម្រោងមានកន្លែងសម្រាប់ដេកហាលថ្ងៃទៀតផង។ទីតាំងនៃកន្លែងអង្គុយកំសាន្តនេះស្ថិតនៅតំបន់ទី២នៃតំបន់អភិវឌ្ឍន៍។ ក្រៅពីកន្លែងអង្គុយកំសាន្តនេះ គម្រោងបានរៀបចំធ្វើជាកន្លែងដើរលេងកំសាន្ត ជុំវិញកោះ ដែលការរៀបចំនេះ មានចាក់បេតុងបាតក្រោម រួចក្រាលកំរាលឈើដែលភ្ញៀវអាចធ្វើដំណើរបានយ៉ាងងាយស្រួល។ ទេសភាពជុំវិញកោះនេះ សំបូរទៅដោយផ្ទាំងថ្មធំ តូច ដុះពប្រះទឹក លាយឡំជាមួយដើមឈើដុះចន្លោះផ្ទាំងថ្ម និងជំនោរសមុទ្រដ៏បរិសុទ្ធ អាចធ្វើឲ្យអារម្មណ៍មនុស្សស្រស់ស្រាយ បាត់ទុកកង្វល់ ទៅស្នាក់នៅម្តងហើយ ចង់ទៅម្តងទៀត។



រូបភាព៤.៣៧៖ ទីតាំងកន្លែងលំហែកាយស្រូបយកខ្យល់អាកាស



រូបភាព៤.៣៨៖ ទីតាំងដើរលំហែកាយ




រូបភាព៤.៣៩៖តំបន់ទេសភាពជុំវិញកោះក្របី ដែលអាចដើរលំហែកាយ

### ៨.៨.៣ គម្រោងប្លង់មេនៃតំបន់ទី៣

តំបន់ទី៣គឺជាកន្លែងសម្រាប់ផ្តល់នូវការផ្គត់ផ្គង់ផ្សេងៗ សម្រាប់រៀបចំនូវម្ហូបអាហារ ការស្នាក់នៅ ការធ្វើដំណើរម៉ាស៊ីន ការផ្គត់ផ្គង់ទឹកស្អាត ការផ្គត់ផ្គង់អគ្គិសនី បង្គន់អនាម័យ ការទុកដាក់កាកសំណល់រឹង-រាវ ការស្នាក់នៅរបស់បុគ្គលិកជាដើម។

#### ក. ការប្រើប្រាស់ដីក្នុងតំបន់ទី៣

តំបន់សេវាកម្មមានផ្ទៃដីសរុប១៥,០០០ម៉ែត្រការ៉េ ប៉ុន្តែក្រឡាផ្ទៃដីប្រើប្រាស់សម្រាប់សាងសង់អគារមាន១,៦២០ម៉ែត្រការ៉េ ដែលស្ថិតក្នុងតំបន់ទី៣នៃកោះ។នៅក្នុងតំបន់នេះ បែងចែកដីប្រើប្រាស់ជាបីទីតាំងគឺ ការសាងសង់ផែ កន្លែងសម្រាប់ដាក់សម្ភារៈ ឬបច្ចេកទេស និងកន្លែងស្នាក់នៅរបស់បុគ្គលិក។

**តារាង៤.៣៣៖ ការបែងចែកដីប្រើប្រាស់ក្នុងតំបន់សាធារណៈលើកោះ**

| អគារ | ក្រឡាផ្ទៃដីសាងសង់ |
|---|---|
| អគារការិយាល័យ | ១៥០ម² |
| ផែសម្រាប់ផ្នែកបច្ចេកទេស | ១៥០ម² |
| កន្លែងដាក់សម្ភារៈ/កន្លែងបច្ចេកទេស | ៥៧០ម² |
| កន្លែងស្នាក់នៅរបស់បុគ្គលិក | ៧៥០ម² |
| សរុប | ១,៦២០ម² |

#### ខ. គម្រោងសាងសង់ក្នុងតំបន់ទី៣

##### ខ.១ កំពង់ផែនៅលើកោះ

កំពង់ផែនៅលើកោះ នឹងត្រូវរៀបចំក្នុងតំបន់ទី៣សម្រាប់ទទួលការមកដល់នៃភ្ញៀវទេសចរនិងសម្រាប់បម្រើដល់ផ្នែកបច្ចេកទេស។ បច្ចុប្បន្នគម្រោង បានសាងសង់ផែនេះរួចជាស្រេច ដើម្បីសម្រួលដល់ការដឹកជញ្ជូនសម្ភារៈក្នុងដំណាក់កាលសាងសង់។ ម៉្យាងទៀតក្នុងដំណាក់កាលប្រតិបត្តិគម្រោង កំពង់ផែនេះ ប្រើសម្រាប់តម្រូវការដំណើរការរបស់ផ្ទះលំហែកាយដូចជាការដឹកជញ្ជូនទំនិញ សម្ភារៈផ្គត់ផ្គង់ ម្ហូបអាហារ និងដឹងជញ្ជូនភ្ញៀវទេសចរទៅមក។ កំពង់នៅលើកោះនេះ ត្រូវបានសាងសង់នៅភាគខាងកើតនៃកោះ ដែលទីតាំងងាយស្រួលចូលចត និង មានរបាំងការពារនូវការបោកបក់នៃរលក ដែលផែនេះ សាងសង់ក្នុងទំហំ១៥០ម៉ែត្រក្រឡា។

ការដឹកជញ្ជូននេះអាចធ្វើដំណើរតាមទូក កប៉ាល់ និងអូប៉រ ដែលបច្ចុប្បន្នគម្រោងបានរៀបចំរួចជាស្រេច សម្រាប់បំរើសេវាកម្មជូនភ្ញៀវទេសចរ។ គម្រោងរៀបចំទូកល្បឿន (អូរប៉័រ) ចំនួន២គ្រឿង កប៉ាល់ចំនួន១គ្រឿង និងទូកចំនួន២គ្រឿង។ ការធ្វើដំណើរតាមផ្លូវទឹកនេះ ក្រុមហ៊ុនបានគិតគូរ ទៅលើសុវត្ថិភាពនាពេលធ្វើដំណើររបស់ភ្ញៀវ ដោយក្រុមហ៊ុនបានបំពាក់នូវអាវពោង សម្រាប់ភ្ញៀវទេសចរឲ្យបានគ្រប់គ្រាន់។ ម្យ៉ាងទៀត ក្រុមហ៊ុនក៏បានសហការជាមួយកងទ័ពជើងទឹកដែលប្រចាំការនៅឃុំរាម មកជួយសង្គ្រោះ ប្រសិនបើមានទូក ឬអូរប៉័រខូច និងបំរុងនឹងលិច។




រូបភាព៤.៨០៖ ផែនៅលើកោះដែលបានសាងសង់រួច



រូបភាព៤.៤១៖ កប៉ាល់សម្រាប់ដឹកជញ្ជូនសម្ភារៈ



រូបភាព៤.៤២៖ កប៉ាល់សម្រាប់ដឹកជញ្ជូនកម្មករ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៤.៤៣៖អូរប៉េសម្រាប់ប្រើប្រាស់ក្នុងដំណើរការគម្រោង



រូបភាព៤.៤៤៖ទូក សម្រាប់ប្រើប្រាស់ក្នុងដំណើរការគម្រោង

### ខ.២ កន្លែងសម្រាប់ដាក់សម្ភារៈ/កន្លែងបច្ចេកទេស

កន្លែងដាក់សម្ភារៈ ឬកន្លែងបច្ចេកទេស មានទីតាំងស្ថិតនៅជាប់នឹងផែសម្រាប់ដឹកជញ្ជូនសម្ភារៈផ្គត់ផ្គង់ លើកលែងតែការិយាល័យទាំងឡាយណា ដែលនៅជិតកន្លែងទទួលភ្ញៀវ និងកន្លែងដាក់របស់ត្រជាក់នៅជិតផ្ទះបាយ។កន្លែងដាក់សម្ភារៈទាំងអស់ស្ថិតនៅក្នុងកន្លែងតែមួយ ដើរតួនាទីសម្រួលដល់ការចាត់ចែង និងការគ្រប់គ្រងនៃរមណីយដ្ឋាននេះ ហើយរក្សាទុកកន្លែងឲ្យបានធំបំផុតសម្រាប់ភ្ញៀវ និងកន្លែងសាធារណៈផ្សេងទៀតនៅលើកោះ។ ម៉ាស៊ីនថ្ទែទឹក អាងប្រព្រឹត្តកម្មសំណល់រាវ កន្លែងស្តុកកាកសំណល់ ម៉ាស៊ីនភ្លើង ប្រដាប់ទប់ភ្លើង និងការតំឡើងផ្នែកបច្ចេកទេសដទៃទៀត ត្រូវបានរៀបចំឡើងក្នុងតំបន់នេះ។

### ខ.៣ កន្លែងស្នាក់នៅរបស់បុគ្គលិក

កន្លែងស្នាក់នៅរបស់បុគ្គលិក ត្រូវបានរៀបចំឡើងដើម្បីបុគ្គលិកស្នាក់នៅលើកោះតែម្តង ដោយមិនចាំបាច់ទៅវិញទៅមក។កន្លែងស្នាក់នៅនេះ មានការរៀបចំបង្គន់ ទឹកផ្កាឈូក ទូរចាក់សោរសម្រាប់បុគ្គលិកប្រុសស្រី អាហារដ្ឋានបុគ្គលិកនិងផ្ទះបាយ កន្លែងសម្រាកមើលទូរទស្សន៍ និងផែកអ៊ិនធឺណិត។ កន្លែងស្នាក់នៅរបស់បុគ្គលិករួមមាន ផ្ទះល្វែងមាន២បន្ទប់សម្រាប់ប្រធាន ផ្ទះល្វែងសម្រាប់ជំនួយការប្រធាន ផ្ទះល្វែងសម្រាប់អ្នកគ្រប់គ្រងជាន់ខ្ពស់ ផ្ទះល្វែងមួយមានបន្ទប់ចំនួន៣ សម្រាប់អ្នកគ្រប់គ្រងផ្នែកការស្នាក់នៅ និងបន្ទប់ស្នាក់នៅសម្រាប់អ្នកគ្រប់គ្រងផ្ទាល់ចំនួន៥បន្ទប់ (បុគ្គលិក២នាក់ក្នុងមួយបន្ទប់) បន្ទប់សម្រាប់បុគ្គលិកស្នាក់នៅចំនួន៨បន្ទប់ (២-៣នាក់ក្នុងមួយបន្ទប់)។នៅតាមអគារស្នាក់នៅរបស់បុគ្គលិកនីមួយៗ ក៏មានរៀបចំបន្ទប់ទឹក ឬបង្គន់អនាម័យផងដែរ ដើម្បីរក្សាអនាម័យក្នុងការរស់នៅរបស់បុគ្គលិក ក៏ដូចជាបរិស្ថានជុំវិញផងដែរ។

### ខ.៤ អគារពេទ្យ

ដើម្បីបម្រើនូវសេវាកម្មឲ្យកាន់តែប្រសើរ ដល់ការស្នាក់នៅរបស់ភ្ញៀវទេសចរណ៍ និងបុគ្គលិកនៅលើកោះនេះ គម្រោងនឹងសាងសង់អគារពេទ្យមួយកន្លែងដែលមានទីតាំងក្បែរអគារស្នាក់នៅរបស់បុគ្គលិក។ អគារពេទ្យនេះ នឹងមានគ្រូពេទ្យប្រចាំការ២៤ម៉ោង ដែលមានបុគ្គលិកពេទ្យចំនួន៨នាក់ដើម្បីព្យាបាល ឬសង្គ្រោះបន្ទាន់ក្នុងករណីមានអ្នកឈឺដោយប្រការណាមួយនោះ។ ម្យ៉ាងទៀត ក្រុមហ៊ុនក៏បានសហការណ៍ជាមួយ មន្ទីរពេទ្យឯកជននៅក្នុងក្រុងព្រះសីហនុ ដើម្បីដឹកជញ្ជូនអ្នកជំងឺប្រសិនបើអ្នកជំងឺណាមួយឈឺធ្ងន់ធ្ងរ។



រូបភាព៤.៤៥៖ ប្លង់បាតអគារស្នាក់នៅរបស់បុគ្គលិក និងបន្ទប់ពេទ្យ



រូបភាព៤.៤៦៖អគារស្នាក់នៅរបស់បុគ្គលិក និងបន្ទប់ពេទ្យកំពុងសាងសង់

### ៥.៥ ទីស្នាក់ការប៉ុស្ដិ៍ប៉ូលីស ឬសន្តិសុខ

តំបន់កោះក្របីគឺជាតំបន់អេកូទេសចរណ៍មួយកន្លែង ដែលនឹងមានភ្ញៀវទេសចរណ៍ទៅសម្រាកកំសាន្ត ហេតុដូចនេះគម្រោងក៏មានការគិតគូរពីបញ្ហាសន្តិសុខ និងសុវត្ថិភាពក្នុងតំបន់គម្រោងជូនដល់ភ្ញៀវផងដែរ។ គម្រោងនឹងរៀបចំទីស្នាក់ការសន្តិសុខមួយកន្លែង ទីស្នាក់ការសន្តិសុខនេះ នឹងសាងសង់ជាប់នឹងអគារស្នាក់នៅរបស់បុគ្គលិក និងអគារពេទ្យ។

ក្រុមហ៊ុននឹងរៀបចំពេលវេលាធ្វើការងាររបស់សន្តិសុខចំនួន២វេណ គឺពេលថ្ងៃ និងពេលយប់។ ការបែងចែកវេណការងារនេះ គឺដើម្បីឲ្យប្រាកដថា ក្នុងមួយថ្ងៃ (២៤ម៉ោង)មានសន្តិសុខយាមកាម ដើម្បីរក្សាសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវ។គម្រោងនឹងមានតម្រូវការសន្តិសុខប្រមាណពី៥នាក់ទៅ១០នាក់យ៉ាងតិច។ ម្យ៉ាងទៀត ក្រុមហ៊ុននឹងសហការជាមួយ នគរបាលឃុំរាម ដើម្បីជួយអន្តរាគមន៍នៅពេលមានបញ្ហាដោយប្រការណាមួយ។



រូបភាព៥.៤៧៖ ទីស្នាក់ការប៉ុស្ដិ៍ប៉ូលីស ឬសន្តិសុខ

### ៥.៦អគារការិយាល័យនៅលើកោះ

អគារការិយាល័យត្រូវបានសាងសង់នៅក្បែរ អគារសន្តិសុខ និងនៅជិតអគារស្នាក់នៅរបស់បុគ្គលិក។ អគារការិយាល័យត្រូវបានរៀបចំឡើង ដោយមានបន្ទប់ទទួលភ្ញៀវ កន្លែងធ្វើការរបស់បុគ្គលិក និងមានសាងសង់បង្គន់អនាម័យមួយផងដែរ។ អគារការិយាល័យនេះ ត្រូវបានសាងសង់ឡើងក្នុងទំហំ១៥០០ម៉ែត្រការ៉េ ជាន់ផ្ទាល់ដី។



រូបភាព៤.៨៨៖អគារការិយាល័យនៅលើកោះ

Creative Green Design Co., Ltd
Social-Environmental Researchs
Quality Researchers

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# គម្រោងប្លង់អភិវឌ្ឍន៍លើដីគោក
# (ជាប់ឆ្នេរសមុទ្ររាម)

## ៤.៩ គម្រោងប្លង់អភិវឌ្ឍន៍លើដីគោក (ឆ្នេរសមុទ្ររាម)

ដីគោកមានទីតាំងស្ថិតនៅលើក្បាលដីប្រវែង ១៥០០ម៉ែត្រការ៉េ (៦០ម×២៥ម)ដែលនឹងយកមកធ្វើជាកន្លែងសម្រាប់ទទួលភ្ញៀវ កំពង់ផែ និងកន្លែងសម្រាប់ដាក់សម្ភារ:/កន្លែងបច្ចេកទេស។ផ្ទៃដីនេះស្ថិតនៅឆ្នេរសមុទ្ររាម និងមានចំងាយពីកោះក្របី៦គីឡូម៉ែត្រដែលផ្ទៃដីនេះគឺជាដីកម្មសិទ្ធរបស់ក្រុមហ៊ុនផ្ទាល់តាំងពីឆ្នាំ២០០៨។ផ្ទៃដីគោកបែងចែក ជា២តំបន់គឺតំបន់ទី៤ និងតំបន់ទី៥ ដែលតំបន់ទី៤ គឺជាតំបន់សម្រាប់សាងសង់នូវផែ កន្លែងចតឡាន និងបន្ទប់ផ្តល់ព័ត៌មានដល់ភ្ញៀវ ដែលមានផ្ទៃក្រឡា១០០០ម៉ែត្រការ៉េ។ ចំណែកឯ តំបន់ទី៥គឺជាកន្លែងសម្រាប់សាងសង់នូវកន្លែងដាក់សម្ភារ:/កន្លែងបច្ចេកទេសដូចជាឃ្លាំងសម្ភារ: រោងជាងវិស្វកម្ម រោងជួសជុលកាណូត ការិយាល័យគណនេយ្យ ចំណតឡាន/ម៉ូតូរបស់បុគ្គលិក និងកន្លែងផ្ទុកឥន្ធនៈ ដែលមានផ្ទៃក្រឡាសរុប ៥០០ម៉ែត្រការ៉េ។




រូបភាព៤.៤៩៖ គម្រោងសាងសង់ផែ (ដីគោក) មើលពីខាងក្រោយ



រូបភាព៤.៥០៖ គម្រោងសាងសង់ផៃ (ដីគោក) មើលពីចំហៀង



រូបភាព៤.៥១៖ គម្រោងសាងសង់ផៃ (ដីគោក) មើលពីខាងមុខ



រូបភាព៤.៥២៖អគារសាងសង់នៅដីគោក មើលពីខាងក្រោយ



រូបភាព៤.៥៣៖អគារសាងសង់នៅដីគោក មើលពីខាងមុខ

### ៨.៩.១ គម្រោងប្លង់មេនៃតំបន់ទី៤

#### ក. ការប្រើប្រាស់ដីសម្រាប់តំបន់ទី៤

ផ្ទៃដីតំបន់ទី៤មានចំនួន ១០០០ម៉ែត្រការ៉េ ដែលនឹងប្រើប្រាស់សម្រាប់សាងសង់អគារ ៨០០ម៉ែត្រការ៉េ។ ក្នុងទំហំផ្ទៃដីនេះគម្រោងបានប្រើប្រាស់ផ្ទៃដី៥០ម៉ែត្រការ៉េសម្រាប់រៀបចំកន្លែងទទួលភ្ញៀវដែលរៀបដំណើរនឹងទៅកំសាន្តលើរមណីយដ្ឋានកោះក្របី។ ចំណែកឯ ២០០ ម៉ែត្រការ៉េ ប្រើប្រាស់សម្រាប់សាងសង់កំពង់ផែ និង៧៥០ម៉ែត្រការ៉េ ប្រើប្រាស់សម្រាប់សាងសង់ចំណតរថយន្តរបស់ភ្ញៀវ។ ការបែកចែកប្រើប្រាស់ដីក្នុងតំបន់ដីគោកមានដូចតារាងខាងក្រោម៖

**តារាង៨.៨៖ ការបែកចែកដីប្រើប្រាស់សម្រាប់តំបន់ទី៤**

| អគារ | ក្រឡាផ្ទៃសាងសង់ (ម៉ែត្រការ៉េ) |
|---|---|
| កន្លែងផ្តល់ពត៌មាន | ៥០ |
| ផែ | ២០០ |
| ចំណត | ៧៥០ |
| សរុប | ១០០០ |

#### ខ. គម្រោងប្លង់សាងសង់លើតំបន់ទី៤

កន្លែងផ្តល់ពត៌មាន៖ សាងសង់ទំហំ ៥០ម៉ែត្រការ៉េ បំពាក់ដោយម៉ាស៊ីនត្រជាក់ ដែលជាកន្លែងភ្ញៀវត្រូវឆ្លងកាត់ពេលចុះឈ្មោះហើយចំណាយពេលមួយរយៈពេលខ្លី មុនឡើងជិះកាណូតទៅកោះ ឬឡានត្រឡប់ទៅព្រលានយន្តហោះវិញ។ បន្ទប់នេះ ត្រូវធ្វើយ៉ាងណាដើម្បីផ្តល់ចំណាប់អារម្មណ៍ដំបូងដល់ភ្ញៀវចំពោះរមណីយដ្ឋាននេះ។ កន្លែងសម្រាប់ទទួលភ្ញៀវត្រូវមានតុស្វាគមន៍ភ្ញៀវមួយសម្រាប់បំពេញឯកសារផ្សេងៗ កន្លែងរង់ចាំមួយសម្រាប់ភ្ញៀវពី៦-៨នាក់ អង្គុយអានសៀវភៅ ឆែកអ៊ីនធឺណែតបានយ៉ាងស្រួល កន្លែងលក់របស់ហូបបន្តិចបន្តួច និងបន្ទប់ទឹកជាច្រើន។ មានកន្លែងនៅខាងក្រោយផ្ទះមួយសម្រាប់ទុករបស់របរឡេផុតពីភ្នែកភ្ញៀវ។

ផែ៖សាងសង់ភ្ជាប់ទៅនឹងបន្ទប់រង់ចាំ ឬបន្ទប់ទទួលភ្ញៀវ។ គម្រោងរៀបចំផែមួយនៅខាងដីគោក ដែលត្រូវប្រើសម្រាប់ដឹកជញ្ជូនភ្ញៀវផង និងសម្ភារៈផ្គត់ផ្គង់ផង។

ចំណត៖កន្លែងចតឡានមួយនៅខាងមុខកន្លែងរង់ចាំ អាចដាក់ឡានលីម៉ូស៊ីនបានចំនួន ៣គ្រឿងនៅពេលជាមួយគ្នា។



រូបភាព៤.៥៤៖ កន្លែងទទួលភ្ញៀវឬកន្លែងអង្គុយចាំ



រូបភាព៤.៥៥៖ កន្លែងទទួលភ្ញៀវ



រូបភាព៤.៥៦៖ គម្រោងប្លង់កំពុងផែ



រូបភាព៤.៥៧៖កំពង់ផែដែលបានសាងសង់រួច (ជីគោក)

### ៨.៩.២ គម្រោងប្លង់មេនៃតំបន់ទី៥

#### ក. ការប្រើប្រាស់ដីក្នុងតំបន់ទី៥

ទីតាំងនេះ ត្រូវបានសង់ផ្កាច់ចេញកុំឲ្យឃើញ និងលឺសម្លេងដល់កន្លែងទទួលភ្ញៀវ ដើម្បីកុំឲ្យប៉ះពាល់ដល់អារម្មណ៍នៃការធ្វើដំណើររបស់ភ្ញៀវ។ តំបន់ទី៥នេះនឹងមានរៀបចំកន្លែងទទួលសម្ភារៈផ្គត់ផ្គង់ (៣២ម$^2$) ឃ្លាំងសម្ភារៈ (៦០ម$^2$) រោងជាងវិស្វកម្ម (៦៤ម$^2$) រោងជាងជួសជុលកាណូត (៥០ម$^2$) ការិយាល័យផ្នែកធនធានមនុស្ស (២៤ម$^2$) បន្ទប់បណ្តុះបណ្តាលបុគ្គលិក (៤៨ម$^2$) ការិយាល័យគណនេយ្យ (៣២ម$^2$) កន្លែងចតឡាន/ម៉ូតូរបស់បុគ្គលិក (៨០ម$^2$) អាងស្តុកប្រេងឥន្ធនៈសម្រាប់កាណូត (៩ម$^2$)។

តារាង៨.៥៖ ការបែកចែកដីប្រើប្រាស់សម្រាប់តំបន់ទី៥ (ដីគោក)

| អគារ | ក្រឡាផ្ទៃសាងសង់ (ម$^2$) |
|---|---|
| កន្លែងទទួលសម្ភារៈផ្គត់ផ្គង់ | ៣២ |
| ឃ្លាំងសម្ភារៈ | ៦០ |
| រោងជាងវិស្វកម្ម | ៦៤ |
| រោងជាងជួសជុលកាណូត | ៥០ |
| ការិយាល័យផ្នែកធនធានមនុស្ស | ២៤ |
| បន្ទប់បណ្តុះបណ្តាលបុគ្គលិក | ៤៨ |
| ការិយាល័យគណនេយ្យ | ៣២ |
| កន្លែងចតឡាន/ម៉ូតូរបស់បុគ្គលិក | ៨០ |
| បន្ទប់ស្តុកឥន្ធនៈសម្រាប់កាណូត | ៩ |
| សរុប | ៣៩៩ |

#### ខ. គម្រោងសាងសង់ក្នុងតំបន់ទី៥

ការិយាល័យទទួលសម្ភារៈផ្គត់ផ្គង់៖សាងសង់លើផ្ទៃក្រឡា៣២ម៉ែត្រការ៉េដែលទំនិញគ្រប់មុខ សម្ភារៈផ្គត់ផ្គង់ អាហារ និងភេសជ្ជៈសម្រាប់រមណីយដ្ឋាននេះ ត្រូវបានគេដឹកជញ្ជូនយកទៅដាក់នៅកន្លែងទទួល ដែលនៅទីនោះមានគេទទួលខុសត្រូវ សំអាត បើសិនជាចាំបាច់ ហើយបញ្ជូនបន្តទៅដាក់ក្នុងឃ្លាំង ឬទៅលើកោះតែម្តង។

ឃ្លាំងសម្ភារៈ៖ សាងសង់លើផ្ទៃក្រឡា៦០ម៉ែត្រការ៉េ ដែលឃ្លាំងនេះគឺជាកន្លែងដែលសម្ភារៈផ្គត់ផ្គង់ទាំងអស់ត្រូវបានគេរក្សាទុកសិន មុនពេលដឹកជញ្ជូនទៅកោះ។ ឃ្លាំងនេះមាន

កន្លែងដាក់ទំនិញស្ងួត កន្លែងដាក់ភេសជ្ជៈ ទូក្លាសេបញ្ឈរ ទូរទឹកកកបញ្ឈរ និងកន្លែងដាក់ឧបករណ៍ដទៃទៀត។ ម៉្យាងទៀតមានបន្ទប់ដាក់សំរាមចំនួន២សម្រាប់ប្រភេទសំរាមស្ងួត/រាវ ដែលបន្ទប់នីមួយៗមានទំហំ៦ម៉ែត្រការ៉េ។

**រោងជាងវិស្វកម្ម៖** សាងសង់លើទំហំផ្ទៃដី ៦៤ម៉ែត្រការ៉េ ដែលគម្រោងនឹងសាងសង់នៅដាច់ដោយឡែកពីគេកុំឲ្យ លឺសំឡេងរំខានដល់អគារដទៃទៀត។

**រោងជាងជួសជុលកាណូត៖** សាងសង់លើទំហំផ្ទៃដី ៤៨ម៉ែត្រការ៉េ ដែលគម្រោងនឹងសាងសង់នៅដាច់ដោយឡែកពីគេកុំឲ្យ លឺសំឡេងរំខានដល់អគារដទៃទៀត។

**ការិយាល័យផ្នែកធនធានមនុស្ស៖** ការិយាល័យនេះប្រើសម្រាប់ដោះស្រាយសម្រួលដល់រាល់បញ្ហា ផ្នែកធនធានមនុស្សទាំងអស់ ហើយក៏យកមកធ្វើជាកន្លែងសម្រាប់សម្ភាសន៍បេក្ខជនផងដែរ។

**បន្ទប់បណ្ដុះបណ្ដាលបុគ្គលិក៖** សាងសង់លើទំហំផ្ទៃដី ៤៨ម៉ែត្រការ៉េ ដែលស្ថិតនៅជិតការិយាល័យផ្នែកធនធានមនុស្ស ប្រើសម្រាប់បើកវគ្គបណ្ដុះបណ្ដាលដល់បុគ្គលិក ដែលទើបចូលបំរើការថ្មីៗ។ការបណ្ដុះបណ្ដាលនេះ គឺជាកត្តាចាំបាច់សម្រាប់បុគ្គលិក ដើម្បីឲ្យប្រាកដថាបុគ្គិលិកស្ទាត់ជំនាញ ដើម្បីបម្រើសេវាកម្មផ្សេងៗឲ្យបានល្អជូនភ្ញៀវ ដែលមកលេងក្នុងតំបន់គម្រោង។

**ការិយាល័យគណនេយ្យ៖** មានផ្ទៃក្រឡា ៣២ម៉ែត្រការ៉េ គឺជាកន្លែងសម្រាប់គ្រប់គ្រងរាល់ការចំណូល និងចំណាយក្នុងដំណើរគម្រោង។

**កន្លែងចតឡាន/ម៉ូតូរបស់បុគ្គលិក៖** មានផ្ទៃក្រឡា ៨០ម៉ែត្រការ៉េ។ ចំណតនេះ នឹងរៀបចំដាច់ដោយឡែកពីចំណតរបស់ភ្ញៀវទេចរ ព្រោះងាយស្រួលក្នុងការធ្វើចរាចរណ៍ចេញចូល និងងាយស្រួលក្នុងការថែរក្សា។

**បន្ទប់ស្តុកឥន្ធនៈសម្រាប់កាណូត៖** មានផ្ទៃក្រឡា ៩ម៉ែត្រការ៉េ ដែលគម្រោងរៀបចំបន្ទប់នេះឡើងដើម្បីរៀបចំឲ្យសេវាកម្ម ដឹកជញ្ជូន ឬសម្ភារៈមិនមានការយឺតយ៉ាវ។ ប្រេងឥន្ធនៈត្រូវបានស្តុកទុកជាស្រេច ដែលការណូតអាចប្រើប្រាស់តាមតម្រូវការ និងគ្រប់វេលានៃការដឹកជញ្ជូន។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៤.៥៨៖គម្រោងប្លង់អគារបុគ្គលិក (ដីគោក)



រូបភាព៤.៥៩៖ អគារបុគ្គលិកដែលកំពុងសាងសង់ (ដីគោក)

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# គម្រោងរៀបចំហេដ្ឋារចនាសម្ព័ន្ធ

# ៤.១០ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ

## ៤.១០.១ ការរៀបចំប្រព័ន្ធផ្លូវ

មុនការសាងសង់ប្រព័ន្ធផ្លូវក្រុមហ៊ុនបានសិក្សាពីស្ថានភាពដី និងព្រៃឈើយ៉ាងច្បាស់លាស់ដើម្បីបញ្ចៀសការកាប់ព្រៃឈើជាអតិបរមា។ តាមគំរូផ្លូវខាងក្រោម បានបង្ហាញថាក្រុមហ៊ុនមានការគិតគូរពីធនធានព្រៃឈើ ដោយការឈូសឆាយមិនឲ្យប៉ះពាល់ដល់ដើមឈើដែលមានទំហំ២០ស.មឡើងទៅឡើយ។

ប្រព័ន្ធផ្លូវនៅលើកោះ នឹងរៀបចំផ្លូវជាពីរប្រភេទគឺប្រព័ន្ធផ្លូវមេ និងផ្លូវថ្មើរជើង។ ប្រព័ន្ធផ្លូវទី១ គឺជាប្រព័ន្ធផ្លូវមេដែលមានទទឹង៥ម៉ែត្រ និងមានប្រវែង៨៥០ម៉ែត្រជាប្រភេទផ្លូវបេតុង ដែលផ្លូវនេះអាចដឹកជញ្ជូនសម្ភារៈឬទំនិញ និងអនុញ្ញាតឲ្យភ្ញៀវទេសចរអាចជិះកង់បានទៅគ្រប់ទីកន្លែងនៅលើកោះ។ ម្យ៉ាងទៀតប្រព័ន្ធផ្លូវមេនេះ គឺសម្រាប់ការបើកបរឡាន់តូចៗដឹកជញ្ជូនភ្ញៀវទេសចរទៅកាន់កន្លែងកំសាន្តផ្សេងៗ និងទៅកាន់ផ្ទះលំហែកាយនីមួយៗ។

ប្រព័ន្ធផ្លូវទី២ គឺប្រព័ន្ធផ្លូវថ្មើរជើង ដែលមានទទឹង១,៥ម៉ែត្រ ជាប្រភេទផ្លូវបេតុង ដែលនឹងសាងសង់តភ្ជាប់ពីបណ្តាញផ្លូវមេចូលទៅកាន់ផ្ទះលំហែកាយនីមួយៗ។ ប្រព័ន្ធផ្លូវថ្មើរជើងនេះភ្ញៀវទេសចរអាចជិះកង់ ឬធ្វើដំណើរដោយថ្មើរជើងទៅកាន់តំបន់កំសាន្តផ្សេងៗនៅលើកោះបានផងដែរ។

ប្រព័ន្ធផ្លូវទី៣ ជាប្រព័ន្ធផ្លូវព័ទ្ធជុំវិញកោះតែម្តង ដែលប្រព័ន្ធផ្លូវនេះ សាងសង់ឡើងក្នុងគោលបំណងឲ្យភ្ញៀវដើរលេងកំសាន្ត មើលទេសភាពជុំវិញកោះ។ ប្រព័ន្ធផ្លូវនេះ មានទំហំ ១,៥ ម៉ែត្រ សាងសង់ឡើងពីបេតុង និងមានក្រាលឈើពីលើ។ ប្រព័ន្ធផ្លូវនេះ មានលក្ខណៈប្រណិតដែលអាចឲ្យភ្ញៀវដើរកំសាន្តបានយ៉ាងងាយស្រួល។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៨.៦០៖គម្រោងប្លង់ប្រព័ន្ធផ្លូវដែលសាងសង់នៅលើផ្ទៃដីកោះ



រូបភាព៨.៦១៖ គំរូផ្លូវដែលនឹងសាងសង់នៅលើកោះ (បញ្ចៀសរាល់ការកាប់ព្រៃឈើ)



រូបភាព៤.៦២៖សកម្មភាពត្រួសត្រាយបើកប្រព័ន្ធផ្លូវ




រូបភាព៤.៦៣៖ផ្លូវថ្មើរជើងដែលបានសាងសង់រួច



រូបភាព៤.៦៤៖ផ្លូវថ្មើរជើងដែលព័ទ្ធជុំវិញកោះសម្រាប់ដើរកំសាន្ត



រូបភាព៤.៦៥៖ ផ្លូវមេមិនទាន់ចាក់បេតុង

### ៤.១០.២ ការរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

### ក. ដំណាក់កាលសាងសង់

ទឹកស្អាតគឺជាតម្រូវការចាំបាច់ សម្រាប់ការរស់នៅរបស់មនុស្ស និងប្រើប្រាស់ក្នុងការសាងសង់សំណង់។ នៅក្នុងដំណាក់កាលសាងសង់គម្រោងមានតម្រូវការទឹក ប្រហែល៥-១០ ម៉ែត្រគូប/ថ្ងៃ។ តម្រូវការនៃការប្រើប្រាស់ទឹកនេះ គឺប្រើប្រាស់សម្រាប់តែនៅលើការងារសំណង់ប៉ុណ្ណោះ ចំណែកតម្រូវការប្រើប្រាស់ទឹករបស់បុគ្គលិក និងកម្មករ មិនមានទេ គឺបុគ្គលិក និងកម្មករទាំងអស់ត្រូវត្រលប់ទៅផ្ទះវិញរៀងៗខ្លួន បន្ទាប់ពីបញ្ចប់ការងារ។ បច្ចុប្បន្នប្រភពទឹកដែលយកមកប្រើប្រាស់នេះ មានប្រភពមកពីខាងដីគោក ដែលក្រុមហ៊ុនត្រូវដឹកជញ្ជូនទឹកតាមទូកដឹកជារៀងរាល់ថ្ងៃ។ ម្យ៉ាងទៀតក្រុមហ៊ុន រៀបចំដាក់ធុងទឹក នៅតាមបង្គន់អនាម័យ និងគ្រប់ទីតាំងអគារដែលកំពុងសាងសង់ក្នុងតំបន់គម្រោងទាំងអស់។

## ខ. ដំណាក់កាលប្រតិបត្តិគម្រោង

នៅក្នុងដំណាក់កាលប្រតិបត្តិគម្រោងនឹងមានតម្រូវការប្រើប្រាស់ទឹកច្រើន ហេតុដូចនេះ ក្រុមហ៊ុនបានសិក្សាទៅលើជម្រើសនៃប្រភពទឹកចំបង២ គឺទី១ ទឹកក្រោមដី និងទី២ គឺការប្រើម៉ាស៊ីនប្រព្រឹត្តិកម្មទឹកសមុទ្រ។តាមការសិក្សាដោយការជីកអណ្តូងតេស្ត និងយកទឹកដើម្បីវិភាគគុណភាពទឹក បានបង្ហាញថា គុណភាពទឹកក្រោមដីនេះ មិនអាចប្រើប្រាស់បានទេ ព្រោះវាមានសារធាតុអំបិលខ្ពស់។ជម្រើសទី២ គឺក្រុមហ៊ុនបានប្រើប្រាស់ម៉ាស៊ីនចំរាញ់ទឹកប្រៃ ដែលតាមលទ្ធផលនៃការពិសោធន៍បានបង្ហាញថា ទឹកដែលចេញពីម៉ាស៊ីននេះ អាចប្រើប្រាស់បាន ជាទឹកមានគុណភាពល្អ។

ដូចនេះនៅដំណាក់កាលប្រតិបត្តិគម្រោង ក្រុមហ៊ុននឹងប្រើប្រាស់ទឹកស្អាតដែលចេញពីម៉ាស៊ីនចំរាញ់ទឹកប្រៃដើម្បីប្រើប្រាស់ និងផ្គត់ផ្គង់ក្នុងតំបន់គម្រោង។ ក្រៅពីនេះក្រុមហ៊ុនក៏មានផែនការរៀបចំប្រព័ន្ធប្រមូលទឹកភ្លៀង ដែលជាប្រភពទឹកបន្ទាប់បន្សំដើម្បីប្រមូលស្តុកទុកប្រើប្រាស់នារដូវវស្សា និងរដូវប្រាំង។

តាមតារាងខាងក្រោម ប្រសិនបើគម្រោងដំណើរការពេញលេញ នោះតម្រូវការទឹកមានប្រហែលជា**៦៥ម៉ែត្រគូប/ថ្ងៃ**ដែលក្នុងបរិមាណតម្រូវការនៅលើកោះប្រហែល**៥៤ម៉ែត្រគូប/ថ្ងៃ**ដែលនឹងចែកចាយទៅតំបន់ផ្ទះល់ហែកាយ តំបន់សេវាកម្ម តំបន់សាធារណៈ និងតំបន់ផ្សេងៗទៀត។ ចំពោះការស្តុកទឹកទុកនេះ គម្រោងនឹង រៀបចំធុងស្តុកទឹកទុក ដែលមានចំណុះ ៦០០០លីត្រ ចំនួន១០។ បរិមាណទឹកនេះក្រុមហ៊ុននឹងមានលទ្ធភាពផ្គត់ផ្គង់ទឹកឲ្យបានគ្រប់គ្រាន់។

តារាង៤.៦៖ការគណនារកបរិមាណទឹកប្រើប្រាស់ប្រចាំថ្ងៃក្នុងតំបន់អភិវឌ្ឍន៍កោះក្របី

| **តម្រូវការប្រើប្រាស់ទឹកស្អាត ក្នុងរមណីយដ្ឋានកោះក្របី** | | | |
|---|---|---|---|
| តំបន់ | អាំងឌីការទ័រនៃការប្រើប្រាស់ទឹក | ក្រឡាផ្ទៃប្រើប្រាស់(ម$^{២}$) | តម្រូវការទឹក (លីត្រ) |
| **តំបន់លើកោះ:** | | | |
| **ទី១៖** ផ្ទះល់ហែកាយ | ១៥០ល/ន/ថ | ១៦០នាក់ | ២៤.០០០ |
| **ទី២៖** តំបន់សាធារណៈ | ៨ល/ម$^{២}$/ថ | ២.០៦០ម$^{២}$ | ១៦.៤៨០ |
| **ទី៣៖** តំបន់សេវាកម្ម(លើកោះ) | ៨ល/ម$^{២}$/ថ | ១.៦២០ម$^{២}$ | ១២.៩៦០ |
| សរុប | | | ៥៣.៤៤០ |
| **ដីគោក (ជាប់ឆ្នេរសមុទ្រភាម)** | | | |
| **ទី៤៖** កំពង់ផែ និងចំណតឡាន | ៨ល/ម$^{២}$/ថ | ១.០០០ម$^{២}$ | ៨.០០០ |

| | | | |
|---|---|---|---|
| ទី៥៖ កន្លែងដាក់សម្ភារៈ/បច្ចេកទេស | ៨ល/ម$^{២}$/ថ | ៨០០ម$^{២}$ | ៣.២០០ |
| សរុប | | | ១១.២០០ |
| **សរុបរួម** | | | **៦៤.៦៤០លីត្រ =៦៥ម៉ែត្រគូប/ថ្ងៃ** |




រូបភាព៤.៦៦៖ ធុងស្តុកទឹកចំណុះ៣០០លីត្រ ដែលប្រើប្រាស់ក្នុងដំណាក់កាលសាងសង់



រូបភាព៤.៦៧៖ធុងស្តុកទឹកចំណុះ១០០០លីត្រ ប្រើប្រាស់សម្រាប់ដឹកទឹកក្នុងណាក់កាលសាងសង់

→ បច្ចេកទេសប្រព្រឹត្តិកម្មទឹកសមុទ្រ

នៅពាក់កណ្តាលឆ្នាំ២០១០ ការចម្រោះអុលត្រាហាយដ្រូម៉ាស្ទឺ (Hydromaster UltraFiltration) ប្រើប្រាស់បច្ចេកវិទ្យាថ្មីរបស់ក្រុមហ៊ុន លើខិតប័ណ្ណ វេបសាយ និងសម្ភារៈទំនាក់ទំនងផ្សេងៗ។ ទាំងហាយដ្រូម៉ាស្ទឺអន្តរជាតិ និងក្រុមហ៊ុនតាមប្រទេសនីមួយៗ ប្រើប្រាស់បច្ចេកវិទ្យាដែលទាក់ទាញថ្មីនេះ ដែលឆ្លុះបញ្ចាំងពីគុណតម្លៃហាយដ្រូម៉ាស្ទឺ (Hydromaster) ក្នុងការផ្តល់ស្ពេរភាពតម្លៃតាមរយៈដំណោះស្រាយគុណភាពថ្នាក់អន្តរជាតិ ព្រមទាំងមិនប៉ះពាល់ដល់បរិស្ថាន។បច្ចេកវិទ្យាថ្មីនេះ គឺមានលក្ខណៈទំនើប និងស្មុគស្មាញ ព្រមទាំងបង្ហាញពីភាពច្នៃប្រឌិតសម្រាប់មនុស្សជំនាន់ថ្មី ដែលហាយដ្រូម៉ាស្ទឺកាត់បន្ថយចំណាយលើឧបករណ៍ច្រើនតែធានាបាននូវការផ្គត់ផ្គង់ទឹកនៅនឹងកន្លែង និងមាននិរន្តភាព។

ស៊ីម៉េមហ៊ុនក្រុមស និងហាយដ្រូម៉ាស្ទឺអន្តរជាតិ )Memesys and Hydromaster International Pte Ltd)បានពិសោធន៍ ប្រព័ន្ធបន្សាបទឹកប្រៃដោយថាមពលព្រះអាទិត្យ នៅទំនប់ម៉ារីនា )PUC's Marina Barrage ។(ប្រព័ន្ធបន្សាបទឹកប្រៃ )desalination unit) ផលិតបានជាទឹកបរិភោគពីទឹកសមុទ្រប្រទេសសិង្ហបុរីដោយប្រើតែថាមពលព្រះអាទិត្យ។ បន្ទាប់មកប្រព័ន្ធបន្សាបទឹកប្រៃនេះមាននៅលើគេហទំព័រ នៅ ខែកញ្ញា ២០១០។

ប្រៃទឹកបន្សាបបច្ចេកវិទ្យានេះ គឺជាប្រព័ន្ធបន្សាបទឹកដោយមិនប្រើប្រាស់សារធាតុគីមីប្រេងសាំង ឬថាមពលផ្សេងៗទៀតនោះទេ។ អាស្រ័យលើកម្រិតពន្លឺព្រះអាទិត្យ បរិមាណទឹកដែលបានបន្សាប នឹងអាចទទួលបានជាមធ្យម ១០០០ម៉ែត្រគូបក្នុង១ថ្ងៃ។ ប្រព័ន្ធបន្សាបទឹកប្រៃនេះអាចចល័តបានដំណើរការដោយថាមពលព្រះអាទិត្យ ហើយទាមទារការថែទាំសមញ្ញប៉ុណ្ណោះ។ ប្រព័ន្ធបន្សាបទឹកប្រៃនេះ គឺភាគច្រើនគេប្រើប្រាស់នៅតំបន់ដាច់ស្រយាល ដែលខ្វះទឹក និងប្រព័ន្ធធារាសាស្ត្រនានា ។(ឆ្ងាយៗរុករកតំបន់កោះ វាលខ្សាច់ និងតំបន់ .ឌ)

ប្រព័ន្ធចំពោះទំនើបនេះ ដែលអាចទាញយកជាតិប្រៃពីទឹកសមុទ្រ។ ប្រព័ន្ធនេះ បន្សាបទឹកប្រៃ១គូប ដោយប្រើថាមពលព្រះអាទិត្យ ដែលមានប្រសិទ្ធិភាពល្អជាង ប្រព័ន្ធចម្រោះទឹកធម្មតា ពី៣ទៅ៥ដង។ ជាពិសេស ចម្រោះទឹកហាយដ្រូម៉ាស្ទឺនេះ អាចកាត់បន្ថយថាមពលប្រើប្រាស់បានយ៉ាងច្រើន ព្រមទាំងកាត់បន្ថយការចំនាយ និងមិនបន្សល់ការបំពុលក្នុងបរិយាកាស។ ប្រព័ន្ធចម្រោះអុលត្រា គឺជាប្រព័ន្ធMU14-8 របស់ហាយដ្រូម៉ាស្ទឺ ដែលអាចបំលែងកម្រិតតម្រូវការអុកស៊ីសែនជីវៈ នឹងកាត់បន្ថយពី ២០ppm ទៅក្រោម ១ppm ហើយទាញចេញនូវសារធាតុអណ្តែត ដែលធ្វើឱ្យទឹកដែលបានច្រោះស្អាតល្អ។ រន្ធតូចៗដែលមានទំហំ ០.១ទៅ ០.០១មីក្រុន ស្ថិតនៅក្នុងប្រព័ន្ធចម្រោះអុលត្រា ធ្វើឱ្យទឹកដែលប្រើប្រាស់ឡើងវិញ មានសុវត្ថិភាព ហើយគ្មានមេរោគ។ ចំពោះសារធាតុគីមីវិញ គឺមិនបានប្រើប្រាស់ក្នុងដំណើរការចម្រោះនេះទេ។



រូបភាព៤.៦៨៖ប្រព័ន្ធសម្អាតទឹកប្រៃ

ប្រព័ន្ធចំរោះទឹកសមុទ្រ

- ប្រអប់ចម្រោះអូស្មូស (៨០៤០)
- ការត្រួតពិនិត្យចរន្តអគ្គិសនី បំពាក់ដោយ PLC ជាមួយនឹងD.O.L/ប្រព័ន្ធគ្រប់គ្រងចំនួនដង
- ការផ្តល់ឧស្ម័ន និងស្នប់សំពាធ(Feed and Hi-pressure pumps)
- ចំរោះការពារ ទំហំ១មីក្រូម៉ែត
- កុងតាក់បញ្ហាអគ្គិសនីណឹត
- រង្វាស់សំពាធលំហូរចំងាយ ,
- រង្វាស់ជម្រៀបកំដៅ
- ប្រព័ន្ធបង្វិល ,PVC និងប្រព័ន្ធទុយោដែក
- CIP ដែលមានធុង

តារាង៤.៧៖ លក្ខណៈបច្ចេកទេសនៃប្រព័ន្ធសំអាតទឹកប្រៃ

| លក្ខណៈបច្ចេកទេសនៃប្រព័ន្ធចំរោះ | |
|---|---|
| ប្រើប្រាស់ឡើងវិញ | ៣៥៤៥%- |
| សីតុណ្ហភាពដំណើរការ | <៥០°C |

#322P, St.271Z, Sk.Terk Tla, Khan Rasey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| | |
|---|---|
| សំពាធដំណើរការ | < 70 បា |
| ថាមពលអគ្គិសនី | ៣ x ៤១៥ វ៉ុលអេីក៦០/ |
| អតិបរិមា SOI (១៥នាទី( | <៥០ |
| កម្រិតបាស | ៣១០- |
| កម្រិតល្អក់ | <១ ០,NTU |
| កំហាក់ក្លរ | <០ ១,ppm |
| លក្ខណៈពិសេសនៃប្រព័ន្ធចម្រោះ | |
| ប្រភេទ | ស្តើង )Thin Film Composite( |
| សារធាតុ | ប៉ូលីអាមីដ |
| បញ្ចូលភ្លើង | អវិជ្ជមាន |
| សណ្ឋាន | រាងមូល ហ៊ុំព័ទ្ធដោយ FRP |
| ទំហំសំណាញ់ | ៨ ដេស៊ីម៉ែត្រ x ប្រវែង ៤០ |
| តំបន់មានប្រសិទ្ធិភាព | ៣៦៥ ហ្វីតការ៉េសំណាញ់/ |
| កម្រិតលំហូរ | ០/ម៉ែត្រគីប៥,ម៉ោងសំណាញ់/ |

### ៤.១០.៣ ការរៀបចំប្រព័ន្ធបង្ហូរទឹកភ្លៀង

តាមរយៈសណ្ឋានដី និងទីជំរាល កោះនេះមានលក្ខណៈចោទ និងមានកម្ពស់ខ្ពស់បំផុត ៤៩ម៉ែត្រ និងទាបបំផុត៣០ហួតដល់០ម៉ែត្រធៀបនឹងនីវ៉ូទឹកសមុទ្រ។ ការរៀបចំបណ្តាញបង្ហូរទឹកភ្លៀងគឺ ក្រុមហ៊ុនត្រូវបានរៀបចំ ជាស្រេច និងបានគិតគូរពីការហូរច្រោះដី។ ក្រុមហ៊ុនបានរៀបចំប្រព័ន្ធបង្ហូរទឹកភ្លៀងដោយដាក់លូតាមបណ្តោយផ្លូវ រួចរៀបចំឲ្យហូរចូលទៅក្នុងសមុទ្រ។ បច្ចេកទេសនៃការរៀបចំប្រព័ន្ធបង្ហូរទឹកភ្លៀងនេះ ក៏មានរៀបចាក់រនាំង ឬជណ្តើរការពារកុំឲ្យមានការហូរច្រោះដីផងដែរ។



រូបភាព៤.៦៩៖ ប្រព័ន្ធបង្ហូរទឹកភ្លៀងដែលរៀបចំនៅលើកោះ

### ៤.១០.៤ ការរៀបចំរនាំងការពារការហូរច្រោះដី

រនាំងការពារការហូរច្រោះដី ត្រូវបានរៀបចំគ្រប់កន្លែងទាំងអស់តាមទីជំរាល ដែលគិតថាអាចមានការហូរច្រោះដីនៅថ្ងៃអនាគត។ រនាំងការពារការហូរច្រោះដីនេះ ត្រូវបានសាងសង់បត់បែនតាមប្រភេទជំរាល ដើម្បីកាត់បន្ថយរាល់ការឈូសឆាយ និងការកាប់ដើមឈើ។ ប្រភេទសំណង់នៃរនាំងនេះ គឺសាងសង់ឡើងជាប្រភេទបេតុង។





រូបភាព៤.៧០៖ការសាងសង់រនាំងការពារ ការហូរច្រោះដី

### ៤.១០.៨ ការរៀបចំប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី

#### ក. ដំណាក់កាលសាងសង់

ប្រភពអគ្គិសនីដែលនឹងរៀបចំឡើងក្នុងគម្រោងអភិវឌ្ឍន៍កោះក្របីនេះ មានពីរប្រភេទគឺ ការប្រើប្រាស់បណ្តាញអគ្គិសនីរបស់រដ្ឋ (កាន់កាប់ដោយឯកជន) និងប្រើប្រាស់អគ្គិសនីប្រើដោយម៉ាស៊ីនភ្លើង។ ចំពោះតំបន់នៅលើគោក(ឆ្នេររាម) នឹងប្រើប្រាស់អគ្គិសនីដែលមានស្រាប់គឺប្រព័ន្ធអគ្គិសនីរបស់រដ្ឋ(គ្រប់គ្រងដោយឯកជន)។ ដោយឡែក តំបន់នៅលើកោះ នឹងប្រើប្រាស់ប្រភពអគ្គិសនីដើរដោយម៉ាស៊ីនភ្លើង ដែលនៅក្នុងដំណាក់កាលសាងសង់នេះ គម្រោងបានប្រើប្រាស់ ម៉ាស៊ីនកំលាំង ៤៥០KVAចំនួន១គ្រឿង និងម៉ាស៊ីនដែលមានកំលាំង ៦០KVA ចំនួន២គ្រឿង។

#### ខ. ដំណាក់កាលប្រតិបត្តិគម្រោង

នៅដំណាក់កាលប្រតិបត្តិគម្រោង ប្រភពថាមពលដែលនឹងប្រើប្រាស់នៅក្នុងតំបន់គម្រោងនេះ ត្រូវបានបែងចែកជាពីរដដែលគឺនៅលើកោះ និងនៅលើដីគោក។ សម្រាប់តំបន់គម្រោងនៅលើដីគោក (ឆ្នេរសមុទ្ររាម) ក្រុមហ៊ុននឹងប្រើប្រាស់ប្រភពថាមពលដែលមានស្រាប់ក្នុងតំបន់ដែល (អគ្គិសនីរដ្ឋ)។ ចំពោះប្រភពថាមពលដែលនឹងផ្គត់ផ្គង់ក្នុងតំបន់គម្រោងលើកោះគឺ ថាមពលដើរដោយម៉ាស៊ីនភ្លើងផ្ទាល់ខ្លួន ចំនួន៤គ្រឿង ដែលក្នុងមួយគ្រឿងមានកំលាំង៤៥០ KVA។ ម៉ាស៊ីនភ្លើងទាំងបួន ក្រុមហ៊ុនបានរៀបចំបន្ទប់ដាក់យ៉ាងត្រឹមត្រូវដើម្បីការពារ ការរំខានដោយសំឡេង ដល់ភ្ញៀវដែលមកស្នាក់នៅក្នុងតំបន់គម្រោង។ ក្រៅពីប្រភពថាមពលអគ្គិសនីនេះ ក្រុមហ៊ុនមានប្រើប្រាស់ថាមពលបន្ទាប់បន្សំ គឺប្រើថាមពលដោយពន្លឺព្រះអាទិត្យ (Solar Energy) នៅតាមតំបន់ខ្លះដូចជាភោជនីយដ្ឋាន ម៉ាស៊ីនត្រជាក់នៅតាមផ្ទះបុគ្គលិក ម៉ាស៊ីនទឹកក្តៅ ទឹកត្រជាក់នៅតាមផ្ទះលំហែកាយនៅមួយៗ។

យ៉ាងណាមិញ ផ្ទះលំហែកាយទាំងអស់ ត្រូវបានរចនាឡើងជាផ្ទះ Eco Friendly កាត់បន្ថយការប្រើប្រាស់អគ្គិសនីមួយផ្នែកធំ។ នៅជុំវិញផ្ទះលំហែការមានរៀបចំសួន និងមានដើមឈើព័ទ្ធជុំវិញ និងនៅលើដំបូលផ្ទះក៏មានដាំដើមឈើ និងផ្កាលំអរផងដែរ។

តាមការគណនាបានបង្ហាញថា ប្រសិនបើគម្រោងដំណើរការពេញលេញ និងមានភ្ញៀវមកស្នាក់នៅគ្រប់ផ្ទះលំហែទាំងអស់នោះបរិមាណតម្រូវការអគ្គិសនី មានប្រហែលជា **១៧៧ គីឡូវ៉ាត់/ថ្ងៃ**។ បរិមាណតម្រូវការអគ្គិសនីនេះ កំលាំងម៉ាស៊ីនខាងលើ និងការដាក់បន្ទះសូឡាអាចផ្គត់ផ្គង់បានយ៉ាងគ្រប់គ្រាន់។

តារាង៤.៨៖តម្រូវការថាមពលអគ្គិសនីក្នុងតំបន់គម្រោងទាំងមូល

| ប្រភេទអគារ | អាំងឌីកាទ័រនៃការប្រើប្រាស់អគ្គិសនី | ក្រឡាផ្ទៃប្រើប្រាស់ (ម$^2$) | មេគុណតម្រូវការ | បរិមាណតម្រូវអគ្គិសនីសរុប (KW) |
|---|---|---|---|---|
| **លើកោះ** | | | | |
| **ទី១៖** ផ្ទះល្ហែកាយ | ៥០វ/ម$^2$ | ៦.៤៦៤ | ០,៣៥ | ១១៣ |
| **ទី២៖** តំបន់សាធារណៈ | ៥០វ/ម$^2$ | ២.០៦០ | ០,៣៥ | ៣៦ |
| **ទី៣៖** តំបន់សេវាកម្ម(លើកោះ) | ៥០វ/ម$^2$ | ១.៦២០ | ០,៣៥ | ២៨ |
| **សរុប** | | | | **១៧៧** |
| ដីគោក | | | | |
| **ទី៤៖** កំពង់ផែ និងចំណតឡាន | ៥០វ/ម$^2$ | ១.០០០ | ០,៣៥ | ១៧,៥ |
| **ទី៥៖** កន្លែងដាក់សម្ភារៈ/កន្លែងបច្ចេកទេស | ៥០វ/ម$^2$ | ៤០០ | ០,៣៥ | ៧ |
| **សរុប** | | | | **២៤,៥** |
| សរុបរួម | | | | ២០១,៥ |



រូបភាព៤.៧១៖ ម៉ាស៊ីនភ្លើងប្រើប្រាស់ក្នុងដំណាក់កាលសាងសង់

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៤.៧២៖ការរៀបចំប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីសម្រាប់ប្រើប្រាស់នៅដំណាក់កាលប្រតិបត្តិគម្រោង

### ៤.១០.៦ ការរៀបចំប្រព័ន្ធការពារអគ្គិភ័យ

តំបន់កោះក្របីគឺសំបូរទៅដោយដើមឈើជាច្រើនប្រភេទ ដោយហេតុនេះក្រុមហ៊ុនបានយកចិត្តទុកដាក់ទៅលើការឆេះព្រៃដោយប្រការណាមួយ។ ក្រុមហ៊ុនមានវិធានការគ្រប់គ្រងបញ្ហានេះដោយរៀបចំបង្កប់បំពង់ទុយោទឹកនៅតាមបណ្តោយផ្លូវ និងដាក់ក្បាលម៉ាស៊ីនទឹកចំងាយ១០០ម៉ែត្រមួយកន្លែង។ ប្រភពទឹកដែលយកមកប្រើប្រាស់ក្នុងការពន្លត់អគ្គីភ័យនេះគឺទឹកសមុទ្រ ព្រោះបើតាមការសិក្សាពីប្រភេទព្រៃឈើនៅក្នុងតំបន់នេះគឺជាភេទព្រៃឈើដែលមានភាពបន្សាំជាមួយទឹកសមុទ្រ ហេតុដូចនេះការប្រើប្រាស់ទឹកសមុទ្រនឹងមិនប៉ះពាល់ដល់រុក្ខជាតិនៅកោះនេះទេ។



រូបភាព៤.៧៣៖ការរៀបចំប្រព័ន្ធការពារអគ្គីភ័យ

### ៤.១០.៧ ការគ្រប់គ្រងសំណល់រាវ

សំណល់រាវដែលនឹងត្រូវបញ្ចេញក្នុងតំបន់គម្រោងមានប្រភពពី ផ្ទះលំហែកាយ ភោជនីយដ្ឋាន កន្លែងផ្សេងៗទៀតក្នុងតំបន់គម្រោងអភិវឌ្ឍន៍។ តាមការគណនាខាងក្រោម បានបង្ហាញថា គម្រោងអភិវឌ្ឍន៍នឹងបញ្ចេញសំណល់រាវប្រមាណ**៤៥ម៉ែត្រគូប/ថ្ងៃ** ដែលក្នុងនោះបរិមាណសំណល់រាវដែលបញ្ចេញនៅលើកោះប្រហែល**៣៧ម៉ែត្រគូប/ថ្ងៃ** និងនៅលើគោកប្រហែល**៨ម៉ែត្រគូប/ថ្ងៃ**។ បរិមាណសំណល់រាវបញ្ចេញនេះ ស្មើរនឹង៧០%នៃបរិមាណទឹកប្រើប្រាស់សរុប។ការបញ្ចេញសំណល់រាវនេះគម្រោងនឹងរៀបចំផែនការគ្រប់គ្រងសំណល់រាវយ៉ាងត្រឹមត្រូវដែលមានសង្ខេបដូចខាងក្រោម៖

→ រៀបចំប្រព័ន្ធលូនៅតាមអគារនីមួយៗ

→ រៀបចំដាក់ប្រព័ន្ធអាងសិបទិកគ្រប់អគារទាំងអស់

→ ក្រុមហ៊ុនសង់បន្ទន់អនាម័យសាធារណៈ ដាច់ដោយឡែក គ្រប់តំបន់សាធារណៈទាំងអស់ទាំងនៅលើកោះ និងដីគោក។

តារាង៤.៩៖ការគណនាបរិមាណសំណល់រាវបញ្ចេញប្រចាំថ្ងៃក្នុងតំបន់អភិវឌ្ឍន៍កោះគ្របី

| តំបន់ | តម្រូវការប្រើប្រាស់ទឹក (លីត្រ) | អាំងឌីកាទ័រនៃបរិមាណបញ្ចេញសំណល់រាវ | សំណល់រាវ (លីត្រ) |
|---|---|---|---|
| លើកោះ | | | |
| ទី១៖ ផ្ទះលំហែកាយ | ២៤.០០០ | ៧០%នៃទឹកប្រើប្រាស់ | ១៦.៨០០ |
| ទី២៖ តំបន់សាធារណៈ | ១៦.៤៨០ | ៧០%នៃទឹកប្រើប្រាស់ | ១១.៥៣៦ |
| ទី៣៖ តំបន់សេវាកម្ម(លើកោះ) | ១២.៩៦០ | ៧០%នៃទឹកប្រើប្រាស់ | ៩.០៧២ |
| សរុប | | | ៣៧.៤០៨=៣៧ម៣ |
| ដីគោក (ជាប់ឆ្នេរសមុទ្ររាម) | | | |
| ទី៤៖ កំពង់ផែ និងចំណតឡាន | ៨.០០០ | ៧០%នៃទឹកប្រើប្រាស់ | ៥.៦០០ |
| ទី៥៖ តំបន់ដាក់សម្ភារៈ/បច្ចេកទេស | ៣.២០០ | ៧០%នៃទឹកប្រើប្រាស់ | ២.២៤០ |
| សរុប | | | ៧.៨៤០=៨ម៣ |
| សរុបរួម | | | ៤៥.១៧៦ល= ៤៥ម៣ |




រូបភាព៤.៧៤៖ទីតាំងដែលត្រូវដាក់អាងសិបទិក

#322P, St.271Z, Sk.Terk Tla, Khan Resey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៤.៧៥៖អាងសិបទិកដែលបានបំពាក់រួច



រូបភាព៨.៧៦៖ប្រភេទអាងសិបទិកដែលក្រុមហ៊ុនជ្រើសរើសយកមកប្រើ

→ **បច្ចេកទេសនៃប្រព័ន្ធអាងសិបទិកប្រភេទ Aqua Pac**

1. សំណល់រាវដែលហូរពីផ្ទះឬអាជីកម្ម (បន្ទប់ទឹក, មាស៊ីនបោកខោអាវ។ល។បានហូរចូលក្នុងAQUA PAC។កាកសំណល់រាវបានហូរចូលក្នុងAqua Grease Trap មុននឹងហូរចូលក្នុងAQUA PAC ដើម្បីធ្វើការសម្អាត។




រូបភាព៨.៧៧៖ ដំណើរនៃការសំអាតទឹករបស់អាងសិបទិក (Aqua Pac)

2. សំណល់រឹងប្រភេទធ្ងន់ហៅថា (ភក់ខាប់) បានលិចចូលទៅក្នុងបាតនៃSeptic Tank ខណៈពេលដែលខ្លាញ់ប្រេងនិងសំណល់ស្រាលៗមួយចំនួនអណ្តែតទៅផ្ទៃខាងលើនិងស្រទាប់កណ្តាលហៅថា (ទីតាំងទឹកស្អាត)។ដំណើរការនេះត្រូវប្រតិបត្តិការយ៉ាងតិចណាស់២-៨ទើបទទួលបាននូវការសម្អាតដែលមានប្រសិទ្ធិភាព។




រូបភាព៨.៧៨៖ លក្ខណៈខាងក្នុងនៃអាងសិបទិក (Aqua Pac)

3. សំណល់រឹងឬភក់ខាប់ត្រូវបានកំចាត់ដោយសេរីរាង្គដែលរស់នៅដោយមិនត្រូវការខ្យល់ (anaerobic organisms )(រូបភាពខាងក្រោម) ជាកន្លែងដែលបែងចែកសំណល់ស្រាលៗនិងទឹកត្រូវបានបំបែកយ៉ាងមានប្រសិទ្ធិភាព។បំពង់ចម្រោះបានទប់មិនអោយសំណល់រាវ និងសំណល់រឹងចេញពីបំពង់AQUA SEPT ខណៈដែលសំណល់រាវពីទីតាំងទឹកស្អាតហូរចូលបំពង់ទុយោរAQUA SEPT ហើយចូលទៅក្នុងAqua Filterនៃ

តម្រងAqua Pac។កាកសំណល់រាវហូរចូលពីលើចុះទៅក្រោមចូលទៅក្នុងបំពង់ចម្រោះ (AQUA FILTER) ដូចដែលបានបង្ហាញនៅក្នុងរូបភាពខាងក្រោម៖




រូបភាព៤.៧៩៖ ដំណើរនៃលំហូរសំណល់រាវ

4. បន្ទាប់មកកាកសំណល់រាវបានរុញចូលទៅក្នុងAquatic Media (ថង់ចម្រោះ) ដូចដែលបានបង្ហាញនៅក្នុងរូបភាពខាងលើ ជាកន្លែងដែលពពួកបាក់តេរីរស់នៅ ហើយវាបានស៊ីសំណល់ទាំងនោះជាអាហារ។
Aquatic Media (ថងចម្រោះ) បានបង្កើតឡើងពីជ័រ(PE) ជាប្លាស្ទិចដែលអាចប្រើប្រាស់បានយូរនឹងមានការរចនាយ៉ាងពិសេសសម្រាប់ផ្ទុកពពួកបាក់តេរី។



រូបភាព៤.៨០៖ ថង់ចំរោះរបស់ Aqua Pac

5. ទឹកដែលបានចម្រោះហើយអាចបញ្ជូនចូលទៅក្នុង ប្រព័ន្ធកាកសំណល់រាវសម្រាប់ធ្វើការសម្អាតបន្ថែមទៀត។
6. លក្ខណៈពិសេសផ្សេងទៀត:

- **Manhole Cover:**ធ្វើឡើងដោយប្លាស្ទិច ABS រាងវែងដែលមានភាពធន់ ហើយអាចអោយមានភាពងាយស្រួលក្នុងការចូលថែទាំ(ការបូម, ល។)
- **Tank Body:**បង្កើតឡើងដោយ ប៉ូលីទីលែន (PE) ប្លាស្ទិចដែលមានភាពស្វិតជាមួយនិង ភាពយាប់ទាបនិងមធ្យម នៃស្តង់ដាឧស្សាហកម្ម ISO9001ប្រទេសថៃ។
- **Anaerobic Bacteria:**បានជ្រើរើសសិរីរាងដែលអាចធ្វើការបានល្អនៅក្នុងអាកាសធាតុដូចជា (ថៃ និងកម្ពុជា, ល។) និងធានាអោយប្រព័ន្ធមានដំណើរការបានល្អ។
- **Aqua Flex (super flex):**ការពារទយាក្នុងការបាក់បែកពីការបំណាក់ស្រុតដី និងងាយស្រួលដំឡើង។
- **Load test:**ឆ្លងកាត់ការធ្វើពិសោធន៍នៃភាពសង្កត់បាន ១២០០គក/ម²
- **Vacuum test:**ឆ្លងកាត់ភាពសម្ពាធពីខាងក្រៅបាន ៦០ ទៅ ៧០ mbar។

7. ប្រសិទ្ធភាពនៃអាងចំរោះ៖ អាងចំរោះនេះ មានប្រសិទ្ធក្នុងការសំអាតសំណល់រាវរហូតដល់ ៩៥% ជាពិសេសចំពោះសារធាតុសាប៊ូ ខ្លាញ់ ប្រេង និងសារធាតុផ្សេងទៀត។
8. ទំហំនៃអាងសិបទិក: អាងសិបទិកនៃមាន៩ទំហំ គឺចាប់ពី ១២០០លីត្រ ១៦០០លីត្រ ១៨០០លីត្រ ២០០០លីត្រ ២២៣០លីត្រ ៣០០០លីត្រ ៤០០០លីត្រ ៥០០០លីត្រ និង ៦០០០លីត្រ។

តារាង៤.១០៖ ទំហំនៃអាងសិបទិក

#322P, St.271Z, Sk.Tek Tla, Khan Resey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| MODEL | Dimensions | | | | | | |
|---|---|---|---|---|---|---|---|
| | Diameter | Height | Inlet Outlet pipe (mm.) | Air vent (mm.) | Effective Volume (Litre) | Septic Zone (Litre) | Filter Zone (Litre) |
| AP-1200 | 1315 | 1400 | 100 | 50 | 1200 | 790 | 410 |
| AP-1600 | 1460 | 1580 | 100 | 50 | 1600 | 1050 | 550 |
| AP-1800 | 1510 | 1635 | 100 | 50 | 1800 | 1200 | 600 |
| AP-2000 | 1550 | 1650 | 100 | 50 | 2000 | 1300 | 700 |
| AP-2230 | 1550 | 1750 | 100 | 50 | 2230 | 1530 | 700 |
| AP-3000 | 1805 | 1775 | 100 | 50 | 3000 | 2000 | 1000 |
| AP-4000 | 1935 | 1975 | 100 | 50 | 4000 | 2700 | 1300 |
| AP-5000 | 2040 | 2295 | 100 | 50 | 5000 | 3350 | 1650 |
| AP-6000 | 2085 | 2480 | 100 | 50 | 6000 | 4000 | 2000 |

## ៤.១០.៨ ការរៀបចំគ្រប់គ្រងសំណល់រឹង

### ក. ដំណាក់កាលសាងសង់

នៅក្នុងដំណាក់កាលសាងសង់ ការបញ្ចេញសំណល់រឹងភាគច្រើនជាសំណល់ ស្លឹកឈើ កំទេចឈើ សំណល់ចេញពីសម្ភារៈសំណង់ និងសម្ភារៈប្រើប្រាស់របស់កម្មករ។ នៅក្នុងរយៈពេលនេះ សំណល់រឹងជាច្រើនដែលបានមកពីសំភារៈសាងសង់មានដូចជា កំណាត់ដែក ជ័របំពង់ទីប ជ័រប្លាស្ទិច កំណាត់ឈើ កំទេចស៊ីម៉ង់ត៍ កំបោរ ថ្នាំលាបពណ៌ជាដើម។នៅក្នុងដំណាក់កាលសាងសង់នេះ ក្រុមហ៊ុនមានតម្រូវការកម្មករចំនួនជាង៧០០នាក់ ប៉ុន្តែចំនួនកម្មករនេះមិនបានបង្កើតសំណល់រឹងនៅក្នុងតំបន់គម្រោងទេ ព្រោះបុគ្គលិក និងកម្មករទាំងអស់ត្រូវវេចខ្ចប់បាយទៅធ្វើការ និងត្រលប់មកនៅផ្ទះវិញរៀងៗខ្លួន នៅពេលល្ងាច ដែលការវិលត្រលប់មកផ្ទះវិញនេះ ប្រសិនបើពួកគាត់មានសល់សំណល់អាហាររបស់ខ្លួនបន្តិចបន្តួច ក៏ត្រូវខ្ចប់ត្រលប់មកផ្ទះវិញផងដែរ។

ដើម្បីគ្រប់គ្រងបញ្ហាសំណល់រឹងទាំងនេះ ក្រុមហ៊ុនមានវិធានការបែងចែកសំណល់រឹងទៅតាមប្រភេទនៃសំណល់។ ចំពោះសំណល់រឹងដែលមានប្លាស្ទិច ជ័រ និងសារធាតុគីមីផ្សេងៗ ក្រុមហ៊ុនមានផែនការដឹកសំរាមមកខាងដីគោកវិញ និងសហការជាមួយក្រុមហ៊ុនដឹកសំរាមខេត្តព្រះសីហនុ មកប្រមូលដឹកទៅចាក់ចោលនៅទីលានចាក់សំរាមខេត្តព្រះសីហនុ។



រូបភាព៤.៨១៖សំណល់វេចខ្ចប់ត្រៀមដឹកមកខាងដីគោក

ខ. ដំណាក់កាលប្រតិបត្តិគម្រោង

នៅក្នុងដំណាក់កាលនេះ សំណល់រឹងទាំងឡាយមានប្រភពមកពី តំបន់លំនៅដ្ឋានតំបន់ភោជនីយដ្ឋាន និងកន្លែងកំសាន្តនៅលើកោះ។ សំណល់រឹងភាគច្រើន ដែលបញ្ចេញក្នុងដំណាក់កាលនេះ ភាគច្រើនជាសំណល់ផ្ទះបាយ និងសម្ភារៈប្រើប្រាស់មួយចំនួន។

ដើម្បីគ្រប់គ្រងបញ្ហាសំណល់រឹងទាំងនេះ ក្រុមហ៊ុនមានផែនការដាក់ធុងសំរាមតាមតំបន់សំខាន់នានាដូចជាតំបន់ផ្ទះលំហែកាយភោជនីយដ្ឋាន និងតំបន់កំសាន្តនានាក្នុងតំបន់គម្រោង។ ក្រៅពីការដាក់ធុងសំរាម ក្រុមហ៊ុនក៏មានវិធានការបែងចែកសំណល់រឹងទៅតាមប្រភេទសំណល់ផងដែរ។ ជាក់ស្តែងដូចជាសំណល់ប្រភេទផ្ទះបាយនឹងត្រូវបានធ្វើជាជីកំប៉ុស ដើម្បីប្រើប្រាស់ធ្វើជាជីសម្រាប់រុក្ខជាតិជាដើម។ ចំពោះសំណល់រឹងដែលមានប្លាស្ទិច ជ័រ ក្រុមហ៊ុនមានផែនការកែច្នៃសំណល់ និងប្រើប្រាស់សំណល់ឡើងវិញ។

រីឯសំណល់រឹង ដែលនៅសេសសល់ ក្រុមហ៊ុននឹងរៀបចំវេចខ្ចប់ដឹកមកខាងដីគោកវិញ ដែលការវេចខ្ចប់នេះប្រើប្រាស់ប្លាស្ទិច ឬធុងដែលរឹងមាំជៀសវាងការលេចជ្រាប និងហូរកំពប់តាមទូកនាពេលដឹកជញ្ជូនមកខាងដីគោក។ ម្យ៉ាងទៀត ក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាមក្រុងព្រះសីហនុ ដើម្បីដឹកយកសំណល់រឹង ទៅចាក់ចោលនៅទីលានចាក់សំរាមក្រុងព្រះសីហនុ។

តាមការប៉ាន់ប្រមាណសំណល់រឹងប្រសិនបើគម្រោងដំណើរការពេញលេញ នោះនឹងបញ្ចេញសំណល់រឹងប្រមាណជា១៩៧គីឡូក្រាមក្នុងមួយថ្ងៃ។ បញ្ហាសំណល់រឹងគឺជាបញ្ហាមួយដែលក្រុមហ៊ុនអភិវឌ្ឍន៍មានការយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយក្រុមហ៊ុនមានវិធានការមួយចំនួនដើម្បីគ្រប់គ្រងនូវបញ្ហានេះដូចមានសង្ខេបខាងក្រោម៖

→ រៀបចំដាក់ធុងសំរាមតាមផ្ទះលំហែកាយ និងតាមទីធ្លាសាធារណៈ
→ រៀបចំបែងចែកសំណល់រឹងទៅតាមប្រភេទនៃសំណល់
→ ប្រើប្រាស់សំណល់ឡើងវិញ(សំណល់ដែលអាចប្រើប្រាស់បាន)
→ ចំពោះសំណល់ដែលចេញពីភោជនីយដ្ឋាន ផ្ទះបាយ គឺរៀបចំធ្វើជីកំប៉ុសដើម្បីស្រោចស្រពរុក្ខជាតិនៅលើកោះដូចជា សួនច្បារ ដើមឈើជាដើម។
→ រៀបចំទីតាំងស្តុកសំណល់បណ្តោះអាសន្ននៅលើដីគោក ឲ្យត្រឹមត្រូវតាមបច្ចេកទេសដើម្បីរងចាំឡានដឹកជញ្ជូន។
→ សហការជាមួយក្រុមហ៊ុនប្រមូលសំរាម ទៅចាក់ចោលនៅទីលានចាក់សំរាម។

តារាង៤.១១៖បរិមាណសំណល់រឹងដែលបញ្ចេញក្នុងតំបន់គម្រោងអភិវឌ្ឍន៍កោះក្របី

| ការបញ្ចេញសំណល់រឹងក្នុងរមណីយដ្ឋានកោះក្របី | | | |
|---|---|---|---|
| តំបន់ | ក្រឡាផ្ទៃប្រើប្រាស់(ម$^{២}$) | អាំងឌីការទ័រនៃការបញ្ចេញសំរាម | សំណល់រឹងដែលបញ្ចេញ (គ/ក្រ) |
| លើកោះ | | | |
| ទី១៖ ផ្ទះលំហែកាយ (៤០ផ្ទះ) | ១៦០នាក់ | ០,៧គក្រ/នាក់ | ១១២ |
| ទី២៖ តំបន់សាធារណៈ | ២.០៦០ម$^{២}$ | - | ៥០ |
| ទី៣៖ តំបន់សេវាកម្ម | ១.៦២០ម$^{២}$ | - | ២០ |
| សរុប | | | ១៨២ |
| ដីគោក (ជាប់ឆ្នេរសមុទ្រកម) | | | |
| ទី៤៖ កំពង់ផែ និងចំណតឡាន(ដីគោក) | ១.០០០ម$^{២}$ | - | ៥ |
| ទី៥៖ កន្លែងដាក់សម្ភារៈ/កន្លែងបច្ចេកទេស | ៤០០ម$^{២}$ | - | ១០ |
| សរុប | | | ១៥ |
| សរុបរួម | | | ១៩៧ |



រូបភាព៤.៨២៖ធុងសម្រាប់ញែកសំណល់




រូបភាព៤.៨៣៖បង្ហាញពីការកែច្នៃសំណល់



រូបភាព៤.៨៤៖សំណល់សម្រាប់ការធ្វើជីកំប៉ុស



រូបភាព៤.៨៥៖គម្រោងការវេចខ្ចប់

## ៤.១១តម្រូវការកម្លាំងពលកម្ម

ក្រុមហ៊ុនត្រូវការកម្លាំងពលកម្មដើម្បី ដំណើរការក្នុងតំបន់គម្រោង ដែលត្រូវជ្រើសរើសដូចបង្ហាញខាងក្រោម៖

### ក. ដំណាក់កាលសាងសង់

ដំណាក់កាលនេះ មានកម្មករធ្វើការសរុបចំនួន៦០០-៧០០នាក់ និងបុគ្គលិកធ្វើការ នៅក្នុងការិយាល័យចំនួន៣០នាក់។ ក្នុងនេះមានជនជាតិបរទេសចំនួន១៥នាក់។ កម្មករដែលធ្វើការងារនៅក្នុងតំបន់គម្រោងនេះ គឺភាគច្រើនមកពីឃុំរាម ស្រុកព្រៃនប់ និងឃុំដែលនៅជិតៗតំបន់គម្រោង។ សម្រាប់ម៉ោងចូលធ្វើការងារ គឺបុគ្គលិក និងកម្មករទាំងអស់ត្រូវមកដល់ផែឲ្យមានមុនម៉ោង ៧:០០ព្រឹក ព្រោះកប៉ាល់ដឹកជញ្ជូនបុគ្គលិក និងកម្មករនឹងចេញដំណើរនៅម៉ោង ៧:១៥នាទីព្រឹក។ ចំពោះម៉ោងចេញធ្វើការងារ គឺបុគ្គលិក និងកម្មករទាំងអស់ត្រូវមកដល់ផែ នៅម៉ោង៤:០០ល្ងាច ព្រោះកប៉ាល់នឹងចេញដំណើរនៅម៉ោង៤:១៥នាទី។

តារាង៤.១២៖ ចំនួនបុគ្គលិក និងកម្មករក្នុងដំណាក់កាលសាងសង់

| ល.រ | បុគ្គលិក/កម្មករ | ចំនួនបុគ្គលិក/កម្មករ | ប្រាក់បៀវត្ស (ដុល្លា) |
|---|---|---|---|
| ១ | ក្នុងស្រុក (ជនជាតិខ្មែរ) | ៦០០-៧០០នាក់ | ១៥០-៨០០ |
| ២ | ក្រៅស្រុក (ជនជាតិរ៉ូស៊ី) | ១៥នាក់ | ១០០០-១៥០០ |

Creative Green Design Co., Ltd
Social-Environmental Researchs
Quality Researchers

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com





រូបភាព៤.៨៦៖កម្មករដែលទៅធ្វើការងារនៅលើកោះ

ខ. ដំណាក់កាលប្រតិបត្តិគម្រោង

នៅក្នុងដំណាក់កាលនេះក្រុមហ៊ុនមានតម្រូវការកម្លាំងពលកម្មក្នុងស្រុកចំនួន១៣០នាក់ និងកំលាំងពលកម្មក្រៅស្រុកយ៉ាងតិចចំនួន ១០នាក់។បុគ្គលិក និងកម្មករទាំងនេះ ក្រុមហ៊ុនបានរៀបចំអគារស្នាក់នៅយ៉ាងសមរម្យសម្រាប់ពួកគាត់ និងមានការផ្តល់ជូននូវសេវាថែរក្សាសុខភាព ដែលក្រុមហ៊ុនបានសាងសង់បន្ទប់ពេទ្យមួយកន្លែង និងមានគ្រូពេទ្យប្រចាំការ២៤ម៉ោង។

តារាង៤.១៣៖ ចំនួនបុគ្គលិក និងកម្មករក្នុងដំណាក់កាលប្រតិបត្តិ

| ល.រ | បុគ្គលិក/កម្មករ | ចំនួនបុគ្គលិក/កម្មករ | ប្រាក់បៀវត្ស (ដុល្លា) |
|---|---|---|---|
| ១ | ក្នុងស្រុក (ជនជាតិខ្មែរ) | ១៣០នាក់ | ២៥០-៤០០ |
| ២ | ក្រៅស្រុក (ជនជាតិរ៉ូស៊ី) | ១០នាក់ | ១០០០-១៥០០ |

## ៤.១២តម្រូវការគ្រឿងចក្រ

ក. ដំណាក់កាលសាងសង់

សម្រាប់ដំណាក់កាលសាងសង់នេះ ក្រុមហ៊ុនមានតម្រូវការ គ្រឿងចក្រច្រើន សម្រាប់បំពេញតម្រូវការនៃការសាងសង់។ តម្រូវការគ្រឿងចក្រទាំងនេះមានដូចក្នុងតារាងខាងក្រោម៖

តារាង៤.១៤៖ គ្រឿងចក្រដែលប្រើប្រាស់ក្នុងដំណាក់កាលសងសង់

| ល.រ | ឈ្មោះគ្រឿងចក្រ | ចំនួនគ្រឿងចក្រ |
|---|---|---|
| ១ | ម៉ាស៊ីនភ្លើង | ៤គ្រឿង |
| ២ | ម៉ាស៊ីនក្រឡុកស៊ីម៉ង់ | ៤គ្រឿង |
| ៣ | អេស្កាវាទ័រ | ២គ្រឿង |
| ៤ | អាប៊ុលឈូសដី | ១គ្រឿង |
| ៥ | ទ្រាក់ទ័រ | ៣គ្រឿង |
| ៦ | រទេះកិនដី | ២គ្រឿង |




រូបភាព៤.៨៧៖គ្រឿងចក្រដែលប្រើប្រាស់ក្នុងដំណាក់កាលសាងសង់

### ខ. ដំណាក់កាលប្រតិបត្តិគម្រោង

ដោយសារគម្រោងអភិវឌ្ឍន៍កោះក្របីនេះ ជាប្រភេទរមណីយដ្ឋាន ហេតុដូវនេះ នៅក្នុងដំណាក់កាលប្រតិបត្តិគម្រោងនេះ មិនមានតម្រូវការគ្រឿងចក្រទៀតទេ គឺគម្រោងមានប្រើប្រាស់តែម៉ាស៊ីនភ្លើងចំនួន៤ មានកំលាំង ៤៥០KVAប៉ុណ្ណោះ។

# ៤.១៣ ផែនការកម្មវិធីសម្រាប់សាងសង់តំបន់លំហែកាយកោះក្របី

ផែនការកម្មវិធីការងារសំរាប់សាងសង់គំរោងអភិវឌ្ឍន៍

តំបន់សំណែកាយកោះក្របី

ស្ថិតនៅក្នុងឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

| ID | DESCRIPTION OF WORKS | Duration | Start | Finish | Predecessors |
|---|---|---|---|---|---|
| 0 | **កម្មវិធីការងារសាងសង់គំរោងទាំងមូល** | **81.4 mons** | **Wed 1/7/09** | **Fri 4/3/15** | |
| 1 | ធ្វើតូប៉ូដី និងវាស់ស្ទង់ដី | 3 mons | Wed 1/7/09 | Tue 3/31/09 | |
| 2 | វាស់ស្ទង់ដើមឈើ | 6 mons | Wed 4/1/09 | Tue 9/15/09 | 1 |
| 3 | រៀបចំគូសប្លង់ស្ថាបត្យកម្ម/បោះពុម្ពប្លង់ | 18 mons | Wed 9/16/09 | Tue 2/1/11 | 2 |
| 4 | រៀបចំគូសប្លង់វិស្វកម្ម/បោះពុម្ពប្លង់ | 18 mons | Mon 11/2/09 | Fri 3/18/11 | |
| 5 | រៀបចំគូសប្លង់ទេសភាព | 10 mons | Mon 7/26/10 | Fri 4/29/11 | |
| 6 | ស្នើសុំការអនុញ្ញាតសាងសង់ | 6 mons | Mon 5/2/11 | Fri 10/14/11 | 5 |
| 7 | សាងសង់កំពុងផែ (លើកោះ) ឃ្លាំង តំបន់បច្ចេកទេស និងផ្លូវជុំវិញកោះ | 28 mons | Mon 10/17/11 | Fri 12/6/13 | 6 |
| 8 | សាងសង់កំពុងផែ (ដីគោក) អគាររង់ចាំរបស់ភ្ញៀវ និងអគារបច្ចេកទេសខាងដីគោក | 18 mons | Mon 10/17/11 | Fri 3/1/13 | |
| 9 | សាងសង់ផ្ទះលំហែកាយ | 36 mons | Mon 5/7/12 | Fri 2/6/15 | |
| 10 | រៀបចំកន្លែងកំសាន្ត ភោជនីយដ្ឋាន និងសេវាកម្មផ្សេងៗ | 25 mons | Mon 11/5/12 | Fri 10/3/14 | |
| 11 | រៀបចំហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | 38 mons | Mon 5/7/12 | Fri 4/3/15 | |




**ផែនការកម្មវិធីការងារសាងសង់**

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| Task | | Rolled Up Milestone | ◇ | Project Summary | | Inactive Milestone | | Manual Summary Rollup | ◆ | External Tasks | |
| Milestone | ◆ | Rolled Up Progress | | Group By Summary | | Inactive Summary | | Manual Summary | ◆ | External Milestone | |
| Summary | | Split | | Inactive Task | | Manual Task | | Start-only | | Progress | |
| Rolled Up Task | | External Tasks | | Inactive Milestone | | Duration-only | | Finish-only | | Deadline | ⇩ |

ទិដ្ឋិការដោយ

RPB



Design By

CREATIVE

ARCHITECTURE · ENGINEERING

25/9/06

ផែនការកម្មវិធីការងារសំរាប់សាងសង់គំរោងអភិវឌ្ឍន៍

តំបន់លំហែកាយកោះក្របី

ស្ថិតនៅក្នុងឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

| ID | DESCRIPTION OF WORKS | Duration | Start | Finish | Predecessors |
|---|---|---|---|---|---|
| 0 | **កម្មវិធីការងារសាងសង់គំរោងទាំងមូល** | **81.4 mons** | **Wed 1/7/09** | **Fri 4/3/15** | |
| 1 | ធ្វើគូប្លង់ដី និងវាស់ស្ទង់ដី | 3 mons | Wed 1/7/09 | Tue 3/31/09 | |
| 2 | វាស់ស្ទង់ដើមឈើ | 6 mons | Wed 4/1/09 | Tue 9/15/09 | 1 |
| 3 | រៀបចំគូសប្លង់ស្ថាបត្យកម្ម/បោះពុម្ពប្លង់ | 18 mons | Wed 9/16/09 | Tue 2/1/11 | 2 |
| 4 | រៀបចំគូសប្លង់វិស្វកម្ម/បោះពុម្ពប្លង់ | 18 mons | Mon 11/2/09 | Fri 3/18/11 | |
| 5 | រៀបចំគូសប្លង់ទេសភាព | 10 mons | Mon 7/26/10 | Fri 4/29/11 | |
| 6 | ស្នើសុំការអនុញ្ញាតសាងសង់ | 6 mons | Mon 5/2/11 | Fri 10/14/11 | 5 |
| 7 | សាងសង់កំពុងផែ (លើកោះ) ឃ្លាំង តំបន់បច្ចេកទេស និងផ្លូវជុំវិញកោះ | 28 mons | Mon 10/17/11 | Fri 12/6/13 | 6 |
| 8 | សាងសង់កំពុងផែ (ដីគោក) អគាររង់ចាំរបស់ភ្ញៀវ និងអគារបច្ចេកទេសខាងដីគោក | 18 mons | Mon 10/17/11 | Fri 3/1/13 | |
| 9 | សាងសង់ផ្ទះលំហែកាយ | 36 mons | Mon 5/7/12 | Fri 2/6/15 | |
| 10 | រៀបចំកន្លែងកំសាន្ត ភោជនីយដ្ឋាន និងសេវាកម្មផ្សេងៗ | 25 mons | Mon 11/5/12 | Fri 10/3/14 | |
| 11 | រៀបចំហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | 38 mons | Mon 5/7/12 | Fri 4/3/15 | |




**ផែនការកម្មវិធីការងារសាងសង់**

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| Task | | Rolled Up Progress | | Inactive Task | | Duration-only | | External Tasks | |
| Milestone | ◆ | Split | | Inactive Milestone | | Manual Summary Rollup | ◆ | External Milestone | |
| Summary | | External Tasks | | Inactive Milestone | | Manual Summary | ◆ | Progress | |
| Rolled Up Task | | Project Summary | | Inactive Summary | | Start-only | | Deadline | ⇩ |
| Rolled Up Milestone | ◇ | Group By Summary | | Manual Task | | Finish-only | | | |

វិនិយោគដោយ



Design By

CREATIVE ARCHITECTURE · ENGINEERING

25/9/06

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី៥៖
# ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់

#322P, St.27*Z, Sk.Terk Tla, Khan Russey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី៥៖
# ការពិពណ៌នាពីស្ថានភាពបរិស្ថានដែលមានស្រាប់

## ៥.១ សេចក្តីផ្តើម

ក្នុងការសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងមួយ ជាការចាំបាច់ណាស់ក្នុងការសិក្សា និងប្រមូលពតិមានអំពីស្ថានភាពបរិស្ថាន ដែលមានស្រាប់នៅក្នុង និងក្បែរតំបន់គម្រោងអភិវឌ្ឍន៍។ ការសិក្សាពីធនធានបរិស្ថានដែលមានស្រាប់នេះ ពិតជាមានសារៈសំខាន់ណាស់ ព្រោះអាចប្រើប្រាស់ពតិមាននេះសម្រាប់កំណត់អាចឲ្យដឹងថាធនធានបរិស្ថានទាំងនោះបានទទួលរងការប៉ះពាល់ស្រាប់មុនពេលគម្រោងសាងសង់ ឬរងការប៉ះពាល់ដោយសារទទួលឥទ្ធពលពីគម្រោង។ ក្នុងគោលបំណងនេះ ក្រុមការងារបានសិក្សាលើទិន្នន័យមានស្រាប់ និងស្រង់ទិន្នន័យចាំបាច់មួយចំនួនដោយផ្ទាល់នៅតំបន់គោលដៅ តាមរយៈការសិក្សាលើធាតុបរិស្ថានសំខាន់ៗ ចំនួនពីរ បរិស្ថានធម្មជាតិ (បរិស្ថានរូបសាស្រ្ត និងបរិស្ថានជីវសាស្រ្ត) និងបរិស្ថានសង្គម-សេដ្ឋកិច្ច រួមមានការសិក្សាលក្ខណៈប្រជាសាស្រ្ត ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ និងសម្បត្តិវប្បធម៌ជាដើម ដែលមានបង្ហាញជាបន្តបន្ទាប់ក្នុងជំពូកនេះ។ ការសិក្សាពីធនធានបរិស្ថាននេះ មានសារៈសំខាន់ក្នុងការបញ្ជាក់ពីស្ថានភាពដើមរបស់តំបន់មុនពេលគម្រោងដំណើរការ ហើយការប្រៀបធៀបស្ថានភាពបរិស្ថានដែលមានស្រាប់មុនគម្រោងដំណើរការ និងស្ថានភាពធនធានបរិស្ថានពេលគម្រោងដំណើរការ អាចអោយគេដឹងពីទំហំនៃផលប៉ះពាល់ដែលកើតមាន និងកម្រិតនៃផលប៉ះពាល់ទាំងនោះ។ ការកែប្រែណាមួយនៃធនធានបរិស្ថាននៅក្នុងតំបន់ អាចជាមូលហេតុបណ្តាលមកពីដំណើរការរបស់គម្រោងអភិវឌ្ឍន៍នេះ ហេតុនេះការសិក្សាព័ត៌មាន ឬធនធានបរិស្ថានមានស្រាប់របស់តំបន់គម្រោងជាការចាំបាច់ និងមានប្រយោជន៍សម្រាប់ដំណើរការត្រួតពិនិត្យនៅពេលដែលគម្រោងដំណើរការ។

## ៥.២ បរិស្ថានរូបសាស្រ្ត

ការសិក្សាអំពីបរិស្ថានរូបសាស្រ្ត គឺផ្តោតទៅលើកត្តាសំខាន់ៗមួយចំនួនដែលទាក់ទងផ្ទាល់ទៅនឹងលក្ខណៈរូបសាស្រ្តនៅក្នុងតំបន់ភូមិសាស្រ្តនៃគម្រោងរួមមាន សណ្ឋានដី ប្រភេទដី ភូគព្ភសាស្រ្ត អាកាសធាតុ និងឧតុនិយម សីតុណ្ហភាព កម្រិតសំណើម កម្រិតរំហួត កម្រិតនិងកម្ពស់ទឹកភ្លៀង គុណភាពទឹក ព្រមទាំងស្ថានភាពនៃការបំពុលបរិស្ថានដែលមានស្រាប់នៅក្នុង និងក្បែរតំបន់គម្រោង។

#322P, St.27'Z, Sk.Tark Tla, Khan Ressy Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

### ៩.២.១ ទូគព្ភសាស្ត្រ

ការសិក្សានូវភូគព្ភសាស្ត្រ អាចឱ្យយើងដឹងបាននូវអាយុរបស់ដីគម្រោងអភិវឌ្ឍន៍ និងបែបផែននៃការកកើតដីនៅក្នុងតំបន់គម្រោងអភិវឌ្ឍន៍។ លើសពីនេះទៅទៀត វាក៏បានចង្អុលបង្ហាញពីសកម្មភាពធម្មជាតិនានាដែលកើតឡើងនៅក្នុងតំបន់គម្រោង ដូចជាការកកើតឡើង នៃរ៉ែ និងពំនើងផ្នត់ជាដើម។

តាមការបកស្រាយរបស់លោក Croker កាលពីឆ្នាំ ១៩៦២ បានបង្ហាញថាដីក្នុងតំបន់នេះគឺជាដីអន្តរតំបន់ ដែលគ្របដណ្តប់លើសលុបនូវប្រភេទដីក្មេង ចំណែកភាគខ្លះដីបានកកើតដោយការបង្កើតស្រទាប់ដីតិចឬមធ្យម។ ដីនេះពុំសូវមានជីជាតិទេ ហើយក៏ពុំសមស្របសម្រាប់កសិកម្មផងដែរ ប៉ុន្តែអាចជួយគាំទ្រដល់ផលិតភាពរបស់ព្រៃ។

### ៩.២.២ សណ្ឋានដី

កោះក្របីមានសណ្ឋានដី ដែលមានលក្ខណៈជាកោះ មានកំពស់ខ្ពស់នៅកណ្តាល និងមានជំរាលទាបចុះក្រោមរហូតដល់កំពស់ទឹកសមុទ្រ។ តំបន់ដែលខ្ពង់ជាងគេមានរយៈកំពស់ ៤៩ម៉ែត្រធៀបនឹងនីវ៉ូទឹកសមុទ្រ ដែលស្ថិតនៅលើកំពូលនៃកោះ និងមានជម្រាលចុះមកក្រោមដែលមានកំពស់៤០ម៉ែត្រ ៣៥ម៉ែត្រ ៣០ម៉ែត្ររហូតដល់០ម៉ែត្រ។ នៅក្នុងតំបន់ទី១គឺជាតំបន់ដែលមានជម្រាលល្អជាងគេ ដោយសារតែរយៈកំពស់ជ្រាលបន្តិចម្តងៗដែលអំណោយផលដល់ការសាងសង់ផ្ទះលំហែកាយ។



រូបភាព៥.១៖ស្ថានភាពកំពស់ដីកោះក្របី

### ៥.២.៣ ប្រភេទដី

តាមផែនទីចំណាត់ថ្នាក់ប្រភេទដីរបស់លោក Crocker (1963) មាត្រដ្ឋាន ១:១,000,000 បានបង្ហាញថាកោះក្របីមានប្រភេទដីមួយប្រភេទ គឺប្រភេទដី Acid Lithosols ដែលមានទំហំ ១០ ហិកតា។

ដី Acid Lithosols៖ មានកំទេចដុំថ្មស្តើងៗផុសលើដីដែលសំបូរដោយកករជាតិអាស៊ីត និងថ្មដែលពុកផុយ (ថ្ម ខ្សាច់ ថ្មឆ្នួនឥដ្ឋ ថ្មក្រួសអាចម៍ផ្កាយ ថ្មជាតិស៊ីលិស និងថ្មឆ្នួន)។ ដីកំទេចថ្មស្តើងមានអាស៊ីតជម្រៅពី ៥-៣០សង់ទីម៉ែត្រ ហើយធម្មតាគឺ ១៥សង់ទីម៉ែត្រ ដែលជម្រៅជាមធ្យមអាចដល់ស្រទាប់ថ្ម ដែលនៅទីកន្លែងជាច្រើនបានវិវត្តជាថ្ម ក្រួសក្រាវែលនៅលើផ្ទៃផ្ទាំងថ្មធំ។ ដីកំទេចថ្មស្តើងមានជាតិអាស៊ីត pH ៤.៥-៦.៥ ដែលខុសគ្នាពីស្រទាប់ដីល្បាយខ្សាច់ ទៅដីឥដ្ឋ ហើយជាធម្មតាភាគច្រើនគឺជាដីឥដ្ឋល្បាយ។ ពណ៌ដីខុសៗគ្នាជាមួយនឹងឥទ្ធិពលពណ៌របស់ថ្មមេ។

### ៥.២.៤ ជលសាស្ត្រ

#### ក. ចរន្តទឹក

នៅរដូវប្រាំង ជាទូទៅចរន្តទឹកនៅតំបន់ខេត្តព្រះសីហនុមានលក្ខណៈហ្នឹង និងស្ងប់។ ប៉ុន្តែនៅរដូវវស្សា ចរន្តទឹកអាចមានភាពខុសពីរដូវប្រាំង ដោយសារតែស្ថានភាពខ្យល់បក់ និងរលក។ ដោយយោងតាមទិន្នន័យទិសខ្យល់នៅឆ្នាំ២០១១ របស់នាយកដ្ឋានឧតុនិយមអាចសន្និដ្ឋានបានថា នៅខែវិច្ឆិកា ដល់ខែមករាចរន្តទឹកហូរពីទិសឦសាន្ត ទៅទិសនិរតី ចំណែកខែមិថុនាដល់ខែតុលា ចរន្តទឹកហូរពីទិសពាយព្យទៅទិសអាគ្នេយ៍។

#### ខ. រលកសមុទ្រ

ជាទូទៅនៅរដូវប្រាំងលក្ខណៈរលកមានភាពស្ងប់ស្ងាត់ ដែលមានកម្ពស់នៅចន្លោះ ០.៤-០.៧ម៉ែត្រ។ ចំណែកឯ នៅរដូវវស្សាលក្ខណៈរលកមានភាពញឹកញាប់ជាងរដូវប្រាំង និងមានកម្ពស់ពី ០.៥-០.៩ម៉ែត្រ និងអាចដល់កម្ពស់ ១.៥-២.០ម៉ែត្រ នៅពេលមានខ្យល់បក់ខ្លាំង។ ជាទូទៅទិសដៅរលកមានទិសដូចគ្នាតាមទិសខ្យល់ ដែលនៅរដូវប្រាំង រលកមានទិសដៅ ពីទិសឧត្តរ និងទិសឦសាន និងនៅរដូវវស្សារលកមានទិសដៅពីទិសនិរតី ទិសបច្ចិម និងទិសពាយ័ព្យ។ ជាទូទៅលក្ខណៈរលកសមុទ្រ ទោះបីជាខ្យល់ស្ងប់ តែរលកសមុទ្រមានភាពយោលយោកតែយឺតៗ ឃ្លងតាមជំនោរខ្យល់បក់។

### គ. ទឹកជោរ និងលំនាច

ជំនោរ និងលំនាចកើតឡើងពីរដងក្នុងមួយថ្ងៃ ដែលជាទូទៅទឹកនាចនៅពេលព្រឹកដល់ពេលរសៀល និងទឹកជោរចាប់ផ្តើមពីពេលរសៀល ដល់ពេលយប់។ លក្ខណៈលំនាចទឹក ត្រូវបានសង្កេតឃើញជាក់ស្តែង ខណៈពេលដែលជំនោរសមុទ្រមានលក្ខណៈស្ងប់ ដែលធ្វើឲ្យទឹកស្រកចុះនៅលើឆ្នេរខ្សាច់ នៅលើថ្ម និងតាមច្រាំងសមុទ្រ។ គេអាចមើលឃើញលំនាចដោយសារ ឆ្នេរខ្សាច់មានឆ្អូតតូចៗនៅតាមឆ្នេរ និងឆ្នេរខ្សាច់មានស្នាមគំលាតវែង ដែលផ្ទុយពីទឹកជោរ ឆ្នេរខ្សាច់មានស្នាមគំលាតខ្លី។ នៅខេត្តព្រះសីហនុ ទឹកជោរមានកម្ពស់ជាមធ្យមពី ០.៥-១.០ ម៉ែត្រ ប៉ុន្តែនៅរដូវរំហើយ ទឹកជោរអាចឡើងដល់កំពស់ ១-១.៥ម៉ែត្រ ដែលចាប់ពីខែវិច្ឆិកា ដល់មករា។ ចំណែកឯ លំនាចជាមធ្យមធ្លាក់ចុះពី០.៥-០.៨ម៉ែត្រធៀបនឹងនីវ៉ូសមុទ្រ។

### ៤.២.៨ គុណភាពទឹក

ការរក្សាកម្រិតបទដ្ឋាន គុណភាពទឹកទាំងទឹកលើដី (Surface Water) និងទឹកក្រោមដី (Ground Water) គឺជាកត្តាសំខាន់ដើម្បីពិនិត្យមើលអោយដឹងជាមុននូវកម្រិតគុណភាពទឹកទាំងនោះ មុននឹងគម្រោងចាប់ផ្តើមដំណើរការសាងសង់ ក្នុងកំឡុងពេលសាងសង់ និងក្រោយពេលសាងសង់រួច។ ដើម្បីធានាឱ្យបានថាការប្រតិបត្តិគម្រោងមិនមានហេតុប៉ះពាល់ធ្ងន់ធ្ងរដល់គុណភាពទឹក នៅក្នុងបរិវេណតំបន់គម្រោង និងនៅជុំវិញតំបន់គម្រោង ចាំបាច់ត្រូវមានការវិភាគគុណភាពទឹកឲ្យបានល្អិតល្អន់។ យ៉ាងណាមិញ **កោះក្របី** តាមលក្ខណៈសណ្ឋានដីប្រព័ន្ធទឹកនៅលើកោះមិនលេចជារូបរាបឹង ត្រពាំង ឬព្រែកនោះទេ គឺគ្រាន់តែមានប្រព័ន្ធអូរតូចៗ ដែលមានទឹកហូរនៅពេលភ្លៀងប៉ុណ្ណោះ។ ប្រព័ន្ធទឹកហូរនេះបានហូរចាក់ចូលនៅក្នុងសមុទ្រទាំងស្រុងនៅពេលមានភ្លៀងធ្លាក់ ហេតុដូចនេះគម្រោងអភិវឌ្ឍន៍តំបន់លំហែកាយកោះក្របី មិនមានប្រភពទឹកសាបនៅលើកោះដើម្បីប្រើប្រាស់ទេ និងមិនមានប្រភពទឹកសាបអាចយកសំណាកដើម្បីពិសោធន៍ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយគម្រោងបានជ្រើសរើសយកសំណាកទឹក៤ទីតាំងដើម្បីធ្វើការពិសោធន៍ផងដែរ។




រូបភាព៥.២៖ ផែនទីយកសំណាកទឹក

ក. លទ្ធផលគុណភាពទឹកអណ្តូង (ក្បែរឆ្នេរសមុទ្រវាម)

តាមលទ្ធផលនៃការវិភាគគុណភាពទឹកបានឲ្យឃើញថា ប៉ារ៉ាម៉ែត្រទាំងអស់ដែលបានយកមកវិភាគគុណភាពទឹកសម្រាប់ការបរិភោគប្រចាំថ្ងៃ មានចំនួន ៣ ប៉ារ៉ាម៉ែត្រដែលមានកំហាប់ប្រែប្រួលខុសពីស្តង់ដារ គឺ Total Dissolved Solid (TDS) សារធាតុរឹងរលាយសរុប Chloride ($Cl^-$) ក្លរ៉ូ Total Coliform កូលីហ្វមសរុប។ តាមស្តង់ដាររបស់ សារធាតុរឹងរលាយសរុប (Total Dissolved Solid) (TDS) មានតម្លៃ 800 mg/l ប៉ុន្តែលទ្ធផលមានតម្លៃ 1433 mg/l។ ចំណែក ក្លរ៉ូ Chloride ($Cl^-$) តាមស្តង់ដារមានតម្លៃ 250 mg/l ប៉ុន្តែតាមលទ្ធផលមានកំហាប់ 498.36 mg/l ។ រីឯ កូលីហ្វមសរុប Total Coliform មានកំហាប់ 0 MPN/100ml នៅក្នុងស្តង់ដារ ប៉ុន្តែលទ្ធផលមាន 200 MPN/100ml ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ចំនួននៃការប្រែប្រួលខុសពីស្តង់ដារនេះមិនបានបង្កឲ្យមានការបំពុលយ៉ាងធ្ងន់ធ្ងរដល់គុណភាពទឹក នោះទេ។

តារាង ៥.១៖ លទ្ធផលនៃការវិភាគគុណភាពទឹកអណ្តូង (ក្បែរឆ្នេរសមុទ្រវាម)

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | ស្តង់ដារ | លទ្ធផល | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| 1 | pH | - | 6.5~8.5 | 6.81 | Method MAJI Meter |
| 2 | Turbidity | NTU | 5.0 | 0.00 | Method MAJI Meter |
| 3 | Total Dissolved Solid (TDS) | mg/l | 800 | 1433.00 | Method MAJI Meter |
| 4 | Dissolved Oxygen (DO) | mg/l | NV | 6.02 | Method MAJI Meter |
| 5 | Salinity | Ppt | NV | 1.10 | Method MAJI Meter |
| 6 | Total Suspended Solid (TSS) | mg/l | NV | 217.00 | Method 2540 D |

| លរ | ប៉ារ៉ាម៉ែត្រ | ខ្នាត | ស្តង់ដារ | លទ្ធផល | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| 7 | Ammonium ($NH_4^+$) | mg/l | NV | ND | Method ICs-90 |
| 8 | Chloride ($Cl^-$) | mg/l | 250 | 498.36 | Method 4500-Cl F |
| 9 | Nitrate ($NO_3^-$) | mg/l | 50 | 5.56 | Method 4500-NO3 C |
| 10 | Phosphate ($PO_4^{3-}$) | mg/l | NV | ND | Method ICs-90 |
| 11 | Sulphate ( $SO_4^{2-}$) | mg/l | 250 | 47.97 | Method 4500-$SO_4^{2-}$ B |
| 12 | Biochemical Oxygen Demand (BOD) | mg/l | NV | 0.92 | Method 5210 B |
| 13 | Chemical Oxygen Demand (COD) | mg/l | NV | 2.01 | Method JIS K 0102 |
| 14 | Total Nitrogen (TN) | mg/l | NV | 0.18 | Method JIS K 0102 45 |
| 15 | Total Phosphorus (TP) | mg/l | NV | 0.03 | Method JIS K 0102 46 |
| 16 | Arsenic (As) | mg/l | 0.05 | ND | Method 3500-As D |
| 17 | Copper (Cu) | mg/l | 1.0 | ND | Method 3500-Cu C |
| 18 | Iron (Fe, Total) | mg/l | 0.3 | ND | Method 3500-Fe C |
| 19 | Lead (Pb) | mg/l | 0.01 | ND | Method 3500-Pb C |
| 20 | Mercury ( Hg) | mg/l | 0.001 | ND | Method ICP-MS |
| 21 | Zinc (Zn) | mg/l | 3.0 | ND | Method 3500-Zn C |
| 22 | Total Coliform | MPN/100ml | 0 | $2.0 \times 10^2$ | Method NF T90-413 (37 °C) |
| 23 | E-Coli | MPN/100ml | 0 | 0 | Method NF T90-413 (44 °C) |

**សំគាល់៖**

- ស្តង់ដារ៖ គឺជាកម្រិតកំណត់ស្តង់ដាគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សម្រាប់អភិរក្សជីវចំរុះនៅក្នុងទឹក និងសម្រាប់ការពារសុខភាពសាធារណៈ។
- ND= Not Detected មិនមានវត្តមាន
- NV= No Value គ្មានតំលៃ

**ខ. លទ្ធផលនៃការវិភាគគុណភាពទឹក យកចេញពីម៉ាស៊ីនទឹកប្រៃ ( បន្ទាប់ពីការសំអាត)**

តាមលទ្ធផលនៃការវិភាគគុណភាពទឹក ដែលយកចេញពីម៉ាស៊ីនទឹកប្រៃ បន្ទាប់ពីការសំអាត (After Treatment) បានឲ្យឃើញថា ប៉ារ៉ាម៉ែត្រដែលបានយកមកវិភាគទាំង ២៣ប៉ារ៉ាម៉ែត្រ សុទ្ធតែស្ថិតនៅក្រោមស្តង់ដារគុណភាពទឹក សម្រាប់ការរស់នៅរបស់ជីវចម្រុះ។ តាមលទ្ធផលនេះអាចសន្និដ្ឋានបានថា ទឹកដែលចេញពីម៉ាស៊ីនទឹកប្រៃពុំមានប៉ារ៉ាម៉ែត្រណាមួយដែលធ្វើឲ្យមានផលប៉ះពាល់ដល់គុណភាពទឹកសមុទ្របន្ទាប់ពីការសំអាត ( After Treatment) ហើយបង្ហូរចូលទៅក្នុងទឹកសមុទ្រវិញនោះទេ។

តារាង៥.២៖ លទ្ធផលនៃការវិភាគគុណភាពទឹក យកចេញពីម៉ាស៊ីនទឹកប្រៃ ( បន្ទាប់ពីការសំអាត)

| លរ | ប៉ារ៉ាម៉ែត្រ | ខ្នាត | ស្តង់ដារ | លទ្ធផល | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| 1 | pH | - | 7.0-8.3 | 7.70 | Method MAJI Meter |
| 2 | Turbidity | NTU | NV | 0.00 | Method MAJI Meter |
| 3 | Total Dissolved Solid (TDS) | mg/l | NV | 324.00 | Method MAJI Meter |
| 4 | Dissolved Oxygen (DO) | mg/l | 2.0-7.5 | 6.57 | Method MAJI Meter |
| 5 | Salinity | ppt | NV | 0.25 | Method MAJI Meter |
| 6 | Total Suspended Solid (TSS) | mg/l | NV | 105.00 | Method 2540 D |
| 7 | Ammonium ($NH_4^+$) | mg/l | NV | ND | Method ICs-90 |
| 8 | Chloride ($Cl^-$) | mg/l | NV | 138.13 | Method 4500-Cl F |
| 9 | Nitrate ($NO_3^-$) | mg/l | NV | 0.36 | Method 4500-NO3 C |
| 10 | Phosphate ($PO_4^{3-}$) | mg/l | NV | ND | Method ICs-90 |
| 11 | Sulphate ( $SO_4^{2-}$) | mg/l | NV | 2.92 | Method 4500-$SO_4^{2-}$ B |
| 12 | Biochemical Oxygen Demand (BOD) | mg/l | NV | 0.55 | Method 5210 B |
| 13 | Chemical Oxygen Demand (COD) | mg/l | 2.0-8.0 | 1.86 | Method JIS K 0102 |

| លរ | ប៉ារ៉ាម៉ែត្រ | ខ្នាត | ស្តង់ដារ | លទ្ធផល | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| 14 | Total Nitrogen (TN) | mg/l | 0.2-1.0 | 0.46 | Method JIS K 0102 45 |
| 15 | Total Phosphorus (TP) | mg/l | 0.02-0.09 | 0.01 | Method JIS K 0102 46 |
| 16 | Arsenic (As) | mg/l | 0.01 | 0.005 | Method 3500-As D |
| 17 | Copper (Cu) | mg/l | NV | ND | Method 3500-Cu C |
| 18 | Iron (Fe, Total) | mg/l | NV | ND | Method 3500-Fe C |
| 19 | Lead (Pb) | mg/l | 0.01 | ND | Method 3500-Pb C |
| 20 | Mercury ( Hg) | mg/l | 0.0005 | 0.0001 | Method ICP-MS |
| 21 | Zinc (Zn) | mg/l | NV | ND | Method 3500-Zn C |
| 22 | Total Coliform | MPN/100ml | 1000 | $1.1 \times 10^2$ | Method NF T90-413 (37 °C) |
| 23 | E-Coli | MPN/100ml | NV | 0 | Method NF T90-413 (44 °C) |

សំគាល់៖

- ស្តង់ដារ៖ គឺជាកម្រិតកំណត់ស្តង់ដាគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សម្រាប់អភិរក្សជីវចំរុះនៅក្នុងទឹក និងសម្រាប់ការពារសុខភាពសាធារណៈ។
- ND= Not Detected មិនមានវត្តមាន
- NV= No Value គ្មានតំលៃ

គ. លទ្ធផលនៃការវិភាគគុណភាពទឹកសមុទ្រ (ជុំវិញកោះក្របី)

ទឹកសមុទ្រនៅជុំវិញកោះក្របី គឺជាទឹកដែលគ្មានការបំពុលពីសកម្មភាពមនុស្ស និងធម្មជាតិឡើយ។ នៅពេលដែលមានគម្រោងអភិវឌ្ឍរមណីយដ្ឋានធម្មជាតិកោះក្របី ត្រូវទាមទារឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមសេដ្ឋកិច្ច។ ដូច្នេះ ត្រូវទាមទារឲ្យមានការវិភាគគុណភាពទឹក នៅជុំវិញកោះក្របី ដើម្បីចង់ដឹងពី គុណភាពរបស់វា មានការប្រែប្រួលកម្រិតណា? យោងតាមលទ្ធផលនៃការវិភាគ បានបង្ហាញថា ប៉ារ៉ាម៉ែត្រទាំងអស់ដែលបានយកមកវិភាគទាំង ២៣ ប៉ារ៉ាម៉ែត្រ ពុំមានប៉ារ៉ាម៉ែត្រណាមួយដែលមានកំហាប់លើសពីស្តង់ដារដែលបានកំណត់ឡើយ។ នេះបញ្ជាក់ឲ្យឃើញថា គុណភាពទឹកនៅជុំវិញកោះក្របី ក្បែរតំបន់គម្រោងពុំមានផលប៉ះពាល់ជាអវិជ្ជមានទេ។

តារាង៥.៣៖ លទ្ធផលនៃការវិភាគគុណភាពទឹកសមុទ្រ (ជុំវិញកោះក្របី)

| លរ | ប៉ារ៉ាម៉ែត្រ | ខ្នាត | ស្តង់ដារ | លទ្ធផល | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| 1 | pH | - | 7.0-8.3 | 7.79 | Method MAJI Meter |
| 2 | Turbidity | NTU | NV | 0.00 | Method MAJI Meter |
| 3 | Total Dissolved Solid (TDS) | mg/l | NV | 1432.00 | Method MAJI Meter |
| 4 | Dissolved Oxygen (DO) | mg/l | 2.0-7.5 | 6.35 | Method MAJI Meter |
| 5 | Salinity | ppt | NV | 1.10 | Method MAJI Meter |
| 6 | Total Suspended Solid (TSS) | mg/l | NV | 258.00 | Method 2540 D |
| 7 | Ammonium ($NH_4^+$) | mg/l | NV | ND | Method ICs-90 |
| 8 | Chloride ($Cl^-$) | mg/l | NV | 20731.62 | Method 4500-Cl F |
| 9 | Nitrate ($NO_3^-$) | mg/l | NV | 40.83 | Method 4500-NO3 C |
| 10 | Phosphate ($PO_4^{3-}$) | mg/l | NV | ND | Method ICs-90 |
| 11 | Sulphate ( $SO_4^{2-}$) | mg/l | NV | 1991.13 | Method 4500-$SO_4^{2-}$ B |
| 12 | Biochemical Oxygen Demand (BOD) | mg/l | NV | 1.26 | Method 5210 B |
| 13 | Chemical Oxygen Demand (COD) | mg/l | 2.0-8.0 | 2.80 | Method JIS K 0102 |
| 14 | Total Nitrogen (TN) | mg/l | 0.2-1.0 | 0.33 | Method JIS K 0102 45 |

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | ស្តង់ដារ | លទ្ធផល | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| 15 | Total Phosphorus (TP) | mg/l | 0.02-0.09 | 0.05 | Method JIS K 0102 46 |
| 16 | Arsenic (As) | mg/l | 0.01 | 0.007 | Method 3500-As D |
| 17 | Copper (Cu) | mg/l | NV | 0.01 | Method 3500-Cu C |
| 18 | Iron (Fe, Total) | mg/l | NV | 0.11 | Method 3500-Fe C |
| 19 | Lead (Pb) | mg/l | 0.01 | 0.006 | Method 3500-Pb C |
| 20 | Mercury ( Hg) | mg/l | 0.0005 | ND | Method ICP-MS |
| 21 | Zinc (Zn) | mg/l | NV | ND | Method 3500-Zn C |
| 22 | Total Coliform | MPN/100ml | 1000 | $7.5 \times 10^2$ | Method NF T90-413 (37 °C) |
| 23 | E-Coli | MPN/100ml | NV | 0 | Method NF T90-413 (44 °C) |

សំគាល់៖

- ស្តង់ដារ៖ គឺជាកម្រិតកំណត់ស្តង់ដាគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សម្រាប់អភិរក្សជីវចំរុះនៅក្នុងទឹក និងសម្រាប់ការពារសុខភាពសាធារណៈ។
- ND= Not Detected មិនមានវត្តមាន
- NV= No Value គ្មានតំលៃ

ឃ. លទ្ធផលនៃការវិភាគគុណភាពទឹកសមុទ្រ

ទឹកសមុទ្រនៅក្បែរតំបន់គម្រោង ក៏ជាទឹកដែលគ្មានការបំពុលពីសកម្មភាពមនុស្ស និងធម្មជាតិដែរ។ នៅពេលដែលមានគម្រោងអភិវឌ្ឍរមណីយដ្ឋានធម្មជាតិកោះក្របី ត្រូវទាមទារឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមសេដ្ឋកិច្ច។ ដូច្នេះ ត្រូវទាមទារឲ្យមានការវិភាគគុណភាពទឹក នៅជុំវិញកោះក្របី ដើម្បីចង់ដឹងថាតើ គុណភាពរបស់វា មានការប្រែប្រួលកម្រិតណា? យោងតាមលទ្ធផលនៃការវិភាគ បានបង្ហាញថា ប៉ារ៉ាម៉ែត្រទាំងអស់ដែលបានយកមកវិភាគទាំង ២៣ ប៉ារ៉ាម៉ែត្រ មានប៉ារ៉ាម៉ែត្រ តែមួយប៉ុណ្ណោះគឺប៉ារ៉ត ( Hg) ដែលមានកំហាប់លើសពីស្តង់ដារ។ នៅក្នុងស្តង់ដារមានតំលៃ <0.0005 mg/l ប៉ុន្តែលទ្ធផលមានតំលៃ 0.062mg/l។ ការលើសកំហាប់បែបនេះអាចប៉ះពាល់យ៉ាងខ្លាំង លើសុខភាពប្រជាជន ដែលបរិភោគត្រីដែលនេសាទពីតំបន់នោះ ដូចជា ប្រព័ន្ធសសៃប្រសាទ ប្រព័ន្ធរំលាយអាហារ ស្បែក ជំងឺសួត តម្រងនោម ស្បែក និងភ្នែក ជាពិសេសវាអាចរាំងស្ទះការលូតលាស់ទារកក្នុងផ្ទៃ និងកុមារ ។

តារាង៥.៨៖ លទ្ធផលនៃការវិភាគគុណភាពទឹកសមុទ្រ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | ស្តង់ដារ | លទ្ធផល | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| 1 | pH | - | 7.0-8.3 | 7.25 | pH-EC& TDS meter |
| 2 | Turbidity | NTU | - | 2.50 | Digital Turbidity Meter |
| 3 | Total Dissolved Solid (TDS) | mg/l | - | 4900.00 | pH-EC& TDS meter |
| 4 | Total Suspended Solid (TSS) | mg/l | - | 306.00 | Method 2540 D |
| 6 | Dissolved Oxygen (DO) | mg/l | 2.0-7.5 | 5.86 | DO meter |
| 7 | Chloride ($Cl^-$) | mg/l | - | 21558.31 | ICS-90 Ion Chromatography |
| 8 | Sulphate ( $SO_4^{2-}$) | mg/l | - | 2031.78 | ICS-90 Ion Chromatography |
| 9 | Nitrate ($NO_3^-$) | mg/l | - | ND<0.1 | ICS-90 Ion Chromatography |
| 10 | Phosphate ($PO_4^{3-}$) | mg/l | - | ND<0.1 | ICS-90 Ion Chromatography |

#322P, St.27'Z, Sk.Tark Tla, Khan Ressy Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 4789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | ស្តង់ដារ | លទ្ធផល | វិធីសាស្ត្រវិភាគ |
|---|---|---|---|---|---|
| 11 | Ammonium ($NH_4^+$) | mg/l | - | ND<0.14 | ICS-90 Ion Chromatography |
| 12 | Biochemical Oxygen Demand (BOD) | mg/l | - | 0.17 | Method 5210 B |
| 13 | Chemical Oxygen Demand (COD) | mg/l | 2.0-8.0 | 0.49 | JIS K 0102 |
| 14 | Total Phosphorus (TP) | mg/l | 0.02-0.09 | 0.03 | K2S208 Decomposition - UV |
| 15 | Total Nitrogen (TN) | mg/l | 0.2-1.0 | 0.24 | K2S208 Decomposition - UV |
| 16 | Arsenic (As) | mg/l | <0.01 | ND<0.0001 | Method 3030 K-ICP MS |
| 17 | Copper (Cu) | mg/l | - | 0.30 | Method 3030 K-ICP MS |
| 18 | Iron (Fe, Total) | mg/l | - | 0.06 | Method 3030 K-ICP MS |
| 19 | Lead (Pb) | mg/l | <0.01 | 0.002 | Method 3030 K-ICP MS |
| 20 | Mercury ( Hg) | mg/l | <0.0005 | 0.062 | Method 3112 B |
| 21 | Zinc (Zn) | mg/l | - | 0.03 | Method 3030 K-ICP MS |
| 22 | Total Coliform | MPN/100ml | <1000 | 90 | MPN- Incubated at 30,37 °C |
| 23 | E-Coli | MPN/100ml | - | 0 | Micro plate, 44 °C |

សំគាល់៖

- ស្តង់ដារ៖ គឺជាកម្រិតកំណត់ស្តង់ដាគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សម្រាប់អភិរក្សជីវចំរុះនៅក្នុងទឹក និងសម្រាប់ការពារសុខភាពសាធារណៈ។
- ND= Not Detected មិនមានវត្តមាន
- NV= No Value គ្មានតំលៃ

### ៤.២.៦ ធាតុអាកាស និង ឧតុនិយម

ជាទូទៅតំបន់កោះក្របី ក៏ដូចជាតំបន់ដ៏ទៃទៀត នៅក្នុងប្រទេសកម្ពុជាទាំងមូល គឺទទួលរបបខ្យល់មូសុងត្រូពិច ដែលមានលក្ខណៈក្តៅហើយសើមពេញមួយឆ្នាំ ក៏ប៉ុន្តែសីតុណ្ហភាពមានសភាពត្រជាក់បន្តិចនៅចន្លោះ ខែវិច្ឆិកា និងមករា។ រដូវភ្លៀង ចាប់ផ្តើមពីខែមិថុនា ដល់ខែតុលា ដោយនាំមកជាមួយនូវ ខ្យល់ សំណើម និងភ្លៀងខ្លាំង។ ទិន្នន័យអំពីកម្ពស់ទឹកភ្លៀង សីតុណ្ហភាព សំណើម និង ល្បឿនខ្យល់បក់ ត្រូវបានវាស់ដោយស្ថានីយ៍អាកាសធាតុ និងឧតុនិយមខេត្តព្រះសីហនុ ដែលមានរយៈទទឹង១០°៣៧' រយៈបណ្តោយ១០៣°២៩' និងរយៈកម្ពស់១៣ម៉ែត្រ។

#### ក. សីតុណ្ហភាព

សីតុណ្ហភាព គឺជាកត្តាអាកាសធាតុសំខាន់មួយ ទាក់ទងទៅនឹងចលនាបម្រែបម្រួល និងការកកើតរបស់ជីវៈចម្រុះទាំងនៅលើគោក និងក្នុងទឹក។ កំណើនសីតុណ្ហភាព អាចបណ្តាលឱ្យមានឥទ្ធិពលផ្ទាល់ទៅលើជីវចម្រុះ ដោយធ្វើឱ្យផ្លាស់ប្តូរបរិស្ថានរស់នៅរបស់ពពួកជីវៈចម្រុះ ដែលធ្វើឱ្យការលូតលាស់របស់រុក្ខជាតិ សត្វមួយចំនួនមានការធ្លាក់ចុះ ឬរហូតដល់បាត់បង់ ហើយក៏អាចធ្វើឱ្យសត្វមួយចំនួន ដែលអាចបន្សាំទៅនឹងកំណើនសីតុណ្ហភាពនេះ អាចមានការកើនឡើងផងដែរ។

តាមរយៈការសិក្សាអំពីសីតុណ្ហភាព នៅស្ថានីយ៍ខេត្តព្រះសីហនុពីឆ្នាំ ២០១០-២០១៤ បានឲ្យដឹងថា សីតុណ្ហភាពអប្បបរមាគិតជាមធ្យមប្រចាំខែ ក្នុងរយៈពេល៥ឆ្នាំគឺ ២១.៤-២៤.៧ អង្សាសេ។ ចំពោះខែ ដែលមានសីតុណ្ហភាពត្រជាក់ជាងគេគឺ ខែធ្នូ និងមករា ដែលមានសីតុណ្ហភាពជាមធ្យម ២០.៨-២២.០អង្សាសេ (តារាង៥.៥)។ ចំនែកឯ ខែដែលមានសីតុណ្ហភាពក្តៅជាងគេ គឺខែ មេសា ឧសភា និងមិថុនា ដែលមានសីតុណ្ហភាពមធ្យមជាអតិបរមា ៣៣.២ អង្សាសេ (តារាង៥.៦ និងក្រាហ្វិក៥.១)។

**តារាង៥.៥៖** កម្រិតសីតុណ្ហភាពមធ្យមអតិបរមា ជាមធ្យមប្រចាំខែនៅស្ថានីយ៍ខេត្តព្រះសីហនុពីឆ្នាំ ២០១០-២០១៤ លើរយៈទទឹង១០°៣៧' រយៈបណ្តោយ១០៣°២៩' និងរយៈកម្ពស់១៣ម៉ែត្រ

| ខែ / ឆ្នាំ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មធ្យមប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2010 | 32.5 | 33.5 | 35.0 | 35.5 | 35.0 | 34.0 | 33.0 | 32.5 | 33.0 | 32.5 | 34.0 | 32.0 | **33.5** |
| 2011 | 34.0 | 35.0 | 32.0 | 33.4 | 33.0 | 34.0 | 32.5 | 32.0 | 32.5 | 33.0 | 33.5 | 32.5 | **33.1** |
| 2012 | 34.5 | 33.0 | 33.0 | 33.5 | 38.5 | 33.0 | 32.5 | 32.0 | 32.8 | 32.5 | 33.5 | 33.0 | **33.5** |
| 2013 | 32.5 | 33 | 35 | 35.5 | 36 | 33.6 | 31.5 | 33 | 33 | 33 | 32.7 | 31.5 | **33.4** |
| 2014 | 29.4 | 29.4 | 30.9 | 32.0 | 32.6 | 31.2 | 30.2 | 31.0 | 30.6 | 31.5 | 31.9 | 31.7 | **31.0** |
| មធ្យម | 32.6 | 32.8 | 33.2 | 34.0 | 35.0 | 33.2 | 31.9 | 32.1 | 32.4 | 32.5 | 33.1 | 32.1 | **32.9** |

ប្រភព: នាយកដ្ឋានឧតុនិយម ឆ្នាំ ២០១៤




ក្រាហ្វិក៥.១៖ កម្រិតសីតុណ្ហភាពអតិបរមាប្រចាំឆ្នាំក្នុងខេត្តព្រះសីហនុ ២០១០-២០១៤

តារាង៥.៦៖ កម្រិតសីតុណ្ហភាពមធ្យមអប្បបរមា ជាមធ្យមប្រចាំខែនៅស្ថានីយ៍ខេត្តព្រះសីហនុពីឆ្នាំ ២០១០-២០១៤ លើរយៈទទឹង១០°៣៧' រយៈបណ្តោយ១០៣°២៥' និងរយៈកម្ពស់១៣ម៉ែត្រ

| ខែ / ឆ្នាំ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មធ្យមប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2010 | 23.0 | 24.0 | 25.5 | 25.0 | 24.5 | 23.5 | 23.0 | 20.5 | 20.0 | 22.0 | 20.5 | 22.5 | **22.8** |
| 2011 | 19.5 | 23.0 | 19.5 | 23.5 | 23.5 | 20.5 | 23.0 | 20.0 | 22.0 | 23.0 | 22.0 | 17.5 | **21.4** |
| 2012 | 22.2 | 20.0 | 23.5 | 24.0 | 23.0 | 24.5 | 23.0 | 21.0 | 20.5 | 23.0 | 20.0 | 21.5 | **22.2** |
| 2013 | 22.9 | 23 | 23 | 24 | 22.5 | 23.4 | 19.5 | 22.5 | 22 | 23 | 23.5 | 19.5 | **22.4** |
| 2014 | 22.5 | 24.5 | 25.2 | 26.3 | 26.8 | 25.4 | 24.2 | 24.7 | 24.3 | 25.3 | 24.8 | 23.2 | **24.8** |
| មធ្យម | 22.0 | 22.9 | 23.3 | 24.6 | 24.1 | 23.5 | 22.5 | 21.7 | 21.8 | 23.3 | 22.2 | 20.8 | **22.7** |

ប្រភព: នាយកដ្ឋានឧតុនិយម ឆ្នាំ២០១៤




ក្រាហ្វិក៥.២៖ កម្រិតសីតុណ្ហភាពអប្បរមាប្រចាំឆ្នាំក្នុងខេត្តព្រះសីហនុ ២០១៤-២០១៥

តាមក្រាហ្វិកខាងក្រោម អាចសន្និដ្ឋានបានថា គម្លាតរវាងកម្រិតមធ្យមនៃសីតុណ្ហភាពអតិបរមា និងអប្បបរមាប្រចាំឆ្នាំមានគម្លាតជាមធ្យមប្រមាណជា ១០អង្សាសេ ដែលជាគម្លាតធម្មតាសម្រាប់ប្រទេសដែលមានអាកាសធាតុត្រូពិច ហើយការប្រែប្រួលនេះ មិនប៉ះពាល់ខ្លាំងធ្ងន់ធ្ងរដល់មនុស្ស សត្វ និងរុក្ខជាតិឡើយ។




ក្រាហ្វិក៥.៣៖ កម្រិតគម្លាតសីតុណ្ហភាព អតិបរមា និងអប្បបរមាមធ្យមប្រចាំឆ្នាំក្នុងខេត្តព្រះសីហនុ

### ខ. កម្ពស់ទឹកភ្លៀង

ទឹកភ្លៀង ត្រូវបានចាត់ទុកជាប្រភពទឹកស្អាត សម្រាប់ការប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ និងជាប្រភពទឹកស្រោចស្រពដ៏សំខាន់ ជាពិសេសនៅក្នុងតំបន់ជនបទប្រទេសអភិវឌ្ឍន៍។ ប្រទេសកម្ពុជា ចាត់ទុកជាតំបន់មួយដែលមានរបបទឹកភ្លៀងខ្ពស់បង្គួរ ដោយសារតែការទទួលរងនូវឥទ្ធិពលខ្យល់មូសុង (១,៨១៣mm/ឆ្នាំ) ។ របាយទឹកភ្លៀងនៅប្រទេសកម្ពុជាមានភាពមិនស្មើគ្នាទេ របបទឹកភ្លៀងមានកម្រិតខ្ពស់នៅតំបន់និរតីប្រទេស(តំបន់ឆ្នេរ) និងតំបន់ប៉ែកឦសាន្ត ហើយតំបន់ដែលមានកម្រិតទឹកភ្លៀងទាប គឺនៅតំបន់ទំនាប។ របាយនៃការប្រែប្រួលទឹកភ្លៀងនេះ ចាប់ពី១.០០០mmទៅ ៣.៤០០mm ជារៀងរាល់ឆ្នាំ។

យោងតាមទិន្នន័យនៃការវាស់កម្រិតទឹកភ្លៀងនៅខេត្តព្រះសីហនុបានឱ្យដឹងថា កម្រិតកម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំ ក្នុងរយៈពេល៥ឆ្នាំពី២០០៩-២០១៣គឺ ២.៤៦០,៧៨mm ហើយកម្រិតទឹកភ្លៀងអតិបរមា ២.៧៥៨,៤mm និងកម្រិតទឹកភ្លៀងអប្បរមាគឺ ២.១៧៥,៦mm ។ ខែដែលមានកម្ពស់ទឹកភ្លៀងច្រើនជាងគេគឺនៅចន្លោះខែកញ្ញា មានកម្ពស់ ៥៨១.៩mm ។ ចំពោះខែ ដែលមានកម្ពស់ទឹកភ្លៀងតិចជាងគេ គឺខែមករា ដែលមានកម្ពស់មធ្យមត្រឹមតែ ២០,៦៨mm ។ ម្យ៉ាងវិញទៀត កម្រិតទឹកភ្លៀងប្រចាំខែកក្កដា កើតឡើងគួរឱ្យកត់សម្គាល់ ពី ៣៧៩.១mm ទៅ ៦០៨.៣mm ដែលអាចបង្កជាហានិភ័យទឹកជំនន់ នៅកំឡុងខែនេះប្រសិនជាកម្រិតទឹកភ្លៀងនៅ តែបន្តកើនឡើងនៅពេលអនាគត (តារាង ៥.៧ និងក្រាហ្វិក៥.៨)។

តារាង៥.៧៖ កម្រិតកម្ពស់ទឹកភ្លៀងជាមធ្យមប្រចាំខែ ពីឆ្នាំ ២០០៩-២០១៣ប្រចាំខេត្តព្រះសីហនុ
លើរយៈទទឹង១០°៣៧' រយៈបណ្តោយ១០៣°២៩' និងរយៈកម្ពស់១៣ម៉ែត្រ

| ខែ / ឆ្នាំ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុបប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2009 | 2.4 | 6.8 | 113.3 | 127.4 | 353.2 | 141.5 | 379.1 | 220.8 | 715.1 | 215.7 | 14.4 | 52.7 | **2342.4** |
| 2010 | 46.2 | 0.6 | 2.6 | 78.4 | 249.8 | 204.4 | 438.8 | 303 | 176.6 | 480.6 | 164.4 | 30.2 | **2175.6** |
| 2011 | 1.2 | 12.8 | 126 | 119.8 | 97 | 277.6 | 355 | 442.8 | 732.5 | 131.9 | 43.3 | 5.4 | **2345.3** |
| 2012 | 47.0 | 126.6 | 97.4 | 108.1 | 394.9 | 273.3 | 397.4 | 271.8 | 714.9 | 169.0 | 145.8 | 12.2 | **2758.4** |
| 2013 | 6.6 | 27.4 | 69.8 | 187.6 | 237.2 | 312.7 | 608.3 | 319.8 | 459.5 | 294.3 | 114.2 | 44.8 | **2682.2** |
| មធ្យម | 20.68 | 34.84 | 81.82 | 124.26 | 266.42 | 241.9 | 435.72 | 311.64 | 559.72 | 258.3 | 96.42 | 29.06 | 2460.78 |
| អប្បបរមា | 1.2 | 0.6 | 2.6 | 78.4 | 97 | 141.5 | 355 | 220.8 | 176.6 | 131.9 | 14.4 | 5.4 | 2175.6 |
| អតិបរមា | 47 | 126.6 | 126 | 187.6 | 394.9 | 312.7 | 608.3 | 442.8 | 732.5 | 480.6 | 164.4 | 52.7 | 2758.4 |

ប្រភព: នាយកដ្ឋានឧតុនិយម ឆ្នាំ២០១៣




ក្រាហ្វិក៥.៩៖ កម្រិតកម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំពីឆ្នាំ ២០០៩-២០១៣

## គ. ល្បឿនខ្យល់បក់

ខេត្តព្រះសីហនុ ក៏ដូចជាតំបន់ផ្សេងៗផងដែរ គឺទទួលរងនូវរបបខ្យល់មូសុងប្រាំង និងមូសុងវស្សា ដែលមានទិស និងសភាពនៃខ្យល់មានលក្ខណៈខុសប្លែកពីគ្នា។ យ៉ាងណាមិញ ខ្យល់ក៏មានឥទ្ធិពល ទៅលើបរិស្ថានរស់នៅរបស់ជីវៈចម្រុះ ព្រមទាំងចរន្តទឹកផងដែរ។ យោងតាមទិន្នន័យរយៈពេល៥ឆ្នាំ(២០០៩-២០១៣) បានឱ្យដឹងថា នៅតំបន់នេះខ្យល់បក់ប្រែប្រួលមិនទៀតទាត់ទេ។ ល្បឿនខ្យល់បក់ជាមធ្យមប្រចាំឆ្នាំ នៅក្នុងរយៈពេល៥ឆ្នាំនេះគឺ ៨,៣ម៉ែត្រ/១នាទី។ ឆ្នាំដែលមានល្បឿនខ្យល់បក់ខ្លាំងជាងគេគឺ ឆ្នាំ២០០៩និង២០១០ ដែលមានល្បឿនជាមធ្យម ៩,៩ម៉ែត្រ/១នាទី។ តាមតារាង ៥.៨ បានបង្ហាញថា ខែកុម្ភៈ មីនានិងមេសា ខ្យល់បក់ពីទិសឦសាន្ត ក្នុងល្បឿនមធ្យម៥,៨-៦,៦ម៉ែត្រ/១នាទី។ ចំណែកឯ កក្កដា សីហា និងកញ្ញា ខ្យល់បក់ពាយ័ព្យ ក្នុងល្បឿនជាមធ្យម ១០,០-១១,០ម៉ែត្រ/១វិនាទី។

តារាង៥.៨៖ កម្រិតល្បឿនខ្យល់បក់ប្រចាំខែនៅខេត្តព្រះសីហនុពីឆ្នាំ ២០០៩-២០១៣ (ម៉ែត្រ/១នាទី)
លើរយៈទទឹង១០°៣៧' រយៈបណ្ដោយ១០៣°២៩' និងរយៈកម្ពស់១៣ម៉ែត្រ

| ទិស | ខែ / ឆ្នាំ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មធ្យមប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| W-dd | 2009 | NW | NE | SE | NW | NE | NW | NW | NW | NW | NW | NW | NE | 9.9 |
| W-ss | | 10.0 | 5.0 | 6.0 | 7.0 | 7.0 | 13.0 | 17.0 | 9.0 | 9.0 | 13.0 | 14.0 | 9.0 | |
| W-dd | 2010 | NW | S | SE | NW | NW | SW | NW | NW | NW | NW | NE | NE | 9.8 |
| W-ss | | 9.0 | 7.0 | 6.0 | 5.0 | 21.0 | 8.0 | 7.0 | 16.0 | 17.0 | 7.0 | 8.0 | 7.0 | |
| W-dd | 2011 | NE | E | N | SW/SE | N | NW | NW | NW/W | NW | NW/W | NE | NE | 6.4 |
| W-ss | | 5.0 | 7.0 | 6.0 | 4.0 | 5.0 | 7.0 | 8.0 | 9.0 | 8.0 | 7.0 | 5.0 | 6.0 | |
| W-dd | 2012 | NE | NE | W/SE | SW/SE | NW | NW | NW | NW/W | NW | NW/W | NE/N | NE | 7.8 |
| W-ss | | 6.0 | 9.0 | 5.0 | 4.0 | 8.0 | 10.0 | 6.0 | 10.0 | 9.0 | 12.0 | 8.0 | 6.0 | |
| W-dd | 2013 | NE | NNE | SW | WNW | SW | SW | NW | WSW | NW | NNW | NNW | NNW | 7.6 |
| W-ss | | 3.0 | 5.0 | 6.0 | 9.0 | 5.0 | 5.0 | 12.0 | 10.0 | 12.0 | 8.0 | 7.0 | 9.0 | |
| មធ្យមប្រចាំខែ | | 6.6 | 6.6 | 5.8 | 5.8 | 9.2 | 8.6 | 10.0 | 10.8 | 11.0 | 9.4 | 8.4 | 7.4 | 8.3 |
| អតិបរមា | | 10.0 | 9.0 | 6.0 | 9.0 | 21.0 | 13.0 | 17.0 | 16.0 | 17.0 | 13.0 | 14.0 | 9.0 | 9.9 |
| អប្បបរមា | | 3.0 | 5.0 | 5.0 | 4.0 | 5.0 | 5.0 | 6.0 | 9.0 | 8.0 | 7.0 | 5.0 | 6.0 | 6.4 |

ប្រភព: នាយកដ្ឋានឧតុនិយមឆ្នាំ២០១៣

## ឃ. កម្រិតសំណើម

កម្រិតសំណើម គឺជាកត្តាមួយសំខាន់ផងដែរសម្រាប់ការរស់រានមានជីវិតរបស់ជីវចម្រុះលើគោកដោយរាប់បញ្ចូលទាំងមនុស្សផងដែរ។ ជាក់ស្តែង កម្រិតសំណើមខ្ពស់ពេកធ្វើអោយរាងកាយមនុស្សពិបាកនឹងបញ្ចេញញើសមកខាងក្រៅ ដែលបណ្តាលអោយកំដៅក្នុងរាងកាយពិបាកនឹងបញ្ចេញមកខាងក្រៅ រីឯជំងឺផ្សិតជាជំងឺរុក្ខជាតិ ដែលនឹងងាយមានកំណើនឆាប់រហ័ស

ហើយក៏ជាបរិស្ថានរស់នៅដ៏សមស្របសម្រាប់សត្វល្អិតផងដែរ។ ផ្ទុយទៅវិញ កម្រិតសំណើមទាបជ្រុល អាចបណ្តាលអោយកើតមានអេឡិចត្រូស្តាទិកដែលប៉ះពាល់សុខភាពមនុស្ស ហើយបង្កអោយមានអគ្គីភ័យយ៉ាងងាយស្រួលផងដែរ។ ប៉ុន្តែសំណើមខ្ពស់ល្មម អាចធ្វើឱ្យភាគល្អិតមួយចំនួនធ្លាក់ចុះ ជួយដល់ការពន្យឺតកំណើតវីរុសផ្តាសាយ និងអាលែហ្ស៊ី (Allergy)។ ម្យ៉ាងទៀត កម្រិតសំណើមអាចចង្អុលបង្ហាញអោយយើងដឹងអំពីបរិមាណភ្លៀង ឬការចុះអ័ព្ទផងដែរ។

យោងតាមទិន្នន័យនៃការវាស់កម្រិតសំណើម ក្នុងកំឡុងពេល៥ឆ្នាំ (២០០៧-២០១១) បានឱ្យដឹងថា នៅខេត្តព្រះសីហនុ មានកម្រិតសំណើមជាមធ្យមប្រចាំឆ្នាំ ៨២%។ ខែដែលមានកម្រិតសំណើមខ្ពស់ជាងគេគឺនៅខែកញ្ញា (៨៦%)។ យោងតាមទិន្នន័យនេះដដែល បញ្ជាក់ឱ្យដឹងថាកម្រិតសំណើមភាគច្រើនកើនឡើងខ្ពស់ស្របពេលនៅរដូវភ្លៀងធ្លាក់។

**តារាង៥.៩៖** កម្រិតភាពសំណើមមធ្យមប្រចាំខែពីឆ្នាំ ២០០៩-២០១៣ ប្រចាំខេត្តព្រះសីហនុ

លើរយៈទទឹង១០°៣៧' រយៈបណ្តោយ១០៣°២៩' និងរយៈកម្ពស់១៣ម៉ែត្រ

| ខែ / ឆ្នាំ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មធ្យមប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 2009 | 75.8 | 84.7 | 84.4 | 82.0 | 83.6 | 83.3 | 86.0 | 83.1 | 88.8 | 86.1 | 80.0 | 79.9 | **83.1** |
| 2010 | 77.5 | 78.8 | 76.8 | 76.8 | 77.4 | 80.5 | 82.1 | 84.7 | 82.6 | 85.0 | 81.4 | 77.9 | **80.1** |
| 2011 | 67.8 | 77.0 | 75.7 | 80.0 | 79.5 | 83.1 | 83.3 | 83.2 | 86.2 | 83.8 | 81.5 | 75.6 | **79.7** |
| 2012 | 77.5 | 81.8 | 87.1 | 82.0 | 81.6 | 83.5 | 84.1 | 86.5 | 90.9 | 85.3 | 86.6 | 79.0 | **83.8** |
| 2013 | 65.2 | 63.5 | 68.4 | 71 | 73.2 | 79.3 | 81.7 | 82 | 81.9 | 80.9 | 73.1 | 64.3 | **73.7** |
| មធ្យម | 72.8 | 77.1 | 78.5 | 78.3 | 79.1 | 81.9 | 83.4 | 83.9 | 86.1 | 84.2 | 80.5 | 75.4 | 80.1 |
| អតិបរមា | 77.5 | 84.7 | 87.1 | 82.0 | 83.6 | 83.5 | 86.0 | 86.5 | 90.9 | 86.1 | 86.6 | 79.9 | 83.8 |
| អប្បបរមា | 65.2 | 63.5 | 68.4 | 71.0 | 73.2 | 79.3 | 81.7 | 82.0 | 81.9 | 80.9 | 73.1 | 64.3 | 73.7 |

ប្រភព: នាយកដ្ឋានឧតុនិយម ឆ្នាំ២០១៣




ក្រាហ្វិក៥.៥៖ កម្រិតសំនើមមធ្យមប្រចាំខែ ២០០៩-២០១៣

# ការសិក្សាធនធានព្រៃឈើ និងសត្វព្រៃ

## ៥.៣ ធនធានជីវសាស្ត្រ

### ៥.៣.១ ការសិក្សាពីព្រៃឈើ

គម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីរបស់ក្រុមហ៊ុន **អគីប៊ី អ៊ិនវេសមេន ខូអិលធីឌី** ជាប្រភេទគម្រោងនៃការ អភិវឌ្ឍន៍រមណីយដ្ឋានដែលមានផ្ទះលំហែកាយចំនួន ៤០ខ្នង ភោជនីយដ្ឋាន និងសេវាកម្មផ្សេងៗ លើផ្ទៃដីលើកោះដែលមានផ្ទៃដីអភិវឌ្ឍន៍សរុប ១០ហិកតា។

ក្នុងការវិនិយោគនេះ ក្រុមហ៊ុនបានកំណត់ទីតាំងសាងសង់ផ្ទះនៅទីវាលជាក់ស្តែងយោងតាមប្លង់គំរូរួចជាស្រេច ដោយការដាក់តាំងប្លង់នេះគឺធ្វើទៅតាមប្លង់មេ និងព្យាយាមជៀសវាងការកាប់ព្រៃឈើជាអតិបរមាតាមរយៈការរំកិលប្លង់ ប្រសិនបើនៅពេលដាក់តាំងប៉ះចំដើមឈើធំចាប់ពីមុខកាត់២០សង់ទីម៉ែត្រឡើងទៅត្រូវរក្សាទុក នោះក្រុមហ៊ុនត្រូវបង្វែទិសដៅទីតាំងសាងសង់វិញទោះបីជាប្លង់មេបានកំណត់រួចហើយក៏ដោយ។

ការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) តំបន់អភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីមានផ្ទៃដីទំហំ ១០ហិកតា ដោយប្រើប្រាស់ផែនទីគម្របព្រៃឈើឆ្នាំ២០០២ ឆ្នាំ២០០៦ និងឆ្នាំ២០១០ ដើម្បីពិនិត្យស្ថានភាពគម្របព្រៃឈើ ដែលតាមការសិក្សាបានបង្ហាញថា ព្រៃឈើតំបន់នេះក្នុងរយៈ ១០ឆ្នាំកន្លងមកពុំមានភាពប្រែប្រួលទេ។

តាមការពិនិត្យពីទិដ្ឋភាពជាក់ស្តែងនៃតំបន់អភិវឌ្ឍន៍ ឃើញថាស្ថានភាពព្រៃឈើជាព្រៃស្រោង ហើយពុំសូវមានរុក្ខជាតិស្រទាប់ក្រោមនោះទេ។ ភាពមិនសូវមានរុក្ខជាតិស្រទាប់ក្រោមដុះដោយសារនៅពេលចុះសិក្សាស្រាវជ្រាវ ក្រុមហ៊ុនបានចាប់ផ្តើមកំណត់ទីតាំងប្លង់សម្រាប់សាងសង់ផ្ទះលំហែកាយរួចជាស្រេច ដែលការដាក់តាំងនេះទាមទាបោសសំអាតរុក្ខជាតិស្រទាប់ក្រោមជាមុនសិន ។ ដោយឡែកចំពោះភាពមិនប្រែប្រួលគម្របព្រៃឈើនៃតំបន់នេះ មកពីកោះនេះមានទីតាំងស្ថិតនៅឆ្ងាយពីភូមិដែលប្រជាជនរស់នៅ និងភាគច្រើនពួកគាត់ប្រកបរបរជាអ្នកនេសាទ។

### ខ. លទ្ធផលវាយតម្លៃធនធានព្រៃឈើ

ការប៉ាន់ស្មានធនធានព្រៃឈើ ដែលមានវត្តមានក្នុងតំបន់គម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី របស់ក្រុមហ៊ុន**អគីប៊ី អ៊ិនវេសមេន ខូអិលធីឌី** បានអនុវត្តន៍តាមលក្ខណៈបច្ចេកទេស និងទទួលបានលទ្ធផលដូចខាងក្រោម:

#### ខ.១ ធនធានឈើ

លទ្ធផលនៃការសិក្សាវាយតម្លៃធនធានព្រៃឈើមានបីកម្រិតផ្សេងៗគ្នាគឺ៖

- ឈើឈរគិតជាកូនឈើ (គ្រប់ប្រភេទឈើដែលមានទំហំអង្កត់ផ្ចិតពី ៥-៣០ស.ម និងមានកំពស់ចាប់ពី៣ម៉ែត្រឡើងទៅ)

- ឈើឈរគុណភាព C (គ្រប់ប្រភេទឈើដែលមានថ្នាក់អង្កត់ផ្ចិតពី ៥- ៣០សម)
- ឈើឈរគិតជាឈើហ៊ុបមូល (ដើមឈើមានគុណភាព A, B និង C មានទំហំអង្កត់ផ្ចិតធំជាង៣០ស.ម និងដើមឈើប្រភេទប្រណិតដែលមានទំហំអង្កត់ផ្ចិតចាប់ពី ១៥ស.មឡើងទៅ)

ជាលទ្ធផលសារពើភណ្ឌប៉ាន់ស្មានធនធានព្រៃឈើ និង ព័ត៌មានជាមូលដ្ឋានខាងលើការប៉ាន់ស្មានធនធានព្រៃ ឈើឈរសរុបមានដូចខាងក្រោម:

តារាង៥.១០៖ បរិមាណធនធានឈើឈរប៉ាន់ស្មានសរុបក្នុងផ្ទៃដីធ្វើអាជីវកម្ម

| ថ្នាក់ ប្រភេទឈើ | កូនឈើតាមគុណភាព និងអង្កត់ផ្ចិត | | | | មាឌឈើឈរសរុបតាមគុណភាព | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | A + B | | | C | A | | B | | C | |
| | ដើម | ដើម | ដើម | មាឌ ម$^៣$ | ដើម | មាឌ ម$^៣$ | ដើម | មាឌម$^៣$ | ដើម | មាឌម$^៣$ |
| | | | | | ដើមឈើមានអង្កត់ផ្ចិតចាប់ពី 15-30ស.ម | | | | | |
| ប្រណិត | | | | | 0 | 0.000 | 0 | 0.000 | 21 | 2.975 |
| | D<15 | D 15-19 | D 20-30 | D5-30 | ដើមឈើមានអង្កត់ផ្ចិតធំជាង 30ស.ម | | | | | |
| ប្រណិត | 0 | 0 | 0 | 1.869 | 0 | 0.000 | 0 | 0.000 | 0 | 0.000 |
| លេខ 1 | 21 | 11 | 0 | 4.351 | 0 | 0.000 | 8 | 4.809 | 16 | 16.519 |
| លេខ 2 | 32 | 0 | 0 | 3.356 | 0 | 0.000 | 13 | 9.538 | 0 | 0.000 |
| លេខ 3 | 0 | 16 | 16 | 17.096 | 0 | 0.000 | 51 | 40.826 | 123 | 89.475 |
| ក្រៅលំដាប់ | 245 | 32 | 91 | 92.370 | 3 | 2.493 | 80 | 68.151 | 205 | 162.199 |
| សរុប | 299 | 59 | 107 | 119.042 | 3 | 2.493 | 152 | 123.324 | 344 | 268.192 |

ក-ឈើឈរគិតជាកូនឈើ (គ្រប់ប្រភេទឈើដែលមានទំហំអង្កត់ផ្ចិតពី ៥-៣០ស.ម និងមានកំពស់ចាប់ពី ៣ម៉ែត្រឡើងទៅ) រួមមាន:

- ប្រភេទប្រណីត

កូនឈើដែលជាប្រភេទឈើប្រណិតដែលមានអង្កត់ផ្ចិតតូចជាង ៥ស.ម ទៅ ៣០ស.ម ពុំមានវត្តមាន ក្នុងតំបន់សិក្សាទេ។

- ប្រភេទលេខ១
  - ទំហំអង្កត់ផ្ចិតតូចជាង ១៥ សម ចំនួន ២១ ដើម (២.១៣ ដើម/ហ.ត)
  - ទំហំអង្កត់ផ្ចិតតូចពី ១៥សម-១៩សម ចំនួន ១១ ដើម (១.០៧ ដើម/ហ.ត)
  - ទំហំអង្កត់ផ្ចិតតូចពី ២០សម-៣០សម ចំនួន ០ ដើម (០ ដើម/ហ.ត)
- ប្រភេទលេខ២

- ទំហំអង្កត់ផ្ចិតតូចជាង ១៥ សម ចំនួន ៣២ ដើម (៣.២០ ដើម/ហ.ត)
- ទំហំអង្កត់ផ្ចិតតូចពី ១៥សម-១៩សម ចំនួន ០ ដើម (០ ដើម/ហ.ត)
- ទំហំអង្កត់ផ្ចិតតូចពី ២០សម-៣០សម ចំនួន ០ ដើម (០ ដើម/ហ.ត)

• ប្រភេទលេខ៣
- ទំហំអង្កត់ផ្ចិតតូចជាង ១៥សម ចំនួន ០ ដើម (០ ដើម/ហ.ត)
- ទំហំអង្កត់ផ្ចិតតូចពី១៥សម-១៩សម ចំនួន ១៦ ដើម (១.៦០ ដើម/ហ.ត)
- ទំហំអង្កត់ផ្ចិតតូចពី ២០សម-៣០សម ចំនួន ១៦ ដើម (១.៦០ ដើម/ហ.ត)

• ប្រភេទក្រៅលំដាប់ថ្នាក់
- ទំហំអង្កត់ផ្ចិតតូចជាង ១៥សម ចំនួន ២៤៥ ដើម (២៤.៥៣ដើម/ហ.ត)
- ទំហំអង្កត់ផ្ចិតតូចពី ១៥សម-១៩សម ចំនួន ៣២ ដើម (៣.២០ដើម/ហ.ត)
- ទំហំអង្កត់ផ្ចិតតូចពី ២០សម-៣០សម ចំនួន ៩១ ដើម (៩.០៦ដើម/ហ.ត)

ខ-ឈើឈរគុណភាព C (គ្រប់ប្រភេទឈើដែលមានថ្នាក់អង្កត់ផ្ចិតពី៥-៣០សម) ចំនួន 119ម$^3$042

(11ម$^3$904/ហ.ត) រួមមាន :

• ប្រភេទប្រណិត ចំនួន 1ម$^3$869 (0ម$^3$187/ហ.ត)
• ប្រភេទលេខ១ ចំនួន 4ម$^3$351 (0ម$^3$435/ហ.ត)
• ប្រភេទលេខ២ ចំនួន 3ម$^3$356 (0ម$^3$335/ហ.ត)
• ប្រភេទលេខ៣ ចំនួន 17ម$^3$096 (1ម$^3$710/ហ.ត)
• ប្រភេទក្រៅលំដាប់ថ្នាក់ ចំនួន 92ម$^3$370 (9ម$^3$237/ហ.ត)

គ- ឈើឈរគិតជាឈើហ៊ុបមូល (ដើមឈើមានគុណភាព A ,B និង C មានទំហំអង្កត់ផ្ចិតធំជាង ៣០ស.ម និង ដើមឈើប្រភេទប្រណិត ដែលមានទំហំអង្កត់ផ្ចិតចាប់ពី ១៥ស.ម ឡើងទៅ) រួមមាន:

• ប្រភេទប្រណីត
- ដើមឈើមានអង្កត់ផ្ចិតចាប់ពី ១៥សម-៣០សម មានគុណភាពC ចំនួន 2ម$^3$975 (0ម$^3$297/ហ.ត)
- ដើមឈើមានអង្កត់ផ្ចិតធំជាង 30សម គ្រប់គុណភាពឈើពុំមាននោះទេ។

• ប្រភេទលេខ១ មានគុណភាព B ចំនួន 4ម$^3$809 (0ម$^3$481/ហ.ត) និងគុណភាព C ចំនួន 16ម$^3$519 (1ម$^3$652/ហ.ត)
• ប្រភេទលេខ២ មានគុណភាព B ចំនួន 9ម$^3$538 (0ម$^3$954/ហ.ត)

#322P, St.271Z, Sk.Terk Tla, Khan Ressy Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- ប្រភេទលេខ៣ គុណភាព B ចំនួន 40ម³826 (4ម³083/ហ.ត) និងគុណភាព C ចំនួន 89ម³475 (8ម³948/ហ.ត)
- ប្រភេទក្រៅលំដាប់ថ្នាក់ មានគុណភាព A ចំនួន 2ម³493(0ម³249/ហ.ត) គុណភាព B ចំនួន 68ម³151 (6ម³815/ហ.ត) និងគុណភាពC ចំនួន 162ម³199 (16ម³220/ហ.ត)។

### ខ.២ ការប៉ាន់ស្មានតំលៃឈើឈរ

ការប៉ាន់ស្មានតំលៃឈើឈរនៅក្នុងតំបន់គម្រោងអភិវឌ្ឍន៍កោះក្របី អនុវត្តទៅតាមប្រកាសលេខ ១,២៧៦សហវ. ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកំណត់ថ្លៃសួយសារលើឈើឈរដើម្បីបង់ចំណូលថវិការដ្ឋនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ជាលទ្ធផលបង្ហាញថាធនធានព្រៃឈើ នៃតំបន់គម្រោងអភិវឌ្ឍន៍កោះក្របី ដែលមានផ្ទៃដីព្រៃស្រោងទំហំ ១០ហិកតា រួមមានអុសចំរុះប្រភេទចំនួន ៣៩០ម³២១០ និងកូនឈើចំរុះប្រភេទចំនួន ៤៦៥ដើម ដែលគិតជាទឹកប្រាក់សរុបប្រហែលជា ៥,៦៧៩,៣០០រៀល ស្មើនឹង ១.៤១៩,៨៤១ដុល្លា។ ដោយឡែកប្រភេទឈើមូលដែលអង្កត់ផ្ចិតធំជាង ៣០សម ឡើងទៅមានចំនួន ១២៥ម³៨១៧ គិតជាទឹកប្រាក់ប្រហែលជា ៣.៩៨៦,៧៥៧ដុល្លា។ ដូច្នេះតំលៃឈើឈរដែលប៉ាន់ស្មាន ក្នុងតំបន់គម្រោងអភិវឌ្ឍកោះក្របីសរុបគឺ ៥.៤០៦,៥៩៨ដុល្លា។

តារាង៥.១១៖ ការប៉ាន់ស្មានតំលៃឈើឈរក្នុងផ្ទៃដីព្រៃឈើទំហំ ១០ហិកតា

| ល.រ | ការពិពណ៌នា | ប្រភេទឈើ | តំលៃ/ឯកត្តា | បរិមាណ | តំលៃសរុប (រៀល) |
|---|---|---|---|---|---|
| 1 | អុសចំរុះ | - | 6,500រៀល/ម³ | 390ម³210 | 2,536,300 |
| 2 | កូនឈើចំរុះ | ឈើគ្រប់ប្រភេទ (D<១៥ស.ម) | 2000រៀល/ដើម | 299 ដើម | 598,000 |
| 3 | កូនឈើអង្កត់ផ្ចិត (D=15-30ស.ម) | លេខ ១ | 20,000រៀល/ដើម | 11 ដើម | 220,000 |
| | | លេខ ៣ និង ក្រៅលំដាប់ថ្នាក់ | 15,000រៀល/ដើម | 155 ដើម | 2,325,000 |
| | | | | សរុប | 5,679,300 |
| | | | គិតជាដុល្លា (អត្រា 1 ដុល្លា = 4000 រៀល) | | $ 1,419.841 |
| | | | (ដុល្លា/ម³) | (គិតជាម³) | (គិតជាដុល្លា) |
| 4 | ឈើមូល (D >30សម) | លេខ ១ | 82.5 | 4.809 | $ 396.742 |
| | | លេខ ២ | 55 | 9.538 | $ 524.590 |
| | | លេខ ៣ និងក្រៅលំដាប់ | 27.5 | 111.470 | $ 3065.425 |

| | | | | | |
|---|---|---|---|---|---|
| | | ថ្នាក់ | | | |
| | | | សរុប | 125.817 | $ 3,986.757 |
| | | | | សរុបរួម | $ 5,406.598 |

## ៥.៣ ប្រភេទរុក្ខជាតិក្នុង IUCN Red List

លទ្ធផលនៃការធ្វើសារពើភ័ណ្ឌវាយតម្លៃធនធានព្រៃឈើ ក្នុងតំបន់អនុវត្តគម្រោងអភិវឌ្ឍន៍កោះក្របី បានរកឃើញថា មានប្រភេទរុក្ខជាតិចំនួនតែ៣ប្រភេទ ដែលស្ថិតនៅក្នុងបញ្ជី IUCN Red List មានដូចជា អង្កត់ខ្មៅ ផ្ដៀក និងដូនចែម ក្នុងនោះដើមឈើអង្កត់ខ្មៅ ជាប្រភេទមានដោយកម្រដែលកំណត់ដោយប្រកាសលេខ ០៨៩ប្រក.កសក ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

តារាង ៥.១២៖ ប្រភេទរុក្ខជាតិដែលរងគ្រោះថ្នាក់ រងការគំរាមកំហែង និងមានដោយកម្រ

| ល.រ | ប្រភេទឈើ | ឈ្មោះវិទ្យាសាស្ត្រ | ចំណាត់ថ្នាក់ | មានដោយកម្រ | កម្រិតគំរាមកំហែង | IUCN Red List |
|---|---|---|---|---|---|---|
| 1 | អង្កត់ខ្មៅ | *Diospyros bejaudi,Loc* | LC | ប្រកាសលេខ ០៨៩ប្រក.កសក | 4 | |
| 2 | ដូនចែម | *Tarrietia javanica, Bl* | 1 | | 3 | |
| 3 | ផ្ដៀក | *Anisoptera costata Korth* | 2 | | 2 | EN |

កំណត់សំគាល់៖

- EN: Endangered (ប្រភេទជិតផុតពូជ)
- LC: List Concern

VU: Vulnerable (ប្រភេទងាយរងគ្រោះ)

កម្រិតគំរាមកំហែង (៥: ប្រភេទងាយរងគ្រោះថ្នាក់ ៤ : ប្រភេទរងគ្រោះថ្នាក់ ១-៣ : ប្រភេទរងគំរាមកំហែង)

## ៥.៤ ប្រភេទដើមឈើដែលមានក្នុងតំបន់គម្រោង

ឆ្លងតាមការធ្វើបញ្ជីសារពើភ័ណ្ឌនៃរុក្ខជាតិ ក្នុងតំបន់គម្រោងកោះក្របី បានបង្ហាញថា នៅក្នុងតំបន់នេះ មានប្រភេទឈើចំនួន ៥០ប្រភេទ (តារាង៥.១១)។ ការធ្វើសារពើភ័ណ្ឌ ធនធានព្រៃឈើក្នុងទីតាំងគម្រោងនៅទីនោះ ភាគច្រើនជាប្រភេទឈើប្រើប្រាស់សម្រាប់ធ្វើផ្ទះ តុ ទូ មួយចំនួនជាប្រភេទឈើហូបផ្លែ និងប្រើប្រាស់ជាឱសថ។

#322P, St.271Z, Sk.Tek Tla, Khan Russey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាង៥.១៣៖ ប្រភេទដើមឈើដែលមានក្នុងតំបន់គម្រោង

| ល.រ | ឈ្មោះភាសាខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ចំណាត់ថ្នាក់ឈើ | ការប្រើប្រាស់ |
|---|---|---|---|---|
| 1 | អង្កត់ខ្មៅ | *Diospyrosbejaudi,Loc* | LC | ឈើ: គុ ទូ ដងកាំបិត គ្រឿងភ្លេង |
| 2 | ដូនចែម រឺ ស្តុងបីសន្លឹក | *Tarrietiajavanica, Bl* | 1 | ឈើ: គ្រឿងសំណង់ ធ្វើទូក |
| 3 | ត្រសេក | *Peltophorumferrugineum Benth* | 1 | ឈើ:ក្តារផ្ទះ សសរផ្ទះ រទេះ នង្គ័ល<br>សំបក:ជាថ្នាំគ្រុន |
| 4 | ច្រម៉ាស់ | *Vaticaastrotricha Dyer* | 2 | ឈើ: សសរផ្ទះ |
| 5 | ផ្ចៀក | *Anisopteracostata Korth* | 2 | ឈើ: គ្រឿងសំណង់ គុ ទូ<br>ជ័រ: ជ័រពិណសរសម្រាប់ធ្វើចន្លុះ និងលាបទូក |
| 6 | គគីរភ្នង់ | *Shoreahypochra* | 2 | ឈើ: សង់ផ្ទះ ធ្វើទូក ជ័រចុង អាចលក់ |
| 7 | ស្មាក្របី | *Knemacorticosa,Lour.* | 3 | ឈើ: គ្រឿងសំណង់<br>គ្រាប់: ថ្នាំព្យាបាលជម្ងឺកមរមាស់ |
| 8 | ធ្លក | *Parinariumannamensis Hance* | 3 | ឈើ: ក្តារបន្ទះ ផ្លែ: ផ្លែខ្ចីស្ងោរបរិភោគ<br>និងផ្លែទុំបរិភោគជាចំណី |
| 9 | ទ្រមូង | *Garciniaoliveri Pierre* | 3 | ឈើ: ធ្វើបង្គោល រឺ ក្តាររឿ<br>សំបក: ព្យាបាលជម្ងឺរលាកទងសួត<br>លាយជាមួយសំបកព្រហូតអាចប្រើសម្រាប់គ្រេចដៃជើង កន្លែងកកឈាម |
| 10 | ព្រីង | *Eugenia spp* | 3 | ឈើ: សង់ផ្ទះ ផ្លែ: ផ្លែទុំបរិភោគ |
| 11 | កោងកាង | *Rhizophoramucronata,Poir* | 3 | សំបក: សម្រាប់សំលាប់ស្បែក |
| 12 | ផ្តុង | *Calophyllum.sp* | 3 | ឈើ: សម្រាប់សងផ្ទះ និងធ្វើទូក |
| 13 | បាយពូរាំង | *Aglaiaspectabilis,S.K.jain Benn* | 3 | ឈើ: សម្រាប់សង់ផ្ទះ<br>ឬស: មានទំហំធំ គេនិយមធ្វើកង់រទេះគោ |
| 14 | ព្រីងស្រទាប់ | *Syzygiumpolyanthum(Wight)Walp* | 3 | ឈើ: សង់ផ្ទះ ផ្លែ: ផ្លែទុំបរិភោគ |
| 15 | ខ្នុរព្រៃ | *Artocarpusasperula Gagn* | 3 | ឈើ: គុ ទូ សំបក: ថ្នាំជ្រលក់ព័ណលឿងរមៀត |
| 16 | ក្រសាំង | *Feroniellalucida(Scheff.)Swingle* | NC | ផ្លែ: ធ្វើម្ជូរ (ក្រសាំងស៊ីផ្លែ) សំបក: អាចធ្វើធូប |
| 17 | នី | *N/A* | NC | |
| 18 | មៀនព្រៃ | *Aporusaplanchoniana Baill* | NC | ផ្លែ: បរិភោគ មែក: ធ្វើអុសដុត |
| 19 | ក្រសាំងភ្នំ | *N/A* | NC | |
| 20 | ឈាមមាន់ | *N/A* | NC | |
| 21 | អង្គុញស្វា | *Archidendronquocense(Pierre)I.C.Nielsem* | NC | ស្លឹកខ្ចីសម្រាប់ធ្វើអន្លក់ រឺ របោយ<br>ផ្លែអាចបរិភោគបាន |
| 22 | ក្រាយ | *Polyalthiacerasoides Benth* | NC | ឈើអាចប្រើជាគ្រឿងផ្ទះរាយរងបាន |
| 23 | ខុស | *N/A* | NC | |

| | | | | |
|---|---|---|---|---|
| 24 | ដោះប៉ែន | *N/A* | NC | |
| 25 | សិរមាន់ | *Nepheliumhypoleucum Kurz* | NC | ផ្លែទុំសម្រាប់បរិភោគ ឈើសម្រាប់ធ្វើដងកាំបិត និងពូថៅ |
| 26 | មន្ត្រី | *AdenantherapavoninaL var.microsperma* | NC | គ្រាប់ពណ៌ក្រហមគេក្រងធ្វើខ្សែក សំបកស្ងោរផឹកសម្រាប់រោគមូល ជំងឺឈាម |
| 27 | ស្រល់ភ្នំ | *Dacrycarpusimbricatus* | NC | ឈើ: ធ្វើក្តារ និងគ្រឿងផ្ទះ |
| 28 | ស៊ិន រីកំពីងរាជព្រៃ | *N/A* | NC | ផ្លែសម្រាប់បរិភោគ និងធ្វើដំណាប់ ស្លឹក និងឫស: ស្ងោរផឹកព្យាបាលជំងឺរាគ |
| 29 | រាំង | *Barringtoniaasistiaca(L.) Kurz* | NC | ស្លឹកខ្ចី: ធ្វើអន្លក់ ឈើ: គេប្រើធ្វើពោងបណ្តោះអាសន្ន ស្លឹក សំបក និងផ្លែ: ព្យាបាលជម្ងឺឈឺក្បាល និងបណ្តេញសប្តិអាក្រក់ |
| 30 | អណ្តែង | *N/A* | NC | |
| 31 | ខ្ទាស់ | *DiospyrossylvaticaRoxb.* | NC | ដុតធ្វើធ្យូងចំណែកគ្រាប់អាចបរិភោគបាន |
| 32 | ក្រចៅ | *Corchoruscapsularis L* | NC | សំបក: សម្រាប់ធ្វើខ្សែ និងបាវការ៉ុង ស្លឹក: ថ្នាំលើកកំលាំង ព្យាបាលជម្ងឺក្អក គ្រាប់: មានរសជាតិល្វីង អាចបំពុលគោក្របី ក៏ជាថ្នាំធ្វើឲ្យបេះដូងដើរស្រួល |
| 33 | គ្រយូង | *N/A* | NC | |
| 34 | រំដួលភ្នំ | *N/A* | NC | ផ្លែមានរសជាតិផ្អែម បរិភោគឆ្ងាញ់ពិសារ ហើយធ្វើឲ្យអាហាររំលាយ |
| 35 | សំបកក្របែក | *N/A* | NC | |
| 36 | ទម្ប៊ូ | *N/A* | NC | |
| 37 | ស៊ិនព្រៃ | *N/A* | NC | |
| 38 | ខ្ទូក | *N/A* | NC | |
| 39 | សំពោង | *SterculiaparvifloraRoxb.* | NC | |
| 40 | ដង្ហក | *N/A* | NC | |
| 41 | ភ្នៅមាន់ | *DecaschistiaparvifloraKurz* | NC | ស្លឹកស្ងោរផឹក ដើម្បីព្យាបាលជម្ងឺគ្រុន |
| 42 | សៅស្រូវ | *N/A* | NC | |
| 43 | ជ្រៃ | *FicusrumphiiBlume* | NC | ជ័រមានជាតិពុល អាចធ្វើឲ្យក្អួត នៅឥណ្ឌាគេប្រើជ័រជាថ្នាំគ្រុន |
| 44 | ជ្រៃធំ | *N/A* | NC | |
| 45 | ស្តៅភ្នំ | *AglaialeptanthaMiq.* | NC | សំបកស្ងោរព្យាបាលជម្ងឺគ្រុន |
| 46 | ម៉ាក់ប្រាង | *Boueaoppositifolia(Roxb.) Meisn* | NC | ផ្លែសម្រាប់ហូប ជ័រលាបតុ ទូឲ្យរលោង ឈើសម្រាប់ធ្វើតុ ទូ កៅអី សសរផ្ទះ |
| 47 | កុយស្វា | *N/A* | NC | |
| 48 | នី | *N/A* | NC | |

| | | | | |
|---|---|---|---|---|
| 49 | ឆ្អឹងមាន់ | *N/A* | NC | |
| 50 | ម្កាក់ព្រៃ | *SpondiascythereaSann* | NC | ផ្លែបរិភោគមានរសជាតិជូរ<br>ជ័រ: ដើមសម្រាប់ ធ្វើថ្នាំគ្រុនចាញ់ |



រូបភាព៥.៣៖ ប្រភេទឈើដែលអតិរេក្ខទុកក្នុងតំបន់គម្រោង

## ខ.៨ ការប៉ាន់ស្មានជីវម៉ាស់

ការប៉ាន់ស្មានជីវម៉ាស់ព្រៃឈើ បានអនុវត្តតាមគោលការណ៍ណែនាំរបស់អង្គការស្បៀងអាហារ និងកសិកម្ម (FAO) ដែលជំហ៊ានសំខាន់ៗក្នុងការសិក្សាមានបីដំណាក់កាលគឺការគណនាជីវម៉ាស់នៃមាឌឈើដែលបានមកពី ទិន្នន័យធ្វើសារពើភ័ណ្ឌព្រៃឈើ គណនាមេគុណបញ្ចេញជីវម៉ាស់ និងគណនាជីវម៉ាស់លើដី (AGB)។ តារាងខាងក្រោមបង្ហាញអំពីទិន្នន័យនៃការ

គណនាជីវម៉ាស់លើដីក្នុងផ្ទៃដីមួយហិកតា ក្នុងតំបន់គម្រោងអភិវឌ្ឍន៍រមណីយដ្ឋាន កោះក្របី របស់ក្រុមហ៊ុន **អេភីប៊ី អ៊ិនវេសមេន ខូអិលធីឌី**។

**តារាង៥.១៤៖** ការប៉ាន់ស្មានជីវម៉ាសលើដីក្នុងផ្ទៃដីមួយហិកតា

| ប្រភេទព្រៃឈើ | មាឌឈើ (VOB ម$^3$/ហ.ត) | ដង់ស៊ីតេ (WD ត/ម$^3$) | ជីវម៉ាស់មាឌឈើ (BV ត/ហ.ត) | មេគុណពង្រីក (BEF) | ជីវម៉ាស់លើដី (AGB ត/ហ.ត) |
|---|---|---|---|---|---|
| ព្រៃស្រោង | | | | | |
| កូនឈើ | 9.210 | 0.57* | 5.247 | 10.742 | 56.368 |
| អុស | 19.065 | | 10.867 | 7.432 | 80.766 |
| ឈើហ៊ុប | 12.582 | | 7.172 | 9.172 | 65.775 |
| សរុប | 40.853 | | 23.286 | | 202.909 |

ចំណាំ៖ * : តំលៃដង់ស៊ីតេជាមធ្យម ត/ម$^3$ (Reyes et al. 1992)

តាមតារាងទី៥.១៤ បង្ហាញថា បរិមាណជីវម៉ាស់លើដីនៃតំបន់សិក្សាមានប្រហែលជា ២០២.៩០៩តោន/ហ.ត ដែលបរិមាណនេះប្រហាក់ប្រហែលនឹងទិន្នន័យឧបសម្ព័ន្ធជីវៈម៉ាស់ព្រៃឈើដែលសិក្សាដោយ អង្គការស្បៀង និង កសិកម្មសហប្រជាជាតិ ។ ជាទូទៅក្នុងការគណនាជីវម៉ាស់ព្រៃឈើ គេគិតទាំងជីវម៉ាស់លើដី និង ជីវម៉ាស់ក្រោមដី ដែលជីវម៉ាស់ក្រោមដីតាមឯកសាររបស់អង្គការ FAO និងលោក Sakasi Nophear គឺយកតំលៃស្មើនឹង ៣០% នៃចំនួនជីវម៉ាស់លើដី។ ដូច្នេះលទ្ធផលនៃការប៉ាន់ស្មានជីវម៉ាស់ព្រៃឈើក្នុងតំបន់គម្រោងអភិវឌ្ឍន៍កោះក្របីលើផ្ទៃដីចំនួន ១០ហិកតា ស្មើនឹង ២.៦៣៧,៨១៧តោនជីវម៉ាស់ ដែលគិតជាបរិមាណក្នុងមួយហិកតាគឺ ២៦៣.៧៨១តោន។

## ៥.៦ ការប៉ាន់ស្មានកាបូនស្តុក

បរិមាណកាបូនស្តុកនៅលើដើមឈើ ឬកំណើនកាបូននៅក្នុងព្រៃឈើនៃតំបន់គម្រោងអភិវឌ្ឍន៍កោះក្របី ស្មើនឹង ៥០% ($r_c$=៥០%) នៃបរិមាណជីវម៉ាស់សរុបដែលបានគណនារួចខាងលើ។ ដូចនេះតំបន់សិក្សាមានទំហំ ១០ហិកតា ដែលជាប្រភេទព្រៃស្រោងគឺមានបរិមាណកាបូនស្តុកប្រមាណជា ១.៣១៨,៩០៨តោន បើគិតជាបរិមាណឧស្ម័នកាបូនិច ($CO_2$)គឺ ៤.៨៣៥,៩៩៧ តោន។

## ៥.៣.២ ការសិក្សាអំពីសត្វ

នៅតំបន់អភិវឌ្ឍន៍កោះក្របី ជាតំបន់អេកូឡូស៊ីមួយដែលមានសត្វសេសសល់ មួយចំនួនរស់នៅលើកោះនេះ ។ តាមរយៈការសិក្សាស្រាវជ្រាវ និងទិន្នន័យបានបង្ហាញពីវត្តមានសត្វជាមួយចំនួនបានតាំងទីជំរកនៅក្នុងតំបន់នោះដោយរាប់បញ្ចូលប្រភេទចតុបាទ ថនិកសត្វ ល្មូន និងសត្វស្លាបជាដើម។

### ក. ថនិកសត្វ

តាមរយៈការសិក្សាបានបង្ហាញថា មានថនិកសត្វចំនួន **៧ប្រភេទ** ដែលរស់នៅលើកោះនេះ។ ដោយផ្អែកលើទិន្នន័យបឋម តាមរយៈការចាប់យកសំលេងសត្វ និង ទិន្នន័យបន្ទាប់បន្សំបានបង្ហាញថា ប្រភេទថនិកសត្វនៅលើកោះនេះ មិនមានសត្វធំៗរស់នៅទេគឺមានតែពពួកសត្វតូចៗរស់នៅប៉ុណ្ណោះ មានដូចជាស្វាក្ដាម ទោច កណ្ដុរ កំប្រុក ប្រម៉ា ជ្រឹង និងប្រចៀវ។

**តារាង៥.១៥៖ ឈ្មោះ និងប្រភេទថនិកសត្វនៅក្នុងតំបន់អភិវឌ្ឍន៍កោះក្របី**

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | ចំណាត់ថ្នាក់នៅក្នុងប្រទេសកម្ពុជា | ប្រភពពីគឺមាន | | រយៈពេល (ឆ្នាំ) |
|---|---|---|---|---|---|---|---|
| | | | | | សម្ភាសន៍ ប្រជ | ប្រានជួប | |
| 1 | ស្វាក្ដាម | Long-tailed macaque | *Macaca fascicularis* | Common | ✓ | | ថ្មីៗ |
| 2 | ទោច | Pileated Gibbon | *Hylobates pileatus* | C | ✓ | ✓ | - |
| 3 | កណ្ដុរ | Lesser white-toothed rat | *Berylmys berdmorei* | - | ✓ | | - |
| 4 | កំប្រុក | Small Flying Squirrel Sp | *Hylopetes sp* | - | ✓ | | - |
| 5 | ប្រម៉ា | East Asia Porcupine | *Hystrix brachyura* | - | ✓ | | - |
| 6 | ជ្រឹង | Flying Fox sp | *Pteropus sp* | ធម្មតា | ✓ | | - |
| 7 | ប្រចៀវ | Diadem Roundleaf Bat | *Hipposideros diadema* | - | ✓ | | - |

### ខ. ពពួកល្មូន

យោងតាមរបាយការណ៍ នៃការសិក្សាពីសត្វព្រៃនៅតំបន់ជុំវិញគម្រោងអភិវឌ្ឍន៍បានបញ្ជាក់ឲ្យដឹងថា មានប្រភេទសត្វល្មូនចំនួន**៩ប្រភេទ** ដែលមានវត្តមានក្នុងតំបន់អភិវឌ្ឍន៍នេះ។ ប្រភេទល្មូនដែលមាននៅលើកោះនេះ ភាគច្រើនជាប្រភេទពស់ដូចជា ពស់ព្រៃ ពស់វែកក្របី ពស់វែករនាម ពស់វែកដំបូក និងពស់ខ្សែគោ។ ចំពោះល្មូនផ្សេងទៀតមានដូចជា ត្រកួត អន្សង និងបង្កួយព្រៃត្រចៀកតូច។ ដោយឡែក មានប្រភេទសត្វមួយចំនួនពុំមានកំណត់ត្រានៅក្នុងបញ្ជីក្រហម IUCN Red List ទេ ប៉ុន្តែត្រូវបានការពារដោយប្រកាស អនុក្រឹត្យ និងច្បាប់ដូចជា៖

- គុកកែ ត្រូវបានការពារដោយប្រកាសលេខ ០២០ ប្រក.កសក ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំណាត់ថ្នាក់ និងបញ្ជីប្រភេទសត្វព្រៃ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ ២០០៧។
- ត្រកួត ត្រូវបានការពារក្រោមច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ និងអនុក្រឹត្យលេខ ០៥៣អនក្រ.បក ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់។
- ពស់វែក ពុំមានចុះក្នុងបញ្ជី IUCN ទេ តែក្នុងCITES ស្ថិតក្នុងឧបសម្ព័ន្ធលេខ II និងការពារដោយច្បាប់ ស្តីពីព្រៃឈើ ឆ្នាំ ២០០២។

តារាង៥.១៦៖ ឈ្មោះប្រភេទសត្វល្មូននៅក្នុងតំបន់អភិវឌ្ឍន៍កោះក្របី

| ល.រ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះភាសាអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | ចំណាត់ថ្នាក់នៅក្នុងប្រទេសកម្ពុជា | ប្រភពព័ត៌មាន | | រយៈពេល (ឆ្នាំ) |
|---|---|---|---|---|---|---|---|
| | | | | | សម្ភាសន៍ ប្រ/ជ | បានជួប | |
| 1 | ត្រកួត | Bengal Monitor | *Varanus bengalensis* | រងការគំរាមកំហែង | ✓ | | ជួបថ្មីៗ |
| 2 | ពស់ព្រៃ | Indochinese Ratsnake | *Pytas korros* | សម្បូរ | ✓ | | ជួបថ្មីៗ |
| 3 | ពស់វែកក្របី | Monocled Cobra | *Naja kaouthia* | ខ្សត់ | ✓ | | ២ខែមុន |
| 4 | ពស់វែករនាម | King Cobra | *Ophiophagus hannah* | - | ✓ | | ៣ ឆ្នាំមុន |
| 5 | ពស់វែកដំបូក | Indochinese Spitting Cobra | *Naja Siamensis* | - | ✓ | | ១ ឆ្នាំមុន |
| 6 | តុកកែ | Tockay | *Gekko gecko* | ខ្សត់ | ✓ | | ជួបថ្មីៗ |
| 7 | អន្សង | Water Monitor | *Varanus salvator* | - | ✓ | | - |
| 8 | ពស់ខ្សែគោ | Striped Keelback | *Amphiesma Stolata* | - | ✓ | | - |
| 9 | បង្កួយព្រៃ ត្រចៀកតូច | Scale-bellied Tree lizard | *Acanthosaura lepidogaster* | - | ✓ | | - |

គ. សត្វស្លាប

តាមការសម្ភាសន៍ប្រជានេសាទ ក៏ដូចជាការសិក្សានៅលើទីតាំងផ្ទាល់បានបង្ហាញថា នៅលើកោះក្របីនេះមានសត្វស្លាបតែ **៦ប្រភេទ** ប៉ុណ្ណោះ ដែលរស់នៅលើទីតាំងនេះ។ សត្វស្លាបទាំងនេះរួមមាន ស្វាំង ចាបពុក កេងកងតូច ត្រចៀកកាំ ពពិចខ្មៅ និងញ៉ាំង។

## តារាង៥.១៧៖ ប្រភេទសត្វស្លាបដែលមាននៅលើកោះក្របី

| [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | | [illegible] |
|---|---|---|---|---|---|---|---|
| | | | | | សម្ភាសន៍ប្រ/ជ | ឃើញ | |
| 1 | ស្ទាំង | Shikra | *Accipiter badius* | ខ្សត់ | ✓ | | ជួបថ្មីៗ |
| 2 | ចាបពូក | Asian Golden Weaver | *Ploceus hypoxanthus* | - | ✓ | | - |
| 3 | កេងកងតូច | Oriental Pied Hornbill | *Anthracoceros albirostris* | - | ✓ | | - |
| 4 | ត្រចៀកកាំ | Barn Swallow | *Hirundo rustica* | ធម្មតា | ✓ | | - |
| 5 | ពពិចខ្មៅ | Black Bulbul | *Hypsipetes leucocephalus* | - | ✓ | | - |
| 6 | ព្រាំង | Wreathed Hornbill | *Aceros undulatus* | - | ✓ | | - |

Creative Green Design Co., Ltd
Social-Environmental Researchs
Quality Researchers

#322P, St.27'Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ការសិក្សាធនធានជលផល និងការនេសាទ

## ៥.៤ ការសិក្សាធនធានជលផល និងការនេសាទ

### ៥.៤.១ លក្ខណៈទូទៅនៃវិស័យជលផល

ព្រះរាជាណាចក្រកម្ពុជាមានវិសាលភាពប្រព័ន្ធទឹកសាបប្រមាណ២,៧% នៃផ្ទៃប្រទេស ដែលសម្បូរ ទៅដោយសារធាតុខនិជ និងសារធាតុចិញ្ចឹមមានផលិតភាពខ្ពស់ក្នុងចំណាត់ថ្នាក់ទី៤ ផ្នែកជលនេសាទ ទឹកសាប បន្ទាប់ពីប្រទេសចិន ឥណ្ឌា និងបង់ក្លាដេស។ ចំណែកឯដែននេសាទសមុទ្រវិញក៏មានផលិតភាព ខ្ពស់ដែរ ហើយសម្បូរទៅដោយសារធាតុចិញ្ចឹមជាច្រើនផងដែរ។

ផ្តើមចេញពីសារសំខាន់របស់វិស័យជលផល ដែលទាក់ទងដោយផ្ទាល់ទៅនឹងជីវភាពប្រជាពលរដ្ឋ ខ្មែរ ក៏ដូចជាសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដែលក្នុងនោះកំណែទម្រង់ វិស័យជលផលជាមុំមួយនៃចតុកោណទី ១សំដៅជម្រុញការសម្របសម្រួលអនុវត្តច្បាប់ រៀបចំផែនការសកម្មភាព និងការពង្រឹងស្ថាប័នដែលពាក់ព័ន្ធនឹងវិស័យជលផល ដើម្បីធ្វើឲ្យសម្រេចបានគោលដៅថ្នាក់ជាតិក្នុង កិច្ចការពារបរិស្ថានជលផល ការអភិរក្សជីវចម្រុះ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម អភិបាលកិច្ចល្អ និងការកាត់ បន្ថយភាពក្រីក្រ ដូចមានចែងក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីវិស័យជលផល។

ទស្សនៈវិស័យជលផលៈ គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចំរើននៃសេដ្ឋ- កិច្ចសង្គម និងការអភិវឌ្ឍប្រទេសជាតិ។

ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាមានប្រវែង៤៣៥គ.មហើយតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) មានទំហំ៥៥.៦០០គ.ម$^{២}$ (DoF, 2005)។ តំបន់ឆ្នេរសមុទ្រនៃប្រទេសកម្ពុជាស្ថិតនៅក្នុងខេត្តចំនួនបួនគឺ ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប។ តាមទស្សនៈវិស័យនៃមុខងារតំបន់ឆ្នេរសមុទ្រនៃ ប្រទេសកម្ពុជាមានប្រព័ន្ធទាក់ទងគ្នាពីរគឺ ប្រព័ន្ធសេដ្ឋកិច្ចសង្គមនិងប្រព័ន្ធអេកូឡូស៊ី (DoF, 2005)។ ប្រព័ន្ធ អេកូឡូស៊ីរួមមានសមាសភាពជីវសាស្ត្រ គីមី និងរូប ដែលបង្កើតធនធានធម្មជាតិ និងផ្តល់មុខងារទ្រទ្រង់ ជីវិតជាគ្រឹះសំខាន់(ឧទាហរណ៍ ខ្យល់បរិសុទ្ធនិងទឹកស្អាត) សម្រាប់មនុស្សនិងសរីរាង្គមានជីវិតដទៃទៀត។ ឯប្រព័ន្ធសេដ្ឋកិច្ចសង្គម ជាពិសេសការរស់នៅរបស់មនុស្សជាតិ គឺពឹងផ្អែកលើមុខងារនិងផលិតភាពជា ច្រើននៃប្រព័ន្ធអេកូឡូស៊ី។

ប្រព័ន្ធអេកូឡូស៊ីសមុទ្រសំខាន់ៗរួមមាន ប្រព័ន្ធអេកូឡូស៊ីផ្កាថ្ម ប្រព័ន្ធអេកូឡូស៊ីស្មៅសមុទ្រ ប្រព័ន្ធ អេកូឡូស៊ីព្រៃកោងកាង និងប្រព័ន្ធអេកូឡូស៊ីដទៃទៀតដែលទ្រទ្រង់ឲ្យប្រព័ន្ធអេកូឡូស៊ីទាំងបីនេះ ដូចជាតំបន់ ថ្ម តំបន់ខ្សាច់ តំបន់ពាម។ល។ ដោយឡែក ប្រព័ន្ធអេកូឡូស៊ីផ្កាថ្ម ព្រៃកោងកាង និងស្មៅសមុទ្រ គឺជាជម្រកដ៏សំខាន់បំផុតដែលបានគាំទ្រដល់ការរស់នៅ

#322P, St.271Z, Sk.Terk Tla, Khan Rasey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

កន្លែងរកចំណី កន្លែងពងកូន និងកន្លែងជម្រករបស់ ប្រភេទសត្វជាច្រើនប្រភេទ ជាពិសេស ប្រភេទសត្វដែលងាយរងការគំរាមកំហែងនិងជិតផុតពូជ។ ជាងនេះទៅទៀត ប្រព័ន្ធទាំងនេះបានជួយរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ី បម្រើឲ្យសេដ្ឋកិច្ចសង្គម និងជាកន្លែងទាក់ ទាញភ្ញៀវទេសចរមកទស្សនាដ៏មានប្រសិទ្ធភាពបំផុត។

បើប្រៀបធៀបទៅនឹងប្រទេសជិតខាង ប្រព័ន្ធអេកូឡូស៊ីសមុទ្រក្នុងប្រទេសកម្ពុជា និងធនធានជល-ផលទាំងនេះ នៅពុំទាន់មានការប្រែប្រួលខ្លាំងនៅឡើយទេ ដោយបានរួមចំណែកបម្រើឱ្យវិស័យសេដ្ឋកិច្ច គ្រួសារនិងសង្គមជាតិទាំងមូល។

ធនធានជលផលសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា គឺពិតជាសំខាន់មួយផ្អែកលើប្រព័ន្ធអេកូឡូស៊ី ស្មៅសមុទ្រ ផ្កាថ្ម ព្រៃកោងកាង និងតំបន់ពាម។ មច្ឆជាតិដែលរស់នៅក្នុងតំបន់ទាំងនេះ ពិសេស បង្គា ក្តាម ត្រីគឺជាប្រភេទសត្វមានតម្លៃសេដ្ឋកិច្ចខ្ពស់ ទាំងទីផ្សារក្នុងស្រុកនិងទីផ្សារបរទេស។ យោងតាមស្ថិតិរបស់ រដ្ឋបាលជលផលឆ្នាំ២០១២ បានអោយដឹងថា មានត្រីសមុទ្រនិងសត្វឥតឆ្អឹង ខ្ទង់ប្រមាណពី៩២.០០០ ដល់ ៩៥.០០០តោន ត្រូវប្រមូលបានពីដែនសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជារៀងរាល់ឆ្នាំ។

ធនធានជលផល ជាពិសេសត្រី គឺជាអាហារដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជា។ ត្រីដើរតួនាទីយ៉ាងសំខាន់នៅក្នុងសន្តិសុខស្បៀង ហើយតាមការស្រាវជ្រាវរបស់រដ្ឋបាលជលផលក្នុងឆ្នាំ ២០០៨ ត្រីបានផ្តល់ប្រូតេអ៊ីនជាង៨១,៥ភាគរយ នៅក្នុងរបបអាហារប្រចាំថ្ងៃរបស់ប្រជាជនយើង។ ត្រីសម្បូរដោយប្រូតេអ៊ីន វីតាមីន និងសារធាតុខនិជផ្សេងៗទៀត ដែលមានសារសំខាន់សម្រាប់សុខភាពមនុស្ស ជាពិសេសស្ត្រីមានផ្ទៃពោះនិងកុមារ។ ជាងនេះទៅទៀត ធនធានជលផលបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងសង្គម និងសេដ្ឋកិច្ចជាតិ ដោយបានផ្តល់ជាមុខរបរដល់ប្រជាជនកម្ពុជាជាង៦លាននាក់ ដែលមានការងារពាក់- ព័ន្ធជាមួយនឹងមុខរបរនេសាទ។ វិស័យជលផលជាប្រភពផ្តល់ប្រាក់ចំណូលយ៉ាងសំខាន់សម្រាប់ទ្រទ្រង់ ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរ ជាពិសេសអ្នករស់នៅតាមជនបទ។ ជាងនេះទៅទៀត ធនធាន ជលផលក៏ជាប្រភពមួយយ៉ាងសំខាន់ក្នុងការទាក់ទាញការចាប់អារម្មណ៍របស់ភ្ញៀវទេសចរជាតិនិងអន្តរជាតិផងដែរ ដូចជាការនេសាទត្រីកំសាន្ត ការទស្សនាព្រៃកោងកាង និងការមុជទឹកមើលផ្កាថ្មជាដើម ដែលសកម្មភាពទាំងនេះ បានចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជាយើងឱ្យរីកចម្រើន។

ទោះជាយ៉ាងនេះក្តី ប្រព័ន្ធអេកូឡូស៊ីផ្កាថ្ម ស្មៅសមុទ្រ ព្រៃកោងកាង និងតំបន់ឆ្នេរដទៃទៀត ព្រមទាំងធនធានវារីសត្វជាច្រើនប្រភេទ កំពុងតែស្ថិតក្នុងស្ថានភាពនៃការគំរាមកំហែងដែលបណ្តាលមកពីការ ធ្វើនេសាទដែលមានលក្ខណៈបំផ្លិចបំផ្លាញ ការចាក់ចោលកាកសំណល់ភាពកករ ការកើនឡើងនៃអ្នក នេសាទ និងការអភិវឌ្ឍតាមតំបន់ឆ្នេរពុំសមស្រប។ ការខូចខាត

និងបាត់បង់ប្រព័ន្ធអេកូឡូស៊ីទាំងនេះ បាននិងកំពុងបង្កផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាននិងសេដ្ឋកិច្ច ហើយចុងក្រោយនឹងប៉ះពាល់ដល់ភាព ក្រីក្រនិងការរស់នៅរបស់ប្រជាពលរដ្ឋជាច្រើនលាននាក់។

នាពេលបច្ចុប្បន្ននេះ ការអភិវឌ្ឍនៅតាមតំបន់ឆ្នេរ ជាពិសេស ការអភិវឌ្ឍទីក្រុងរណប ការកសាង ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និងការអភិវឌ្ឍរមណីយដ្ឋាននានា គឺមានសន្ទុះលឿនបំផុត ដែលសកម្មភាពទាំងនេះបង្កឲ្យមានការព្រួយបារម្ភពីអ្នកអភិរក្ស និងបរិស្ថានទាំងក្នុងនិងក្រៅប្រទេស។ ដូច្នេះហើយ ដើម្បីឲ្យការ អភិវឌ្ឍទាំងនេះប្រព្រឹត្តទៅប្រកបដោយចីរភាព ជាពិសេសមានការថ្លឹងថ្លែងពីតុល្យភាពរវាងការអភិវឌ្ឍនិង ការអភិរក្ស ការសិក្សាពីផលប៉ះពាល់បរិស្ថាន គឺជាការចាំបាច់បំផុត ដើម្បីកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន ឲ្យបានជាអតិបរមានិងមានវិធានការកាត់បន្ថយជាបន្ទាន់ នៅពេលមានហានិភ័យផ្សេងៗកើតឡើងក្នុងពេលកំពុងសាងសង់និងក្នុងពេលដំណើរការពេញលេញ។

### ៥.៤.២ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងរួមនៃការសិក្សានេះ គឺដើម្បីវាយតម្លៃពីស្ថានភាពធនធានជលផល ស្ថានភាពស្រទាប់បាត និងស្ថានភាពនេសាទក្នុងតំបន់ជុំវិញកោះក្របី ដើម្បីចាត់វិធានកាត់បន្ថយផលប៉ះពាល់លើធនធាន ជលផលដែលអាចបណ្តាលមកពីការអភិវឌ្ឍគម្រោងលំហែកាយនៅតំបន់ **កោះក្របី** នៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ របស់ក្រុមហ៊ុន **អភីប៊ី អ៊ិនវេសមេន ខូអិលធីឌី** ( RPB Investment co,. LTd)។

ចំពោះគោលបំណងបន្ទាន់នៃការសិក្សាស្រាវជ្រាវគឺ ៖

- → ដកស្រង់ព័ត៌មានដែលមានស្រាប់ពាក់ព័ន្ធធនធានជលផលក្នុងតំបន់គម្រោង
- → ពិនិត្យនិងអង្កេតផ្ទាល់ក្នុងតំបន់គម្រោង
- → វាយតម្លៃជីវចម្រុះ ជាពិសេសស្ថានភាពប្រព័ន្ធផ្កាថ្មស្រទាប់បាត ទីតាំងជាក់ស្តែង និងធនធាន ជីវចម្រុះដែលមានវត្តមាននៅក្នុងតំបន់ផ្កាថ្មនោះ
- → សិក្សានិងវាយតម្លៃពីធនធានជលផលសមុទ្រនិងសកម្មភាពនេសាទនៅជុំវិញកោះ
- → កំណត់អំពីផលប៉ះពាល់និងវិធានការកាត់បន្ថយផលប៉ះពាល់

ទិន្នន័យដែលប្រមូលបានអាចត្រូវបានចាត់ទុកជាទិន្នន័យគ្រឹះដ៏មានសារសំខាន់បំផុតនៅមុន ពេលដំណើរការសាងសង់គម្រោង ពីព្រោះទិន្នន័យនេះអាចយកធ្វើជាអំណះអំណាងក្នុងការតាមដានបម្រែ បម្រួលធនធានជលផលក្នុងអំឡុងពេលកំពុងសាងសង់និង អំឡុងពេលដំណើរការគម្រោង (ក្រោយពេលសាងសង់)។ ក្នុងករណីការតាមដានឃើញថាមានការប្រែប្រួលជាពិសេស ធនធានជលផល ព្រៃកោងកាង និងផ្កាថ្ម នោះយើងត្រូវមានវិធានការជាបន្ទាន់។

ទិន្នន័យដែលនឹងត្រូវប្រមូលរួមមានបីទិដ្ឋភាពសំខាន់ៗគឺ សកម្មភាពនេសាទ ធនធានជលផល និងទីជម្រកជលផល។

### ៥.៤.៣ សំយោគឯកសារ

#### ក. ទីតាំងភូមិសាស្ត្រ

កោះក្របី មានទីតាំងនៅមុខឧទ្យានជាតិរាម ក្នុងឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានទំហំ ប្រមាណ១០ហិកតា និងមានចម្ងាយប្រមាណ៦គីឡូម៉ែត្រពីឆ្នេររាម។ តាមការស្រាវជ្រាវរបស់រដ្ឋបាល ជលផល ដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ីផ្កាថ្មនៅក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា ប្រជុំកោះត្រូវបានបែងចែកជា ៧ប្រជុំកោះ គឺប្រជុំកោះរុង ប្រជុំកោះតាគៀវ ប្រជុំកោះស្ដេច ប្រជុំកោះកុង ប្រជុំកោះតាង ប្រជុំកោះពោធិ៍ និងព្រែកអំពិល។ តាមរយៈការដាក់ជាប្រជុំកោះនេះ កោះក្របីត្រូវបានដាក់ឲ្យស្ថិតនៅក្នុងតំបន់ប្រជុំកោះ តាគៀវ ដែលមានកោះជាច្រើនទៀតនៅជុំវិញ ដូចជាកោះត្រេះ កោះច្រឡុះ កោះឫស្សី កោះតាគៀវ។ល។ តាមការវាយតម្លៃជាបឋមរបស់រដ្ឋបាលជលផលឆ្នាំ២០០៥ បានបង្ហាញថា នៅក្នុងតំបន់ប្រជុំកោះតាគៀវ មានផ្កាថ្មប្រមាណ ២៩២,៥ហិកតា (DoF, 2005)។




រូបភាព ៥.៤ ៖ ផែនទីប្រជុំកោះតាគៀវ ខេត្តព្រះសីហនុ




រូបភាព៥.៥៖ រូបភាពកោះក្របី ក្នុងប្រជុំកោះតាគៀវ ខេត្តព្រះសីហនុ

ខ. ធនធានជលផល

ត្រី គឺជាពពួកសត្វឆ្អឹងកងដែលសម្បូរជាងគេនៅក្នុងសមុទ្រ ហើយមានប្រមាណជាង ៥០០ប្រភេទ ត្រូវបានរកឃើញនៅក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា (FiA, 2011)។ ត្រីសមុទ្រទាំងនេះភាគ ច្រើនមានតម្លៃសេដ្ឋកិច្ចខ្ពស់ សម្រាប់ជាតម្រូវការស្រស់និងសម្រាប់កែច្នៃ (ផលិតជាចំណីត្រី ទឹកត្រីឬម្សៅ ត្រី)។ ត្រីត្រូវបានចែកជាពីរក្រុមសំខាន់ៗ គឺក្រុមឆ្អឹងទន់ Chondrichthyes (មានពពួកឆ្លាមនិងបបែល) និងក្រុមឆ្អឹងរឹង Osteichthye។

ឆ្លាមនិងបបែល: គឺជាក្រុមបុរេសត្វដែលមានតាំងពីជាង៣៥០លានឆ្នាំមុនម្ល៉េះ។ នៅក្នុងព្រះរាជា ណាចក្រកម្ពុជា ពពួកបបែល (Stingrays) ជាប្រភេទដែលជាគោលដៅចាប់ ឯឆ្លាមជាប្រភេទចាប់ដោយ ចៃដន្យ។ ឆ្លាមនិងបបែលមានការលូតលាស់និងការពេញវ័យយឺត ហើយមានកូនតិចតួចប៉ុណ្ណោះ។ ដូច្នេះ ពួកវាត្រូវបានគេគិតថា ងាយរងគ្រោះដោយសារសកម្មភាព

មនុស្ស។ ពពួកឈ្មោលមានពងស្វាសមួយគូសម្រាប់បន្តពូជ ប្រភេទខ្លះឱ្យកំណើតមកជាកូនតូចៗ ឯប្រភេទខ្លះទៀតឱ្យកំណើតមកជាកន្សោមពង។ ត្រី ឆ្លាមដែលមាននៅក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាភាគច្រើនជាប្រភេទតូចៗ។ ប្រភេទឆ្លាមដែល ធំជាងគេគឺ បាណន់គីង្គក់ (Whale shark) ដែលចាត់ជាប្រភេទដែលកំពុងរងគ្រោះថ្នាក់។

**ត្រីឆ្អឹងរឹង:** ភាគច្រើនជាប្រភេទត្រីដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់នៅក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។ ប្រភេទជាច្រើនរស់នៅក្នុងតំបន់ផ្កាថ្ម ហើយពួកវាភាគច្រើនត្រូវនេសាទបានដោយឧបករណ៍ខុសច្បាប់ដូចជា ការប្រើគ្រឿងផ្ទុះឬថ្នាំពុល។ ប្រភេទខ្លះគម្រហើយរស់នៅក្នុងទីជម្រក និងស៊ីប្រភេទចំណីជាក់លាក់ហើយមានប្រភេទខ្លះទៀតហែលជាហ្វូងនៅក្នុងដែនសមុទ្រ។ ប្រភេទខ្លះ មានប្រវែងដងខ្លួន ២-៣ស.ម ប៉ុណ្ណោះពេលពេញវ័យ ប្រភេទខ្លះទៀតលូតលាស់រហូតដល់២-៣គ.ក្រ មុនពេលវាពង ហើយពួក វាមានរូបរាង និងពណ៌ផ្សេងៗគ្នា។ ត្រីឆ្អឹងរឹងភាគច្រើនផលិតពងបានច្រើន ហើយបង្កកំណើតនៅក្នុងទឹក។ ពពួកត្រីតុកកែ ត្រីឆ្កង់ និងត្រីអាំងកឹយ គឺជាប្រភេទត្រីដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ជាងគេក្នុងចំណោមប្រភេទផលនេសាទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### គ. ធនធានជលផលដែលកំពុងរងគ្រោះថ្នាក់

រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរកឃើញថា មានប្រភេទធនធានជលផល ដែលកំពុងរងគ្រោះថ្នាក់ចំនួន៥៨ប្រភេទ ដែលក្នុងនោះ ប្រភេទធនធានជលផលសមុទ្រកំពុង រងគ្រោះថ្នាក់ចំនួន២៩ប្រភេទ និងប្រភេទធនធានជលផលទឹកសាបដែលកំពុងរងគ្រោះថ្នាក់មានចំនួន២៩ ប្រភេទដែរ។ ប្រភេទដែលកំពុងរងគ្រោះថ្នាក់ទាំងនេះ ត្រូវបានចែកជាបីក្រុមធំ គឺប្រភេទដែលជិតផុតពូជ ប្រភេទដែលកំពុងរងគ្រោះនិងប្រភេទងាយរងគ្រោះ។ ការចាត់ថ្នាក់ក្រុមនេះធ្វើឡើងទៅតាមស្ថានភាពរបស់ វានៅក្នុងដែនទឹកធម្មជាតិដូចខាងក្រោម៖

- ក្រុមប្រភេទជិតផុតពូជ៖ ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរងគ្រោះ ថ្នាក់ដែលចំពោះមុខផលស្តុកក្រុមប្រភេទនេះកំពុងប្រឈមទៅនឹងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ ហើយ អាចវិនាសផុតពូជទាំងស្រុងនៅក្នុងធម្មជាតិនាពេលអនាគតដ៏ខ្លីខាងមុខដោយបរិមាណ សរុបបានថយចុះយ៉ាងតិច ៨០(ប៉ែតសិប)ភាគរយ ក្នុងរយៈពេល១០(ដប់)ឆ្នាំចុងក្រោយឬ ក្នុងរយៈពេលបីជំនាន់តំណពូជកន្លងមក តាមរយៈការអង្កេតការប៉ាន់ប្រមាណឬការសន្និដ្ឋាន។
- ក្រុមប្រភេទកំពុងរងគ្រោះ៖ ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរង គ្រោះថ្នាក់ដែលមានភស្តុតាងបង្ហាញច្បាស់ថា ក្រុមប្រភេទនេះកំពុងប្រឈមនឹងគ្រោះថ្នាក់ដ៏ខ្លាំង ហើយអាចវិនាសផុតពូជនៅក្នុងធម្មជាតិនាពេលអនាគតមិនយូរប៉ុន្មាន

ដោយបរិមាណ សរុបបានថយចុះយ៉ាងតិច៥០(ហាសិប)ភាគរយ ក្នុងរយៈពេល១០ (ដប់) ឆ្នាំចុងក្រោយឬ ក្នុងរយៈពេលបីជំនាន់តំណពូជកន្លងមកតាមរយៈការអង្កេត ការប៉ាន់ប្រមាណ ការសន្និដ្ឋាន ឬការរំពឹងទុក។

- ក្រុមប្រភេទងាយរងគ្រោះ៖ ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរង គ្រោះដែលងាយប្រឈមនឹងគ្រោះថ្នាក់ដ៏ខ្លាំង ហើយអាចនឹងវិនាសផុតពូជនៅក្នុងធម្មជាតិ នាពេលអនាគតខាងមុខ ដោយបរិមាណសរុបបានថយចុះយ៉ាងតិច២០ (ម្ភៃ) ភាគរយ ក្នុងរយៈពេល១០(ដប់)ឆ្នាំចុងក្រោយ ឬរយៈពេលបីជំនាន់តំណពូជកន្លងមកតាមរយៈការអង្កេត ការប៉ាន់ប្រមាណ ការសន្និដ្ឋានឬការរំពឹងទុក។

តារាង៥.១៨៖ ប្រភេទធនធានជលផលសមុទ្រដែលកំពុងរងគ្រោះថ្នាក់ទាំង២៩ប្រភេទ

| លរ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះពាណិជ្ជកម្ម | សាយតេស |
|---|---|---|---|---|
| **ប្រភេទជិតផុតពូជ** | | | | |
| 1 | ក្រពើសមុទ្រ | *Crocodylus porosus* | Estuarine crocodile | I |
| 2 | ជ្រូកទឹកឬពយ៉ុង | *Dugong dugon* | Dugong | I |
| **ប្រភេទកំពុងរងគ្រោះ** | | | | |
| 3 | ត្រីសេកបូក | *Cheilinus undulates* | Humphead Wrasse | II |
| 4 | បាឡែនក្របី | *Pseudorca crassidens* | False killer whale | II |
| 5 | បាឡែនក្បាលធំ | *Globicephala macrorhynchus* | Short-finned pilot whale | II |
| 6 | ផ្សោតចម្រុះដបចំពុះខ្លី | *Tursiops aduncus* | Indo-Pacific bottlenose dolphin | II |
| 7 | ផ្សោតក្បាលត្រឡោក | Orcaella brevirostris | Irrawaddy dolphin | I |
| 8 | ផ្សោតចម្រុះដបចំពុះវែង | *Tursiops truncates* | Common bottlenose dolphin | II |
| 9 | ផ្សោតឃ្លៀច | *Sousa chinensis* | Indo-Pacific hump-backed dolphin | I |
| 10 | ផ្សោតឆ្នូតភ្នែក | *Stenella longirostris roseinventris* | Dwarf spinner dolphin | II |
| 11 | ផ្សោតអុច | Stenella attenuate | Pantropical spotted dolphin | II |
| 12 | ផ្សោតឥតព្រុយខ្នង | *Neophocaena phocaenoides* | Finless porpoise | I |
| 13 | ផ្សោតខ្មៅលឿង | *Dolphinus capensis tropicalis* | Long-beaked common dolphin | I |
| 14 | ល្មិច | *Chelonia mydas* | Green turtle | I |
| 15 | ក្រាស | Eretmochelys imbricate | Hawksbill turtle | I |

#322P, St.271Z, Sk.Terk Tla, Khan Russey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| | | | | |
|---|---|---|---|---|
| 16 | ល្មិចព្រុយបីឬល្មិចស្តី | *Dermochelys coriacea* | Leatherback turtle | I |
| 17 | ល្មិចក្បាលធំ | Caretta caretta | Loggerhead turtle | I |
| 18 | ល្មិចប្រផេះ | *Lepidochelys olivacea* | Olive ridley turtle | I |
| 19 | គ្រុំយក្ស | *Tridacna squamosa* | Fluted giant clam | II |
| 20 | គ្រុំយក្ស | *Tridacna maxima* | Elongate giant clam | II |
| 21 | គ្រុំយក្ស | Tridacna crocea | Crocus giant clam | II |
| 22 | គ្រុំយក្ស | *Tridacna gigas* | Giant clam | II |
| 23 | ខ្យងកោដ្ឋ | *Trochus niloticus* | Commercial top | |
| 24 | ខ្យងគុជឬខ្យងប្រាក់ | *Turbo marmoratus* | Green turbo or green snail | |
| 25 | សេះសមុទ្រ | *Hippocampus spp.* | Seahorse | II |
| 26 | ផ្កាថ្ម | *Anthozoa spp.* | Corals and sea anemones | |
| 27 | ប្រឡាំងកាស | Tachypleus gigas | Traingular-tail horseshoe crab | |
| 28 | កាចរ | *Carcinoscorpius rotundicauda* | Mangrove horseshoe crab | |
| 29 | ត្រីបាណន់គីង្គក់ | *Rhincodon typus* | Whale shark | II |

ក្នុងឆ្នាំ២០០៩ ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ទាំងនេះ ត្រូវបានកំណត់ជាផ្លូវការ ដោយអនុក្រឹត្យលេខ១២៣ អនក្រ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩។ យោងតាមច្បាប់ស្តីពីជលផល ប្រភេទដែលកំពុងរងគ្រោះថ្នាក់ទាំងនេះ ត្រូវបានហាមឃាត់ការចាប់ ការលក់ ការទិញ ការដឹកជញ្ជូន ការ ប្រមូលផល ការកែច្នៃ និងការធ្វើសន្និធិពីដែនទឹកធម្មជាតិ លើកលែងតែក្នុងគោលបំណងសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្រដែលត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋបាលជលផល។

ប្រភេទទាំងអស់នេះ ភាគច្រើនត្រូវការជម្រកព្រៃកោងកាង ស្មៅសមុទ្រ និងផ្កាថ្មជាសំខាន់ ដើម្បីរស់នៅធំធាត់ និងបន្តពូជ ដូច្នេះយើងចាំបាច់ត្រូវការពារជម្រកទាំងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ឃ. ធនធានជម្រកជលផល និងការគំរាមកំហែង

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយប្រកបដោយធនធានធម្មជាតិយ៉ាងសម្បូរបែប ក្នុងនោះ ផ្កាថ្ម ស្មៅសមុទ្រ និងព្រៃកោងកាង គឺជាធនធានធម្មជាតិដ៏មានសារសំខាន់បំផុតក្នុងការផ្តល់ទីជម្រកពង កូននិងរកចំណីដល់វារិសត្វជាច្រើនប្រភេទ រក្សាលំនឹងប្រព័ន្ធអេកូឡូស៊ី

និងបម្រើឲ្យសេដ្ឋកិច្ចសង្គម។ ធនធាន ទាំងអស់នេះ មិនត្រឹមតែបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ត្រីដែលជាអាហារប្រចាំថ្ងៃរបស់ប្រជាជន កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែវាមានសារសំខាន់សម្រាប់ការពារឆ្នេរសមុទ្រ ជីវៈចម្រុះគ្រប់ប្រភេទ និងបម្រើទេស ចរណ៍ធម្មជាតិទៀតផង។

ផ្កាថ្មនៅក្នុងប្រទេសកម្ពុជាចែកចាយនៅទីកន្លែងជាច្រើន ជាទូទៅវាជុះជាប់ទៅនឹងកោះដែលនៅ ឆ្ងាយពីឆ្នេរនិងតំបន់ដែលមានថ្ម។ តំបន់ផ្កាថ្មសរុបត្រូវបានប៉ាន់ស្មានថា មានទំហំប្រមាណ២៨,០៦៥ គ.ម² ហើយនៅប្រជុំកោះតាគៀវ មានផ្កាថ្មសរុបប្រហែល២៩២,៥ហិកតា។ តាមការវាយតម្លៃពីគម្រោងសមុទ្រ ចិនភាគខាងត្បូងបានឲ្យដឹងថា ផលិតផលផលផលផ្ទាល់ដែលបានទទួលពីផ្កាថ្មក្នុងមួយហិកតាក្នុងមួយឆ្នាំ មានតម្លៃជាប្រាក់ដុល្លាអាមេរិក២.៣០០ដុល្លា។ នេះជាតួលេខដោយផ្ទាល់ដោយពុំបានរាប់បញ្ចូលនូវតួនាទី ដ៏មានសារសំខាន់ក្នុងការបម្រើឲ្យវិស័យទេចរណ៍ ជាជម្រក និងកន្លែងបន្តពូជរបស់សត្វសមុទ្រជាច្រើន ប្រភេទ ទប់ស្កាត់នឹងរលក ព្រមទាំងមានតួនាទីរក្សាលំនឹងបរិស្ថានជាច្រើនទៀត។ តាមរយៈការសិក្សាពី ជីវៈចម្រុះបានបង្ហាញថា មានផ្កាថ្មចំនួន៧០ប្រភេទ ស្ថិតក្នុង៣៣ពូជ និង១១អំបូរ (Nelson 1999)។ ជា មធ្យមផ្កាថ្មនៅមានជីវិតគ្របដណ្តប់តំបន់ឆ្នេរប្រមាណពី២៣%ទៅ៥៨%។ ផ្កាថ្មរស់ក្នុងតំបន់ទឹកដែលមាន កំហាប់អំបិលចន្លោះ៣៤-៣៧ភាគ៣ាន់ ជាតំបន់គ្មានល្បាប់ភក់ ទឹកមានសភាពស្អាតនិងថ្លាមានពន្លឺគ្រប់ គ្រាន់ និងជាតំបន់គ្មានការបំពុល។ ប្រព័ន្ធផ្កាថ្មនៅក្នុងប្រទេសកម្ពុជាកំពុងតែទទួលរងនូវការគំរាមកំហែងដ៏គួរឲ្យព្រួយបារម្ភបំផុត ដូចជា ៖

- កំណកនិងសារធាតុចិញ្ចឹម (ចេញពីតំបន់ដីគោក) ការធ្វើកសិកម្មនិងការអភិវឌ្ឍនៅតំបន់ឆ្នេរ បានរួមចំណែកបង្កការបំផ្លាញផ្កាថ្មនៅក្នុងប្រទេសកម្ពុជា ដោយធ្វើឱ្យមានកំណកនិងភាពកខ្វក់ហូរពីតំបន់ដីគោក។ ដោយគ្មានវិធានការបន្ធូរបន្ថយឱ្យទាន់ពេលវេលាបរិមាណដីនិងការហូរច្រោះធ្លាក់ពីតំបន់ខ្ពស់ៗចាក់ទៅតំបន់ផ្កាថ្មក្បែរឆ្នេរជារៀងរាល់ឆ្នាំ។ ការហូរចាក់ដោយ កំណកករនេះបានរុំព័ទ្ធតួផ្កាថ្ម ហើយទីបំផុតបានធ្វើឲ្យផ្កាថ្មងាប់ ដោយសារពុំអាចធ្វើរស្មីសំយោគបាន។
- វិធីសាស្ត្រនេសាទដែលបង្កឱ្យមានការខូចខាតផ្អែកលើទិន្នន័យ Reef checknig និងការសិក្សាផ្សេងៗបានបង្ហាញថា គ្រឿងផ្ទុះ គឺជាការគំរាម កំហែងដ៏ចម្បងមួយទៅលើផ្កាថ្មនៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះ ការប្រើគ្រឿងផ្ទុះក្នុង ការនេសាទស្ទើរតែពុំមានទៀតទេ។ ជាងនេះទៅទៀត ការនេសាទដោយប្រើថ្នាំបំពុល ដើម្បីចាប់ត្រីផ្កាថ្ម ជាពិសេស ត្រីគុកៃបានធ្វើឲ្យបំពុលដល់ផ្កាថ្ម និងការនេសាទដោយអួនអូសនៅក្បែរតំបន់ផ្កាថ្មដែលបង្កជា កករុំព័ទ្ធតួផ្កាថ្ម ហើយធ្វើឲ្យផ្កាថ្មងាប់។
- ការបាក់បែកផ្កាថ្មដោយយុថ្កានិងអួនអូស ព្រមទាំងការបំផ្លាញផ្សេងៗទៀតការបាក់បែកផ្កាថ្មដែលបណ្តាលមកពីយុថ្កាកើតឡើងនៅលើតំបន់ផ្កាថ្មជាច្រើនក្នុងប្រទេសកម្ពុជា។ ការ

បាក់បែកផ្កាថ្មដែលបណ្តាលពីយុថ្កាភាគច្រើនមកពីទូកអ្នកនេសាទ ព្រោះគ្មានពោងបណ្តែតសម្រាប់ឱ្យ ទូកអាចចងភ្ជាប់បាន ហើយកត្តាដែលអ្នកនេសាទពុំមានការយល់ដឹងឬយកចិត្តទុកដាក់ចំពោះការបាក់បែក ដែលបណ្តាលមកពីការបោះយុថ្កាទៅលើតំបន់ផ្កាថ្ម។ ការទម្លាក់យុថ្ការបស់ទូកទេសចរណ៍នៃអ្នកមុជទឹក និងការដើរជាន់ផ្កាថ្ម កំពុងមានការគំរាមកំហែងទៅលើផ្កាថ្មនៅមានកម្រិតទាបបំផុត។ ទោះជាយ៉ាងនេះក្តី វាក៏អាចជាសក្តានុពលនៃការគំរាមកំហែងមួយនាពេលអនាគត នៅពេលដែលឧស្សាហកម្មទេសចរណ៍មាន ការកើនឡើង។ការបំផ្លាញផ្កាថ្មដែលកើតឡើងដោយសកម្មភាពនេះ គឺបណ្តាលពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដូចជា ការដាំសារាយដោយផ្ទាល់នៅលើតំបន់ផ្កាថ្មដែលបង្កឱ្យមានការបាក់បែក ដោយសារការដើរជាន់ផ្កាថ្មនិង ការបោះចោលកាកសំណល់ឧបករណ៍នេសាទ។

- ការអភិវឌ្ឍដែលធ្វើឱ្យបាក់បែកដល់ផ្កាថ្ម (ផែ ព្រលានយន្តហោះ ការជីកកកាយ)មានសកម្មភាពសាងសង់ជាច្រើននៅលើតំបន់ឆ្នេរ ប៉ុន្តែទំហំនៃផលប៉ះពាល់ទៅលើផ្កាថ្មយ៉ាងណា នោះមិនទាន់ត្រូវបានគេដឹងនៅឡើយទេ។ សកម្មភាពសាងសង់ រួមមានការពង្រីកកំពង់ផែពាណិជ្ជកម្ម សណ្ឋាគារផ្កាយប្រាំ និងទីលានវាយកូនហ្គោលត្រូវបានគេធ្វើឡើងនៅក្រុងព្រះសីហនុ។ ទោះបីជារដ្ឋាភិបាលមានគោលនយោបាយអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថានក៏ដោយ ប៉ុន្តែផលប៉ះពាល់នៅតែកើត មានដដែល។
- ការបង្កឱ្យផ្កាថ្មងាប់ (ធ្វើឱ្យផ្កាថ្មប្រែជាពណ៌ស bleaching)មានទិន្នន័យជាក់ច្បាស់បង្ហាញថា ក្នុងឆ្នាំ២០១០ នៅពេលដែលកំដៅនៃទឹកសមុទ្របានកើនដល់ ៣២ទៅ៣៥អង្សាសេ ផ្កាថ្មប្រមាណ៨០% នៅខេត្តព្រះសីហនុ បានប្រែជាពណ៌ស ហើយនឹងឈានទៅ ងាប់។ ប៉ុន្តែដោយសារមានការសង្គ្រោះបន្ទាន់ ជាពិសេស ក្រុមការងារបានសំអាតបរិស្ថានផ្កាថ្ម ហាម ឃាត់ទូកអូសនៅក្បែរតំបន់ផ្កាថ្ម និងជាពិសេសទប់ស្កាត់ការបោះចោលកាកសំណល់លើតំបន់ផ្កាថ្មបានទាន់ ពេលវេលា ទើបយើងអាចស្តារផ្កាថ្មឲ្យរស់មកវិញជាបណ្តើរៗ។
- ការបំផ្លាញផ្កាថ្មតាមរយៈបាតុភូតធម្មជាតិ (ខ្យល់ព្យុះ។ល។) ពុំមានភស្តុតាងជាលក្ខណៈវិទ្យាសាស្ត្រណាដែលបង្ហាញពីការបាក់បែកផ្កាថ្មដោយបាតុភូតធម្មជាតិទេ។ ប៉ុន្តែមានរបាយការណ៍ស្តីពីព្រឹត្តិការណ៍បំផ្លាញផ្កាថ្មធ្ងន់ធ្ងរនៅក្នុងឆ្នាំ១៩៩៨ ដោយបាតុភូតខ្យល់ព្យុះ ឡិនដានៅតំបន់អាស៊ីអាគ្នេយ៍។

### ៥.៤.៤ លទ្ធផលនៃការស្រាវជ្រាវលើធនធានជលផល

#### ក. ប្រភេទធនធានជលផលដែលប្រមូលបាន

មានធនធានជលផលចំនួនប្រាំប្រភេទសំខាន់ៗដែលប្រមូលបានក្នុងតំបន់គម្រោង និងជាប្រភពចំណូលយ៉ាងសំខាន់សម្រាប់អ្នកនេសាទ គឺក្តាមសេះ បង្គាស/ខ្លឹង ត្រីកាម៉ុង បបែល និងត្រីប៉ាឡាំង។

តារាង៥.១៩៖ ប្រភេទធនធានជលផលសំខាន់ៗដែលមានវត្តមាននៅក្នុងតំបន់គម្រោង

| ចំណាត់ថ្នាក់ | ប្រភេទ | ភាគរយ | តំលៃ/គីឡូក្រាម |
|---|---|---|---|
| ១ | ក្តាមសេះ | ៤០% | ៥-៧ដុល្លា |
| ២ | បង្គាស/ខ្លឹង | ២០% | ៥ដុល្លា |
| ៣ | ត្រីកាម៉ុង | ២០% | ០,៣ដុល្លា |
| ៤ | បបែល | ១០% | ១ដុល្លា |
| ៥ | ត្រីប៉ាឡាំង | ១០% | ១,៥ដុល្លា |

តាមរយៈការប្រើឧបករណ៍ខាងលើបានបញ្ជាក់ថា ប្រភេទក្តាមសេះសម្បូរក្នុងចន្លោះខែមីនាដល់ ឧសភា បង្គាសសម្បូរក្នុងចន្លោះខែមិថុនាដល់សីហា និងត្រីកាម៉ុងសម្បូរក្នុងខែមករាដល់មីនា និងត្រីផ្សេងៗ ទៀតអាចចាប់បានគ្រប់រដូវ។

ជារួម ធានធានជលផលនៅក្នុងតំបន់នេះមានប្រមាណជាង៤៦ប្រភេទ ដែលមានវត្តមានក្នុងតំបន់ គម្រោង ដូចក្នុងតារាងទី៥.២០ ខាងក្រោម។ ក្នុងចំណោមប្រភេទទាំងអស់នេះ មានប្រភេទខ្លះមានវត្តមានជា អចិន្ត្រៃយ៍ ជាពិសេសពពួកប្រភេទត្រីផ្កាថ្ម ពពួកប្រភេទក្តាមនិងបង្គាប្រភេទសត្វគ្មានឆ្អឹងខ្នង និងប្រភេទ ខ្យង គ្រំ ងាវ ឯប្រភេទផ្សេងទៀត ជាពិសេសពពួកផ្សោតមានទៅតាមរដូវប៉ុណ្ណោះ។

តារាង៥.២០៖ ប្រភេទធនធានជលផលដែលមាននៅជុំវិញតំបន់គម្រោង

| លរ | ឈ្មោះខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះពាណិជ្ជកម្ម | សំគាល់ |
|---|---|---|---|---|
| ប្រភេទត្រី (ប្រភេទដែលពិនិត្យឃើញក្នុងពេលសម្ភាសន៍) | | | | |
| 1 | ត្រីបោះគ្រា | *Lutjanusrusselli* | Russell's snapper | Coral reef fish |
| 2 | ត្រីគុកែជ្រូក | *Cromileptesaltivelis* | Humpback grouper | Coral reef fish |
| 3 | ត្រីគុកែប៉ាវ៉ា | *Epinephelusquoyanus* | Longfin grouper | Coral reef fish |

| | | | | |
|---|---|---|---|---|
| 4 | ត្រីតុកែកៅ | *Epinepheluscoioides* | Orange spotted grouper | Coral reef fish |
| 4 | ត្រីតុកែអុចខៀវ | *Plectropomusoligocanthus* | Highfin grouper | Coral reef fish |
| 5 | ត្រីកន្តាំងភ្លើង | *Siganusguttatus* | Orangespottedspinefoot | Coral reef fish |
| 6 | ត្រីមេអំបៅ | *Chelmonrostratus* | Copperbanded butterfly fish | |
| 7 | ត្រីសេក | *Cheilinusundulatus* | Humphead Wrasse | Coral reef fish |
| 8 | ត្រីគ្រាប់ខ្នុរ | *Lethrinuslentjan* | Pinkear emperor | |
| 9 | ត្រីគ្រាប់ខ្នុរ | *Lethrinusminiatus* | Sweetlip emperor | |
| 10 | ត្រីគោ | *Pseudotriacanthusstrigilifer* | Longspinedtripodfish | |
| 11 | ត្រីឆ្លាមឆ្នូត | *Chiloscylliumpunctatum* | Brown banded bamboos shark | |
| 12 | ត្រីត្រសក់ | *Petatestheraps* | Largesscaledterapon | |
| 13 | ត្រីប្រម៉ា | *Nibeasoldado* | Soldier croaker | |
| 14 | ត្រីប្រម៉ាអូច | *Nibea soldado* | Soldier croaker | |
| 15 | ត្រីអណ្តាតឆ្កែ | *Paraplagusiabilineata* | Doublelinedtonguesole | |
| 16 | ត្រីកន្តាំងក្រអូប | *Siganuscanaliculatus* | White spotted spinefoot | |
| 17 | ត្រីកន្តាំងប្រផេះ | *Siganus argenteus* | Streamlined spinefoot | |
| 18 | ត្រីកាម៉ុងខ្លួនខ្លី | *Rastrelligerbrachysoma* | Short mackerel | |
| 19 | ត្រីប៉ាឡាំង | *Rastrelligerkanagurta* | Indian mackerel | ត្រីកាម៉ុងខ្លួនវែង |
| 20 | ត្រីកាឡាំង | *Scomberoides commersonianus* | Talang queenfish | |
| 21 | ត្រីចិន | *Saurida sp.* | Lizardfish | |
| 22 | ត្រីស្តង់ក្រហម | *Lutjanusvitta* | Brownstripe snapper | |
| 23 | ត្រីបេកាឆ្នូត . | *Scomberomoruscommerson* | Narrowbarred | |
| 24 | ត្រីកូនគុំ | *Atule mate* | Yellotailscad | |
| 25 | ត្រីកុក | *Trichiurus lepturus* | Largehead hairtail | |
| 26 | ត្រីកន្ទុយរឹង | *Megalaspis cordyla* | Torpedo scad | |
| 27 | ត្រីការ៉ាវ | *Polydactylus indicus* | Indian threadfin | |
| 28 | ត្រីគូនបារាំង | *Amblygaster sirm* | Spotted sardinella | |
| 29 | ត្រីក្អុក | *Arius maculatus* | Spotted catfish | |

| | | | | |
|---|---|---|---|---|
| 30 | ត្រីកាម៉យ | *Anodontostoma chacunda* | Chacunda gizzard shad | |
| 31 | បបែលមាន់ | *Himanturaimbricata* | Scaly whipray | |
| ប្រភេទក្តាមនិងបង្គា (ប្រភេទដែលពិនិត្យឃើញក្នុងពេលសម្ភាសន៍) | | | | |
| 32 | ក្តាមសេះ | *Portunuspelagicus* | Flower crab | |
| 33 | ក្តាមអុចបី | *Portunussanguinolentus* | Three spot swimming crab | |
| 34 | ក្តាមថ្ម | *Scylla serrata* | Giant mud crab | |
| 35 | ក្តាមពីងពាងគូថស្រួច | Doclea tetraptera | | |
| 36 | បង្កងកណ្តូប | *Anchisquilla fasciata* | | |
| 37 | បង្គាប៉ាវ៉ា | *Penaeus semisulcatus* | Green tiger shrimp | |
| 38 | បង្គាខ្លឹង | *Penaeusmonodon* | Giant tiger prawn | |
| 39 | បង្គាកុងឡាយ | *Penaeusesculentus* | Tiger Prawn | |
| 40 | បង្គាអាងខា | *Penaeuspenicillatus* | | |
| ពពួកខ្យង គ្រុំ ងាវ (ប្រភេទដែលពិនិត្យឃើញក្នុងពេលសម្ភាសន៍) | | | | |
| 41 | ខ្យងដូង | *Melomelo* | Indian volute | |
| 42 | ខ្យងត្នោត | *Cymbiolanobilis* | Nodle volute | |
| 43 | ខ្យងជើងមួយ | *Strombuscanarium* | Dog conch | |
| 44 | ខ្យងពងគ្រួច | *Babylonia areolata* | Maculated ivory whelk | |
| 45 | គ្រែងឈាម | *Anadara nodifera* | Nodular ark | |
| 46 | ងាវហ្វូល | *Meretrix lusaria* | Poker-chip venus | |
| 47 | ងាវស | *Donax faba* | Pacific bean donax | |
| 48 | គ្រុំចំពុះទា | *Pernaviridis* | Green mussel | |
| 49· | គ្រុំចបជីក | *Atrinavexillum* | Fleg pen shell | |
| 50 | គ្រុំយក្ស | *Tridacna* sp. | Giant clam | ប្រភេទកំពុងរងគ្រោះ |
| ពពួកមឹក (ប្រភេទដែលពិនិត្យឃើញក្នុងពេលសម្ភាសន៍) | | | | |
| 51 | មឹកពីងពាង | *Octopus sp.* | | |
| 52 | មឹកស្នូក | *Sepiellainermis* | Spineless cuttlefish | |
| 53 | មឹកបំពង់ | *Uroteuthisduvaucelii* | | |

| | | | | |
|---|---|---|---|---|
| 54 | មឹកដូង | *Sepiola sp.* | | |
| ប្រភេទកំពុងរងគ្រោះថ្នាក់ (ប្រភេទដែលផ្តល់ព័ត៌មានដោយអ្នកនេសាទនិងមន្ត្រីជលផលខេត្ត) | | | | |
| 55 | ផ្សោតឃ្លៀច | *Sousa chinensis* | Indo-Pacific humpback dolphin | ប្រភេទកំពុងរងគ្រោះ |
| 56 | ផ្សោតឥតព្រុយខ្នង | *Neophocaenaphocaenoides* | Finless porpoise | ប្រភេទកំពុងរងគ្រោះ |
| 57 | ផ្សោតក្បាលត្រឡោក | *Orcaellabrevirostris* | Irrawaddy dolphin | ប្រភេទកំពុងរងគ្រោះ |
| 58 | ល្មិច | *Chelonia* | Green turtle | ប្រភេទកំពុងរងគ្រោះ |
| 59 | ក្រាស | *Eretmochelys imbricate* | Hawksbill turtle | ប្រភេទកំពុងរងគ្រោះ |
| 60 | ប្រទ្បាំងកាស | *Tachypleus gigas* | Triangular-tail horseshoe crab | ប្រភេទកំពុងរងគ្រោះ |
| 61 | ក្រចាប់ | *Protoreaster nodosus* | Horned sea star | |
| ប្រភេទសត្វគ្មានឆ្អឹងខ្នង (ប្រភេទដែលពិនិត្យឃើញផ្ទាល់នៅពេលមុជស្រាវជ្រាវ) | | | | |
| 62 | កាំប្រមា៉ | *Diadema urchins* | Sea urchin | |
| 63 | ឈ្លើងសមុទ្រ | *Holothuraatra* | Black Sea cucumber | |

តាមការស្រាវជ្រាវនិងប្រមូលព័ត៌មានពីអ្នកនេសាទបានបង្ហាញថា មានផ្សោតយ៉ាងហោចណាស់ បីប្រភេទមានវត្តមាននៅក្នុងតំបន់ប្រជុំកោះតាគៀវ (តំបន់កោះក្របី) ជាពិសេសក្នុងចន្លោះខែវិច្ឆិកាដល់ខែ មករា ជារៀងរាល់ឆ្នាំ។ ផ្សោតទាំងនេះហែលជាហ្វូងៗ បម្លាស់ទីពីតំបន់ផ្សេងៗ ពិសេសពីតំបន់ប្រជុំកោះរុង និងកោះតាង មកក្នុងតំបន់នេះដើម្បីចាប់ចំណីជាអាហារដូចជាត្រី មឹក និងបង្គា។ ក្រៅពីនេះ ម្តងម្កាល ពួកអ្នកនេសាទបានប្រទះឃើញត្រីបាឡែនក្នុងអំឡុងខែកញ្ញា ដើម្បីស៊ីគីជាអាហារ។

តាមក្រាហ្វិក៥.៨ ខាងក្រោមបានបង្ហាញថា ផលចាប់ជាមធ្យមក្នុងមួយគ្រួសារក្នុងមួយខែពុំមានការ ប្រែប្រួលទៅតាមខែនោះទេ គឺក្នុងចន្លោះពី៤៣៨ដល់ ៤៦០គីឡូក្រាម និងប្រមាណ ៥.២៨០គីឡូក្រាមក្នុង មួយឆ្នាំក្នុងមួយគ្រួសារ។ មូលហេតុដែលផលដែលចាប់បានមានលក្ខណៈបែបនេះ គឺដោយសារតែការចាប់ មានការប្រែប្រួលទៅតាមរដូវ និងទៅតាមប្រភេទដែលសំបូរ។

តាមរយៈការសម្ភាសន៍ពីអ្នកនេសាទបានឲ្យដឹងថា មានប្រជាពលរដ្ឋប្រមាណ៥០គ្រួសារកំពុងធ្វើនេសាទនៅក្នុងតំបន់ប្រជុំកោះតាគៀវ ប៉ុន្តែមានតិចតួច ប្រមាណ២០គ្រួសារបានធ្វើនេសាទនៅ ជុំវិញកោះក្របី។ តាមរយៈតួលេខនេះ យើងអាចគណនាបានថា ផលនេសាទដែលបានដកពីតំបន់កោះក្របីនេះមានជាមធ្យម ១០៥,៦តោនក្នុងមួយឆ្នាំ (៥២,៨០តោន

X២០(គ្រួសារ)។ ប្រសិនយើងយកតម្លៃ ទីផ្សារជាមធ្យម២,៨ដុល្លាក្នុងមួយគីឡូក្រាមផលជលផល នោះយើងអាចគណនាតម្លៃសរុបដែលទទួលបាន ជារៀងរាល់ឆ្នាំពីតំបន់កោះក្របីប្រហែលជាង ១០ម៉ឺនដុល្លាអាមេរិក។

នេះគ្រាន់តែជាការគណនាតម្លៃមួយឲ្យឃើញថា ប្រសិនមានការទប់ស្កាត់ការនេសាទក្នុងតំបន់ **កោះក្របី** នោះប្រជាពលរដ្ឋទាំងមូលនឹងបាត់បង់ប្រាក់ចំណូលប្រមាណ ១០ម៉ឺនដុល្លាអាមេរិកក្នុងមួយឆ្នាំ តាមរយៈការបាត់បង់ដែននេសាទ។ តែទោះជាយ៉ាងនេះក្តី បើក្រុមហ៊ុនបានកំណត់ទីតាំងដែលហាមឃាត់ការនេសាទច្បាស់លាស់ ហើយមានកន្លែងផ្សេងៗទៀតជាច្រើនដែលប្រជាពលរដ្ឋអាចធ្វើនេសាទបាននៅក្នុងតំបន់ប្រជុំកោះនេះ (ពីព្រោះពួកគេធ្វើនេសាទចល័តពីទីតាំងមួយទៅទីតាំងមួយទៀត) នោះអាចនឹងមិនបង្កបញ្ហាខ្លាំងដល់ពួកអ្នកនេសាទទេ។




ក្រាហ្វិកទី៥.៦៖ ផលចាប់តាមខែក្នុងមួយគ្រួសារៗក្នុងតំបន់កោះក្របី




ក្រាហ្វិកទី៥.៧៖ ផលចាប់សរុបតាមខែក្នុងតំបន់កោះក្របី

#322P, St.271Z, Sk.Tuek Tla, Khan Russey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

## ខ. លទ្ធផលនៃការស្រាវជ្រាវធនធានជីវចម្រុះនិងប្រភេទស្រទាប់បាត

### ខ.១ ទីតាំងជុំវិញកោះក្របី

តាមការស្រាវជ្រាវនៅបាតសមុទ្រក្នុងតំបន់ជុំវិញកោះក្របី ទាំង២០ទីតាំងបានបញ្ជាក់ថា ផ្កាថ្មគ្រប ដណ្តប់ពី០ដល់៧០% ហើយក្នុងចំណោមភាគរយនៃផ្កាថ្មនេះ មានប្រមាណ២០ដល់៥០% ភាគរយជា ផ្កាថ្មងាប់ ហើយមូលហេតុនៃការងាប់នេះភាគច្រើនបណ្តាលមកពីការប្រើគ្រឿងផ្ទុះក្នុងអតីតកាល និង ដោយសារកំទិចកំទីព្រមទាំងកករវព័ទ្ធផ្កាថ្ម។ តាមការអង្កេតក៏មានផ្កាថ្មមួយចំនួន បានងាប់ដោយបម្រែបម្រួល អាកាសធាតុដែរ ជាពិសេសក្នុងឆ្នាំ២០១០ ហើយពុំបានស្តារឡើងវិញ។ ទោះជាយ៉ាងនេះក្តី គេឃើញមាន ផ្កាថ្មតូចៗមួយចំនួនទើបនឹងដុះឡើងវិញ ហើយអាចនឹងធ្វើឲ្យតំបន់នេះសម្បូរផ្កាថ្មឡើងវិញបាន ប្រសិន មានការការពារបានត្រឹមត្រូវ។ ជារួម ផ្កាថ្មនៅទីតាំងនេះជាប្រភេទផ្កាថ្មរឹង ភាគច្រើនពពួកផ្កាថ្មចង្អេរ ប៉ុន្តែ មានផ្កាថ្មទន់និងរឹងមួយចំនួនទៀតផងដែរ។

ទីតាំងដែលសម្បូរផ្កាថ្ម ហើយដែលត្រូវយកចិត្តទុកដាក់ក្នុងការការពារ គឺទីតាំង ១ ២ ៣ ៧ ៨ ៩ ១០ ១១ ១២ ១៣ ១៧ ១៩ និង២០ ចំណែកទីតាំង ៤ ៥ ៦ ១៤ ១៥ ១៦ និង១៨ មានផ្កាថ្មតិច តូចបំផុត។ រូបទី៥ និងតារាងទី៥ ខាងក្រោមបង្ហាញលំអិតពីធនធានជលផលនិងជីវចម្រុះស្រទាប់បាតក្នុង ទីតាំងនីមួយៗ។ ចំពោះទីតាំងដែលមានវត្តមានផ្កាថ្ម ភាគច្រើនមានពីមាត់ច្រាំងរហូតដល់ចម្ងាយ២០០ ម៉ែត្រទៅក្នុងសមុទ្រ ដែលមានជម្រៅទឹកពី១ដល់៦ម៉ែត្រ។

តាមលទ្ធផលនៃការស្រាវជ្រាវបានបញ្ជាក់ច្បាស់ថា ទីតាំងដែលសម្បូរផ្កាថ្ម គឺទីនោះសម្បូរត្រី។ ពពួកត្រីសេកនិងត្រីមេអំបៅមានវត្តមានជាបង្គួរនៅក្នុងតំបន់ផ្កាថ្ម ហើយប្រភេទត្រីទាំងពីរនេះជាសូចនាករ បង្ហាញពីវត្តមាននិងសុខភាពផ្កាថ្ម។ ជាក់ស្តែង ក្នុងទីតាំងទី១ ២ ៣ ១០ ១១ ១៣ និង១៧ នៅពេលដែលផ្កាថ្មស្ថិតក្នុងស្ថានភាពល្អប្រសើរ វត្តមានហ្វូងត្រីសេក និងហ្វូងត្រីមេអំបៅក៏មានវត្តមាននៅទីនោះដែរ ដូច្នេះត្រូវមានវិធានការការពារ និងរៀបចំទីតាំងទាំងនេះសម្រាប់ជាកន្លែងស្រាវជ្រាវ អភិរក្ស និងបម្រើអេកូ ទេសចរណ៍។ ជាងនេះទៅទៀត ការបង្ហូរកាកសំណល់ឬកករដីពីតំបន់ដីគោក ឬការកាយដីក្នុងទីតាំងលើ គោកក្បែរទីតាំងនេះគួរមានការហាមឃាត់ឬត្រូវមានការប្រុងប្រយ័ត្នខ្ពស់។




រូបទី៥.៦៖ ផែនទីបង្ហាញពីធនធានជលផលសំខាន់ៗជុំវិញកោះក្របី

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាង៥.២១៖ លទ្ធផលស្រាវជ្រាវធនធានជលផលស្រទាប់បាតនៅជុំវិញកោះក្របី

| ទីតាំង (A=Area) | ចំណុចនិយាមការ | ជម្រៅទឹក (m) | កម្រិតថ្លា (m) | ប្រភេទស្រទាប់បាតសំខាន់ៗ និងប្រភេទត្រី | រូបថតតាមទីតាំងនីមួយៗ |
|---|---|---|---|---|---|
| A01 | X=0343600<br>Y=1161696 | 2,2 | 2,5 | នៅទីតាំងនេះមានផ្កាថ្មគ្របដណ្ដប់ប្រមាណ៧០% ក្នុងនោះងាប់២០% , ៣០%កំទេចកំទីសំបកសិប្បី សត្វ និងខ្សាច់។ មានពពួកកាំប្រម៉ាសមុទ្រ (Sea Urchin), Delicate Whip Coral, Barrel Sponge, មានហ្វូងកូនត្រី Red-striped Cardinal fish (Family Apogonidae) និងមានត្រីសេកទំហំ ២០សម។ ផ្កាថ្មមានចំងាយប្រមាណ ១០ម៉ែត្រពីឆ្នេរ។ |  |
| A02 | X=0343589<br>Y=1161573 | 4,2 | 2,5 | នៅលើទីតាំងនេះមានផ្កាថ្មគ្របដណ្ដប់៧០% ក្នុងនោះងាប់៣០%។ មានត្រីមេអំបៅ២ក្បាល (Butterfly fish) Seafan, Sponge និងហ្វូងកូនត្រីមេអំបៅ) និងត្រីសេកទំហំក្រោម២០សម ជាច្រើនរស់នៅក្នុង ចំណុចនោះ។ ជាចំណុចមានធនធានជលផលសម្បូរ បែបហើយផ្កាថ្មស្ថិតក្នុងស្ថានភាពល្អប្រសើរ។ |  |

| | | | | | |
|---|---|---|---|---|---|
| A03 | X=0343570<br>Y=1161493 | 3,3 | 2,5 | មានផ្កាថ្មគ្របដណ្តប់ប្រមាណ៨០% ក្នុងនោះងាប់ប្រមាណ ២០%។ មានប្រភេទ Sea Fan, Sponge និងមានហ្វូងកូនត្រីក្នុងតំបន់ថ្មនិងត្រីសេកជាច្រើនរស់នៅក្នុងចំណុចនោះ។ ជាចំណុចមានធនធាន ជលផលសម្បូរបែបដែលត្រូវការពារ។ |  |
| A04 | X=0343555<br>Y=1161416 | 6,3 | 1,5 | បាតសមុទ្រក្នុងទីតាំងនេះសម្បូតទៅដោយកំទេចកំទីសំបកខ្យងខ្ចៅ និងមានប្រភេទSea Fan ដុះមួយៗ។ មានប្រភេទគ្រំចបតិចតួច តែគ្មានហ្វូងត្រីទេ។ |  |
| A05 | X=0343684<br>Y=1161479 | 6,1 | 1 | បាតសមុទ្រក្នុងទីតាំងទី៥នេះសម្បូរទៅដោយកំទេចកំទីសំបកខ្យងខ្ចៅ។ មានគ្រំចបតិចតួនិងពុំមាន ប្រទះឃើញហ្វូងត្រីទេ។ |  |

| | | | | | |
|---|---|---|---|---|---|
| A06 | X=0343691<br>Y=1161586 | 6,5 | 1 | បាតក្នុងទីតាំងនេះជាប្រភេទខ្សាច់ភក់ មានរន្ធតូចៗជាមធ្យម២/១ម² និងពុំមានហ្វូងត្រីទេ។ |  |
| A07 | X=0343444<br>Y=1161470 | 5,5 | 1,5 | នៅក្នុងតំបន់នេះមានផ្កាថ្មគ្របដណ្តប់ប្រមាណ៥០% ដែលជាពពួកផ្កាថ្មទន់១០% និងរឹង៩០% ហើយប្រហែល៥០% ងាប់។ ក្នុងការមុជនៅទីតាំងនេះមានប្រទះឃើញហ្វូងកូនត្រីសេកជាច្រើន និងប្រភេទកាំប្រម៉ាសមុទ្រ។ មានប្រភេទSea Fan និង Sponge ដុះមួយៗ។ ជារួមទីតាំងនេះមានសក្តានុពល នៃធនធានជលផល។ |  |
| A08 | X=0343325<br>Y=1161492 | 5,8 | 1,5 | នៅទីតាំងនេះមានផ្កាថ្មគ្របដណ្តប់៥០% ក្នុងនោះងាប់ ៥០%។ ក្នុងការមុជក្នុងទីតាំងនេះ មានជួបប្រភេទត្រីអាំងកើយ២ក្បាល (លើស២០សម)ធំៗ , ត្រីតុកែធំៗ២ក្បាលផងដែរ។ |  |

| | | | | | |
|---|---|---|---|---|---|
| A09 | X=0343242<br>Y=1161547 | 5,77 | 2 | ទីតាំងនេះមានខ្សាច់៦០% ផ្កាថ្ម៤០%ក្នុងនោះងាប់៤០% ហើយភាគច្រើនផ្កាថ្មជាប្រភេទCF, ផ្កាថ្មទាំងនេះដុះពីលើផ្ទាំងថ្មធំៗ។ ជាទីតាំងសម្បូរផ្ទាំងថ្ម និងមានផ្កាថ្មដុះពីលើ។ |  |
| A10 | X=0343228<br>Y=1161625 | 5,2 | 2 | ទីតាំងនេះមានផ្កាថ្មគ្របដណ្តប់៧០% ក្នុងនោះមានផ្កាថ្មទន់២០%និងងាប់៣០%។ មានកូនត្រីសេកតិចតួចនិងហ្វូងត្រី Red-striped Cardinalfish ។ មានត្រីមេអំបៅ២ក្បាល និងត្រីត្រចៀកដំរី១ក្បាល។ ទីតាំងគួរត្រូវបានការពារសម្រាប់បម្រើអេកូទេសចរណ៍ដ៏ប្រសើរបំផុត។ |  ត្រីមេអំបៅ |
| A11 | X=0343176<br>Y=1161633 | 5,4 | 2 | នៅលើទីតាំងនេះមានផ្ទាំងថ្មគ្របដណ្តប់ប្រមាណ៦០% ក្នុងនោះមានផ្កាថ្មទន់១០% និងងាប់២០%។ ផ្កាថ្ម ភាគច្រើនជាប្រភេទDisc Cora, Delicate Whip Coral , Barrel Sponge និងមានហ្វូងកូន ត្រីសេកតិចតួចនិងត្រីតុកែក្រោមទំហំ២០សម។ ជារួមជាទីតាំងល្អដែលត្រូវការពារសម្រាប់ជាកន្លែង ពងកូននិង |  |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| | | | | | |
|---|---|---|---|---|---|
| | | | | បម្រើឲ្យទេសចរណ៍ធម្មជាតិ។ |  |
| A 12 | X=0343152<br>Y=1161778 | 6,2 | 2 | ទីតាំងនេះ មានផ្កាថ្មគ្របដណ្ដប់តិចតួច គឺប្រមាណ ១០% និងមានកំទេចកំទីសំបកខ្យងខ្ចៅនិងខ្សាច់ ៩០%។ ផ្កាថ្មភាគច្រើនជាពពួកថាស (Disc Coral) ទើបនឹងដុះឡើង និងពពួក Delicate Whip Coral ដុះមួយៗ។ តាមការអង្កេតលើធនធានជលផលមាន ពពួកកាំប្រម៉ាសមុទ្រនិងកូនត្រីផ្កាថ្មតិចតួច។ | <br> |
| A 13 | X=0343174<br>Y=1161897 | 4,5 | 2 | ផ្កាថ្មគ្របដណ្ដប់ប្រមាណ៥០%, មានសម្បូរផ្ទាំងថ្មធំៗចាក់ចុះទៅក្នុងទឹកជ្រៅ។ ផ្កាថ្មភាគច្រើនជាប្រភេទ Disc Coral មាន Sea Urchin , Delicate Whip Coral , និងមានហ្វូងកូនត្រីសេក ត្រីកន្ទាំង ភ្លើង ត្រីចាប ព្រុយលឿង និងត្រីគុកែ ទំហំក្រោម ២០សម ។ ជាទីតាំងមានធនធានជលផលយ៉ាង សម្បូរបែបដែលរក្សាជាកន្លែងអភិរក្ស។ | <br> |

| | | | | | |
|---|---|---|---|---|---|
| A 14 | X=0343190<br>Y=1161929 | 5,6 | 1,5 | ទីតាំងនេះមានផ្កាថ្មគ្របដណ្តប់៣០% មាន Sea Urchin , សម្បូរប្រភេទ Delicate Whip Coral , Barrel Sponge , មានកូនត្រីតុកែតិចតួចរស់នៅ។ |  |
| A 15 | X=0343211<br>Y=1162055 | 8,1 | 1,2 | បាតសម្បូរទៅដោយកំទេចកំទីសំបកខ្យងខ្ចៅនិងមានគ្រុំចបតិចតួច និងគ្មានហ្វូងត្រីក្នុងទីតាំងនេះទេ។ |  |
| A 16 | X=0343322<br>Y=1162048 | 6,4 | 1.5 | ទីតាំងនេះមានផ្កាថ្មគ្របដណ្តប់ប្រមាណ១០% រីឯ៩០%ទៀតជាដុំថ្មតូចៗ រួមជាមួយកំទេចកំទីសំបកខ្យងខ្ចៅនិងខ្យាច់។ ផ្កាថ្មភាគច្រើនជាប្រភេទDisc Coral ទើបនឹងដុះឡើង។ មាន Sea Urchin, Delicate Whip Coral ដុះមួយៗ។ មានហ្វូងត្រីជាច្រើនប្រភេទនិងផ្កាយសមុទ្រ។ |  |

| | | | | | |
|---|---|---|---|---|---|
| A 17 | | | | ទីតាំងនេះមានផ្កាថ្មគ្របដណ្តប់ប្រមាណ៨០% ក្នុងនោះ Sponge ២០%។ ផ្កាថ្មភាគច្រើនជាប្រភេទ Blue Coral ។ មាន Sea Urchin មួយៗ និងមានហ្វូងកូនត្រីសេក កូនត្រី Red-striped Cardinalfish និងត្រីកន្តាំង។ ជាទីតាំងមានធនធានជលផលយ៉ាងសម្បូរបែបដែលគួរក្សាជាកន្លែងការពារនិងអភិរក្សជលផលសមុទ្រ។ |  |
| A 18 | X=0343538<br>Y=1161936 | 7,00 | 2 | ទីតាំងនេះ បាតមានលក្ខណៈជាខ្សាច់-ភក់លាយឡើងទៅដោយកំទេចកំទីសំបកខ្យងខ្ចៅ។ គ្មានហ្វូងត្រីមានរន្ធក្តាម- ត្រីជាមធ្យម២រន្ធក្នុង១ម²។ |  |
| A 19 | X=0343593<br>Y=1161816 | 3,5 | 1,5 | បាតក្នុងទីតាំងនេះមានលក្ខណៈខ្សាច់-ភក់សម្បូរទៅដោយកំទេចកំទីសំបកខ្យងខ្ចៅ និងមានគ្រុំចបតិចតួច និងគ្មានហ្វូងត្រីទេ។ |  |
| A20 | X=0343594<br>Y=1161757 | 2,3 | 2 | ជាចំណុចនៅក្បែរច្រាំង ។ ផ្កាថ្មគ្របដណ្តប់ប្រមាណ៨០% ភាគច្រើនជាប្រភេទ Hump coral ។ មាន Sea Urchin មួយៗនិងមានហ្វូងកូនត្រីសេក និងត្រី កន្តាំង និងមានកូនត្រីគុកែថ្មមួយៗ (២០សម)។ ជាកន្លែងប្រសើរដែលត្រូវការពារ។ |  |

ខ.២ ទីតាំងឆ្នេរសមុទ្ររាម (សាងសង់ផែដីគោក)

តាមការស្រាវជ្រាវវាយតម្លៃធនធានជលផលនៅបាតសមុទ្រ ក្នុងតំបន់សាងសង់ផែនេះ បានបង្ហាញថា ទីតាំងសាសង់ផែនេះពុំមានវត្តមានធនធានផ្កាថ្ម និងស្មៅសមុទ្រ ប្រភេទធនធានជលផលដែលមានតម្លៃសេដ្ឋកិច្ច និងប្រភេទដែលកំពុងរងគ្រោះឡើយ។ ទោះជាយ៉ាងនេះក្តី ដោយសារប្រភេទស្រទាប់បាតមានលក្ខណៈជាខ្សាច់លាយភក់ ដែលអាចបង្កឲ្យមានកម្រិតកករខ្ពស់ នឹងបង្កផលប៉ះពាល់លើធនធានជលផល ជាពិសេសផ្កាថ្ម នៅក្បែរតំបន់នេះ ជាពិសេសតំបន់ជុំវិញកោះ។ លទ្ធផលនៃការសិក្សានៅចំណុចទីតាំងនីមួយ២មានរៀបរាប់ដូចខាងក្រោមៈ

**ទីតាំងទី១ៈ** នៅទីតាំងនេះមានជម្រៅទឹក១,៨ម៉ែត្រ និងមានកម្រិតថ្លា ទាប ត្រឹម០,៨ម៉ែត្រ។ បាតសមុទ្រនៅទីតាំងនេះ មានផ្ទាំង ថ្ម ជាដុំៗ មានទំហំតូចៗល្មម នៅលើថ្មនេះមានរុក្ខជាតិសមុទ្រនិងប្រភេទសារាយ (*Sargassum oligocystum*)។ ទីតាំងនេះពុំមានវត្តមានផ្កាថ្មនិង ស្មៅសមុទ្រឡើយ គឺបាតសមុទ្រជាប្រភេទថ្មនិងខ្សាច់ម៉ត់ពណ៌ក្រហមក្រមៅ។ ពុំឃើញមានប្រភេទត្រីណាឬប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ក្នុងទីតាំងនេះឡើយ។

**ទីតាំងទី២ៈ** បាតសមុទ្រនៅចំណុចនេះមានមានផ្ទាំងថ្មជាដុំៗ តែមានទំហំតូចៗល្មម និងមានកំរិតកករដីខ្ពស់។ នៅលើថ្មទាំងនេះ មានផ្កាថ្មតិចតួច ជាប្រភេទ *Favites flexuosa* , *Turbinaria spp* , *Porites lobata* Hump coral ប៉ុន្តែពុំឃើញមានប្រភេទត្រីណាមួយឡើយ ហើយមានកាំប្រម៉ាសមុទ្រ (*Sea urchin*) នៅពាសពេញទីតាំងនេះ។ សត្វកាំប្រម៉ាជាសូចនាករមួយបង្ហាញពីសុខភាពនៃផ្កាថ្ម ដែលសំបូរកាំប្រម៉ាច្រើន សុខភាពភាពផ្កាថ្មថយចុះ ពីព្រោះកាំ ប្រម៉ាជាប្រភេទស៊ីបំផ្លាញផ្កាថ្ម។ ពុំមានវត្តមានស្មៅសមុទ្រ។

**ទីតាំងទី៣ៈ** ទីតាំងនេះមានជម្រៅ៣ម៉ែត្រនិងកម្រិតថ្លាត្រឹម១ម៉ែត្រ។ នៅចំណុចនេះពុំមានវត្តមានផ្កាថ្ម ស្មៅសមុទ្រ ឬសារាយដុះឡើយ រីឯប្រភេទត្រីនិងធនធានជលផលដទៃទៀតក៏ពុំឃើញមានវត្តមានដែរ។ បាតសមុទ្រមានខ្សាច់ពណ៌ក្រមៅនិងសំបូររន្ធជាច្រើន ដែលនេះបញ្ជាក់ពីវត្តមានរបស់ពពួកខ្យងខ្ចៅ និងក្តាមក្នុងទីតាំងនេះ។

**ទីតាំងទី៤ៈ** ទីតាំងនេះមានជម្រៅ២,៣ម៉ែត្រ កម្រិតថ្លាត្រឹម១ម៉ែត្រ បាតសមុទ្រជាលក្ខណៈខ្សាច់ក្រហមក្រមៅលាយនឹងកម្ទេចកំទីសំបកសិប្បីសត្វ។ ពុំឃើញមានវត្តមានផ្កាថ្ម ស្មៅសមុទ្រ ឬសារាយឡើយ ប៉ុន្តែមានហ្វូងកូនខ្យងផ្ញើប្រាណទំហំប៉ុនចង្កឹសនិងហ្វូងកូនត្រីតូចៗរិចតួច។

**ទីតាំងទី៥ៈ** ទីតាំងនេះមានជម្រៅ២,៣ម៉ែត្រ កម្រិតថ្លាត្រឹម១ម៉ែត្រ។ នៅចំណុចនេះពុំមានវត្តមានផ្កាថ្ម ស្មៅសមុទ្រ ឬសារាយដុះឡើយ រីឯប្រភេទត្រីនិងធនធានជលផលដទៃទៀតក៏គ្មាន

ដែរ។ បាតសមុទ្រមានលក្ខណៈខ្សាច់ក្រម៉ៅ និងមានរន្ធច្រើន ដែលបញ្ជាក់វត្តមានពពួកខ្យងខ្ចៅ និងក្តាមមួយចំនួន។

**ទីតាំងទី៦៖** ទីតាំងនេះមានជម្រៅ២ម៉ែត្រនិងកម្រិតថ្លាត្រឹម១ម៉ែត្រ។ បាតសមុទ្រនៅចំណុចនេះមានផ្ទាំងថ្មជាដុំៗ មានទំហំតូចៗល្មមនៅរាយប៉ាយដាច់ពីគ្នា ហើយនៅចន្លោះនៃដុំថ្មទាំងនេះមានខ្សាច់ក្រហមក្រម៉ៅនៅផ្នែកបាត។ នៅលើថ្មទាំងនេះមានដុះកូនផ្កាថ្មតូចៗតិចតួច ប៉ុន្តែពុំឃើញមានប្រភេទត្រីណាមួយឡើយ។ ចំណុចនេះមានកម្រិតកករដីខ្ពស់ ដែលស្ថានភាពនេះពុំល្អសម្រាប់ការរស់នៅរបស់វារីសត្វទេ។ ចំពោះផ្កាថ្មតូចៗ ដែលដុះនៅលើដុំថ្មទាំងនេះអាចនឹងងាប់ទៅវិញដោយសារកម្រិតកករខ្ពស់ ដូច្នេះគួរមានវិធានការកាត់បន្ថយការបង្ករឲ្យមានភាពកករនេះឲ្យបានជាអតិបរិមា។ ពុំមានវត្តមានស្មៅសមុទ្រឡើយ។

**ទីតាំងទី៧៖** តាំងនេះមានជម្រៅ២,២ម៉ែត្រនិងកម្រិតថ្លាត្រឹម១ម៉ែត្រ។ បាតសមុទ្រនៅទីតាំងនេះមានលក្ខណៈដូចគ្នានឹងទៅតាំងទី០៦ដែរ។

**ទីតាំងទី៨៖** នៅទីតាំងស្រាវជ្រាវនេះមានជម្រៅ៣,១ម៉ែត្រនិងកម្រិតថ្លាត្រឹម១ម៉ែត្រ។ បាតសមុទ្រនៅទីតាំងនេះជាលក្ខណៈភក់លាយខ្សាច់ម៉ត់ពណ៌ក្រហមក្រម៉ៅ មានរន្ធតូចធំចំនួនប្រមាណពី៥-១០រន្ធក្នុង១ម២ ដែលរន្ធទាំងនេះជាជម្រកយ៉ាងសំខាន់នៃពពួកបង្គា បង្កងកណ្តូប អន្ទង់សមុទ្រ និងកូនត្រីតូចៗមួយចំនួន ប៉ុន្តែរន្ធទាំងនេះអាចពុំមានធនធានជលផលកំពុងរស់នៅឡើយ ដោយសារតែមានការរំខានច្រើន។

**ទីតាំងទី៩៖** ទីតាំងនេះមានជម្រៅជ្រៅរហូតដល់៣,៨ម៉ែត្រ ប៉ុន្តែមានកម្រិតថ្លាត្រឹម១ម៉ែត្រប៉ុណ្ណោះ។ បាតសមុទ្រនៅចំណុចនេះយើងពិនិត្យឃើញមានលក្ខណៈភក់-ខ្សាច់ម៉ត់ពណ៌ក្រហមក្រម៉ៅ មានរន្ធតូចធំចំនួនប្រមាណពី១០-២០រន្ធក្នុង១ម២ ដែលរន្ធទាំងនេះជាជំរកបង្គា បង្កងកណ្តូប អន្ទង់សមុទ្រនិងកូនត្រីតូច ៗមួយចំនួន។ ពុំមានវត្តមានផ្កាថ្មនិងស្មៅសមុទ្រឡើយ ហើយប្រភេទត្រីធំៗដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ក៏ពុំមានវត្តមានដែរ។

**ទីតាំងទី១០៖** នៅទីតាំងស្រាវជ្រាវនេះមានជម្រៅទឹក៣ម៉ែត្រ និងកម្រិតថ្លា១ម៉ែត្រ។ ទីតាំងនេះស្ថិតនៅចំពីមុខនិងពាក់កណ្តាលតួផែ ដែលនៅស្រទាប់បាតសមុទ្រមានលក្ខណៈជាខ្សាច់ម៉ត់ពណ៌ក្រហមក្រម៉ៅលាយភក់ និងកម្ទេចកំទីសំបកសិប្បីសត្វ។ ពុំមានវត្តមានផ្កាថ្ម ស្មៅសមុទ្រ សារាយ និងប្រភេទធនធានជលផលដែលមានតម្លៃសេដ្ឋកិច្ចឡើយ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាង៥.២២៖ លទ្ធផលនៃការសិក្សាធនធានស្រទាប់បាតនៅឆ្នេររាម (តំបន់សាងសង់ផែដីគោក)

| ទីតាំង | ចំណុចនិយាមការ | ជម្រៅទឹក (m) | កម្រិតថ្លា (m) | លក្ខណៈស្រទាប់បាត | រូបថត |
|---|---|---|---|---|---|
| A01 | X=0347954<br>Y=1163562 | 1.8 | 0.8 | នៅទីតាំងនេះមានជម្រៅទឹក១,៨ម៉ែត្រ និងមានកម្រិតថ្លា ទាបត្រឹម០,៨ម៉ែត្រ។ បាតសមុទ្រនៅទីតាំងនេះ មានផ្ទាំង ថ្ម ជាដុំៗមានទំហំតូចៗល្មម នៅលើថ្មនេះមានរុក្ខជាតិសមុទ្រនិងប្រភេទសារាយ (*Sargassum oligocystum*) ។ ទីតាំងនេះពុំមានវត្តមានផ្កាថ្មនិង ស្មៅសមុទ្រឡើយ គឺបាតសមុទ្រជាប្រភេទថ្មនិងខ្សាច់ម៉ត់ពណ៌ក្រហមក្រម៉ៅ។ ពុំឃើញមានប្រភេទត្រីណាឬប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ក្នុងទីតាំងនេះឡើយ។ |  |
| A02 | X=0347943<br>Y=1163610 | 2 | 1 | បាតសមុទ្រនៅចំណុចនេះមានមានផ្ទាំងថ្មជាដុំៗ តែមានទំហំតូចៗល្មម និងមានកំរិតកករដីខ្ពស់។ នៅលើថ្មទាំងនេះ មានផ្កាថ្មតិចតួច ជាប្រភេទ *Favites flexuosa* , *Turbinaria spp* , *Porites lobata* Hump coral ប៉ុន្តែពុំឃើញមានប្រភេទត្រីណាមួយឡើយ ហើយមានកាំប្រម៉ាសមុទ្រ (*Sea urchin*) នៅពាសពេញទីតាំងនេះ។ សត្វកាំប្រម៉ាជាសូចនាករមួយបង្ហាញពីសុខភាពនៃផ្កាថ្មដែលសំបូរកាំប្រម៉ាច្រើន សុខភាពភាពផ្កាថ្មថយចុះ ពីព្រោះកាំប្រម៉ាជាប្រភេទស៊ីបំផ្លាញផ្កាថ្ម។ ពុំមានវត្តមានស្មៅសមុទ្រ។ | <br> |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| | | | | | |
|---|---|---|---|---|---|
| A03 | X=0347897<br>Y=1163612 | 3 | 1 | ទីតាំងនេះមានជម្រៅ៣ម៉ែត្រនិងកម្រិតថ្លាត្រឹម១ម៉ែត្រ។ នៅចំណុចនេះពុំមានវត្តមានផ្កាថ្ម ស្មៅសមុទ្រ ឬសារាយដុះឡើយ រីឯប្រភេទត្រីនិងធនធានជលផលដទៃទៀតក៏ពុំឃើញមានវត្តមានដែរ ។ បាតសមុទ្រមានខ្សាច់ពណ៌ក្រមៅនិងសំបូររន្ធជាច្រើន ដែលនេះបញ្ជាក់ពីវត្តមានរបស់ពពួកខ្យងខ្ចៅ និងក្តាមក្នុងទីតាំងនេះ។ |  |
| A04 | X=0347916<br>Y=1163584 | 2.8 | 1 | ទីតាំងនេះមានជម្រៅ២,៣ម៉ែត្រ កម្រិតថ្លាត្រឹម១ម៉ែត្រ បាតសមុទ្រជាលក្ខណៈខ្សាច់ក្រហមក្រមៅលាយនឹងកម្ទេចកំទីសំបកសិប្បីសត្វ ។ ពុំឃើញមានវត្តមានផ្កាថ្ម ស្មៅសមុទ្រ ឬសារាយឡើយ ប៉ុន្តែមានហ្វូងកូនខ្យងផ្ញើប្រាណទំហំប៉ុនចង្កឹសនិងហ្វូងកូនត្រីតូចៗវិចតូច។ | <br> |
| A05 | X=0347924<br>Y=1163706 | 2.8 | 1 | ទីតាំងនេះមានជម្រៅ២,៣ម៉ែត្រ កម្រិតថ្លាត្រឹម១ម៉ែត្រ។ នៅចំណុចនេះពុំមានវត្តមានផ្កាថ្ម ស្មៅសមុទ្រ ឬសារាយដុះឡើយ រីឯប្រភេទត្រីនិងធនធានជលផលដទៃទៀតក៏គ្មានដែរ។ បាតសមុទ្រមានលក្ខណៈខ្សាច់ក្រមៅ និងមានរន្ធច្រើន ដែលបញ្ជាក់វត្តមានពពួកខ្យងខ្ចៅ និងក្តាមមួយចំនួន។ |  |

| | | | | | |
|---|---|---|---|---|---|
| A06 | X=0347962<br>Y=1163696 | 2 | 1 | ទីតាំងនេះមានជម្រៅ២ម៉ែត្រនិងកម្រិតថ្លាត្រឹម១ម៉ែត្រ។ បាតសមុទ្រនៅចំណុចនេះមានផ្ទាំងថ្មជាដុំៗ មានទំហំតូចៗល្មមនៅរាយប៉ាយដាច់ពីគ្នា ហើយនៅចន្លោះនៃដុំថ្មទាំងនេះមានខ្សាច់ក្រហមក្រមៅនៅផ្នែកបាត។ នៅលើថ្មទាំងនេះមានដុះកូនផ្កាថ្មតូចៗតិចតួច ប៉ុន្តែពុំឃើញមានប្រភេទត្រីណាមួយឡើយ។ ចំណុចនេះមានកម្រិតកករជីខ្ពស់ ដែលស្ថានភាពនេះពុំល្អសម្រាប់ការរស់នៅរបស់វារីសត្វទេ។ ចំពោះផ្កាថ្មតូចៗ ដែលដុះនៅលើដុំថ្មទាំងនេះអាចនឹងងាប់ទៅវិញដោយសារកម្រិតកករខ្ពស់ ដូច្នេះគួរមានវិធានការកាត់បន្ថយការបង្ករឲ្យមានភាពកករនេះឲ្យបានជាអតិបរិមា។ ពុំមានវត្តមានស្មៅសមុទ្រឡើយ។ | <br> |
| A07 | X=0347953<br>Y=1163658 | 2.2 | 1 | តាំងនេះមានជម្រៅ២,២ម៉ែត្រនិងកម្រិតថ្លាត្រឹម១ម៉ែត្រ។ បាតសមុទ្រនៅទៅតាំងនេះមានលក្ខណៈដូចគ្នានឹងទៅតាំងទី០៦ដែរ។ |  |
| A08 | X=0347914<br>Y=1163651 | 3.1 | 1 | នៅទីតាំងស្រាវជ្រាវនេះមានជម្រៅ៣,១ម៉ែត្រនិងកម្រិតថ្លាត្រឹម១ម៉ែត្រ។ បាតសមុទ្រនៅទីតាំងនេះជាលក្ខណៈភក់លាយខ្សាច់ម៉ត់ពណ៌ក្រហមក្រមៅ មានរន្ធតូចធំចំនួនប្រមាណពី៥-១០រន្ធក្នុង ១ម$^{២}$ ដែលរន្ធទាំងនេះជាជម្រកយ៉ាងសំខាន់នៃពពួកបង្គា បង្កងកណ្តូប អន្ទង់សមុទ្រ និងកូនត្រីតូចៗមួយចំនួន ប៉ុន្តែរន្ធទាំងនេះ |  |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| | | | | | |
|---|---|---|---|---|---|
| | | | | អាចពុំមានធនធានជលផលកំពុងរស់នៅឡើយ ដោយសារតែមានការរំខានច្រើន។ | |
| A09 | X=0347861<br>Y=1163631 | 3.4 | 1 | ទីតាំងនេះមានជម្រៅជ្រៅរហូតដល់៣,៨ម៉ែត្រ ប៉ុន្តែមានកម្រិតថ្លាត្រឹម១ម៉ែត្រប៉ុណ្ណោះ។ បាតសមុទ្រនៅចំណុចនេះយើងពិនិត្យឃើញមានលក្ខណៈភក់-ខ្សាច់ម៉ត់ពណ៌ក្រហមក្រមៅ មានរន្ធតូចធំចំនួនប្រមាណពី១០-២០រន្ធក្នុង១ម² ដែលរន្ធទាំងនេះជាជំរកបង្គា បង្កងកណ្តូប អន្ទង់សមុទ្រនិងកូនត្រីតូច ៗមួយចំនួន។ ពុំមានវត្តមានផ្កាថ្មនិងស្មៅសមុទ្រឡើយ ហើយប្រភេទត្រីធំៗដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ក៏ពុំមានវត្តមានដែរ។ | <br> |
| A10 | X=0347911<br>Y=1163633 | 3 | 1 | នៅទីតាំងស្រាវជ្រាវនេះមានជម្រៅទឹក៣ម៉ែត្រ និងកម្រិតថ្លា១ម៉ែត្រ ។ ទីតាំងនេះស្ថិតនៅចំពីមុខនិងពាក់លណ្តាលតួផៃ ដែលនៅស្រទាប់បាតសមុទ្រមានលក្ខណៈជាខ្សាច់ម៉ត់ពណ៌ក្រហមក្រមៅលាយភក់ និងកម្ទេចកំទីសំបកសិប្បីសត្វ ។ ពុំមានវត្តមានផ្កាថ្មស្មៅសមុទ្រ សារាយ និងប្រភេទធនធានជលផលដែលមានតម្លៃសេដ្ឋកិច្ចឡើយ។ |  |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ធនធានសង្គម និងសេដ្ឋកិច្ច

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

## ៥.៥ ធនធានសង្គម-សេដ្ឋកិច្ច

គោលបំណងនៃការសិក្សានូវធនធានសង្គម-សេដ្ឋកិច្ច មុនពេលមានវត្តមានគម្រោងគឺដើម្បីយល់ដឹងពីស្ថានភាព និងសក្តានុពលនៃសេដ្ឋកិច្ច-សង្គមរបស់ប្រជាពលរដ្ឋក្បែរតំបន់គម្រោងអភិវឌ្ឍន៍ ដែលក្នុងនោះ ក្រុមការងាររបស់ក្រុមហ៊ុនទីប្រឹក្សា Creative Green Design Co., Ltd បានជ្រើសរើសប្រជាជនដែលរស់នៅឃុំរាមដើម្បីធ្វើការសម្ភាសន៍។

គោលបំណងនៃការសិក្សាទៅលើបរិស្ថាន សង្គម សេដ្ឋកិច្ចក្នុងតំបន់គម្រោងអភិវឌ្ឍន៍ គឺត្រូវបានផ្តោតទៅលើះ

- ប្រជាសាស្ត្រ និងការតាំងទីលំនៅ
- ស្ថានភាពសេដ្ឋកិច្ចៈ មុខរបរ ប្រាក់ចំណូល (ប្រភពចំណូលសំខាន់ និងបន្ទាប់បន្សំ)
- ការប្រើប្រាស់ដី
- ការប្រើប្រាស់ទឹក
- ការប្រើប្រាស់ថាមពល
- ការអប់រំ
- សុខភាព និងអនាម័យ
- ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ
- សម្បត្តិវប្បធម៌ និងទំនៀមទំលាប់ និងសាសនា

### ៥.៥.១ លទ្ធផលនៃការសិក្សា

តាមការសិក្សានៅលើកោះក្របីបានបង្ហាញឱ្យដឹងថា តំបន់កោះនេះពុំមានប្រជាជនរស់នៅទីនោះ ហើយក៏ពុំមានភូមិ-ឃុំដែរ។ ទោះបីជាយ៉ាងណា ក្រុមហ៊ុននឹងយកទិន្នន័យធនធានសង្គម-សេដ្ឋកិច្ច-បរិស្ថាននៃភូមិ/ឃុំ ដែលស្ថិតនៅក្បែរកោះនេះ ដើម្បីយកសិក្សាគឺ **ឃុំរាម**។

### ៥.៥.២ ប្រជាសាស្ត្រ

លំហូរចូលនៃប្រជាជនទៅរស់នៅក្នុងខេត្តព្រះសីហនុមានការកើនឡើង ដោយសារតែវិស័យសេដ្ឋកិច្ចមានការរីកចំរើនដូចជាការអភិវឌ្ឍន៍កំពង់ផែ ទេសចរណ៍ រោងចក្រឧស្សាហកម្ម ជាដើម។ ក្នុងតារាងខាងក្រោម គឺជាទិន្នន័យនៃការធ្វើជំរឿនស្ថិតិប្រជាជន ក្នុងខេត្តព្រះសីហនុ។ ចំណែកតារាង ៥.១៩ គឺជាទិន្នន័យស្ថិតិប្រជាជននៅឆ្នាំ២០១១ នៅក្នុងឃុំរាមដែលជាទីតាំងសិក្សារបស់គម្រោង។

### តារាង៥.២៣៖ ស្ថិតិប្រជាជនក្នុងខេត្តព្រះសីហនុ

| ក្រុង/ស្រុក | ឃុំ/សង្កាត់ | ភូមិ | ចំនួនគ្រួសារសរុប | ចំនួនប្រ/ជ | | | ទំហំគ្រួសារជាមធ្យម |
|---|---|---|---|---|---|---|---|
| | | | | សរុប | ប្រុស | ស្រី | |
| ក្រុងព្រះសីហនុ | ៥ | ១៩ | ១៩.១៥៧ | ៩១.២៨៤ | ៤៥.២៨១ | ៤៦.០០៣ | ៤,៧ |
| ព្រៃនប់ | ១៤ | ៦៥ | ១៨.៤៤៤ | ៩៣.១៤១ | ៤៦.៤៥៨ | ៤៦.៦៨២ | ៥ |
| ស្ទឹងហាវ | ៣ | ១១ | ៤.១៧៩ | ២០.២៧៧ | ១០.៤៨០ | ៩.៧៩៧ | ៤,៨ |
| កំពង់សីលា | ៤ | ១៤ | ៣.៤៥៧ | ១៦.៦៩៤ | ៨.៥៥៨ | ៨.១៣៦ | ៤,៨ |
| សរុប | ២៦ | ១០៩ | ៤៥.២៣៧ | ២២១.៣៩៦ | ១១០.៧៧៧ | ១១០.៦១៩ | ៤,៨ |

### តារាង៥.២៤៖ ស្ថិតិប្រជាជនក្នុងឃុំរាម

| ភូមិ | ចំនួនគ្រួសារ | ប្រជាជនសរុប | | | មេម៉ាយជាមេគ្រួសារ | ក្មេងកំព្រា |
|---|---|---|---|---|---|---|
| | | សរុប | ប្រុស | ស្រី | | |
| ស្មាច់ដែង | ៧០៣ | ៣.៣៦៧ | ១.៦០០ | ១.៧៦៧ | ៣៩ | ៤ |
| រាម | ៣៧៩ | ១.៨៨៧ | ៩១៨ | ៩៦៩ | ៩១ | ៥ |
| ថ្មធំ | ៣១៦ | ១.៦៩០ | ៧៩៩ | ៨៩១ | ៣១ | ៤ |
| អុង | ៦៧១ | ២.៨៦១ | ១.៤៤៤ | ១.៤១៧ | ៦២ | ២៨ |
| សរុប | ២០៦៩ | ៩.៨០៥ | ៤.៧៦៦ | ៥.០៣៩ | ២២៣ | ៤១ |

យោងតាមការសិក្សារបស់ក្រុមការងារ គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ (Creative Green Design Co., Ltd) ដែលបានធ្វើបទសម្ភាសន៍ប្រជាជនចំនួន ៩៥គ្រួសារ បានឱ្យដឹងថាអ្នកឆ្លើយតបជាភេទប្រុសមាន៣៩នាក់(៤១,០៥%) និងស្ត្រី ៥៦នាក់(៥៨,៩៥%)។ ពួកគេមានតួនាទីជាមេគ្រួសារ ៤៧,៣៧% និងជាសមាជិកគ្រួសារ៥២,៦៣% ក្នុងចំណោមពួកគាត់ដែលបានជ្រើសរើសដើម្បីសម្ភាសន៍ សុទ្ធតែមានតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចលើអ្វីមួយនៅក្នុងគ្រួសារ ហើយពួកគេភាគច្រើនមានអាយុ៖

- តិចជាង ៣៥ឆ្នាំ មានចំនួន ២៩នាក់ ស្មើនឹង ៣០,៥៣%
- ចន្លោះពី ៣៥-៤៥ឆ្នាំ មានចំនួន ១១នាក់ ស្មើនឹង ១១,៥៨%
- ចន្លោះពី ៤៥-៥៥ឆ្នាំ មានចំនួន ៣០នាក់ ស្មើនឹង ៣១,៥៨%
- ចន្លោះពី ៥៥-៦៥ឆ្នាំ មានចំនួន ១៥នាក់ ស្មើនឹង១៥,៧៩%
- ច្រើនជាង ៦៥ឆ្នាំ មានចំនួន ១០នាក់ ស្មើនឹង១០,៥២%។




ក្រាហ្វិក៥.៨៖ ភាគរយនៃតួនាទីក្នុងគ្រួសារដែលបានសម្ភាសន៍




ក្រាហ្វិក៥.៩៖ ភាគរយនៃភេទដែលបានសម្ភាសន៍




ក្រាហ្វិក៥.១០៖ ភាគរយនៃអាយុប្រជាជនដែលបានសម្ភាសន៍

### ៥.៤.២.១ ការអប់រំ

តាមទិន្នន័យនៃការសិក្សា បានឱ្យដឹងថាកម្រិតអប់រំរបស់ប្រជាជននៅក្នុងភូមិទាំង៣ ដែលស្ថិតនៅជុំវិញគម្រោងនេះនៅមានកម្រិតនៅឡើយ។ ដោយផ្អែកលើក្រាហ្វិក៥.១៣ បានបញ្ជាក់ថា មានប្រមាណជា១៦នាក់ (១៦,៨៤%) នៃប្រជាជនដែលបានធ្វើបទសម្ភាសន៍សរុបជាអនក្ខរជន និងប្រមាណ៥៨នាក់ (៦១,០៥%) មានកម្រិតអប់រំត្រឹមតែកម្រិតបឋមសិក្សាប៉ុណ្ណោះ ខណៈពេលដែលមានត្រឹមតែ១១នាក់ (១១,៥៨%) បានរៀនត្រឹមកម្រិតអនុវិទ្យាល័យ និង ១០នាក់ (១០,៥៣%) រៀនបានកម្រិតវិទ្យាល័យ។ តាមទិន្នន័យខាងក្រោមនេះ អាចសន្និដ្ឋានបានថានៅតំបន់នេះ កម្រិតអប់រំរបស់ប្រជាជននៅមានកម្រិតនៅឡើយ បើប្រៀបទៅនឹងតំបន់

ផ្សេងៗដូចជាទីរួមខេត្តព្រះសីហនុ។ កត្តាចម្បងដែលបណ្តាលឱ្យប្រជាជននៅក្នុងតំបន់នេះនៅមានកម្រិត គឺទាក់ទិនទៅនឹងកត្តាជីវភាពដូចដែលបានបង្ហាញនៅក្នុងកម្រិតនៃប្រាក់ចំណូលខាងក្រោម ហើយផ្ទួបផ្សំទៅកត្តាសង្គមមួយចំនួនដែលមានដូចជា សាលារៀននៅឆ្ងាយពីផ្ទះ ការខ្វះនូវគ្រូបង្រៀន និងអសន្តិសុខជាដើម។




ក្រាហ្វិក៥.១១៖ កម្រិតនៃការសិក្សារបស់ប្រជាជនដែលបានសម្ភាសន៍

### ៥.៥.២.២ មុខរបរ

យោងតាមទិន្នន័យ ដែលទទួលបានពីលោកមេឃុំរាម និងទិន្នន័យដែលបានសម្ភាសន៍ប្រជាជនបានបង្ហាញថា ប្រជាជនភាគច្រើនប្រកបរបរជាប្រជានេសាទ ប្រមាណជា២៩,៤៧% ហើយ១៧,៨៩% គឺជាអ្នកលក់ដូរតូចតាច ប្រមាណជា ១១,៥៨% គឺជាកសិករ និងមានមុខរបរផ្សេងៗទៀត ដូចជាប៉ូលីស មន្ត្រីរាជការ កម្មកររោងចក្រ និងអាជីវករជាដើម(ក្រាហ្វិក៥.១៥)




ក្រាហ្វិក៥.១២៖ មុខរបររបស់ប្រជាជន ក្នុងឃុំរាម



រូបភាព៥.៧៖ ការធ្វើកសិកម្មរបស់ប្រជាជនក្នុងឃុំរាម



រូបភាព៥.៨៖ ការនេសាទរបស់ប្រជាជនក្នុងឃុំរាម



រូបភាព៥.៩៖ការលក់ដូរក្នុងផ្សាររបស់ប្រជាជនក្នុងឃុំរាម



រូបភាព៥.១០៖ ការលក់ដូរតាមផ្ទះរបស់ប្រជាជនក្នុងឃុំរាម

### ៥.៥.២.៣ ប្រាក់ចំណូល

ប្រាក់ចំណូលប្រចាំខែក្នុងគ្រួសារនីមួយៗ ដែលរស់នៅក្នុងភូមិទាំងបួន (រាម ស្មាច់ដែង ថ្មធំ និងអុង) ក្បែរតំបន់គម្រោងនេះ គឺអាស្រ័យទៅលើកម្រិតអប់រំ ប្រភេទមុខរបរ និងចំនួនអ្នករកចំណូលនៅក្នុងគ្រួសារ។ តាមក្រាហ្វិក៤.១៥ បានឱ្យដឹងថាប្រជាពលរដ្ឋក្នុងមួយគ្រួសារអាចរកប្រាក់ចំណូលបានជាមធ្យមប្រចាំខែតិចជាង២៤ម៉ឺនរៀល ប្រហែល១,០៥% ចន្លោះពី២៤ម៉ឺនទៅ៤០ម៉ឺនរៀលប្រហែលជា៦,៣២% ចន្លោះពី៤០ម៉ឺនទៅ៨០ម៉ឺនប្រហែលជា២៨,៤២% ខណៈដែលមានប្រមាណ៣១,៥៨% មានលទ្ធភាពក្នុងការរកប្រាក់ចំណូលប្រចាំខែបានពី៨០ម៉ឺនទៅ២លានរៀលនិងប្រមាណជា៣២,៦៣%អាចរកចំណូលបានច្រើនជាង២លានរៀល។ យោងតាមការវិភាគលើប្រាក់ចំណូល និងមុខរបរ បានឱ្យដឹងថាមុខរបរ ដែលទទួលប្រាក់ចំណូលខ្ពស់ជាងគេ គឺបានមកពីការប្រកបនេសាទ ដែលអាចរកចំណូលបានទៅច្រើនជាង២លានរៀលក្នុង១ខែ ខណៈដែលមុខរបរផ្សេងៗ ដូចជា មន្ត្រីរាជការ កម្មករ និង កសិកម្មអាចរកប្រាក់ចំណូលបានត្រឹមតែ ពី ២៤ម៉ឺនរៀល ទៅ ៨០ម៉ឺនរៀលប៉ុណ្ណោះ។

តាមទិន្នន័យខាងលើ អាចបញ្ជាក់ថាកម្រិតជីវភាពប្រជាជន ដែលរស់នៅក្នុងតំបន់នេះមានលក្ខណៈល្អប្រសើរ គឺប្រជាជនភាគច្រើនរស់ក្នុងកម្រិតជីវភាពមធ្យម ដែលទិន្នន័យនេះស្របតាមទិន្នន័យដែលទទួលបានពីលោកមេឃុំ ដែលបានបញ្ជាក់ថានៅក្នុងឃុំរាមនេះ មានចំនួន៧០%ជាប្រជាជន ដែលមានកម្រិតជីវភាពមធ្យម៣០% ជាប្រជាជនដែលរស់នៅក្នុងកម្រិតជីវភាពក្រីក្រ។




ក្រាហ្វិក៥.១៣៖ កម្រិតប្រាក់ចំណូលរបស់ប្រជាជន

### ៥.៥.២.៤ ប្រាក់ចំណាយ

ជាទូទៅប្រាក់ចំណាយរបស់ប្រជាជនភាគច្រើននៅតាមគ្រួសារនីមួយៗ គឺអាស្រ័យទៅតម្រូវការប្រចាំថ្ងៃរបស់ពួកគេ ដែលភាគច្រើនសង្កេតឃើញពួកគាត់ចំណាយលើ កសិកម្ម ទឹកភ្លើង ម្ហូបអាហារ សំលៀកបំពាក់ ប្រេងឬសាំង ការព្យាបាលជំងឺ និងសម្ភារៈប្រើប្រាស់ផ្សេងៗ។ លើសពីនេះទៅទៀត កម្រិតនៃប្រាក់ចំណាយនេះក៏ពាក់ព័ន្ធទៅនឹងទំហំនៃសមាជិកគ្រួសារផងដែរ។ ជាក់ស្តែង គ្រួសារដែលមានសមាជិកតិច នាំឱ្យតម្រូវការនៅក្នុងការរស់នៅក៏មានកម្រិតតិច ចំពោះគ្រួសារដែលមានសមាជិកច្រើន តម្រូវការនៃការរស់ប្រចាំថ្ងៃ ក៏កាន់តែច្រើន នាំឱ្យការចំណាយរបស់ពួកគេក៏កាន់តែច្រើនផងដែរ។ យោងតាមលទ្ធផលនៃការសិក្សា ដែលបានបង្ហាញនៅក្នុងក្រាហ្វិក៤.១៦ បានឱ្យដឹងថាភាគច្រើននៅក្នុងគ្រួសារធ្វើការចំណាយជាមធ្យមប្រចាំខែ គឺនៅចន្លោះ៤០មុឺនទៅ៨០មុឺនរៀលមាន៣៦,៨៤%។ ចំនែកឯ គ្រួសារដែលធ្វើការចំណាយតិចជាង២៤មុឺនស្មើនឹង ៣,១៦% នៅក្នុងចន្លោះពី២៤ទៅ៤០មុឺនរៀល ស្មើនឹង១៥,៧៩% ហើយគ្រួសារដែលធ្វើការចំណាយច្រើនជាង២លាន មានប្រមាណជា១១,៥៨%។ យោងតាមទិន្នន័យខាងលើបានឱ្យដឹងថា គ្រួសារដែលធ្វើការចំណាយចន្លោះពី៤០មុឺនរៀលទៅ៨០មុឺនរៀល ភាគច្រើនជាប្រភេទគ្រួសារដែលរស់នៅក្នុងរង្វង់គ្រួសារដែលមានសមាជិកតិចគឺ៥នាក់ ខណៈដែលគ្រួសារដែលធ្វើការចំណាយច្រើនលើសពី៨០មុឺនរៀល ជាប្រភេទគ្រួសារដែលបានសមាជិកច្រើន(៧ទៅ៩នាក់)។




ក្រាហ្វិក៥.១៩៖ កម្រិតប្រាក់ចំណាយរបស់ប្រជាជន

តាមរយៈទិន្នន័យចំណូល និងចំណាយខាងលើ បានបញ្ជាក់ថា ប្រជាជនដែលមានប្រាក់ចំនូលតិចគឺមានការចំណាយតិច ចំណែកឯប្រជាជនដែលមានប្រាក់ចំណូលច្រើនមានការចំណាយច្រើន។ ជាទូទៅប្រជាជននៅក្នុងឃុំរាម ភាគច្រើនមានប្រាក់ចំណូល និងចំណាយស្ថិតនៅចន្លោះ ៨០ម៉ឺន-៨០ម៉ឺនរៀលក្នុងមួយខែ។ តាមរយៈទិន្នន័យនេះបញ្ជាក់ថា ប្រជាជនក្នុងឃុំរាមស្ថិតនៅលើបន្ទាត់ភាពក្រីក្រ ដែលអាចរកចំណូលបានច្រើនជាង១ដុល្លាក្នុងមួយថ្ងៃ។

៥.៥.២.៥ លក្ខណៈទូទៅនៃគ្រួសារអ្នកនេសាទ

ការស្រាវជ្រាវលើសកម្មភាពទូទៅនៃការនេសាទ ត្រូវបានធ្វើទៅលើគ្រួសារអ្នកនេសាទចំនួន៣០ គ្រួសារប៉ុន្តែលទ្ធផលដែលយកមកវិភាគត្រូវបានធ្វើតែទៅលើតែ១៧គ្រួសារប៉ុណ្ណោះ ដែលអ្នកទាំងនោះតែង តែធ្វើនេសាទនៅក្នុងតំបន់ **កោះក្របី** ហើយពួកគេទាំងអស់នេះភាគច្រើនមកពីឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

ការធ្វើនេសាទក្នុងតំបន់នេះភាគច្រើន គឺជាបុរសដែលជាមេគ្រួសារ ដែលមានវ័យប្រមាណ១៩ដល់៥៥ឆ្នាំ។ ជារួមអ្នកនេសាទទាំងនេះភាគច្រើនពុំមានដីស្រែសម្រាប់ប្រកបរបកសិកម្មទេ គឺពឹងផ្អែកទាំងស្រុង ទៅលើការនេសាទ។

តាមការវិភាគទិន្នន័យបានបង្ហាញថា ប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំនៃគ្រួសារអ្នកនេសាទគិតជា ដុល្លាគឺ១២.៥៥៦ដុល្លា ហើយមានគ្រួសារខ្លះអាចរកប្រាក់ចំណូលប្រចាំឆ្នាំរហូតដល់២៦.២០០ដុល្លា ប៉ុន្តែមានមួយចំនួនទៀតទទួលបានតិចតួចត្រឹមតែជិត ៣.០០០ដុល្លាប៉ុណ្ណោះ។ ជារួម សមាជិកអ្នកនេសាទក្នុង មួយគ្រួសារជាមធ្យមគឺ៦នាក់ ហើយប្រសិនយើងគិតប្រាក់ចំណូលត្រឹម១ដុល្លាក្នុងម្នាក់ក្នុងមួយថ្ងៃនោះ ប្រាក់ចំណូលប្រចាំឆ្នាំក្នុងមួយគ្រួសារ គឺ២.១៩០ដុល្លា ប្រសិនគិតប្រាក់ចំណូលក្នុងចន្លោះ១ទៅ២ដុល្លា នោះប្រាក់ចំណូលប្រចាំឆ្នាំគឺ២.១៩០ទៅ៤.៣៨០ ហើយប្រសិនចំណូលច្រើនជាង២ដុល្លា ប្រាក់ចំណូល ប្រចាំឆ្នាំនឹងកើនលើស៤.៣៨០ដុល្លា។ តាមរយៈការវិភាគ និងក្រាហ្វិកទី៥.៦ បានបង្ហាញថា ពុំមានគ្រួសារ ណាទទួលបានប្រាក់ចំណូលប្រចាំឆ្នាំតិចជាង២.១៩០ដុល្លាទេ ឯគ្រួសាដែលមានប្រាក់ចំណូលចន្លោះ២.១៩០ទៅ៤៣៨០ដុល្លាមាន២% ឯគ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំច្រើនជាង៤.៣៨០ដុល្លាមានរហូតដល់៨៨%ឯណោះ។

បើប្រៀបធៀបនឹងបន្ទាត់ភាពក្រីក្រ ដោយយកចំណូល១ដុល្លាក្នុងម្នាក់ក្នុង០១ថ្ងៃជាគោលនោះប្រាក់ ចំណូលប្រចាំឆ្នាំរបស់គ្រួសារអ្នកនេសាទនីមួយៗនៅក្នុងតំបន់នេះមានជីវភាពសមរម្យបំផុត។




ក្រាហ្វិក៥.១៥ ៖ គម្លាតប្រាក់ចំណូលប្រចាំឆ្នាំដែលគ្រួសារអ្នកនេសាទទទួលបាន

តាមក្រាហ្វិកទី៥.៧បង្ហាញថា ប្រភពប្រាក់ចំណូលរបស់អ្នកនេសាទជាសំខាន់ គឺបានមកពីការលក់ ផលនេសាទរបស់ខ្លួនផ្ទាល់ ដែលមានរហូតដល់៩៨% ហើយក្រៅពីនេះបានមកពីលក់ស្រូវតិចតួចត្រឹម១% និងលក់កម្លាំងពលកម្មត្រឹមតែ១%ប៉ុណ្ណោះ។ នេះសបញ្ជាក់ថា ប្រជាពលរដ្ឋដែលធ្វើនេសាទក្នុងតំបន់នេះពុំ អាចបាត់បង់មុខរបរនេសាទនេះបានឡើយ ហើយធនធានជលផលនៅក្នុងតំបន់នេះមានសារសំខាន់ណាស់ ដែលជាប្រភពចំណូលជាចម្បងបំផុត ដែលនេះចាំបាច់ត្រូវថែរក្សាការពារឲ្យបានគង់វង្សជានិរន្ត។




ក្រាហ្វិក៥.១៦៖ ប្រភពប្រាក់ចំណូលប្រចាំគ្រួសារ

ខ. សកម្មភាពនេសាទ៖

ជាទូទៅ ការនេសាទក្នុងតំបន់នោះមានសកម្មភាពខ្លាំងក្នុងរយៈពេល១៥ឆ្នាំក្រោយនេះ ប៉ុន្តែមាន អ្នកនេសាទមួយចំនួនបានធ្វើនេសាទនេះចាប់តាំងពីក្រោយរបប ប៉ុល ពត មកម្ល៉េះគឺមានរយៈពេលរហូត ដល់ជាង៣០ឆ្នាំមកហើយ។

មានប្រភេទឧបករណ៍នេសាទជាច្រើនប្រភេទត្រូវបានប្រើនៅក្នុងតំបន់គម្រោង ប៉ុន្តែប្រភេទសំខាន់ រួមមានមងក្ដាម មងត្រី មងបង្គា និងលបក្ដាមសេះ ហើយប្រភេទឧបករណ៍នេសាទទាំងអស់នេះត្រូវបាន ប្រើទៅតាមរដូវ ជាពិសេសទៅតាមប្រភេទដែលពួកគេចង់ចាប់និងសម្បូរ។ ទំហំនិងបរិមាណឧបករណ៍ នេសាទដែលប្រើនេះមានការប្រែប្រួលទៅតាមស្ថានភាពអ្នកនេសាទ ប៉ុន្តែជាទូទៅក្នុងមួយគ្រួសារៗមានប្រើ លបក្ដាមពី១០០ទៅ៥០០លប មងក្ដាមពី៥ទៅ៤០ដៃ (១៥០ដល់១.២០០ម៉ែត្រ) មងត្រី២៥ទៅ៣០ដៃ (៦២៥ដល់៧៥០ម៉ែត្រ) និង មងបង្គាពី១០ដល់១០០ដៃ (២៥០ដល់២.៥០០ម៉ែត្រ)។ ក្រៅពីការប្រើប្រាស់ ឧបករណ៍ទាំងនេះ ពួកអ្នកនេសាទបានរាវយកពពួកគ្រុំ ខ្យង និងងាវផងដែរ។

តាមការវិភាគនិងពិនិត្យជាក់ស្តែង ជារៀងរាល់ឆ្នាំ មងនិងលបក្ដាមត្រូវបានប្រើភាគច្រើនក្នុងចន្លោះ ចាប់ពីខែមីនាដល់ឧសភា មងបង្គាចាប់ពីខែមិថុនាដល់សីហា ឯមងត្រីត្រូវបានប្រើភាគច្រើនក្នុងចន្លោះចាប់ ពីខែកញ្ញាដល់កុម្ភៈ។

៤.៤.២.៤ ការប្រើប្រាស់ទឹក

ទឹកមានសារៈប្រយោជន៍ខ្លាំងណាស់សម្រាប់ការរស់នៅរបស់មនុស្ស ជាពិសេសទឹកស្អាតសម្រាប់ប្រើប្រាស់ និងតម្រូវការប្រចាំថ្ងៃផ្សេងៗ។ ឆ្លងតាមលទ្ធផលនៃការសិក្សា បានឱ្យដឹងថា នៅរដូវប្រាំងប្រជាជននិយមចូលចិត្តប្រើប្រាស់ទឹកប្រព័ន្ធឯកជនសម្រាប់បរិភោគ និងទឹកអណ្ដូងប្រើប្រាស់សម្រាប់ បោកគក់ និងលាងសម្អាតផ្សេងៗ។ តាមក្រាហ្វិក៤.១៧ បង្ហាញថា នៅរដូវប្រាំងមានប្រមាណជា ៤៧,៩២% ប្រើប្រាស់ប្រភពទឹកមកពីប្រព័ន្ធស្អាតឯកជន និងប្រមាណជា ៥២,០៨%ប្រើប្រាស់ទឹកអណ្ដូង។ ចំនែកឯនៅរដូវវស្សា ប្រជាជននិយមប្រើប្រាស់ទឹកភ្លៀងដែលប្រមាណជា ៣៥,៦២% និងអ្នកដែលនិយមប្រើប្រាស់ប្រព័ន្ធទឹកស្អាតមានប្រមាណជា៣០,១៤% ខណៈពេលដែលប្រជាជនប្រើប្រាស់ទឹកអណ្ដូងតែ១,៣៧% ប៉ុណ្ណោះ។

យោងតាមការសិក្សាស្រាវជ្រាវ អាចសន្និដ្ឋានបានថាប្រជាជននៅក្នុងឃុំរាម ប្រើប្រាស់ទឹកស្អាតមានបីប្រភពគឺ ប្រព័ន្ធទឹកឯកជន ទឹកភ្លៀង និងទឹកអណ្ដូង។




ក្រាហ្វិក៥.១៧៖ ការប្រើប្រាស់ទឹករបស់ប្រជាជន

### ៥.៥.២.៦ ការប្រើប្រាស់ថាមពល

#### ក. ការប្រើប្រាស់ថាមពលសម្រាប់បំភ្លឺ

យោងតាមលទ្ធផលនៃការសម្ភាសន៍ប្រជាជននៅក្នុងឃុំរាម បានឱ្យដឹងថាប្រជាជនភាគច្រើនប្រើប្រាស់ថាមពលផ្សេងៗសម្រាប់បំភ្លឺគេហដ្ឋានរបស់ពួកគេ។ ប្រមាណជា ៧២% ប្រើប្រាស់ថាមពលអគ្គិសនីរដ្ឋ ហើយប្រមាណជា ២៣% ប្រើប្រាស់ថាមពលអគ្គិសនីឯកជន និងប្រមាណជា២% ប្រើប្រាស់ថាមពលដែលប្រភពមកពីអាគុយ ខណៈមានត្រឹមតែ៣%ប៉ុណ្ណោះដែលប្រើប្រាស់ថាមពលចេញពីទាន និងប្រេងកាត (ក្រាហ្វិក៥.១៨)។ តាមទិន្នន័យខាងលើនេះផងដែរ ភាគច្រើនអ្នកដែលប្រើប្រាស់ថាមពលអគ្គិសនីឯកជន ត្រូវបានគេរកឃើញថាជាប្រជាជនដែលរស់នៅក្នុងភូមិរាម ស្មាច់ដែង និងថ្មធំ។ ចំនែកឯប្រជាជន ដែលប្រើប្រាស់ថាមពលប្រេងកាត់និងទានភាគច្រើនជាប្រជាជនដែលមានជីវភាពក្រីក្រមិនមានលទ្ធភាពភ្ជាប់បណ្តាញ។




ក្រាហ្វិក៥.១៨៖ ការប្រើប្រាស់ថាមពលសម្រាប់បំភ្លឺរបស់ប្រជាជន

### ខ. ការប្រើប្រាស់ថាមពលសម្រាប់ចំអិន

យោងតាមលទ្ធផលនៃការសិក្សាបានឱ្យដឹងថា ប្រភពថាមពលចំនួន៤ ដែលប្រជាជនប្រើប្រាស់សម្រាប់ដាំស្លរ និងចំអិនអាហាររបស់ពួកគាត់។ ប្រជាជន បានប្រើប្រាស់ធ្យូង ៤២,៦៨% អុស៣៧,៥៨% ហ្គាស១៤,៦៥% និងប្រើប្រាស់ថាមពលអគ្គិសនីចំនួន៥,១០% ។ តាមទិន្នន័យខាងលើនេះ អាចបញ្ជាក់បានថាប្រជាជននៅក្នុងឃុំរាម ភាគច្រើននិយមប្រើប្រាស់ធ្យូង និងអុស ជាថាមពលសម្រាប់ចំអិនអាហារ និងដាំស្លរប្រចាំថ្ងៃ។ កត្តាដែលពួកគាត់ប្រើប្រាស់ថាមពលធ្យូង និងអុសនេះ ដោយសារតែបញ្ហានៃជីវភាពដែលធ្វើឱ្យគាត់មិនមានលទ្ធភាពក្នុងការប្រើប្រាស់ថាមពលហ្គាស និងអគ្គិសនីមកប្រើប្រាស់សម្រាប់ចំអិនអាហារ។ ម្យ៉ាងវិញទៀត អុសនិងធ្យូងមានតម្លៃថោក ដែលប្រជាជនចំណាយថវិកាតែបន្តិចបន្តួចក្នុងការប្រើប្រាស់ថាមពលនេះ ឬគ្រួសារមួយចំនួនអាចទៅរកអុសនៅតំបន់ព្រៃជិតបាន ដោយមិនចាំបាច់ចំណាយថវិកាទៅលើថាមពលសម្រាប់ចំអិន។




ក្រាហ្វិក៥.១៩៖ ចំនួនភាគរយដែលប្រជាជនប្រើប្រាស់ថាមពលដើម្បីចំអិនអាហារ

### ៥.៥.២.៧ សុខភាព និងសុខុមាលភាពសាធារណ:

#### ក. អនាម័យ

#### ក.១ អនាម័យទឹក

អនាម័យទឹក គឺជាបញ្ហាមួយដែលទាក់ទងនឹងជំងឺផ្សេងៗ ដែលកើតឡើងចំពោះមនុស្ស។ យោងតាមការសិក្សា បានឱ្យដឹងថាប្រជាជននៅតំបន់នេះ និយមចូលចិត្តពិសាទឹកឆ្អិន (ទឹកដាំ) ៨៨% ទឹកសុទ្ធ៨% និងទឹកចម្រោះ៤% (ក្រាហ្វិក៥.២០)។ តាមទិន្នន័យខាងលើនេះ អាច សន្និដ្ឋានបានថា ប្រជាជននៅតំបន់នេះមិនសូវមានបញ្ហានៃការកើតជម្ងឺដែលទាក់ទងនឹងទឹក ដូចជា រាករូស គ្រុនពោះវៀន ជំងឺភ្នែក និងសើរស្បែកជាដើម។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com




ក្រាហ្វិក៥.២០៖ ចំនួនភាគរយដែលប្រជាជនប្រើប្រាស់ទឹកសម្រាប់ពិសារ

## ក.២ បង្គន់អនាម័យ

ចំនែកឯ បញ្ហាអនាម័យពាក់ព័ន្ធទៅនឹងរបន្ទោរបង់វិញ នៅក្នុងឃុំរាមត្រូវបានសង្កេតឃើញថា គ្រួសារដែលមានបង្គន់អនាម័យសម្រាប់ប្រើប្រាស់មាន៧៥,៧៩% និងគ្រួសារដែលមិនមានបង្គន់អនាម័យប្រើប្រាស់ ២៤,២១% (ក្រាហ្វិក៤.២១)។ តាមទិន្នន័យនេះ បានបង្ហាញថាប្រជាជនដែលមានបង្គន់អនាម័យប្រើប្រាស់មានចំនួនច្រើនជាង អ្នកមិនមានបង្គន់ប្រើប្រាស់ ហេតុដូច្នេះ អាចសន្និដ្ឋានបានថា ប្រជាជននៅក្នុងឃុំនេះ បានយកចិត្តទុកដាក់ទៅលើបញ្ហាអនាម័យលើបង្គន់។

ប្រជាជនដែលមានបង្គន់អនាម័យប្រើប្រាស់ ភាគច្រើនប្រើប្រាស់ប្រភេទបង្គន់ចាក់ទឹកដែលមានចំនួន៩២% ប្រើប្រាស់បង្គន់នៅលើទឹក ចំនួន៥% និងបង្គន់ចុចទឹក៣% (ក្រាហ្វិក៤.២២)។ ចំណែកឯ ប្រជាជនដែលមិនមានបង្គន់អនាម័យប្រើប្រាស់ ពួកគាត់ភាគច្រើនទៅបន្ទោរបង់នៅលើទឹក (៥៥,៨៣%) ទៅបន្ទោរបង់ក្នុងព្រៃ (៣៣,៣៣%) ទៅបន្ទោរបង់បង្គន់អ្នកជិតខាង (១២,៥%) និងជីកកប់បន្ទាប់ពីពួកគេបន្ទោរបង់រួច (ក្រាហ្វិក៤.២៣)។ បញ្ហានៃការខ្វះខាតបង្គន់អនាម័យនេះ គឺភាគច្រើនបណ្តាលមកពីកត្តាជីវភាព និងកម្រិតនៃការយល់ដឹងរបស់ប្រជាជននៅមានកម្រិត ដែលអាចធ្វើឱ្យពួកគេងាយនឹងកើតជម្ងឺផ្សេងៗ ពាក់ព័ន្ធទៅនឹងអនាម័យទៅលើខ្លួនប្រាណ ។

#322P, St.271Z, Sk.TERK Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com




ក្រាហ្វិក៥.២១៖ ចំនួនភាគរយដែលប្រជាជនមានបង្គន់អនាម័យប្រើប្រាស់




ក្រាហ្វិក៥.២២៖ ប្រភេទបង្គន់ដែលប្រជាជនប្រើប្រាស់




ក្រាហ្វិក៥.២៣៖ ការបន្ទោរបង់របស់ប្រជាជនមិ

## ខ. របៀបគ្រប់គ្រងសំណល់រឹង និងរាវរបស់ប្រជាជន

យោងតាមការសិក្សារបស់ក្រុមសិក្សាស្រាវជ្រាវរបស់ក្រុមហ៊ុន គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ បានបញ្ជាក់ឱ្យដឹងថាការគ្រប់គ្រងសំណល់រឹង និងរាវរបស់ប្រជាជនមានលក្ខណៈល្អប្រសើរ បើផ្អែកទៅលើការអង្កេតផ្ទាល់ និងទិន្នន័យដែលបានមកពីការសម្ភាសន៍ប្រជាជនដែលរស់នៅក្នុងតំបន់។

ការគ្រប់គ្រងសំណល់រឹងរបស់ប្រជាជនភាគច្រើនគឺ ប្រមូលទុកមួយកន្លែង ដើម្បីដុតចោល មានប្រមាណជា ៥៤,៧៤% ខណៈដែលមានប្រមាណជា២,១១% ធ្វើការគ្រប់គ្រងសំណល់រឹងរបស់ខ្លួនមិនបានត្រឹមត្រូវ គឺធ្វើការបោះចោលកាកសំណល់នៅក្បែរផ្ទះ (ក្រាហ្វិក៥.២៥)។

ចំនែកឯការគ្រប់គ្រងសំណល់រាវ របស់ប្រជាជន សង្កេតឃើញថាមានលក្ខណៈល្អប្រសើរ។ ប្រជាជនភាគច្រើនធ្វើការបង្ហូរសំណល់រាវរបស់ពួកគាត់ នៅលើផ្ទៃដីក្បែរផ្ទះតែម្តង ដោយគាត់ជីកប្រឡាយក្បែរផ្ទះ (៣២,៦៣%) ហើយមានប្រមាណជា១៣,៦៨% ធ្វើការបង្ហូរសំណល់រាវលើដីក្បែរផ្ទះ និងមានប្រមាណជា១៨,៩៥% ធ្វើការបង្ហូរសំណល់រាវចូលទៅក្នុងប្រឡាយ និងប្រព័ន្ធលូដែលបានរៀបចំឡើង នៅមុខផ្ទះរបស់ពួកគាត់(ក្រាហ្វិក៥.២៥)។




**ក្រាហ្វិក៥.២៥៖** ការគ្រប់គ្រងសំណល់រឹង និងរាវរបស់ប្រជាជន

គ. បញ្ហាសុខភាព

នៅក្នុងឃុំរាមនេះ មានមណ្ឌលសុខភាពចំនួន១មានទីតាំងស្ថិតនៅក្នុងភូមិរាម ដែលមានភាពងាយស្រួលដល់ប្រជាជននៅក្នុងភូមិស្មាច់ដែង ភូមិថ្មធំ និងភូមិអុងក្នុងការមកទទួលនូវការថែទាំសុខភាព។ ប៉ុន្តែទោះបីជា នៅក្នុងភូមិនេះ មានមណ្ឌលសុខភាពក៏ដោយ ក៏ប្រជាជនមួយចំនួននិយមទៅមន្ទីរពេទ្យរដ្ឋ និងឯកជននៅឯទីរួមខេត្តព្រះសីហនុដែលមានចម្ងាយ១៨គីឡូម៉ែត្រពីតំបន់នេះ។

យោងតាមបទសម្ភាសន៍ប្រជាជន បានឱ្យដឹងថាកត្តាធ្វើឱ្យប្រជាជននៅតំបន់នេះ ទៅព្យាបាលនៅមន្ទីរពេទ្យផ្សេងៗ គឺបណ្តាលមកពីមណ្ឌលសុខភាពនៅក្នុងតំបន់នេះមិនមានសម្ភារៈបរិក្ខាគ្រប់គ្រាន់សម្រាប់ព្យាបាលនូវជម្ងឺ គួបផ្សំជាមួយនឹងការខ្វះខាតនូវគ្រូពេទ្យជំនាញសម្រាប់ព្យាបាលជម្ងឺជាដើម។

ជាទូទៅប្រជាជននៅក្នុងភូមិនេះ ភាគច្រើនកើតនូវជម្ងឺគ្រុនក្តៅធម្មតា ដែលមានប្រមាណជា ៥០% ហើយមានប្រមាណជា ២៣,៧៣% កើតនូវជម្ងឺរលាកប្រព័ន្ធរំលាយអាហារ ៥,០៨% កើតជម្ងឺគ្រុនចាញ់ ចំនែកឯប្រមាណជា ១៥,២៥% កើតនៅជម្ងឺផ្សេងៗទៀត ដូចជា ជម្ងឺរាគរុសផ្តាសាយ សន្លាក់ និងទឹកនោមផ្អែមជាដើម (ក្រាហ្វិក៥.២៥)។




ក្រាហ្វិក៥.២៥៖ ជំងឺដែលប្រជាជនកើតញឹកញាប់

ជាទូទៅក្នុងការថែរទាំសុខភាព ប្រជាជននៅក្នុងឃុំរាមនេះ ភាគច្រើនទៅសេវាថែទាំសុខភាព នៅមន្ទីរពេទ្យដែលស្ថិតនៅក្នុងភូមិ ឃុំរបស់គេ ក្នុងករណីដែលពួកគេមានជម្ងឺធម្មតា និងអ្នកខ្លះទៅរកសេវាសុខភាពឯកជននៅពេលដែលពួកគេកើតនៅជម្ងឺធ្ងន់ធ្ងរ។ យោងតាមទិន្នន័យនៃការសិក្សាស្រាវជ្រាវរបស់ក្រុមសិក្សា បានបញ្ជាក់ឱ្យដឹងថាមានប្រមាណជា ៣៨,៥៣% នៃប្រជាជនដែលបានសម្ភាសន៍សរុប ទៅទទួលការព្យាបាលសុខភាពរបស់គេនៅ មណ្ឌលសុខភាព និងមាន៥៨,៧២% ទៅទទួលការព្យាបាលជម្ងឺរបស់ខ្លួននៅមន្ទីរឯកជន និងមានប្រមាណជា២,៧៥% ធ្វើការព្យាបាលជម្ងឺរបស់ខ្លួនជាមួយថ្នាំខ្មែរ និងការព្យាបាលដោយខ្លួនឯង (ក្រាហ្វិក៥.២៦)។




ក្រាហ្វិក៥.២៦៖ ជម្រើសនៃការព្យាបាលជម្ងឺរបស់ប្រជាជន

### ៥.៥.២.៨ ហេដ្ឋាចរនាសម្ព័ន្ធ

#### ក. ប្រព័ន្ធគមនាគមន៍

នៅក្នុងឃុំរាមនេះ មានប្រព័ន្ធផ្លូវ៤ប្រភេទគឺ ផ្លូវទៅទីរួមខេត្ត ផ្លូវក្រុមហ៊ុនឃិៈជា ផ្លូវកៅស៊ូក្នុងឃុំ និងផ្លូវលំក្នុងភូមិ។ ប្រព័ន្ធផ្លូវទី១ គឺជាផ្លូវទៅកាន់ទីរួមខេត្តស្ថិតនៅលើផ្លូវជាតិលេខ៤ ដែលមានចំងាយ១៨គីឡូម៉ែត្រពីក្រុងព្រះសីហនុ។ ប្រព័ន្ធផ្លូវទី២ គឺជាផ្លូវរបស់ក្រុមហ៊ុនឃិៈជា សាងសង់ឡើង ដើម្បីសម្រួលដល់ការធ្វើដំណើរចេញ-ចូលក្នុងតំបន់គម្រោងអភិវឌ្ឍន៍របស់គេ ដែលផ្លូវនេះសាងសង់ជាប្រភេទផ្លូវកៅស៊ូមានប្រវែង១៤គីឡូម៉ែត្រ និងមានទទឹង៨ម៉ែត្រ។ ប្រព័ន្ធផ្លូវទី៣ គឺជាផ្លូវកៅស៊ូរបស់ឃុំមានទទឹង១០ម៉ែត្រដែលសភាពល្អងាយស្រួលក្នុងការធ្វើដំណើរ។ ចំណែកផ្លូវមួយទៀត គឺផ្លូវលំក្នុងភូមិជាប្រភេទគ្រួសក្រហម ដែលសាងសង់ខ្វាត់ខ្វែងក្នុងភូមិ។ ផ្លូវលំក្នុងភូមិនេះ មានកន្លែងខ្លះមានសភាពល្អងាយស្រួលក្នុងការធ្វើដំណើរ និងមានកន្លែងខ្លះមានលក្ខណៈទ្រុឌទ្រោមពិបាកក្នុងការធ្វើដំណើរ។



រូបភាព៥.១១៖ ប្រភេទផ្លូវកៅស៊ូក្នុងឃុំរាម



រូបភាព៥.១២៖ ប្រភេទផ្លូវគ្រួសក្រហមក្នុងឃុំរាម

### ខ. បណ្តាញអគ្គិសនី

នៅក្នុងឃុំរាមមានបណ្តាញអគ្គិសនីខ្វែងខ្វាត់ ដែលបណ្តាញអគ្គិសនីនេះ គឺជាបណ្តាញអគ្គិសនីរបស់រដ្ឋ ប៉ុន្តែកាន់កាប់ដោយឯកជន។ បណ្តាញអគ្គិសនីនេះ ត្រូវបានរៀបចំតបណ្តាញនិងប្រើប្រាស់នៅឆ្នាំ២០១១ ដែលលក់ក្នុងតំលៃ១៨០០ក្នុងមួយគីឡូវ៉ាត់។ បណ្តាញអគ្គិសនីនេះត្រូវបានតបណ្តាញពាសពេញទាំង៥ភូមិក្នុងឃុំរាម ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយតាមការសម្ភាសន៍ប្រជាជនបានឲ្យដឹងថា គ្រួសារមួយចំនួនមិនទាន់បានប្រើប្រាស់នៅឡើយព្រោះមិនមានលទ្ធភាពភ្ជាប់បណ្តាញ។ តាមការសម្ភាសន៍លោកមេឃុំបានឲ្យដឹងថា បណ្តាញអគ្គិសនីនេះមានប្រភពមកពីក្រុងព្រះសីហនុ។ ចាប់ទាំងពីមានបណ្តាញអគ្គិសនីប្រើប្រាស់មក ប្រជាជនក្នុងឃុំអាចរស់នៅក្នុងភាពទាន់សម័យជាងមុន ព្រោះគាត់អាចប្រើប្រាស់អគ្គិសនីនេះ សម្រាប់ចំអិនអាហារ បំភ្លឺ និងប្រើប្រាស់ទៅតាមតម្រូវការផ្សេងៗ។

ចំពោះគម្រោងអភិវឌ្ឍន៍កោះក្របីវិញ ដោយសារតែកោះស្ថិតនៅចំងាយ៦គីឡូម៉ែត្រពីឆ្នេររាម ហេតុដូច្នេះហើយ គម្រោងអភិវឌ្ឍន៍មិនអាចទាញយកថាមពលអគ្គិសនីនេះ ប្រើបានទេ គឺគម្រោងនឹងរៀបចំទាញយកថាមពលអគ្គិសនីពីពន្លឺព្រះអាទិត្យដើម្បីប្រើប្រាស់តាមតម្រូវការ និងត្រៀមម៉ាស៊ីនអគ្គិសនីដោយខ្លួនឯង។




រូបភាព៥.១៣៖ បណ្តាញអគ្គិសនីក្នុងឃុំរាម

### គ. បណ្តាញទឹកស្អាត

បណ្តាញទឹកស្អាតនៅក្នុងឃុំរាម ចាប់ផ្តើមដំណើរការចែកចាយជូនប្រជាជនក្នុងឃុំរាម នៅឆ្នាំ២០១១ ដែលជាសេវាកម្មរបស់ឯកជន មានឈ្មោះថា រស្មីអរុណ។ បច្ចុប្បន្នការចែកចាយនេះ បាន៣ភូមិប៉ុណ្ណោះ គឺភូមិស្មាច់ដែង រាម និងថ្មធំ ដោយឡែកភូមិអុងមិនទាន់មានបណ្តាញទឹកស្អាតប្រើប្រាស់នៅឡើយទេ ព្រោះភូមិអុងគឺជាភូមិនៅដាច់ឆ្ងាយពីគេ ដែលស្ថិតនៅក្បែរឆ្នេរចំការដូង។ ទោះបីជាភូមិទាំងបីខាងលើ មានបណ្តាញទឹកស្អាតក៏ដោយ ប្រជាជនប្រមាណ៦០% នៃភូមិទាំងបី ប៉ុណ្ណោះដែលប្រើបណ្តាញទឹកទុយោនេះ ព្រោះគ្រួសារខ្លះប្រើប្រាស់ទឹកអណ្តូង និងគ្រួសារខ្លះទៀតប្រមូលទឹកភ្លៀងទុកប្រើប្រាស់។ ចំពោះភូមិអុងវិញមានសេវាកម្មឡានដឹកជញ្ជូនទឹកដល់ផ្ទះប្រជាជន ជារៀងរាល់ថ្ងៃ។

ចំពោះគម្រោងអភិវឌ្ឍន៍កោះក្របីវិញ ដោយសារតែកោះស្ថិតនៅចំងាយ៦គីឡូម៉ែត្រពីឆ្នេររាម ហេតុដូចច្នេះហើយ គម្រោងអភិវឌ្ឍន៍មិនមានបណ្តាញទឹកស្អាតប្រើប្រាស់ទេ គឺគម្រោងនឹងរៀបចំទូក ធុងទឹក និងស៊ីតែនទឹក ដើម្បីប្រើប្រាស់តាមតម្រូវការក្នុងតំបន់គម្រោង និងដើម្បីបំពេញតម្រូវការរបស់ភ្ញៀវ ដែលទៅកំសាន្តនៅលើកោះ។

### ឃ. មណ្ឌលសុខភាព

យោងតាមការអង្កេត និងការសំភាសន៍បានឱ្យដឹងថា នៅក្នុងឃុំរាមនេះមានមណ្ឌលសុខភាពចំនួនមួយកន្លែង មានឈ្មោះថា **មណ្ឌលសុខភាព រាម** ដែលបានសាងសង់តាំងពីឆ្នាំ១៩៧៩មក។ មណ្ឌលសុខភាពនេះ មានទីតាំងស្ថិតនៅក្នុង ភូមិរាម ឃុំរាម ស្ថិតនៅចំកណ្តាលនៃឃុំ ដែលងាយស្រួលដល់ប្រជាជន ក្នុងការមកទទួលសេវាថែទាំសុខភាពរបស់ពួកគេ។ ក្រៅពីមណ្ឌលសុខភាព ក្នុងឃុំរាមនេះ ក៏មានឱសថស្ថានមួយកន្លែងផងដែរ ដែលប្រជាជនមួយចំនួនអាចទៅទិញថ្នាំ និងព្យាបាលបានក្នុងតំលៃសមរម្យ (យោងតាមសម្ភាសន៍)។




រូបភាព៥.១៥៖ មណ្ឌលសុខភាពរាម

### ង. សេវាអប់រំបែបជាប្រព័ន្ធ

សព្វថ្ងៃ សេវាអប់រំបែបជាប្រព័ន្ធនៅក្នុងឃុំរាមនេះ មាន៤កម្រិតគឺ គម្រិតថ្នាក់មត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដែលជាកន្លែងសម្រាប់ផ្តល់នូវ ការបណ្តុះបណ្តាលអប់រំដល់កុលបុត្រកុលធីតា នៅក្នុងឃុំនេះ ឱ្យក្លាយជាកូនល្អ សិស្សល្អនៅក្នុងសង្គម និងមានអនាគតល្អនាថ្ងៃអនាគត។

#### ថ្នាក់មត្តេយ្យ

បច្ចុប្បន្ន នៅក្នុងឃុំរាម មានសេវាអប់រំសម្រាប់ថ្នាក់មត្តេយ្យមាន២ប្រភេទគឺ សេវាអប់រំថ្នាក់មត្តេយ្យសហគមន៍ ដែលមានថ្នាក់សិក្សាចំនួន ២បន្ទប់ គ្រូបង្រៀនចំនួន២នាក់ និងមានសិស្សចំនួន៦៧នាក់។ សេវាអប់រំថ្នាក់មត្តេយ្យមួយទៀត គឺសេវាអប់រំថ្នាក់មត្តេយ្យឯកជន ដែលមានថ្នាក់សិក្សាចំនួន៣ គ្រូបង្រៀនមានចំនួន៤ និងមានចំនួនសិស្សចូលសិក្សាចំនួន៩៧នាក់។ យោងតាមទិន្នន័យរបាយការណ៍របស់ភូមិឃុំបានឱ្យដឹងថា កុមារដែលមានអាយុពី៣ឆ្នាំ ដល់ ៥ ឆ្នាំ បានចុះឈ្មោះចូលរៀនសាលាមត្តេយ្យទាំងពីនេះមានការកើនឡើងជារៀងរាល់ឆ្នាំ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១០ មានចំនួនកុមារត្រឹមតែ១៦.៩១ភាគរយ ហើយបានឡើងដល់ ២២.៦០

ភាគរយនៅឆ្នាំ ២០១១ និងកើនឡើងដល់២៤.៦៣ភាគរយនៅឆ្នាំ២០១២។ ប៉ុន្តែទោះជា នៅក្នុងឃុំនេះមានសេវាអប់រំថ្នាក់មត្តេយ្យក៏ដោយ ចំនួនកុមារដែលសិក្សានៅថ្នាក់កំរិតនេះ នៅមានចំនួនតិចតួចនៅឡើយ។

តារាង៥.២៥៖ ទិន្នន័យចំនួនកុមារ(អាយុ៣ ដល់ ៥ឆ្នាំ) បានចូលរៀនថ្នាក់មត្តេយ្យ

| ល.រ | កុមារអាយុពី៣-៥ ឆ្នាំ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|
| | | ភាគរយ | ភាគរយ | ភាគរយ |
| ១ | ថ្នាក់មត្តេយ្យសហគមន៍ | ៤.៣២ | ៨.៧៣ | ១០ |
| ២ | ថ្នាក់មត្តេយ្យឯកជន | ១២.០៩ | ១៣.៨៨ | ១៤.៦៣ |
| សរុប | | ១៦.៤១ | ២២.៦០ | ២៤.៦៣ |

ប្រភព៖ របាយការណ៍ឃុំរាម ២០១២

**ថ្នាក់បឋមសិក្សា**

ចំណែកថ្នាក់បឋមសិក្សាវិញ នៅក្នុងភូមិនេះមាន៣គឺ សាលាបឋមសិក្សា **ហ៊ុន សែន រាម** ដែលមានទីតាំងស្ថិតភូមិរាម សាលាបឋមសិក្សា ស្មាច់ដែង និងសាលាបឋមសិក្សា **ធា** វិញ ដែលមានទីតាំងក្នុងភូមិអុង។ សាលាបឋមសិក្សាទាំងបីនេះ មានបន្ទប់សម្រាប់សិក្សាសរុបចំនួន ៣០បន្ទប់ និងមានគ្រូបង្រៀនចំនួន៣៧នាក់ និងមានសិស្សចំនួន១,៣២៣នាក់ ក្នុងនោះសិស្សស្រីមានចំនួន ៦០៧នាក់។



រូបភាព៥.១៥៖ បឋមសិក្សាហ៊ុនសែន រាម



រូបភាព៥.១៦៖ បឋមសិក្សាស្អាច់ ដែង

ថ្នាក់អនុវិទ្យាល័ និងវិទ្យាល័យ

ក្រៅពីកម្រិតបឋមសិក្សា ឃុំរាមមានសាលារៀនចំនួន១ សម្រាប់បង្ហាត់បង្រៀនសិស្សថ្នាក់កម្រិត អនុវិទ្យាល័យ និងវិទ្យាល័យ។ សាលារៀននេះ មានឈ្មោះថា **វិទ្យាល័យ ហ៊ុនសែន ស្នាច់ដែង** ដែលមានទីតាំងស្ថិតនៅក្នុងភូមិរាម។ សព្វសាលារៀននេះ មានថ្នាក់សិក្សាសម្រាប់សិស្សកម្រិតអនុវិទ្យាល័យមានចំនួន ១០បន្ទប់ និងគ្រូបង្រៀនចំនួន ២៥នាក់ ហើយមានចំនួនសិស្សចូលរៀនមានចំនួន ៨២៦នាក់ ក្នុងនោះមួយសិស្សប្រុសមានចំនួន៥០៥នាក់ និងសិស្សស្រីមានចំនួន ៤២៣នាក់។ ចំណែកឯ កម្រិតវិទ្យាល័យវិញមានថ្នាក់សម្រាប់សិក្សាចំនួន ១២បន្ទប់ ប៉ុន្តែថ្នាក់សម្រាប់សិក្សាមានត្រឹមតែ៨ថ្នាក់តែប៉ុណ្ណោះ ដែលមានគ្រូសម្រាប់បង្ហាត់បង្រៀនត្រឹមតែ៥ប៉ុណ្ណោះ និងមានសិស្សសិក្សាចំនួន ៨១៨នាក់ ក្នុងនោះសិស្សប្រុសមានចំនួន ៣៩៥នាក់ និងសិស្សស្រីមានចំនួន៤២៣នាក់។ យោងតាមទិន្នន័យស្តីពីថ្នាក់កម្រិតវិទ្យាល័យខាងនេះ បានឱ្យដឹងថាចំនួនសិស្សសម្រាប់កម្រិតថ្នាក់វិទ្យាល័យនេះមានចំនួនតិចបើធៀបទៅនឹងបន្ទប់សម្រាប់សិក្សា ព្រោះថ្នាក់បម្រុងសម្រាប់ថ្នាក់វិទ្យាល័យនេះមានដល់ទៅ១២ថ្នាក់ ប៉ុន្តែសព្វថ្ងៃនេះមានតែ៨ថ្នាក់តែប៉ុណ្ណោះ។



រូបភាព៥.១៧៖ វិទ្យាល័យ ហ៊ុនសែន ស្នាច់ដែង ស្ថិតក្នុងឃុំរាម

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ច. សេវាអប់រំបែបក្រៅប្រព័ន្ធ

ក្រៅពីសេវាអប់រំក្នុងប្រព័ន្ធ ក្នុងឃុំរាមនេះ ក៏សេវាអប់រំក្រៅប្រព័ន្ធមួយគឺ **ភូមិកុមារអរុណរះទី៣** (Sunrise Children's Villages) ដែលបង្កើតឡើងក្រោមសកម្មភាពសប្បុរសគ្មានដែនកំណត់របស់មូលនិធិអូស្ត្រាលី ហើយជាសមិទ្ធផលថ្មីមួយរវាងកិច្ចសហប្រតិបត្តិការរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយមូលនិធិអូស្ត្រាលី-កម្ពុជា។ ភូមិកុមារអរុណរះទី៣ ដែលមានទីតាំងស្ថិតនៅក្នុងភូមិស្មាច់ដែង មានផ្ទៃក្រឡាចំនួន ៥ហិកតា បំពាក់នូវសម្ភារៈបរិក្ខារ គ្រឿងសង្ហារឹម ដែលចំណាយថវិកាសរុបចំនួន ២.២៤១.៤៦៩ ដុល្លារអាមេរិក។

គោលបំណងនៃការបង្កើតភូមិកុមារអរុណរះទី៣នេះ គឺដើម្បីផ្តល់ការថែទាំ ការពារ អប់រំ ការអភិវឌ្ឍន៍បញ្ញាស្មារតីដល់កុមារកំព្រា កុមារដែលត្រូវគេបោះបង់ចោល កុមារត្រូវគេជួញដូរ ដើម្បីប្រែក្លាយកុមារទាំងនោះឱ្យក្លាយទៅជាកូនល្អ សិស្សល្អ មិត្តល្អ និងជាពលរដ្ឋល្អរបស់សង្គមនាពេលអនាគត។

យោងតាមបទសម្ភាសន៍ជាមួយ **លោក ផាង ច័ន្ទចំរើន** ជាគ្រូបង្រៀនភាសាខ្មែរនៅក្នុងភូមិកុមារអរុណរះទី៣ បានឱ្យដឹងសព្វថ្ងៃកុមារដែលចូលមកទទួលការអប់រំ និងសិក្សាចំនួន៣៦នាក់ និងគ្រូសម្រាប់បង្ហាត់បង្រៀនចំនួន៤នាក់ ក្នុងនោះគ្រូបង្ហាត់ភាសាខ្មែរចំនួន២នាក់គ្រូបង្រៀនភាសាអង់គ្លេសចំនួន១នាក់ និងគ្រូបង្រៀនកុំព្យូទ័រចំនួន១នាក់។ ចំនួនសិស្សសិក្សា និងគ្រូបង្រៀន ត្រូវបានរំពឹងថានឹងកើនឡើងនាពេលអនាគត។ យោងតាមសេចក្តីថ្លែងសុន្ទរកថារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១២ នៃឱកាសបើកសម្ពោធន៍ជាផ្លូវការនៃភូមិកុមារអរុណរះទី៣នេះ បានបញ្ជាក់ឱ្យដឹងថាមណ្ឌលថ្មីនេះពិតជាកន្លែងមួយសម្រាប់ផ្តល់នូវសេចក្តីសង្ឃឹមពិតសម្រាប់កុមារដែលគ្មានទីពឹង ជាពិសេសកុមារដែលមានផ្ទុកជម្ងឺHIVជាដើម ព្រោះកុមារដែលមកទីកន្លែងនេះ ពិតជាបានទទួលនូវការថែទាំ និងថែរក្សាយ៉ាងយកចិត្តទុកដាក់ ហើយពួកគេអាចទទួលបាននូវការអប់រំ និងការបណ្តុះបណ្តាលជំនាញផ្សេងៗ ដែលស្ពានជួយចម្លងពួកគេឱ្យទទួលបានភាពជោគជ័យ និងអនាគតថ្លៃថ្លា។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៥.១៨៖ ភូមិកុមារអេរុណរះទី៣

ច. បណ្តាញទូរគមនាគមន៍

ចំពោះវិស័យទូរគមនាគមន៍នៅក្នុងតំបន់នោះវិញ មានភាពល្អប្រសើរ ពោលគឺមានបណ្តាញសេវាប្រព័ន្ធទូរស័ព្ទស្ទើរតែគ្រប់ប្រព័ន្ធ គឺប្រព័ន្ធបណ្តាញទូរសព្ទចល័ត ហេ ឡូ (Hello Mobile Phone Service) អឹម ហ្វូន (Mfone Mobile Phone Service) ម៉ូ ប៊ី ថែល (Mobitel Mobile Phone Service) ប្រព័ន្ធទូរស័ព្ទមិត្តហ្វូន (Metfone Mobile Phone Service) ប្រព័ន្ធប៊ីឡាញ (Bee Line Mobile Phone Service) និងប្រព័ន្ធស្មាត ( Smart Mobile Phone Service)ជាដើម។ ប្រព័ន្ធទូរស័ព្ទនេះ អាចទំនាក់ទំនងបានគ្រប់ទីកន្លែងក្នុងតំបន់គម្រោង និងក្បែរតំបន់គម្រោង ដែលផ្តល់លក្ខណៈងាយស្រួលក្នុងការទំនាក់ទំនងដល់ប្រជាជននៅក្នុងតំបន់នេះ។

៥.៥.២.៩ សម្បត្តិវប្បធម៌ ទំនៀមទំលាប់ និងសាសនា

យោងតាមការអង្កេតផ្ទាល់ និងការសម្ភាសន៍លោកមេឃុំ និងមេភូមិបានឲ្យដឹងថា នៅក្នុងឃុំរាមមានសាសនា២បែបគឺ ប្រជាជនប្រហែល៩៩%កាន់ព្រះពុទ្ធសាសនា និងមានតែ១% ប៉ុណ្ណោះកាន់សាសនាគ្រីស្ត។ នៅក្នុងឃុំរាមនេះ មានវត្តចំនួន២ ដែលប្រជាជនក្នុងតំបន់តែងតែទៅ នៅពេលមានកម្មវិធីបុណ្យព្រះពុទ្ធសាសនាផ្សេងៗ ដូចជាវត្តស្នាច់ដែង និងវត្តឧត្តមវណ្ណារាម។ ម៉្យាងទៀត នៅក្នុងឃុំរាមនេះក៏មានមជ្ឈមណ្ឌលវិបស្សនាធុរៈគិរីនា វ៉ែន សម្រាប់លោក

យាយ លោកតា និងជូនជីកាន់សីល។ ចំណែកឯសាសនាគ្រិស្តវិញក៏មានទីតាំងមួយកន្លែងសម្រាប់ជួបជុំគ្នាផងដែរ ដែលមានឈ្មោះថា **ក្រុមជំនុំជ្រើសរើសពីធីរាន រាម**។



រូបភាព៥.១៩៖ ក្លោងទ្វារវត្តឧត្តមវណ្ណារាម



រូបភាព៥.២០៖ ក្លោងទ្វាមជ្ឈមណ្ឌលវិបស្សនាធុរៈគិរីនា វ៉ែន




រូបភាព៥.២១៖ ក្រុមជំនុំប្រេសប៊ីធើរាន រាម

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

### ៩.៩.២.១០ តំបន់ទេសចរណ៍

នៅក្នុងឃុំរាមមានតំបន់ទេសចរណ៍ជាច្រើន ដែលភ្ញៀវទេសចរអាចដើរកំសាន្តបានគ្រប់ទីកន្លែងជាមួយនឹងទេសភាពធម្មជាតិដ៏ស្រស់ត្រកាលមិនអាចបំភ្លេចបាន ដែលតំបន់កំសាន្តទាំងនោះរួមមានដូចខាងក្រោម៖

→ **តំបន់ព្រៃកោងកាង៖** ភ្ញៀវទេសចរអាចធ្វើដំណើរដោយទូក ដើម្បីទស្សនាទិដ្ឋភាពព្រៃកោងកាង រុក្ខជាតិផ្សេងៗ សកម្មភាពអ្នកនេសាទ ដែលអាចស្តាប់លឺសំឡេងខ្យល់បក់ប៉ះស្លឹកឈើគួរឲ្យចាប់អារម្មណ៍។ ម៉្យាងទៀត ភ្ញៀវទេសចរអាចទស្សនាត្រី ដូហ្វាំង (ផ្សោត) ដែលតែងតែមកលេងតំបន់នេះថែមទៀតផង។

→ **ឆ្នេរសមុទ្ររាម៖** ភ្ញៀវទេសចរអាចដើរកាត់គ្រាប់ខ្សាច់តូចៗ និងស្រូបយកខ្យល់អាកាសបរិសុទ្ធនៅតាមដងឆ្នេរសមុទ្រដែលមានប្រវែង៦គីឡូម៉ែត្រ។ ម៉្យាងទៀតភ្ញៀវទេសចរអាចបរិភោគអាហារសមុទ្រស្រស់ៗ មានរស់ជាតិឆ្ងាញ់ពិសារ នៅតាមដងឆ្នេរ ដែលអាចគយគន់រលកសមុទ្រក្នុងពេលជាមួយគ្នា ដែលមានលក្ខណៈអំណោយផលពីធម្មជាតិនៃខ្យល់បក់មកពីសមុទ្រ។

→ **ធម្មជាតិនៃឧទ្យានជាតិរាម៖** ភ្ញៀវទេសចរអាចធ្វើដំណើរឡើងលើភ្នំ ដើម្បីទស្សនាសម្រស់សត្វព្រៃ ព្រៃឈើ និងទឹកជ្រោះដែលមាននៅរដូវវស្សា ដោយមានអ្នកជូនភ្ញៀវទៅដល់ទឹកធ្លាក់តែម្តង។

→ **តំបន់កោះ៖** ភ្ញៀវទេសចរអាចធ្វើដំណើរទៅលេងកោះផ្សេងៗ ដែលស្ថិតនៅក្បែរកោះក្របី ដែលមានដូចជា កោះក្របី កោះឫស្សី កោះតាកៀវ និងកោះព្រះជាដើម។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com




រូបភាព៥.២២៖តំបន់កោះផ្សេងៗ ដែលភ្ញៀវទេសចរអាចដើរកំសាន្ត



រូបភាព៥.២៣៖ ឆ្នេរសមុទ្រវាម ដែលភ្ញៀវទេសចរអាចដើរកំសាន្ត



រូបភាព៥.២៤៖ ឧទ្យានជាតិរាម ដែលភ្ញៀវទេសចរអាចដើរកំសាន្ត



រូបភាព៥.២៥៖ ឧទ្យានជាតិរាម ដែលភ្ញៀវទេសចរអាចដើរកំសាន្ត

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី៦៖

# ការចូលរួមជាសាធារណៈ

# ជំពូកទី៦៖ ការចូលរួមជាសាធារណៈ

## ៦.១ សេចក្តីផ្តើម

ការចូលរួមជាសាធារណៈ គឺជាផ្នែកមួយដ៏សំខាន់ សម្រាប់ធ្វើឱ្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមពេញលេញអាចប្រព្រឹត្តទៅដោយមានប្រសិទ្ធភាព។ ការសិក្សានេះ **ក្រុមហ៊ុន គ្រីអេធីវ គ្រីនឌីហ្សាញ** (Creative Green Design Co, Ltd) បានចុះធ្វើការផ្សព្វផ្សាយ ស្ទង់មតិ និងជួបពិភាក្សាជាមួយ មន្ទីរ-ស្ថាប័នដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋនៅជុំវិញតំបន់គម្រោងអភិវឌ្ឍន៍។ មូលហេតុដែលនាំឱ្យមានការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណៈជន និងប្រជាជនដែលពាក់ព័ន្ធ ដោយសារតែគម្រោងនេះ គឺជាចំណុចមួយដ៏សំខាន់ដែលធ្វើឡើងដើម្បីឱ្យសាធារណៈដែលមានការពាក់ព័ន្ធទាំងអស់ ផ្តល់នូវសំណួរ សំណូមពរ និងអនុសាសន៍ផ្សេងៗក្នុងការជួយដល់ការអនុវត្តគម្រោងឱ្យបានល្អប្រសើរ មានប្រសិទ្ធភាព និងមានភាពរលូនទៅតាមលំអាននៃគម្រោងអភិវឌ្ឍន៍។ ម៉្យាងទៀត ការចូលរួមជាសាធារណៈ ធ្វើឡើងក្នុងដំណាក់កាលសាងសង់ ដែលធ្វើឱ្យសាធារណៈជនពាក់ព័ន្ធបានដឹងលឺថា មានក្រុមហ៊ុននឹងមកវិនិយោគលើគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានធម្មជាតិនៅក្នុងតំបន់របស់គាត់។

ការចូលរួមជាសាធារណៈនេះ បានធ្វើការពិភាក្សាវែកញែក និងពន្យល់ឱ្យប្រជាពលរដ្ឋនៅក្នុង និងក្បែរតំបន់គម្រោងបានយល់អំពីគោលបំណងនៃការអភិវឌ្ឍន៍គម្រោងដែលទៅថ្ងៃអនាគតនឹងនាំឱ្យពួកគេបានរីកចំរើន (ចូលរួមចំណែកជាមួយរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅក្បែរតំបន់គម្រោង) និងចូលរួមពង្រីកសក្តានុពលនៃវិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជា ទៅកាន់ពិភពលោកតាមរយៈការលេចចេញនូវរមណីយដ្ឋានដ៏ស្រស់ស្អាតរបស់គម្រោង។

## ៦.២ គោលបំណងនៃការពិគ្រោះយោបល់

គោលបំណងនៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណៈជនជាមួយមន្ទីរ ស្ថាប័នដែលពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាជលរដ្ឋមានដូចតទៅ៖

- ធ្វើការផ្សព្វផ្សាយដល់សាធារណៈជន និងអ្នកដែលពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ទាំងអស់ យល់ពីគោលបំណងរបស់គម្រោងអភិវឌ្ឍន៍ និងបានដឹងលឺថាមានគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានធម្មជាតិមួយក្នុងតំបន់របស់គាត់។

- ដកស្រង់មតិយោបល់ ចូលរួមសហការណ៍ និងការគាំទ្រពីសំណាក់ស្ថាប័នដែលពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើគម្រោងអភិវឌ្ឍន៍រមណីយដ្ឋាននេះ ដើម្បីឲ្យការអភិវឌ្ឍន៍នេះដំណើរការទៅបានរលូន។
- ស្វែងរកមតិយោបល់ រិះគន់ សំណូមពរ បញ្ហាទំនាស់ ការងឿងឆ្ងល់ និងការគាំទ្ររបស់ប្រជាពលរដ្ឋ ចំពោះគម្រោងអភិវឌ្ឍន៍នេះនិងការបកស្រាយរបស់ម្ចាស់គម្រោងពោលគឺរកវិធីសាស្រ្តសម្របសម្រួល និងកែលំអរ ដែលអាចធ្វើឲ្យការអភិវឌ្ឍន៍ប្រកបដោយតម្លាភាព និងនិរន្តរភាពទាំងបច្ចុប្បន្នទៅអនាគត។

## ៦.៣ ការផ្សព្វផ្សាយអំពីគម្រោង និងពិគ្រោះយោបល់ជាមួយមន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធ

### ៦.៣ការផ្សព្វផ្សាយ ១.អំពីគម្រោង និងការពិគ្រោះយោបល់ជាមួយសាលាខេត្តព្រះសីហនុ

នៅថ្ងៃទី៣១ ខែ តុលា ឆ្នាំ ២០១៤ វេលាម៉ោង ២:០០រសៀល ក្រុមការងារចម្រុះបានប្រជុំវាយតំលៃហេតុប៉ះពាល់បរិស្ថានលើគម្រោងអភិវឌ្ឍន៍ រមណីយដ្ឋានកោះក្របី របស់ក្រុមហ៊ុន RPB INVESTMENT Co.,Ltd ដែលស្ថិតនៅក្នុងភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្រោមអធិបតីភាព **លោក ឯម ភាព** នាយកទីចាត់ការ និងវិនិយោគ តំណាង **ឯកឧត្តម ឈិន សេងឆួន** អភិបាលរងខេត្តព្រះសីហនុ និងជាប្រធានក្រុមការងារចម្រុះពិនិត្យ និងវាយតម្លៃផលប៉ះពាល់បរិស្ថានដែលមានសមាសភាពចូលរួមក្នុងអង្គប្រជុំរួមមាន៖

១. លោក ឯម ភាព នាយកទីចាត់ការផែនការ និងវិនិយោគខេត្តព្រះសីហនុ
២. លោក នួន ប៊ុនថុល នាយកទីចាត់ការអន្តរវិស័យខេត្តព្រះសីហនុ
៣. លោក វង្ស សាមិត្ត ប្រធានការិយាល័យវិនិយោគខេត្តព្រះសីហនុ
៤. លោក យ៉ាង ភារម្យ មន្ត្រីសាលាខេត្តព្រះសីហនុ
៥. លោក អក សុងហ៊ិន អភិបាលរងស្រុកព្រៃនប់
៦. លោក សំ គល់ អនុប្រធានមន្ទីរបរិស្ថាន
៧. លោក ស៊ិន សត្ថារតន៍ នាយករងខណ្ឌរដ្ឋបាលជលផល
៨. លោក ឌី សុភី នាយរងខណ្ឌរដ្ឋបាលព្រៃឈើ
៩. លោក ឆោម រិទ្ធ មន្ត្រីទេសចរណ៍
១០. លោក លិល សារិន មេឃុំរាម
១១. លោក គង់ ប៊ុនទ្រី មេភូមិ
១២. លោក ទេព ស៊ីណ្ហា៉ តំណាងក្រុមហ៊ុន
១៣. កញ្ញា និន លក្ខិណា គណនេយ្យករ ក្រុមហ៊ុន

ជាកិច្ចចាប់ផ្តើម **លោក ៦ម ឆាត** នាយកទីចាត់ការផែនការ និងវិនិយោគ និងជាតំណាងអភិបាលរងខេត្ត មានមតិស្វាគមន៍ដល់សមាជិក សមាជិកាអង្គប្រជុំ ដោយបានបញ្ជាក់ថា បន្ទាប់ពីបានចុះទៅពិនិត្យជាក់ស្តែង ដល់ការដ្ឋានគម្រោងអភិវឌ្ឍន៍កោះក្របី រួចមកក្រុមការងារសង្កេតឃើញថាជាទូទៅក្រុមហ៊ុនអភិវឌ្ឍន៍បានអនុវត្តន៍តាមច្បាប់ និងគោរពតាមស្តង់ដាបច្ចេកទេសសំណង់បានល្អប្រសើរ តែនៅក្នុងនោះក៏នៅមានបញ្ហាអវិជ្ជមានមួយចំនួនផងដែរ។ បន្ទាប់មកលោកប្រធានអង្គប្រជុំបានអនុញ្ញាតឲ្យក្រុមការងារចម្រុះផ្តល់យោបល់តាមជំនាញដូចតទៅ៖

- លោក **ស៊ិន សត្ថារតន៍** នាយករងខណ្ឌរដ្ឋបាលជលផល បានផ្តល់យោបល់ដល់ក្រុមហ៊ុនជាបីដំណាក់កាល៖

១. មុនពេលដំណើរការការដ្ឋាន

- ក្រុមហ៊ុនត្រូវច្រកបាវខ្សាច់ធ្វើជាទំបន់ការពារការធ្លាក់ដី ថ្ម និងស៊ីម៉ង់តិចូលក្នុងសមុទ្រដែលធ្វើឲ្យប៉ះពាល់ដល់ផ្កាថ្ម និងធនធានជលផលផ្សេងៗជាពិសេសភាគខាងលិចកោះ។
- ស្នើរសុំឲ្យមានការគ្រប់គ្រងសំណល់រឹង រាវឲ្យបានល្អ និងយកចេញឲ្យបានឆាប់រហ័ស។

២. ក្នុងពេលដំណើរការការដ្ឋាន

- សិក្សាធនធានដែលមាននៅជុំវិញកោះឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីធានាថាក្នុងរយៈកំពុងសាងសង់នឹងមិនមានបង្កផលប៉ះពាល់ ឬខូចខាតដល់ធនធាននៅជុំវិញកោះ។
- ស្នើរសុំរក្សាជុំវិញកោះចូលទៅផ្ទៃទឹកត្រឹម ១០០ម៉ែត្រ និងអនុញ្ញាតឲ្យប្រជានេសាទ អាចចូលនេសាទបានក្នុងចំងាយ១០០ម៉ែត្រពីកោះ និងការស្ទូចត្រីកំសាន្តរបស់ភ្ញៀវទេសចរណ៍ខាងក្រៅ។

៣. ក្រោយដំណើរការការដ្ឋាន

- ស្នើរសុំក្រុមហ៊ុនជួយស្តារឡើងវិញ ក្នុងករណីបង្កផលប៉ះពាល់ និងខូចខាតដល់ធនធានលើកោះ។
- ក្រុមហ៊ុនត្រូវមានថវិកាប្រចាំឆ្នាំសម្រាប់ថែរក្សាបរិស្ថានផ្ទៃទឹកជុំវិញកោះ។
- ក្រុមហ៊ុនត្រូចសិក្សាស្រាវជ្រាវជារៀងរាល់ឆ្នាំពីបរិស្ថានទឹក ត្រី ផ្កាថ្ម ឲ្យដឹងពីការកើនឡើង ឬថយចុះ។

- **លោក សំគល់** អនុប្រធានមន្ទីរបរិស្ថាន បានផ្តល់យោបល់ដល់ក្រុមហ៊ុនដូចខាងក្រោម៖

- ស្នើរសុំក្រុមហ៊ុនគ្រប់គ្រងនូវសំណល់រឹង រាវ និងសំឡេងឲ្យបានសមស្របតាមកិច្ចសន្យា និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

- ស្នើរសុំក្រុមហ៊ុនសិក្សាឡើងវិញនូវទិន្នន័យចំបងៗទាំងក្នុង និងក្រៅគម្រោង។
- ស្នើរសុំក្រុមហ៊ុនវិភាគផលប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច សង្គម។
- ស្នើរសុំឲ្យមានការចូលរួម និងផ្តល់ពត៌មានទៅមន្ទីរជំនាញ។

- **លោក ឌី សុគី** នាយករងខណ្ឌរដ្ឋបាលព្រៃឈើ បានថ្លែងកោតសរសើរដល់ក្រុមហ៊ុនអភិវឌ្ឍន៍ថា ជាទូទៅធ្វើបានល្អ ដោយក្រុមហ៊ុនបានរក្សាព្រៃឈើរហូតដល់ជាង៧០% ដែលមានលក្ខណៈសមស្រប សម្រាប់វិស័យអេកូទេសចរណ៍។ ប៉ុន្តែលោកក៏បានមានប្រសាសន៍បន្ថែមទៀតថា ប្រសិនបើទៅថ្ងៃអនាគមក្រុមហ៊ុនធ្វើការពង្រីកផ្លូវបន្ថែម នោះវានឹងបង្កផលប៉ះពាល់ដល់ព្រៃឈើបន្ថែមទៀត។
- **លោក នួន ម៉ុនថុល** នាយកទីចាត់ការអន្តរវិស័យ បានផ្តល់យោបល់ដល់ក្រុមហ៊ុនត្រូវគោរព ច្បាប់វិនិយោគ និងច្បាប់សាងសង់នៃព្រះរាជាណាចក្រកម្ពុជាឲ្យបានខ្ជាប់ខ្ជួន។
- **លោក ឯម តាត** នាយកទីចាត់ការផែនការ និងវិនិយោគ និងជាតំណាងអភិបាលរងខេត្តបានផ្តល់យោបល់ដល់ក្រុមហ៊ុនដូចខាងក្រោម៖
  - ស្នើរសុំក្រុមហ៊ុនគ្រប់គ្រងកាកសំណល់រឹង រាវឲ្យបានល្អ ដើម្បីការពារធនធានសមុទ្រ និងបរិស្ថាន។
  - ស្នើរសុំក្រុមហ៊ុនគោរព ច្បាប់វិនិយោគ និងច្បាប់សំណង់នៃព្រះរាជាណាចក្រកម្ពុជា។
  - ស្នើរសុំក្រុមហ៊ុនផ្តល់កិច្ចសន្យា លិខិតអនុញ្ញាតសាងសង់ ច្បាប់សុំវិនិយោគដែលចេញដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងពាណិជ្ជកម្ម។
- **លោក ទេព ស៊ីណូរ៉ា** តំណាងក្រុមហ៊ុន បានថ្លែងអំណរអគុណដល់ក្រុមការងារដែលបានចុះទៅពិនិត្យជាក់ស្តែងដល់ការដ្ឋានគម្រោងអភិវឌ្ឍន៍កោះក្របី ស្ថិតក្នុងភូមិសាស្ត្រឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ របស់ក្រុមហ៊ុន RPB Investment Co,.Ltd និងបានសន្យាកែលំអរ និងពាំនាំយោបល់ដ៏មានសារៈសំខាន់ទាំងអស់នេះទៅជំរាបជូននាយកក្រុមហ៊ុនដើម្បីធ្វើការសម្រេចចិត្ត។

ជាចុងក្រោយ **លោក ឯម តាត** នាយកទីចាត់ការផែនការ និងវិនិយោគ និងជាតំណាងអភិបាលរងខេត្ត និងជាប្រធានក្រុមការងារវាយតំលៃហេតុប៉ះពាល់បរិស្ថានលើការវិនិយោគរបស់ក្រុមហ៊ុន RPB Investment Co., Ltd លើកោះក្របីដែលស្ថិតនៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ បានថ្លែងអំណរគុណដល់ក្រុមការងារ និងតំណាងក្រុមហ៊ុន ដែលមានការសហការគ្នាបានល្អ ក្នុងការចុះសិក្សាជាក់ស្តែង និងផ្តល់យោបល់កែលំអរផ្សេងៗ។ ហើយអង្គប្រជុំ ទទួលស្គាល់ថាការអភិវឌ្ឍន៍របស់ក្រុមហ៊ុនមានលក្ខណៈល្អប្រសើរ ហើយសង្ឃឹមថាក្រុមហ៊ុននឹងធ្វើការកែលំអរនូវចំណុចអវិជ្ជមានមួយចំនួន ដែលក្រុមការងារបានលើកឡើងៗ។ ជាទីបញ្ចប់លោកបានគោរពជូនពរដល់ក្រុមការងារ និងតំណាងក្រុមហ៊ុនទាំងអស់ឲ្យជួបប្រទះតែសំណាង

#322P, St.271Z, Sk.Terk Tla, Khan Resey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ល្អ សុខភាពល្អគ្រប់ៗគ្នា និងថ្លែងបិទអង្គប្រជុំនាថ្ងៃខែឆ្នាំដ៏ដែលក្នុងបរិយាកាសរីករាយស្និតស្នាលក្រៃលែង។

បន្ទាប់ពីក្រុមការងារចម្រុះបានចុះពិនិត្យទីតាំងការដ្ឋានសាងសង់រមណីយដ្ឋានកោះក្របីមក នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ក្រុមការងារគ្រីអេធីវ ហ្គ្រីនឌីហ្សាញ បានស្នើរសុំជួបសម្ភាសន៍ផ្ទាល់ជាមួយ **ឯកឧត្តម ឈិត សុខុន** អភិបាលខេត្តព្រះសីហនុ នៅវេលាម៉ោង ១០:០០ព្រឹក។ ការជួបសម្ភាសន៍សំណេះសំណាលនេះ បានផ្តោតសំខាន់លើមតិយោបល់របស់ឯកឧត្តមអភិបាលលើគម្រោងអភិវឌ្ឍន៍កោះក្របីរួមមានដូចខាងក្រោម៖

<u>**សំណួរទី១៖**</u> តើឯកឧត្តមយល់យ៉ាងណាដែរចំពោះគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីបន្ទាប់ក្រុមការងារចម្រុះបានចុះអង្កេត និងវាយតំលៃដល់ទីតាំងការដ្ឋានសាងសង់។

<u>**ចម្លើយទី១៖**</u>បន្ទាប់ពីក្រុមការងារចម្រុះបានចុះពិនិត្យនៅការដ្ឋានជាក់ស្តែង ក្រុមហ៊ុនការងារបានផ្តល់កំណត់ហេតុឃើញថា ការសាងសង់រមណីយដ្ឋាននៅលើកោះក្របី មានលក្ខណៈល្អប្រសើរដោយក្រុមហ៊ុនវិនិយោគខិតខំប្រឹងប្រែងក្នុងការសាងសង់ ហើយបានគិតគូរទៅលើបញ្ហា ហើយខ្ញុំក៏មានការសប្បាយរីករាយណាស់ដែរ ដែលបានក្រុមហ៊ុន RPB Investment Co., Ltd បានមកធ្វើការអភិវឌ្ឍន៍ជារមណីយដ្ឋានធម្មជាតិក្នុងខេត្តព្រះសីហនុខ្ញុំនេះ តែសូមឲ្យការអភិវឌ្ឍនេះគោរពទៅតាមច្បាប់នៃរាជាណាចក្រកម្ពុជា។យ៉ាងណាមិញ យោងតាមកំណត់ហេតុរបស់ក្រុមការងារចម្រុះបានឲ្យដឹងថា ការអភិវឌ្ឍន៍នេះក៏អាចមានផលប៉ះពាល់ទៅលើធនធានធម្មជាតិដែលមានស្រាប់ក្នុង និងជុំវិញកោះក្របីនេះផងដែរ ដូចជាអាចបង្កឲ្យមានការបំពុលទឹក ខ្យល់ ធនធានព្រៃ ផ្កាថ្ម និងធនធានសមុទ្រផ្សេងៗទៀតតាមរយៈសកម្មភាពសាងសង់របស់ក្រុមហ៊ុន។ ហេតុដូចនេះក្នុងនាមខ្ញុំជាអាជ្ញាធរខេត្ត សូមផ្ញើរសារដល់ម្ចាស់គម្រោងអនុវត្តទៅតាមកិច្ចសន្យាក្នុងការអភិវឌ្ឍន៍ គោរពទៅប្លង់មេ និងប្រើប្រាស់វិធានការកាត់បន្ថយផលប៉ះពាល់ទៅលើបរិស្ថានប្រកបដោយប្រសិទ្ធភាព។

<u>**សំណួរទី២៖**</u> តើឯកឧត្តមគាំត្រចំពោះការអភិឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ធម្មជាតិកោះក្របីនេះដែរ ឬទេ?

<u>**ចម្លើយទី២៖**</u> រាល់ការអភិវឌ្ឍន៍ខ្ញុំពិតជាគាំទ្រ និងសូមលើកទឹកចិត្តដល់ម្ចាស់គម្រោងដែលបានមកវិនិយោគក្នុងខេត្តព្រះសីហនុខ្ញុំនេះ តែក្នុងលក្ខខណ្ឌគម្រោងនោះមិនធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន និងសង្គមមនុស្សយ៉ាងធ្ងន់ធ្ងរ ហើយក៏សូមធ្វើការគាំទ្រណាស់ចំពោះក្រុមហ៊ុនដែលបានអនុវត្តច្បាប់។ ខ្ញុំសូមបញ្ជាក់ដែរថា ខេត្តព្រះសីហនុជាខេត្តដែលមានភ្ញៀវទេសចរណ៍មកច្រើនសណ្ឋិកសណ្ឋាប់ពីមួយឆ្នាំទៅមួយឆ្នាំ ឧទាហរណ៍ ក្នុងមួយថ្ងៃមានប្រជាជនមិនតិចជាង ៦០០នាក់ទេដែលចូលមកទស្សនានៅកោះរ៉ុង ហេតុដូននេះ ដើម្បីទាញទាញភ្ញៀវទេសចរណ៍កាន់តែច្រើនឡើងនោះ គ្រប់គម្រោងអភិវឌ្ឍន៍រមនីយដ្ឋាន ត្រូវរក្សាបាននូវបរិស្ថាន ធម្មជាតិស្រស់ស្អាត និងសេវាកម្មល្អ។ ខេត្តព្រះសីហនុពិតជាមានមោតនភាពណាស់ដែល បានក្រុម

ហ៊ុនRPB Investment Co., Ltd បានមកវិនិយោគទុន ដោយបង្កើតជារមណីយដ្ឋានធម្មជាតិ ហើយខ្ញុំក៏សូមលើកទឹកចិត្ត និងគាំទ្រដល់ការអភិវឌ្ឍន៍នេះប្រព្រឹត្តទៅបានយ៉ាងរលូននិងប្រសើរ មុននឹងដាក់ដំណើរគម្រោងនៅថ្ងៃខាងមុខ។

<u>សំណួរទី៣</u>៖ តើឯកឧត្តមមានអនុសាសន៍ ឬសំណូមពរអ្វីខ្លះសម្រាប់ជាសារដល់ក្រុមហ៊ុនអភិវឌ្ឍន៍?

<u>ចម្លើយទី៣</u>៖ តាមរយៈកំណត់ហេតុរបស់ក្រុមការងារចម្រុះប្រជុំពិនិត្យ និងវាយតំលៃ អាជ្ញាធរខេត្តព្រះសីហនុបានផ្តល់អនុសាសន៍ដូចខាងក្រោម៖

- សិក្សាធនធានដែលមានស្រាប់នៅជុំវិញកោះឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីធានាថាក្នុងរយៈពេលកំពុងសាងសង់នឹងមិនមានបង្កផលប៉ះពាល់ ឬខូចខាតឡើយ។
- ក្រុមហ៊ុនត្រូវរៀបចំយន្តការដំណើរការសាងសង់ឲ្យបានសមស្របតាមកិច្ចសន្យា។
- ក្នុងការដំណើរការសាងសង់ក្រុមហ៊ុនត្រូវគ្រប់គ្រងសំណល់រឹង និងរាវកុំឲ្យចូលសមុទ្រតាមកិច្ចសន្យា និងច្បាប់ព្រះរាជាណាចក្រកម្ពុជា។
- ក្រុមហ៊ុនត្រូវច្រកបាវខ្សាច់ធ្វើជាទំនប់ការពារការធ្លាក់ដី ថ្ម និងស៊ីម៉ងត៍ចូលសមុទ្រ ដែលធ្វើឲ្យប៉ះពាល់ដល់ផ្កាថ្ម និងធនធានសមុទ្រផ្សេងៗ។
- ក្រុមហ៊ុនត្រូវសិក្សាស្រាវជ្រាវរៀងរាល់ឆ្នាំពីបរិស្ថានទឹក ផ្កាថ្ម ត្រីថាតើមានការកើនឡើង ឬថយចុះ។
- ក្រុមហ៊ុនគួររក្សាត្រឹម១០០ម៉ែត្រពីកោះចូលទៅក្នុងទឹកដើម្បីឲ្យទេសចរណ៍ខាងក្រៅបានស្ទូចត្រីកំសាន្តបាន។
- ក្រុមហ៊ុនត្រូវមានថវិកាប្រចាំឆ្នាំដើម្បីថែរក្សាបរិស្ថាន។



រូបភាព៦.១៖ ការជួបសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយឯកឧត្តមអភិបាលខេត្តព្រះសីហនុ

### ៦.៣.២ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានខេត្តព្រះសីហនុ

ជំនួសឲ្យមន្ទីរបរិស្ថានខេត្តព្រះសីហនុ**លោក សំ គល់** មានតួនាទីជាអនុប្រធានបានផ្តល់ឱកាសជួបសម្ភាសជាមួយក្រុមការងារគ្រីអេធីវហ្គ្រីនឌីហ្សាញ (CGD) នៅថ្ងៃទី៣១ខែតុលាឆ្នាំ២០១៤នៅម៉ោង២:០០ដល់៣:៣០ល្ងាច។ការជួបសម្ភាសនេះមានសំណួរនិងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដូចខាងក្រោម៖

**<u>សំណួរទី១</u>៖** តើលោកធ្លាប់បានដឹងពីគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី នៅឃុំរាម ខេត្តព្រះសីហនុដែរឬទេ?

**<u>ចម្លើយទី១</u>៖** គម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីនេះ ខ្ញុំធ្លាប់បានដឹង និងលឺតាំងពីឆ្នាំ២០១២មកម្លេះ។

**<u>សំណួរទី២</u>៖** តើលោកធ្លាប់បានដឹង និងលឺអំពីការអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីនេះដោយរបៀបណា?

**<u>ចម្លើយទី២</u>៖**គម្រោងអភិវឌ្ឍន៍រមណីយដ្ឋាននេះជាគម្រោងអភិវឌ្ឍន៍របស់ជនជាតិរុស្សី ដែលទទួលបានសិទ្ធអភិវឌ្ឍន៍រាជរដ្ឋាភិបាល ហើយគម្រោងនេះបានធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងម្តងរួចមកហើយ។ ខ្ញុំបានចូលរួមក្នុងការធ្វើបទបង្ហាញស្តីពីគម្រោងនេះនៅសាលាខេត្តព្រះសីហនុក្នុងកំឡុងឆ្នាំ២០១២ម្តង និងនៅក្រសួងបរិស្ថានម្តងនៅឆ្នាំ២០១៣។

**<u>សំណួរទី៣</u>៖**តើលោកធ្លាប់បានចុះពិនិត្យដោយផ្ទាល់នៅទីតាំងការដ្ឋានគម្រោងអភិវឌ្ឍកោះក្របីនេះដែរឬទេ?

**<u>ចម្លើយទី៣</u>៖**ខ្ញុំធ្លាប់បានចុះពិនិត្យដល់ការដ្ឋានផ្ទាល់ ជាមួយក្រុមការងាររបស់សាលាខេត្តព្រះសីហនុ។ គម្រោងអភិវឌ្ឍន៍រមណីយដ្ឋាននេះ ខ្ញុំសូមសរសើរ និងលើកទឹកចិត្តខ្លាំងណាស់ព្រោះការអភិវឌ្ឍនេះបានគិតគូរជាចំបងទៅលើបញ្ហាបរិស្ថាន ដូចជាសំណង់រឹង-រាវ និងការរក្សាទុកព្រៃឈើជាដើម។

**<u>សំណួរទី៤</u>៖**តើលោកគិតថា គម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របី បានធ្វើឲ្យប៉ះពាល់ដល់ធនធានព្រៃឈើដែរឬទេ។

**<u>ចម្លើយទី៤</u>៖**គម្រោងអភិវឌ្ឍនេះ ជាគម្រោងដែលបានគិតគូរយ៉ាងល្អិតល្អន់ទៅលើការអភិរក្សព្រៃឈើ។ គម្រោងនេះបានរក្សាទុកព្រៃឈើបានរហូតដល់៨០% ខ្ញុំពិតជាសូមសរសើរចំពោះការអភិវឌ្ឍន៍របស់គាត់ខ្លាំងណាស់។ រាល់ការសាងសង់ផ្ទះលំហែរកាយ ផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត បានបញ្ចៀសរាល់ការកាប់ព្រៃឈើដល់កម្រិតអប្បបរមា។ ធម្មតាការអភិវឌ្ឍតែងតែមានការប៉ះពាល់ គ្រាន់តែការប៉ះពាល់នេះក្នុងកម្រិតប៉ុណ្ណា បើតាមការចុះអង្កេតជាក់

ស្តែងឃើញថា គម្រោងអភិវឌ្ឍនេះមានផលប៉ះពាល់ទៅលើធនធានព្រៃឈើក្នុងកម្រិតតិចតួចបំផុត។

__សំណួរទី៥៖__ចំពោះបញ្ហាសំណល់រឹង-រាវវិញតើមានការគ្រប់គ្រងបានត្រឹមត្រូវដែរឬទេ?
__ចម្លើយទី៥៖__បញ្ហាសំណល់រឹងរាវ គឺជាបញ្ហាចំបងដែលគួរឲ្យព្រួយបារម្ភ។ ក្នុងដំណាក់កាលសាងសង់នេះ តាមការអង្កេតរបស់ខ្ញុំ សំណល់រឹងនៅលើកោះក្រុមហ៊ុនបានវេចខ្ចប់រួចដឹកមកកាន់ដីគោកវិញ ចំណែកសំណល់រាវក្រុមហ៊ុនបានធ្វើបង្គន់អនាម័យសម្រាប់កម្មករបានត្រឹមត្រូវ។ប៉ុន្តែនៅដំណាក់កាលប្រតិបត្តិគម្រោងខ្ញុំមិនដឹងថា ប្រព័ន្ធនៃការគ្រប់គ្រងរបស់គាត់បែបណានោះទេ?

__សំណួរទី៦៖__ចំពោះការឈូសឆាយដីវិញតើមានការហូរច្រោះដីដែរទេ?
__ចម្លើយទី៦៖__ការឈូសឆាយដីឃើញថាក្រុមហ៊ុនក៏បានគិតគូរទៅលើការហូរច្រោះដីផងដែរ។ ក្រុមហ៊ុនបានឈូសឆាយដីតាមជម្រាលដី និងមានរៀបចំដាក់ថ្មដើម្បីទប់ស្កាត់ការហូរច្រោះដី ព្រោះការទប់ស្កាត់ការហូរច្រោះដីធ្វើឲ្យគុណភាពសំណង់ និងអគារបានល្អ។

__សំណួរទី៧៖__តើគម្រោងអភិវឌ្ឍកំពង់ផែជាប់ឆ្នេរសមុទ្រាមស្ថិតនៅក្នុងដីឧទ្យានជាតិរាមដែរឬទេ?
__ចម្លើយទី៧៖__កំពង់ផែនេះមិនស្ថិតនៅក្នុងឧទ្យានជាតិរាមទេ តែស្ថិតនៅក្នុងការការគ្រប់គ្រងរបស់គណកម្មការតំបន់ឆ្នេរ។

__សំណួរទី៨៖__តើគម្រោងអភិវឌ្ឍកំពង់ផែនេះមានផលប៉ះពាល់ដែរ ឬទេ? អ្វីខ្លះ?
__ចម្លើយទី៨៖__ការអភិវឌ្ឍផែនេះឃើញថានៅជាប់នឹងផ្លូវ ដែលអាចធ្វើឲ្យប៉ះពាល់ចំណីផ្លូវ ហើយក៏មានការប៉ះពាល់ដល់ចំណីឆ្នេរផងដែរ។

__សំណួរទី៩៖__តើលោកគាំទ្រការអភិវឌ្ឍរមណីយដ្ឋានកោះក្របីនេះដែរឬទេ?
__ចម្លើយទី៩៖__ខ្ញុំសូមគាំទ្រការអភិវឌ្ឍន៍នេះ និងលើកទឹកចិត្តដល់ការអភិវឌ្ឍនេះព្រោះការអភិវឌ្ឍផ្តល់ផលយោជន៍សេដ្ឋកិច្ចជាតិ។

__សំណួរទី១០៖__តើលោកមានយោបល់ ឬសំណូមពរអ្វីបន្ថែមទេ?
__ចម្លើយទី១០៖__ជាចុងក្រោយខ្ញុំសំណូមពរដល់ក្រុមហ៊ុនអភិវឌ្ឍន៍ធ្វើការគ្រប់គ្រងសំណល់រឹង-រាវឲ្យបានត្រឹមត្រូវ ដោយគោរពទៅតាមច្បាប់ស្តីពីការគ្រប់គ្រងសំណល់រឹង-រាងរបស់ព្រះរាជាណាចក្រកម្ពុជា។ ចំពោះក្រុមហ៊ុនទីប្រឹក្សាគួរសិក្សា និងវិភាគឲ្យបានត្រឹមត្រូវទៅលើធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសង្គម-សេដ្ឋកិច្ច។ ចុងបញ្ចប់ក៏សូមសើកទឹកចិត្តដល់ក្រុមហ៊ុនអភិវឌ្ឍន៍ដែលមានខិតខំប្រឹងប្រែងពុះពារគ្រប់ឧបសគ្គក្នុងការអភិវឌ្ឍនេះ។



រូបភាព៦.២៖ ការជួបសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានខេត្តព្រះសីហនុ

### ៦.៣.៣ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ

ជំនួសឲ្យមន្ទីរទេសចរណ៍ លោកស្រី **អ៊ឹម ចន្ថា** និងលោក **ម៉េង ស៊ីសុវណ្ណ** ដែលមានតួនាទីជាអនុប្រធានមន្ទីទេសចរណ៍ និងលោក **អឿ វិបុល** មានតួនាទីជា ប្រធានការិយាល័យអេកូទេសចរណ៍ ខេត្តព្រះសីហនុ បានផ្តល់ឱកាសជួបសម្ភាសជាមួយក្រុមការងារ គ្រីអេធីវហ្គ្រីនឌីហ្សាញ (CGD) នៅថ្ងៃទី៣១ខែតុលាឆ្នាំ២០១៤នៅម៉ោង៩:៣០ដល់ ១០:៣០។ការជួបសម្ភាសនេះមានសំណួរដែលពាក់ព័ន្ធជាមួយគម្រោងអភិវឌ្ឍរមណីយដ្ឋាន កោះក្របីដូចខាងក្រោម៖

សំណួរទី១ ៖ តើអ្នកធ្លាប់ឮ ពីគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដែរឺទេ?
ចម្លើយទី១ ៖ ខ្ញុំមិនធ្លាប់បានឮពីគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីទេ។

សំណួរទី២៖ តើមកដល់ពេលបច្ចុប្បន្ននេះមានកោះចំនួនប៉ុន្មានដែលបានអភិវឌ្ឍន៍ចេញជារូបរាងនៅខេត្តព្រះសីហនុនេះ?
ចម្លើយទី២៖ មកដល់ពេលបច្ចុប្បន្ននេះមានកោះចំនួន៤ ដែលបានអភិវឌ្ឍស្របតាមច្បាប់របស់រដ្ឋាភិបាល។ កោះទាំងនោះមានដូចជា កោះពស់ កោះដែកគោល កោះសង្ឃា និងកោះក្របី។

សំណួរទី៣៖ តើមន្ទីរទេសចរណ៍បានចូលរួមចំណែកអ្វីខ្លះក្នុងការថែរក្សាបរិស្ថាន និងផ្សព្វផ្សាយតំបន់ទេសចរណ៍ខេត្តព្រះសីហនុនេះឲ្យបានល្អប្រសើរ?
ចម្លើយទី៣៖ ដើម្បីថែរក្សាបរិស្ថាន និងផ្សព្វផ្សាយតំបន់ទេសចរណ៍អោយកាន់តែមានភាពល្បីល្បាញមន្ទីរបានចូលរួមចំណែកក្នុងការថែរក្សាបរិស្ថានដូចជា ធ្វើការសំអាតឆ្នេរ អប់រំដល់អាជីវករតាមឆ្នេរ និងសណ្ឋាគារឲ្យគ្រប់គ្រងកាកសំណល់របស់ខ្លួនឲ្យបានត្រឹមត្រូវ។ ចំពោះរមណីយដ្ឋានតាមកោះក៏មានការស្នើរសុំឲ្យម្ចាស់គម្រោងគ្រប់គ្រង និងចាត់វិធានការអភិរក្សផ្កាថ្មផងដែរ។

សំណួរទី៤៖ ផ្អែកតាមទស្សនៈរបស់លោក និងលោកស្រីតើប្រជាជននៅក្នុងឃុំរាមអាចនឹងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍរមណីយដ្ឋានធម្មជាតិកោះក្របី តាមរយៈវិស័យទេសចរណ៍ដែរឺទេ? បើមានតើទទួលបានដោយរបៀបណាខ្លះ?
ចម្លើយទី៤៖ ផ្អែកតាមទស្សនៈរបស់យើងខ្ញុំ ប្រជាជននៅក្នុងឃុំរាមអាចនឹងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍរមណីយដ្ឋានធម្មជាតិកោះក្របីតាមរយៈវិស័យទេសចរណ៍ដូចជា៖

- អាចទទួលប្រាក់ចំណូលបន្ថែមតាមរយៈការលក់ដូរបន្លែផ្លែឈើ និងផលនេសាទដែលពួកគាត់ដាំបាន។
- អាចលក់ផលិតផលនេសាទទៅឲ្យភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ
- អាចទទួលប្រាក់ចំណូលពីការលក់កំលាំងពលកម្ម និងជម្រើសការងារផ្សេងៗក្រៅពីការនេសាទ និងការរកអនុផលព្រៃឈើ។

សំណួរទី៥៖ តើខាងមន្ទីរទេសចរណ៍គាំទ្រគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដែរឺទេ?
ចម្លើយទី៥៖ មន្ទីរទេសចរណ៍យើងខ្ញុំសូមធ្វើការគាំទ្រចំពោះគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីនេះ។ ពីព្រោះគម្រោងអភិវឌ្ឍរមណីយដ្ឋាននេះជាផ្នែកមួយអាចជួយអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការរីកចម្រើន។

<u>សំណួរទី៦៖</u> តើអ្នកមានមតិយោបល់ និងអនុសាសន៍បន្ថែមអ្វីខ្លះ ចំពោះគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីនេះ?

<u>ចម្លើយទី៦៖</u> មន្ទីរទេសចរណ៍ខេត្តព្រះសីហនុមានសំណូមពរមួយចំនួនដូចខាងក្រោម៖

- សូមគម្រោងអភិវឌ្ឍមានការគោរពតាមច្បាប់ទេសចរណ៍ និងការគោរពច្បាប់បរិស្ថាន
- គួរកុំសាងសង់បង្គន់អនាម័យ ឫបន្ទប់ទឹកឲ្យបានគ្រប់គ្រាន់ នៅខាងផែដីគោកក៏ត្រូវមានផងដែរ។



រូបភាព៦.៣៖ ការជួបសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ

### ៦.៣.៤ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះសីហនុ

ជំនួសឲ្យមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះសីហនុ**លោក ថាវ៉ាឌុច** មានតួនាទីជាអនុប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះសីហនុ បានផ្តល់ឱកាសជួបសម្ភាសជាមួយក្រុមការងារ គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ (CGD) នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ នៅវេលាម៉ោង ៣: ៣០ ដល់៤:៣០ល្ងាច។ ការជួបសម្ភាសនេះមានសំណួរ និងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដូចខាងក្រោម៖

<u>សំណួរទី១</u>៖ តើលោកធ្លាប់បានដឹងពីគម្រោងអភិវឌ្ឍន៍កោះក្របី នៅឃុំរាម ខេត្តព្រះសីហនុដែរឬទេ?

<u>ចម្លើយទី១</u>៖ គម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីនេះ ខ្ញុំធ្លាប់បានដឹងខ្លះដែរ តែមិនសូវជាដឹងច្បាស់លាស់នោះទេ។

<u>សំណួរទី២</u>៖ តើលោកធ្លាប់ចុះត្រួតពិនិត្យការដ្ឋានសាងសង់រមណីយដ្ឋានកោះក្របីនេះដែរឬទេ?

<u>ចម្លើយទី២</u>៖ ការដ្ឋានអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីនេះខ្ញុំធ្លាប់បានចូលមើលដែរ តែក្នុងលក្ខណៈឯកជនទេ។

<u>សំណួរទី៣</u>៖ តើលោកមានយោបល់យ៉ាងណាចំពោះការសាងសង់ផ្លូវរបស់ក្រុមហ៊ុនអភិវឌ្ឍន៍?

<u>ចម្លើយទី៣</u>៖ តាមការសាងសង់ផ្លូវរបស់ក្រុមហ៊ុនឃើញថាមានលក្ខណៈល្អប្រសើរ ដោយក្រុមហ៊ុនសាងសង់បានគិតគូរទៅលើការប៉ះពាល់ដើមឈើ ប្រើប្រាស់ប្រព័ន្ធការពារការបាក់ដីនិងហូរច្រោះដីបានល្អ។ ចំពោះបញ្ហាផ្លូវជាប់ទីតាំងសាងសង់ផែដីគោក ឃើញថាមានលក្ខណៈតូចចង្អៀត ដែលក្រុមហ៊ុនគួរតែពង្រីកផ្លូវនេះឲ្យធំជាងមុន។ កាលពីថ្មីៗនេះលោកអភិបាលខេត្តក៏បានលើកពីបញ្ហានេះដែរ ដែលលោកបានប្រគល់តួនាទីពង្រីកផ្លូវនេះមកមន្ទីរសាធារណៈការ និងសហការណ៍ជាមួយក្រុមហ៊ុនអភិវឌ្ឍន៍ ដែលត្រូវពង្រីកបន្ថែមទទឹង៨ម៉ែត្រ និងបណ្តោយ២០០ម៉ែត្រ តែបច្ចុប្បន្នពុំទាន់ឃើញក្រុមហ៊ុនមកទាក់ទងសោះ។

<u>សំណួរទី៤</u>៖ ចំពោះបញ្ហាសំណល់រឹង តើក្រុមហ៊ុនបានសហការជាមួយមន្ទីររបស់លោកដែរឬទេ?

<u>ចម្លើយទី៤</u>៖ ឃើញថាក្រុមហ៊ុនមិនដែលបានសហការជាមួយមន្ទីរខ្ញុំទេ តែប្រហែលជាក្រុមហ៊ុនសហការជាមួយសាលាខេត្តព្រះសីហនុ ព្រោះខាងមន្ទីរខ្ញុំមិនបានដឹងពីរឿងនេះ។

<u>សំណួរទី៥</u>៖ តាមយោបល់លោកតើក្រុមហ៊ុនគួរគ្រប់គ្រងសំណល់រាវយ៉ាងដូចម្តេចដែរ?

<u>ចម្លើយទី៥</u>៖ តាមយោបល់ខ្ញុំដើម្បីគ្រប់គ្រងសំណល់រាវឲ្យបានល្អប្រសើរ ក្រុមហ៊ុនត្រូវសាងសង់អាងសិបទិចតាមផ្ទះលំហែរកាយនីមួយៗ និងត្រូវធ្វើប្រព័ន្ធបង្ហូរសំណល់រាវរួមមួយ និងធ្វើអាង

ប្រព្រឹត្តិកម្មសំណល់រាវនេះមុនបង្ហូរចោល។ មធ្យោបាយផ្សេងទៀត បើក្រុមហ៊ុនមិនធ្វើអាងប្រព្រឹត្តិកម្មសំណល់រាវ ក្រុមហ៊ុនអាចសហការជាមួយខាងមន្ទីរខ្ញុំ ព្រោះមន្ទីរខ្ញុំមានកប៉ាល់សម្រាប់ដឹកសំណល់រាវមកដាក់ក្នុងអាងប្រព្រឹត្តកម្មរបស់មន្ទីរនៅក្រុងព្រះសីហនុបាន។

<u>សំណួរទី៦</u>៖ក្នុងការដឹកជញ្ជូនសម្ភារៈសំណង់តើក្រុមហ៊ុនប្រើប្រាស់មធ្យោបាយបែបណាក្នុងការសាងសង់? បើតាមគំនិតលោកតើមធ្យោបាយដឹកជញ្ជូនមួយណាល្អប្រសើរសម្រាប់គម្រោងអភិវឌ្ឍនេះ?
<u>ចម្លើយទី៦</u>៖ ការអភិវឌ្ឍនៅលើកោះពិតជាមានការលំបាកណាស់ ក្នុងការដឹកជញ្ជូនសម្ភារៈសំណង់ ជាទូទៅការអភិវឌ្ឍនៅខេត្តព្រះសីហនុនេះ ធ្វើការដឹកជញ្ជូនសម្ភារៈតាមកប៉ាល់។ ឃើញថារាល់សម្ភាៈសំណង់គឺដឹកចេញពីកំពុងផែកំពុងសោម រួចដឹកបញ្ជូនដល់កោះតែម្តង។ ចំពោះខ្សាច់ និងដុំថ្មត្រូវច្រកចូលប៉ាវរួចទើបធ្វើការដឹកជញ្ជូនតាមកប៉ាល់។ ការដឹកជញ្ជូនមានការលំបាក តែក្រុមហ៊ុនអភិវឌ្ឍន៍នៅលើកោះក្របីពិតជាមានឆន្ទះក្នុងការអភិវឌ្ឍពិតប្រាកដមែនខ្ញុំសូមសរសើរ។

<u>សំណួរទី៧</u>៖ តើលោកក៏ដូចជាមន្ទីររបស់លោកផ្ទាល់គាំទ្រចំពោះការអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីនេះដែរឬទេ?
<u>ចម្លើយទី៧</u>៖ ការអភិវឌ្ឍន៍នេះខ្ញុំសូមគាំទ្រ ព្រោះគម្រោងនេះជាគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានដែលនឹងមិនបញ្ចេញសារធាតុគីមីបំពុលធ្ងន់ធ្ងរនោះទេ។ គម្រោងនេះនឹងបញ្ចេញនូវសំណល់ផ្ទះបាយតែប៉ុណ្ណោះ តែបើក្រុមហ៊ុនមានការគ្រប់គ្រងបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសនោះមិនមានបញ្ហានោះទេ។ ម្យ៉ាងទៀតការអភិវឌ្ឍន៍នេះ ជាមោតនភាពរបស់ខេត្តព្រះសីហនុ ដែលការអភិវឌ្ឍន៍ធ្វើឲ្យមានការរីកចំរើននូវវិស័យទេសចរ។

<u>សំណួរទី៨</u>៖ ជាចុងក្រោយតើលោកមានយោបល់ និងសំណូមពរទេ?
<u>ចម្លើយទី៨</u>៖ ជាចុងក្រោយខ្ញុំសូមសំណូមពរដល់ក្រុមហ៊ុនអភិវឌ្ឍន៍កោះក្របីនេះគ្រប់គ្រងសំណល់របស់ខ្លួនឲ្យបានល្អកុំឲ្យមានការបំពុល។



រូបភាព៦.៤៖ ការជួបសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះសីហនុ

**៦.៣.៥ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តព្រះសីហនុ**

ជំនួសឲ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លោក **ឃី សៅរ៉េត** មានតួនាទីជាប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់និងភូមិបាលខណ្ឌព្រៃនប់ខេត្តព្រះសីហនុបានផ្តល់ឱកាសជួបសម្ភាសជាមួយក្រុមការងារគ្រីអេធីវហ្គ្រីនឌីហ្សាញ (CGD)

#322P, St.271Z, Sk.Tork Tla, Khan Resey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

នៅថ្ងៃទី៣១ខែតុលាឆ្នាំ២០១៤នៅម៉ោង១០: ៣០ដល់១១: ៣០ព្រឹក។ការជួបសម្ភាសនេះមានបញ្ជីរសំណួរមួយចំនួនដែលពាក់ព័ន្ធជាមួយគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដូចខាងក្រោម៖

<u>សំណួរទី១</u> ៖ តើអ្នកធ្លាប់ឮ ពីគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដែររឺទេ?
<u>ចម្លើយទី១</u>៖ ខ្ញុំធ្លាប់បានឮពីគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របី។ រមណីយដ្ឋាននេះត្រូវបានសាងសង់ឡើងតាំងពីឆ្នាំ ២០១២ ដោយក្រុមហ៊ុនវិនិយោគរបស់រុស្ស៊ី។

<u>សំណួរទី២</u>៖ តើក្រុមហ៊ុនវិនិយោគបានសុំច្បាប់អនុញ្ញាតសាងសង់នៅលើកោះ និងកំពង់ផែរដីគោកដែររឺទេ?
<u>ចម្លើយទី២</u>៖ ក្រុមហ៊ុនបានចុះបញ្ជី និងសុំការអនុញ្ញាតបានត្រឹមត្រូវ ពីព្រោះកោះទាំងអស់គឺជាកម្មសិទ្ធិរបស់រដ្ឋ។

<u>សំណួរទី៣</u>៖ តើមន្ទីររបស់អ្នកបានចុះត្រួតពិនិត្យនៅការដ្ឋានគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដោយផ្ទាល់ដែររឺទេ?
<u>ចម្លើយទី៣</u>៖ មន្ទីររបស់ខ្ញុំធ្លាប់បានចុះទៅ ចុះបញ្ជីដីធ្លីលើកោះក្របីមុនការវិនិយោគ ប៉ុន្តែបន្ទាប់ពីមានការវិនិយោគគម្រោង មន្ទីរមិនបានចុះទៅត្រួតពិនិត្យទៀតទេ។

<u>សំណួរទី៤</u>៖តើអ្នកបានដឹងពីរចនាបទនៃគម្រោងប្លង់សាងសង់រមណីយដ្ឋានកោះក្របីដែររឺទេ? តើក្រុមហ៊ុនវិនិយោគប្រើប្រាស់រចនាបទអ្វី?
<u>ចម្លើយទី៤</u>៖ ចំពោះរចនាបទនៃគម្រោងអភិវឌ្ឍ គឺក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ជាអ្នករៀបចំ។

<u>សំណួរទី៥</u>៖បើតាមយោបល់របស់អ្នកតើក្រុមហ៊ុនវិនិយោគគួរតែរចនាប្លង់សាងសង់ឲ្យមានលក្ខណៈបែបណាដើម្បីឲ្យសមទៅនឹងធម្មជាតិដែលមានស្រាប់នៅក្នុងតំបន់គម្រោង?
<u>ចម្លើយទី៥</u>៖ តាមយោបល់របស់ខ្ញុំដើម្បីឲ្យសមទៅនឹងធម្មជាតិដែលមានស្រាប់នៅក្នុងតំបន់គម្រោងក្រុមហ៊ុនវិនិយោគគួរតែរចនាប្លង់ដោយអនុលោមទៅតាមផែនការមេដែលបានប្រគល់ជូនក្រសួង (Master plan ) និងការសិក្សារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) រួចមកហើយ។

<u>សំណួរទី៦</u> ៖ តើអ្នកមានយោបល់រឺសំណូមពរបែបណាចំពោះម្ចាស់គម្រោងវិនិយោគកោះក្របី? តើអ្នកគាំទ្រចំពោះការអភិវឌ្ឍនេះដែររឺទេ?
<u>ចម្លើយទី៦</u>៖ ខ្ញុំគាំទ្រចំពោះគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របី។សម្រាប់យោបល់និងសំណូមពរខ្ញុំមានសំណូមពរឲ្យគម្រោងវិនិយោគអនុវត្តទៅតាមសារាចរណ៍០១និងផែនការមេ

របស់គម្រោងវិនិយោគ (Master Plan)។កំណត់ខ្សែទឹកចូលនិងគម្លាតពិចារណាលើគម្របព្រៃសួនបៃតងលំហរបៃតងសាធារណៈកំពង់ផែនិងនាវាចម្លងជាពិសេសការគ្រប់គ្រងសំណល់រឹងនិងរាវ។



រូបភាព៦.៥៖ ការជួបសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តព្រះសីហនុ

៦.៣.៦ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយខណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ

ជំនួសឲ្យខណ្ឌរដ្ឋបាលជលផល **លោក ស៊ិន សត្ថារតន៍** មានតួនាទីជាអភិបាលរងខណ្ឌបានផ្តល់ឱកាសជួបសម្ភាសជាមួយក្រុមការងារ គ្រីអេធីវហ្គ្រីនឌីហ្សាញ (CGD) នៅថ្ងៃទី៣០ខែតុលាឆ្នាំ២០១៤នៅម៉ោង២:៣០ដល់៣:៣០ ល្ងាច។ការជួបសម្ភាសនេះមានសំណួរដែលពាក់ព័ន្ធជាមួយគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដូចខាងក្រោម៖

<u>សំណួរទី១</u> ៖ តើអ្នកធ្លាប់ឮ ពីគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដែររឺទេ?
<u>**ចម្លើយទី១**</u>៖ ខ្ញុំធ្លាប់បានឮពីគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របី។ រមណីយដ្ឋាននេះត្រូវបានសាងសង់ឡើងតាំងពីឆ្នាំ ២០១២ មកម្លេះ។

**សំណួរទី២៖** តាមការយល់ឃើញរបស់អ្នក តើការអភិវឌ្ឍគម្រោងនេះបានផ្តល់នូវសារៈប្រយោជន៍អ្វីខ្លះ?

**ចម្លើយទី២៖** ការអភិវឌ្ឍគម្រោងនេះបានផ្តល់នូវសារៈប្រយោជន៍២គឺ៖

- ធនធានធម្មជាតិ៖ នៅពេលមានក្រុមហ៊ុនចូលមកអភិវឌ្ឍន៍នៅតំបន់លើកោះ ធ្វើឲ្យមានការអភិរក្ស និងថែរក្សាធនធានធម្មជាតិនៅក្នុងតំបន់នោះ និងបំពេញបន្ថែមរាល់អ្វីដែលខ្វះខាតដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ។
- សេដ្ឋកិច្ច-សង្គម៖ ការអភិវឌ្ឍរមណីយដ្ឋាននេះជាផ្នែកមួយដែលអាចជួយឲ្យសេដ្ឋកិច្ចប្រទេសកម្ពុជាមានការអភិវឌ្ឍផងដែរ។ លើសពីនេះទៅទៀត ប្រជាជននៅក្នុងតំបន់គម្រោងអាចទទួលបានឱកាសការងារនៅដំណាក់កាលសាងសង់គម្រោង និងអាចរកប្រាក់ចំណូលបន្ថែមបានពីវិស័យទេសចរណ៍។

**សំណួរទី៣៖** តើអ្នកគិតថាគម្រោងអភិវឌ្ឍរមណីយដ្ឋានធម្មជាតិកោះក្របី អាចនឹងធ្វើឲ្យប៉ះពាល់ដល់ការនេសាទដែរឬទេ?

**ចម្លើយទី៣៖** គម្រោងអភិវឌ្ឍរមណីយដ្ឋានធម្មជាតិកោះក្របី បានធ្វើឲ្យប៉ះពាល់តំបន់នេសាទ។ ការមិនពេញចិត្តរបស់អ្នកនេសាទគ្រួសារ និងទេសចរណ៍ ជាមួយនឹងការកំណត់ព្រំដែនរបស់ក្រុមហ៊ុនវិនិយោគ នៅចំងាយ ២០០ម៉ែត្រពីកោះ។ ពួកគាត់គិតថា ការកំណត់ព្រំនេះមានចំងាយឆ្ងាយពេក ធ្វើឲ្យពួកគាត់ពិបាកនេសាទ ហើយអ្នកស្ទូចត្រីទេសចរណ៍ក៏ត្រូវបានហាមឃាត់មិនឲ្យចូលនេសាទដូចមុនដែរ។

**សំណួរទី៤៖** តើសកម្មភាពនេសាទនៅជុំវិញកោះក្របីមុននិងក្រោយគម្រោងអភិវឌ្ឍរមណីយដ្ឋានធម្មជាតិកោះក្របីមានលក្ខណៈដូចម្តេច? (សូមរៀបរាប់)

**ចម្លើយទី៤៖** ស្ថានភាពមុន និងក្រោយគម្រោងសាងសង់៖

ក.ស្ថានភាពមុនពេលគម្រោង៖ ជាតំបន់ Marine Zone ដែលហាមឃាត់រាល់សកម្មភាពបំផ្លាញធនធានជលផលទាំងនៅក្នុងទឹក និងនៅលើគោក។ ស្ថានភាពកោះមានលក្ខណៈធម្មជាតិ ពុំទាន់មានសកម្មភាពបំផ្លាញព្រៃឈើអ្វីទាំងអស់។

ខ. ស្ថានភាពអំឡុងពេលសាងសង់គម្រោង៖ ធនធានត្រីនឹងអាចមានការកើនឡើងដោយសារការកំណត់ព្រំចំងាយ ២០០ម៉ែត្រពីកោះ។ ប៉ុន្តែស្ថានភាពកោះមានការផ្លាស់ប្តូរ ដោយមានការប្រែប្រួលគម្របព្រៃឈើ និងបញ្ហាសំណល់រឹង រាវ។

**សំណួរទី៥៖**តើផលនេសាទមានការកើនឡើងឬថយចុះបន្ទាប់ពីគម្រោងនេះក៏កើតឡើង?

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

<u>ចម្លើយទី៥</u>៖ ចំពោះការកើនឡើង ឬថយចុះនៃផលនេសាទ ខ្ញុំមិនទាន់អាចកំណត់បាននៅឡើយទេពីព្រោះមិនទាន់មានការសិក្សាឲ្យបានស៊ីជំរៅទៅលើទំនាក់ទំនងបច្ចេកទេស និងសង្គម និងធនធានជលផលនៅតំបន់រាមឲ្យបានច្បាស់នៅឡើយទេ។

<u>សំណួរទី៦</u>៖តើនៅក្នុងឃុំរាមមានប្រជាជនប៉ុន្មានគ្រួសារដែលប្រកបរបរនេសាទ?
<u>ចម្លើយទី៦</u>៖ ប្រជាជននៅក្នុងឃុំរាមមានប្រមាណ១០ ទៅ២០គ្រួសារប៉ុណ្ណោះដែលប្រកបរបរនេសាទ។

<u>សំណួរទី៧</u> ៖ តើអ្នកគិតថាគម្រោងអភិវឌ្ឍកោះក្របី មានផលប៉ះពាល់ដល់ធនធានជលផលដែរឬទេ ?
<u>ចម្លើយទី៧</u>៖ ខ្ញុំគិតថាគម្រោងអភិវឌ្ឍកោះក្របីនេះ មិនមានផលប៉ះពាល់ដល់ធនធានជលផលនៅក្នុងតំបន់កោះក្របីទេប្រសិនបើគម្រោងអភិវឌ្ឍមានវិធានការណ៍គ្រប់គ្រងការបំពុលបរិស្ថានឲ្យបានល្អប្រសើរ ជាពិសេសការគ្រប់គ្រងសំណល់រឹងនិង រាវ ។

<u>សំណួរទី៨</u>៖តើអ្នកគាំទ្រគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដែរឬទេ?
<u>ចម្លើយទី៨</u>៖ ខ្ញុំគាំទ្រចំពោះគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របី។ ពីព្រោះគម្រោងអភិវឌ្ឍរមណីយដ្ឋាននេះជាផ្នែកមួយអាចជួយអភិវឌ្ឍន៍ប្រទេសឲ្យមានការរីកចម្រើនថែមមួយកម្រិតទៀត។

<u>សំណួរទី៨</u>៖តើអ្នកចង់ឲ្យមានការអភិវឌ្ឍបែបណានៅក្នុងតំបន់កោះក្របី? សូមរៀបរាប់និងពន្យល់?
<u>ចម្លើយទី៩</u>៖ ខ្ញុំចង់ឲ្យតំបន់កោះក្របីអភិវឌ្ឍន៍ស្របទៅតាមគោលការណ៍មួយចំនួនដូចជា៖

- សម្រាប់ថ្ងៃអនាគត ខ្ញុំចង់ឲ្យសំណង់នៅលើកោះក្របីត្រូវសង់ឲ្យមានគុណភាពល្អ គួរតែយកចិត្តទុកដាក់ទៅលើវត្ថុធាតុដើម។ ប្រសិនបើអាចជៀសវាងបានគួរជៀសវាងពីការប្រើប្រាស់ដែកក្នុងការសាងសង់ ពីព្រោះសំណង់នៅលើកោះនឹងអាចមានប្រតិកម្មជាមួយសារធាតុដែក។ ដូច្នេះ បើមានភាពខូចខាត ធ្លាក់ចូលទៅក្នុងសមុទ្រ នឹងអាចបំពុលសមុទ្រ និងធនធាននៅក្នុងសមុទ្រ។
- គ្រប់គ្រងគុណភាពទឹក ខ្យល់ សំលេង ជាពិសេសសំណល់រឹង និងរាវអោយបានល្អប្រសើរ។

<u>សំណួរទី១០</u>៖ មតិយោបល់និងអនុសាសន៍បន្ថែមចំពោះគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របី?
<u>ចម្លើយទី១០</u>៖ ខ្ញុំមានសំណូមពរមួយចំនួនដូចខាងក្រោម៖

- គ្រប់គ្រងសំណល់រឹងឲ្យបានត្រឹមត្រូវ បែងចែកសំណល់អោយបានច្បាស់ ថាប្រភេទណាត្រូវយកទៅចោលនៅលើគោក និងប្រភេទណាត្រូវគ្រប់គ្រងនៅលើកោះ និងធ្វើការវេចខ្ចប់ឲ្យបានត្រឹមត្រូវ ។
- សំណល់រាវដែលចេញពីគ្រឿងចក្រត្រូវគ្រប់គ្រងអោយបានត្រឹមត្រូវផងដែរ។
- ការដឹកជញ្ជូន និងការលើកដាក់ត្រូវគ្រប់គ្រងឲ្យបានត្រឹមត្រូវ។
- សូមឲ្យក្រុមហ៊ុនវិនិយោគកំណត់ព្រំនៃតំបន់ការពារត្រឹម ១០០ម៉ែត្រ ចេញពីកោះ និងផ្តល់ឱកាសឲ្យអ្នកនេសាទគ្រួសារ និងទេសចរណ៍ចូលនេសាទបាន។



រូបភាព៦.៦៖ ការជួបសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយខណ្ឌរដ្ឋបាលជលផល ខេត្តព្រះសីហនុ

### ៦.៣.៧ ការផ្សព្វផ្សាយអំពីគម្រោង និងការពិគ្រោះយោបល់ជាមួយខណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុ

ជំនួសឲ្យខណ្ឌរដ្ឋបាលព្រៃឈើ លោក **ឌី សុធី** មានតួនាទីជាអភិបាលរងខណ្ឌរដ្ឋបាលព្រៃឈើ បានផ្តល់ឱកាសជួបសម្ភាសជាមួយក្រុមការងារ គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ(CGD)

នៅថ្ងៃទី៣០ខែតុលាឆ្នាំ២០១៤នៅម៉ោង៣:៣០ដល់៤:៣០ល្ងាច។ការជួបសម្ភាសនេះមាន សំណួរដែលពាក់ព័ន្ធជាមួយគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដូចខាងក្រោម៖

<u>សំណួរទី១៖</u> តើអ្នកធ្លាប់ឮ ពីគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីដែរឬទេ?
<u>ចម្លើយទី១៖</u> ខ្ញុំធ្លាប់បានឮពីគម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របី។

<u>សំណួរទី២៖</u> តើអ្នកដឹងពីស្ថានភាពភូមិសាស្ត្រ និងគម្របព្រៃឈើនៅតំបន់កោះក្របីដែរឬទេ?
<u>ចម្លើយទី២៖</u> ខ្ញុំបានដឹង ពីស្ថានភាពភូមិសាស្ត្រ និងគម្របព្រៃឈើនៅតំបន់កោះក្របី។

<u>សំណួរទី៣៖</u> តើព្រៃឈើនៅក្នុងតំបន់កោះក្របីជាប្រភេទព្រៃអ្វីខ្លះ?
<u>ចម្លើយទី៣៖</u>តាំងពីដើមឡើយព្រៃឈើនៅលើកោះក្របីនេះមានប្រភេទឈើល្អតែ២ប្រភេទ ប៉ុណ្ណោះ គឺ ឈើទាល និងផ្ចឹក។ ប៉ុន្តែក្រោយពេលមានអាជីវកម្មអាណាធិបតេយ្យ ព្រៃក្លាយទៅជារិចរិល និងបាត់បង់ប្រភេទសំខាន់ៗ។ លុះក្រោយមកទើបមានក្រុមហ៊ុនមកវិនិយោគលើកោះក្របីនេះ ដែលព្រៃឈើនេះត្រូវបានអភិរក្ស និងអាចមានភាពប្រសើរជាងមុន។

<u>សំណួរទី៤៖</u> តើព្រៃឈើទាំងនោះមានប្រភេទសត្វព្រៃរស់នៅដែរឬទេ?
<u>ចម្លើយទី៤៖</u> ព្រៃឈើទាំងនោះមានប្រភេទសត្វព្រៃរស់នៅមួយចំនួនដែរ ប៉ុន្តែមិនមែនជាប្រភេទថនិកសត្វទេ ពីព្រោះប្រភេទថនិកសត្វជាសត្វដែលត្រូវការទឹកសាប មិនអាចរស់នៅលើកោះបានទេ។

<u>សំណួរទី៥៖</u> តើអ្នកគិតថា ការអភិវឌ្ឍនៅតំបន់កោះក្របីមានផលប៉ះពាល់ដល់ប្រភេទសត្វ និងរុក្ខជាតិដែរឬទេ?
<u>ចម្លើយទី៥៖</u> ខ្ញុំគិតថាការអភិវឌ្ឍនៅតំបន់កោះក្របីមានផលប៉ះពាល់ដល់ប្រភេទសត្វ និងរុក្ខជាតិតិចតួចប៉ុណ្ណោះ ពីព្រោះនៅលើកោះនេះពុំសូវមានព្រៃធំៗ ចំណែកឯការអភិវឌ្ឍរមណីយដ្ឋានក៏អាច នឹងមានការការពារនឹងអភិរក្សផងដែរ។

<u>សំណួរទី៦៖</u> តើគម្រោងនេះ ធ្វើឲ្យប៉ះពាល់ដល់ប្រជាជននៅឃុំរាម ក្នុងការស្វែងរកអនុផលព្រៃឈើនៅលើតំបន់កោះក្របីដែរឬទេ?
<u>ចម្លើយទី៦៖</u> គម្រោងនេះ ធ្វើឲ្យប៉ះពាល់ដល់ប្រជាជននៅឃុំរាម ក្នុងការស្វែងរកអនុផលព្រៃឈើនៅលើតំបន់កោះក្របីខ្លះដែរ ពីព្រោះកាលពីមុនមានប្រជាជនពឹងផ្អែកលើអនុផលព្រៃឈើដូចជា ផ្តៅ និងវល្លិ៍ផ្សេងៗ ប៉ុន្តែនៅមានគម្រោងអភិវឌ្ឍ ប្រជាជនមិនអាចចូលទៅអាស្រ័យផលដូចមុនឡើយ។

<u>សំណួរទី៧៖</u> យោងទៅលើការវិនិយោគនៃគម្រោងរមណីយដ្ឋានកោះក្របីនេះ តើយើងគួរមានវិធានការណ៍ និងវិធីសាស្ត្របែបណាដើម្បីកាត់បន្ថយនូវហេតុប៉ះពាល់ទាំងអស់នេះ?

<u>ចម្លើយទី៧៖</u> វិធានការណ៍ និងវិធីសាស្ត្រដោះស្រាយចំពោះបញ្ហាដែលនឹងអាចកើតឡើងមានដូចខាងក្រោម៖

ក្រុមហ៊ុនវិនិយោគ៖គួរតែអនុវត្តគម្រោងទៅតាមផែនការមេដែលបានដាក់ជូនរដ្ឋាភិបាលនិងក្រុមហ៊ុនផ្តល់ប្រឹក្សាផ្នែកបរិស្ថាន។លើសពីនេះក្រុមហ៊ុនវិនិយោគគួររក្សាទុកព្រៃឈើឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបានពីព្រោះព្រៃឈើមិនងាយស្រួលក្នុងការដាំឡើងវិញទេ។

អាជ្ញាធរដែលពាក់ព័ន្ធ៖ជួយសម្រួលដល់ការអភិវឌ្ឍដោយគិតគូរទៅលើផលប៉ះពាល់និងអនុវត្តន៍ទៅតាមការអនុម័តរបស់រដ្ឋាភិបាល។

<u>សំណួរទី៨៖</u> តើអ្នកគាំទ្រចំពោះគម្រោងអភិវឌ្ឍរមណីយដ្ឋានធម្មជាតិកោះក្របីដែររឺទេ?

<u>ចម្លើយទី៨៖</u> ខ្ញុំគាំទ្រចំពោះគម្រោងអភិវឌ្ឍរមណីយដ្ឋានធម្មជាតិកោះក្របី។

<u>សំណួរទី៩៖</u> តើអ្នកមានមតិយោបល់ និងអនុសាសន៍បន្ថែម អ្វីខ្លះចំពោះរមណីយដ្ឋានកោះក្របី?

<u>ចម្លើយទី៩៖</u> ជំនួសមុខឲ្យខណ្ឌរដ្ឋាលព្រៃឈើ ខេត្តព្រះសីហនុ ខ្ញុំមានមតិយោបល់មួយចំនួនដូចខាងក្រោម៖

- សូមឲ្យក្រុមហ៊ុនវិនិយោគអនុវត្តន៍ទៅតាមការសំរេចព្រមព្រៀងរបស់រដ្ឋាភិបាល និងការផ្តល់មតិយោបល់របស់ក្រុមហ៊ុនផ្តល់ប្រឹក្សា។
- សូមឲ្យក្រុមហ៊ុនផ្តល់ប្រឹក្សា ផ្តល់ជាមតិណែនាំ និងការបង្ហាញផ្លូវ វិភាគឲ្យបានល្អិតល្អន់ និងផ្តល់ពត៌មានឲ្យបានច្បាស់លាស់។



រូបភាព៦.៧៖ ការជួបសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តព្រះសីហនុ

## ៦.៤ ការផ្សព្វផ្សាយអំពីគម្រោង និងពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន

កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ វេលាម៉ោង ២:០០ដល់ម៉ោង ៣:០០ល្ងាច នៅសាលាឃុំរាម ក្រុមការងារគ្រីអេធីវ ហ្គ្រីន ឌីហ្សាញ បានជួបប្រជុំសំណេះសំណាលផ្ទាល់ជាមួយអាជ្ញាធរមូលដ្ឋានក្នុងឃុំរាម។ ការជួបប្រជុំនេះមានការចូលរួមពីលោកមេឃុំ ក្រុមប្រឹក្សាឃុំ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

និងលោកមេភូមិទាំង៤ ដែលផ្តោតសំខាន់ទៅលើការអភិវឌ្ឍរមណីយដ្ឋានកោះក្របី និងស្ថានភាពរស់នៅរបស់ប្រជាជនក្នុងឃុំរាមទាំងមូល។ ការផ្តល់មតិយោបល់មានរៀបរាប់ដូចខាងក្រោម៖

### ៦.៤.១ មតិ យោបល់របស់លោកមេឃុំរាម

លោក **លិល សារិន** ភេទប្រុស មានអាយុ ៤៨ឆ្នាំ មានតួនាទីជាប្រធានឃុំរាម បានផ្តល់បទសម្ភាសន៍ និងមតិយោបល់ទាក់ទងនឹងគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីដូចខាងក្រោម៖

- កោះក្របីគឺជាកោះតូចមួយមួយ ដែលហៅថាកោះច្រឡុស មិនមានប្រជាជនរស់នៅលើកោះនេះទេតាំងពីដើមមក។ មូលហេតុដែលមិនមានប្រជាជនរស់នៅព្រោះកោះនេះមានលក្ខណៈចោទខ្លាំង ពិបាកក្នុងការតាំងលំនៅខ្លាំងណាស់ និងមិនមានប្រភពទឹកសាប (ស្ទឹង បឹង អូរ) សម្រាប់ប្រើប្រាស់ផងដែរ។ តែទោះជាយ៉ាងណាកោះនេះតាំងពីដើមមកជារណាំងការពារប្រជានេសាទនៅពេលមានខ្យល់ មានព្យុះផងដែរ មានន័យថា ប្រជានេសាទបានចូលចតទូកនៅលើកោះនោះនៅពេលមានព្យុះភ្លៀងម្តងម្កាល។
- លុះមកដល់ដើមឆ្នាំ២០១១ មានក្រុមហ៊ុន **អេធីប៊ី** បានមកអភិវឌ្ឍន៍ក្របីនេះ ជារមណីយដ្ឋាន ដែលបច្ចុប្បន្នឃើញថាចេញជារូបរាងបានប្រហែល៨០%ហើយ។ ចាប់តាំងពីពេលសាងសង់រហូតមកដល់បច្ចុប្បន្ន ក្រុមហ៊ុនបានធ្វើប័ណ្ណកម្មសិទ្ធរួចហើយ។
- ខ្ញុំធ្លាប់បានចុះពិនិត្យវាយតំលៃពីការសាងសង់ ដល់ការដ្ឋានសាងសង់ផ្ទាល់ឃើញថា ពិតជាល្អខ្លាំងណាស់។ ខ្ញុំសង្កេតឃើញថា ក្រុមហ៊ុនព្យាយាមមិនកាប់ព្រៃ ដោយបញ្ចៀសតាមដែលអាចធ្វើបាន សូម្បីតែប៉ុនកូនដៃក៏មិនកាប់ដែរ។
- បញ្ហាសំណល់រឹងឃើញថា មិនមានបញ្ហាអ្វីទេ ព្រោះក្រុមហ៊ុនបានធ្វើការដឹកជញ្ជូនមកកាន់ដីគោកវិញ និងយកទៅចោលនៅទីតាំងបានសមស្រប។ តែចំណុចដែលគួរចាប់អារម្មណ៍នោះគឺ បញ្ហាសំណល់រាវ តើកន្លែងស្តុករួមរៀបចំដោយរបៀបណា? ដឹកជញ្ជូនចេញរបៀបណា?
- ដោយសារកោះនេះមានលក្ខណៈចោតខ្លាំង ហេតុដូច្នេះដើម្បីកាត់បន្ថយការហូរច្រោះដីគួរច្រកដីចូលបាវ ធ្វើទំនប់ជុំវិញកោះកុំឲ្យហូរច្រោះដីហូរចូលសមុទ្រ។
- បញ្ហាផ្លូវក្រុមហ៊ុនគួរពង្រីកបន្ថែម នៅជាប់ផែដីគោក ព្រោះមានលក្ខណៈតូចចង្អៀតពិបាកក្នុងការចេញចូល និងធ្វើដំណើរ។

- បញ្ហាប្រឈមសព្វថ្ងៃគឺបញ្ហាដែននេសាទ ខ្ញុំសូមឲ្យក្រុមហ៊ុនដាក់តំបន់ការពារតែចំងាយ ១០០ម៉ែត្រចេញពីកោះបានហើយ ព្រោះទុកកន្លែងសម្រាប់ឲ្យនេសាទលក្ខណៈគ្រួសារ និងទេសចរណ៍។ មួយវិញទៀត ក៏សូមឲ្យក្រុមហ៊ុនអនុញ្ញាតឲ្យប្រជានេសាទ អាចចូលចតទូកបាននៅពេលមានខ្យល់ព្យុះ។
- ជាចុងក្រោយខ្ញុំក៏សូមគាំទ្រ និងលើកទឹកចិត្តដល់គម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីនេះ ព្រោះក្រុមហ៊ុនបានខិតខំប្រឹងប្រែងពុះពារក្នុងការសាងសង់។ ហើយការអភិវឌ្ឍន៍ក៏បានស្រូបយកកំលាំងពលកម្មក្នុងឃុំរាម និងពីតំបន់ដ៏ទៃទៀតបានច្រើន ដែលអាចលើកស្ទួយវិស័យទេសចរណ៍ជាតិនៅថ្ងៃអនាគត។

### ៦.៤.២ មតិ យោបល់របស់លោកមេភូមិរាម

លោក **ខូ ឈាខ** ភេទប្រុស មានអាយុ ៥៩ឆ្នាំ មានតួនាទីជាប្រធានភូមិរាម បានផ្តល់បទសម្ភាសន៍ និងមតិយោបល់ទាក់ទងនឹងគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីដូចខាងក្រោម៖

- ខ្ញុំមានការសប្បាយរីករាយណាស់ ដែលមានក្រុមហ៊ុន**អភីប៊ី** បានមកអភិវឌ្ឍន៍ជារមណីយដ្ឋាននៅក្នុងកោះក្របីនេះ។ បច្ចុប្បន្ននេះឃើញថាគម្រោងអភិវឌ្ឍន៍នេះបានស្រូបយកកំលាំងពលកម្មក្នុងភូមិខ្ញុំបានប្រហែល១០%ផងដែរ។
- ការអភិវឌ្ឍន៍នេះ ពិតជាមិនបានធ្វើឲ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ប្រជាជនក្នុងភូមិរបស់ខ្ញុំទេ ព្រោះនេះជាគម្រោងអភិវឌ្ឍន៍នៅលើកោះមិនមានប្រជាជនរស់នៅ ហើយម៉្យាងទៀតប្រជាជននៅក្នុងភូមិខ្ញុំមិនទៅនេសាទនៅក្បែរតំបន់នោះទេ គឺគាត់ទៅនេសាទនៅព្រែកទឹកសាប។
- តែយ៉ាងណាមិញ អំពីបញ្ហាដែននេសាទ ខ្ញុំសូមផ្តល់អនុសាសន៍ដល់ក្រុមហ៊ុនអភិវឌ្ឍន៍ដាក់ពោងបណ្តែត ធ្វើជាព្រំដែនកំណត់របស់ខ្លួនដើម្បីឲ្យប្រជានេសាទបានដឹងអំពីដែនដែលគាត់មិនអាចចូលនេសាទបាន។
- ចំពោះបញ្ហាការអភិវឌ្ឍន៍នៅក៏សូមស្នើក្រុមហ៊ុនចេះស្រលាញ់ធម្មជាតិ កុំកាប់បំផ្លាញឈូសឆាយបង្កឲ្យមានការបំពុល។
- ជាចុងក្រោយខ្ញុំក៏សូមគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍នេះ ព្រោះការអភិវឌ្ឍន៍នឹងធ្វើឲ្យមានការរីកចំរើន។

### ៦.៤.៣ មតិ យោបល់របស់លោកមេភូមិស្ពាន់ដែង

លោក **ហាក់ ផន** ភេទប្រុស មានអាយុ ៦៦ឆ្នាំ មានតួនាទីជាប្រធានភូមិស្ពាន់ដែង បានផ្តល់បទសម្ភាសន៍ និងមតិយោបល់ទាក់ទងនឹងគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីដូចខាងក្រោម៖

- សម្រាប់ភូមិខ្ញុំក៏មានការសប្បាយរីករាយ និងធ្វើការគាំទ្រទៅលើការអភិវឌ្ឍន៍គម្រោងនេះដែរ ព្រោះប្រជាជនក្នុងខ្ញុំក៏បានចូលទៅធ្វើការងារសំណង់នៅលើកោះក្របីនេះដែរ ដែលចំនួនអ្នកធ្វើការនេះមានប្រហែល១០%ផងដែរ។
- ក្តីសង្ឃឹមរបស់ខ្ញុំ សង្ឃឹមថានៅពេលគម្រោងដំណើរការអាចមានភ្ញៀវទេសចរណ៍ចេញចូលក្នុងតំបន់នេះ ធ្វើឲ្យសកម្មភាពទេសចរមានការរីកចំរើន ដែលប្រជាជនអាចប្រកបរបរ លក់ដូរដាច់ជាងមុន។
- ទន្ទឹមនឹងនេះដែរខ្ញុំក៏សូមឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ ធ្វើការគ្រប់គ្រងសំណល់រឹង-រាវឲ្យបានត្រឹមត្រូវ និងអភិរក្សធនធានធម្មជាតិឲ្យបានប្រសើរជាងមុន។

### ៦.៤.៤ មតិ យោបល់របស់លោកមេភូមិថ្មធំ

លោក **ពិន តាខ** ភេទប្រុស មានអាយុ ៧៦ឆ្នាំ មានតួនាទីជាប្រធានភូមិថ្មធំ បានផ្តល់បទសម្ភាសន៍ និងមតិយោបល់ទាក់ទងនឹងគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីដូចខាងក្រោម៖

- សម្រាប់ភូមិខ្ញុំក៏មិនខុសពីភូមិដទៃដែរ វត្តមាននៃគម្រោងអភិវឌ្ឍន៍កោះក្របីនេះ បានផ្តល់ការងារជូនប្រជាពលរដ្ឋក្នុងភូមិខ្ញុំ ឃុំរាមទាំងមូល និងតំបន់ដទៃជាច្រើនទៀត។ ចំនួនប្រជាពលរដ្ឋក្នុងភូមិខ្ញុំបានចូលធ្វើការងារសំណង់ប្រហែល១០%ផងដែរ ដែលកម្មករមិនមានជំនាញអាចទទួលបាន ៧ដុល្លាក្នុងមួយថ្ងៃ កម្មករមានជំនាញអាចទទួលបាន១០ដុល្លាក្នុងមួយថ្ងៃ និងមេជាង១៥ដុល្លាក្នុងមួយថ្ងៃ។
- ចំពោះបញ្ហាការគ្រប់គ្រងធនធានធម្មជាតិ ក៏ដូចជាគ្រប់គ្រងការបំពុលឃើញថា មានលក្ខណៈល្អប្រសើរ បើតាមពត៌មានពីកម្មករ។ កម្មករដែលធ្វើនៅលើកោះនោះ បានឲ្យដឹងថា ក្រុមហ៊ុនអភិវឌ្ឍន៍បានហាមឃាត់មិនឲ្យកម្មករកាប់បំផ្លាញព្រៃឈើ និងមិនចោលសំរាមពាលវាលពាសកាលទេ បើសិនជាមានកម្មករល្មើសនឹងត្រូវផាកពិន័យ។
- សម្រាប់ភូមិខ្ញុំផ្ទាល់មិនមានប្រជានេសាទ ដែលទៅនេសាទនៅក្បែរតំបន់គម្រោងនេះដែរ តែខ្ញុំសូមស្នើរសុំឲ្យម្ចាស់គម្រោងដាក់ពោងបណ្តែតជាដែនព្រំរបស់ខ្លួនដែលផ្តល់ភាពងាយស្រួលដល់ប្រជានេសាទបានដឹងពីទីតាំងហាមឃាត់។

- ជាចុងក្រោយខ្ញុំសូមគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍នេះ និងសូមលើកទឹកចិត្តដល់ក្រុមហ៊ុនដែលខិតខំពុះពារគ្រប់ឧបសគ្គក្នុងការអភិវឌ្ឍន៍។

៦.៤.៥ មតិ យោបល់របស់លោកមេភូមិអុង

លោក **គង់ ម៉ុនទ្រី** ភេទប្រុស មានអាយុ ៦៣ឆ្នាំ មានតួនាទីជាប្រធានភូមិអុង បានផ្តល់បទសម្ភាសន៍ និងមតិយោបល់ទាក់ទងនឹងគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីដូចខាងក្រោម៖

- សម្រាប់ភូមិខ្ញុំគឺជាភូមិដែលពាក់ព័ន្ធជាមួយគម្រោងអភិវឌ្ឍន៍នេះច្រើន ព្រោះប្រជាពលរដ្ឋក្នុងភូមិរបស់ខ្ញុំប្រកបរបរជាអ្នកនេសាទប្រមាណ៦០%ដែលការនេសាទនេះមានលក្ខណៈជាគ្រួសារភាគច្រើនតែប៉ុណ្ណោះ។
- បច្ចុប្បន្នការនេសាទរបស់ប្រជាជននៅមានលក្ខណៈធម្មតា មិនទាន់មានការហាមឃាត់ពីសំណាក់ក្រុមហ៊ុនអភិវឌ្ឍន៍កោះក្របីនេះនៅឡើយទេ។ តែទោះជាយ៉ាងណាខ្ញុំក៏សូមស្នើសុំឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ដាក់ពោងបណ្តែតជាសញ្ញាណ និងជាដែនការពាររបស់ខ្លួនក្នុងចំងាយ១០០ម៉ែត្រពីកោះបានហើយ។ ហេតុផលដែលខ្ញុំស្នើសុំចំងាយ១០០ម៉ែត្រនោះ ព្រោះកោះទាំងអស់នឹងមានកាអភិវឌ្ឍន៍ជារមណីយដ្ឋានទាំងអស់នៅថ្ងៃអនាគត បើកោះនីមួយៗយកចំងាយចេញពីកោះច្រើនពេក នោះប្រជានេសាទនឹងអស់ដែននេសាទជាមិនខាន។
- ចំពោះស្ថានភាពទូទៅនៃការនេសាទលក្ខណៈគ្រួសារបច្ចុប្បន្នឃើញថា មានការកើនឡើងជាងមុន ដោយសារក្រុមហ៊ុនអភិវឌ្ឍន៍បានចូលរួមថែរក្សា អភិរក្ស និងការនេសាទខុសច្បាប់ត្រូវបានលុបបំបាត់។
- ភូមិខ្ញុំក៏មិនខុសពីភូមិដ៏ទៃដែរ ប្រជាជនក្នុងភូមិខ្ញុំបានចូលធ្វើការងារសំណង់នៅលើកោះក្របីនេះ ប្រហែល១០%ផងដែរ ដែលតំលៃកំលាំងពលកម្មសមរម្យអាចទទួលយកបាន។
- ជាចុងក្រោយខ្ញុំសូមធ្វើការគាំទ្រទៅលើគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីនេះ និងលើកទឹកចិត្តដែលបានជំនះការលំបាកក្នុងការអភិវឌ្ឍន៍។ ហើយខ្ញុំក៏សូមស្នើសុំឲ្យក្រុមហ៊ុននៅពេលដំណើរការគម្រោង សូមជួយទិញផលនេសាទ និងបន្លែធម្មជាតិនៅភូមិខ្ញុំផង។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៦.៨៖ ការជួបសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាននៅសាលាឃុំរាម

#322P, St.271Z, Sk.Tark Tla, Khan Resey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

## ៦.៥៖ ការផ្សព្វផ្សាយអំពីគម្រោង និងពិគ្រោះយោបល់ជាមួយប្រជាជនមូលដ្ឋាន

កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ វេលាម៉ោង ៣:០០ដល់ម៉ោង ៥:០០ល្ងាច នៅក្នុងភូមិអុង ក្រុមការងារ គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ បានជួបប្រជុំសំណេះសំណាលផ្ទាល់ជាមួយប្រជានេសាទដែលតែងតែទៅនេសាទនៅតំបន់ប្រជុំកោះតាគៀវ។ ការជួបប្រជុំនេះមានការចូលរួមពីលោកមេភូមិអុងនិងប្រជានេសាទចំនួន១៨គ្រួសារ។

តាមរយៈទិន្នន័យពីលោកមេភូមិអុងបានឲ្យដឹងថា ប្រជាពលរដ្ឋសរុបមានចំនួន២៧៧គ្រួសារ ដែលក្នុងនោះមានប្រជាជនប្រកបមុខរបរជាប្រជានេសាទចំនួន១០០គ្រួសារ ហើយភាគច្រើនគាត់នេសាទជាលក្ខណៈគ្រួសារប៉ុណ្ណោះ។ការចូលរួមពិភាក្សា និងពិគ្រោះយោបល់ចំនួនប្រជានេសាទចូលរួមចំនួន១៨គ្រួសារ ដែលមានបុរសចូលរួមចំនួន៩នាក់ និងស្ត្រី១១នាក់។ ការពិភាក្សានេះមានសំនួរ និងមតិយោបល់ដូចខាងក្រោម៖

**សំណួរទី១៖** តើប្រជាជនក្នុងភូមិអុងធ្លាប់បានដឹង និងលឺអំពីគម្រោងអភិវឌ្ឍន៍កោះក្របីដែរ ឬទេ?

**ចំលើយទី១៖** មានប្រជាជនប្រហែល៧០%បានឆ្លើយថា គាត់ធ្លាប់បានដឹង និងលឺអំពីគម្រោងអភិវឌ្ឍន៍កោះក្របីនេះ និងមានប្រជាជនប្រហែល៣០%មិនធ្លាប់បានដឹងលឺអំពីគម្រោងអភិវឌ្ឍន៍កោះក្របីនេះ។ ប្រជាជនដែលឆ្លើយថាធ្លាប់បានដឹងលឺអំពីគម្រោងអភិវឌ្ឍន៍នេះ ធ្លាប់មានក្រុមការងារចុះសំភាសន៍ និងផ្សព្វផ្សាយអំពីគម្រោងអភិវឌ្ឍន៍នេះម្តងរួចទៅហើយ ម៉្យាងទៀតក៏មានបងប្អូនកូនក្មួយរបស់ពួកគាត់បានទៅធ្វើការងារសំណង់នៅលើកោះនោះ។ ចំណែកប្រជាជនដែលឆ្លើយថា មិនធ្លាប់បានដឹងលឺអំពីគម្រោងអភិវឌ្ឍន៍នេះ ព្រោះគាត់ឃើញតែគេចេញចូលសាងសង់ តែគេកំពុងធ្វើអ្វីគាត់មិនបានឃើញ និងមិនដឹង។

**សំណួរទី២៖** តើក្រុមហ៊ុនអភិវឌ្ឍន៍បានហាមឃាត់ប្រជានេសាទមិនឲ្យនេសាទទេ?

**ចំលើយទី២៖** ប្រជាជន១០០%បានឆ្លើយថា ក្រុមហ៊ុនមិនធ្លាប់បានហាមឃាត់ប្រជានេសាទក្នុងការនេសាទទេ តែប្រជាជនខ្លួនឯងដែល មិនហ៊ានចូលនេសាទនៅជិតកោះនោះ ម៉្យាងទៀតជាធម្មតានៅក្បែរកោះក៏មិនសូវមានត្រីរស់នៅដែរ។

**សំណួរទី៣៖** តើមុនពេលក្រុមហ៊ុនអភីប៊ីចូលមកអភិវឌ្ឍន៍តើប្រជាពលរដ្ឋដែលទៅរកអនុផលព្រៃឈើដែរឬទេ?

**ចំលើយទី៣៖**មុនពេលក្រុមហ៊ុនចូលមកអភិវឌ្ឍន៍ ប្រជាជនធ្លាប់បានទៅកាប់ឈើធ្វើអុស រកផ្តៅ និងចូលចតទូកនៅពេលមានព្យុះភ្លៀង។ បច្ចុប្បន្នប្រជានេសាទនៅតែអាចចូលចតទូកបានដោយមិនការហាមឃាត់ពីក្រុមហ៊ុនោះឡើយ ប៉ុន្តែក្តីព្រួយបារម្ភរបស់ពួកគាត់នៅពេលក្រុមហ៊ុន

សាងសង់រួចរាល់ ដាក់ដំណើរការគម្រោង ក្រុមហ៊ុនអាចមិនអនុញ្ញាតឲ្យពួកគាត់បានចូលជ្រក នៅពេលមានព្យុះភ្លៀង។

**សំណួរទី៨៖** តើប្រជាពលរដ្ឋចង់ឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ទុកចំងាយប៉ុន្មានម៉ែត្រចេញពីកោះ ទុកជាតំបន់ការពារ?

**ចំលើយទី៨៖**ប្រជាជន១០០% បានស្នើរសុំឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ទុកគម្លាតចេញពីកោះត្រឹម១០០ ម៉ែត្របានហើយព្រោះបើក្រុមហ៊ុនអភិវឌ្ឍន៍កោះទាំងអស់ទុកគម្លាតឆ្ងាយគ្រប់កោះទាំងអស់នោះ ប្រជានេសាទនឹងបាត់បង់ដែននេសាទ។

**សំណួរទី៨៖** តើមានបងប្អូនសាច់ញាតិបានទៅធ្វើការការងារសំណង់នៅលើកោះក្របីនេះដែរ ឬទេ?

**ចំលើយទី៨៖**ក្នុងចំណោមប្រជាជន២នាក់មានប្រជាជន៣នាក់បានឆ្លើយថាមានសាច់ញាតិបាន ទៅធ្វើការងារសំណង់នៅលើកោះក្របីនោះ។ បងប្រុសម្នាក់បានឲ្យដឹងថាកាត់មានកូនស្រីគាត់ បានទៅធ្វើការជាអ្នកសំអាតនៅលើកោះក្របីនោះ។ ចំណែកឯបងស្រីម្នាក់ទៀតបានឲ្យដឹងថា គាត់មានក្មួយប្រុសបានទៅធ្វើកម្មករសំណង់នៅលើកោះនោះដែរ។

**សំណួរទី៥៖** តើប្រជាពលរដ្ឋគាំទ្រលើគម្រោងអភិវឌ្ឍន៍កោះក្របីនេះដែរ ឬទេ?

**ចំលើយទី៥៖** ប្រជាពលរដ្ឋបានលើកដៃគាំទ្រគម្រោងអភិវឌ្ឍន៍នេះទាំងអស់គ្នា ស្មើនឹង១០០%។

**សំណួរទី៦៖** តើប្រជាពលរដ្ឋសំណូមពរអ្វីដល់រាជរដ្ឋាភិបាល និងក្រុមហ៊ុនអភិវឌ្ឍន៍?

**ចំលើយទី៦៖**ជាចុងក្រោយប្រជាពលរដ្ឋទាំងអស់ សូមស្នើរសុំឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលកំណត់ដែននេសាទត្រឹមតែ១០០ម៉ែត្រចេញពីកោះបានហើយ និងប្រជានេសាទនៅតែ អាចចូលចតទូកបាននៅពេលមានព្យុះភ្លៀង។ ម៉្យាងទៀតក៏សូមស្នើរសុំឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ ជ្រើសរើសបុគ្គលិកធ្វើការងារនៅលើកោះនេះផងដែរ។





រូបភាព៦.៩៖ ការជួបសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយប្រជាជនក្នុងភូមិអុង

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

## តារាង ៦.២ សេចក្តីសង្ខេបយោបល់ និងសំណូមពរ

| ល.រ | ឈ្មោះ | តួនាទី | គាំទ្រការអភិវឌ្ឍន៍ | មិនគាំទ្រការអភិវឌ្ឍន៍ | មតិយោបល់/អនុសាសន៍ |
|---|---|---|---|---|---|
| ១ | ឯកឧត្តម ឈិត សុខុន | អភិបាលខេត្តព្រះសីហនុ | ✓ | | ខេត្តព្រះសីហនុពិតជាមានមោតនភាពណាស់ដែលបានក្រុមហ៊ុនRPB Investment Co., Ltd បានមកវិនិយោគទុន ដោយបង្កើតជារមណីយដ្ឋានធម្មជាតិ ហើយខ្ញុំក៏សូមលើកទឹកចិត្ត និងគាំទ្រដល់ការអភិវឌ្ឍន៍នេះប្រព្រឹត្តទៅបានយ៉ាងរលូននិងប្រសើរមុននឹងដាក់ដំណើរគម្រោងនៅថ្ងៃខាងមុខ។យ៉ាងណាមិញ ការអភិវឌ្ឍន៍នេះក៏អាចមានផលប៉ះពាល់ទៅលើធនធានធម្មជាតិ ដែលមានស្រាប់ក្នុង និងជុំវិញកោះក្របីនេះផងដែរ ដូចជាអាចបង្កឲ្យមានការបំពុលទឹក ខ្យល់ ធនធានព្រៃ ផ្កាថ្ម និងធនធានសមុទ្រផ្សេងៗទៀតតាមរយៈសកម្មភាពសាងសង់របស់ក្រុមហ៊ុន។ ហេតុដូចនេះក្នុងនាមខ្ញុំជាអាជ្ញាធរខេត្ត សូមផ្ញើរសារដល់ម្ចាស់គម្រោងអនុវត្តទៅតាមកិច្ចសន្យាក្នុងការអភិវឌ្ឍន៍ គោរពទៅប្លង់មេ និងប្រើប្រាស់វិធានការកាត់បន្ថយផលប៉ះពាល់ទៅលើបរិស្ថាន ប្រកបដោយប្រសិទ្ធភាព។ |
| ២ | លោក សំគល់ | អនុប្រធានមន្ទីរបរិស្ថានខេត្តព្រះសីហនុ | ✓ | | គាត់បានសរសើរ និងលើកទឹកចិត្តដល់គម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី ព្រោះគម្រោងអភិវឌ្ឍន៍នេះមានការគិតគូរទៅលើការអភិរក្សបរិស្ថាន ជាពិសេសគម្រោងបានអភិរក្សព្រៃឈើបាន៨០%។ ចំពោះការអភិវឌ្ឍន៍កំពុងផែមិនស្ថិតនៅក្នុងដីឧទ្យានជាតិរាមទេ ហើយក៏មិនប៉ះពាល់ដល់ឧទ្យានជាតិរាមដែរ។ គាត់បានធ្វើការគាំទ្រទៅលើគម្រោងអភិវឌ្ឍន៍នេះ ហើយជាចុងក្រោយគាត់ក៏មានសំណូមពរដល់ក្រុមហ៊ុន សូមធ្វើការគ្រប់គ្រងសំណល់រឹង-រាវរបស់ខ្លួនឲ្យបានត្រឹមត្រូវ |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| | | | | | |
|---|---|---|---|---|---|
| | | | | | នៅពេលដំណើរការគម្រោង។ |
| ៣ | -លោកស្រី អ៊ឹម ចន្ថា<br>-លោក ម៉េង ស៊ីសូវង្ស<br>-លោក អឿ វិបុល | - អនុប្រធានមន្ទីរទេសចរណ៍<br>- អនុប្រធានមន្ទីរទេសចរណ៍<br>- ប្រធានការិយាល័យ អេកូទេសចរណ៍ | ✓ | | គាត់គិតថាគម្រោងអភិវឌ្ឍន៍កោះក្របីបានផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងឃុំរាមតាមរយៈវិស័យទេសចរណ៍ដូចជា៖ (១) លក់បន្លែ ផ្លែឈើ និងផលនេសាទជូនក្រុមហ៊ុន ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ។ (២)លក់កំលាំងពលកម្ម និងជម្រើសការងារផ្សេងៗ។ គាត់បានធ្វើការគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍កោះក្របីព្រោះគាត់គិតថា គម្រោងអភិវឌ្ឍន៍នេះអាចជួយអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការរីកចំរើន។ ចុងក្រោយគាត់ក៏មានសំណូមពរដល់ក្រុមហ៊ុនអភិវឌ្ឍន៍ សូមឲ្យមានការគោរពច្បាប់ទេសចរណ៍ និងគោរពច្បាប់បរិស្ថាន និងសូមឲ្យមានបង្គន់សាធារណៈឲ្យបានគ្រប់គ្រាន់។ |
| ៤ | លោក ថាវ៉ារុធ | អនុប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូន ខេត្តព្រះសីហនុ | ✓ | | គាត់មានប្រសាសន៍ថាពល់គម្រោងសាងសង់នៅលើកោះមានការលំបាកណាស់ទាំងការដឹកជញ្ជូនសម្ភារៈសំណង់ និងប្រភពទឹកប្រើប្រាស់ ហេតុដូច្នេះគាត់សូមសរសើរ និងលើកទឹកចិត្តចំពោះក្រុមហ៊ុនអភិវឌ្ឍន៍អភិវឌ្ឍន៍កោះក្របីនេះ ដែលមានឆន្ទះក្នុងការអភិវឌ្ឍន៍ពិតប្រាកដ។ ចំពោះការសាងសង់ផែដីគោក ឃើញថាមានលក្ខណៈជាប់ផ្លូវ ហេតុដូចនេះ ក្រុមហ៊ុនគួរបើកផ្លូវបន្ថែមទទឹង៨ម៉ែត្រ និងបណ្តោយ២០០ម៉ែត្រក្បែរផែនេះ ដើម្បីសម្រួលក្នុងការធ្វើដំណើរចេញចូល។ ចុងក្រោយគាត់ធ្វើការគាំទ្រទៅលើការអភិវឌ្ឍន៍នេះ ហើយក៏មានសំណូមពរមួយចំនួនដល់ក្រុមហ៊ុន ឲ្យមានការគ្រប់គ្រងសំណល់របស់ខ្លួនកុំឲ្យមានការបំពុល។ |

| | | | | | |
|---|---|---|---|---|---|
| ៥ | លោក ឃី សៅរ៉េត | ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ | ✓ | | គាត់មានប្រសាសន៍ថា គម្រោងអភិវឌ្ឍន៍កោះក្របីនេះ បានចុះបញ្ជីរ និងស្នើរសុំការអនុញ្ញាតសាងសង់បានត្រឹមត្រូវពីមន្ទីររៀបចំដែនដី។ យ៉ាងណាវិញចំពោះគម្រោងប្លង់សាងសង់ ក្រុមហ៊ុនអភិវឌ្ឍន៍គួរតែរចនាប្លង់ដោយអនុលោមទៅតាមផែនការមេ ដែលប្រគល់ជូនក្រសួងរៀបចំដែនដី និងក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា។ ចុងក្រោយគាត់ក៏មានការគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីនេះ និងមានសំណូមពរដល់ក្រុមហ៊ុនវិនិយោគឲ្យគោរពទៅតាមសាវាចរណ៍០១ កំណត់ខ្សែទឹកចូល និងគម្លាតដោយពិចារណាទៅលើគម្រងព្រៃ សួនបៃតង កំពង់ផែ ជាពិសេសការគ្រប់គ្រងសំណល់រឹង-រាវ។ |
| ៦ | លោក ស៊ិន សត្ថារតន៍ | អភិបាលរងខណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ | ✓ | | គាត់មានប្រសាសន៍ថា គម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី បានផ្តល់ផលប្រយោជន៍សំខាន់២គឺ៖ (១) ក្រុមហ៊ុនអភិវឌ្ឍន៍នឹងមានការអភិរក្សា និងថែរក្សាធនធានធម្មជាតិដែលមានស្រាប់នៅក្នុងតំបន់ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍។ (២) អាចជួយឲ្យសេដ្ឋកិច្ចកម្ពុជាមានការអភិវឌ្ឍន៍ តាមរយៈការផ្តល់ការងារ។ យ៉ាងណាមិញ ការអភិវឌ្ឍន៍នេះក៏មានការមិនពេញចិត្តពីប្រជានេសាទមួយចំនួន និងភ្ញៀវទេសចរណ៍ផងដែរ ព្រោះគាត់ខ្លាចបាត់បង់ដែននេសាទ បើតាមយោបល់គាត់ផ្ទាល់សូមឲ្យ ក្រុមហ៊ុនវិនិយោគទុកចំងាយចេញពីកោះតែ១០០ម៉ែត្របានហើយ។ គាត់បានសម្តែងការគាំទ្រចំពោះការអភិវឌ្ឍន៍នេះ ហើយជាចុងក្រោយគាត់ក៏មានសំណូមពរឲ្យក្រុមហ៊ុនវិនិយោគធ្វើការវេចខ្ចប់ដឹកជញ្ជូនឲ្យបានត្រឹមត្រូវ នឹងដាក់ពោងបណ្តែតកំណត់ព្រំត្រឹម១០០ម៉ែត្រ។ |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| | | | | | |
|---|---|---|---|---|---|
| ៧ | លោក ឌី សុភី | អភិបាលរងខណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុ | ✓ | | គាត់មានប្រសាសន៍វត្តមាននៃគម្រោងអភិវឌ្ឍន៍នេះ ផ្តល់ភាពប្រសើរឡើងសម្រាប់ធនធានធម្មជាតិ ព្រោះមុនគម្រោងអភិវឌ្ឍន៍ព្រៃឈើនៅលើកោះនេះបានក្លាយជាព្រៃរិចរិល គាត់សង្ឃឹមថាក្រោយពេលអភិវឌ្ឍន៍ក្រុមហ៊ុននឹងធ្វើការអភិរក្សព្រៃឈើសដើម្បីទាក់ទាញភ្ញៀវទេសចរណ៍។ ជាចុងក្រោយគាត់បានគាំទ្រចំពោះការអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីនេះ និងមានសំណូមពរដល់ក្រុមហ៊ុនអភិវឌ្ឍន៍អនុវត្តទៅតាមការសម្រេចព្រមព្រៀងរបស់រដ្ឋាភិបាល ចំណែកក្រុមហ៊ុនប្រឹក្សាគួរផ្តល់មតិណែនាំ វិភាគឲ្យបានល្អិតល្អន់ និងផ្តល់ពត៌មានឲ្យបានច្បាស់លាស់។ |
| ៨ | លោក លិល សារិន | ប្រធានឃុំរាម | ✓ | | លោកមេឃុំបានរៀបរាប់ពីប្រវត្តិកោះក្របី ដែលជាកោះទុកចោលមិនមានប្រជាជនរស់នៅ ព្រោះជាកោះតូចមួយមានចំណោតខ្លាំង មិនមានប្រភពទឹកសាបសម្រាប់ប្រើប្រាស់។ វត្តមាននៃគម្រោងអភិវឌ្ឍន៍កោះក្របីនេះ បានស្រូបយកកំលាំងពលកម្មពីឃុំរាម និងតំបន់ដទៃ ដែលជាផ្នែកមួយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ គាត់ធ្លាប់បានចុះដល់ការដ្ឋានសាងសង់កោះក្របីនេះ ហើយធ្វើការកោតសរសើរចំពោះក្រុមហ៊ុនមានឆន្ទៈក្នុងការអភិវឌ្ឍន៍ពិតប្រាកដ ហើយក្រុមហ៊ុននេះបានរក្សាទុកព្រៃ ដោយបញ្ចៀសរាល់ការកាប់ព្រៃ និងគិតគូរទៅលើបញ្ហាបរិស្ថាន។ ចុងក្រោយគាត់ក៏បានធ្វើការគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍នេះ។ |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| | | | | | |
|---|---|---|---|---|---|
| ៩ | លោក ងូ ឈាង | ប្រធានភូមិរាម | ✓ | | គាត់មានតែពាក្យសរសើរ និងគ្រេកអរដែលក្រុមហ៊ុនអភីប៊ីបានមកបោះទុនវិនិយោគ នៅលើកោះក្របី ព្រោះវត្តមាននៃគម្រោងនេះបានស្រូបយកកំលាំងពលកម្មក្នុងភូមិរបស់គាត់បាន១០%។ គម្រោងអភិវឌ្ឍន៍នេះក៏មិនបានធ្វើឲ្យមានការប៉ះពាល់ដល់មុខរបរប្រជាជនក្នុងភូមិរបស់គាត់ទេ។ ចុងក្រោយគាត់បានធ្វើការគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍ និងមានសំណូមពរដល់ក្រុមហ៊ុនវិនិយោគ ឲ្យមានការកំណត់ដែនទឹករបស់ខ្លួនឲ្យបានច្បាស់លាស់ និងចេះស្រលាញ់ធម្មជាតិកុំឲ្យមានការបំផ្លិចបំផ្លាញ។ |
| ១០ | លោក ហាក់ ផន | មេភូមិស្នាច់ដែង | ✓ | | លោកមេភូមិស្នាច់ដែងក៏មានតែពាក្យសរសើរ និងគាំទ្រចំពោះការអភិវឌ្ឍន៍រមណីយដ្ឋាននៅលើកោះក្របីនេះ ព្រោះវត្តមានគម្រោងអភិវឌ្ឍន៍មិនបានធ្វើឲ្យមានការប៉ះពាល់ដល់ប្រជាជនក្នុងភូមិរបស់គាត់ទេ តែថែមទាំងបានផ្តល់ការងារដល់ប្រជាជនក្នុងភូមិរបស់គាត់បានប្រហែល១០%។ |
| ១១ | លោក ពិន ភាង | មេភូមិថ្មធំ | ✓ | | សម្រាប់ភូមិរបស់គាត់មានតែពាក្យសរសើរ លើកទឹកចិត្ត និងការគាំទ្រចំពោះការអភិវឌ្ឍន៍ ព្រោះក្រុមហ៊ុនវិនិយោគនេះបានស្រូបយកកំលាំងពលកម្មក្នុងភូមិគាត់បានប្រហែល១០%ផងដែរ។ ក្រុមហ៊ុននេះពិតជាមានការស្រលាញ់ធម្មជាតិ ព្រោះគាត់បានហាមឃាត់កម្មករមិនឲ្យមានការកាប់បំផ្លាញ។ ចុងក្រោយគាត់ក៏បានស្នើរសុំក្រុមហ៊ុនគួរមានការកំណត់ព្រំដែនទឹករបស់ខ្លួនដោយដាក់ពោងបណ្តែតជាសញ្ញា។ |

| | | | | | |
|---|---|---|---|---|---|
| ១២ | លោក គង់ ប៊ុនទ្រី | មេភូមិអុង | ✓ | | គាត់មានប្រសាសន៍ថាភូមិរបស់គាត់ជាភូមិដែលមានការពាក់ព័ន្ធ ជាមួយគម្រោងអភិវឌ្ឍន៍មេណីយដ្ឋានកោះក្របីនេះ ព្រោះភូមិគាត់មានទីតាំងជិតសមុទ្រ ហើយប្រជាជនប្រមាណ៦០% ប្រកបមុខរបរជាអ្នកនេសាទ។ បច្ចុប្បន្នប្រជានេសាទនៅក្នុងភូមិរបស់គាត់នៅតែនេសាទបានធម្មតា តែពួកគាត់បានព្រួយបារម្ភថា នៅពេលគម្រោងអភិវឌ្ឍន៍នេះ ប្រតិបត្តិគម្រោងនឹងមានការហាមឃាត់ពួកគាត់មិនឲ្យនេសាទ និងចូលចតទូកនៅលើកោះ។តែទោះជាយ៉ាងណាគាត់បានធ្វើការគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍នេះ ព្រោះវត្តមាននៃគម្រោងនេះបានធ្វើការអភិក្សធនធានជលផល និងការនេសាទខុសច្បាប់ក៏ត្រូវបានលប់បំបាត់។ ចុងក្រោយគាត់ក៏មានសំណូមពរដល់ ម្ចាស់គម្រោងគួរដាក់ពោងបណ្តែតជាសញ្ញា ដែលជាដែននេសាទរបស់ខ្លួនក្នុងចំងាយ១០០ម៉ែត្រចេញពីកោះបានហើយ។ |

## ៦.៧ សេចក្តីសន្និដ្ឋានរួមលើលទ្ធផលពិគ្រោះយោបល់

តាមការពិគ្រោះយោបល់ដែលមានការចូលរួមពីសាលាខេត្តព្រះសីហនុ មន្ទីរពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាជនបានឱ្យដឹងថាគម្រោងអភិវឌ្ឍន៍**រមណីយដ្ឋានកោះក្របី**នេះ មានការគាំទ្រទាំងស្រុង ការសរសើរ និងការលើកទឹកចិត្តពីសំណាក់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាជន។ មូលហេតុដែលពួកគាត់ធ្វើការគាំទ្រ ព្រោះគាត់ពិតជាចង់ឲ្យកោះក្របីនេះក្លាយជារមណីយដ្ឋានមានភាពស្រស់ស្អាត អាចទាក់ទាញភ្ញៀវទេសចរបានកាន់តែច្រើន ដែលអាចលើកស្ទួយមុខមាត់ប្រទេសជាតិឲ្យកាន់តែរីកចំរើនដូចតាមបណ្តាប្រទេសលំដាប់អន្តរជាតិ។ ទន្ទឹមនឹងការគាំទ្រនេះ ក៏មានសំណូមពរមួយចំនួនទៅដល់ក្រុមហ៊ុនអភិវឌ្ឍន៍(**អឌីធី**)ផងដែរ ជាពិសេសទាក់ទងបញ្ហាការគ្រប់គ្រងសំណល់រឹង-រាវការប្រើប្រាស់ទឹក ការប្រើប្រាស់អគ្គិសនី និងប្រព័ន្ធការពារសុវត្ថិភាពជាដើម។ ពួកគាត់ក៏សំណូមពរឱ្យក្រុមហ៊ុនធ្វើការសាងសង់ទៅតាមប្លង់មេដែលបានកំណត់ ដោយធ្វើការកែប្រែតំបន់កោះក្របី ឱ្យក្លាយជារមណីយដ្ឋានបៃតង និងប្រកាន់ភ្ជាប់ការអភិវឌ្ឍន៍ជានិរន្តភាពជានិច្ច។

យ៉ាងណាមិញប្រជាជនភាគច្រើនសំដែងនូវការពេញចិត្តទៅនឹងគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីព្រោះពួកគាត់យល់ឃើញថា ការអភិវឌ្ឍន៍នេះនឹងអាចធ្វើប្រទេសកម្ពុជាមានភាពរីកចំរើន និងសម្បូរសប្បាយ និងជឿនលឿនផងដែរ។ ជាក់ស្តែងសព្វថ្ងៃ ប្រជាជននៅក្នុងឃុំរាម និងមកពីតំបន់ផ្សេងៗទៀតបានមកធ្វើការងារសំណង់នៅលើកោះក្របីនេះ ដែលទទួលបានតំលៃកំលាំងពលកម្មសមរម្យ។ នេះសរបញ្ជាក់ឲ្យឃើញថាវត្តមាននៃគម្រោងអភិវឌ្ឍន៍កោះក្របីនេះ បានធ្វើឲ្យជីវភាពប្រជាជនមានភាពប្រសើរជាងមុន។

យ៉ាងណាមិញ ក៏មានសំណូមពរពីសំណាក់អាជ្ញាធរមួយចំនួន និងប្រជាជន សូមឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ដាក់ពោងបណ្តែតជាសញ្ញា ដែលបង្ហាញពីដែនការពាររបស់ខ្លួន ក្នុងចំងាយចេញពីកោះ១០០ម៉ែត្របានហើយ ព្រោះគាត់ចង់ឲ្យមានដែននេសាទទូលំទូលាយសម្រាប់ប្រជានេសាទ និងសូមឲ្យក្រុមហ៊ុនមេត្តាអនុញ្ញាតឲ្យប្រជានេសាទបានចូលចតនៅពេលមានព្យុះភ្លៀង។ ម៉្យាងវិញទៀតក៏សូមស្នើរឲ្យក្រុមហ៊ុននៅពេលដំណើរការអាជីវកម្មគម្រោង មេត្តាជ្រើសរើសបុគ្គលិក និងទិញផលនេសាទ ផលដំណាំ បន្លែ ផ្លែឈើរបស់អ្នកភូមិក្នុងឃុំរាមជាចំបង។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី៧៖
# ហេតុប៉ះពាល់បរិស្ថាន និង
# វិធានការកាត់បន្ថយ

#322P, St.271Z, Sk.Tek Tla, Khan Rosey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី៧៖ ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

## ៧.១ សេចក្តីផ្តើម

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមពេញលេញនេះ គឺជាការសិក្សាដើម្បីកំណត់មើលហេតុផលនៃការប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមពេញលេញក្នុងរាល់ដំណាក់កាលនីមួយៗដូចជាដំណាក់កាលរចនាគម្រោង (Project Design) ដំណាក់កាលសាងសង់ (Project Construction) ដំណាក់កាលប្រតិបត្តិគម្រោង (Project Operation) និង ដំណាក់កាលបញ្ចប់គម្រោង (Project Finished)។ រាល់ហេតុប៉ះពាល់អវិជ្ជមានត្រូវរិះរកវិធានការកាត់បន្ថយយ៉ាងណាអោយដល់កំរិតអប្បបរមា និងធ្វើផែនការគ្រប់គ្រងបរិស្ថាននៃដំណាក់កាលទាំងនោះ ដោយមានការអនុវត្តពីម្ចាស់គម្រោង និងរួមកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័នជំនាញដែលពាក់ព័ន្ធក្នុងមូលដ្ឋាន និងដោយមានការត្រួតពិនិត្យតាមរយៈខ្សែបណ្តោយពីក្រសួងបរិស្ថាន និងក្រសួង/ស្ថាប័នពាក់ព័ន្ធ។

ក្នុងការវាយតំលៃនេះក្រុមការងារបានជ្រើសរើសយកតារាងបញ្ជីផ្ទៀងផ្ទាត់ (Checklist) និងតារាងម៉ាទ្រីក (Matrix) ដើម្បីកំណត់ទំហំនៃការប៉ះពាល់បរិស្ថានអវិជ្ជមានណាមួយដែលមានកំរិតតិច មធ្យម និងខ្លាំងមកធ្វើការវិភាគ ព្រមទាំងរៀបចំវិធានការកាត់បន្ថយហេតុប៉ះពាល់ទាំងនោះឲ្យដល់កម្រិតអប្បបរមា។

## ៧.៣ ការពិពណ៌នាហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គមអវិជ្ជមាន

ផ្ទៃដីគម្រោងដែលត្រូវអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របីគឺមានទំហំ១០ហិកតា។ ដោយផ្អែកទៅលើទំហំនៃសកម្មភាពរបស់គម្រោង និងការប្រើតារាងបញ្ជីផ្ទៀងផ្ទាត់(Checklist) ដែលអាចឱ្យយើងកំណត់នូវហេតុប៉ះពាល់បរិស្ថាន និងសង្គមមួយចំនួនដែលអាចកើតមានឡើងនៅក្នុងដំណាក់កាលមុនប្រតិបត្តិគម្រោង ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោង។

### ៧.៣.១ ដំណាក់កាលមុនប្រតិបត្តិគម្រោង

ក្នុងដំណាក់កាលនេះ រួមមានដំណាក់កាលរចនាគម្រោង និងដំណាក់កាលសាងសង់។ ដំណាក់កាលរចនាគម្រោង ជាដំណាក់កាលដំបូងដែលគម្រោងត្រូវបានពិចារណាគ្រប់ជ្រុងជ្រោយមុននឹងធ្វើការសាងសង់ដូចជា ការកំណត់ទីតាំងសំរាប់ធ្វើផ្លូវព័ទ្ធជុំវិញទីតាំងគម្រោង និង

ផ្ទះលំហែរកាយជាដើម។ សកម្មភាពទាំងនេះមិនមានឥទ្ធិពលប៉ះពាល់ទៅលើបរិស្ថានធម្មជាតិទេ។ ចំណែក ដំណាក់កាលសាងសង់វិញគឺមានសកម្មភាពមួយចំនួនដូចជា ការឈូសឆាយដីធ្វើផ្លូវ ផ្ទះលំហែកាយ កំពង់ផែទេសចរណ៍ ភោជនីយដ្ឋាន កន្លែងស្នាក់នៅរបស់កម្មករ ឃ្លាំង ការិយាល័យចំណតរថយន្តនៅលើដីគោក និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាទៀត។

សកម្មភាពសាងសង់នេះអាចបង្ករហេតុប៉ះពាល់ទៅលើធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសេដ្ឋកិច្ច-សង្គមមួយចំនួន ដូចខាងក្រោមៈ

### ៧.៣.១.១ ធនធានរូបសាស្ត្រ

ក. សណ្ឋានដី

នៅដំណាក់កាលនេះ ទ្រង់ទ្រាយសណ្ឋានដី និងឋានលេខានៅលើកោះនឹងត្រូវប្រែប្រួលដោយសារការឈូសឆាយដីទីទួល ឬដំបូកខ្ពស់ ដែលមានរយៈកម្ពស់ខ្ពស់ត្រឹម ៨៨ម៉ែត្រធៀបនឹងនីវ៉ូសមុទ្រ ដើម្បីពង្រាបដីឲ្យរាបស្មើ សំរាប់ធ្វើផ្លូវក្រវ៉ាត់ព័ទ្ធជុំវិញ ផ្ទះវីឡាចំនួន៨០ និងហេដ្ឋារចនាសម្ព័ន្ធនានាទៀតនៅក្នុងទីតាំងគម្រោង។ ការបំបែកយកផ្ទាំងថ្មនៅកន្លែងមួយចំនួន ដើម្បីរៀបចំគ្រឹះអគារ និងសំណង់រូបវន្តដទៃទៀតនៅលើកូនកោះក្របីនឹងធ្វើឲ្យផ្លាស់ប្តូរផ្ទៃដីធម្មជាតិផងដែរ។ លើសពីនេះទៀត ការឈូសឆាយដីនឹងបង្កឲ្យមានអាចម៍ដីរាយប៉ាយនៅក្នុងតំបន់គម្រោង។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុននឹងធ្វើការឈូសឆាយដីទៅតាមលក្ខណៈសណ្ឋានដី ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាក្នុងតំបន់គម្រោងដូចមានចែងក្នុងផែនការមេរបស់ក្រុមហ៊ុន ដោយមានការត្រួតពិនិត្យ និងវាយតំលៃយ៉ាងត្រឹមត្រូវពីមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បីកាត់បន្ថយនូវការប្រែប្រួលសណ្ឋានដីតំបន់គម្រោងអោយស្ថិតនៅកំរិតអប្បបរមា។
- ក្រុមហ៊ុននឹងសិក្សាពីប្លង់គម្រោងលំអិតជាមុនសិន មុននឹងធ្វើការឈូសឆាយសំរាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។ ក្រុមហ៊ុនមានផែនការជៀសវាងការបំបែកយកថ្មច្រើនពេក ឬការជីកយកដីជ្រៅហួសហេតុពេក ដោយក្រុមហ៊ុនមានការរៀបចំជាថ្នាក់ៗចំពោះការដ្ឋានសាងសង់មួយចំនួនដើម្បីកាត់បន្ថយការផ្លាស់ប្តូរសណ្ឋានដីភ្នំនេះ។
- ក្រុមហ៊ុនរៀបចំយកអាចម៍ដី ដែលបានមកពីការដ្ឋាននីមួយៗទៅចាក់បំពេញនៅតំបន់ទំនាប ឬកន្លែងដែលមានគ្រលុកធំនៅតំបន់ក្នុងតំបន់គម្រោង ដោយក្រុមហ៊ុនមិនទុកអាចម៍ដីទាំងនោះចោលឡើយ។

#322P, St.271Z, Sk.Terk Tla, Khan Rasey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ខ. ការហូរច្រោះដី /ការខូចគុណភាពដី

សកម្មភាពរបស់គម្រោងនៅក្នុងដំណាក់កាលនេះ អាចនាំអោយមានការហូរច្រោះដី និងខូចគុណភាពដី ដោយសារៈ

- ការឈូសឆាយរុក្ខជាតិគំរបដី ដើម្បីធ្វើផ្លូវព័ទ្ធជុំវិញ និងហេដ្ឋារចនាសម្ព័ន្ធនានារបស់គម្រោង បង្កអោយមានការបាក់ដី និងអាចមានការហូរច្រោះដីចូលទៅក្នុងសមុទ្រ ដោយសារតំបន់គម្រោងជាកូនកោះ និងមានរយៈកំពស់ខ្ពស់បំផុតត្រឹម ៤៨ម៉ែត្រ ធៀបនឹងនីវ៉ូសមុទ្រ។
- ការប្រើប្រាស់គ្រឿងចក្រសំរាប់គោលបំណងផ្សេងៗរបស់គម្រោង បានចូលរួមធ្វើអោយប៉ះពាល់គុណភាពដី ដោយសារការហៀរកំពប់ ការទុកដាក់ ឬច្រាលចោលប្រេងម៉ាស៊ីនចាស់ ទៅលើដី និងការហូរនាំនូវសារធាតុទាំងនោះតាមទឹកភ្លៀងទៅតំបន់ក្បែរៗនោះ។
- ការបង្កឡើងដោយបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ក្នុងការទុកដាក់/ការចោលនូវសំណល់ប្រេង-ខ្លាញ់ សំបក កំប៉ុង ប្រេងម៉ាស៊ីន សំណល់ផ្ទះបាយ និងសំណល់ផ្សេងៗទៀតក្បែរបរិវេណការដ្ឋាន ក៏នឹងធ្វើអោយមានការខូចគុណភាពដីផងដែរ ប្រសិនបើ ក្រុមហ៊ុនមិនបានធ្វើការគ្រប់គ្រងឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុន និងអ្នកម៉ៅការធ្វើការឈូសឆាយដី ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធទៅតាមផែនការមេ ដោយជៀសវាងអោយបាននូវការឈូសឆាយនៅតំបន់ដែលមានលក្ខណៈទីជំរាលខ្លាំង។
- ក្រុមហ៊ុន និងអ្នកម៉ៅការធ្វើឲ្យបង្ហាប់ដី ដើម្បីកាត់បន្ថយការហូរច្រោះ និងសំណឹកដី នៅតាមកន្លែងនានាដែលក្រុមហ៊ុនបានធ្វើការឈូសឆាយ។
- ក្រុមហ៊ុនបានប្រើប្រាស់វិធីសាស្រ្តជាច្រើនក្នុងការទប់ស្កាត់ការហូរច្រោះដីនៅតាមទីជម្រាល និងតំបន់គម្រោងទាំងមូលដូចមានបញ្ជាក់ដូចខាងក្រោមៈ
    - ក្រុមហ៊ុននឹងដាំស្មៅនៅតំបន់ណាដែលពុំមានគម្របព្រៃ
    - ក្រុមហ៊ុននឹងរៀបចំជញ្ជាំងឥដ្ឋដោយចាក់បេតុងយ៉ាងរឹងមាំ និងតម្រៀបថ្មនៅតាមជម្រាល និងចំណោតខ្លាំង
    - ក្រុមហ៊ុននឹងជីកដីជាថ្នាក់ៗ ធ្វើជាជណ្តើរថ្ម សំរាប់ទប់ទល់ល្បឿនទឹកហូរខ្លាំង ជៀសវាងការបាក់ដី និងការហូរច្រោះដី។
    - ក្រុមហ៊ុននឹងរៀបចំចង្ហូរទឹកនៅសងខាងផ្លូវព័ទ្ធជុំវិញទីតាំងកោះទាំងមូល

#322P, St.271Z, Sk.Terk Tla, Khan Resey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ដើម្បីទុកជាផ្លូវទឹកហូរ ដែលអាចទប់ទល់ការបាក់ផ្លូវ និងការហូរច្រោះដី។

- ក្រុមហ៊ុនមានផែនការគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទអោយបានល្អប្រសើរ ដោយសាងសង់បន្ទប់ដាក់សំណល់រឹងសំរាប់ដាក់កំទេចថ្ម ស្បោងប្លាស្ទិក ធុងថ្នាំលាប និងសំណល់ផ្ទះបាយជាដើម រួចដឹកសំណល់ទាំងនេះតាមទូកទៅចាក់ចោលនៅលើដីគោក ទៅតាមការកំណត់របស់ក្រសួងបរិស្ថាន និងសាលាខេត្តព្រះសីហនុ។ លើសពីនេះទៀត ក្រុមហ៊ុនសាងសង់បង្គន់អនាម័យដែលមានអាងស្តុកសំណល់រាវត្រឹមត្រូវ រួចយកសំណល់លាមកនេះមកប្រើប្រាស់ជាជីធម្មជាតិ សំរាប់ដាំដើមឈើ ផ្កានៅក្នុងសួនច្បារ និងដំណាំរួមផ្សំផ្សេងៗទៀតនៅក្នុងតំបន់គម្រោង។
- ក្រុមហ៊ុនធ្វើការណែនាំ និងអប់រំដល់បុគ្គលិក-កម្មករ ដោយហាមប្រាមមិនអោយមានការបោះចោលសំរាមពាសវាលពាសកាល ឬបង្ហូរសំណល់រាវចូលទៅទឹកសមុទ្រឡើយ។



រូបភាព៧.១៖ ការរៀបចំប្រព័ន្ធលូ

### គ. គុណភាពទឹក

ការឈូសឆាយដីក្នុងតំបន់គម្រោង ដើម្បីសាងសង់ផ្ទះលំហែកាយ ផ្លូវ ភោជនីយដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗនៅក្នុងតំបន់គម្រោងធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹកសមុទ្រ ជាពិសេសការឈូសឆាយដីនៅរដូវវស្សា។ ដោយឡែក ការសាងសង់កំពង់ផែទេសចរណ៍បណ្តាលឲ្យកខ្វក់ដល់គុណភាពទឹកនៅពេលបុកគ្រឹះ ការធ្លាក់កំទេចស៊ីម៉ងត៍ និងសំណល់ផ្សេងៗ ព្រមទាំងធ្វើឲ្យមានការប្រែប្រួលចរន្តទឹកផងដែរ។

ចំណែក ការចោលសំណល់រឹងដែលមានប្រភពចេញពីសំណល់សម្ភារៈសាងសង់ សំណល់ផ្ទះបាយ និងសំណល់ផ្សេងៗមកពីការប្រើប្រាស់របស់បុគ្គលិក-កម្មករគម្រោង និងការបង្ហូរសំណល់រាវពីកន្លែងស្នាក់នៅ ឬពីការហៀរកំពប់សារធាតុប្រេងពីគ្រឿងចក្រ និងរថយន្តក៏បង្កឲ្យមានការប៉ះពាល់ដល់គុណភាពទឹកផងដែរ។

នៅក្នុងរយៈពេលនេះ អាចនឹងមានសំណល់រឹងជាច្រើនដែលបានមកពីសម្ភារៈសាងសង់ ដូចជាកំណាត់ដែក ជ័របំពង់ទីប ជ័រប្លាស្ទិក កំណាត់ឈើ កំទេចស៊ីម៉ង់ត៍ កំបោរជាដើម ក៏ដូចគ្នានោះដែរ ចំពោះសំណល់ដែលបង្កើតឡើងដោយបុគ្គលិក-កម្មករ (Household/living waste)។ នៅក្នុងដំណាក់កាលសាងសង់ដ៏ស្រួចស្រាវ (Peak construction period) មានកម្មករជាមធ្យម ៧០០នាក់ ហើយប្រសិនបើកម្មករម្នាក់បង្កើតសំណល់រឹងយ៉ាងតិច ០,៧គ.ក្រ/ថ្ងៃ នោះអាចមានសំណល់ប្រមាណ ៤៩០គ.ក្រ/ថ្ងៃ។ តែបើជាយ៉ាណាក៏ដោយបញ្ហាសំណល់រឹងដែលបង្កើតឡើងដោយបុគ្គលិក និងកម្មករនេះត្រូវបានកាត់បន្ថយទាំងស្រុងដោយសារបុគ្គលិក និងកម្មករមានផ្ទះនៅតំបន់ក្បែរតំបន់គម្រោងដែរពួកគាត់ត្រូវត្រលប់ទៅផ្ទះវិញរៀងៗខ្លួននៅពេលបញ្ចប់ការងារ។

ចំពោះសំណល់រាវ រួមមានសំណល់ចេញពីការសាងសង់ សំណល់ប្រេង សំណល់ចេញពីការប្រើប្រាស់ទឹក របស់បុគ្គលិកកម្មករសំណង់ និងសំណល់ចេញពីបង្គន់អនាម័យ។ យោងតាមស្តង់ដារប៉ាន់ស្មានថ្នាក់ជាតិ និងអន្តរជាតិដោយផ្អែកលើតួលេខជាគោលបរិមាណសំណល់រាវដែលបញ្ចេញចោលពីលំនៅដ្ឋានគឺ២០០លីត្រ/ម្នាក់/ថ្ងៃ ត្រូវបានគណនាថាកម្មករជាមធ្យម ៧០០នាក់ ដូចនេះសំណល់រាវមានប្រមាណ ១៤០ម៉ែត្រគូប/ថ្ងៃ។

ដោយឡែក ការឈូសឆាយដែលមិនមានផែនការច្បាស់លាស់ ក្នុងការកាត់បន្ថយការហូរច្រោះ និងសំណឹកដី ដោយបង្កឲ្យមានការកើនឡើងនូវកករល្បាប់ម៉ដ្ឋ/ភក់ ដែលនាំមានការបំពុលដល់ទឹកសមុទ្រ។

**វិធានការកាត់បន្ថយ (Mitigation Measures)**

ទោះបីជាមានហេតុប៉ះពាល់អវិជ្ជមានយ៉ាងណាក៏ដោយ ក្រុមហ៊ុនមានវិធានការការពារ ឬកាត់បន្ថយហេតុប៉ះពាល់ជាយថាហេតុដែលបណ្តាលមកពីសកម្មភាព និងសម្ភារៈសាងសង់ដល់គុណភាពទឹក ដោយមានវិធានការទុកដាក់សំណល់ទាំងអស់ឱ្យបានត្រឹមត្រូវមួយចំនួនដូចខាងក្រោម៖

- ក្រុមហ៊ុនបានយកសំណាកទឹកសមុទ្រ ទៅពិនិត្យនៅមន្ទីរពិសោធន៍របស់ ក្រសួងបរិស្ថាន ឆ្នាំ២០១២ និងឆ្នាំ២០១៤ បានបង្ហាញថា ប៉ារ៉ាម៉ែត្រដូចជា pH, TSS, DO, BOD, COD, TP, TN, Arsenic, Lead,Total Coliform និងប៉ារ៉ាម៉ែត្រ១៣ផ្សេងទៀតគឺស្ថិតនៅក្រោមស្តង់ដាររបស់ក្រសួងបរិស្ថាន ដែលបង្ហាញពីលទ្ធផលនៃសកម្មភាពសាងសង់គឺពុំមានការបំពុលដល់សមុទ្រឡើយ។

- សាងសង់កន្លែងស្តុកប្រេងឥន្ធនៈអោយបានត្រឹមត្រូវ ដោយមិនអោយកំពប់លើដី ដែលនាំអោយហូរចូលក្នុងទឹកសមុទ្រ ហើយក្រុមហ៊ុននឹងប្រើប្រាស់ម៉ាស៊ីន/គ្រឿងចក្រ និងរថយន្តដឹកជញ្ជូនដែលថ្មីៗល្អ និងត្រូវបានត្រួតពិនិត្យជាប្រចាំយ៉ាងម៉ត់ចត់មុននឹងប្រតិបត្តិ ដើម្បីធានាមិនអោយមានការលេច ឬជ្រាបប្រេង។
- ពិនិត្យគ្រឿងចក្រមុននឹងចេញប្រតិបត្តិការ ដើម្បីជៀសវាងការជ្រាប ឬលេចប្រេងចេញពីម៉ាស៊ីន។
- ធ្វើការឈូសឆាយដីនៅរដូវប្រាំង ក្នុងករណីមានការឈូសឆាយដីរដូវវស្សា ក្រុមហ៊ុននឹងប្រតិបត្តិក្នុងទ្រង់ទ្រាយតូច ហើយនៅក្នុងស្ថានភាពលើសល្បានដីរាបស្មើ ហើយក្រុមហ៊ុននឹងធ្វើរបាំងការពារកកជើ ឬកំទេចកំទីកុំអោយហូរចូលទៅក្នុងប្រភពទឹកសមុទ្រ។
- ធ្វើការអប់រំដល់បុគ្គលិក-កម្មករឱ្យយល់ដឹងអំពីអនាម័យនៅក្នុងតំបន់សាងសង់ ដោយត្រូវវេចខ្ចប់រាល់សំណល់ ទុកដាក់នៅកន្លែងកំណត់ឱ្យត្រឹមត្រូវ។
- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់ការដ្ឋានសាងសង់ ដោយតំរូវឱ្យបុគ្គលិក និងកម្មករគោរពយ៉ាងហ្មឹងម៉ាត់ ឬត្រូវទទួលពិន័យយ៉ាងតឹងរឹង។
- ប្រើប្រាស់បច្ចេកវិទ្យាឈានមុខ និងម៉ាស៊ីនទំនើប (Advanced technology and machinery) ដើម្បីកាត់បន្ថយការលេចជ្រាបប្រេង ហើយត្រូវធ្វើការត្រួតពិនិត្យរាល់គ្រឿងចក្រនីមួយៗជាប្រចាំ។
- បិទស្លាកបំរាម (Use warning label) សម្រាប់សំគាល់ចំពោះសម្ភារៈដែលមានជាតិពុល និងគ្រោះថ្នាក់ធ្ងន់ធ្ងរដល់បរិស្ថានដូចជាប្រេងឥន្ធនៈ ឬថ្នាំលាបជាដើម (Poisonous materials such as fuel, paints, etc.)។
- រាល់សំណល់រាវទាំងអស់ដែលចេញមកពីការសាងសង់ រួមទាំងសំណល់រាវដែលបង្កើតឡើងដោយកម្មករត្រូវបង្ហូរចូលទៅក្នុងប្រព័ន្ធបង្ហូរសំណល់រាវ ដែលមានស្រាប់របស់ក្រុមហ៊ុន។ ទោះបីយ៉ាងណា ក្រុមហ៊ុនមានការសន្សំសំចៃនៃការប្រើប្រាស់ទឹកដោយសារតំបន់នោះពុំមានប្រភពទឹកលើដី និងក្រោមដីសម្រាប់បម្រើឲ្យការសាងសង់។
- ជ្រើសរើសកម្មករដែលមកពីតំបន់ជិត និងក្បែរតំបន់គម្រោងដែលអាចកាត់បន្ថយចំនួនសំណល់រឹង-រាវ ព្រោះកម្មករអាចទៅសំរាកនៅផ្ទះវិញនៅពេលចេញពីការងារពេលល្ងាច។

ឃ. គុណភាពខ្យល់

ការបុកគ្រឹះ ការប្រើប្រាស់ថ្នាំលាប ការប្រើប្រាស់ប្រេងឥន្ធនៈ និងកន្លែងទុកសំណល់រឹង-រាវធ្វើឱ្យមានធូលី សារធាតុគីមី និងក្លិនស្អុយភាយចេញទៅបរិយាកាសដែលធ្វើឱ្យគុណភាពខ្យល់ត្រូវរងការបំពុល។ លើសពីនេះទៀត សកម្មភាពរបស់ក្រុមហ៊ុននឹងប្រើប្រាស់ម៉ាស៊ីនភ្លើង

ទាំងស្រុង ដោយសារតំបន់គម្រោងពុំមានបណ្តាញអគ្គិសនីឡើយ ហើយការបញ្ឆេះម៉ាស៊ីនភ្លើងនឹងបង្កឲ្យមានការសាយភាយឧស្ម័នពុលទៅក្នុងបរិយាកាស។

វិធានការកាត់បន្ថយ (Mitigation Measures)

រាល់ការកាត់បន្ថយឥទ្ធិពលដែលធ្វើឱ្យមានការប៉ះពាល់ដល់គុណភាពខ្យល់ ក្រុមហ៊ុនបានគិតគូរនូវវិធានការមួយចំនួនដូចខាងក្រោម៖

- ក្រុមហ៊ុនធ្វើការវិភាគគុណភាពខ្យល់ ១កន្លែង គឺនៅលើកោះក្របី ដែលមានប៉ារ៉ាម៉ែត្រគុណភាពខ្យល់សំខាន់ៗ មួយចំនួនដូចជា CO $NO_2$ $SO_2$ និងTSP ដែលលទ្ធផលបានបង្ហាញគ្រប់ប៉ារ៉ាម៉ែត្រដែលបានវិភាគស្ថិតនៅក្រោមស្តង់ដារបស់ក្រសួងបរិស្ថាន ដែលបង្ហាញថាមិនប៉ះពាល់ដល់បរិស្ថានឡើយ។
- អ្នកម៉ៅការនឹងត្រូវតំរូវឱ្យអនុវត្តជាប្រចាំចំពោះការត្រួតពិនិត្យមើលម៉ាស៊ីន គ្រឿងចក្រ និងឧបករណ៍នានា ដើម្បីធានាថារបស់របរទាំងនេះអាចធ្វើការបានល្អ។
- សេវាកម្មថែរក្សាការពារជាទៀងទាត់នៃគ្រឿងចក្រ និងឧបករណ៍សាងសង់ ត្រូវអនុវត្តឲ្យបានតឹងរ៉ឹង។
- សំណល់នៃសម្ភារៈសាងសង់នៅក្នុងការដ្ឋាន ត្រូវគ្រួចចូលទៅក្នុងការ៉ុង/បាវចងឲ្យជិតរួចដឹកជញ្ជូនមកកាន់ដីគោកវិញ នឹងធ្វើការដឹកជញ្ជូនយកទៅចោលទៅតាមការកំណត់របស់ក្រសួងបរិស្ថាន និងសាលាខេត្តព្រះសីហនុ។
- បាញ់ស្រោចទឹកនៅក្នុងតំបន់សាងសង់ និងនៅផ្លូវមេជុំវិញតំបន់គម្រោង។
- ប្រើប្រាស់គ្រឿងចក្រថ្មីៗដែលមិនមានការបញ្ចេញផ្សែងពុលទៅក្នុងខ្យល់/បរិយាកាសជាពិសេសសារធាតុ NOx, SOx និង TSP ព្រមទាំងធ្វើការត្រួតពិនិត្យឲ្យបានទៀងទាត់។ ករណីសារធាតុទាំងនេះមានកម្រិតលើសស្តង់ដារកំណត់របស់ក្រសួងបរិស្ថាន ក្រុមហ៊ុនត្រូវមានវិធានការបន្ទាន់ និងត្រួតពិនិត្យឡើងវិញនូវរាល់សកម្មភាពដែលមានការបំពុល។

### ង. ការរំខានដោយសំលេង និងរំញ័រ

ឧបករណ៍ សម្ភារៈសាងសង់ និងគ្រឿងចក្រ ត្រូវបានប្រើប្រាស់នៅពេលសាងសង់សំរាប់សកម្មភាពមួយចំនួន ដូចជាការឈូសឆាយដី ការបង្ហាប់ដី ការបុកគ្រឹះ ព្រមទាំងការប្រើប្រាស់ម៉ាស៊ីនភ្លើងដែលអាចធ្វើឱ្យមានសំលេង និងរំញ័រ ដែលអាចមានការប៉ះពាល់ដល់បុគ្គលិក និងកម្មករដែលធ្វើការនៅទីនោះ។ ទន្ទឹមនឹងនោះចំពោះអ្នកបញ្ជាគ្រឿងចក្រផ្ទាល់ដែលទាមទារឱ្យមានការការពារត្រឹមត្រូវ ដើម្បីចៀសវាងហេតុប៉ះពាល់ធ្ងន់ធ្ងរដល់សោតវិញ្ញាណ (Noise-induced hearing loss) ប្រសិនបើការប្រឈមទៅនឹងសំលេងលើសពីកំរិតមធ្យម ៨៥ដេស៊ីបែល (៨៥dB (A)) នៅក្នុងរយៈពេលប្រាំបីម៉ោង។

វិធានការកាត់បន្ថយ (Mitigation Measures)

- គ្រឿងទប់សំលេងដូចជា ឧបករណ៍កាត់បន្ថយសំលេងត្រូវបំពាក់នៅពេលដែលយល់ថាមានការចាំបាច់ ដើម្បីកាត់បន្ថយការបញ្ចេញសំលេងពីគ្រឿងចក្រ និងឧបករណ៍សាងសង់គ្រប់ប្រភេទ ដែលត្រូវបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។
- រាល់សកម្មភាពសាងសង់ដែលបង្កើតឱ្យមានកំរិតសំលេងខ្លាំង ក្រុមហ៊ុនត្រូវកំណត់ពេលវេលាឱ្យមានតែនៅពេលថ្ងៃប៉ុណ្ណោះ (៦:០០ព្រឹក ដល់៦:០០ល្ងាច) ដើម្បីជៀសវាងការរំខានដោយសំលេងទៅដល់ការសំរាករបស់បុគ្គលិក និងកម្មករ។
- ចំពោះបុគ្គលិក-កម្មករដែលប្រឈមទៅនឹងសំលេងខ្លាំង និងមានរយៈពេលយូរត្រូវពាក់ឧបករណ៍ទប់សំលេងដែលផ្តល់ឱ្យដោយក្រុមហ៊ុន (Personal hearing devices)។
- ក្រុមហ៊ុននឹងប្រើប្រាស់គ្រឿងចក្រ ព្រមទាំងម៉ាស៊ីនភ្លើងធុនទំនើបដែលបញ្ចេញសំលេងតិចមិនឱ្យប៉ះពាល់ដល់សុខភាពរបស់បុគ្គលិក-កម្មករ ។
- កំរិតសំលេងចេញពីប្រភពគ្រឿងចក្រ នៅក្នុងចំងាយ១០០ម៉ែត្រ ទៅកាន់បរិស្ថានដែលនៅជុំវិញគឺមិនលើសពី ៧៥dB(A)នៅពេលថ្ងៃ។ អ្នកម៉ៅការសំណង់ត្រូវតំរូវឱ្យប្រើប្រាស់ឧបករណ៍ម៉ាស៊ីនដែលមានកំរិតរំញ័រទាបនៅគ្រប់ពេលទាំងអស់គឺជាការចាំបាច់ (តំបន់ប្រជាជនរស់នៅ<60dB តំបន់ចំរុះ<៦0db តំបន់ពាណិជ្ជកម្ម<៧0dB និងតំបន់ងាយទទួលរងការប៉ះពាល់ដោយសំលេង <៤៥dB)។

## ៧.៣.១.២ ធនធានជីវសាស្រ្ត

### ក. ធនធានព្រៃឈើ និងទីជំរករបស់សត្វ

នៅក្នុងតំបន់គម្រោងមានផ្ទៃដីចំនួន ១០ហិកតារួមមាន ព្រៃស្រោងចំនួន ៨ហិកតា និងដីមិនមានព្រៃចំនួន ២ហិកតា គណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្រ្ត។ ដូចនេះ សកម្មភាពឈូសឆាយដីរបស់គម្រោងសំរាប់សាងសង់ផ្ទះលំហែកាយ ធ្វើផ្លូវ កន្លែងស្នាក់នៅរបស់កម្មករ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ នឹងមានការប៉ះពាល់ដល់ប្រភេទព្រៃឈើប្រមាណ ៨ហិកតានៅលើដីកោះដូចជា ផ្ទៃដីសម្រាប់សាងសង់តំបន់សាធារណៈមានចំនួន ២.០៦០ម$^{២}$ តំបន់សេវាកម្ម ១.៦២០ម$^{២}$ និងផ្ទៃដីសម្រាប់សាងសង់ផ្ទះលំហែកាយចំនួន៦.៨៦៨ម$^{២}$ ។ល។ ដោយផ្ទៃដីដែលក្រុមហ៊ុននឹងធ្វើការសាងសង់ប៉ះពាល់ត្រឹមតែ ២ហិកតាប៉ុណ្ណោះ ដូច្នេះធនធានឈើដែលត្រូវបាត់បង់គឺរួមមានអុសចំរុះប្រភេទ ៧៨,០៨២ដើម កូនឈើចំរុះប្រភេទ ៩៣ដើម និងប្រភេទឈើមូលដែលអង្កត់ផ្ចិតធំជាង ៣០ស.មឡើងទៅ ២៥ម$^{៣}$១៦ គិតជាទឹកប្រាក់ប្រហែលជា ១០៨១,៣២ ដុល្លាសហរដ្ឋអាមេរិក។

ដោយឡែក ចំពោះកម្មករដែលបំរើការងារក្នុងតំបន់គម្រោងក៏នឹងអាចមានការធ្វេសប្រហែសនានាដូចជា ការចោលកន្ទុយបារី ការបង្កាត់ភ្លើងដាំបាយជាដើម ដែលកត្តានេះបានបណ្តាលអោយមានភ្លើងឆេះព្រៃ។

<u>វិធានការកាត់បន្ថយ</u>

- ការកាប់ព្រៃឈើត្រូវធ្វើឡើងតែតំបន់គ្មានព្រៃឈើ ឬព្រៃឈើតូចៗដោយមិនកាប់ដើមឈើធំៗដើម្បីតម្រូវការសាងសង់ឡើយ។
- ក្រុមហ៊ុនថែរក្សាប្រភេទឈើ ឬបណ្តុំព្រៃដែលមានលក្ខណៈបច្ចេកទេសសំរាប់ជីវៈចម្រុះការពារបរិស្ថាន ដូចជាព្រៃឈើនៅតាមទីជំរាលមាត់ឆ្នេរ។
- ដាំដើមឈើ ឬរុក្ខជាតិនានាដែលត្រូវនឹងស្ថានភាពភូមិសាស្ត្រក្នុងតំបន់គម្រោង បន្ទាប់ពីបញ្ចប់សកម្មភាពសាងសង់នៅតាមការដ្ឋាននីមួយៗ ដើម្បីរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ីនៅលើកោះក្របី ជាពិសេស ក្រុមហ៊ុននឹងធ្វើការដាំដើមឈើបន្ថែម ដើម្បីបង្កើនគម្របព្រៃឈើ និងជួយឲ្យតំបន់កោះក្របីក្លាយជាតំបន់អេកូទេសចរណ៍សម្បូរទៅដោយភាពបៃតង។
- មុននឹងធ្វើការឈូសឆាយដី ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាក្នុងតំបន់គម្រោង ក្រុមហ៊ុននឹងអនុវត្តទៅតាមផែនការមេ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច។
- ក្រុមហ៊ុននឹងធ្វើការពិន័យ ឬបញ្ឈប់ការងារដល់កម្មករណាដែលកាប់ដើមឈើដោយពុំមានការអនុញ្ញាតជាមុនពីអ្នកគ្រប់គ្រងគម្រោង ឬអ្នកមៅការ។
- ធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មករទាំងអស់របស់ក្រុមហ៊ុន អោយមានការប្រុងប្រយ័ត្ន ចំពោះការបង្កាត់ភ្លើងសំរាប់គោលបំណងផ្សេងៗ និងការចោលកន្ទុយបារី ដើម្បីជៀសវាងភ្លើងឆេះព្រៃ ហើយត្រូវរាយការណ៍ដល់អាជ្ញាធរមូលដ្ឋាននៅពេលខ្លួនប្រទះឃើញភ្លើងឆេះព្រៃក្នុងតំបន់គម្រោងដើម្បីធ្វើការទប់ស្កាត់អោយបានទាន់ពេលវេលា។
- ក្រុមហ៊ុនបំពាក់ឧបករណ៍បង្ការគ្រោះអគ្គីភ័យគ្រប់តំបន់ ដែលការរៀបចំនេះបានដាក់ភ្ជាប់បំពង់ស្របជាមួយប្រព័ន្ធផ្លូវមេ និងតំបន់កំសាន្តនានា។

ខ. ពពួកសត្វព្រៃ

ពពួកសត្វព្រៃ ដែលមាននៅក្នុងតំបន់គម្រោងបានពឹងអាស្រ័យទៅលើព្រៃធម្មជាតិកោះក្របីដែលជាជំរកសត្វដ៏ល្អសំរាប់ពពួកបក្សី ល្មូន និងសត្វព្រៃនានា ដូចនេះ ប្រភេទសត្វមួយចំនួននឹងមានការថយចុះដោយការងាប់ ឬបំលាស់ទីទៅរស់នៅកន្លែងផ្សេង ដើម្បីស្វែងរកចំណីអាហារចិញ្ចឹមជីវិត។ តាមការសិក្សារបស់ក្រុមហ៊ុនបានបង្ហាញថា តំបន់កោះក្របីមានថនិកសត្វចំនួន ៧ប្រភេទ និងតាមចំណាត់ថ្នាក់នៅប្រទេសកម្ពុជាមានចំនួន ៣ប្រភេទ ដែលមានដោយ

កម្រងការគំរាមកំហែង និងជិតផុតពូជផងដែរ។ ប្រភេទសត្វទាំងនោះរួមមានកណ្តុរ កំប្រុក ប្រម៉ា ជ្រឹង ប្រចៀវ ត្រកួត ពស់ព្រៃ ពស់វែកក្របី ពស់វែកដំបូក តុកកែ អន្សង ពស់ខ្សែគោ និងបង្កួយព្រៃ។ ចំណែក សត្វស្លាបរួមមានត្រចៀកកាំ ពពិចខ្លៅ ញ៉ាំង ស្វាំង ចាបពួក និង កេងកងតូចៗ

ដោយឡែកប្រភេទសត្វមួយចំនួនពុំមានកំណត់ត្រានៅក្នុងបញ្ជីក្រហម IUCN Red List ទេ ប៉ុន្តែត្រូវបានការពារដោយប្រកាស អនុក្រឹត្យ និងច្បាប់ដូចជាតុកកែ ត្រកួត និងពស់វែក។

មិនតែប៉ុណ្ណោះ សំលេងចេញពីសកម្មភាពប្រើប្រាស់គ្រឿងចក្រសំរាប់ឈូសឆាយដី រណាអារឈើ និងការបញ្ឆេះម៉ាស៊ីនភ្លើងក្នុងតំបន់គម្រោងនៅពេលយប់ក៏បានធ្វើអោយមានការ រំខានដល់សត្វព្រៃដែលមានវត្តមាននៅក្នុងតំបន់នោះ។

<u>វិធានការកាត់បន្ថយ</u>

- ទីតាំងគម្រោងនេះពុំមានសត្វព្រៃធំៗរស់នៅទេគឺមានតែប្រភេទសត្វតូចៗប៉ុណ្ណោះ
- ក្រុមហ៊ុនសហការជាមួយរដ្ឋបាលព្រៃឈើ និងអាជ្ញាធរមានសមត្ថកិច្ចដើម្បីយកសត្វ មកចិញ្ចឹមបន្ថែម ព្រមទាំងការពារឲ្យបានតឹងរ៉ឹងនូវប្រភេទសត្វដែលមានស្រាប់នៅ លើកោះ
- កំណត់ពេលវេលាធ្វើការច្បាស់លាស់ដូចជាធ្វើការតែនៅពេលថ្ងៃ ដើម្បីកាត់បន្ថយ ការបញ្ចេញសំលេង
- ធ្វើការអប់រំដល់បុគ្គលិក-កម្មករ របស់ក្រុមហ៊ុនមិនអោយធ្វើការបរបាញ់សត្វគ្រប់ ប្រភេទនៅតំបន់គម្រោង និងធ្វើការគ្រប់គ្រងយ៉ាងណាកុំឲ្យមានបទល្មើសសត្វព្រៃ នានាដែលកើតឡើងនៅក្នុងតំបន់នេះ ដោយសហការជាមួយនឹងអាជ្ញាធរមាន សមត្ថកិច្ចជាប្រចាំ

គ. ជីវៈចំរុះក្នុងទឹក

សកម្មភាពឈូសឆាយដីអាចបង្កអោយប៉ះពាល់តិចតួចដល់ជីវៈចំរុះក្នុងទឹក ជាពិសេស គ្រុំយក្ស ផ្កាថ្ម ផ្សោតឥតព្រុយខ្នង និងផ្សោតក្បាលត្រឡោក ព្រមទាំងមានប្រភេទមច្ឆាជាតិ ប្រមាណ ៣៧ប្រភេទ ដែលអាចបណ្តាលមកពីការកើនឡើងនូវភាពកករល្អក់ និងការនាំមកនូវ កករដី ភាពល្អូយនៃកំទេចកំទីមែកឈើនិងស្លឹកឈើ ការចោលសំណល់រឹង ការបង្ហូរសំណល់រាវ ចូលទៅក្នុងប្រភពទឹកសមុទ្រ។

<u>វិធានការកាត់បន្ថយ</u>

- ការឈូសឆាយដីសំរាប់សាងសង់មានទ្រង់ទ្រាយតូច ហើយធ្វើឡើងតែនៅរដូវប្រាំង ប៉ុណ្ណោះ ដោយមិនមានការប៉ះពាល់ដល់ជីវៈចម្រុះក្នុងទឹកឡើយ។

- ចូលរួមថែទាំនូវគុណភាពទឹកសមុទ្រ ការពារការហូរច្រោះដី ជាពិសេសគ្រប់គ្រងសំណល់រឹង-រាវ ដោយណែនាំដល់បុគ្គលិក-កម្មករមិនឱ្យបោះចោល ឬបង្ហូរដោយផ្ទាល់ចូលទៅប្រភពទឹកសមុទ្រជាដាច់ខាត។
- ក្រុមហ៊ុនរក្សាព្រៃឈើធម្មជាតិដែលមានស្រាប់នៅលើកោះក្របី និងដាំដើមឈើបន្ថែមនៅតាមតំបន់ឆ្នេរ និងទីជម្រាល ជៀសវាងការហូរច្រោះដីដោយជួយថែរក្សាគុណភាពទឹក និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់គម្រោង។

### ៧.៣.១.៣ ធនធានសេដ្ឋកិច្ច-សង្គម

#### ក. មុខរបរ និងប្រាក់ចំណូល

នៅដំណាក់កាលនេះអាចមានការប៉ះពាល់ដល់មុខរបរ និងប្រាក់ចំណូលរបស់ប្រជានេសាទមួយចំនួនដែលតែងតែទៅនេសាទនៅក្បែរតំបន់កោះក្របីនោះ ព្រោះម្ចាស់គម្រោងបានហាមឃាត់ប្រជាជនមិនឲ្យធ្វើការនេសាទនៅជិតកោះឡើយ ដោយតម្រូវឲ្យពួកគាត់នេសាទឲ្យឆ្ងាយពីកោះចម្ងាយ២៥០ម៉ែត្រ ដើម្បីសុវត្ថិភាពរបស់ភ្ញៀវទេសចរណ៍ដែលមកស្នាក់នៅផង និងដើម្បីអភិរក្សធនធានជលផល (ផ្កាថ្ម)ផង។ ការកំណត់ដែននេសាទនេះបានប៉ះពាល់ដល់ចំណូលអ្នកនេសាទ ប៉ុន្តែការប៉ះពាល់នេះមានកម្រិតតិចតួចប៉ុណ្ណោះ។

<u>វិធានការកាត់បន្ថយ</u>

- ម្ចាស់គម្រោងបានអនុញ្ញាត្យប្រជាជននេសាទជុំវិញកោះក្របីនៅចម្ងាយ ២៥០ម៉ែត្រពីមាត់ទឹក ដោយដាក់ពោងបណ្តែតជាសញ្ញានៅជុំវិញកោះ។
- ម្ចាស់គម្រោងបានផ្តល់អាទិភាពដល់ប្រជាជនដែលធ្វើការនេសាទនៅជុំវិញកោះក្របីនោះ ចូលបម្រើការងារជាបុគ្គលិក/កម្មករនៅក្នុងដំណាក់កាលសាងសង់នេះ។
- ម្ចាស់គម្រោងបានអនុញ្ញាតឲ្យប្រជានេសាទអាចចូលចតទូកបាន នៅពេលមានខ្យល់ព្យុះ និងភ្លៀង។
- ម្ចាស់គម្រោងនឹងផ្តល់អាទិភាពដល់ប្រជាពលរដ្ឋក្នុងស្រុកព្រៃដើម្បីចូលបំរើការងារនៅដំណាក់កាលប្រតិបត្តិគម្រោង។

#### ខ. សុខភាព និងសុខាមាលភាពសាធារណៈ

នៅដំណាក់កាលនេះអាចមានការប៉ះពាល់ដល់សុខភាពរបស់កម្មករសំណង់ ដោយសារការប្រើប្រាស់ទឹកមិនស្អាត ការទុកដាក់សំណល់មិនបានត្រឹមត្រូវ និងគ្រោះថ្នាក់ ឬរបួសបណ្តាលមកពីសកម្មភាពសាងសង់ ឬការប្រឈមទៅនឹងជំងឺផ្សេងៗ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

បញ្ហាសុខភាពដែលអាចនឹងកើតមានឡើងដោយសារធូលីហុយ រួមផ្សំនឹងផ្សែងគ្រឿងចក្រមួយចំនួនរួមមានការរលាកផ្លូវដង្ហើម ជំងឺភ្នែក ជំងឺសើស្បែកជាដើម ប៉ុន្តែការបំពុលខ្យល់ដោយសារសកម្មភាពនេះមានរយៈពេលខ្លី។

<u>វិធានការកាត់បន្ថយ</u>

- ផ្តត់ផ្គង់ទីកន្លែងស្នាក់នៅសមរម្យ និងទឹកស្អាតដល់កម្មករៈ ទីកន្លែងស្នាក់នៅសំរាប់កម្មករត្រូវបានរៀបចំឡើងដោយធ្វើយ៉ាងណាឱ្យមានពន្លឺ មានខ្យល់ចេញចូលបានគ្រប់គ្រាន់ និងមានភាពទូលាយសមរម្យ ដើម្បីចៀសវាងការរស់នៅកកកុញនៅក្នុងកន្លែងតែមួយ (បន្ទប់តូចចង្អៀតហួស) ដែលអំណោយផលដល់ការចម្លងជំងឺផ្សេងៗដូចជាជំងឺផ្លូវដង្ហើម។ល។
- ក្រុមហ៊ុនបានជ្រើសរើសកម្មករភាគច្រើនមកពីក្នុងឃុំរាម និងឃុំផ្សេងៗទៀតនៅជិតតំបន់គម្រោង ដែលពួកគាត់អាចត្រលប់ទៅសំរាកនៅផ្ទះវិញបាននៅពេលចេញពីការងារ។
- ក្រុមហ៊ុនមានកប៉ាល់ផ្ទាល់ខ្លួនសម្រាប់ដឹកជញ្ជូនកម្មករទៅធ្វើការនៅលើកោះ និងត្រលប់មកវិញ ដោយកំណត់ពេលវេលាចេញ-ចូលច្បាស់លាស់ (ចូលម៉ោង៨:០០ព្រឹក ចេញម៉ោង៤:០០ល្ងាច)។
- តំរូវការទឹកស្អាតសំរាប់ប្រើប្រាស់នៅពេលកំពុងសាងសង់ គឺចាំបាច់ណាស់រួមទាំងទឹកសំរាប់បរិភោគ និងការលាងសំអាតរាងកាយប្រចាំថ្ងៃ។ ក្រុមហ៊ុននឹងមានដំឡើងស៊ីទែនស្តុកទឹកដោយដឹកទឹកពីដីគោក សម្រាប់ទុកប្រើប្រាស់។
- សាងសង់បង្គន់បណ្តោះអាសន្នដោយគោរពទៅតាមស្តង់ដារអនាម័យត្រឹមត្រូវ ដូចជាប្រភេទបង្គន់មានអាងស្តុកលាមកសឹបទិកដល់កម្មករជាដើម។
- ធ្វើការអប់រំបុគ្គលិក-កម្មករឱ្យយល់ដឹងអំពីជំងឺកាមរោគ-អេដស៍ និងវិធីការពារជាពិសេសចំពោះបុគ្គលិក-កម្មករ ដែលឃ្លាតឆ្ងាយពីក្រុមគ្រួសារព្រោះពួកគេអាចស្វែងរកសេវាផ្លូវភេទនៅទីកន្លែងកំសាន្តនានា ដែលអាចឱ្យគេប្រឈមទៅនឹងការឆ្លងជំងឺកាមរោគទាំងនោះ។ ឆ្លើយតបទៅនឹងបញ្ហានេះ គម្រោងនឹងធ្វើការទាក់ទងជាមួយលេខាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃមន្ទីរសុខាភិបាលខេត្តព្រះសីហនុ ដោយអញ្ជើញមន្ត្រីជំនាញមកធ្វើការផ្សព្វផ្សាយអប់រំអំពីមេរោគអេដស៍-ជំងឺអេដស៍ និងអំពីវិធានការការពារ។ ដើម្បីកុំឱ្យរាំងស្ទះដល់ដំណើរការសាងសង់របស់គម្រោង ការផ្សព្វផ្សាយអប់រំអាចធ្វើនៅពេលថ្ងៃឈប់សំរាកពីការងាររបស់កម្មករ ហើយការអប់រំសុខភាពនេះអាចមានរយៈពេលជាមធ្យមពី ១-២ម៉ោងក្នុងមួយលើក។

- ជ្រើសរើសគ្រូពេទ្យប្រចាំការនៅការដ្ឋាន ដើម្បីធ្វើការពិនិត្យពិគ្រោះព្យាបាលដល់បុគ្គលិក-កម្មករ និងសង្គ្រោះបន្ទាន់ក្នុងករណីដែលមានជំងឺ ឬរបួសធ្ងន់ធ្ងរជាយថាហេតុ។ បន្ថែមពីនេះទៀត គ្រូពេទ្យប្រចាំការត្រូវរាយការណ៍ជាបន្ទាន់ក្នុងករណីសង្ស័យ ឬរកឃើញករណីជំងឺឆ្លងរាតត្បាតណាមួយទៅដល់រដ្ឋអំណាចសុខាភិបាលខេត្តព្រះសីហនុ។
- ប្រកាន់យកសុវត្ថិភាពជាចំបងនៅការដ្ឋានសាងសង់ (Safety first)។



រូបភាព៧.២៖ ការដឹកជញ្ជូន និងការស្តុកទឹក

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

គ. សុវត្ថិភាពបុគ្គលិក និងកម្មករ

នៅក្នុងដំណាក់កាលសាងសង់នេះ អាចមានការប៉ះពាល់ដល់បុគ្គលិក និងកម្មករ ទៅលើសុវត្ថិភាពក្នុងការធ្វើដំណើរដោយផ្លូវទឹក សុវត្ថិភាពក្នុងពេលបំពេញការងារ។ ជាក់ស្តែងនៅក្នុងដំណាក់កាលសាងសង់នេះ មានបុគ្គលិក និងកម្មករកំពុងបំរើការងារ រហូតដល់ ៧០០នាក់។ បញ្ហានេះក្រុមហ៊ុនបានគិតគូរ និងមានវិធានការកាត់បន្ថយមួយចំនួនដូចខាងក្រោម៖

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុនបានកំណត់ម៉ោងធ្វើការងារចូលម៉ោង ៨:០០ព្រឹក និងចេញ៥:០០ល្ងាច ដែលមិនមែនជាពេលវេលាសុវត្ថិភាពក្នុងការធ្វើដំណើរ។
- នៅពេលមានព្យុះភ្លៀង ដែលប្រកាសដោយក្រសួងធនធានទឹក និងឧត្តុនិយម ក្រុមហ៊ុនបានប្រកាសដល់បុគ្គលិក និងកម្មករឈប់សំរាក រងចាំរហូតដល់អាកាសធាតុល្អទើបចូលបំពេញការងារវិញ។
- ក្រុមហ៊ុនមានកប៉ាក់ធន់ធំសម្រាប់ដឹកជញ្ជូនបុគ្គិលិក និងកម្មករ នឹងផ្តល់ជូនអាងពងដើម្បីការពារ។
- ក្រុមហ៊ុនមានបន្ទប់ពេទ្យ ដែលមានគ្រូពេទ្យប្រចាំការ២៤ម៉ោង សម្រាប់សង្រោះបន្ទាន់នៅពេល បុគ្គលិកមានជំងឺ ឬបញ្ហាផ្សេងៗ។
- ផ្តល់ជូនដល់បុគ្គលិក និងកម្មករនូវការធានារ៉ាប់រងអាយុជីវិត ដល់បុគ្គលិទាំងអស់។

## ៧.៣.២ ដំណាក់កាលប្រតិបត្តិគម្រោង(Operational Phase)

នៅក្នុងដំណាក់កាលនេះ សកម្មភាពរបស់ក្រុមហ៊ុនមានលក្ខណៈយូរអង្វែង ដែលរាជរដ្ឋាភិបាលបានផ្តល់សម្បទានកោះក្របីរយៈពេល៩៩ឆ្នាំ សំរាប់អភិវឌ្ឍន៍ កោះក្របីទៅជារមណីយដ្ឋានផ្ទះលំហែរកាយទំនើបលំដាប់ពិភពលោក។ ដូចនេះ ក្រុមហ៊ុននឹងដាក់ឲ្យដំណើរការនូវផ្ទះលំហែរកាយចំនួន ៥០ខ្នង ស្ថិតនៅលើជួរកំពស់នីវ៉ូសមុទ្រផ្សេងៗពីគ្នា ព្រមទាំងភោជនីយដ្ឋានដែលអាចមើលឃើញទិដ្ឋភាពផ្ទៃសមុទ្រចំនួនពីរគឺ ភោជនីយដ្ឋានដ៏ប្រណិតមួយសម្រាប់ញ៉ាំអាហារពេលល្ងាច និងភោជនីយដ្ឋានសមញ្ញជាងនេះមួយទៀតដែលមានបានីយដ្ឋានក្នុងនោះ។ ម្យ៉ាងទៀតសកម្មភាពកំពុងផែខាងដីគោកក៏មានការមមាញឹកផងដែរ ដែលនឹងត្រូវដឹកជញ្ជូនទៅមក ចំណីអាហារ និងសម្ភារៈសម្រាប់ប្រើប្រាស់ផ្សេងៗ។

### ៧.៤.២.១ ធនធានរូបសាស្ត្រ

ក. ការបំពុលខ្យល់

នៅក្នុងដំណាក់កាលនេះនឹងមានការបំពុលខ្យល់ចេញមកពីកន្លែងទុកដាក់សំរាម និងអាងប្រព្រឹត្តកម្មសំណល់រាវ ពីព្រោះថាគម្រោងនឹងមានការបញ្ចេញសំណល់រាវប្រមាណ៤៥ម³/ថ្ងៃ និងសំណល់រឹង១៩៧គីឡូក្រាម/ថ្ងៃពីតំបន់ផ្ទះលំហែកាយ និងតំបន់សេវាកម្មសាធារណៈ (Service of Public area) ដូចជាអគាររដ្ឋបាលសាធារណៈ ស្ថានីយ៍ប្រេងឥន្ធនៈជាដើម។

ករណីអគ្គិសនីលើកោះ ក្រុមហ៊ុននឹងប្រើប្រាស់ម៉ាស៊ីនភ្លើងសំរាប់ផ្គត់ផ្គង់នៅក្នុងទីតាំងគម្រោងដែលវានឹងបណ្តាលឱ្យមានការបំពុលខ្យល់។ ក្រុមហ៊ុនមានផែនការនឹងប្រើប្រាស់ម៉ាស៊ីនភ្លើងចំនួន ០៤គ្រឿង ដោយម៉ាស៊ីនភ្លើងដែលមានកម្លាំង ៤៥០KVA ។

នៅក្នុងបន្ទប់នីមួយៗមានការបំពាក់ឧបករណ៍អេឡិចត្រូនិចដូចជា ទូរទឹកកក និងម៉ាស៊ីនត្រជាក់ដែលអាចបណ្តាលអោយមានប៉ះពាល់ដល់ស្រទាប់អូហ្សូនដោយសារការបញ្ចេញហ្គាសចេញពីម៉ាស៊ីនត្រជាក់។

<u>វិធានការកាត់បន្ថយ</u>

ក្រុមហ៊ុនត្រូវមានវិធានការកាត់បន្ថយមួយចំនួនដូចខាងក្រោមៈ

- ក្រុមហ៊ុននឹងប្រើប្រាស់ប្រភពធនធានថាមពលជំនួសបាន និងធម្មជាតិឲ្យបានជាអតិបរមា និងការសាងសង់ទីលានពណ៌បៃតង។ ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ (បន្ទះស្រូបពន្លឺព្រះអាទិត្យនៅលើដំបូលផ្ទះលំហែរកាយ) អំពូលភ្លើងបំភ្លឺផ្លូវប្រើពន្លឺព្រះអាទិត្យ ព្រមទាំងបំពាក់អំពូលភ្លើង ដែលស៊ីថាមពលតិចដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល។
- បង្កើតកន្លែងស្តុកសំរាមលើកោះក្របី ដោយមានផែនការគ្រប់គ្រងយ៉ាងត្រឹមត្រូវមានការបែងចែកសំរាម និងមានពេលកំណត់ពេលវេលានៃការដឹកជញ្ជូនយ៉ាងច្បាស់លាស់នៅតាមតំបន់វីឡានីមួយៗ ព្រមទាំងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធ្វើការញែកសំរាម និងកែច្នៃធ្វើជាជីកំប៉ុសសំរាប់ប្រើប្រាស់នៅក្នុងសួនច្បារវិញ ព្រមទាំងកែច្នៃទៅជាឧស្ម័នសំរាប់ជាប្រភពថាមពលក្នុងការចំអិនអាហារ។ លើសពីនេះទៀត ការប្រមូលសំរាមត្រូវធ្វើជារៀងរាល់ថ្ងៃ ជៀសវាងការទុកសំរាមនៅក្នុងផ្ទះវីឡានីមួយៗយូរ។
- សាងសង់អាងចំរោះ (Septic tank) នៅតាមតំបន់ផ្ទះវីឡានីមួយៗដែលមានគំរបបិទជិត និងមានការគ្រប់គ្រងត្រឹមត្រូវ។ រាល់ទឹកស្អុយដែលចេញពីផ្ទះវីឡា និងភោជនីយដ្ឋាន និងអគារផ្សេងៗទាំងអស់ដែលស្ថិតនៅក្នុងតំបន់គម្រោង ក្រុមហ៊ុនបានដាក់អាងសិបទិកគ្រប់អគារទាំងអស់ក្នុងតំបន់គម្រោង ដើម្បីសំលាប់មេរោគ។
- ក្រុមហ៊ុនត្រៀមបំរុងម៉ាស៊ីនភ្លើង ដោយរៀបចំកន្លែងទុកដាក់ម៉ាស៊ីនភ្លើងនៅក្នុងបន្ទប់ដែលបំពាក់ដោយជញ្ជាំងអ៊ីសូឡង់ និងបំពាក់ឧបករណ៍ចម្រោះខ្យល់នៅហ្វឹងម៉ាស៊ីន ឬនៅត្រង់បំពង់ផ្សែងតែម្តង ដើម្បីជៀសវាងការរំខានដល់អ្នកទេសចរណ៍នៅលើកោះ។

- ក្រុមហ៊ុនត្រូវដាំដើមឈើនៅតាមដងផ្លូវ និងជុំវិញផ្ទះវីឡាបន្ថែមទៀតក្នុងតំបន់គម្រោង ព្រមទាំងដាំព្រៃឈើបន្ថែមកន្លែងណាដែលគ្មានព្រៃឈើដើម្បីស្រូបយកឧស្ម័នពុល។
- ក្រុមហ៊ុនបានរក្សាទុកព្រៃធម្មជាតិដែលមានស្រាប់នៅលើកោះបាន៨០% ដើម្បីរក្សាលំនឹងធម្មជាតិ និងកាត់បន្ថយការបំពុល។
- ក្រុមហ៊ុននឹងបំពាក់ឧបករណ៍គ្រឿងអេឡិចត្រូនិចដូចជា ទូរទឹកកក និងម៉ាស៊ីនត្រជាក់ដែលគ្មានសារធាតុបំផ្លាញស្រទាប់អូហ្សូន។

ខ. ការរំខានដោយសំលេង និងរំញ័រ

ការរំខានដោយសារសំលេងនៅក្នុងដំណាក់កាលនេះ បណ្តាលមកពីដំណើរការម៉ាស៊ីនភ្លើង ទូកដឹកភ្ញៀវ ទូកនេសាទ និងទូកទេសចរណ៍។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុននឹងប្រើប្រាស់ប្រភពធនធានថាមពលជំនួសបាន និងធម្មជាតិឲ្យបានជាអតិបរមា និងការសាងសង់ទីលានពណ៌បៃតង។ ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ (បន្ទះស្រូបពន្លឺព្រះអាទិត្យនៅលើដំបូលអគារ) អំពូលភ្លើងបំភ្លឺផ្លូវប្រើពន្លឺព្រះអាទិត្យ ព្រមទាំងបំពាក់អំពូលភ្លើងដែលស៊ីថាមពលតិច ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល ។
- ក្រុមហ៊ុននឹងប្រើប្រាស់ម៉ាស៊ីនភ្លើងដោយរៀបចំបន្ទប់សំរាប់ម៉ាស៊ីនភ្លើង និងម៉ាស៊ីនសំអាតសំណល់រាវព្រមទាំងមានការបំពាក់ឧបករណ៍ការពារការរំខានដោយសំលេង និងរំញ័រ ដើម្បីជួយកាត់បន្ថយសំលេងយ៉ាងមានប្រសិទ្ធិភាព។
- ក្រុមហ៊ុនមានផែនការរៀបចំដាំដើមឈើនៅតាមផ្លូវសំខាន់ៗមួយចំនួន និងនៅតាមសួនសាធារណៈ ដើម្បីជួសជុលនូវព្រៃឈើដែលបាត់បង់ និងជួយកាត់បន្ថយការរំខានដោយសំលេងពីទូកនេសាទ ទូកទេសចរណ៍ និងមាស៊ីននានាទៀត។
- ក្រុមហ៊ុនមានផែនការរៀបចំដាក់ផ្លាកសញ្ញាចរាចរណ៍នៅជុំវិញកោះ ដើម្បីកំណត់កន្លែងសម្រាប់ទូកនេសាទ និងទូកទេសចរណ៍។

គ. គុណភាពទឹក

នៅក្នុងដំណាក់កាលនៃការប្រតិបត្តិគម្រោង នឹងមានការបញ្ចេញសំណល់រាវប្រមាណ ៩៥ម$^{៣}$/ថ្ងៃ ព្រមទាំងសំណល់រឹង១៩៧គីឡូក្រាម/ថ្ងៃពីតំបន់ផ្ទះលំហែកាយ និងភោជនីយដ្ឋាន។ ករណីក្រុមហ៊ុនគ្រប់គ្រងសំណល់រឹង-រាវពុំបានត្រឹមត្រូវនោះទេ វានឹងបណ្តាលឱ្យមានការបំពុល

ដល់ទឹកសមុទ្រជាក់ជាពុំខាន ដោយសារការបោះចោលសំរាម និងបង្ហូរសំណល់រាវចូលទៅក្នុងទឹកសមុទ្រ។

<u>វិធានការកាត់បន្ថយ</u>

ដើម្បីទប់ស្កាត់ការបំពុលដល់គុណភាពទឹកសមុទ្រ ក្រុមហ៊ុនត្រូវមានវិធានការមួយចំនួនដូចខាងក្រោម៖

- បង្កើតកន្លែងស្តុកសំរាមនៅលើកោះក្របី ដោយមានផែនការគ្រប់គ្រងយ៉ាងត្រឹមត្រូវ ធ្វើការបែងចែកសំរាម និងកំណត់ពេលវេលានៃការដឹកជញ្ជូនយ៉ាងច្បាស់លាស់នៅតាមតំបន់ផ្ទះវីឡានីមួយៗ ព្រមទាំងសហការជាមួយអាជ្ញាធរមូលដ្ឋានទទួលបន្ទុកគ្រប់គ្រងសំណល់ ដើម្បីយកសំរាមទៅទុកដាក់នៅទីលានចាក់សំរាមតាមការកំណត់របស់អាជ្ញាធរដែនដី ឬក្រសួងបរិស្ថាន។
- ក្រុមហ៊ុនសាងសង់អាងចំរោះ (Septic tank) នៅតាមផ្ទះវីឡា ភោជនីយដ្ឋាន និងអគារផ្សេងៗទៀត។ ដើម្បីធ្វើការសំអាតដោយអនុលោមទៅតាមស្តង់ដាបរិស្ថាន នៃការបញ្ចេញសំណល់រាវទៅក្នុងប្រភពទឹកសាធារណៈ រួចយកសំណល់រាវដែលសំអាតរួចមកប្រើប្រាស់ឡើងវិញសម្រាប់ស្រោចសួនច្បារ ដើមឈើ ផ្កា និងដំណាំបន្លែផ្សេងៗនៅលើកោះ។

### ៧.៣.២.២ ធនធានជីវសាស្ត្រ

#### ក. ព្រៃឈើ និងសត្វព្រៃ

នៅក្នុងដំណាក់កាលដំណើរការគម្រោងនេះ បុគ្គលិក-កម្មកររបស់ក្រុមហ៊ុនមានការកាប់ឈើយកធ្វើអុសដុតសម្រាប់ដាំស្ល ឬការចំអិនអាហារនៅក្នុងភោជនីយដ្ឋាន ដែលមានការធ្វេសប្រហែលបង្កឲ្យមានភ្លើងឆេះព្រៃ។ សកម្មភាពគម្រោងនឹងមិនប៉ះពាល់ដល់វត្តមានសត្វព្រៃដែលមានស្រាប់នៅក្នុងតំបន់គម្រោងឡើយ ដោយក្រុមហ៊ុនសហការជាមួយរដ្ឋបាលព្រៃឈើដើម្បីយកសត្វព្រៃមួយចំនួនមកចិញ្ចឹមដូចជាសត្វស្វា ទោច ជាដើម។

ទន្ទឹមនឹងនេះដែរ អ្នកទេសចរណ៍មកស្នាក់នៅផ្ទះវីឡាអាចមានការធ្វេសប្រហែសនានាដូចជា ការចោលកន្ទុយបារីជាដើម អាចបណ្តាលអោយមានភ្លើងឆេះព្រៃនៅលើកោះក្របីនេះ។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុនត្រូវធ្វើការអប់រំណែនាំដល់បុគ្គលិក-កម្មករ និងអ្នកទេសចរណ៍នៅលើកោះក្របីទាំងអស់ កុំឱ្យកាប់ឈើ ជាពិសេសត្រូវអប់រំអោយមានការប្រុងប្រយ័ត្នក្នុងការចោលកន្ទុយបារី និងការបង្កាត់ភ្លើង ដើម្បីជៀសវាងភ្លើងឆេះព្រៃ។
- ក្រុមហ៊ុននឹងបន្តការដាំដើមឈើនៅតាមតំបន់ដែលគ្មានគម្របព្រៃឈើ ដើម្បីបង្កើនគម្របព្រៃឈើ និងជួយឲ្យតំបន់កោះក្របីក្លាយជាតំបន់អេកូទេសចរណ៍សម្បូរទៅដោយភាពបៃតង។
- ក្រុមហ៊ុននឹងសហការណ៍ជាមួយរដ្ឋបាលព្រៃឈើ ដើម្បីប្រលែងសត្វនៅក្នុងតំបន់កោះក្របីបានច្រើនថែមទៀតទៅតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច។
- ក្រុមហ៊ុនបំពាក់ឧបករណ៍បង្ការគ្រោះអគ្គីភ័យគ្រប់តំបន់ ដែលការរៀបចំនេះបានដាក់ភ្ជាប់បំពង់ស្របជាមួយប្រព័ន្ធផ្លូវមេ និងតំបន់កំសាន្តនានា។ ការប្រើប្រាស់ក្បាលម៉ាស៊ីនទឹកសំរាប់បំពង់ពន្លត់អគ្គីភ័យត្រូវបានដាក់ចំងាយ ១០០ម៉ែត្រមួយ តាមបណ្តោយផ្លូវសំខាន់ៗ ដោយយកប្រភពទឹកសមុទ្រ ហើយស្ថានីយ៍គ្រប់គ្រងប្រព័ន្ធបង្ការអគ្គីភ័យរៀបចំឡើងនៅក្នុងស្ថានីយ៍ត្រួតពិនិត្យសេវាកម្មផ្គត់ផ្គង់ផ្សេងៗ។

### ខ. ជីវៈចម្រុះក្នុងទឹកសមុទ្រ

សកម្មភាពគម្រោងនឹងបង្កឲ្យមានការប៉ះពាល់ដល់ពពួកសត្វ និងជីវៈចំរុះដែលរស់នៅក្នុងទឹកសមុទ្រជាពិសេសពពួកផ្កាថ្ម ដោយសារការបង្ហូរសំណល់រាវ និងការបោះចោលសំណល់រឹងចូលទៅក្នុងទឹកសមុទ្រ ពីសំណាក់អ្នកទេសចរដែលមកលេងកំសាន្តនៅរមណីយដ្ឋានកោះក្របីនេះ។ កត្តាសំខាន់នៅពេលប្រភពទឹកត្រូវបានបំពុល ពេលនោះប្រព័ន្ធជីវៈចំរុះនៅក្នុងទឹកសមុទ្រនឹងទទួលរងការប៉ះពាល់ដែរ។

លើសពីនេះទៀត សកម្មភាពទូកទេសចរណ៍ដែលបើកជុំវិញកោះនឹងបង្កឲ្យមានការលេចធ្លាយ ឬជ្រាបប្រេងចូលទៅក្នុងសមុទ្រ និងការប៉ះពាល់ដោយផ្ទាល់ដល់ប្រភេទផ្កាថ្មដែលមាននៅជុំវិញកោះ។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុនត្រូវរក្សាទុកព្រៃនៅតាមតំបន់ឆ្នេរជុំវិញកោះ ទៅតាមការកំណត់របស់ក្រសួង/ស្ថាប័នពាក់ព័ន្ធ ព្រមទាំងធ្វើការដាំដើមឈើនៅតាមឆ្នេរណាដែលគ្មានគំរបព្រៃ ឬមានព្រៃរេចរឹល។
- ចូលរួមថែទាំនូវគុណភាពសមុទ្រ ព្រមទាំងការពារការហូរច្រោះដី
- បង្កើតកន្លែងស្តុកសំរាមរបស់កោះក្របី ដោយមានផែនការគ្រប់គ្រងយ៉ាងត្រឹមត្រូវ។

- ក្រុមហ៊ុនសាងសង់អាងចំរោះ (Septic tank) នៅតាមអគារផ្ទះវីឡា ភោជនីយដ្ឋាន និងអគារនានាទៀត។ សំណល់ដែលសំអាតរួច ក្រុមហ៊ុនត្រូវយកមកប្រើប្រាស់ឡើងវិញសំរាប់ស្រោចសួនច្បារ ដើមឈើ និងដំណាំបន្លែផ្សេងៗទៅតាមតម្រូវការរបស់ក្រុមហ៊ុន។
- សាងសង់ប្រព័ន្ធបណ្តាញលូឱ្យបានត្រឹមត្រូវនៅគ្រប់អគារផ្ទះលំហែកាយ និងនៅតាមតំបន់ពាក់ព័ន្ធជៀសវាងការបង្ហូរសំណល់រាវចូលទៅក្នុងទឹកសមុទ្រ។
- ត្រូវដាក់ផ្លាកសញ្ញាកន្លែងដែលមានផ្កាថ្មច្រើន ឬតិច និងតំបន់ដែលហាមឃាត់មិនទូកទេសចរណ៍បើកឆ្លងកាត់។
- ត្រូវធ្វើការហាមឃាត់ដល់ប្រជាជនដែលមកធ្វើការនេសាទខុសច្បាប់ និងមិនត្រូវរកត្រីនៅតំបន់ណាដែលក្រុមហ៊ុនបានហាមឃាត់។

### ៧.៣.២.៣ ធនធានសេដ្ឋកិច្ច-សង្គម

#### ក. មុខរបរ និងប្រាក់ចំណូល

នៅដំណាក់កាលនេះអាចមានការប៉ះពាល់ដល់មុខរបរ និងប្រាក់ចំណូលរបស់ប្រជានេសាទមួយចំនួនដែលតែងតែទៅនេសាទនៅក្បែរតំបន់កោះក្របីនោះ ហើយម្ចាស់គម្រោងបានហាមឃាត់ប្រជាជនមិនឲ្យធ្វើការនេសាទនៅជិតកោះឡើយ ដោយតម្រូវឲ្យពួកគាត់នេសាទឲ្យឆ្ងាយពីកោះចម្ងាយ ២៥០ម៉ែត្រពីមាត់ទឹក។ ការកំណត់ដែននេសាទនេះនឹងប៉ះពាល់ដល់ចំណូលខ្លះៗរបស់អ្នកនេសាទ។

<u>វិធានការកាត់បន្ថយ</u>

- ម្ចាស់គម្រោងនឹងអនុញ្ញាត្យប្រជាជននេសាទជុំវិញកោះក្របីនៅចម្ងាយ ២៥០ម៉ែត្រពីមាត់ទឹក ដោយដាក់ពោងបណ្តែតជាសញ្ញានៅជុំវិញកោះ។ ម្ចាស់គម្រោងនឹងផ្តល់អាទិភាពដល់ប្រជាជនដែលធ្វើការនេសាទនៅជុំវិញកោះ ចូលបម្រើការងារជាបុគ្គលិក/កម្មករនៅក្នុងដំណាក់កាលដំណើរការគម្រោង។
- ទន្ទឹមនឹងនោះ ម្ចាស់គម្រោងនឹងរៀបចំមូលនិធិបរិស្ថាន-សង្គម ដើម្បីជួយសម្រួលដល់ជីវភាពប្រជាជនដែលងាយរងឥទ្ធិពលពីគម្រោងដូចជា ចូលរួមក្នុងការអភិរក្សព្រៃ ផ្កាថ្ម និងបណ្តុះបណ្តាលប្រជាជនឲ្យមានជំនាញ អាចធ្វើការនៅក្នុងតំបន់អភិវឌ្ឍន៍បានជាដើម។
- ក្រុមហ៊ុននឹងទិញផលនេសាទដែលគាត់នេសាទបាន និងទិញបន្លែ ផ្លែឈើដែលគាត់ដាំបានដើម្បីផ្គត់ផ្គង់នៅក្នុងភោជនីយដ្ឋានលើកោះក្របី។

### ខ. សុខភាព និងសុខមាលភាពសាធារណៈ

ពាក់ព័ន្ធនឹងដំណាក់កាលប្រតិបត្តិ និងដាក់ឲ្យដំណើរការអគារផ្ទះលំហែកាយ ភោជនីយដ្ឋាន និងសំណង់រូបវន្តនានា នឹងមានគ្រោះថ្នាក់មួយចំនួនដល់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ ដោយសារការលង់ទឹក ឬលិចទូកនៅពេលភ្ញៀវទាំងនោះមិនមានការប្រុងប្រយ័ត្ន ដូចជាស្រវឹងស្រាចុះងូតទឹក ឬជិះទូកកំសាន្តជាដើម។ ការប៉ះពាល់ដល់សុខភាពមួយចំនួនដោយសារសត្វល្អិតទិច ឬខាំ ឬសត្វមូសគ្រុនចាញ់ដែលកើតមាននៅលើកោះ។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុនមានផែនការរៀបចំជារមណីយដ្ឋានទេសចរណ៍ដ៏ប្រណិត សម្រាប់ទាក់ទាញអ្នកទេសចរណ៍មកស្នាក់នៅលំហែកាយ ងូតទឹកសមុទ្រ និងការចុះទស្សនាផ្កាថ្មបាតសមុទ្រ។ ជាងនេះទៅទៀត តំបន់កោះក្របីមានផ្ទាំងថ្មស្អាតៗលាយឡំជាមួយទឹកសមុទ្រ និងខ្យល់អាកាសបរិសុទ្ធដែលអាចឲ្យអ្នកទេសចរណ៍អាចសម្រាកលំហែកាយរយៈពេលយូរថ្ងៃ។
- ក្រុមហ៊ុនមានផែនការរៀបចំដាក់ផ្លាកសញ្ញាពោងបណ្តែតទឹកនៅតំបន់មានទឹកជ្រៅ ឬតំបន់ដែលអាចងូតទឹកបាន ឬតំបន់អាចជិះទូក ឬម៉ូតូលើទឹកបាន។ បន្ថែមពីនេះ ម្ចាស់គម្រោងនឹងតម្រូវឲ្យអ្នកទេសរចណ៍ដែលជិះទូក ឬម៉ូតូលើទឹកត្រូវបំពាក់សម្ភារៈការពារខ្លួនដូចជាអាវពោង វ៉ែនតា និងសម្ភារៈផ្សេងៗទៀត។
- ក្រុមហ៊ុនត្រៀមឧបករណ៍ និងសម្ភារៈសង្គ្រោះបន្ទាន់ ករណីមានអ្នកលង់ទឹក ឬលិចទូកដោយត្រៀមទូកល្បឿន ឧបករណ៍មុជទឹក ឧបករណ៍សង្គ្រោះ និងបន្ទប់ព្យាបាលជម្ងឺដោយមានគ្រូពេទ្យប្រចាំការនៅតំបន់គម្រោងនេះ។ ករណីមានអ្នកជមង្ឺឈឺខ្លាំង ឬគ្រោះថ្នាក់ខ្លាំង ក្រុមហ៊ុនមានផែនការបញ្ជូនអ្នកជម្ងឺតាមទូកល្បឿន ឬរថយន្តទៅកាន់ទីរួមខេត្តព្រះសីហនុ ឬដឹកអ្នកជម្ងឺតាមរថយន្តទៅព្យាបាលនៅរាជធានីភ្នំពេញ។
- ក្រុមហ៊ុនមានបន្ទប់ពេទ្យ ដែលមានគ្រូពេទ្យប្រចាំការ២៤ម៉ោង សម្រាប់សង្គ្រោះបន្ទាន់នៅពេលភ្ញៀវទេសចរណ៍ ឬបុគ្គលិកមានជំងឺ ឬបញ្ហាផ្សេងៗ។

### គ. ការប្រើប្រាស់ទឹកស្អាត និងថាមពលអគ្គិសនី

អាស្រ័យដោយគម្រោងនេះស្ថិតនៅលើកោះដែលជាកន្លែងពុំមានប្រភពទឹកសាប ឬបណ្តាញអគ្គិសនីឡើយ ហើអ្នកទេសចរណ៍មកស្នាក់នៅប្រមាណពី ៨០នាក់ទៅ ១០០នាក់ (ករណីភ្ញៀវទេសចរណ៍មកស្នាក់នៅក្នុងផ្ទះវីឡាទាំង ៥០ពេញទាំងអស់) និងបុគ្គលិកធ្វើការចំនួន១៣០នាក់ ដែលជាហេតុតម្រូវការទឹកស្អាតប្រមាណ ៦៥ម៉ែត្រគូប ហើយអគារដែលតម្រូវ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ការទឹកច្រើនជាងគេគឺតំបន់ផ្ទះលំហែរកាយ ដែលតម្រូវការទឹកចំនួន១៦ម៉ែត្រគូបក្នុង១ថ្ងៃ និងអគារ ដែលតម្រូវការច្រើនបន្ទាប់គឺអគារការិយាល័យ និងប្រើប្រាស់សំរាប់ថែទាំផ្លូវ និងសួនច្បារ ដែលមានចំនួន ៨ម៉ែត្រគូបក្នុង១ថ្ងៃ។

ដោយឡែក តម្រូវការថាមពលអគ្គិសនីប្រើប្រាស់ប្រមាណ ២០០KW ហើយអគារដែលប្រើប្រាស់អគ្គិសនីច្រើនជាងគេគឺអគារផ្ទះលំហែកាយ ដែលមានតម្រូវការ ១១៣KW ក្នុង១ថ្ងៃ។ ចំណែក អគារដែលមានតម្រូវការថាមពលអគ្គិសនីតិចជាងគេគឺការិយាល័យ។

ដូចនេះ គម្រោងអភិវឌ្ឍន៍រមណីដ្ឋានកោះក្របីនេះនឹងជួបប្រទះនូវបញ្ហាប្រភពទឹកស្អាត និងការផ្គត់ផ្គង់ថាមពលអគ្គិសនី ដោយសារតំបន់នេះគ្មានបណ្តាញដែលមានស្រាប់ឡើយ។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុននឹងប្រើប្រាស់ប្រភពធនធានថាមពលជំនួសបាន និងធម្មជាតិឲ្យបានជាអតិបរមា និងការសាងសង់ទីលានពណ៌បៃតង។ ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ (បន្ទះស្រូបពន្លឺព្រះអាទិត្យនៅលើដំបូលផ្ទះលំហែរកាយ) អំពូលភ្លើងបំភ្លឺផ្លូវប្រើពន្លឺព្រះអាទិត្យ ព្រមទាំងបំពាក់អំពូលភ្លើងដែលស៊ីថាមពលតិច ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល។
- ក្រុមហ៊ុនរៀបចំអាងស្តុកទឹកភ្លៀងសម្រាប់ផ្គត់ផ្គង់ទឹក ក្នុងតំបន់គម្រោង។ លើសពីនេះទៀត ក្រុមហ៊ុនមានផែនការផលិតទឹកឡើងវិញដោយការបន្សុតទឹក និងការប្រើប្រាស់ឧបករណ៍ចម្រាញ់ទឹកប្រើឡើងវិញ។
- ក្រុមហ៊ុនរៀបចំប្រព័ន្ធស្តុកទឹកដោយយកទឹកពីដីគោក មកស្តុកទុកនៅលើកោះដើម្បីផ្គត់ផ្គង់ទឹកស្អាតឲ្យបានគ្រប់គ្រាន់សម្រាប់អ្នកទេសចរ។
- ក្រុមហ៊ុននឹងបំពាក់ឧបករណ៍បន្ទប់ទឹក និងផ្ទះបាយណាដែលអាចសន្សំសំចៃទឹកបាននៅក្នុងអគារនីមួយៗ។
- ក្រុមហ៊ុនបានរចនាសំណង់អគារនេះដោយបានគិតពីចំនាំងពន្លឺព្រះអាទិត្យ ចូលអគារដែលអាចជួយកាត់បន្ថយការប្រើប្រាស់ភ្លើងបំភ្លឺនៅពេលថ្ងៃ។
- ក្រុមហ៊ុននឹងបំពាក់ឧបករណ៍អេឡិចត្រូនិចណាដែលអាចជួយសន្សំសំចៃថាមពលបាននៅក្នុងអគារ។
- ក្រុមហ៊ុននឹងធ្វើសេចក្តីជូនដំណឹងដល់អ្នកទេសចរ ដែលមកស្នាក់នៅលើកោះក្របីឱ្យប្រើប្រាស់ថាមពលអគ្គិសនី និងទឹកស្អាតប្រកបដោយការសន្សំសំចៃ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

### ឃ. គ្រោះថ្នាក់ដោយគ្រោះធម្មជាតិ

គ្រោះធម្មជាតិ និងគ្រោះអាសន្នផ្សេងៗដូចជា ទឹកជំនន់ រញ្ជួយដី រន្ទះបាញ់ ខ្យល់ព្យុះ ការបាក់ដី និងគ្រោះអគ្គីភ័យអាចកើតមានឡើងជាយថាហេតុអាចបង្កអោយមានការខូចខាត និងរលំអគារផ្ទះលំហែកាយ និងហេដ្ឋារចនាសម្ព័ន្ធនានានៅលើកោះក្របីដែលអាចបណ្តាលអោយមានការប៉ះពាល់ដល់អ្នកទេសចរណ៍ បុគ្គលិក/កម្មករ និងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុននឹងបំពាក់ឧបករណ៍ការពាររន្ទះ lightning system នៅក្នុងអគារផ្ទះវីឡានីមួយៗនេះដើម្បីការពាររន្ទះបាញ់។
- សំណង់អគារទាំងឡាយនៅលើកោះក្របី ត្រូវបានរចនាឡើងដោយគិតអំពីទិសខ្យល់បក់ និងទប់ទល់ខ្យល់ព្យុះ ដោយវិស្វករ និងអ្នកបច្ចេកទេសមកពីបរទេស។
- ក្រុមហ៊ុននឹងបង្កើតសញ្ញាប្រកាសអាសន្ននៅលើកោះក្របីទាំងមូល ដោយមានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានដែលប្រចាំការនៅលើកោះក្របីនេះ។
- ក្រុមហ៊ុននឹងបំពាក់ប្រព័ន្ធគ្រប់គ្រងអគ្គីភ័យយ៉ាងគ្រប់គ្រាន់ និងមានប្រសិទ្ធិភាពខ្ពស់នៅគ្រប់អគារផ្ទះវីឡា ភោជនីយដ្ឋាន និងអគារនានា។
- បណ្តាញអគ្គិសនីនៅក្នុងអគារនេះត្រូវបានរៀបចំឡើងដោយវិស្វករមកពីប្រទេសបរទេស និងធ្វើសហប្រតិបត្តិការជាមួយអ្នកជំនាញការជាតិកម្ពុជា ដើម្បីធានាអោយបាននូវសុវត្ថិភាព។

### ង. សុវត្ថិភាពបុគ្គលិក និងកម្មករ

នៅក្នុងដំណាក់កាលអាចមានបញ្ហាទាក់ទងទៅនឹងសុវត្ថិភាពរបស់បុគ្គលិក និងកម្មករដែលបម្រើការងារនៅលើកោះក្របីនេះ ដែលបញ្ហានេះទាក់ទងទៅនឹងសុវត្ថិភាពក្នុងការធ្វើដំណើរ ការស្នាក់នៅ ក្នុងកំឡុងពេលបំពេញការងារ។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុនបានសាងសង់កន្លែងស្នាក់នៅដល់បុគ្គលិក និងកម្មករដើម្បីស្នាក់នៅលើកោះមានបន្ទប់គេង មានផ្ទះបាយសម្រាប់បុគ្គលិកទាំងអស់ ដោយមិនអនុញ្ញាតឲ្យបុគ្គលិកធ្វើដំណើរទៅមក ដែលអាចកាត់បន្ថយការប៉ះពាល់ទៅលើសុវត្ថិភាព ក្នុងការធ្វើដំណើរដោយផ្លូវទឹកជារៀងរាល់ថ្ងៃ។
- ក្រុមហ៊ុនមានបន្ទប់ពេទ្យ ដែលមានគ្រូពេទ្យប្រចាំការ២៤ម៉ោង សម្រាប់សង្គ្រោះបន្ទាន់នៅពេល បុគ្គលិកមានជំងឺ ឬបញ្ហាផ្សេងៗ។
- ផ្តល់ជូនដល់បុគ្គលិក និងកម្មករនូវការធានារ៉ាប់រងអាយុជីវិត ដល់បុគ្គលិទាំងអស់។

- ក្នុងករណីបុគ្គលិកធ្វើដំណើរម្តងម្កាល ក្រុមហ៊ុនផ្តល់ជូនអាវពង និងមានត្រៀមកប៉ាល់សង្គ្រោះបន្ទាប់នៅពេលមានបញ្ហាលិចទូក។

### ៨.៣.៣ ដំណាក់កាលបញ្ចប់គម្រោង(Final Phase)

នៅក្នុងដំណាក់កាលនេះ សកម្មភាពរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់នៃការទទួលបានការសម្បទានកោះក្របីពីរាជរដ្ឋាភិបាល សំរាប់អភិវឌ្ឍន៍ រមណីយដ្ឋានផ្ទះលំហែរកាយទំនើបលំដាប់ពិភពលោក។ ដូចនេះ ក្រុមហ៊ុននឹងផ្ទេររមណីយដ្ឋានដ៏ស្រស់ស្អាតនេះ ជូនរាជរដ្ឋាភិបាលវិញ ដើម្បីកាន់កាប់ និងដំណើរការបន្ត។

### ៧.៣.៣.១ ធនធានរូបសាស្ត្រ

ក. ការបំពុលខ្យល់

នៅក្នុងដំណាក់កាលនេះនឹងអាចមានការបំពុលខ្យល់ចេញមកពី ផ្សែងម៉ាស៊ីនទូក និងកប៉ាល់ ដែលដឹកជញ្ជូនសម្ភារៈចេញពីកោះ។ ម៉ាស៊ីនទូក និងកប៉ាល់នេះ នឹងបញ្ចេញនូវសារធាតុបំពុលខ្យល់មួយចំនួន ដូចជា $NO_x$ , $SO_x$ , $SO_x$ និងTSP។

<u>វិធានការកាត់បន្ថយ</u>

ក្រុមហ៊ុនត្រូវមានវិធានការកាត់បន្ថយមួយចំនួនដូចខាងក្រោមៈ

- ក្រុមហ៊ុនបានរក្សាទុកព្រៃធម្មជាតិដែលមានស្រាប់នៅលើកោះបាន៨០% ដើម្បីរក្សាលំនឹងធម្មជាតិ និងកាត់បន្ថយការបំពុល។
- ក្រុមហ៊ុននឹងបំពាក់ឧបករណ៍ផលិតកម្មស្អាត នៅតាមបំពង់បញ្ចេញផ្សែងរបស់ទូកកប៉ាល់ និងគ្រឿងម៉ាស៊ីនផ្សេងៗ។
- រាល់សម្ភារៈ និងឧបករណ៍ផ្សេងៗក្នុងតំបន់គម្រោង ក្រុមហ៊ុនមិនយកចេញទេ។

ខ. ការរំខានដោយសំលេង និងរំញ័រ

ការរំខានដោយសារសំលេងនៅក្នុងដំណាក់កាលនេះ បណ្តាលមកពីដំណើរការម៉ាស៊ីនទូក កប៉ាល់ និងម៉ាស៊ីនផ្សេងៗទៀត។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុនមានផែនការរៀបចំដាំដើមឈើនៅតាមផ្លូវសំខាន់ៗមួយចំនួន និងនៅតាមសួនសាធារណៈ ដើម្បីជួសជុលនូវព្រៃឈើដែលបាត់បង់ និងជួយកាត់បន្ថយការរំខានដោយសំលេងពីទូកនេសាទ ទូកទេសចរណ៍ និងមាស៊ីននានាទៀត។

- ក្រុមហ៊ុនបានរៀបចំដាក់ផ្លាកសញ្ញាចរាចរណ៍នៅជុំវិញកោះ ដើម្បីកំណត់កន្លែងសម្រាប់ទូកនេសាទ និងទូកទេសចរណ៍។
- រាល់សម្ភារៈ និងឧបករណ៍ផ្សេងៗក្នុងតំបន់គម្រោង ក្រុមហ៊ុនមិនយកចេញទេ។

គ. គុណភាពទឹក

នៅក្នុងដំណាក់កាលនេះ អាចមានការប៉ះពាល់ដល់គុណភាពទឹក ដោយសារបន្សល់នូវសម្ភារៈចាស់ៗមួយចំនួន និង សំណល់ភក់ដែលនៅសេសសល់ក្នុងអាងសិបទិក។

<u>វិធានការកាត់បន្ថយ</u>

- សហការជាមួយមន្ទីរសាធារណៈការខេត្តព្រះសីហនុ ដើម្បីសំអាតភក់នៅក្នុងអាងសិបទិក។
- ការដេកជញ្ជូនចេញត្រូវបានធ្វើឡើងដោយមានការបំរ៉ុងប្រយ័ត្នចំពោះការកំពប់រឺលេចជ្រាប។
- សម្ភារៈចាស់ៗ និងដឹងជញ្ជូនចេញ ហើយចែកចាយជូនប្រជាជននូវសម្ភារៈដែលអាចប្រើប្រាស់បាន។ ចំណែកសម្ភារៈប្រើប្រាស់មិនបានក្រុមហ៊ុនសហការជាមួយក្រុមហ៊ុនប្រមូលសំរាមដើម្បីយកទៅបោះចោលនៅទីលានចាក់សំរាមខេត្តព្រះសីហនុ។

## ៧.៣.៣.២ ធនធានជីវសាស្ត្រ

ក. ជីវៈចម្រុះក្នុងទឹកសមុទ្រ

សកម្មភាពបញ្ចប់គម្រោងនេះ នឹងបង្កឲ្យមានការប៉ះពាល់ដល់ពពួកសត្វ និងជីវៈចំរុះដែលរស់នៅក្នុងទឹកសមុទ្រជាពិសេសពពួកផ្កាថ្ម ដោយសារការបង្ហូរសំណល់ភក់ ចេញពីអាងសិបទិក ចូលទៅក្នុងទឹកសមុទ្រ។ កត្តាសំខាន់នៅពេលប្រភពទឹកត្រូវបានបំពុល ពេលនោះប្រព័ន្ធជីវៈចំរុះនៅក្នុងទឹកសមុទ្រនឹងទទួលរងការប៉ះពាល់ដែរ។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុនត្រូវរក្សាទុកព្រៃនៅតាមតំបន់ឆ្នេរជុំវិញកោះ ទៅតាមការកំណត់របស់ក្រសួង/ស្ថាប័នពាក់ព័ន្ធ ព្រមទាំងធ្វើការដាំដើមឈើនៅតាមឆ្នេរណាដែលគ្មានគំរបព្រៃ ឬមានព្រៃរេចរឹល។
- សំណល់ភក់ដែលនៅសេសសល់ក្រុមហ៊ុន នឹងសហការជាមួយមន្ទីរសាធារណៈការ និងដឹកជញ្ជូន ដើម្បីដឹកជញ្ជូនចេញទៅចោលនៅទីតាំងដែលមន្ទីរសាធារណៈការ បរិស្ថាន និងអាជ្ញធរខេត្តអនុញ្ញាត។

- ការដឹកជញ្ជូនសំណល់ភក់ចេញ គឺ ត្រឹមត្រូវតាមបច្ចេកទេសកុំឲ្យមានការកំពប់ ឬលេចជ្រាប។

### ៧.៣.៣.៣ ស្ថានភាពសង្គមសេដ្ឋកិច្ច

#### ក. មុខរបរ និងប្រាក់ចំណូល

នៅដំណាក់កាលនេះអាចមានការប៉ះពាល់ដល់មុខរបរ និងប្រាក់ចំណូលរបស់ប្រជាជនមួយចំនួនបានទៅធ្វើការនៅរមណីយដ្ឋានកោះក្របីនោះ ហើយនៅពេលបញ្ចប់គាត់នឹងជួបបញ្ហាគ្មានការងារធ្វើ។

<u>វិធានការកាត់បន្ថយ</u>

- ម្ចាស់គម្រោងនឹងផ្តល់វគ្គអប់រំបណ្តុះបណ្តាលបុគ្គលិក ទាំងអស់ឲ្យមានជំនាញកាន់តែច្បាស់លាស់ និងពិតប្រាកដ ដែលពួកគាត់អាចរកការងារបានធ្វើនៅពេលបញ្ចប់គម្រោង។
- ផ្តល់ព័ត៌មានជូនបុគ្គលិក នៅពេលវេលាបញ្ចប់គម្រោងឲ្យបានច្បាស់លាស់ ដែលពួកគាត់អាចរកការងារនៅកន្លែងទៀតបានធ្វើនៅពេលបញ្ចប់គម្រោង។
- នៅពេលបញ្ចប់ក្រុមហ៊ុន នឹងសហការជាមួយរដ្ឋាភិបាល ដើម្បីអនុញ្ញាតឲ្យបុគ្គិលិកទាំងអស់អាចបន្តការងារធ្វើដូចធម្មតា។

### ៧.៣.៤ បណ្តុំនៃហេតុប៉ះពាល់ដែលអាចកើតមានឡើង

តាមស្ថានភាពជាក់ស្តែងនៃទីតាំងគម្រោងអភិវឌ្ឍន៍កោះក្របីនេះ បានបង្ហាញថានៅជុំវិញតំបន់គម្រោងមានគម្រោងអភិវឌ្ឍន៍ផ្សេងៗទៀត ដែលអាចធ្វើឲ្យមានការប៉ះពាល់ដល់បរិស្ថានជុំវិញផងដែរ ក្នុងនោះមានគម្រោងអភិវឌ្ឍន៍កោះតាកៀវ គម្រោងអភិវឌ្ឍន៍កោះឬស្សី គម្រោងអភិវឌ្ឍន៍ព្រះ និងតំបន់ទេសចរណ៍ឆ្នេរសមុទ្ររាម។ ម្យ៉ាងទៀតប្រជាពលរដ្ឋដែលរស់នៅភូមិអុង ក៏រួមចំណែកក្នុងការបំផ្លាញបរិស្ថាន ជុំវិញតំបន់គម្រោងផងដែរ។ ការបង្ហាញនៃហេតុប៉ះពាល់ទាំងនេះ មានដូចខាងក្រោម៖

#### ក. គម្រោងអភិវឌ្ឍន៍កោះដែលនៅជុំវិញ

នៅជុំវិញតំបន់គម្រោងអភិវឌ្ឍន៍កោះក្របីនេះ មានគម្រោងអភិវឌ្ឍន៍កោះជារមណីយដ្ឋានមួយចំនួនដែលនៅជុំវិញ ដូចជារមណីយដ្ឋានកោះឬស្សីមានចំងាយ០,៨គីឡូម៉ែត្រពីកោះក្របី រមណីយដ្ឋានកោះតាកៀវមានចំងាយ១,៣គីឡូម៉ែត្រពីកោះក្របី និងរមណីយដ្ឋានកោះព្រះ

មានចំងាយ២,៥គីឡូម៉ែត្រពីកោះក្របី។ ដោយសារកោះដែលនៅជុំវិញក្របី សុទ្ធតែតំបន់គម្រោងដែលត្រូវអភិវឌ្ឍន៍ ហេតុដូចនេះគម្រោងអភិវឌ្ឍន៍ទាំងនេះអាចធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹកសមុទ្រ គុណភាពខ្យល់ ការហូរច្រោះដី ធនធានជលផល និងផ្កាថ្ម តាមរយៈសកម្មភាពនៃការប្រតិបត្តិគម្រោងដូចខាងក្រោម៖

- ការឈូសឆាយដីដើម្បីសាងសង់ មិនត្រឹមត្រូវតាមបច្ចេកទេស
- ការគ្រប់គ្រងសំណល់រឹង និងរាវមិនបានត្រឹមត្រូវ
- ការហៀរកំពប់ប្រេងចេញពីម៉ាស៊ីន និងគ្រឿងចក្រ
- ការភាពអនាធិបតេយ្យរបស់បុគ្គលិក និងកម្មករ ក្នុងការនេសាទ និងបំផ្លាញធនធានផ្កាថ្ម
- ការបោះចោលនូវកាកសំណល់របស់បុគ្គលិក និងកម្មករចូលក្នុងទឹកសមុទ្រដែលធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹកសមុទ្រ។

### ខ. ប្រជាពលរដ្ឋដែលលក់ដូរនៅតាមឆ្នេរសមុទ្ររាម

ប្រជាពលរដ្ឋដែលលក់ដូរនៅតាមឆ្នេរសមុទ្ររាមក៏អាចរួមចំណែកក្នុងការធ្វើឲ្យខូចគុណភាពបរិស្ថានផងដែរ។ ការប៉ះពាល់នេះស្តែងឡើងតាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ការបោះចោលសំណល់រឹង ចូលក្នុងទឹកសមុទ្រ។
- ការបង្ហូរចូលសំណល់រាវចូលក្នុងទឹកសមុទ្រ។
- ការហៀរកំពប់ប្រេងពីម៉ាស៊ីនទូក ដែលដឹកជញ្ជូនភ្ញៀវទេសចរណ៍កំសាន្តនៅតំបន់ជុំវិញ។

### គ. ប្រជាពលរដ្ឋដែលរស់នៅភូមិអុង

ប្រជាពលរដ្ឋដែលរស់នៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ គឺជាភូមិដែលជាប់សមុទ្រ និងមានប្រជាជនប្រកបរបរនេសាទផងដែរ។ ប្រជាជនដែលរស់ក្នុងភូមិនេះ ក៏អាចរួមចំណែកក្នុងការធ្វើឲ្យខូចគុណភាពបរិស្ថានផងដែរ ការប៉ះពាល់នេះស្តែងឡើងតាមរយៈសកម្មភាពមួយចំនួនដូចខាងក្រោម៖

- ការគ្រប់គ្រងសំណល់រឹង ចូលក្នុងទឹកសមុទ្រ។
- ការបង្ហូរចូលសំណល់រាវចូលក្នុងទឹកសមុទ្រ។
- ការហៀរកំពប់ប្រេងពីម៉ាស៊ីនទូកនេសាទ និងការចោលកន្ទុយបារីចូលក្នុងសមុទ្រ។
- ការបោះយុតថ្កា នៅពេលចតទូកដែលអាចប៉ះពាល់ដល់ធនធានផ្កាថ្ម។




រូបភាព៧.៣៖ គម្រោងអភិវឌ្ឍន៍កោះផ្សេងៗទៀតដែលនៅជុំវិញតំបន់តំបន់កោះក្របី

## តារាង ៧.២ ៖ សង្ខេបទំហំនៃហេតុប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច-សង្គមអវិជ្ជមាន និងវិធានការកាត់បន្ថយ

| ហេតុប៉ះពាល់សំខាន់ៗ | ទំហំនៃហេតុប៉ះពាល់ | | | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| | តិច | មធ្យម | ខ្លាំង | |
| **ដំណាក់កាលសាងសង់គម្រោង** | | | | |
| **១-ធនធានរូបសាស្ត្រ** | | | | |
| (ក)-សណ្ឋានដី<br>- ការឈូសឆាយដីទួល ឬដំបូកខ្ពស់ដើម្បីពង្រាបដីឲ្យស្មើ<br>-ការបំបែកយកផ្ទាំងថ្មនៅកន្លែងមួយចំនួនដើម្បីរៀបចំគ្រឹះអគារ និងសំណង់រូបវន្តដទៃទៀត<br>- បង្កឲ្យមានអាចម៍ដីជាច្រើននៅតាមការដ្ឋាន | | ✓ | | - ឈូសឆាយដីទៅតាមលក្ខណៈសណ្ឋានដី<br>- សិក្សាពីប្លង់គម្រោងលំអិតជាមុនសិន មុននឹងធ្វើការឈូសឆាយ<br>- ជៀសវាងការបំបែកយកថ្មច្រើនពេក ឬការជីកយកដីជ្រៅហួសហេតុពេក<br>- ប្រមូលអាចម៍ដីទៅចាក់បំពេញនៅតំបន់ទំនាប ឬកន្លែងគ្រលុក។ |
| (ខ)-ការហូរច្រោះដី និងការខូចគុណភាពដី<br>- ការឈូសឆាយដី ការចាក់បំពេញដី<br>- ការបោះចោលសំណល់រឹង និងការបង្ហូរសំណល់រាវ<br>- ភ្លៀងធ្លាក់ខ្លាំង | | ✓ | | - ការកិនបង្ហាប់ដី<br>- ការដាំរុក្ខជាតិនៅជុំវិញតំបន់អភិវឌ្ឍន៍ និងរៀបថ្មទប់ការបាក់ដី និងហូរច្រោះដី<br>- មានផែនការគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទ។ |
| (គ)-ការបំពុលទឹក<br>- ការឈូសឆាយដី<br>- សំណល់ពីការសាងសង់ ដូចជាកំណាត់ដែក កំណាត់ឈើ កំទេចស៊ីម៉ង់ត៍ កំបោរ ។ល។ | | ✓ | | - ឈូសឆាយដីនៅរដូវប្រាំង<br>- ធ្វើការអប់រំដល់បុគ្គលិក-កម្មករឱ្យយល់ដឹងអំពីអនាម័យដោយត្រូវវេចខ្ចប់រាល់សំណល់ផ្ទះបាយរបស់ខ្លួន និងទុកដាក់ឱ្យបានត្រឹមត្រូវ។<br>- សង់ប្រព័ន្ធបង្ហូរសំណល់រាវ។ |
| (ឃ)-គុណភាពខ្យល់:<br>- សកម្មភាពឈូសឆាយដី<br>- គ្រឿងចក្រ និងម៉ាស៊ីនភ្លើង<br>- ទីតាំងទុកដាក់សំណល់ | | ✓ | | -សំណល់សំណង់ត្រូវច្រកចូលទៅក្នុងការ៉ុង/បាវរួចចងឱ្យជិត មុននឹងធ្វើការដឹកជញ្ជូនយកទៅចោលទៅតាមការកំណត់របស់ ក្រសួងបរិស្ថាន<br>-បាញ់ស្រោចទឹកនៅក្នុងតំបន់សាងសង់<br>-ប្រើប្រាស់រថយន្តដឹកជញ្ជូន និងគ្រឿងចក្រថ្មីៗព្រមទាំងធ្វើការត្រួតពិនិត្យ និងថែទាំជាទៀងទាត់ |

| | | | | |
|---|---|---|---|---|
| | | | | នូវគុណភាពរបស់វា។ |
| **(ង)-ការរំខានដោយសំលេង និងរំញ័រ:**<br>- សកម្មភាពរបស់គ្រឿងចក្រ<br>- ការបុកគ្រឹះបង្ហាប់ដី<br>- ម៉ាស៊ីនភ្លើង | | ✓ | | -កំណត់ម៉ោងធ្វើការសាងសង់គឺចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៥:០០ ល្ងាច<br>-បំពាក់ឧបករណ៍ទប់សំឡេងដល់បុគ្គលិក-កម្មករដែលនៅជាមួយគ្រឿងម៉ាស៊ីន។<br>-ប្រើប្រាស់គ្រឿងចក្រ និងម៉ាស៊ីនភ្លើងធុនទំនើបដែលបញ្ចេញសំលេងតិច<br>-កម្រិតសំលេងចេញពីប្រភពគ្រឿងចក្រនៅក្នុងចំងាយ ១០០ម៉ែត្រទៅកាន់បរិស្ថានដែលនៅជុំវិញគឺមិនលើសពី ៧៥ dB(A) នៅពេលថ្ងៃ។ |
| **២-ធនធានជីវសាស្ត្រ** | | | | |
| **ក-ធនធានព្រៃឈើ និងទីជំរកៈ**<br>- ធនធានព្រៃឈើមានការបាត់បង់ប្រមាណ ២ហិកតា ដោយសារក្រុមហ៊ុនធ្វើការឈូសឆាយដើម្បីអភិវឌ្ឍន៍នៅលើកោះ<br>- បញ្ហាភ្លើងឆេះព្រៃ។ | | ✓ | | -កំណត់កន្លែងដែលត្រូវឈូសឆាយដីព្រៃ<br>- ដាំដើមឈើ និងរុក្ខជាតិឡើងវិញ<br>- សហការជាមួយស្ថាប័នមានសមត្ថកិច្ច មុននឹងធ្វើការឈូសឆាយ<br>- ដាក់ពិន័យដល់កម្មករដែលកាប់ព្រៃឈើដោយមិនមានការអនុញ្ញាត<br>- អប់រំដល់កម្មករឲ្យប្រយ័ត្នពីភ្លើងឆេះព្រៃ។<br>- តំបន់ដែលគ្មានព្រៃ ក្រុមហ៊ុននឹងធ្វើការដាំបន្ថែមដើម្បីបង្កើនគម្របព្រៃឈើ និងប្រែក្លាយទៅជាតំបន់បៃតង។ |
| **ខ-ពពួកសត្វព្រៃៈ**<br>អាចមានការប៉ះពាល់ដល់ប្រភេទសត្វតូចៗចំនួន ៧ប្រភេទដែលមានវត្តមាននៅក្នុងតំបន់គម្រោង | | | ✓ | -ក្រុមហ៊ុនបានយកសត្វព្រៃមកចិញ្ចឹមនៅលើកោះនេះបន្ថែមដូចជាសត្វស្វាជាដើម។<br>-ដាំដើមឈើ និងរុក្ខជាតិឡើងវិញ<br>- ដាក់ពិន័យដល់កម្មករដែលបរបាញ់សត្វព្រៃ។ |
| **គ-ជីវចំរុះក្នុងទឹកៈ**<br>- ការប៉ះពាល់ដល់ប្រភេទមច្ឆជាតិប្រមាណ ៣៧ប្រភេទ និងផ្កាថ្ម ដោយសារការសាងសង់កំពង់ផែទេសចរណ៍<br>- ការចោលសំណល់រឹង ការបង្ហូរសំណល់រាវចូលទៅក្នុងប្រភពទឹកសមុទ្រ | | ✓ | | - ការឈូសឆាយដីសំរាប់សាងសង់ផែទេសចរណ៍មានទំហំតូច ហើយអ្នកមៅការរកទីតាំងណាដែលពុំមានផ្កាថ្ម ដោយជៀសវាងមិនឲ្យមានការប៉ះពាល់ដល់ផ្កាថ្មឡើយ។<br>- ចូលរួមថែទាំនូវគុណភាពទឹកសមុទ្រ និងការពារការហូរច្រោះដី<br>-គ្រប់គ្រងសំណល់រឹង-រាវឲ្យបានត្រឹមត្រូវ<br>-ក្រុមហ៊ុនរក្សាព្រៃឈើធម្មជាតិនៅតាមទីជម្រាលដើម្បីជួយថែរក្សាគុណភាពទឹក និងប្រព័ន្ធអេកូឡូ |

| | | | | |
|---|---|---|---|---|
| | | | | ស៊ីក្នុងតំបន់គម្រោង។ |
| **៣-ធនធានសេដ្ឋកិច្ច-សង្គម** | | | | |
| (ក)-មុខរបរ និងប្រាក់ចំណូល<br>ការប៉ះពាល់ដល់មុខរបរ និងប្រាក់ចំណូលរបស់ប្រជានេសាទ ដោយសារការហាមឃាត់នេសាទនៅនៅជិតកោះក្របី។ | ✓ | | | - អនុញ្ញាត្យប្រជាជននេសាទនៅចម្ងាយ ២៥០ ម៉ែត្រពីមាត់ទឹកកោះក្របី ដោយដាក់ពោងបណ្តែតជាសញ្ញានៅជុំវិញកោះ។<br>- ផ្តល់អាទិភាពដល់ប្រជាជនដែលធ្វើការ នេសាទនៅជុំវិញកោះក្របីនោះ ចូលបម្រើការងារជាបុគ្គលិក/កម្មករនៅក្នុងដំណាក់កាលសាងសង់នេះ។ |
| (ខ)-សុខភាព និងសុខាមាលភាពសាធារណៈ៖<br>- ការប្រើប្រាស់ទឹកមិនស្អាត<br>- ការទុកដាក់សំណល់មិនបានត្រឹមត្រូវ<br>- ការមានគ្រោះថ្នាក់ ឬរបួសបណ្តាលមកពីសកម្មភាពសាងសង់។ | ✓ | | | - ផ្តល់កន្លែងស្នាក់សមស្របដល់កម្មករ<br>- សង់បង្គន់ ផ្តល់ទឹកស្អាតប្រើប្រាស់ឱ្យបានគ្រប់គ្រាន់<br>- ធ្វើការអប់រំសុខភាពដល់កម្មករអំពីអនាម័យទូទៅ និងការបង្ការឆ្លងរោគផ្សេងៗ ជាពិសេសជំងឺកាមរោគ (មេរោគអេដស៍/ជំងឺអេដស៍)<br>- ជ្រើសរើសគ្រូពេទ្យប្រចាំការនៅការដ្ឋានសំរាប់ពិគ្រោះព្យាបាល និងសង្គ្រោះបន្ទាន់<br>- ប្រកាន់យកសុវត្ថិភាពជាចំបងនៅការដ្ឋានសាងសង់។ |
| **ដំណាក់កាលប្រតិបត្តិគម្រោង** | | | | |
| **១-ធនធានរូបសាស្ត្រ** | | | | |
| (ក)-ការបំពុលខ្យល់:<br>- សំណល់រឹង និងសំណល់រាវ<br>- ការប្រើប្រាស់សម្ភារៈដែលបំផ្លាញស្រទាប់អូហ្សូន<br>- កំណើនទូកទេសចរណ៍។ | ✓ | | | - ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ដើម្បីកាត់បន្ថយការបំពុលខ្យល់<br>-បង្កើតកន្លែងស្តុកសំរាមបណ្តោះអាសន្ននៅលើកោះក្របី និងមានផែនការគ្រប់គ្រងត្រឹមត្រូវ<br>- អាងចំពោះ សិបទិកត្រូវមានគំរបបិទជិត<br>- ដាំដើមឈើនៅតាមប្លុកផ្ទះវីឡានីមួយៗ និងរក្សាទុកតំបន់បៃតងឱ្យបានច្រើន។ |
| (ខ)-ការរំខានដោយសំលេង៖<br>- ការកើនឡើងចំនួនអ្នកទេសចរណ៍ង្កើតបានជាសំលេង<br>- ម៉ាស៊ីនសំអាត សំណល់រាវ<br>- ការបញ្ចេញសំលេងពីទូកនេសាទ និងទូកទេសចរណ៍។ | ✓ | | | - ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ កាត់បន្ថយប្រើប្រាស់ម៉ាស៊ីនភ្លើង<br>- ក្រុមហ៊ុនមានផែនការរៀបចំដាំដើមឈើបន្ថែមនៅលើកោះដើម្បីកាត់បន្ថយសំលេងពីទូកនេសាទ និងទូកទេសចរណ៍<br>- ក្រុមហ៊ុនមានផែនការរៀបចំដាក់ស្លាកសញ្ញា |

| | | | | |
|---|---|---|---|---|
| | | | | ពោងបណ្ដែតទឹក ដើម្បីកំណត់កន្លែងនេសាទ និងជិះទូកទេសចរណ៍ ឬម៉ូតូលើទឹក។ |
| (គ)-គុណភាពទឹក<br>បំពុលគុណភាពទឹកសមុទ្រនៅក្នុងទីតាំងគម្រោងមកពី ៖<br>- ការបញ្ចេញសំណល់រាវ ៩៥ម³/ថ្ងៃ នៅកោះ។<br>- ការបង្កើតសំណល់រឹង ១៩៧ គីឡូក្រាម/ថ្ងៃ ពីតំបន់ប្លុកផ្ទះលំហែកាយនិងភោជនីយដ្ឋាន។ | ✓ | | | - បង្កើតកន្លែងស្តុកសំរាមនៅក្នុងកោះក្របី ហើយយកទៅទុកដាក់នៅលើដីគោកតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច<br>- រៀបចំដាក់អាងសិបទិកប្រព័ន្ធលូឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមបទដ្ឋាននៃការបញ្ចេញសំណល់រាវទៅក្នុងប្រភពទឹកសាធារណៈរបស់ក្រសួងបរិស្ថាន។ |
| **២-ធនធានជីវសាស្រ្ត** | | | | |
| (ក)-ធនធានព្រៃឈើនិងសត្វព្រៃ៖<br>-អ្នកទេសចរណ៍កើនឡើងនាំឲ្យមានតម្រូវការលើធនធានព្រៃឈើ។<br>-សត្វព្រៃធំៗពុំឃើញវត្តមាននៅក្នុងទីតាំងគម្រោងទេ គឺមានតែប្រភេទសត្វព្រៃតូចៗចំនួន ៧ប្រភេទ | | ✓ | | - ដាំដើមឈើ និងរុក្ខជាតិឡើងវិញ<br>- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីប្រលែងសត្វបន្ថែមនៅលើកោះ<br>- អប់រំដល់កម្មករ និងអ្នកទេសចរណ៍ឲ្យប្រយ័ត្នពីភ្លើងឆេះព្រៃ។ |
| (ខ)-ជីវចំរុះក្នុងទឹក៖<br>-ប៉ះពាល់ដោយសារការបំពុលទឹក<br>- ការចាប់ត្រី ឬស្ទូចត្រីកំសាន្តការចុះទឹកទស្សនាផ្កាថ្មធ្វើឲ្យខូចខាតដល់ផ្កាថ្ម។ | | ✓ | | - រក្សាទុកព្រៃនៅតាមមាត់សមុទ្រ ព្រមទាំងដាំដើមឈើឡើងវិញនៅតំបន់ណាដែលគ្មានគម្របព្រៃឈើ<br>- ចូលរួមថែទាំនូវគុណភាពទឹកសមុទ្រ និងផ្កាថ្ម<br>-ការពារការហូរច្រោះដី<br>- គ្រប់គ្រងសំណល់រឹង-រាវឲ្យបានត្រឹមត្រូវ<br>- ហាមការនេសាទខុសច្បាប់។ |
| **៣-ធនធានសេដ្ឋកិច្ច-សង្គម** | | | | |
| (ក)-មុខរបរ និងប្រាក់ចំណូល៖<br>ការហាមឃាត់នេសាទនៅតំបន់ក្បែរកោះ | ✓ | | | - អនុញ្ញាតឲ្យប្រជាជននេសាទនៅចម្ងាយ ២៥០ ម៉ែត្រពីមាត់ទឹក<br>-ផ្ដល់អាទិភាពដល់ប្រជាជនដែលធ្វើការនេសាទនៅជុំវិញកោះ ចូលបម្រើការងារជាបុគ្គលិក/កម្មករនៅក្នុងដំណាក់កាលដំណើរការគម្រោង |

| | | | | |
|---|---|---|---|---|
| | | | | - រៀបចំមូលនិធិបរិស្ថាន-សង្គម សម្រាប់បណ្តុះបណ្តាលប្រជាជនឲ្យមានជំនាញអាចធ្វើការនៅក្នុងតំបន់អភិវឌ្ឍន៍បានជាដើម។ |
| (ខ)-សុខភាព និងសុខមាលភាពសាធារណៈ នឹងមានការប៉ះពាល់ដល់សុខភាពបុគ្គលិក និងអ្នកទេសចរ ដោយសារ ៖<br>- ការលង់ទឹក ឬលិចទូកនៅពេលចុះងូតទឹក ឬជិះទូកកំសាន្ត<br>- សត្វល្អិតទិច ឬខាំ<br>- គ្រុនចាញ់ដោយសារមូសខាំ | ✓ | | | - រមណីដ្ឋានទេសចរណ៍ដ៏ប្រណិត សម្រាប់ទាក់ទាញអ្នកទេសចរមកស្នាក់នៅលំហែកាយងូតទឹកសមុទ្រ និងការចុះទស្សនាផ្កាថ្មបាតសមុទ្រ។<br>-ដាក់ស្លាកសញ្ញាពោងបណ្តែតទឹកនៅតំបន់មានទឹកជ្រៅ ឬតំបន់ដែលអាចងូតទឹកបាន ឬតំបន់អាចជិះទូក ឬម៉ូតូលើទឹកបាន។<br>- ត្រូវបំពាក់សម្ភារៈការពារខ្លួនដូចជាអាវពោងវ៉ែនតា និងសម្ភារៈផ្សេងៗទៀតនៅពេលចុះលេងទឹក។<br>- ត្រៀមឧបករណ៍ មធ្យោបាយ សម្ភារៈសង្គ្រោះបន្ទាន់ និងគ្រូពេទ្យប្រចាំការ។ |
| (គ)- ការប្រើប្រាស់ទឹកស្អាត និងអគ្គិសនី៖<br>ភ្ញៀវទេសចរណ៍កើនឡើងធ្វើឱ្យមានការប្រើប្រាស់ទឹកស្អាត និងអគ្គិសនីកើនឡើង។ | ✓ | | | - ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ<br>- រៀបចំអាងស្តុកទឹកភ្លៀង<br>- រៀបចំប្រព័ន្ធប្រើប្រាស់ទឹក និងអគ្គិសនីដោយមានលក្ខណៈសន្សំសំចៃ<br>- ជូនដំណឹងដល់អ្នកទេសចរឱ្យយល់ដឹង ពីការប្រើប្រាស់ទឹក និងភ្លើង ដោយសន្សំសំចៃ។<br>- ក្រុមហ៊ុនរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹក និងអគ្គិសនីសំរាប់បំរើការនៅក្នុងកោះក្របី នេះឲ្យគ្រប់គ្រាន់។ |
| (ឃ)-គ្រោះថ្នាក់ដោយគ្រោះធម្មជាតិ៖<br>គ្រោះធម្មជាតិជាយថាហេតុដូចជារញ្ជួយដី រន្ទះបាញ់ ខ្យល់ព្យុះ គ្រោះទឹកជំនន់ និងគ្រោះអគ្គិភ័យ | ✓ | | | - បំពាក់ឧបករណ៍ការពាររន្ទះ Lightning System នៅក្នុងប្លុកផ្ទះវីឡានីមួយៗនេះ ដើម្បីការពាររន្ទះបាញ់។<br>- បំពាក់ប្រព័ន្ធគ្រប់គ្រងអគ្គិភ័យយ៉ាងគ្រប់គ្រាន់ និងមានប្រសិទ្ធិភាពខ្ពស់។<br>- បណ្តាញអគ្គិសនីនៅក្នុងអគារត្រូវបានរៀបចំឡើងដោយវិស្វករមកពីបរទេស និងជំនាញក្នុងស្រុកដើម្បីធានាអោយបាននូវសុវត្ថិភាព។ |

| ដំណាក់កាលបញ្ចប់គម្រោង | | | | |
|---|---|---|---|---|
| ក. ការបំពុលខ្យល់៖ អាចមានការបំពុលខ្យល់ចេញមកពី ផ្សែងម៉ាស៊ីនទូក និងកប៉ាល់ ដែលដឹកជញ្ជូនសម្ភារៈចេញពីកោះ | ✓ | | | -ក្រុមហ៊ុនបានរក្សាទុកព្រៃធម្មជាតិដែលមានស្រាប់នៅលើកោះបាន៨០% ដើម្បីរក្សាលំនឹងធម្មជាតិ និងកាត់បន្ថយការបំពុល។<br>-ក្រុមហ៊ុននឹងបំពាក់ឧបករណ៍ផលិតកម្មស្អាតនៅតាមបំពង់បញ្ចេញផ្សែងរបស់ទូក កប៉ាល់ និងគ្រឿងម៉ាស៊ីនផ្សេងៗ។<br>-រាល់សម្ភារៈ និងឧបករណ៍ផ្សេងៗក្នុងតំបន់គម្រោងក្រុមហ៊ុនមិនយកចេញទេ។ |
| ខ. ការរំខានដោយសំលេង និងរំញ័រ៖ ការរំខានដោយសារសំលេងនៅក្នុងដំណាក់កាលនេះ បណ្តាលមកពីដំណើរការម៉ាស៊ីនទូក កប៉ាល់ និងម៉ាស៊ីនផ្សេងៗទៀត។ | ✓ | | | -ក្រុមហ៊ុនមានផែនការរៀបចំដាំដើមឈើនៅតាមផ្លូវសំខាន់ៗមួយចំនួន និងនៅតាមសួនសាធារណៈ ដើម្បីជួសជុលនូវព្រៃឈើដែលបាត់បង់ និងជួយកាត់បន្ថយការរំខានដោយសំលេងពីទូកនេសាទ ទូកទេសចរណ៍ និងមាស៊ីននានាទៀត។<br>-ក្រុមហ៊ុនបានរៀបចំដាក់ផ្លាកសញ្ញាចរាចរណ៍នៅជុំវិញកោះ ដើម្បីកំណត់កន្លែងសម្រាប់ទូកនេសាទ និងទូកទេសចរណ៍។<br>-រាល់សម្ភារៈ និងឧបករណ៍ផ្សេងៗក្នុងតំបន់គម្រោងក្រុមហ៊ុនមិនយកចេញទេ។ |
| គ. គុណភាពទឹក៖ អាចមានសម្ភារៈសេសសល់មួយចំនួន និងសំណល់ភក់ចេញពីអាងសិបទិក។ | | ✓ | | -សហការជាមួយមន្ទីរសាធារណៈការខេត្តព្រះសីហនុ ដើម្បីសំអាតភក់នៅក្នុងអាងសិបទិក។<br>-ការដេកជញ្ជូនចេញត្រូវបានធ្វើឡើងដោយមានការបំរ៉ុងប្រយ័ត្នចំពោះការកំពប់ រឺលេចជ្រាប។ |
| ឃ. ជីវៈចម្រុះក្នុងទឹកសមុទ្រ<br>មានការប៉ះពាល់ដល់ពពួកសត្វ និងជីវៈចំរុះដែលរស់នៅក្នុងទឹកសមុទ្រជាពិសេសពពួកផ្កាថ្ម ដោយសារការបង្ហូរសំណល់ភក់ចេញពីអាងសិបទិក ចូលទៅក្នុងទឹកសមុទ្រ។ | | ✓ | | -ក្រុមហ៊ុនត្រូវរក្សាទុកព្រៃនៅតាមតំបន់ឆ្នេរជុំវិញកោះ ទៅតាមការកំណត់របស់ក្រសួង/ស្ថាប័នពាក់ព័ន្ធ ព្រមទាំងធ្វើការដាំដើមឈើនៅតាមឆ្នេរណាដែលគ្មានគំរបព្រៃ ឬមានព្រៃរេចរឹល។<br>-សំណល់ភក់ដែលនៅសេសសល់ក្រុមហ៊ុន នឹងសហការជាមួយមន្ទីរសាធារណៈការ និងដឹកជញ្ជូនដើម្បីដឹកជញ្ជូនចេញទៅចោលនៅទីតាំងដែលមន្ទីរសាធារណៈការ បរិស្ថាន និងអាជ្ញធរខេត្តអនុញ្ញាត។<br>-ការដឹកជញ្ជូនសំណល់ភក់ចេញគឺ ត្រឹមត្រូវតាម |

| | | | | |
|---|---|---|---|---|
| | | | | បច្ចេកទេសកុំឲ្យមានការកំពប់ ឬលេចជ្រាប។ |
| ឃ. មុខរបរ និងប្រាក់ចំណូល<br>អាចមានការប៉ះពាល់ដល់មុខរបរ និងប្រាក់ចំណូលរបស់ប្រជាជនមួយចំនួនបានទៅធ្វើការនៅរមណីយដ្ឋានកោះក្របីនោះ ហើយនៅពេលបញ្ចប់គាត់នឹងជួបបញ្ហាគ្មានការងារធ្វើ។ | | ✓ | | -ម្ចាស់គម្រោងនឹងផ្តល់វគ្គអប់រំបណ្តុះបណ្តាលបុគ្គលិក ទាំងអស់ឲ្យមានជំនាញកាន់តែច្បាស់លាស់ និងពិតប្រកដ ដែលពួកគាត់អាចរកការងារបានធ្វើនៅពេលបញ្ចប់គម្រោង។<br>-ផ្តល់ពត៌មានជូនបុគ្គលិកនៅពេលវេលាបញ្ចប់គម្រោងឲ្យបានច្បាស់លាស់ ដែលពួកគាត់អាចរកការងារនៅកន្លែងទៀតបានធ្វើនៅពេលបញ្ចប់គម្រោង។<br>-នៅពេលបញ្ចប់ក្រុមហ៊ុននឹងសហការជាមួយរដ្ឋាភិបាល ដើម្បីអនុញ្ញាតឲ្យបុគ្គលិកទាំងអស់អាចបន្តការងារធ្វើដូចធម្មតា។ |

## ៧.៥ ពិពណ៌នាហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គមវិជ្ជមាន

ដោយផ្អែកទៅលើទំហំនៃសកម្មភាពរបស់គម្រោងជាទូទៅ នៅក្នុងដំណាក់កាលនៃប្រតិបត្តិគម្រោងនេះមានហេតុប៉ះពាល់បរិស្ថាន និងសង្គមវិជ្ជមានដោយសារតែគម្រោងអភិវឌ្ឍន៍កោះក្របីនេះ បានចូលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចរបស់ខេត្តព្រះសីហនុ ដូចជាប្រាក់ចំណូល និងហេដ្ឋារចនាសម្ព័ន្ធថ្មី ដូចជាប្រព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធគ្រប់គ្រងសំណល់រឹង-រាវ និងសេវាកម្មនានា។ល។ បន្ថែមពីនេះទៀត រមណីយដ្ឋានកោះក្របីអាចទាក់ទាញភ្ញៀវទេសចរឱ្យចូលមកកំសាន្តកាន់តែច្រើនថែមទៀត។

### ៧.៥.១ ហេដ្ឋារចនាសម្ព័ន្ធ

- គម្រោងវិនិយោគមានការសាងសង់ផ្លូវជុំវិញកោះក្របី ០១ខ្សែដែលមានទទឹង៣ម៉ែត្រ ប្រវែង៨៥០ម៉ែត្រ និងផ្លូវលំតូចៗដែលមានទទឹង១.៥ម៉ែត្រ បណ្តោយ១,៦៧០ម៉ែត្រនិងហេដ្ឋារចនាសម្ព័ន្ធជាច្រើននៅក្នុងតំបន់គម្រោង ដែលមានចែងក្នុងផែនការមេរបស់ក្រុមហ៊ុន។ ប្រការនេះបានជំរុញអោយមានការឈានទៅមុខមួយជំហ៊ានទៀតនូវការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់។
- រមណីយដ្ឋានកោះក្របី នេះមានការអភិវឌ្ឍន៍នូវតំបន់សេវាកម្មរដ្ឋបាលសាធារណៈ ដូចជាប៉ុស្តិ៍នគរបាលជាដើម។ ដូច្នេះនៅក្នុងដំណាក់កាលនេះ អ្នកទេសចរមានភាពកក់ក្តៅពីសន្តិសុខ និងសុវត្ថិភាព។

#322P, St.271Z, Sk.Terk Tla, Khan Resey Kao, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- គម្រោងនេះបានផ្តល់នូវប្រព័ន្ធផ្គត់ផ្គង់ថាមពលអគ្គិសនី ប្រើថាមពលពន្លឺព្រះអាទិត្យ ប្រព័ន្ធគ្រប់គ្រងសំណល់រឹង-រាវ និងមជ្ឈមណ្ឌលទូរគមនាគមន៍។ល។

### ៧.៨.២ មុខរបរ និងប្រាក់ចំណូល

- ការងារជាច្រើន និងត្រូវបានបង្កើតឡើងដោយសារតំរូវការរបស់គម្រោងវិនិយោគ ដែលកត្តានេះបានធ្វើអោយប្រជាជនក្នុងសហគមន៍មានការងារធ្វើ ដែលនឹងអាចទទួលបានចំណូលជាទៀងទាត់ សំរាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ បន្ថែមពីនេះទៀត ការទទួលបានជំនាញពីការងារ ដែលទទួលបានពីការបំពាក់បំប៉នពីសំណាក់ក្រុមហ៊ុន។
- នៅក្នុងដំណាក់កាលសាងសង់អាចមានប្រជាជនមួយចំនួន ត្រូវបានជ្រើសរើសឱ្យធ្វើជាកម្មករសំណង់ទៅតាមកំរិតមុខជំនាញរបស់ពួកគេ ឬក៏អាចជ្រើសរើសជាកម្មករបំរើការផ្នែកសន្តិសុខជាដើម។ បន្ថែមពីនេះទៀត ប្រជាជនដែលរស់នៅក្បែរនោះអាចបង្កើនប្រាក់ចំណូលរបស់គាត់ដោយការលក់ផលិតផលនេសាទ របស់របរប្រើប្រាស់ប្រចាំថ្ងៃ ឬម្ហូបអាហារដល់បុគ្គលិក-កម្មករដែលបំរើការនៅក្នុងការដ្ឋានសាងសង់នោះ។ ជារួមនៅក្នុងដំណាក់កាលនេះ គឺអាចជួយបង្កើនកំរិតសេដ្ឋកិច្ចរបស់ប្រជាជនមួយចំនួនដែលរស់នៅក្បែរតំបន់គម្រោងឱ្យបានល្អប្រសើរផងដែរ។
- នៅក្នុងដំណាក់កាលប្រតិបត្តិគម្រោង ប្រជាជនមួយចំនួនអាចត្រូវបានជ្រើសរើសឱ្យធ្វើការនៅលើកោះក្របីទៅតាមប្រភេទមុខជំនាញរបស់ពួកគេ ដូចជាធ្វើការងារនៅតាមភោជនីយដ្ឋាន ផ្ទះលំហែកាយ ឬសេវាកម្មនានានៅក្នុងតំបន់។

### ៧.៨.៣ ការកាត់បន្ថយចំណាកស្រុកទៅក្រៅប្រទេស

- គម្រោងនេះនឹងបង្កើតការងារប្រមាណ ១០០នាក់ដល់ប្រជាពលរដ្ឋនៅក្នុងខេត្តព្រះសីហនុក៏ដូចជាតាមបណ្តាខេត្តនានា ដោយបានជួយកាត់បន្ថយចំណាកស្រុកទៅធ្វើជាកម្មករនៅក្រៅប្រទេស ដែលនេះបានផ្តល់ជាប្រយោជន៍សំរាប់រាជរដ្ឋាភិបាលក្នុងការធ្វើផែនការគ្រប់គ្រង និងអភិវឌ្ឍន៍។

### ៧.៨.៤ ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ

- ក្រុមហ៊ុននឹងជំរុញអោយមានការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តាមរយៈការបង់ពន្ធអាករ លើការនាំចូលប្រេង ឥន្ធនៈសំរាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀត ក្នុងរយៈពេលសាងសង់ និងប្រតិបត្តិការ ទៅតាមកិច្ចសន្យារវាងក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាលកម្ពុជា។
- សកម្មភាពរបស់ក្រុមហ៊ុនបានបង្កើតនូវទំនាក់ទំនងសេវាកម្មនានា ដល់ក្រុមហ៊ុនផ្សេងៗ ដោយក្រុមហ៊ុនមានទុនវិនិយោគរាប់លានដុល្លាអាមេរិកសំរាប់អភិវឌ្ឍន៍កោះក្របីនេះ។

### ៧.៩.៩ តំបន់ទេសចរណ៍ធម្មជាតិដ៏ប្រណិត

- ដោយសារវត្តមាននៃគម្រោងនៅតំបន់នោះ បានជួយជំរុញបន្ថែមទៀតលើវិស័យទេសចរណ៍នៅក្នុងខេត្តព្រះសីហនុ ដើម្បីផ្សារភ្ជាប់ពីតំបន់ទេសចរណ៍មួយចំនួននៅតាមបណ្តារាជធានី-ខេត្តដូចជា រាជធានីភ្នំពេញ និងខេត្តសៀមរាប ជាដើម។
- បង្កើតកន្លែងកំសាន្តបានច្រើន ដែលទាក់ទាញភ្ញៀវទេសចរមកលេងបានយូរថ្ងៃនិងចំណាយលុយកាន់តែច្រើន។
- បង្កើតតំបន់ទេសចរណ៍បន្ថែមទៀតសំរាប់ទាក់ទាញអ្នកទេសចរក្នុងស្រុក ក៏ដូចជាអ្នកទេសចរក្រៅស្រុកដើម្បីមកលេងកំសាននៅទឹកដីខេត្តព្រះសីហនុនេះ។
- ផ្តល់ប្រភពថវិកាជាច្រើនមកដល់ខេត្ត និងរាជរដ្ឋាភិបាល ដើម្បីចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិបានមួយកំរិត។

# ជំពូកទី៨៖
# ផែនការគ្រប់គ្រងបរិស្ថាន

# ជំពូកទី៨៖ ផែនការគ្រប់គ្រងបរិស្ថាន

## ៨.១ សេចក្តីផ្តើម

ផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប) គឺជាផែនការមួយដែលត្រូវរៀបចំឡើងដោយម្ចាស់គម្រោងស្ថិតក្រោមកិច្ចសហការចុះត្រួតពិនិត្យពីស្ថាប័នជំនាញចម្រុះដែលពាក់ព័ន្ធ ដើម្បីធ្វើការត្រួតពិនិត្យនៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគម្រោងក្នុងគោលដៅកាត់បន្ថយហេតុប៉ះពាល់ដែលអាចនឹងកើតមាន។ ផែនការគ្រប់គ្រងបរិស្ថានធ្វើឡើង ដើម្បីធ្វើការតាមដានទៅលើការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលបានលើកឡើងនៅក្នុងជំពូកទី០៦ ដើម្បីឲ្យប្រាកដថារាល់វិធានការទាំងអស់ដែលបានលើកឡើងត្រូវបានអនុវត្ត ដោយម្ចាស់គម្រោងនៅរាល់ដំណាក់កាល ដែលគេរកឃើញថាមានហេតុប៉ះពាល់។ ផែនការគ្រប់គ្រងបរិស្ថានត្រូវ កំណត់ឲ្យបានច្បាស់លាស់ទៅលើហេតុប៉ះពាល់ ទីតាំងដែលត្រូវត្រួតពិនិត្យ រយៈកាលតាមដាន និងសមាសភាពអ្នកចូលរួមត្រួតពិនិត្យ។

ផែនការនេះត្រូវគូសបញ្ជាក់អំពីកិច្ចការពារបរិស្ថាន និងវិធានការនានាដែលត្រូវអនុវត្តនៅពេលកំពុងធ្វើការសាងសង់ ពេលប្រតិបត្តិគម្រោង និងបញ្ចប់គម្រោង ដោយគោរពទៅតាមច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងគោលបំណងកាត់បន្ថយ ឬក៏លុបបំបាត់ចោលនូវហេតុប៉ះពាល់អាក្រក់ដែលអាចកើតមាន (Adverse impacts)។ បន្ថែមពីនេះទៀត ត្រូវមានការបង្កើនចំណេះដឹងអំពីកិច្ចការពារបរិស្ថាន-សង្គម តាមរយៈការបណ្តុះបណ្តាលដល់បុគ្គលិកដែលពាក់ព័ន្ធ (ឧទាហរណ៍បុគ្គលិកបំរើការរបស់អ្នកទទួលមៅការអភិវឌ្ឍន៍គម្រោង។ល។)

## ៨.២ ការទទួលខុសត្រូវក្នុងការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន

ការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប) នេះជាកាតព្វកិច្ចរបស់ក្រុម ផ្នែកឬការិយាល័យបរិស្ថានដែលបានបង្កើតឡើងដោយក្រុមហ៊ុន និងស្ថិតនៅក្រោមការត្រួតពិនិត្យពីម្ចាស់ក្រុមហ៊ុនដោយមានការចូលរួមសហការជាមួយក្រសួងបរិស្ថាន និងក្រសួង-ស្ថាប័នពាក់ព័ន្ធដូចខាងក្រោម៖

### ៨.២.១ ការទទួលខុសត្រូវរបស់គណៈកម្មការអន្តរក្រសួង

សមាសភាពគណៈកម្មការអន្តរក្រសួងមានដូចខាងក្រោម៖

តារាង៨.១៖ ការទទួលខុសត្រូវរបស់គណៈកម្មការអន្តរក្រសួង

| ស្ថាប័នថ្នាក់ជាតិ | ស្ថាប័នថ្នាក់ក្រោមជាតិ |
|---|---|
| ១. ក្រសួងបរិស្ថាន | ១. សាលាខេត្តព្រះសីហនុ |
| ២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២. មន្ទីរបរិស្ថានខេត្តព្រះសីហនុ |
| ៣.ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ | ៣. មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តព្រះសីហនុ |
| ៤. ក្រសួង ទេសចរណ៍ | ៤. មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ |
| ៥. ក្រសួងធនធានទឹក និងឧតុនិយម | ៥. មន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រះសីហនុ |
| ៦. ក្រសួង សាធារណការ និងដឹកជញ្ជូន | ៦. មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ |
| ៧.ក្រសួងសុខាភិបាល | ៧. មន្ទីរសុខាភិបាលខេត្តព្រះសីហនុ |
| | ៨. ខណ្ឌរដ្ឋបាលព្រៃឈើ |
| | ៩. ខណ្ឌរដ្ឋបាលជលផល |

សមាជិកនៃគណៈកម្មការខាងលើនេះ គឺស្ថិតនៅក្រោមការចង្អុលបង្ហាញ និងណែនាំពីក្រសួងបរិស្ថាន។ គណៈកម្មការនេះនឹងចុះពិនិត្យទីតាំងជាក់ស្តែងជាបន្ទាន់ ករណីមានការប្រែប្រួលបរិស្ថានខ្លាំងក្នុងតំបន់គម្រោង ដើម្បីជួយរកវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និងទប់ស្កាត់ហានិភ័យដែលនឹងកើតមានឡើង។

ជាទូទៅ ក្រសួងបរិស្ថានដែលមាននាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថានតែងតែចុះអង្កេតតាមដានពីសកម្មភាពគម្រោងរៀងរាល់ ៣ខែ ឬ៦ខែ ឬ០១ឆ្នាំម្តង។ ករណី សកម្មភាពគម្រោងមានការប៉ះពាល់អវិជ្ជមានខ្លាំងដល់បរិស្ថាន និងសេដ្ឋកិច្ចសង្គម គឺក្រសួងបរិស្ថានអាចចុះពិនិត្យគ្រប់ពេល ដើម្បីចាត់វិធានការជាបន្ទាន់។

ដោយឡែក រដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចទទួលខុសត្រូវសម្របសម្រួល និងដោះស្រាយរាល់បញ្ហាដែលនឹងកើតមានឡើងនៅក្នុងតំបន់គម្រោង។

### ៨.២.២ ការទទួលខុសត្រូវរបស់ម្ចាស់គម្រោង

ដើម្បីកំណត់ និងធ្វើការកាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថាន ដែលអាចកើតមានដោយសារសកម្មភាពគម្រោងអភិវឌ្ឍន៍តំបន់ **រមណីយដ្ឋានកោះក្រមី** នេះ ម្ចាស់ក្រុមហ៊ុន ក្រុមហ៊ុន

សាងសង់ និងអ្នកប្រតិបត្តិ (វិស្វករប្លង់ និងវិស្វករសំណង់) ត្រូវទទួលខុសត្រូវទាំងស្រុងលើគ្រប់សកម្មភាពសាងសង់និងប្រតិបត្តិគម្រោង ដែលនឹងបង្កគ្រោះថ្នាក់ដល់ធនធានបរិស្ថាន និងសង្គម។ ការត្រួតពិនិត្យនិងតាមដាននេះត្រូវបានប្រចាំសប្តាហ៍ ឬប្រចាំខែក្នុងតំបន់គម្រោងនៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគម្រោង។

នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន តួនាទីរបស់វិស្វករ គឺត្រូវពិនិត្យសកម្មភាពរបស់អ្នកម៉ៅការ និងធ្វើសកម្មភាពក្នុងល័ក្ខខ័ណ្ឌកិច្ចសន្យា ដើម្បីការពារ និងកាត់បន្ថយនូវការខូចខាតបរិស្ថាន ដោយមានការរៀបចំការគ្រប់គ្រងជាបីដូចខាងក្រោម៖

### ក. ការរៀបចំរបស់អ្នកម៉ៅការ

រាល់ឯកសារដែលបានស្នើឡើង តម្រូវអោយអ្នកម៉ៅការបង្ហាញពីគោលការណ៍ណែនាំផ្នែកបរិស្ថានអោយបានច្បាស់លាស់។ ការរៀបរាប់លំអិតអំពីការងារទទួលខុសត្រូវសម្រាប់កិច្ចការពារបរិស្ថាននៅក្នុងអង្គភាពអ្នកម៉ៅការ គឺជាកត្តាសំខាន់សម្រាប់កិច្ចការត្រួតពិនិត្យបរិស្ថានអោយបានល្អ។ ដូច្នេះ វាជាកត្តាចំបាច់ណាស់តម្រូវអោយអ្នកម៉ៅការផ្តល់អោយនូវគម្រោងការគ្រប់គ្រងបរិស្ថាន។

### ខ. ការរៀបចំរបស់វិស្វករប្រចាំកន្លែង

ការរៀបចំខាងក្រោមនេះអាចជាការចំបាច់ នៅពេលដែលរចនាសម្ព័ន្ធបុគ្គលិករបស់គម្រោងត្រូវបានបញ្ចប់។ ការទទួលខុសត្រូវចុងក្រោយនៃបញ្ហាបរិស្ថានជាមួយនឹងក្រុមវិស្វកម្មនឹងធ្លាក់ទៅលើអ្នកគ្រប់គ្រងគម្រោង និងប្រធានវិស្វករនៅទីនោះ ដែលទទួលខុសត្រូវសម្រាប់ការដឹកនាំ និងការគ្រប់គ្រងប្រចាំថ្ងៃ។ វាគឺជាការចាំបាច់ណាស់សម្រាប់ការអនុញ្ញាត្តអោយអ្នកត្រួតពិនិត្យបរិស្ថានមានវត្តមានជាអចិន្ត្រៃយ៍នៅនឹងទីតាំង ហើយពួកគេជាជំនួយការសម្រាប់ការត្រួតពិនិត្យគម្រោងប្រចាំថ្ងៃ។ បុគ្គលិកត្រួតពិនិត្យត្រូវមានបទពិសោធន៍គ្រប់គ្រាន់អំពីការគ្រប់គ្រងបរិស្ថាន។

### គ. ការធ្វើរបាយការណ៍

អ្នកត្រួតពិនិត្យបរិស្ថាននឹងចូលរួមជារៀងរាល់សប្តាហ៍ នៅកន្លែងសាងសង់ជាមួយនឹងបុគ្គលិកអ្នកម៉ៅការ ហើយនឹងផ្តល់ព័ត៌មានអ្វីដែលកើតឡើងនៅរយៈពេលខ្លីខាងមុខនៅទីនោះ។ អ្នកត្រួតពិនិត្យបរិស្ថាននឹងរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស និងឆមាសសម្រាប់ដាក់ជូនទៅភ្នាក់ងារពាក់ព័ន្ធដូចជា ក្រសួងបរិស្ថានជាដើម។

### តារាង ៨.២ ៖ ផែនការគ្រប់គ្រងបរិស្ថាន និងការទទួលខុសត្រូវ

| សកម្មភាព | ការអនុវត្តន៍ និង ការទទួលខុសត្រូវ |
|---|---|
| ការប្រមូលទិន្នន័យ | ម្ចាស់គម្រោង និង ទីប្រឹក្សាគម្រោង |
| ការវិភាគទិន្នន័យ | ម្ចាស់គម្រោង និង ទីប្រឹក្សាគម្រោង |
| ការធ្វើរបាយការណ៍:<br>-ប្រចាំខែ<br>-ប្រចាំត្រីមាស និង<br>-ប្រចាំឆ្នាំ | ការិយាល័យគ្រប់គ្រងគម្រោង និង ទីប្រឹក្សាគម្រោង |
| ការទទួលរបាយការណ៍:<br>-ប្រចាំឆមាស | - ម្ចាស់គម្រោង<br>- ក្រសួងបរិស្ថាន និង មន្ទីរបរិស្ថានខេត្តព្រះសីហនុ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងសាធារណៈការ និងដឹកជញ្ជូន<br>- ក្រសួងធនធានទឹក និងឧតុនិយម<br>- សាលាខេត្តព្រះសីហនុ។ |
| ការផ្តល់យោបល់/ប្រឹក្សា | ក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្តព្រះសីហនុ និងស្ថាប័នពាក់ព័ន្ធនានា។ |

## ៨.៣ ការសង្ខេបពីហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

នៅក្នុងផែនការគ្រប់គ្រងបរិស្ថាននេះ ក្រុមហ៊ុននឹងលើកយកនូវចំណុចហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និងវិធានការកាត់បន្ថយជាលក្ខណៈសង្ខេបបំផុត។ ទោះបីជាយ៉ាងណា ក្រុមហ៊ុនត្រូវតែអនុវត្តឲ្យបានរាល់ការលើកឡើងពីហេតុប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច-សង្គមអវិជ្ជមាន និងវិធានការកាត់បន្ថយដែលមានរៀបរាប់នៅក្នុងជំពូកទី០៦ ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ ដោយធ្វើយ៉ាងណាអាចធានាបាននូវដំណើរការអភិវឌ្ឍន៍កោះក្របីនេះឲ្យមាននិរន្តរភាពបរិស្ថាន និងសេដ្ឋកិច្ច-សង្គម។ ការសង្ខេបពីហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយមានបញ្ជាក់ដូចខាងក្រោម:

### ៨.៣.១ ហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ

#### ក. ដំណាក់កាលសាងសង់

ការត្រួតពិនិត្យក្នុងកំឡុងពេលសាងសង់រមណីយដ្ឋានកោះក្របី ត្រូវអនុវត្តចំពោះហេតុប៉ះពាល់បរិស្ថានសំខាន់ៗទៅលើធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសេដ្ឋកិច្ច-សង្គមនៅក្នុង

តំបន់នោះដែលអាចបង្កឡើងដោយសារសកម្មភាពនានានៅក្នុងដំណាក់កាលនេះ ដូចជាហេតុប៉ះពាល់ដល់សណ្ឋានដី ការហូរច្រោះដី គុណភាពទឹក គុណភាពដី គុណភាពខ្យល់ ការរំខានដោយសំលេង និងរំញ័រ ធនធានព្រៃឈើ ធនធានជីវៈចំរុះក្នុងទឹក និងសុខភាពសាធារណៈ។

ខ. ដំណាក់កាលប្រតិបត្តិគម្រោង

ការងារសម្រាប់ការត្រួតពិនិត្យបរិស្ថាននៅក្នុងដំណាក់កាលនេះ ជាការងារសំខាន់ជាងដំណាក់កាលផ្សេងៗទៀត ដែលអាចបង្កអោយមានហេតុប៉ះពាល់បរិស្ថានដល់ធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសេដ្ឋកិច្ច-សង្គមសំខាន់ៗក្នុងតំបន់នោះ ដោយសារសកម្មភាពនានារបស់ក្រុមហ៊ុនមានដូចជា គុណភាពខ្យល់ ការរំខានដោយសំលេង និងរំញ័រ ធនធានព្រៃឈើ/សត្វព្រៃ ធនធានជីវៈចំរុះក្នុងទឹក ការប្រើប្រាស់ទឹក ការប្រើប្រាស់ថាមពល សុខភាពសាធារណៈ និងគ្រោះធម្មជាតិៗល។

គ. ដំណាក់កាលបញ្ចប់គម្រោង

ការត្រួតពិនិត្យបរិស្ថាននៅក្នុងដំណាក់កាលនេះ ជាការងារសំខាន់ដែលត្រូវត្រួតពិនិត្យលើផ្នែកសំខាន់ៗមួយចំនួនពេលក្រុមហ៊ុនបញ្ចប់គម្រោង។ ការងារដែលត្រូវត្រួតពិនិត្យ ដូចជា គុណភាពខ្យល់ ការរំខានដោយសំឡេង និងរំញ័រ ធនធានជីវៈចំរុះក្នុងទឹក បញ្ហាសំណល់រឹង-រាវ និងមុខរបរ។

## ៨.៣.២ វិធានការការពារបរិស្ថាន

យោងតាមអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងយោងតាមលទ្ធផលនៃការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ដែលបង្កឡើងដោយសារសកម្មភាពនៅគ្រប់ដំណាក់កាល នៃគម្រោងដូចបានរៀបរាប់នៅក្នុងជំពូកទី០៧ ម្ចាស់គម្រោងនឹងរៀបចំកំណត់នូវវិធានការសំខាន់ៗមួយចំនួនសម្រាប់ធ្វើការទប់ស្កាត់ និងកាត់បន្ថយនូវរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដើម្បីធានាបានការគ្រប់គ្រងធនធានបរិស្ថានតំបន់នោះដោយប្រសិទ្ធិភាពស្របទៅតាមលក្ខណៈបច្ចេកទេស និងបទដ្ឋានបរិស្ថានព្រមទាំងធានាឲ្យគម្រោងអភិវឌ្ឍន៍ប្រកបដោយស្ថេរភាព ដែលក្នុងនោះម្ចាស់ក្រុមហ៊ុនត្រូវអនុវត្តនូវចំណុចសំខាន់ៗដូចខាងក្រោម៖

- ការរៀបចំក្រុមការងាររបស់ក្រុមហ៊ុនទទួលខុសត្រូវសម្រាប់ការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន
- កំណត់ពេលវេលាធ្វើការងារឲ្យច្បាស់លាស់ក្នុងកិច្ចការការពារបរិស្ថាន
- បំពាក់ឧបករណ៍ការពារសុខភាព គ្រោះថ្នាក់ និងគ្រឿងចក្រទំនើបៗតាមបែបផែនបច្ចេកទេស នៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគម្រោង ដូចជាឧបករណ៍ត្រួតពិនិត្យអគ្គីភ័យ សម្ភារៈការពារគ្រោះថ្នាក់ដោយលង់ទឹក
- ធ្វើការផ្សព្វផ្សាយ ការពារ និងបង្ការជម្ងឺរាតត្បាតផ្សេងៗដែលអាចនឹងកើតមាន និងរៀបចំឲ្យមានផ្ទះសម្រាប់កម្មករស្នាក់នៅឲ្យបានសមរម្យ ចំពោះកម្មករធ្វើការក្នុងតំបន់គម្រោង។ លើសពីនេះទៀត ក្រុមហ៊ុនត្រូវអប់រំណែនាំវិធីសាស្ត្រការពារសុខភាពអនាម័យ និងសុវត្ថិភាពនៅពេលបំពេញការងារ ណែនាំដល់កម្មករពីសារៈសំខាន់នៃបរិស្ថាន និងវិធីសាស្ត្រក្នុងការថែទាំបរិស្ថានរូបសាស្ត្រ និងបរិស្ថានរស់នៅរបស់កម្មករផ្ទាល់
- ការគ្រប់គ្រងសំណល់រឹង-រាវ ជាពិសេសសំណល់ប្រកបដោយគ្រោះថ្នាក់
- ជំរុញអោយមានការដាំដើមឈើ និងរៀបចំសួនច្បារនៅក្នុងតំបន់គម្រោងអភិវឌ្ឍន៍
- សហការជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យការងារសាងសង់-បច្ចេកទេស និងទទួលយកនូវការកែលំអបច្ចេកទេសណាមួយពីមន្ត្រីជំនាញ
- ណែនាំដល់អ្នកទេសចរណ៍មកកំសាន្តនៅលើកោះក្របីនេះឲ្យចេះប្រើប្រាស់ដោយសន្សំសំចៃនូវថាមពលអគ្គិសនី និងទឹក
- ក្រុមហ៊ុនត្រៀមថវិកាមួយផ្នែកតូច បន្ទាប់ប្រតិបត្តិគម្រោងសម្រាប់មូលនិធិបរិស្ថាន និងសង្គម

### ៨.៣.៣ ផែនការថវិកាមូលនិធិបរិស្ថាន និងសង្គម

#### ក. មូលនិធិបរិស្ថាន

ដើម្បីចូលរួមក្នុងការស្តារបរិស្ថានឡើងវិញ និងអភិរក្សធនធានធម្មជាតិ ក្រុមហ៊ុនមានផែនការចំណាយថវិកាសម្រាប់បង់មូលនិធិការពារបរិស្ថាន ៥.០០០ដុល្លាសហរដ្ឋអាមេរិក (ប្រាំពាន់ដុល្លាសហរដ្ឋអាមេរិក) ក្នុងមួយឆ្នាំសម្រាប់រយៈពេល២០ឆ្នាំ ដោយគិតចាប់ពីដំណាក់កាលប្រតិបត្តិគម្រោង។ ថវិកានេះសម្រាប់ការស្តារ និងដាំដើមឈើឡើងវិញ ការអភិរក្សជីវៈចំរុះនានានៅក្នុងតំបន់កោះក្របីនេះ។

### ខ. មូលនិធិសង្គម

នៅពេលក្រុមហ៊ុនដំណើរអាជីវកម្ម នោះក្រុមហ៊ុនមានផែនការនឹងផ្តល់វិភាគដល់មូលនិធិសង្គមចំនួន ៥.០០០ដុល្លាសហរដ្ឋអាមេរិក (ប្រាំពាន់ដុល្លាសហរដ្ឋអាមេរិក) ក្នុង០១ឆ្នាំ ក្នុងរយៈពេល ២០ឆ្នាំ ដោយគិតចាប់ពីដំណាក់កាលប្រតិបត្តិគម្រោង សម្រាប់ការអភិវឌ្ឍន៍ភូមិ-ឃុំពាក់ព័ន្ធជាមួយគម្រោងវិនិយោគដើម្បីៈ (១)-បណ្តុះបណ្តាលវិជ្ជាជីវៈជំនាញផ្សេងៗ (២)-ផ្តល់មូលនិធិសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធសង្គម ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

## តារាងទី ៨.៣៖ ផែនការថវិកាសម្រាប់អនុវត្តផែនការគ្រប់គ្រងបរិស្ថានរយៈ ពេល២០ឆ្នាំ

| ល.រ | មូលនិធិបរិស្ថាន | | មូលនិធិសង្គម | | សរុប |
|---|---|---|---|---|---|
| | ចូលរួមដាំដើមឈើ | អភិរក្សជីវៈចំរុះ | បណ្តុះបណ្តាលជំនាញផ្សេងៗ | កសាងហេដ្ឋារចនាសម្ព័ន្ធនានា | (USA) |
| ឆ្នាំទី១ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.000 |
| ឆ្នាំទី២ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.000 |
| ឆ្នាំទី៣ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.000 |
| ឆ្នាំទី៤ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.000 |
| ឆ្នាំទី៥ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.000 |
| ឆ្នាំទី៦ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.000 |
| ឆ្នាំទី៧ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.000 |
| ឆ្នាំទី៨ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.000 |
| ឆ្នាំទី៩ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.000 |
| ឆ្នាំទី១០ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.000 |

| ល.រ | មូលនិធិបរិស្ថាន | | មូលនិធិសង្គម | | សរុប (USA) |
|---|---|---|---|---|---|
| | ចូលរួមដាំដើមឈើ | អភិរក្សជីវៈចំរុះ | បណ្តុះបណ្តាលជំនាញផ្សេងៗ | កសាងហេដ្ឋារចនាសម្ព័ន្ធនានា | |
| ឆ្នាំទី១១ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.០០០ |
| ឆ្នាំទី១២ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.០០០ |
| ឆ្នាំទី១៣ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.០០០ |
| ឆ្នាំទី១៤ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.០០០ |
| ឆ្នាំទី១៥ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.០០០ |
| ឆ្នាំទី១៦ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.០០០ |
| ឆ្នាំទី១៧ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.០០០ |
| ឆ្នាំទី១៨ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.០០០ |
| ឆ្នាំទី១៩ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.០០០ |
| ឆ្នាំទី២០ | ២.៥០០ | ២.៥០០ | ២.៥០០ | ២.៥០០ | ១០.០០០ |
| សរុប | ៥០.០០០ | ៥០.០០០ | ៥០.០០០ | ៥០.០០០ | ២០០.០០០ |

## ៨.៤ កម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលក៏ជាកត្តាសំខាន់មួយ នៅក្នុងផែនការគ្រប់គ្រងបរិស្ថានផងដែរ ដែលម្ចាស់គម្រោងត្រូវយកចិត្តទុកដាក់ដើម្បីអនុវត្តផែនការមេរបស់គម្រោងឲ្យបានជោគជ័យ។

ដើម្បីធ្វើឲ្យអាជីវកម្មនេះមានការអភិវឌ្ឍន៍ប្រកបដោយស្ថេរភាព ចាំបាច់ត្រូវមានធនធានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញការងារឲ្យបានរីកចំរើន សុក្រឹត្យភាព ត្រឹមត្រូវទាំងការងារបច្ចេកទេស និងការងារបរិស្ថាន។ ការបណ្តុះបណ្តាលទាំងនេះក្រុមហ៊ុននឹងទទួលបន្ទុកលើការចំណាយទាំងស្រុង។ ដូច្នេះ ម្ចាស់គម្រោងនឹងរៀបចំឲ្យមានវគ្គអប់រំបំពាក់បំប៉នបន្ថែមដល់បុគ្គលិក-កម្មកររួមមានដូចខាងក្រោម ៖

- បណ្តុះបណ្តាលចំណេះដឹងអំពីបច្ចេកទេសសម្រាប់ប្រើ ឬបញ្ជាគ្រឿងម៉ាស៊ីនគ្រប់ប្រភេទក្នុងពេលដំណើរការសាងសង់ និងប្រតិបត្តិគម្រោង
- បណ្តុះបណ្តាលចំណេះដឹងអំពីការការពារសុវត្ថិភាពពេលកំពុងបំពេញការងារក្នុងគម្រោង និង អប់រំដល់កម្មករឲ្យបំពាក់ឧបករណ៍ការពារសុខភាពពេលកំពុងធ្វើការងារ
- បណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ
- បណ្តុះបណ្តាល និងអប់រំអំពីវិធីសាស្ត្រការពារជំងឺរាតត្បាតផ្សេងៗ ជាពិសេសជំងឺអេដស៍ជាដើម
- បណ្តុះបណ្តាល និងអប់រំអំពីវិធីសាស្ត្រជួយការពារបរិស្ថានក្នុង-ជុំវិញតំបន់គម្រោង និងចំណេះដឹង ពីការត្រួតពិនិត្យដែលទាក់ទងទៅនឹងផែនការគ្រប់គ្រងបរិស្ថាន
- បណ្តុះបណ្តាលដល់កម្មករក្នុងការគ្រប់គ្រងសំណល់រឹង-រាវទាំងក្នុងដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិគម្រោង និងបញ្ចប់គម្រោង
- បណ្តុះបណ្តាលបុគ្គិលិក និងកម្មករឲ្យចេះស្រលាញ់ព្រៃឈើ ហាមមិនឲ្យមានការកាប់បំផ្លិចបំផ្លាញព្រៃឈើ។
- បណ្តុះបណ្តាល និងអប់រំបុគ្គលិកមិនឲ្យបង្កសកម្មភាពដែលនាំឲ្យមានការប៉ះពាល់ធនធានជលផល និងផ្កាថ្មនៅជុំវិញកោះ។
- បណ្តុះបណ្តាលពីរបៀបហែលទឹក និងសង្គ្រោះអ្នកលង់ទឹក។

ការបណ្តុះបណ្តាលនេះ ក្រុមហ៊ុនអាចមានលទ្ធភាពជ្រើសរើសបុគ្គលិក-កម្មករ ដែលមានសមត្ថភាពខ្ពស់ឲ្យទៅសិក្សានៅក្រៅប្រទេស ដើម្បីដកស្រង់បទពិសោធន៍ពីអន្តរជាតិ។ ជាមួយគ្នានេះដែរ ប្រសិនបើក្រុមហ៊ុនមិនអាចបញ្ជូនបុគ្គលិក-កម្មករទៅបណ្តុះបណ្តាលនៅក្រៅប្រទេសបានទេ ក្រុមហ៊ុននឹងជួលគ្រូឲ្យមកបណ្តុះបណ្តាល នៅក្នុងក្រុមហ៊ុនទៅតាមជំនាញជាក់ស្តែង។ រាល់ការបណ្តុះបណ្តាលដែលមានរយៈពេលមធ្យម ឬវែង ក្រុមហ៊ុនត្រូវតែធ្វើកិច្ចសន្យា

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6769
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

ជាមួយបុគ្គលិក-កម្មករទាំងនេះថា បុគ្គលិក-កម្មករទាំងនេះនឹងបំរើការងារឲ្យក្រុមហ៊ុនវិញយ៉ាងតិច ០២ឆ្នាំ។

## ៨.៥ កម្មវិធីអង្កេតតាមដានបរិស្ថាន (Environmental Monitoring Program)

កម្មវិធីអង្កេតតាមដានគម្រោង គឺជាកម្មវិធីមួយសម្រាប់ធ្វើការត្រួតពិនិត្យ និងតាមដាននូវរាល់ហេតុប៉ះពាល់បរិស្ថានទាំងឡាយ ដែលអាចនឹងកើតមានឡើងដោយសារសកម្មភាពរបស់គម្រោងនៅក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិគម្រោង និងបញ្ចប់គម្រោង ដើម្បីផ្តល់ភាពងាយស្រួលឲ្យម្ចាស់គម្រោងរិះរកវិធានការកាត់បន្ថយនូវហេតុប៉ះពាល់ទាំងនោះ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ពោលគឺជួយតំរង់ទិសដៅដល់កិច្ចដំណើរការគម្រោងឲ្យមានស្ថេរភាព និងជាចំណែកមួយជួយថែរក្សា និងការពារធនធានបរិស្ថាន។ ទន្ទឹមនឹងនេះដែរ ក្រុមហ៊ុនត្រៀមថវិកាយ៉ាងតិចពី ១ម៉ឺនដុល្លាអាមេរិកក្នុង០១ឆ្នាំ ដើម្បីអនុវត្តផែនការគ្រប់គ្រងបរិស្ថានទៅតាមសកម្មភាពនីមួយៗរបស់គម្រោង ដូចជាការរៀបចំរបាយការណ៍ត្រួតពិនិត្យបរិស្ថានជាដើម។

ការត្រួតពិនិត្យបញ្ហាបរិស្ថាននឹងត្រូវអនុវត្តដោយម្ចាស់គម្រោងនៅគ្រប់ដំណាក់កាល នៃគម្រោង។ លទ្ធផលនៃការត្រួតពិនិត្យនេះ ក្រុមហ៊ុននឹងធ្វើរបាយការណ៍ត្រួតពិនិត្យបរិស្ថានផ្ញើជូនក្រសួងបរិស្ថានរៀងរាល់០៦ខែម្តង ដើម្បីចុះពិនិត្យ និងអង្កេតតាមដានសម្រាប់កែលំអក្នុងកិច្ចដំណើរការរបស់គម្រោង ស្របតាមបទពិសោធន៍ និងបច្ចេកទេស និងបញ្ចៀសបាននូវហេតុប៉ះពាល់បរិស្ថានអវិជ្ជមានធ្ងន់ធ្ងរឲ្យដល់កំរិតអប្បបរមា។ ចំណែកហេតុប៉ះពាល់វិជ្ជមាន ក្រុមហ៊ុននឹងខិតខំធ្វើឲ្យប្រសើរឡើងដល់កំរិតអតិបរមា។ ក្នុងករណីពិសេសណាមួយដែលបង្កឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមដោយសារសកម្មភាពគម្រោង ក្រុមហ៊ុននឹងសហការជាមួយមន្រ្តីជំនាញនៃក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ ដើម្បីចុះពិនិត្យ និងកែលំអ។

កម្មវិធីត្រួតពិនិត្យបរិស្ថាននេះបំណងសំខាន់គឺដើម្បីកំណត់ និងប្រៀបធៀបអោយដឹងថារវាងហេតុប៉ះពាល់បរិស្ថាន "ហ.ប.ស" និងវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន "វ.ក.ប" ដែលបានសិក្សាហើយ ធៀបទៅនឹងលទ្ធផលនៃការងារត្រួតពិនិត្យបរិស្ថានជាក់ស្តែងនៅគ្រប់ដំណាក់កាលនៃគម្រោង។

ក្នុងករណីលទ្ធផលពិនិត្យរបស់គម្រោងមានភាពមិនច្បាស់លាស់ ពេលនោះក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធចុះពិនិត្យធនធានបរិស្ថាននេះបន្ថែមទៀត ដើម្បីផ្ទៀងផ្ទាត់ជាមួយលទ្ធផលដែលក្រុមហ៊ុនបានពិនិត្យ។

ដោយឡែក កម្មវិធីត្រួតពិនិត្យបរិស្ថានសំខាន់ៗ នៅគ្រប់ដំណាក់កាលរបស់គម្រោងនេះ ម្ចាស់គម្រោងនឹងសហការជាមួយក្រសួងបរិស្ថាន ដើម្បីធ្វើការត្រួតពិនិត្យលើធនធានបរិស្ថានសំខាន់ៗមួយចំនួនដូចក្នុងតារាង៨.៣។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# តារាង ៨.៤ ៖ កម្មវិធីត្រួតពិនិត្យបរិស្ថាន

| ធនធានបរិស្ថាន | ការត្រួតពិនិត្យ | ទីតាំង | ខួបនៃការត្រួតពិនិត្យ | អ្នកទទួលខុសត្រូវ | ស្ថាប័នត្រួតពិនិត្យ | ការប៉ាន់ប្រមាណតំលៃជាដុល្លា |
|---|---|---|---|---|---|---|
| **ដំណាក់កាលសាងសង់** | | | | | | |
| ក. ធនធានរូបសាស្ត្រ | | | | | | |
| សណ្ឋានដី | ត្រួតពិនិត្យការឈូសឆាយដី ដោយ ធានាថាអ្នកមៅការត្រូវអនុវត្តបានល្អ ដូចបានបញ្ជាក់នៅវិធានការកាត់បន្ថយ។ | - ទីតាំងឈូសឆាយដី និងចាក់ដីបំពេញ<br>- ទីតាំងកាយដីយកមកចាក់<br>- ការស្រុតដី | រៀងរាល់ពេលនៃការកាយដី | - ម្ចាស់គម្រោង<br>- អ្នកមៅការ | ក្រសួងបរិស្ថាន | តាមការជាក់ស្តែង |
| ការហូរច្រោះដី និងការស្រុតដី | ត្រួតពិនិត្យការឈូសឆាយដី ដោយធានាថាអ្នកមៅការត្រូវអនុវត្តបានល្អ ដូចបានបញ្ជាក់នៅវិធាន ការកាត់បន្ថយ។ | ក្នុងបរិវេណនៃទីតាំងសាងសង់កំពង់ផែ ទីតាំងកាយដីធ្វើផ្ទះលំហែកាយ និងហេដ្ឋារចនាសម្ព័ន្ធ | រៀងរាល់ខែក្នុងអំឡុងពេលនៃការឈូសឆាយដី និងសាងសង់ | - ម្ចាស់គម្រោង<br>- អ្នកមៅការ | ក្រសួងបរិស្ថាន | តាមការជាក់ស្តែង |
| គុណភាពទឹក និងជលសាស្ត្រ | ត្រួតពិនិត្យតំលៃប៉ារ៉ាម៉ែត្រមួយចំនួនរួមមាន ៖ pH; សីតុណ្ហភាព; TSS; COD; BOD5; $PO_4$, Oil, Grease។ល។ | - ប្រភពទឹកសមុទ្រ<br>- អាងសំអាត សំណល់រាវ<br>- ទីតាំងដាក់សំរាម | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- អ្នកមៅការ | ក្រសួងបរិស្ថាន | តាមការជាក់ស្តែង |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ធនធានបរិស្ថាន | ការត្រួតពិនិត្យ | ទីតាំង | ខួបនៃការត្រួតពិនិត្យ | អ្នកទទួលខុសត្រូវ | ស្ថាប័នត្រួតពិនិត្យ | ការប៉ាន់ប្រមាណតំលៃជាដុល្លា |
|---|---|---|---|---|---|---|
| គុណភាពខ្យល់ | ត្រួតពិនិត្យតំលៃប៉ារ៉ាម៉ែត្រមួយចំនួនរួម TSP; $NO_x$; CO; $SO_2$ ពី<br>- សកម្មភាពដឹកជញ្ជូន<br>- គ្រឿងចក្រ<br>- សកម្មភាពឈូសឆាយដី<br>- ការកំណត់ពេលវេលា និងម៉ោងធ្វើការរបស់គម្រោង<br>- ម៉ាស៊ីនភ្លើងដែលប្រើប្រាស់នៅក្នុងគម្រោង។ | - អាងសំអាត សំណល់រាវ<br>- ទីតាំងដាក់សំរាម<br>- បន្ទប់ម៉ាស៊ីនភ្លើង | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- អ្នកម៉ៅការ | ក្រសួងបរិស្ថាន | តាមការជាក់ស្តែង |
| ការរំខានដោយសំលេង និង រំញ័រ | ត្រួតពិនិត្យកំរិតសំលេង និងរំញ័រពីៈ<br>- សកម្មភាពរបស់គ្រឿងចក្រ<br>- ការបុកគ្រឹះបង្ហាប់ដី និងបុកគ្រឹះផ្ទះលំហែរ និងសំណង់នានា<br>- ម៉ាស៊ីនភ្លើងដែលប្រើប្រាស់នៅក្នុងគម្រោង | - ក្នុងបរិវេណនៃទីតាំគម្រោង<br>- បន្ទប់ម៉ាស៊ីនភ្លើង | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- អ្នកម៉ៅការ | ក្រសួងបរិស្ថាន | តាមការជាក់ស្តែង |
| សំណល់ | - សំណល់នៃសម្ភារៈសាងសង់ | - អាងសំអាតសំណល់រាវ | រៀងរាល់ថ្ងៃ | - ម្ចាស់គម្រោង | ក្រសួងបរិស្ថាន | តាមការ |

| ធនធានបរិស្ថាន | ការត្រួតពិនិត្យ | ទីតាំង | ខួបនៃការត្រួតពិនិត្យ | អ្នកទទួលខុសត្រូវ | ស្ថាប័នត្រួតពិនិត្យ | ការប៉ាន់ប្រមាណតំលៃជាដុល្លា |
|---|---|---|---|---|---|---|
| | នៅក្នុងការដ្ឋាននីមួយៗ<br>- លូបង្ហូរទឹកស្អុយតាមប្លុកនីមួយៗ។ | - ទីតាំងដាក់សំរាម<br>- ទូកដឹកសំរាម | | - អ្នកម៉ៅការ | និងសាលាខេត្តព្រះសីហនុ | ជាក់ស្តែង |
| **ខ. ធនធានជីវសាស្ត្រ** | | | | | | |
| ធនធានព្រៃឈើ និងសត្វព្រៃ | - ការឈូសឆាយ និងការដាំដុះ<br>- ភ្លើងព្រៃ និងប្រព័ន្ធផ្លូវការពារភ្លើងព្រៃ។ | - ព្រៃឈើតាមទីជម្រាលនិងតាមតំបន់ឆ្នេរ<br>- កន្លែងដាក់ប្រព័ន្ធការពារភ្លើងឆេះព្រៃ<br>- ព្រៃក្នុងតំបន់រក្សាទុក | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- អ្នកម៉ៅការ | ក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ | តាមការជាក់ស្តែង |
| ជីវៈចំរុះក្នុងទឹក | - ការគ្រប់គ្រងសំណល់រឹង-រាវរបស់គម្រោង<br>- ការឈូសឆាយដី<br>- គុណភាពទឹកនៅក្នុងតំបន់គម្រោង | - ព្រៃឈើនៅតាម ទីជម្រាល<br>- កន្លែងទុកដាក់សំណល់រឹង និងកន្លែងបង្ហូរសំណល់រាវ<br>- ព្រៃរក្សាទុកក្នុងតំបន់គម្រោង<br>- សង់ប្រព័ន្ធបង្ហូរសំណល់រាវឲ្យបានត្រឹមត្រូវ។ | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- អ្នកម៉ៅការ | ក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ | តាមការជាក់ស្តែង |
| **គ. ធនធានសេដ្ឋកិច្ច-សង្គម** | | | | | | |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ធនធានបរិស្ថាន | ការត្រួតពិនិត្យ | ទីតាំង | ខួបនៃការត្រួតពិនិត្យ | អ្នកទទួលខុសត្រូវ | ស្ថាប័នត្រួតពិនិត្យ | ការប៉ាន់ប្រមាណតំលៃជាដុល្លា |
|---|---|---|---|---|---|---|
| សុខុមាលភាពសាធារណៈ: | អង្កេតទៅលើស្ថានភាព សុខភាពរបស់បុគ្គលិក-កម្មករ | កន្លែងស្នាក់នៅ ទឹកស្អាត និង បង្គន់អនាម័យក្នុងទីតាំងគម្រោង | រៀងរាល់១ខែ/ម្តង | - ម្ចាស់គម្រោង<br>- អ្នកម៉ៅការ | ក្រសួងបរិស្ថាន និងមន្ទីរសុខាភិបាលខេត្តព្រះសីហនុ | តាមការជាក់ស្តែង |
| គ្រឹះអគារ និងគុណភាពសំណង់ | ពិនិត្យទៅលើការសាងសង់ដោយប្រៀបធៀប ជាមួយប្លង់លំអិតគ្រឿងបង្គុំសំណង់ដែលបានអនុម័ត | ប្លង់លំអិតគ្រឿង បង្គុំសំណង់ និង សំណង់កំពុងសាងសង់ | ដំណាក់ការសាងសង់៨ម៉ោង/ថ្ងៃ | - ម្ចាស់គម្រោង<br>- អ្នកម៉ៅការ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | តាមការជាក់ស្តែង |
| **ដំណាក់កាលប្រតិបត្តិគម្រោង (ដំណើរការគម្រោង)** | | | | | | |
| ក. ធនធានរូបសាស្ត្រ | | | | | | |
| គុណភាពទឹក | ត្រួតពិនិត្យតំលៃប៉ារ៉ាម៉ែត្រមួយចំនួនរួមមាន ៖ pH; សីតុណ្ហភាព TSS; COD; BOD5; $PO_4$ $NH_4$, Oil, Grease | នៅត្រង់ចំណុចបញ្ចេញទឹកពីអាងសំអាតសំណល់រាវ | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងបរិស្ថាន | តាមការជាក់ស្តែង |
| ការរំខានដោយសំលេង និង ការបំពុលខ្យល់ | - ទូកនេសាទ<br>- ទូកទេសចរណ៍ និងម៉ូតូបើកលើទឹក។ | - អាងសំអាត សំណល់រាវ<br>- ទីតាំងដាក់សំរាម<br>- ទីតាំងដាក់ម៉ាស៊ីនភ្លើង | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងបរិស្ថាន | តាមការជាក់ស្តែង |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ធនធានបរិស្ថាន | ការត្រួតពិនិត្យ | ទីតាំង | ខួបនៃការត្រួតពិនិត្យ | អ្នកទទួលខុសត្រូវ | ស្ថាប័នត្រួតពិនិត្យ | ការប៉ាន់ប្រមាណតំលៃជាដុល្លា |
|---|---|---|---|---|---|---|
| សំណល់រឹង-រាវ | - ការបែងចែកសំរាមតាមប្លុកផ្ទះលំហែកាយនីមួយៗ<br>- លូបង្ហូរទឹកស្អុយតាមប្លុកនីមួយៗ។ | - អាងសំអាត សំណល់រាវ<br>- ទីតាំងដាក់សំរាម<br>- ទូកដឹកសំរាម | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងបរិស្ថាន និងសាលាខេត្តព្រះសីហនុ | តាមការជាក់ស្តែង |
| **ខ.ធនធានជីវសាស្ត្រ** | | | | | | |
| ធនធានព្រៃឈើ និងសត្វព្រៃ | - ការកាប់ឈើ និងបរបាញ់សត្វព្រៃ<br>- ព្រៃឈើតាមទីជម្រាល និងមាត់ឆ្នេរ<br>- ភ្លើងឆេះព្រៃ និងប្រព័ន្ធផ្លូវការពារភ្លើងឆេះព្រៃ | - ព្រៃឈើនៅតាមមាត់ឆ្នេរ និងទីជម្រាល<br>- កន្លែងដាក់ប្រព័ន្ធការពារភ្លើង<br>- ព្រៃដែលរក្សាទុក | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ | តាមការជាក់ស្តែង |
| ជីវៈចំរុះក្នុងទឹក | - ការគ្រប់គ្រងសំណល់រឹង-រាវរបស់គម្រោង<br>- ព្រៃឈើតាមទីជម្រាល និងមាត់ឆ្នេរ<br>- តំបន់ផ្កាថ្ម<br>- គុណភាពទឹកក្នុងតំបន់គម្រោង | - ព្រៃឈើតាមទីជម្រាល និងមាត់ឆ្នេរ<br>- កន្លែងទុកដាក់សំណល់រឹង និងកន្លែងបង្ហូរសំណល់រាវ ព្រៃរក្សាទុកក្នុងតំបន់គម្រោង | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងបរិស្ថាន និងរដ្ឋបាលជលផល | តាមការជាក់ស្តែង |

#322P, St.271Z, Sk.Terk Tla, Khan Ressy Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ធនធានបរិស្ថាន | ការត្រួតពិនិត្យ | ទីតាំង | ខួបនៃការត្រួតពិនិត្យ | អ្នកទទួលខុសត្រូវ | ស្ថាប័នត្រួតពិនិត្យ | ការប៉ាន់ប្រមាណតំលៃជាដុល្លា |
|---|---|---|---|---|---|---|
| គ. ធនធានសេដ្ឋកិច្ច-សង្គម | | | | | | |
| សុខមាលភាពសាធារណៈ: | - អង្កេតទៅលើស្ថានភាព សុខភាពរបស់បុគ្គលិក-កម្មករ<br>- ទូកទេសចរណ៍ និងម៉ូតូបើកលើទឹក។ | - កន្លែងស្នាក់នៅ ទឹកស្អាត និងបង្គន់អនាម័យក្នុងទីតាំងគម្រោង<br>- តំបន់ជិះទូក និងម៉ូតូលើទឹក | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងសុខាភិបាល និងសាលាខេត្តព្រះសីហនុ | តាមការជាក់ស្តែង |
| សំណល់ | - ការបែងចែកសំរាមតាមប្លុកផ្ទះលំហែកាយនីមួយៗ<br>- លូបង្ហូរទឹកស្អុយតាមប្លុកនីមួយៗ | - អាងសំអាតសំណល់រាវ<br>- ទីតាំងដាក់សំរាម<br>- ទូកដឹកសំរាម | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងបរិស្ថាន និងសាលាខេត្តព្រះសីហនុ | តាមការជាក់ស្តែង |
| ការប្រើប្រាស់ទឹក និងអគ្គិសនី | - ពិនិត្យបណ្តាញខ្សែភ្លើង<br>-ពិនិត្យកន្លែងស្តុកទឹកស្អាត និង<br>ប្រភពទឹកដែលយកមកប្រើប្រាស់ | ទីតាំងបង្គោលភ្លើង និងកន្លែងស្តុកទឹក | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | សាលាខេត្តព្រះសីហនុ | តាមការជាក់ស្តែង |
| | | | | | | |

**ដំណាក់កាលបញ្ចប់គម្រោង**

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ធនធានបរិស្ថាន | ការត្រួតពិនិត្យ | ទីតាំង | ខួបនៃការត្រួតពិនិត្យ | អ្នកទទួលខុសត្រូវ | ស្ថាប័នត្រួតពិនិត្យ | ការប៉ាន់ប្រមាណតំលៃជាំដុល្លា |
|---|---|---|---|---|---|---|
| **ក. ធនធានរូបសាស្ត្រ** | | | | | | |
| គុណភាពទឹក | ត្រួតពិនិត្យតំលៃប៉ារ៉ាម៉ែត្រមួយចំនួនរួមមាន ៖ pH; សីតុណ្ហភាព TSS; COD; BOD5; $PO_4$ $NH_4$, Oil, Greae | នៅត្រង់ចំណុចបញ្ចេញទឹកពីអាងសំអាតសំណល់រាវ | ពេលបញ្ចប់គម្រោង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងបរិស្ថាន | តាមការជាក់ស្តែង |
| ការរំខានដោយសំលេង និងការបំពុលខ្យល់ | - ទូកនេសាទ<br>- ទូកទេសចរណ៍ និងម៉ូតូបើកលើទឹក។ | - អាងសំអាត សំណល់រាវ<br>- ទីតាំងដាក់សំរាម<br>- ទីតាំងដាក់ម៉ាស៊ីនភ្លើង | ពេលបញ្ចប់គម្រោង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងបរិស្ថាន | តាមការជាក់ស្តែង |
| សំណល់រឹង-រាវ | - សំរាមតាម ផ្ទះលំហែកាយនីមួយៗ<br>- លូបង្ហូរទឹកស្អុយតាមប្លុកនីមួយៗ។ | - អាងសំអាត សំណល់រាវ<br>- ទីតាំងដាក់សំរាម | ពេលបញ្ចប់គម្រោង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងបរិស្ថាន និងសាលាខេត្តព្រះសីហនុ | តាមការជាក់ស្តែង |
| **ខ. ធនធានជីវសាស្ត្រ** | | | | | | |
| ធនធានព្រៃឈើ និងសត្វព្រៃ | - ការកាប់ឈើ និងបរបាញ់សត្វព្រៃ<br>- ព្រៃឈើតាមទីជម្រាល និងមាត់ឆ្នេរ | - ព្រៃឈើនៅតាមមាត់ឆ្នេរ និងទីជម្រាល<br>- កន្លែងដាក់ប្រព័ន្ធការពារភ្លើង<br>- ព្រៃដែលរក្សាទុក | ពេលបញ្ចប់គម្រោង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ | តាមការជាក់ស្តែង |

| ធនធានបរិស្ថាន | ការត្រួតពិនិត្យ | ទីតាំង | ខួបនៃការត្រួតពិនិត្យ | អ្នកទទួលខុសត្រូវ | ស្ថាប័នត្រួតពិនិត្យ | ការប៉ាន់ប្រមាណតំលៃជាដុល្លា |
|---|---|---|---|---|---|---|
| ជីវៈចំរុះក្នុងទឹក | - ព្រៃឈើតាមទីជម្រាល និងមាត់ឆ្នេរ<br>- តំបន់ផ្កាថ្ម<br>- គុណភាពទឹកក្នុងតំបន់គម្រោង | - ព្រៃឈើតាមទីជម្រាល និងមាត់ឆ្នេរ<br>- កន្លែងទុកដាក់សំណល់រឹង និងកន្លែងបង្ហូរសំណល់រាវ ព្រៃកក្សាទុកក្នុងតំបន់គម្រោង | ពេលបញ្ចប់គម្រោង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងបរិស្ថាន និងរដ្ឋបាលជលផល | តាមការជាក់ស្តែង |
| គ. ធនធានសេដ្ឋកិច្ច-សង្គម | | | | | | |
| សុខមាលភាពសាធារណៈ | - អង្កេតទៅលើស្ថានភាព សុខភាពរបស់បុគ្គលិក-កម្មករ | - សុខភាពបុគ្គលិក និងកម្មករ | រៀងរាល់៣ខែ/ម្តង | - ម្ចាស់គម្រោង<br>- ទីប្រឹក្សាឯករាជ្យ | ក្រសួងសុខាភិបាល និងសាលាខេត្តព្រះសីហនុ | តាមការជាក់ស្តែង |

កំណត់សំគាល់ ៖

- ថវិកាសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន ក្រុមហ៊ុននឹងធ្វើការត្រៀមបំរុងប្រមាណពី ១០.០០០ ដុល្លាអាមេរិក សម្រាប់ចំណាយទៅលើការអនុវត្តសកម្មភាពនីមួយៗនៃផែនការគ្រប់គ្រងបរិស្ថាន

# ជំពូកទី៩

# ការវិភាគសេដ្ឋកិច្ច និងតម្លៃធនធានបរិស្ថាន

# ជំពូកទី៩៖ ការវិភាគសេដ្ឋកិច្ច និងតម្លៃធនធានបរិស្ថាន

## ៩.១ សេចក្ដីផ្ដើម

ការអភិវឌ្ឍតំបន់កោះក្របី ឲ្យប្រែក្លាយជារមណីដ្ឋានទេសចរណ៍ តំបន់លំហែកាយកោះក្របី ពិតជាមានសារៈសំខាន់ណាស់ក្នុងការរួមចំណែកលើកស្ទួយសេដ្ឋកិច្ចរបស់ប្រជាជនមូលដ្ឋាន តាមរយៈការផ្ដល់ឱកាសការងារ និងសេដ្ឋកិច្ចជាតិទាំងមូលតាមរយៈការទទួលបានចំណូលពន្ធពីការអភិវឌ្ឍ។ ទោះបីជាយ៉ាងណា ដើម្បីធានាឲ្យបានថាការវិនិយោគរបស់គម្រោងនីមួយៗលើផ្ទៃដីសម្បទានរបស់រាជរដ្ឋាភិបាលកម្ពុជា **ក្រសួងបរិស្ថាន** បានតម្រូវឲ្យម្ចាស់ក្រុមហ៊ុនវិនិយោគទាំងអស់ធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីជៀសវាង ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាននានាមកត្រឹមកម្រិតអប្បបរមា។ ជាមួយគ្នានេះ ក្នុងរបាយការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម បានតម្រូវឲ្យមានការសិក្សារួមបញ្ចូលជំពូកទី៩ ដើម្បីធ្វើការសិក្សាវិភាគនិងវាយតម្លៃលើផលចំណេញផ្នែកសេដ្ឋកិច្ច និងតម្លៃខាតបង់ផ្នែកបរិស្ថានឲ្យបានច្បាស់មុននឹងធ្វើការសម្រេចចិត្តអនុញ្ញាតឲ្យក្រុមហ៊ុនវិនិយោគធ្វើការវិនិយោគបន្ត ឬយ៉ាងណា។

ជំពូកទី៩នេះនឹងធ្វើការពិពណ៌នាអំពីការវិភាគផ្នែកសេដ្ឋកិច្ច និងតម្លៃធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គម្រោងអភិវឌ្ឍន៍កោះក្របី (កោះចន្លុះ)។ ជំពូកនេះ ពិពណ៌នាអំពីផលចំណេញដែលម្ចាស់គម្រោងអាចនឹងទទួលបានដោយប្រៀបធៀបទៅលើផលចំណេញ និងតម្លៃនៃការខូចខាតធនធានបរិស្ថានដែលអាចកើតមានឡើងពីសកម្មភាពគម្រោង។ការវិភាគសេដ្ឋកិច្ច និងតម្លៃធនធានបរិស្ថាន អាចផ្ដល់ព័ត៌មានសំខាន់ដល់រាជរដ្ឋាភិបាល និងអ្នករៀបចំគោលនយោបាយ ដើម្បីធ្វើការប្រៀបធៀបតម្លៃសេដ្ឋកិច្ចដែលអាចទទួលបាន និងតម្លៃនៃការខូចខាតធនធានបរិស្ថានដែលបណ្ដាលមកពីវត្តមាននៃគម្រោង។ ការវិភាគតម្លៃសេដ្ឋកិច្ច និងតម្លៃនៃការខូចខាតធនធានបរិស្ថាន ត្រូវបានវិភាគតាមក្របខ័ណ្ឌទ្រឹស្ដីសេដ្ឋកិច្ច។ ការសិក្សានេះ នឹងប្រើប្រាស់វិធីសាស្ត្រវិភាគផលចំណេញ និងការខាតបង់ (Cost and Benefit Analysis) វិភាគរកតម្លៃអត្រាចំណូលវិនិយោគខាងក្នុង (IRR) បន្ទេរតម្លៃផលចំណេញ (Benefit Transfers) និងការវិភាគរយៈពេលនៃការទទួលបានផលចំណេញមកវិញ (Payback Period) ក្នុងរយៈពេលវិនិយោគ ៩៩ឆ្នាំ ដែលរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចផ្ដល់ដីសម្បទានចំនួន ១០ហិចតា ឲ្យទៅ **ក្រុមហ៊ុន អភីប៊ី អ៊ិនវេសមេន ខូអិលធីឌី** សម្រាប់ធ្វើការអភិវឌ្ឍ។

## ៩.២ ការពិពណ៌នាអំពីផលចំណេញដែលទទួលបានពីគម្រោង

### ៩.២.១ ប្រជាជនមូលដ្ឋាន

ក. ទទួលបានការងារពីគម្រោង

វត្តមាននៃគម្រោងអភិវឌ្ឍន៍កោះក្របី មិនត្រឹមតែបានផ្តល់ឱកាសការងារដល់ប្រជាជនមូលដ្ឋានដែលរស់នៅជិតតំបន់អភិវឌ្ឍន៍កោះក្របីប៉ុណ្ណោះទេ ហើយថែមទាំងបានផ្តល់ឱកាសការងារដល់ប្រជាជនដែលរស់នៅតាមបណ្តាខេត្តដទៃទៀតដូចជា តាកែវ ស្វាយរៀង កំពង់ចាម កំពត កំពង់ធំ និងខេត្តកណ្តាលជាដើម។ តាមរយៈការសម្ភាសន៍ជាមួយអនុប្រធានទទួលបន្ទុកលើផ្នែកសាងសង់នៃគម្រោងអភិវឌ្ឍន៍កោះក្របីបានឱ្យដឹងថា ប្រជាជនប្រមាណ ៧០០ នាក់ ត្រូវបានផ្តល់ការងារជារៀងរាល់ថ្ងៃ បែងចែកទៅតាមកម្រិតជំនាញ និងប្រភេទការងារនីមួយៗ។



រូបភាពទី៩.១៖ កម្មករ កម្មការនីពេលចេញពីធ្វើការ



រូបភាពទី៩.២៖ កម្មករដឹកជញ្ជូន និងទម្លាក់ទំនិញ

ប្រភេទការងារទាំងនោះរួមមាន ផ្នែកដឹកជញ្ជូន (ខ្សាច់ ដែក ស៊ីម៉ង់ ទឹក និងសម្ភារៈសំណង់ផ្សេងៗ ។ល។) ផ្នែកសាងសង់ និងផ្នែកបោសសម្អាត។ពួកគេធ្វើការ ៧ ថ្ងៃក្នុងមួយសប្តាហ៍ ហើយក្នុងមួយថ្ងៃពួកគេ បានតម្រូវឱ្យធ្វើការរយៈពេល ៧ ម៉ោង គឺចាប់ពីម៉ោង ៧ ព្រឹករហូតដល់ម៉ោង ១២ ថ្ងៃត្រង់ និងចាប់ពីម៉ោង ១ ថ្ងៃត្រង់រហូតដល់ម៉ោង ៤ រសៀល។ ចំពោះប្រាក់ថ្លៃឈ្នួលប្រចាំថ្ងៃមានលក្ខណៈខុសគ្នាបន្តិចបន្តួចទៅតាមសមត្ថភាពជំនាញរបស់កម្មករ/កម្មការនីម្នាក់ៗ ចន្លោះពី ២០,០០០ រៀល/ម្នាក់/ថ្ងៃ ទៅ ៣៦,០០០ រៀល/ម្នាក់/ថ្ងៃ (៥-៩ ដុល្លារសហរដ្ឋអាមេរិច/ម្នាក់/ថ្ងៃ)។កម្មករ/កម្មការនីទាំងអស់ ត្រូវបានស្នើឡើងឱ្យធ្វើការថែមម៉ោងតាមរយៈការស្ម័គ្រចិត្តជាមួយនឹងតម្លៃថ្លៃឈ្នួលបន្ថែម ៤,០០០រៀល/មួយម៉ោង/ម្នាក់ (១ ដុល្លារសហរដ្ឋអាមេរិច/មួយម៉ោង/ម្នាក់)។ ជាមធ្យម កម្មករ/កម្មការនី ដែលធ្វើការនៅក្នុងគម្រោងអភិវឌ្ឍន៍កោះក្របីនេះ អាចទទួលបានប្រាក់ឈ្នួលប្រមាណពី ៦០០,០០០ រៀល/ម្នាក់/ខែ ទៅ ១,០៨០,០០០ រៀល/ម្នាក់/ខែ (១៥០-២៧០ ដុល្លារសហរដ្ឋអាមេរិច/ម្នាក់/ខែ) និងប្រមាណពី ៦៤០,០០០ រៀល/ម្នាក់/ខែ ទៅ ១,៣៨០,០០០ រៀល/ម្នាក់/ខែ (១៦០-៣៧៥ ដុល្លារសហរដ្ឋអាមេរិច/ម្នាក់/ខែ) ប្រសិនបើពួកគេធ្វើការថែមម៉ោង។

ជាមធ្យមពួកគេធ្វើការថែមម៉ោងប្រមាណពី ១០ ទៅ ៧៥ ម៉ោងក្នុងមួយខែ។ ប្រាក់ខែ ត្រូវបានបើកជូនកម្មករ/កម្មការនីជាពីរដំណាក់កាលនៅរៀងរាល់ពីរសប្តាហ៍ម្តង។

ខ. ការលក់ដូរដាច់ជាងមុន

បច្ចុប្បន្ន ប្រជាពលរដ្ឋប្រមាណ ២០គ្រួសារ បានបើកអាហារដ្ឋាននៅតាមមាត់ឆ្នេរ ដើម្បីផ្តល់សេវាកម្មម្ហូបអាហារ និងគ្រឿងវត្ថុអនុស្សាវរីយ៍ដល់ភ្ញៀវទេសចរណ៍ក្នុងស្រុក និងបរទេស ដែលមានបំណងធ្វើដំណើរកំសាន្តនៅតាមកោះ ដូចជាកោះតាគៀវ និងកោះឬស្សី។ ដូចនេះ វត្តមានគម្រោងអភិវឌ្ឍន៍កោះក្របី អាចនឹងបង្កើនភាពទាក់ទាញដល់ភ្ញៀវទេសចរណ៍ទាំងក្នុងស្រុក និងបរទេស ឲ្យមកទស្សនាកាន់តែច្រើនឡើងៗ។ ទន្ទឹមនេះ លក្ខណៈអាជីវកម្មរបស់ប្រជាជននៅតាមមាត់ឆ្នេរ ក៏អាចនឹងមានភាពមមាញឹក និងទទួលបានប្រាក់ចំណូលច្រើនជាងមុនផងដែរ។

គ. ហេដ្ឋារចនាសម្ព័ន្ធ

ចំពោះហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងភ្លើងអគ្គីសនី ត្រូវបានតភ្ជាប់ និងអភិវឌ្ឍរួចជាស្រេចនៅក្នុងតំបន់គម្រោងមុននឹងដាក់ដំណើរការគម្រោង។ ទន្ទឹមនេះ វត្តមានគម្រោងអភិវឌ្ឍន៍កោះក្របី បានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបន្ថែមទាំងនៅតំបន់មាត់ច្រាំង និងលើកោះ។ ការអភិវឌ្ឍនៅមាត់ច្រាំង រួមមានកំពង់ផែចំនួន ០១ និងបន្ទប់ទទួលភ្ញៀវចំនួន ០១ ដែលបំពាក់ដោយម៉ាស៊ីនត្រជាក់ និងប្រព័ន្ធអ៊ីនធឺណេតដើម្បីផ្តល់ភាពងាយស្រួលដល់ភ្ញៀវទេសចរណ៍ដែលមកទស្សនាកំសាន្តនៅកោះក្របី។ ចំណែកឯការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅលើកោះរួមមានកំពង់ផែសម្រាប់ចុះចតនៅលើកោះចំនួន ០១ ឃ្លាំងដាក់ សម្ភារៈបច្ចេកទេសចំនួន ០១ អាគារស្នាក់នៅសម្រាប់បុគ្គលិកចំនួន ០១ អាគារពេទ្យចំនួន ០១ និងទីស្នាក់ការប៉ុស្តិ៍ប៉ូលីសចំនួន ០១។ យោងតាមអនុក្រឹត្យលេខ ១៦១ អនក្រប.ក ចុះថ្ងៃទី ០១ ខែ វិច្ឆិកាឆ្នាំ ២០០៧ ស្តីពីការធ្វើអនុបយោគ និងសំបុត្រចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០៨ បានបញ្ជាក់ថា តំបន់កោះក្របី ត្រូវបានជូលឱ្យក្រុមហ៊ុនអគីប៊ីអ៊ិនវេសមេន ខូអិលធីឌី ដើម្បីធ្វើការអភិវឌ្ឍរយៈពេល ៩៩ ឆ្នាំ។ ដូចនេះ ហេដ្ឋារចនាសម្ព័ន្ធដែលបានអភិវឌ្ឍទាំងនៅតំបន់មាត់ច្រាំង និងលើកោះក្របី នឹងត្រូវចាត់ទុកជាសម្បត្តិរដ្ឋបន្ទាប់ពីកុងត្រាជួលរយៈពេល ៩៩ឆ្នាំ ត្រូវបានបញ្ចប់។

### ៩.២.២ រាជរដ្ឋាភិបាល និងសង្គមជាតិ

ក. ការបង់ពន្ធ

ចំពោះការបង់ពន្ធចូលរដ្ឋ ក្រុមហ៊ុនវិនិយោគលើតំបន់កោះក្របី ត្រូវបានតម្រូវឱ្យបង់៣% (បីភាគរយ)នៃចំណូលដុលជារៀងរាល់ឆ្នាំ (ចាប់ពីថ្ងៃទី១ ដល់១៥ខែមករានៅឆ្នាំបន្ទាប់)។ ប៉ុន្តែ ក្នុង

ករណីការគណនាតាមអត្រានៃចំណូលដុល តិចជាងការគណនានៃការបង់ថ្លៃឈ្នួលអប្បបរមា ភាគីក្រុមហ៊ុននឹងត្រូវតម្រូវឱ្យបង់ពន្ធថ្លៃឈ្នួលក្នុងតម្លៃអប្បបរមាចំនួន៨៤០០ដុល្លាក្នុងមួយឆ្នាំ រួចនឹងកើនឡើងចំនួន ១.០៥០ដុល្លារៀងរាល់៥ឆ្នាំម្តងរហូតដល់ចប់កិច្ចសន្យា។ តាមរយៈនៃការជួលតំបន់កោះក្របី របស់រដ្ឋាភិបាលឱ្យទៅក្រុមហ៊ុន សម្រាប់វិនិយោគ ភាគីរដ្ឋាភិបាលអាចនឹងមានលទ្ធភាពទទួលបានចំណូលតាមរយៈការបង់ពន្ធប្រមាណ**៨២.៨០០ដុល្លាសហរដ្ឋអាមេរិក** ក្នុងមួយឆ្នាំ។

ក្រៅពីទទួលបានចំណូលពីការកាត់ពន្ធពីចំណូលដុលរបស់ក្រុមហ៊ុនវិនិយោគ រដ្ឋាភិបាលអាចនឹងទទួលបានចំណូលបន្ថែមទៀតពីការកាត់ពន្ធប្រាក់បៀវត្តន៍ពីនិយោជិករបស់ក្រុមហ៊ុននេះក្នុងកំឡុងពេលប្រតិបត្តិគម្រោង។ ចំណូលពីការកាត់ពន្ធប្រាក់បៀវត្តន៍ពីនិយោជិកគឺខុសគ្នាទៅតាមទំហំនៃប្រាក់បៀវត្តន៍របស់ពួកគេ។ ជាទូទៅ តាមគោលការណ៍កាត់ពន្ធលើប្រាក់ខែដើម្បីបង់ពន្ធចូលរដ្ឋត្រូវអនុវត្តន៍ចំពោះនិយោជិកណាដែលមានប្រាក់បៀវត្តន៍ចាប់ពី១លានរៀលឡើងទៅ ហើយអត្រានៃការកាត់ពន្ធគឺចាប់ពី៥% រហូតដល់៣០% ដោយអាស្រ័យទំហំខុសគ្នានៃប្រាក់ខែរបស់និយោជិក។

### ខ. ថវិកាសម្រាប់កិច្ចគាំពារបរិស្ថាន និងសង្គម

ការអភិវឌ្ឍន៍រមណីយដ្ឋានលំហែកាយស្ថិតលើតំបន់កោះក្របី គឺពុំសូវមានជាបញ្ហាចោទលើបរិស្ថានក្នុងតំបន់នោះប៉ុន្មានទេ តែផ្ទុយទៅវិញការអភិវឌ្ឍន៍នេះអាចជួយកែប្រែតំបន់កោះក្របីនេះឱ្យក្លាយជារមណីយដ្ឋានទំនើបបែបធម្មជាតិសម្រាប់ភ្ញៀវទេសចរណ៍បានមកទទួលយកការសម្រាកលំហែកាយ និងទទួលបានខ្យល់ដកដង្ហើមបរិសុទ្ធទៀតផង។ ក្រោមរូបភាពនៃការអភិវឌ្ឍនេះ ក្រុមហ៊ុននឹងមានផែនការកែលម្អបរិស្ថានធម្មជាតិក្នុងតំបន់នោះ ឱ្យក្លាយជាតំបន់រមណីយដ្ឋានបែបធម្មជាតិនៅលើកោះ ដោយមានសកម្មភាពនៃការដាំដើមឈើឬរុក្ខជាតិលម្អនៅក្នុងតំបន់គម្រោង។ ការកែលម្អបរិស្ថានក្នុងតំបន់នោះ ឱ្យមានភាពស្រស់ស្អាត និងទាក់ទាញ គឺជាផ្នែកមួយធ្វើឱ្យបរិស្ថានក្នុងតំបន់នោះកាន់តែមានភាពល្អប្រសើរឡើង និងអាចចូលរួមក្នុងការស្តារបរិស្ថានក្នុងតំបន់នោះទៀតផង។ មិនត្រឹមតែប៉ុណ្ណោះ វាក៏អាចចូលរួមចំណែកមួយភាគតូចក្នុងការគ្រប់គ្រងបរិស្ថានតំបន់នោះឱ្យល្អប្រសើរ ជាជាងការទុកចោល ដែលអាចបង្កឱ្យតំបន់នោះក្លាយជាបរិស្ថានកខ្វក់ និងគ្មានការយកចិត្តទុកដាក់ថែរក្សា។ លើសពីនេះទៀត ការដាំដើមឈើឬរុក្ខជាតិលម្អ អាចចូលរួមចំណែកមួយផ្នែកតូចក្នុងការស្រូបយកកាបូនឌីអុកស៊ីតពីបរិយាកាស។

ម្យ៉ាងវិញទៀត ការអភិវឌ្ឍន៍រមណីយដ្ឋានលំហែកាយនេះអាចផ្តល់នូវជាទស្សនីយភាពដ៏ស្រស់ស្អាតដល់ប្រជាជនរស់ក្នុងស្រុក និងក្រៅស្រុកអាចទទួលបានការកម្សាន្ត និងលំហែរកាយក្រៅពីកិច្ចការងារទៀតផង ដែលវាអាចរួមចំណែកមួយផ្នែកណាមួយដល់វិស័យទេសចរណ៍ក្នុង

តំបន់នោះផងដែរ។ វាក៏ជាឱសថព្យាបាលជម្ងឺផ្លូវចិត្តបែបធម្មជាតិមួយ ដែលធ្វើឱ្យភ្ញៀវទេសចរណ៍បានសប្បាយរីករាយនឹងការផ្តល់ជូនរបស់រមណីយដ្ឋានលំហែកាយនេះថែមទៀតផង។

ក្រៅពីសកម្មភាពដាំដើមឈើឬរុក្ខជាតិលម្អរក្នុងតំបន់រមណីដ្ឋាននេះ
ក៏អាចមានសកម្មភាពជួយជួសជុលផ្លូវថ្នល់ឆ្ពោះទៅកាន់រមណីដ្ឋាននេះមួយចំនួន ដែលមានទីតាំងក្បែរតំបន់គម្រោងនេះ
ដើម្បីផ្តល់ភាពងាយស្រួលដល់ការធ្វើដំណើររបស់ភ្ញៀវទេសចរណ៍ទៀតផង។

សរុបសេចក្តីមក ការផ្តល់សម្បទានកោះក្របី (កោះចន្លុះ) រយៈពេល៩៩ឆ្នាំរបស់រដ្ឋាភិបាលកម្ពុជាឱ្យទៅក្រុមហ៊ុនអគីប៊ីសម្រាប់អភិវឌ្ឍជារមណីយដ្ឋានលំហែកាយប្រណីតបែបធម្មជាតិ ពិតជាបានចូលរួមក្នុងការថែរក្សាបរិស្ថាន និងជួយដល់សង្គមក្នុងតំបន់នោះ ក៏ដូចជាសង្គមជាតិទាំងមូលដែរ។

### គ. ការរីកចម្រើនលើវិស័យទេសចរណ៍

ការអភិវឌ្ឍន៍រមណីយដ្ឋានលំហែកាយកោះក្របីលើផ្ទៃដីទំហំ**១០ហិកតា**ស្ថិតលើកោះក្របី (កោះចន្លុះ) អាចជម្រុញដល់ការរីកចម្រើនបន្ថែមទៀតលើវិស័យទេសចរណ៍នៅកម្ពុជា ដោយសារតែ កម្ពុជាអាចនឹងលេចមុខមាត់បន្ថែមទៀតនៅពេលមានវត្តមានរបស់រមណីយដ្ឋានលំហែកាយទំនើបបែបធម្មជាតិហើយក៏ជារមណីយដ្ឋានដ៏ស្រស់ស្អាតខ្នាតអន្តរជាតិ។ ពិតប្រាកដណាស់ការផ្តល់នូវទីកន្លែងលំហែកាយនិងទីកន្លែងស្នាក់នៅដែលមានផាសុខភាពដល់ភ្ញៀវទេសចរណ៍គឺជាផ្នែកមួយដ៏សំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរណ៍អន្តរជាតិលំដាប់ខ្ពស់ ហើយក៏ជាឱកាសដ៏វិសេសវិសាលរបស់កម្ពុជាក្នុងការបង្ហាញពីវិសាលភាពផ្នែកទេសចរណ៍ដល់វិនិយោគិនបរទេសផ្សេងទៀតឱ្យចូលមកកម្សាន្តនិងសិក្សាលើទីផ្សារសេដ្ឋកិច្ចរបស់កម្ពុជា។

ការរីកចម្រើនលើវិស័យរូបណីយកម្ម ក៏ដូចជាភាពប្រសើរឡើងនូវទីកន្លែង សម្រាក់លំហែរកាយ គឺជាកត្តាមួយជម្រុញឱ្យមានកំណើរភ្ញៀវទេសចរណ៍បរទេសកាន់តែច្រើនឡើងៗ។ ទន្ទឹមនឹងនេះ ការរីកចម្រើនលើវិស័យទេសចរណ៍ ក៏ជាធាតុចូលមួយនៃកំណើនសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជាផងដែរៗ ដូចនេះ ការវិនិយោគលើគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានលំហែកាយកោះក្របីមិនត្រឹមតែចូលរួមចំណែកក្នុងការលើកស្ទួយវិស័យទេសចរណ៍ទេ ហើយថែមទាំងរួមចំណែកលើកកំពស់សេដ្ឋកិច្ចសង្គមក្នុងតំបន់ និងការកើនឡើងនូវកំណើនសេដ្ឋកិច្ចជាតិមួយកម្រិតទៀតផង។

## ៩.២.៣ ម្ចាស់គម្រោងអភិវឌ្ឍន៍

### ក. ការប៉ាន់ប្រមាណការចំណាយក្នុងការអភិវឌ្ឍន៍គម្រោង

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphosuntous09@yahoo.com / www.CREATIVE09.com

យោងតាមគំរូប្លង់មេរបស់ក្រុមហ៊ុន តំបន់កោះក្របី នឹងត្រូវបែងចែកជា ៥តំបន់សម្រាប់ធ្វើការអភិវឌ្ឍ។ តំបន់ទី១៖ ក្រុមហ៊ុន គ្រោងនឹងសាងសង់ផ្ទះលំហែរកាយ លើទំហំផ្ទៃដី ៧,៥ ហិចតា។ តំបន់ទី២៖ ក្រុមហ៊ុន គ្រោងនឹងសាងសង់តំបន់សេវាកម្ម លើទំហំផ្ទៃដី ១ហិចតា។ តំបន់ទី៣៖ ក្រុមហ៊ុន គ្រោងនឹងសាងសង់ឃ្លាំងសម្រាប់ស្តុកទុកសម្ភារៈផ្សេងៗ លើទំហំផ្ទៃដី ១,៥ហិចតា។ តំបន់ទី៤៖ ក្រុមហ៊ុន គ្រោងនឹងសាងសង់កន្លែងចំណតឡាន និងកំពង់ផែសម្រាប់រង់ចាំការមកដល់របស់ភ្ញៀវទេសចរណ៍ លើទំហំផ្ទៃដី ០,១ហិចតា។ ចំណែកឯតំបន់ទី៥៖ ក្រុមហ៊ុន គ្រោងនឹងសាងសង់អគារសម្រាប់ដាក់សម្ភារៈបច្ចេកទេស លើទំហំផ្ទៃដី ០,០៥ហិចតា។ ដើម្បីអភិវឌ្ឍតំបន់កោះក្របីឲ្យក្លាយជាតំបន់រមណីដ្ឋានលំហែរកាយកោះក្របីដ៏ស្រស់ស្អាត ក្រុមហ៊ុនគ្រោងនឹងចំណាយទុនវិនិយោគចំនួន **១០.០០៩.០០០ ដុល្លា** (**ដប់លានប្រាំបួនពាន់ដុល្លាសហរដ្ឋអាមេរិច**)ក្នុងរយៈពេលកិច្ចសន្យាវិនិយោគ ៩៩ឆ្នាំ។

ចន្លោះឆ្នាំ២០០៧ ដល់ចុងឆ្នាំ២០១៣ **ក្រុមហ៊ុនអតីប៊ី** បានចំណាយទុនវិនិយោគសរុបប្រមាណ **៤.៥៤៨.៨៥០ដុល្លា** (**បួនលានប្រាំរយសែសិបប្រាំបីពាន់ប្រាំបីរយហាសិបដុល្លាសហរដ្ឋអាមេរិច**)សម្រាប់ដំណាក់កាលនៃការសាងសង់គម្រោង។ ក្នុងអំឡុងឆ្នាំ២០១៤ ក្រុមហ៊ុនបន្តការចំណាយលើការសាងសង់ និងការអភិវឌ្ឍន៍តំបន់រមណីយដ្ឋានលំហែរកាយនេះ ចំនួនប្រមាណជាង **៣.៥០០.០០០ ដុល្លា** (**បីលានប្រាំរយពាន់ដុល្លាសហរដ្ឋអាមេរិច**) និងរហូតដល់សព្វថ្ងៃនេះ (ក្នុងឆ្នាំ២០១៥) ក្រុមហ៊ុនបានចំណាយទុនប្រមាណ **២.០០០.០០០ដុល្លា**បន្ថែមទៀតលើការសាងសង់ និងប្រែក្លាយតំបន់កោះក្របីឱ្យក្លាយជាមណីយដ្ឋានទំនើប និងស្រស់ស្អាត។ មកទល់សព្វថ្ងៃនេះ **ក្រុមហ៊ុនអតីប៊ី** បានចំណាយទុនសរុបប្រមាណជាង **១០លានដុល្លា** (**១០.០៤៨.៨៥០ដុល្លា**)។ការចំណាយលើដំណើរការសាងសង់ និងកែប្រែតំបន់កោះក្របីនេះ រួមបញ្ចូលទាំង (១) ការចំណាយលើកម្មករសាងសង់ (២) សម្ភារៈសាងសង់ និងគ្រឿងសង្ហារឹមតុបតែងវីឡា និងរមណីយដ្ឋាន (៣) ទិញគ្រឿងចក្រ (៤) ចំណាយលើការសិក្សានិងរៀបចំប្លង់ និង (៥) ចំណាយលើផ្នែករដ្ឋបាល។

## ខ. ការប៉ាន់ប្រមាណចំណូលដែលទទួលបានពីគម្រោង

តាមការអង្កេតនិងការប៉ាន់ប្រមាណចំណូលដែលទទួលបានពីគម្រោង បញ្ជាក់ថា ប្រភពចំណូលចំនួនពីរសំខាន់ៗ ដែលគម្រោងវិនិយោគនេះអាចទទួលបានគឺ (១)ការជួលបន្ទប់សណ្ឋាគារលំដាប់ផ្កាយ៥និងម៉ូតែលប្រណិត និង(២) ការផ្តល់សេវាកម្មនានារបស់រមណីយដ្ឋានលំហែរកាយ ដូចជា សេវាបោកកក់ សេវាម៉ាស្សានិងស្ប៉ា សេវាចំណីអាហារនិងភេសជ្ជៈ សេវាជូនភ្ញៀវទេសចរណ៍ដើរកម្សាន្ត និងសេវាផ្សេងៗទៀត។ល។ តម្លៃជួលវីឡាសម្រាប់ភ្ញៀវទេសចរណ៍គឺ**៥០០ដុល្លា**ក្នុងមួយយប់ និងតម្លៃសេវាកម្មផ្សេងទៀតគឺប្រែប្រួលទៅតាមប្រភេទនៃតម្រូវការរបស់ភ្ញៀវទេសចរណ៍។ តាមផែនការនៃគម្រោងសាងសង់របស់គម្រោងនេះ គឺមានបន្ទប់

សណ្ឋាគារលំដាប់ផ្កាយប្រាំ**ចំនួន៤០បន្ទប់** សម្រាប់ជួលជូនដល់ការស្នាក់នៅរបស់ភ្ញៀវទេសចរណ៍។ បន្ទាប់ពីបញ្ចប់គម្រោងសាងសង់ ក្រុមហ៊ុនប្រឹក្សាយោបល់បានធ្វើការព្យាករណ៍ថា រមណីយដ្ឋានលំហែកាយកោះក្របីអាចទាក់ទាញភ្ញៀវទេសចរណ៍ចូលមកស្នាក់នៅជាមធ្យមចាប់ពី**៥០០បន្ទប់**ក្នុងមួយខែ ស្មើនឹង**២២០.០០០ដុល្លាសហរដ្ឋអាមេរិច**ក្នុងមួយខែ។

គ. ផលចំណេញដែលក្រុមហ៊ុនអភិវឌ្ឍន៍ទទួលបាន

**ក្រុមហ៊ុនអតីទី**ដែលវិនិយោគលើគម្រោងរមណីយដ្ឋានលំហែកាយកោះក្របីអាចនឹងទទួលបាននូវប្រាក់ចំណូលមកវិញនៅចន្លោះឆ្នាំទី៣ និងទី៤ដោយគិតពីកំឡុងពេលនៃការប្រតិបត្តិគម្រោង។ ប៉ុន្តែប្រាក់ចំណូលទាំងនោះ អាចប្រែប្រួលកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារកំណើននៃការចូលទស្សនា និងការរីកចម្រើនលើវិស័យទេសចរណ៍។តាមការវិភាគប៉ាន់ស្មាន នៅដំណាក់កាលប្រតិបត្តិគម្រោង ការវិនិយោគរបស់**ក្រុមហ៊ុនអតីទី** អាចទទួលបានប្រាក់ចំណេញប្រចាំឆ្នាំជិត**៣លានដុល្លាសហរដ្ឋអាមេរិច** ក្រោយពីការទូទាត់ការចំណេញផ្សេងៗ ជារៀងរាល់ឆ្នាំ។

### ៩.២.៤ ការវិភាគស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់គម្រោងវិនិយោគ

ការវិភាគស្ថានភាពសេដ្ឋកិច្ចរបស់គម្រោងវិនិយោគត្រូវបានអនុវត្តន៍ដោយប្រើប្រាស់ក្របខណ្ឌវិភាគសេដ្ឋកិច្ចដូចជាការវិភាគផលចំណេញនិងការខាតបង់ (Cost and Benefit Analysis) ការវិភាគរកតម្លៃអត្រាចំណូលវិនិយោគខាងក្នុង (IRR) និងការវិភាគរយៈពេលនៃការទទួលបានផលចំណេញមកវិញ (Payback Period)។ដោយហេតុថាក្នុងដំណាក់កាលនៃការប្រតិបត្តគម្រោងស្ថានភាពនៃការប៉ាន់ស្មានលំហូរសាច់ប្រាក់ប្រចាំឆ្នាំមានស្ថានភាពស្មើៗគ្នាក្នុងឆ្នាំនីមួយៗដូចនេះ យើងបានកំណត់យករយៈពេល២៥ឆ្នាំក្នុងការវិភាគសេដ្ឋកិច្ចនៅក្នុងគម្រោងនេះ។

ក. ក្របខណ្ឌវិភាគផលចំណេញនិងការខាតបង់ (Cost and Benefit Analysis)

លទ្ធផលវិភាគផលចំណេញខាតនៃគម្រោងវិនិយោគរមណីយដ្ឋានលំហែកាយកោះក្របីបានបង្ហាញថា ការវិនិយោគលើគម្រោងនេះ ពិតជាបានផ្តល់នូវផលចំណេញផ្នែកហិរញ្ញវត្ថុច្រើនគួរសមដល់ម្ចាស់គម្រោងវិនិយោគនេះ ដោយសារតែការវិភាគនេះរកឃើញតម្លៃអត្រាផលធៀបចំណេញខាត (Benefit-cost ratio) ស្មើនឹង១,៥០។ តួលេខនេះ សបញ្ជាក់ឱ្យដឹងថាប្រសិនបើការវិនិយោគរបស់ក្រុមហ៊ុននេះ១ដុល្លា នោះនឹងទទួលបានផលចំណេញសុទ្ធមកវិញ០,៥០ដុល្លា។ ជាក់ស្តែង តាមការប៉ាន់ស្មានលំហូរសាច់ប្រាក់នៃការវិនិយោគ បង្ហាញថា ក្រុមហ៊ុនវិនិយោគលើរមណីយដ្ឋានលំហែកាយកោះក្របីនេះ នឹងចំណាយជាង**១០ម៉ឺនដុល្លា**ក្នុងមួយឆ្នាំៗ នៅក្នុង

ដំណាក់កាលប្រតិបត្តិគម្រោង ហើយក្រុមហ៊ុននេះអាចនឹងទទួលបានចំណូលដុលសរុបប្រមាណជិត**៣លានដុល្លា**ក្នុងមួយឆ្នាំៗ។ ក្រោយការទូទាត់ការចំណាយក្នុងដំណាក់កាលប្រតិបត្តិគម្រោង ក្រុមហ៊ុនអាចនឹងទទួលបានផលចំណេញសុទ្ធសរុបប្រមាណជាង**២,៥លានដុល្លា**ក្នុងមួយឆ្នាំ។ សរុបមក ការវិនិយោគរមណីយដ្ឋានលំហែកាយកោះក្របីពិតជាផ្តល់នូវផលចំណេញច្រើនដល់ការវិនិយោគទុនរបស់**ក្រុមហ៊ុនអតីប៊ី**។

ខ. ក្របខណ្ឌវិភាគរកតម្លៃអត្រាចំណូលវិនិយោគខាងក្នុង (IRR)

តម្លៃអត្រាចំណូលវិនិយោគខាងក្នុង (IRR) ត្រូវបានវិភាគឃើញថាស្មើនឹង១៥% ធៀបនឹងតម្លៃអត្រាប៉ាន់ស្មាន១០%។ ដោយមើលឃើញ ពីតម្លៃអត្រា IRR ត្រូវបានគណនាឃើញខ្ពស់ជាងអត្រាភាគរយដែលក្រុមហ៊ុនរំពឹងទុកថាប្រាក់ចំណូលអាចរកបាន នោះការវិនិយោគរបស់ក្រុមហ៊ុននេះគឺមានសង្ឃឹមទទួលបានផលចំណេញច្រើនពីគម្រោងនេះ។ ផ្ទុយទៅវិញ បើការគណនាតម្លៃ IRR ទាបជាងតម្លៃ (Discount rate) អត្រាដែលក្រុមហ៊ុនរំពឹងទុក នោះក្រុមហ៊ុននេះមិនគួរវិនិយោគលើគម្រោងនេះទេ ដោយសារតែការទទួលបានប្រាក់ចំណូលមកវិញមានសង្ឃឹមតិចតួច ហើយងាយប្រឈមនឹងហានិភ័យនៃហិរញ្ញវត្ថុ។

គ. ក្របខណ្ឌវិភាគរករយៈពេលនៃការទទួលបានផលចំណេញមកវិញ (Payback Period)

ជាទូទៅ ការវិនិយោគលើគម្រោងអភិវឌ្ឍអ្វីមួយ គឺតែងតែចំណាយទុនដំបូងខ្ពស់ហើយអ្នកវិនិយោគិនគ្រប់រូបរំពឹងថានឹងទទួលបានការទូទាត់ផលចំណេញមកវិញក្នុងថេរៈវេលាណាមួយ។ ស្រដៀងគ្នានេះដែរ ក្នុងផ្នែកនេះ យើងនឹងវិភាគរករយៈពេលនៃការទទួលបានផលចំណេញមកវិញ របស់គម្រោងវិនិយោគនេះ។ តាមការវិភាគថ្លឹងថ្លែង យើងឃើញថាការវិនិយោគលើគម្រោងរមណីយដ្ឋានកោះក្របី អាចនឹងទទួលបានផលចំណេញសុទ្ធមកវិញក្នុងឆ្នាំទី៣,៦៣ ឬចន្លោះឆ្នាំទី៣ និងទី៤នៃការប្រតិបត្តិដំណើរការរបស់រមណីយដ្ឋានលំហែកាយកោះក្របី។ តាមកិច្ចព្រមព្រៀងជួលដីសម្បទានរយៈពេល៩៩ឆ្នាំរបស់រដ្ឋាភិបាលឱ្យទៅក្រុមហ៊ុនវិនិយោគលើគម្រោងនេះ យើងពិនិត្យឃើញថារយៈពេលនៃការទទួលបានផលចំណេញមកវិញពីគម្រោងគឺពិតជាសមល្មមសម្រាប់ការវិនិយោគនេះ ដោយហេតុថា ក្រុមហ៊ុនអាចមានឱកាសវែងឆ្ងាយក្នុងការទាញយកផលចំណេញពីវិស័យទេសចរណ៍ក្នុងតំបន់នោះ។ លើសពីនេះ ទៀតភាគីរដ្ឋាភិបាលអាចនឹងទទួលបានចំណូលច្រើនគួរសម ដែលចំណូលទាំងនោះគឺបានពីការប្រមូលពន្ធអាករនានាពីគម្រោងវិនិយោគនេះ។

### ៩.២.៤ ការវិភាគកម្រិតហានិភ័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់គម្រោងវិនិយោគ

ជាទូទៅ ការវិភាគស្ថានភាពសេដ្ឋកិច្ច ឬហិរញ្ញវត្ថុរបស់ក្រុមហ៊ុនណាមួយ ចំណាយ និងចំណូលរបស់គម្រោងនោះ គឺត្រូវបានធ្វើការវិភាគដោយការប៉ាន់ស្មាន។ ដូចនេះ ដើម្បីធានាឱ្យបានថាគម្រោងវិនិយោគនោះ ពុំមាន ឬមានហានិភ័យផ្នែកហិរញ្ញវត្ថុតិចតួច អ្នកសេដ្ឋកិច្ចអាចប្រើប្រាស់វិធីសាស្ត្រមួយចំនួន ដើម្បីធ្វើការវិភាគ គឺប្រើវិធីសាស្ត្រវិភាគកម្រិតហានិភ័យ ដោយផ្អែកលើការប្រើប្រាស់សេណារីយ៉ូចំនួនបី។ សេណារីយ៉ូទីមួយគឺជាករណីអាក្រក់បំផុត (Worse-case) សេណារីយ៉ូទីពីរគឺជាករណីធម្មតា(Base-case) និងសេណារីយ៉ូទីបីគឺជាករណីដែលល្អបំផុត (Best-case)។តារាង៨.១ បង្ហាញពីការបកស្រាយលើករណីនៃសេណារីយ៉ូទាំងបី ដែលត្រូវបានកំណត់ដោយការសិក្សានេះ។

តារាង៩.១៖ ការពន្យល់ពីសេណារីយ៉ូដោយបកស្រាយករណីនីមួយៗ

| សេណារីយ៉ូ | បំណកស្រាយ/ការពន្យល់ |
|---|---|
| ករណីអាក្រក់បំផុត (Worse-case) | • ការជួលបន្ទប់សណ្ឋាគារលំដាប់ផ្កាយប្រាំក្នុងមួយខែបានចំនួន៣៥០បន្ទប់<br>• តម្លៃឈ្នួលបន្ទប់សណ្ឋាគារលំដាប់ផ្កាយប្រាំស្មើនឹង ៤០០ដុល្លា និងម៉ូតែល៥០០ដុល្លាក្នុងមួយយប់<br>• កំណត់យកការគណនា២០ថ្ងៃក្នុងមួយខែ |
| ករណីធម្មតា (Base-case) | • ការជួលបន្ទប់សណ្ឋាគារលំដាប់ផ្កាយប្រាំក្នុងមួយខែបានចំនួន៥០០បន្ទប់<br>• តម្លៃឈ្នួលបន្ទប់សណ្ឋាគារលំដាប់ផ្កាយប្រាំស្មើនឹង ៤០០ដុល្លា និងម៉ូតែល៥០០ដុល្លាក្នុងមួយយប់<br>• កំណត់យកការគណនា២០ថ្ងៃក្នុងមួយខែ |
| ករណីល្អបំផុត (Best-case) | • ការជួលបន្ទប់សណ្ឋាគារលំដាប់ផ្កាយប្រាំក្នុងមួយខែបានចំនួន៨០០បន្ទប់<br>• តម្លៃឈ្នួលបន្ទប់សណ្ឋាគារលំដាប់ផ្កាយប្រាំស្មើនឹង ៤០០ដុល្លា និងម៉ូតែល៥០០ដុល្លាក្នុងមួយយប់<br>• កំណត់យកការគណនា២០ថ្ងៃក្នុងមួយខែ |

លទ្ធផលនៃការបកស្រាយលើករណីនៃសេណារីយ៉ូនិមួយៗ បានបង្ហាញថា គម្រោងវិនិយោគរមណីយដ្ឋានលំហែកាយកោះក្របី នៅតែបន្តរក្សាការទទួលបានផលចំណេញដដែល

បើទោះបីជាក្នុងករណីសេណារីយ៉ូទីមួយ (ករណីអាក្រក់បំផុត) ទទួលបានផលចំណេញតិចតួចក៏ដោយ។ នេះ អាចបញ្ជាក់បានថា ការវិនិយោគគម្រោងលំហែកាយកោះក្របីអាចមានសក្តានុពលទទួលបានផលចំណេញពីការវិនិយោគលើវិស័យទេសចរណ៍ បើទោះជាក្នុងករណីនៃរដូវដែលពុំសូវមានភ្ញៀវទេសចរណ៍ក៏ដោយ ក៏ការវិនិយោគនេះ នៅតែទទួលបានផលចំណេញតិចតួច។ ផ្ទុយទៅវិញ ក្នុងករណីនៅរដូវសម្បូរភ្ញៀវទេសចរណ៍វិញ ការវិនិយោគនេះ នឹងអាចទទួលបានផលចំណេញកាន់តែច្រើន។ ដូចនេះ រដ្ឋាភិបាលអាចមានទំនុកចិត្តខ្ពស់ក្នុងការផ្តល់ដីសម្បទានឱ្យទៅក្រុមហ៊ុនអភីប៊ី សម្រាប់ធ្វើការវិនិយោគលើវិស័យទេសចរណ៍បាន ដោយពុំចាំបាច់ព្រួយបារម្ភការក្ស័យធនរបស់ក្រុមហ៊ុន។




ដ្យាក្រាម៩.១៖ កម្រិតប្រែប្រួលនៃការវិភាគហានិភ័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់គម្រោងវិនិយោគ

## ៩.៣ តម្លៃ និងទំហំនៃការខូចខាតធនធានបរិស្ថាន

### ៩.៣.១ តម្លៃ និងទំហំនៃការខូចខាតធនធានព្រៃឈើ

លទ្ធផលពីការធ្វើសារពើភ័ណ្ឌព្រៃឈើ បានបង្ហាញថា ធនធានព្រៃឈើនៅលើកោះក្របីភាគច្រើនជាប្រភេទព្រៃពាក់កណ្តាលស្រោងចំនួន ៨ហិចតា និងជាតំបន់គ្មានគម្របព្រៃឈើចំនួន ០២ហិចតា។ ប្រភេទព្រៃឈើភាគច្រើនចំនួន ៥០ប្រភេទ ជាប្រភេទឈើហូបផ្លែ ឈើឱសថ និងឈើសម្រាប់កែច្នៃធ្វើជាសម្ភារៈប្រើប្រាស់ដូចជាតុ ទូជាដើម។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាពទី៩.៣៖ ប្រភេទកូនឈើនៅក្នុងតំបន់គម្រោង



រូបភាពទី៩.៤៖ ប្រភេទដើមឈើនៅក្នុងតំបន់គម្រោង

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

យោងតាមការសិក្សារបស់ Troy និង Mathew ឆ្នាំ២០០៦ ប្រភេទឈើទាំងនេះ អាចមានតម្លៃជាមធ្យមប្រមាណ ១.៨២៦ ដុល្លារសហរដ្ឋអាមេរិចក្នុងមួយហិចតាក្នុងមួយឆ្នាំ។ ដោយមើលឃើញថា លក្ខណៈភូមិសាស្ត្រ និងធនធាននៅតំបន់សិក្សា (Study Site) របស់ Troy et al. (2006) មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងលក្ខណៈភូមិសាស្ត្រ និងធនធាននៅតំបន់កោះក្របី (Policy Site) តម្លៃធនធានព្រៃឈើដែលមាននៅលើកោះក្របី អាចត្រូវបានគណនាតាមរយៈវិធីសាស្ត្រ បន្ទេរតម្លៃផលចំណេញ(Benefit Transfer)។ តាមរយៈវិធីសាស្ត្រនេះ ធនធានព្រៃឈើនៅលើកោះក្របីអាចមានតម្លៃប្រហែល ១៨.២៦០ ដុល្លារសហរដ្ឋអាមេរិច/ឆ្នាំ។

តម្លៃធនធានព្រៃឈើនៅលើកោះក្របី = ១.៨២៦ដុល្លាក្នុងមួយឆ្នាំ × ៨ហិចតា

តម្លៃធនធានព្រៃឈើនៅលើកោះក្របី = ១៤.៦០៨ដុល្លាក្នុងមួយឆ្នាំ

យើងកត់សម្គាល់ឃើញផងដែរថា តម្លៃធនធានព្រៃឈើដែលសិក្សាដោយក្រុមសិក្សាស្រាវជ្រាវផ្នែកវិភាគសេដ្ឋកិច្ច និងតម្លៃធនធានធម្មជាតិ មានតម្លៃខ្ពស់ជាងការសិក្សារបស់ក្រុមសិក្សាស្រាវជ្រាវផ្នែកធនធានជីវសាស្ត្រប្រមាណ៣ដង។ ភាពខុសគ្នានេះ គឺដោយសារក្រុមសិក្សាស្រាវជ្រាវផ្នែកធនធានជីវសាស្ត្រ បានគណនាតែលើតម្លៃឈើ និងអុសដែលជាតម្លៃប្រើប្រាស់ដោយផ្ទាល់ (direct use value) ដែលបានផ្តល់ដោយសេវាកម្មព្រៃឈើតាមរយៈវិធីសាស្ត្រ តម្លៃទីផ្សារ (Market Price Method)។ ប៉ុន្តែ ក្រុមសិក្សាស្រាវជ្រាវផ្នែកធនធានជីវសាស្ត្រ មិនបានរួមបញ្ចូលតម្លៃមិនបានប្រើប្រាស់ដោយផ្ទាល់ (non-direct use value) ដែលបានផ្តល់ដោយសេវាកម្មព្រៃឈើនោះទេ។ ហេតុនេះ តម្លៃធនធានព្រៃឈើនៅកោះក្របី ដែលសិក្សាដោយក្រុមសិក្សាស្រាវជ្រាវផ្នែកវិភាគសេដ្ឋកិច្ច និងតម្លៃធនធានធម្មជាតិ មានតម្លៃខ្ពស់ជាង បើប្រៀបធៀបទៅនឹងការសិក្សារបស់ក្រុមសិក្សាស្រាវជ្រាវផ្នែកជីវសាស្ត្រ។

ចំពោះទំហំនៃការខូចខាតធនធានព្រៃឈើវិញ យោងតាមការសម្ភាសន៍ ជាមួយអនុប្រធានទទួលបន្ទុកសាងសង់លើកោះក្របីរបស់**ក្រុមហ៊ុន អតីប៊ីអ៊ិនវេសមិនខូអិលធីឌី** បានឲ្យដឹងថា ដំណើរការសកម្មភាពសាងសង់ផ្ទះលំហែរកាយធម្មជាតិ និងឈូសឆាយផ្លូវតភ្ជាប់ពីតំបន់មួយទៅតំបន់មួយទៀតនៅលើកោះ មិនបានធ្វើឱ្យប៉ះពាល់ដល់ធនធានព្រៃឈើដែលមានស្រាប់នោះទេ។ ក្នុងដំណាក់កាលសាងសង់ និងឈូសឆាយផ្លូវ គោលការណ៍របស់ក្រុមហ៊ុន បានតម្រូវឱ្យបុគ្គលិកសាងសង់ធ្វើផ្លូវកោងបញ្ចៀសការកាប់ដើមឈើ ឬ/និងគាស់ដើមនោះទៅដាំនៅតំបន់ដីទំនេរដទៃទៀត។ ទោះបីជាយ៉ាងនេះក្តី តាមរយៈការចុះអង្កេតជាក់ស្តែងនៅតំបន់សិក្សា ក្រុមសិក្សាបានអង្កេតឃើញថា ព្រៃឈើមួយចំនួនត្រូវបានទទួលរងផលប៉ះពាល់ដោយសារសកម្មភាពគម្រោងក្នុងកម្រិតអប្បបរមា។



រូបភាពទី៩.៥៖ ការរំកិលបង្គោលរបងដើម្បីកាប់ដើមឈើ



រូបភាពទី៩.៦៖ កូនឈើដែលត្រូវដាំនៅតំបន់ដីទំនេរ

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តាមរយៈអនុប្រធានទទួលបន្ទុកសាងសង់ដែលបានបញ្ជាក់ឱ្យដឹងថា ក្រុមហ៊ុនបានដាក់ពិន័យជាទឹកប្រាក់ប្រមាណ ពី ៨០,០០០រៀល ទៅ ២០០,០០០ រៀលប្រសិនបើបុគ្គលិកណាម្នាក់កាប់ដើមឈើដែលមានស្រាប់នៅលើកោះក្របី។ ការកំណត់ដូច្នេះរបស់ក្រុមហ៊ុន គឺក្នុងគោលបំណងទីមួយរួមចំណែករក្សាទុកគម្របព្រៃឈើនៅលើកោះក្របីឱ្យមានសភាពដដែល និងទីពីរគឺដើម្បីរក្សានូវសម្រស់ព្រៃឈើធម្មជាតិដើម្បីទាក់ទាញភ្ញៀវទេសចរណ៍មកទស្សនាកំសាន្ត។ លើសពីនេះ ក្រុមហ៊ុន បានទិញកូនឈើបន្ថែមពីក្រុងព្រះសីហនុ ដើម្បីដាំនៅតំបន់ដីទំនេរទៀតផង ដើម្បីបង្កើនគម្របព្រៃឈើ និងភាពទាក់ទាញដល់ភ្ញៀវទេសចរណ៍។

### ៩.៣.២ តម្លៃ និងទំហំនៃការខូចខាតធនធានសត្វព្រៃ

តាមរយៈការសិក្សារបស់ក្រុមសិក្សាស្រាវជ្រាវឆ្នាំ ២០១៣ បានបង្ហាញថា ធនធានសត្វព្រៃដែលមាននៅលើកោះក្របី មិនមានប្រភេទសត្វកម្រនោះទេ គឺមានតែពពួកសត្វថនិកសត្វ ល្មូន និងសត្វស្លាបក្នុងស្រុកមួយចំនួនតូចតែប៉ុណ្ណោះ។ ប្រភេទថនិកសត្វមាន ០៦ ប្រភេទរួមមាន ស្វាក្ដាម កណ្ដុរ កំប្រុក ប្រម៉ា ជ្រើង និងប្រចៀវ។ ប្រភេទល្មូន មាន ០៩ ប្រភេទដូចជាត្រកួត ពស់ព្រៃ ពស់វែកក្របី ពស់វែករនាម ពស់វែកដំបូក តុកកែ អន្សង ពស់ខ្សែគេ បង្កួយព្រៃត្រចៀកតូច។ ប្រភេទសត្វស្លាបមាន ០៦ ប្រភេទរួមមាន ស្វាំង ចាបពួក គេងកងតូច ត្រចៀកកាំ ពពិចខ្មៅ និងព្រាំង។ ពួកសត្វទាំងនេះ ត្រូវបានអភិរក្សដោយក្រុមហ៊ុន ដើម្បីជាផ្នែកមួយក្នុងការទាកទាញភ្ញៀវទេសចរណ៍។ ដូចនេះ ទំហំនៃការខូចខាតនៃធនធានសត្វព្រៃ គឺមិនមាននោះទេ ហើយក៏មិនត្រូវបានរួមបញ្ចូលក្នុងការវិភាគសេដ្ឋកិច្ចផងដែរ។

### ៩.៣.៣ តម្លៃ និងទំហំនៃការខូចខាតធនធានជលផល

គម្រោងវិនិយោគលើរមណីយដ្ឋានលំហែកាយកោះក្របីត្រូវបានដំឡើងប្រព័ន្ធប្រព្រឹត្តិកម្មទឹកស្អាត និងប្រព្រឹត្តិកម្មទឹកសំអុយមុននឹងចាក់បង្ហូរចោលទៅក្នុងសមុទ្រ ដោយពុំមានកត្តាបង្កណាមួយធ្ងន់ធ្ងរ ដែលអាចប៉ះពាល់ដល់ធនធានជលផលក្នុងសមុទ្រឡើយ។ ដូចនេះ នៅក្នុងផ្នែកសិក្សាអំពីតម្លៃ និងទំហំនៃការខូចខាតធនធានជលផល មិនត្រូវបានសិក្សាលម្អិតឡើយ។

### ៩.៣.៤តម្លៃ និងទំហំនៃការខូចខាតលើមុខរបរ និងប្រាក់ចំណូលប្រជាជន

វត្តមាននៃគម្រោងវិនិយោគរមណីយដ្ឋានលំហែកាយ ដោយកែប្រែតំបន់កោះក្របី (កោះចន្ទុះ) ឱ្យក្លាយជារមណីយដ្ឋានលើកោះធម្មជាតិ មិនបានបង្កជាកត្តារារាំង ឬជាឧបសគ្គដល់មុខរបរ និងការបាត់បង់ប្រាក់ចំណូលរបស់ប្រជាជនឡើយ ដោយសារតែនៅលើកោះនោះពុំមានវត្តមានភូមិរបស់ប្រជាជនរស់នៅ ហើយក៏ពុំមានវត្តមានប្រជាជននេសាទនៅតំបន់នោះដែរ។ ម្យ៉ាងវិញ

ទៀត ការវិនិយោគនេះ ពុំបានធ្វើឱ្យមានការថយចុះនូវធនធានជលផលក្នុងសមុទ្រ ដែលអាចបណ្តាលឱ្យប៉ះពាល់ដល់របរ និងផលនេសាទរបស់ប្រជានេសាទទេ។ តែផ្ទុយទៅវិញ ការវិនិយោគនេះអាចពាំនាំនូវមុខរបរបន្ថែមទៀតជូនដល់ប្រជាជន ដែលមានទីតាំងក្បែរតំបន់កោះនោះទៅវិញទេ។ ប្រាកដណាស់ ប្រជាជនអាចនឹងបង្កើនប្រាក់ចំណូលរបស់ពួកគាត់តាមរយៈការផលិត និងលក់វត្ថុអនុស្សាវរីយ៍ដែលធ្វើអំពីសម្ភារៈសត្វសមុទ្រ និងសម្ភារៈផ្សេងទៀត សម្រាប់លក់ជូនភ្ញៀវទេសចរណ៍ ដែលទៅកម្សាន្តនៅទីនោះ។

## ៩.៤ សេចក្តីសន្និដ្ឋាន

សរុបមកឡើងវិញ ការវិនិយោគលើគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី (កោះចន្លុះ) ពិតជាការអភិវឌ្ឍមួយ ដែលអាចចូលរួមចំណែកដល់ការរីកចម្រើនលើវិស័យទេសចរណ៍ទាំងនៅក្នុងតំបន់ដីសម្បទាន ទាំងនៅក្នុងប្រទេសកម្ពុជាទាំងមូល។ ការអភិវឌ្ឍនេះក៏ជាផ្នែកមួយដែលបានចូលរួមជួយអភិវឌ្ឍន៍សង្គម ដោយបានផ្តល់នូវឱកាសការងារជូនដល់ប្រជាជនដែលរស់ក្បែរ ឬក្រៅតំបន់នោះផងដែរ តាមរយៈការផ្តល់ការងារជាកម្មករសំណង់ក្នុងដំណាក់កាលសាងសង ផ្តល់ការងារជាបុគ្គលិកបម្រើក្នុងរមណីយដ្ឋានក្នុងដំណាក់កាលប្រតិបត្តិគម្រោង និងថែមទាំងផ្តល់ឱកាសការងារផ្សេងទៀតដូចជាការលក់ដូរវត្ថុអនុស្សាវរីយ៍។ ការផ្តល់នូវឱកាសការងារនេះ ហាក់បីដូចជាជួយដល់ស្ថានភាពសេដ្ឋកិច្ចសង្គមក្នុងតំបន់នោះឱ្យមានដំណើរការនៃចរន្តសាច់ប្រាក់ក្នុងតំបន់នោះថែមទៀតផង។

ក្រៅពីការចូលរួមអភិវឌ្ឍន៍សង្គម គម្រោងវិនិយោគនេះក៏បានរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិតាមរយៈការបង់ពន្ធអាករចូលរដ្ឋថែមទៀតផង។ តាមរយៈការអភិវឌ្ឍគម្រោងនេះ រដ្ឋាភិបាលអាចនឹងទទួលបានប្រាក់ចំណូលក្នុងរូបភាពជាការបង់ពន្ធអាករ ប្រមាណ**៨២.៨០០ដុល្លារសហរដ្ឋអាមេរិក** ក្នុងមួយឆ្នាំ ដែលស្មើនឹង៣%នៃប្រាក់ចំណូលដុលរបស់ក្រុមហ៊ុន។ ក្រៅពីការបង់ពន្ធពីការកាត់ពន្ធប្រាក់ចំណូលដុលរបស់ក្រុមហ៊ុន រដ្ឋាភិបាលក៏នឹងអាចទទួលបានចំណូលផ្សេងទៀតដូចជាការកាត់ពន្ធប្រាក់បៀវត្សន៍របស់បុគ្គលិកក្រុមហ៊ុន។

លើសពីនេះ គម្រោងអភិវឌ្ឍន៍គឺជាប្រភេទអភិវឌ្ឍលើវិស័យទេសចរណ៍ ដោយផ្តោតលើការសាងសង់ និងប្រតិបត្តិលើរមណីយដ្ឋានលំហែកាយលើកោះ។ ហេតុនេះ ការអភិវឌ្ឍនេះពុំមានសកម្មភាពណាមួយដែលគំរាមកំហែងដល់ធនធានបរិស្ថាននៅក្នុងតំបន់នោះទេ។ តែផ្ទុយទៅវិញ គម្រោងនេះ នឹងមានផែនការដាំដើមឈើលម្អបន្ថែមទៀតដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ឱ្យចូលទស្សនា និងសម្រាក់កម្សាន្តនៅទីនោះ។

ក្រលែកមកមើលពីផលចំណេញរបស់ក្រុមហ៊ុនវិញ យើងអាចសន្និដ្ឋានបានថាការវិនិយោគនេះ ក៏អាចផ្តល់នូវផលចំណេញច្រើនគួរសមដល់អ្នកវិនិយោគ ហើយដោយផ្អែកលើវិធីសាស្ត្រ

វិភាគហានិភ័យនៃស្ថានភាពហិរញ្ញវត្ថុនៃគម្រោងអភិវឌ្ឍនេះ យើងបានរកឃើញថាពុំមានហានិភ័យណាមួយនឹងអាចកើតឡើងចំពោះគម្រោងនេះក្នុងកំឡុងពេលប្រតិបត្តិដំណើរការជាផ្លូវការឡើយ។ ជាក់ស្តែងតាមលទ្ធផលវិភាគស្ថានភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចរបស់គម្រោងបានបង្ហាញថាជាមធ្យមការវិនិយោគនេះនឹងអាចទទួលបានផលចំណេញសុទ្ធ (net benefit) ប្រមាណជាង**២,៥លានដុល្លា**ក្នុងមួយឆ្នាំ។ បន្ថែមពីនេះទៀត តាមការវិភាគការប្រៀបធៀបសន្ទស្សន៍ផលចំណេញខាត (Benefit-cost ratio) នៅករណីធម្មតា (base-case scenario) បានបង្ហាញថាស្មើនឹង១,៥ ដែលជាតួលេខធំជាង១ នោះមានន័យថាការវិនិយោគនេះគឺទទួលបានផលចំណេញច្រើន។ ដូចនេះការវិនិយោគនេះគួរតែមានការគាំទ្រពីភាគីរដ្ឋាភិបាលដើម្បីអនុញ្ញាតឱ្យការប្រតិបត្តិគម្រោងនេះដំណើរការទៅបានដោយរលូន ដែលវាជាការអភិវឌ្ឍលើវិស័យទេសចរណ៍ ក៏ដូចជាជួយដល់សង្គម និងសេដ្ឋកិច្ចជាតិផងដែរ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី១០៖
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

#322P, St.271Z, Sk.Tark Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូកទី១០៖ សន្និដ្ឋាន និងអនុសាសន៍

## ១០.១ សេចក្តីសន្និដ្ឋាន

គម្រោងអភិវឌ្ឍន៍ **រមណីយដ្ឋានកោះក្របី** របស់ក្រុមហ៊ុន RPB Investment Co., LTD ដែលមានទីតាំង ស្ថិតនៅលើតំបន់កោះក្របី ក្នុងឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ត្រូវបាន រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានសំរេចជាចុងក្រោយដោយចេញអនុក្រឹត្យលេខ ១៦១ អនក្រ.បក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការធ្វើអនុបយោគប្តូរចំណាត់ថ្នាក់ពីទ្រព្យ សម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋក្នុងតំបន់កោះក្របី ដោយជួលដី នេះទៅឲ្យក្រុមហ៊ុន តាមកិច្ចសន្យារវាងរាជរដ្ឋាភិបាល និងក្រុមហ៊ុនចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០០៨។ គម្រោងនេះគឺឆ្លើយតបនឹងផែនការអភិវឌ្ឍន៍ទេសចរណ៍ដែលជាមាសបៃតង ដែល កំពុងមានកំណើនអ្នកទេសចរជារៀងរាល់ឆ្នាំ និងដើម្បីកែប្រែមុខមាត់ខេត្តព្រះសីហនុ ឲ្យក្លាយ ទៅជាទីក្រុងស្អាត បរិស្ថានបៃតង និងសាកសមជាតំបន់អេកូទេសចរណ៍ដ៏ប្រណិត។

តាមលទ្ធផលនៃការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញបាន បង្ហាញឲ្យឃើញថា ទីតាំងគម្រោងស្ថិតនៅក្នុងតំបន់កោះក្របីដែលមានវត្តមានធនធានព្រៃឈើ និងសត្វព្រៃ និងអេកូឡូស៊ីក្នុងទឹក ប៉ុន្តែពុំមានវត្តមានរបស់ប្រជាពលរដ្ឋរស់នៅតំបន់នេះទេ។

លើសពីនេះទៀត សកម្មភាពឈូសឆាយដី ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការសាង សង់អគារផ្ទះលំហែកាយ គម្រោងនេះនឹងមានហេតុប៉ះពាល់អវិជ្ជមានមួយចំនួនទៀតដូចជា ការ បំពុលទឹក ការបំពុលខ្យល់ ការរំខានដោយសំលេងនិងរំញ័រ ធនធានព្រៃឈើ សត្វព្រៃ ជីវៈចំរុះ ក្នុងទឹក មុខរបរ និងប៉ះពាល់ដល់សុខភាពសាធារណៈ។

ទោះបីជាមានហេតុប៉ះពាល់អវិជ្ជមានយ៉ាងណាក៏ដោយ ការសិក្សាបានបង្ហាញឲ្យឃើញ ថា ការប៉ះពាល់ទាំងអស់នេះអាចគ្រប់គ្រង និងកាត់បន្ថយបានមួយចំនួនធំតាមរយៈការអនុវត្ត ឲ្យបានត្រឹមត្រូវនូវវិធានការកាត់បន្ថយនានាដូចជា៖

→ ការរក្សាទុកតំបន់បៃតងឲ្យបានច្រើន និងលំហសាធារណៈនៅក្នុងរមណីយដ្ឋាន កោះក្របី

→ ធ្វើសហការជាមួយក្រសួង/ស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានឲ្យដល់កំរិតអប្បបរមា

→ រៀបចំផែនការគ្រប់គ្រងសំណល់រឹង-រាវ ការបំពុលខ្យល់ ការរំខានដោយសំលេង និងរំញ័រ ព្រមទាំងទប់ស្កាត់ការខូចខាតផ្កាថ្មនៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគម្រោង

→ បង្កើត ប្រព័ន្ធបណ្តាញលូសម្រាប់ដោះទឹកលូសំអុយ និងទឹកភ្លៀង

→ សហការជាមួយក្រុមហ៊ុនប្រមូលសំរាមនៅខេត្តព្រះសីហនុ និងអាជ្ញាធរខេត្តដើម្បីដឹកជញ្ជូនសំរាមចោលនៅទីលានសំរាមរបស់ខេត្ត

→ រៀបចំ ដាក់អាងសិបទិក នៅតាមអគារនីមួយៗទាំងអស់ដើម្បីសំអាតសំណល់រាង និងយកទឹកចេញពីការសំអាតនៅស្រោចស្រពតាមសួនច្បារ

→ អប់រំ និងណែនាំដល់បុគ្គលិក-កម្មករឲ្យយល់ដឹងពីអនាម័យបរិស្ថាន និងសុវត្ថិភាពការងារជាចំបង។ ក្រុមហ៊ុនត្រូវយកចិត្តទុកដាក់ដល់សុខភាព និងសុខមាលភាព របស់អ្នកទេសចរណ៍ បុគ្គលិក និងកម្មករដែលទទួលរងការប៉ះពាល់ដោយសារសកម្មភាពរបស់គម្រោង។

ជាមួយគ្នានេះដែរ ក្រុមហ៊ុនបានរៀបចំផែនការគ្រប់គ្រងបរិស្ថាន ដើម្បីកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានពីសកម្មភាពគម្រោង និងបែងចែកភារៈកិច្ចអ្នកទទួលខុសត្រូវ ព្រមទាំងពេលវេលា ភាពញឹកញាប់នៃការអនុវត្តផែនការនេះក្នុងដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិគម្រោង និងបញ្ចប់គម្រោង។

ទន្ទឹមនឹងនេះដែរ តំបន់គម្រោងនេះនឹងក្លាយទៅជាបណ្តុំនៃតំបន់អេកូទេសចរណ៍ តំបន់អភិវឌ្ឍន៍សេដ្ឋកិច្ច និងនាំមកនូវផលប្រយោជន៍ជាច្រើនដូចជា៖

១-ជួយកាត់បន្ថយនូវរាល់សកម្មភាពប្រព្រឹត្តបទល្មើសព្រៃឈើ សត្វព្រៃនានា និងការនេសាទខុសច្បាប់នៅក្នុងតំបន់កោះក្របីដោយក្រុមហ៊ុនបានធ្វើការគ្រប់គ្រងយ៉ាងម៉ឹងម៉ាត់

២-បង្កើនមុខរបរ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋក្នុងតំបន់ ពិសេសប្រជាពលរដ្ឋរស់នៅក្នុងខេត្តព្រះសីហនុ តាមរយៈការជ្រើសរើសឲ្យចូលបំរើការងារនៅក្នុងគម្រោង

៣-ជួយបង្កើនប្រាក់ចំណូលជាតិ តាមរយៈការបង់ពន្ធផ្សេងៗដល់រដ្ឋាភិបាល នៅក្នុងកំឡុងពេលដាក់ឲ្យដំណើរការគម្រោង ដែលជាការរួមចំណែកមួយជួយទ្រទ្រង់ដល់សេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា

៤-គម្រោងនេះនឹងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិតាមរយៈការទាក់ទាញអ្នកវិនិយោគ និងភ្ញៀវទេសចរណ៍

៥-គម្រោងនេះនឹងបង្កើនសោភ័ណ្ឌភាពស្រស់ស្អាតដល់ខេត្តព្រះសីហនុ និងលើកស្ទួយការរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយផាសុខភាព

៦-គម្រោងនេះនឹងជួយដល់ការសម្រេចនូវគោលនយោបាយចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយនិរន្តរភាពជាក់ជាពុំខាន។

## ១០.២ អនុសាសន៍

អនុសាសន៍មួយចំនួន ដែលក្រុមហ៊ុនវិនិយោគត្រូវអនុវត្តនៅក្នុងដំណាក់កាលមុនសាងសង់ ដំណាក់កាលសាងសង់ ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោង ដូចមានរៀបរាប់ដូចខាងក្រោម៖

1. រាល់លក្ខខណ្ឌក្នុងការរៀបចំគម្រោង និងការសាងសង់ត្រូវគោរពតាមគោលការណ៍ ណែនាំ និងបទដ្ឋានបច្ចេកទេសសំណង់របស់ប្រទេសកម្ពុជា ឬអន្តរជាតិ។
2. ត្រូវមានការសហការល្អជាមួយគ្រប់ក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធនានានៅក្នុងគ្រប់ដំណាក់កាលសាងសង់ និងការដាក់ឲ្យដំណើរការដូចជា ការជូនដំណឹង ការផ្សព្វផ្សាយស្តីពីកម្មវិធីសាងសង់ សុវត្ថិភាព ការពារគ្រោះថ្នាក់ទៅដល់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។
3. ម្ចាស់គម្រោង ក្រុមហ៊ុនទីប្រឹក្សាសាងសង់ អ្នករៀបចំគម្រោងប្លង់ និងអ្នកម៉ៅការត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមវិធានការកាត់បន្ថយហេតុប៉ះពាល់ និងកម្មវិធីត្រួតពិនិត្យដូចដែលបានកំណត់ក្នុងផែនការគ្រប់គ្រងបរិស្ថាន កិច្ចសន្យាការពារបរិស្ថាន កិច្ចសន្យាសាងសង់ និងឯកសារបច្ចេកទេសផ្សេងៗទៀតដែលទាក់ទងនឹងគម្រោងវិនិយោគទាំងមូល។

ជាចុងបញ្ចប់ ក្រុមហ៊ុន RPB Investment Co., LTD. ដែលជាក្រុមហ៊ុនវិនិយោគអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី មានឱកាសក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជាឲ្យមានការរីកចំរើនយ៉ាងឆាប់រហ័ស។

ដូចនេះ ក្រុមហ៊ុនសូមសំណូមពរដល់ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធនានា មេត្តាអនុញ្ញាតជួយជ្រោមជ្រែង និងបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុន RPB Investment Co., LTD. ដើម្បីអនុវត្តគម្រោងសាងសង់រមណីយដ្ឋានកោះក្របីនេះឲ្យបានសមស្របនឹង ច្បាប់ស្តីពីវិនិយោគ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

| | |
|---|---|
| បានឃើញ និងឯកភាពលើរបាយការណ៍ | ក្រុមហ៊ុនរៀបចំរបាយការណ៍ |
| វាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមពេញលេញ | វាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមពេញលេញ |
| ថ្ងៃទី...12...ខែ...11...ឆ្នាំ២០១៩ | ថ្ងៃទី...12...ខែ...11...ឆ្នាំ២០១៩ |
| **ក្រុមហ៊ុន អភីប៊ី អ៊ិនវេសមេន** | **ក្រុមហ៊ុន គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ** |
| **នាយកក្រុមហ៊ុន** | **នាយកក្រុមហ៊ុន** |
| RPB INVESTMENT CO., LTD | CREATIVE GREEN DESIGN Co., Ltd. |
| KIRILL KENZHEEV | ឡូស សារឿន |

# ឯកសារយោង


1 រដ្ឋបាលព្រៃឈើ (2004) សៀវភៅគោលការណ៍ណែនាំធ្វើសារពើភ័ណ្ឌ

2 រដ្ឋបាលព្រៃឈើ (2010) វគ្គបណ្តុះបណ្តាលស្តីពីពិធីការបច្ចេកទេសសារពើភ័ណ្ឌប៉ាន់ ស្មានធនធានព្រៃឈើ នៅក្នុងសម្បទានដីសេដ្ឋកិច្ច។

3 ក្រសួងធនធានទឹក និងឧតុនិយម (2008) ទិន្នន័យសីតុណ្ហភាពខេត្តរតនគិរី

4 រដ្ឋបាលព្រៃឈើ (2004) សៀវភៅណែនាំស្តីពីការធ្វើផែនការគ្រប់គ្រងព្រៃឈើ
ប្រកាសលេខ ៨៩ ប្រក.កសក ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០០៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្តីពីផល អនុផលព្រៃឈើដែលត្រូវហាមឃាត់ការប្រមូលផល

5 ប្រកាសលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពី ការកំណត់ថ្លៃសួយសារ ឈើ ឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ។

6 អនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រភេទផល ផលិតផល ជលផលដែលកំពុងរងគ្រោះថ្នាក់។

7 អាស៊ានវែន ឆ្នាំ ២០១២, អត្តសញ្ញាកម្មសត្វព្រៃដែលគេជួញដូរក្នុងតំបន់អាស៊ីអាគ្នេយ៍

8 *DoF, (2005). NATIONAL REPORT ON STATUS OF CORAL REEF AND SEAGRASS iN CAMBODIA.*

9 FiA, (2011). Marine Fish Species Identification Book. The book produced by the Fisheries Administration to identify maine fish speries in Cambodia

10 FiA, (2007). Law on Fisheries. Royal decree N° 0506/011 promulgated by the King of the Kingdom of Cambodia on 21 May 2006.

11 Nelson, V. (1999). *State of Coral Reefs Cambodia.* Environment Coastal Zone Project, MoE/Danida, Phnom Penh, Cambodia.

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី០១

១.១-លិខិតលេខ ២៩៨៣/០៧ គ.វ.ក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា "គណៈកម្មាធិការវិនិយោគកម្ពុជា" ស្តីអំពីការសម្រេចចេញវិញ្ញាបនប័ត្រចុះបញ្ជីរជាស្ថាពរ នូវគម្រោងអភិវឌ្ឍន៍កោះក្រចី (កោះច្រឡុះ) ខេត្តព្រះសីហនុ

១.២-លិខិតលេខ ១៦១ អនក្រ.បក ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ២០០៧ អនុក្រឹត្យស្តីអំពី ការធ្វើអនុប្រយោគទីតាំង កោះស្រមោច កោះប្រើស កោះក្រចី និងកោះត្រេះ

១.៣- លិខិតលេខ ២៩៨៣/០៧គ.វ.ក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អំពីការផ្តល់ដំណឹងជូន ក្រសួង/ស្ថាប័នពាក់ព័ន្ធ ឲ្យបានជ្រាបថា: ក្រុមហ៊ុន R P B Investment Co.,Ltd បានបង់ថ្លៃចុះបញ្ជីរគម្រោងវិនិយោគ លើគម្រោងអភិវឌ្ឍន៍កោះក្រចី (ហៅកោះចន្លុះ) ក្រុងព្រះសីហនុៗ

១.៤- ប័ណ្ណសម្គាល់សិទ្ធកាន់កាប់អចលនវត្ថុ ជួលរយៈពេលវែង ឲ្យក្រុមហ៊ុនអភីប៊ី អ៊ិនវេស - មេនខូអិលធីឌី

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation - Religion - King*

រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia
គណៈកម្មាធិការវិនិយោគកម្ពុជា
Cambodian Investment Board
លេខ [illegible]/០៧ គ.វ.ក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០០៧

# សេចក្តីជូនដំណឹង

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការវិនិយោគកម្ពុជា សូមជូនដំណឹងដល់ក្រសួង/ស្ថាប័នពាក់ព័ន្ធ អោយបានជ្រាបថា ៖ ក្រុមហ៊ុន R P B INVESTMENT CO., LTD. បានបង់ថ្លៃចុះបញ្ជីគំរោងវិនិយោគលើគំរោង *អភិវឌ្ឍន៍កោះក្របី (ហៅកោះចន្ទុះ) ក្រុងព្រះសីហនុ* ចំនួន *៧,០០០,០០០ (ប្រាំពីរលាន) រៀល* នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា តាមបង្កាន់ដៃទទួលប្រាក់លេខ *០០០២៤៨ គ.វ.ក* ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៦ (ដូចមានថតចំលងជូនភ្ជាប់) ដែលជាថ្លៃសេវារដ្ឋបាល "ដើម្បីទទួលបាននូវរាល់ការយល់ព្រម-ការអនុញ្ញាត-អាជ្ញាប័ណ្ណ ឬបញ្ជិកានានា ពីគ្រប់ក្រសួង/ស្ថាប័ន/មន្ទីរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ រួមទាំងពន្ធប្រថាប់ត្រាផងដែរ ស្របតាមមាត្រា៥.១ នៃអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តនីច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជារួចហើយ ។

គំរោងវិនិយោគនេះ ពុំស្ថិតក្នុងបញ្ជីអវិជ្ជមាននៃអនុក្រឹត្យលេខ១១១ អនក្រ បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ទេ ហើយអង្គប្រជុំ"ច្រកចេញ-ចូលតែមួយ" នៃ ក.អ.ក"គ.វ.ក" នាថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៧ និងចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី ប្រធាន"ក.អ.ក" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧ ក៏បានសំរេចឯកភាពជាគោលការណ៍អោយវិនិយោគរួចហើយដែរ ។

អនុលោមទៅតាមច្បាប់ និងអនុក្រឹត្យស្តីពីវិនិយោគ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ការយល់ព្រម-ការអនុញ្ញាត-អាជ្ញាប័ណ្ណ-លិខិតអនុញ្ញាត ឬបញ្ជិកានានា ក្នុងរយៈពេលមិនលើសពី២៨ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ដោយរាល់ការចំណាយត្រូវប្រើប្រាស់កញ្ចប់ថវិកា ដែលសាមីក្រុមហ៊ុនបានបង់ខាងលើនេះ ។

អាស្រ័យហេតុនេះ សូមក្រសួង/ស្ថាប័ន/មន្ទីរពាក់ព័ន្ធទាំងអស់ មេត្តាចាត់ចែងចេញលិខិតយល់ព្រម-ការអនុញ្ញាត-អាជ្ញាប័ណ្ណ-លិខិតអនុញ្ញាត ឬបញ្ជិកាសំខាន់នានា ដែលជាតំរូវការស្របច្បាប់ សំរាប់ដំណើរការគំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ របស់ក្រុមហ៊ុន R P B INVESTMENT CO., LTD. ទៅតាមសមត្ថកិច្ចរៀងៗខ្លួន អោយបានទាន់ពេលកំណត់ តាមការគួរ ។

អគ្គលេខាធិការ
គណៈកម្មាធិការវិនិយោគកម្ពុជា

(signature)

ស៊ុន ចាន់ថុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគទីតាំង
## កោះស្រមោច កោះប្រឹស កោះត្របី និង កោះត្រលស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ៣៦១០/០៧ ក.អ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

មាត្រា ១.-

ត្រូវបានដាក់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីកោះ ដូចមានខាងក្រោមៈ

- កោះស្រមោចទំហំ ២៩៦.៥០០ ពីររយកៅសិបប្រាំមួយពាន់ ប្រាំរយ ម៉ែត្រក្រឡា ដើម្បីក្រុមហ៊ុន Ream Resort & Development Co.,Ltd. ធ្វើការអភិវឌ្ឍន៍ ក្រោមល័ក្ខខ័ណ្ឌជួល ។

-កោះប្រឹស ហៅកោះចន្លុះ ទំហំ ៩៦២.៨០០ "ប្រាំបួនរយហុកសិបពីរពាន់ប្រាំបីរយ" ម៉ែត្រក្រឡា ដើម្បីក្រុមហ៊ុន Angela Real Estate Co.,Ltd. ធ្វើការអភិវឌ្ឍន៍ ក្រោមល័ក្ខខ័ណ្ឌជួល ។

-កោះក្របី ហៅកោះចន្លុះ ទំហំ ១២២.៣០០ "មួយរយម្ភៃពីរពាន់ បីរយ" ម៉ែត្រក្រឡា ដើម្បីក្រុមហ៊ុន RPB Investment Co.,Ltd.ធ្វើការអភិវឌ្ឍន៍ ក្រោមល័ក្ខខ័ណ្ឌជួល ។

-កោះព្រេះ ទំហំប្រមាណ ៨៩.៧០០ "ប៉ែតសិបប្រាំបួនពាន់ ប្រាំពីររយ" ម៉ែត្រក្រឡា ដើម្បីក្រុមហ៊ុន Twin Golden Lion Co.,Ltd.ធ្វើការអភិវឌ្ឍន៍ ក្រោមល័ក្ខខ័ណ្ឌជួល ។

**មាត្រា ២.-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង សាលាខេត្តក្រុង ពាក់ព័ន្ធ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និង អភិបាលគ្រប់ខេត្តក្រុងពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ទីស្តីការគណៈ
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia
គណៈកម្មាធិការវិនិយោគកម្ពុជា
Cambodian Investment Board
លេខ ... /ក.វ.ក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៧

## លិខិតឆ្លើយតប

ជូន លោក FEDOROV VITALY សញ្ជាតិ រុស្ស៊ី

**កម្មវត្ថុ** : ការស្នើសុំវិនិយោគលើគម្រោង *អតិថិដ្ឋានកោះក្របី (ហៅកោះធន្លះ) ក្រុងព្រះសីហនុ* ។

**យោង** :
- ពាក្យស្នើវិនិយោគរបស់ក្រុមហ៊ុន នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០៧
- ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០៣ នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣
- អនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តន៍ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- ស្មារតីអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៃ ក.អ.ក "គ.វ.ក" នាថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៧ និងចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី ប្រធាន "ក.អ.ក" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧

តបតាមន័យ ដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកប្រធានជ្រាបថា : ចំពោះសំណើសុំវិនិយោគ *អតិថិដ្ឋានកោះក្របី (ហៅកោះធន្លះ)* ដែលមានអនុគំរោងមួយចំនួន ក្នុងនោះរួមមាន : *សណ្ឋាគារផ្កាយ៥ ចំនួន៣០បន្ទប់, ប៊ុងកាឡូចំនួន២០ មណ្ឌលព្យាបាលសុខភាព (Sanatorium)*,... របស់ក្រុមហ៊ុនលោកនោះ អង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៃ ក.អ.ក "គ.វ.ក" និងចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី ប្រធាន "ក.អ.ក" បានសំរេចឯកភាព តាមសំណើហើយ ។

ផ្អែកលើការសំរេចខាងលើនេះ ក.អ.ក "គ.វ.ក" បានសំរេចចេញ *វិញ្ញាបនប័ត្រចុះបញ្ជីមានល័ក្ខខ័ណ្ឌ* ជូនគំរោងអតិថិដ្ឋានខាងលើ ស្របតាមខ្លឹមសារមាត្រា៦.៣ នៃអនុក្រឹត្យយោងខាងលើ តាមខ្លឹមសារដូចខាងក្រោម :

១- *តាមលំនាំឯកសារលក្ខន្តិកៈរបស់ក្រុមហ៊ុន ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧* នៅ ក.អ.ក "គ.វ.ក" ដែលមានខ្លឹមសារសំខាន់ៗដូចខាងក្រោម :
- *នាមករណ៍ក្រុមហ៊ុន* : *អឺភីប៊ី អ៊ិនវេសមេន* ( KPB INVESTMENT CO., LTD. )
- *សមាសភាពក្រុមប្រឹក្សាភិបាល* :
  - លោក FEDOROV VITALY សញ្ជាតិ "រុស្ស៊ី" ជាប្រធានក្រុមប្រឹក្សាភិបាល
  - លោក ...RADSHENKO NIKOLAI សញ្ជាតិ "ខ្មែរ" ជាអភិបាល

២- *...* [illegible]
- *...ក្រុមប្រឹក្សាភិបាល...* : ... ។

ក្នុងរយៈពេល៩០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីដំណាក់ផ្តល់សារាចរធ្វើពន្ធទីមួយ ។

- *ក្រសួងពាណិជ្ជកម្ម* : ចុះបញ្ជីជាក្រុមហ៊ុនវិនិយោគ
- *នាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* : ចុះបញ្ជីការផ្នែកពន្ធដារ
- *ក្រសួងបរិស្ថាន* : ធ្វើកិច្ចសន្យាការពារបរិស្ថាន ឬធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ESIA ដោយអនុលោមតាមការតំរូវរបស់ក្រសួងបរិស្ថានស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។
- *ក្រសួងទេសចរណ៍* : ផ្តល់ការអនុញ្ញាតធ្វើអាជីវកម្ម សំរាប់មុខសញ្ញាពាក់ព័ន្ធ និងវាយតំលៃចំណាត់ថ្នាក់សណ្ឋាគារ
- *ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* : ផ្តល់ការឯកភាពលើប្លង់សាងសង់ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។
- *អាជ្ញាធរដែនដី* : ផ្តល់ការឯកភាពលើប្លង់សាងសង់ តាមគោលការណ៍កំណត់ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។
- *ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត*

៣- *ប្រសិនបើក្លាយជាគម្រោងវិនិយោគ ត្រូវបានចេញជូនក្រុមហ៊ុនលោកហើយនោះ គំរោងនេះ នឹងត្រូវបានទទួលនូវការលើកទឹកចិត្តសំខាន់ៗ ដោយផ្អែកទៅតាមប្រភេទគម្រោងវិនិយោគនីមួយៗ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដូចខាងក្រោម* :

- រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញនឹងត្រូវកំណត់នៅពេលក្រោយ តាមរូបមន្ត : រយៈពេលគន្លឹះ បូករយៈពេល៣ឆ្នាំ បូករយៈពេលអាទិភាព ។
  - រយៈពេលគន្លឹះជាអតិបរមា : គឺជាឆ្នាំទី១ ដែលគំរោងវិនិយោគ របស់ក្រុមហ៊ុនលោកទទួលបានប្រាក់ចំណេញ ឬរយៈពេល៣ឆ្នាំ បន្ទាប់ពីគំរោងវិនិយោគរបស់ក្រុមហ៊ុនលោក បានទទួលប្រាក់ចំណូលដំបូង ដោយជ្រើសរើសយកជំរើសណាមួយដែលឆាប់ជាង ។
  - រយៈពេលអាទិភាព : នឹងត្រូវកំណត់តាមខ្លឹមសារ នៃច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ។
- ការលើកទឹកចិត្តដោយរដ្ឋជាអ្នកទទួលបន្ទុកលើពន្ធនាំចូលនូវគ្រឿងចក្រ-សំភារៈសាងសង់-សំភារៈបរិក្ខារបំពាក់សំរាប់បំរើគំរោងអភិវឌ្ឍន៍នេះ ។
- ការលើកទឹកចិត្តផ្សេងៗទៀត និងការធានាលើការវិនិយោគ ក៏នឹងត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យ-ច្បាប់ ក៏ដូចជាបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀតដែរ ។

៤- *ចំពោះមុខនេះ ក្រុមហ៊ុនលោកត្រូវ* :

- សហការជាមួយ ក.អ.ក ក.វ.ក ដើម្បីរៀបចំជាសេចក្តីព្រាងកិច្ចសន្យាជួល សំរាប់ដាក់ជូនអង្គប្រជុំអន្តរក្រសួងពិនិត្យ និងសុំការសំរេចជាចុងក្រោយពីរាជរដ្ឋាភិបាល ។ ការរៀបចំសេចក្តីព្រាងកិច្ចសន្យានេះ ក្រុមហ៊ុនលោកត្រូវអនុវត្តតាមលិក្ខខ័ណ្ឌមួយចំនួន ក្នុងនោះក្រុមហ៊ុនលោកត្រូវបង់ប្រាក់កក់តាមអត្រា១,០០០ (មួយ

[illegible]

បំលង់ពីវិសាលភាពមួយដែលច្រើនជាង ។

- សហការជាមួយគណៈកម្មការអន្តរក្រសួង ដឹកនាំដោយ ឯកឧត្តម ខ្ញុំ ឈាភីម ត្រូវលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះធ្វើការសិក្សារៀបចំប្លង់មេក្នុងរយៈពេលមិនលើសពី០៣ខែ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីលក្ខខ័ណ្ឌនេះតទៅ ។ ការរៀបចំប្លង់មេ ពុំចាំបាច់កំណត់មុនសញ្ញាវិនិយោគលើតំបន់នីមួយៗទេ ពោលគឺគ្រាន់តែធ្វើការបែងចែកតំបន់ ដែលអាចវិនិយោគបាន-តំបន់ត្រូវការពារ-តំបន់សំរាប់កងទ័ព-តំបន់រដ្ឋបាល-តំបន់សំរាប់ប្រយោជន៍សាធារណៈ ឬតំបន់សំរាប់ប្រជាពលរដ្ឋប៉ុណ្ណោះ ។ ប៉ុន្តែក្នុងករណីកោះនេះ មានទំហំតូចទេ គឺអាចប្រគល់ជូនក្រុមហ៊ុនលោកវិនិយោគទាំងអស់ ដោយគ្រាន់តែរក្សាទុកតំបន់ការពារខ្លះបានហើយ ពោលគឺពុំចាំបាច់រក្សាទុកតំបន់សំរាប់កងទ័ព-តំបន់រដ្ឋបាលសាធារណៈ-តំបន់សំរាប់ប្រជាពលរដ្ឋទេ ។

*៩- ក្រោយពីគំរោងនេះ ត្រូវបានចុះបញ្ជីជាផ្លូវការរួចហើយ ក្រុមហ៊ុនលោកត្រូវ :*

- គោរពអោយបានត្រឹមត្រូវតាមលក្ខខ័ណ្ឌបច្ចេកទេសនានា ស្តីពីវិធានការការពារបរិស្ថាន ស្របតាមការណែនាំរបស់ក្រសួងបរិស្ថាន ។
- រៀបចំបញ្ជីគណនេយ្យដោយឡែកៗ សំរាប់អនុវត្តគំរោងនីមួយៗ ដើម្បី ក.អ.ក មានមូលដ្ឋានកំណត់រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ចំពោះសកម្មភាពអាជីវកម្មនៃអនុគំរោងទាំងនោះ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន មុខសញ្ញានៃអនុគំរោងវិនិយោគខុសគ្នា ការកំណត់រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញក៏ខុសគ្នាដែរ ហើយមុខសញ្ញាវិនិយោគខ្លះ ដូចជាសកម្មភាពកាស៊ីណូ-សំណង់លំនៅដ្ឋាន និងក្លិបកំសាន្តជាដើម ដែលស្ថិតក្នុងបញ្ជីអវិជ្ជមាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ នឹងមិនទទួលបាននូវការលើកទឹកចិត្តទេ ។
- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីវាយតំលៃនូវប្រភេទអនុគំរោងមួយចំនួនឡើងវិញ ព្រោះថាចំពោះអនុគំរោងមួយចំនួន ការផ្តល់ការលើកទឹកចិត្ត អាស្រ័យលើការវាយតំលៃចុងក្រោយ បន្ទាប់ពីអនុគំរោងនេះបានដំណើរការរួចហើយ ដូចជាគំរោងសណ្ឋាគារ និងគំរោងមានលក្ខណៈប្រហាក់ប្រហែលជាដើម ដែលត្រូវមានការវាយតំលៃចំណាត់ថ្នាក់ផ្កាយពីក្រសួងទេសចរណ៍ ។ ក្នុងករណីអនុគំរោងនោះ ត្រូវបានវាយតំលៃថាមានចំណាត់ថ្នាក់ពុំសមស្របតាមកំរិតដែលត្រូវលើកទឹកចិត្តទេនោះ ក្រុមហ៊ុនលោកត្រូវបង់ពន្ធជូនរដ្ឋវិញនូវសំភារៈសាងសង់ និងសំភារៈបំពាក់ ដែលបាននាំចូលដោយរដ្ឋជាអ្នកទទួលបន្ទុកលើពន្ធនាំចូលកន្លងមក ។
- អនុវត្តតាមល័ក្ខខ័ណ្ឌនានា ដែលនឹងមានចែងក្នុងកិច្ចសន្យាជួលទីតាំងវិនិយោគ រវាងរាជរដ្ឋាភិបាល ជាមួយក្រុមហ៊ុនលោក នាពេលឆាប់ៗខាងមុខ ។
- គោរពច្បាប់ការងារជាធរមាន អោយបានម៉ឺងម៉ាត់ ។
- ប្រយ័ត្នខ្ពស់នឹងការបកប្រែតាមការត្រូវសិទ្ធិ និងផលប្រយោជន៍ទាំងស្រុង ឬមួយផ្នែក ដែលក្រុមហ៊ុនបានទទួលស្របតាមខ្លឹមសារនៃអនុក្រឹត្យដូចបានចែងខាងលើ ប្រសិនបើក្រុមហ៊ុនលោកមានការរំលោភផ្ទុយនឹងច្បាប់ បទប្បញ្ញត្តិជាធរមាន ឬពុំបានអនុវត្តគំរោងវិនិយោគអោយបានទាន់ពេលកំណត់ទេនោះ ។

ពីថ្ងៃចុះហត្ថលេខានេះតទៅ សូមលោកប្រធាន មេត្តាអនុវត្តតាមការណែនាំដូចបានរៀបរាប់ខាងលើនេះ តាមការគួរ។

សូមលោកប្រធាន ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

អគ្គលេខាធិការ

គណៈកម្មាធិការអភិវឌ្ឍន៍កម្ពុជា

ស៊ួន ផារ៉ី

ចម្លងជូន ៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងផែនការ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងទេសចរណ៍
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អនុប្រធាន "ក.អ.ក"
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ប្រធាន "ក.អ.ក"
- បញ្ជាការដ្ឋានកងទ័ពជើងទឹក
- អគ្គលេខាធិការ "ក.អ.ក"
- គ្រប់សមាជិកគណៈកម្មការអន្តរក្រសួង
- ខុទ្ទកាល័យអនុប្រធានទី១ "ក.អ.ក"
- សាលាក្រុងព្រះសីហនុ
- គ្រប់នាយកដ្ឋានចំណុះ "គ.វ.ក"
- នាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកសារ-កាលប្បវត្តិ

[illegible] ............ ឈ្មោះភូមិ [illegible]

ព្រំប្រទល់ :

[illegible] ............................................

[illegible] ............................................

[illegible] ............................................

[illegible] ............................................

[illegible] ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

[illegible] ការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល [illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ

លេខ : ក.ន 008473

ឃុំ-សង្កាត់ : [illegible]

ក្រុង-ស្រុក-ខណ្ឌ : [illegible]

រាជធានី-ខេត្ត : [illegible]

ព្រះសីហនុ. ថ្ងៃទី............ខែ............ឆ្នាំ............

ក.ប រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត

2020801_0016

ទំព័រលេខ ២

| [illegible] | អត្តានុកូលដ្ឋានអ្នកជាប់ | | | | | ការផ្លាស់ប្តូរ | | |
|---|---|---|---|---|---|---|---|---|
| [illegible] | គោត្តនាម និងនាមខ្លួន | ថ្ងៃ ខែ ឆ្នាំ និងស្រុកកំណើត | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] |
| [illegible] 28 [illegible] | [illegible] | – | – | – | – | [illegible] 06.5.2011 [illegible] 18.01.[illegible] 602 | [illegible] | [illegible] 01 [illegible] |

# ឧបសម្ព័ន្ធទី០២

២.១- លិខិតលេខ ៧៣៣ស.ជ.ណ ប.ស្ថ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ ២០១៤ របស់ក្រសួងបរិស្ថាន ស្តីពីការឯកភាពលើសំណើរសុំការចុះសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញលើគម្រោងអភិវឌ្ឍន៍ រមណីយដ្ឋានកោះក្របី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែតុលា ឆ្នាំ២០១៤

**ជម្រាបជូន**

**លោកនាយកក្រុមហ៊ុន** CREATIVE GREEN DESIGN CO., LTD

**កម្មវត្ថុ** ៖ ករណីសំណើសុំការអនុញ្ញាតចុះសិក្សា និងពិគ្រោះយោបល់ជាសាធារណៈជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ លើគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី

**យោង** ៖ លិខិតលេខ ១២១ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រុមហ៊ុន

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកនាយកជ្រាបថា ក្រសួងបរិស្ថានឯកភាពលើសំណើសុំការអនុញ្ញាតចុះសិក្សា និងពិគ្រោះយោបល់ជាសាធារណៈជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ សម្រាប់គម្រោងលើគម្រោងអភិវឌ្ឍន៍រមណីយដ្ឋានកោះក្របី ដែលមានទីតាំងស្ថិតនៅក្នុងភូមិសាស្រ្តឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ របស់ក្រុមហ៊ុន RPB Investment Co., Ltd. ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខានេះរហូតដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥។ ដោយក្នុងនោះក្រុមហ៊ុនត្រូវ៖

- ធ្វើការសិក្សាដោយផ្អែកទៅលើលក្ខខ័ណ្ឌការងារដែលបានផ្តល់យោបល់ដោយនាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ធ្វើការទំនាក់ទំនងជាមួយក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន នៅក្នុងតំបន់គម្រោង
- មានការចូលរួមអង្កេតការណ៍លើការសិក្សារបស់ក្រុមហ៊ុនពីសំណាក់មន្ទីរបរិស្ថានខេត្ត
- សិក្សាឱ្យបានចប់តាមពេលវេលាកំណត់ដើម្បីកុំឱ្យរាំងស្ទះដល់ការវិនិយោគ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកនាយក អនុវត្ត និងចាត់ចែងតាមការគួរ។ សូមលោកនាយក ទទួលនូវសេចក្តីរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ចម្លងជូន៖**
- សាលាខេត្តព្រះសីហនុ
- មន្ទីរបរិស្ថានខេត្តព្រះសីហនុ
- ក្រុមហ៊ុន RPB Investment Co., Ltd.
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី០៣

៣.១- ព្រឹត្តិប័ត្រលទ្ធផលវិភាគគុណភាពទឹក

ក្រសួងបរិស្ថាន

[illegible]

Ministry of En[illegible]

Kingdom of Cambodia

Nation Religion King

# ព្រឹត្តិបត្រលទ្ធផលវិភាគ

## Analysis Report

ប្រភពសំណាក/Sample Source : ក្រុមហ៊ុន RPB Investment Co., Ltd.

ថ្ងៃ ខែ ឆ្នាំទទួលសំណាក/Date: June 11, 2014

ប្រភេទសំណាក/Type of Sample: សំណាកទឹកអណ្តូង(កៀ្បរឆ្នេរសមុទ្ររាម)

| លរ No | ប៉ារ៉ាម៉ែត្រ Parameter | ខ្នាត Unit | លទ្ធផល Result | ស្តង់ដារ CNDWQS | Method LDL | វិធីសាស្ត្រវិភាគ Reference Method |
|---|---|---|---|---|---|---|
| 1 | pH | - | 6.81 | 6.5-8.5 | 4.0 | Method MAJI Meter |
| 2 | Turbidity | NTU | 0.00 | 5.0 | 0 | Method MAJI Meter |
| 3 | Total Dissolved Solid (TDS) | mg/l | 1433.00 | 800 | 0 | Method MAJI Meter |
| 4 | Dissolved Oxygen (DO) | mg/l | 6.02 | NV | 0 | Method MAJI Meter |
| 5 | Salinity | ppt | 1.10 | NV | 0 | Method MAJI Meter |
| 6 | Total Suspended Solid (TSS) | mg/l | 217.00 | NV | NV | Method 2540 D |
| 7 | Ammonium ($NH_4^+$) | mg/l | ND | NV | 0.1 | Method ICs 90 |
| 8 | Chloride ($Cl^-$) | mg/l | 498.36 | 250 | 0.1 | Method 4500-Cl F |
| 9 | Nitrate ($NO_3^-$) | mg/l | 5.56 | 50 | 0.1 | Method 4500-NO3 C |
| 10 | Phosphate ($PO_4^{3-}$) | mg/l | ND | NV | 0.1 | Method ICs 90 |
| 11 | Sulphate ($SO_4^{2-}$) | mg/l | 47.97 | 250 | 0.1 | Method 4500-$SO4^{2-}$ B |
| 12 | Biochemical Oxygen Demand (BOD) | mg/l | 0.92 | NV | NV | Method 5210 B |
| 13 | Chemical Oxygen Demand (COD) | mg/l | 2.01 | NV | NV | Method JIS K 0102 |
| 14 | Total Nitrogen (TN) | mg/l | 0.18 | NV | 0.01 | Method JIS K 0102 45 |
| 15 | Total Phosphorus (TP) | mg/l | 0.03 | NV | 0.01 | Method JIS K 0102 46 |
| 16 | Arsenic (As) | mg/l | ND | 0.05 | 0.0001 | Method 3500-As D |
| 17 | Copper (Cu) | mg/l | ND | 1.0 | 0.0003 | Method 3500-Cu C |
| 18 | Iron (Fe, Total) | mg/l | ND | 0.3 | NV | Method 3500-Fe C |
| 19 | Lead (Pb) | mg/l | ND | 0.01 | 0.0002 | Method 3500-Pb C |
| 20 | Mercury (Hg) | mg/l | ND | 0.001 | NV | Method ICP-MS |
| 21 | Zinc (Zn) | mg/l | ND | 3.0 | 0.0004 | Method 3500-Zn C |
| 22 | Total Coliform | MPN/100ml | $2.0x10^2$ | 0 | 0 | Method NF T90-413(37 °C) |
| 23 | E-Coli | MPN/100ml | 0 | 0 | 0 | Method NF T90-413(44 °C) |

សំគាល់៖ 1- ការយកសំណាក ការរក្សាទុក និងការដឹកជញ្ជូនសំណាកទឹកមកមន្ទីពិសោធន៍ក្រុមហ៊ុន(គំរោង)អនុវត្តដោយខ្លួនឯង។

2- CNDWQS ស្តង់ដារគុណភាពទឹកផឹកថ្នាក់ជាតិ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា។

3- LDL mean Lowest Detechtion Limit, ND Mean Not Detected (Lower than LDL), NV Mean No Value.

ចេញអោយនៅ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

ប្រធានការិយាល័យ

Date of Issue:

Laboratory Chief

បានឃើញនៅ ថ្ងៃទី ខែ ឆ្នាំ២០១៤

ប្រធាននាយកដ្ឋាន

Was seen on date:

Director Department

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

ក្រសួងបរិស្ថាន
នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន
ការិយាល័យពិសោធន៍ និង វិភាគ
Ministry of Environment
Department of Pollution Control
Laboratory Office

# វិញ្ញាបនបត្រលទ្ធផលវិភាគ
## Analysis Report

ប្រភពសំណាក/Sample Source : ក្រុមហ៊ុន Creative Green Design Co., Ltd
ថ្ងៃ ខែ ឆ្នាំទទួលសំណាក/Date: 27/09/2012
ប្រភេទសំណាក/Type of Sample: សំណាកទឹកសមុទ្រ

| លរ No | ប៉ារ៉ាម៉ែត្រ Parameter | ខ្នាត Unit | លទ្ធផល Result | ស្តង់ដារ Standard(*) | វិធីសាស្ត្រវិភាគ/ឧបករណ៍ Method/Equipment |
|---|---|---|---|---|---|
| 1 | pH | - | 7.25 | 7.0~8.3 | pH-EC & TDS meter |
| 2 | Turbidity | NTU | 2.50 | - | Digital Turbidity Meter |
| 3 | Total Dissolved Solid (TDS) | mg/l | 4900.00 | - | pH-EC & TDS meter |
| 4 | Total Suspended Solid (TSS) | mg/l | 306.00 | - | Method 2540 D |
| 5 | Dissolved Oxygen (DO) | mg/l | 5.86 | 2.0~7.5 | DO meter |
| 6 | Chloride ($Cl^-$) | mg/l | 21558.31 | - | ICS-90 Ion Chromatography |
| 7 | Sulphate ($SO_4^{2-}$) | mg/l | 2031.78 | - | ICS-90 Ion Chromatography |
| 8 | Nitrate ($NO_3^-$) | mg/l | ND< 0.1 | - | ICS-90 Ion Chromatography |
| 9 | Phosphate ($PO_4^{3-}$) | mg/l | ND< 0.1 | - | ICS-90 Ion Chromatography |
| 10 | Ammonium ($NH_4^+$) | mg/l | ND< 0.14 | - | ICS-90 Ion Chromatography |
| 11 | Biochemical Oxygen Demand (BOD) | mg/l | 0.17 | - | Method 5210 B |
| 12 | Chemical Oxygen Demand (COD) | mg/l | 0.49 | 2.0~8.0 | JIS K 0102 |
| 13 | Total Phosphorus (TP) | mg/l | 0.03 | 0.02-0.09 | K2S2O8 Decomposition- UV |
| 14 | Total Nitrogen (TN) | mg/l | 0.24 | 0.2-1.0 | K2S2O8 Decomposition- UV |
| 15 | Arsenic (As) | mg/l | ND< 0.0001 | < 0.01 | Method 3030 K -ICP MS |
| 16 | Copper (Cu) | mg/l | 0.30 | - | Method 3030 K -ICP MS |
| 17 | Iron (Fe) | mg/l | 0.06 | - | Method 3030 K -ICP MS |
| 18 | Lead (Pb) | mg/l | 0.002 | < 0.01 | Method 3030 K -ICP MS |
| 19 | Mercury (Hg) | mg/l | 0.062 | < 0.0005 | Method 3112 B |
| 20 | Zinc (Zn) | mg/l | 0.03 | - | Method 3030 K -ICP MS |
| 21 | Total Coliform | MPN/100ml | 90 | < 1000 | MPN-Incubated at 30, 37 °C |
| 22 | E-Coli | MPN/100ml | 0 | - | Micro plate, 44 °C |

**Note:** ១ ការយកសំណាក ការរក្សាទុក និងការដឹកជញ្ជូនសំណាកទឹកមកមន្ទីរពិសោធន៍(គំរោង)ក្រុមហ៊ុនអនុវត្តដោយខ្លួនឯង ។
២ (*) កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសំរាប់អភិរក្សជីវចំរុះនៅក្នុងទឹក។

ចេញអោយនៅ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
ប្រធានការិយាល័យ
Date of Issue:
Laboratory Chief

បានឃើញនៅ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
ប្រធាននាយកដ្ឋាន
Was seen on date:
Director Department

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងបរិស្ថាន

# ព្រឹត្តិប័ត្រលទ្ធផលវិភាគ

## Analysis Report

ប្រភពសំណាក/Sample Source : ក្រុមហ៊ុន RPB Investment Co., Ltd.
ថ្ងៃ ខែ ឆ្នាំទទួលសំណាក/Date: June 11, 2014
ប្រភេទសំណាក/Type of Sample: សំណាកទឹកសមុទ្រ (ជុំវិញកោះក្របី)

| លរ No | ប៉ារ៉ាម៉ែត្រ Parameter | ខ្នាត Unit | លទ្ធផល Result | ស្តង់ដារ Standard | Method LDL | វិធីសាស្ត្រវិភាគ Reference Method |
|---|---|---|---|---|---|---|
| 1 | pH | - | 7.79 | 7.0-8.3 | 4.0 | Method MAJI Meter |
| 2 | Turbidity | NTU | 0.00 | NV | 0 | Method MAJI Meter |
| 3 | Total Dissolved Solid (TDS) | mg/l | 1432.00 | NV | 0 | Method MAJI Meter |
| 4 | Dissolved Oxygen (DO) | mg/l | 6.35 | 2.0-7.5 | 0 | Method MAJI Meter |
| 5 | Salinity | ppt | 1.10 | NV | 0 | Method MAJI Meter |
| 6 | Total Suspended Solid (TSS) | mg/l | 258.00 | NV | NV | Method 2540 D |
| 7 | Ammonium ($NH_4^+$) | mg/l | ND | NV | 0.1 | Method ICs 90 |
| 8 | Chloride ($Cl^-$) | mg/l | 20731.62 | NV | 0.1 | Method 4500-Cl F |
| 9 | Nitrate ($NO_3^-$) | mg/l | 40.83 | NV | 0.1 | Method 4500-NO3 C |
| 10 | Phosphate ($PO_4^{3-}$) | mg/l | ND | NV | 0.1 | Method ICs 90 |
| 11 | Sulphate ($SO_4^{2-}$) | mg/l | 1991.13 | NV | 0.1 | Method 4500-$SO4^{2-}$ B |
| 12 | Biochemical Oxygen Demand (BOD) | mg/l | 1.26 | NV | NV | Method 5210 B |
| 13 | Chemical Oxygen Demand (COD) | mg/l | 2.80 | 2.0-8.0 | NV | Method JIS K 0102 |
| 14 | Total Nitrogen (TN) | mg/l | 0.33 | 0.2-1.0 | 0.01 | Method JIS K 0102 45 |
| 15 | Total Phosphorus (TP) | mg/l | 0.05 | 0.02-0.09 | 0.01 | Method JIS K 0102 46 |
| 16 | Arsenic (As) | mg/l | 0.007 | 0.01 | 0.0001 | Method 3500-As D |
| 17 | Copper (Cu) | mg/l | 0.01 | NV | 0.0003 | Method 3500-Cu C |
| 18 | Iron (Fe, Total) | mg/l | 0.11 | NV | NV | Method 3500-Fe C |
| 19 | Lead (Pb) | mg/l | 0.006 | 0.01 | 0.0002 | Method 3500-Pb C |
| 20 | Mercury (Hg) | mg/l | ND | 0.0005 | NV | Method ICP-MS |
| 21 | Zinc (Zn) | mg/l | ND | NV | 0.0004 | Method 3500-Zn C |
| 22 | Total Coliform | MPN/100ml | $7.5 \times 10^2$ | 1000 | 0 | Method NF T90-413 (37 °C) |
| 23 | E-Coli | MPN/100ml | 0 | NV | 0 | Method NF T90-413 (44 °C) |

សំគាល់៖ 1- ការយកសំណាក ការរក្សាទុក និងការដឹកជញ្ជូនសំណាកទឹកមកមន្ទីរពិសោធន៍ក្រុមហ៊ុន (តំរោង) អនុវត្តដោយខ្លួនឯង។
2- Standards គឺកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសំរាប់អភិរក្សជីវចំរុះនៅក្នុងទឹក និងសំរាប់ការពារសុខភាពសាធារណៈ។
3- LDL mean Lowest Detechtion Limit, ND Mean Not Detected (Lower than LDL), NV Mean No Value.

ចេញអោយនៅ ថ្ងៃទី ខែ ឆ្នាំ២០១៤
ប្រធានការិយាល័យ
Date of Issue:
Laboratory Chief

បានឃើញនៅ ថ្ងៃទី ខែ ឆ្នាំ២០១៤
ប្រធាននាយកដ្ឋាន
Was seen on date:
Director Department

Kingdom of Cambodia

Nation Religion King

## Analysis Report

ប្រភពសំណាក/Sample Source : ក្រុមហ៊ុន RPB Investment Co., Ltd.

ថ្ងៃ ខែ ឆ្នាំទទួលសំណាក/Date: June 11, 2014

ប្រភេទសំណាក/Type of Sample: សំណាកទឹកយកចេញពីម៉ាស៊ីនទឹកប្រៃ (After Treatment)

| លរ No | ប៉ារ៉ាម៉ែត្រ Parameter | ខ្នាត Unit | លទ្ធផល Result | ស្តង់ដារ Standard | Method LDL | វិធីសាស្ត្រវិភាគ Reference Method |
|---|---|---|---|---|---|---|
| 1 | pH | | 7.70 | 7.0-8.3 | 4.0 | Method MAJI Meter |
| 2 | Turbidity | NTU | 0.00 | NV | 0 | Method MAJI Meter |
| 3 | Total Dissolved Solid (TDS) | mg/l | 324.00 | NV | 0 | Method MAJI Meter |
| 4 | Dissolved Oxygen (DO) | mg/l | 6.57 | 2.0-7.5 | 0 | Method MAJI Meter |
| 5 | Salinity | ppt | 0.25 | NV | 0 | Method MAJI Meter |
| 6 | Total Suspended Solid (TSS) | mg/l | 105.00 | NV | NV | Method 2540 D |
| 7 | Ammonium ($NH_4^+$) | mg/l | ND | NV | 0.1 | Method ICs 90 |
| 8 | Chloride ($Cl^-$) | mg/l | 138.13 | NV | 0.1 | Method 4500-Cl F |
| 9 | Nitrate ($NO_3^-$) | mg/l | 0.36 | NV | 0.1 | Method 4500-NO3 C |
| 10 | Phosphate ($PO_4^{3-}$) | mg/l | ND | NV | 0.1 | Method ICs 90 |
| 11 | Sulphate ($SO_4^{2-}$) | mg/l | 2.92 | NV | 0.1 | Method 4500-$SO_4^2$ B |
| 12 | Biochemical Oxygen Demand (BOD)5 | mg/l | 0.55 | NV | NV | Method 5210 B |
| 13 | Chemical Oxygen Demand (COD)OH | mg/l | 1.86 | 2.0-8.0 | NV | Method JIS K 0102 |
| 14 | Total Nitrogen (TN) | mg/l | 0.46 | 0.2-1.0 | 0.01 | Method JIS K 0102 45 |
| 15 | Total Phosphorus (TP) | mg/l | 0.01 | 0.02-0.09 | 0.01 | Method JIS K 0102 46 |
| 16 | Arsenic (As) | mg/l | 0.005 | 0.01 | 0.0001 | Method 3500-As D |
| 17 | Copper (Cu) | mg/l | ND | NV | 0.0003 | Method 3500-Cu C |
| 18 | Iron (Fe, Total) | mg/l | ND | NV | NV | Method 3500-Fe C |
| 19 | Lead (Pb) | mg/l | ND | 0.01 | 0.0002 | Method 3500-Pb C |
| 20 | Mercury (Hg) | mg/l | 0.0001 | 0.0005 | NV | Method ICP-MS |
| 21 | Zinc (Zn) | mg/l | ND | NV | 0.0004 | Method 3500-Zn C |
| 22 | Total Coliform | MPN/100ml | $1.1x10^2$ | 1000 | 0 | Method NF T90-413 (37 °C) |
| 23 | E-Coli | MPN/100ml | 0 | NV | 0 | Method NF T90-413 (44 °C) |

**សំគាល់៖** 1- ការយកសំណាក ការរក្សាទុក និងការដឹកជញ្ជូនសំណាកទឹកមកមន្ទីពិសោធន៍ក្រុមហ៊ុន(តំរោង)អនុវត្តដោយខ្លួនឯង។

2- Standards កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសំរាប់អភិរក្សជីវចំរុះនៅក្នុងទឹក និងសំរាប់ការពារសុខភាពសាធារណៈ។

3- LDL mean Lowest Detechtion Limit, ND Mean Not Detected (Lower than LDL), NV Mean No Value.

ចេញអោយនៅ ថ្ងៃទី ខែ ឆ្នាំ២០១៤

ប្រធានការិយាល័យ

Date of Issue:

Laboratory Chief

បានឃើញនៅ ថ្ងៃទី ខែ ឆ្នាំ២០១៤

ប្រធាននាយកដ្ឋាន

Was seen on date:

Director Department

# ឧបសម្ព័ន្ធទី០៤

៤.១- កម្រិតសំណើម

៤.២-កម្ពស់ទឹកភ្លៀង

៤.៣-សីតុណ្ហភាពអប្បរមា

៤.៤-សីតុណ្ហភាពអតិបរមា

៤.៥-ទិសខ្យល់

Monthly Rainfall Record (mm)
SIHANOUK VILLE
Longitude:103°29' , Latitude:10°37', Altitude: 13m

| Month | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec | Total |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **2009** | 2.4 | 6.8 | 113.3 | 127.4 | 353.2 | 141.5 | 379.1 | 220.8 | 715.1 | 215.7 | 14.4 | 52.7 | **2342.4** |
| **2010** | 46.2 | 0.6 | 2.6 | 78.4 | 249.8 | 204.4 | 438.8 | 303 | 176.6 | 480.6 | 164.4 | 30.2 | **2175.6** |
| **2011** | 1.2 | 12.8 | 126 | 119.8 | 97 | 277.6 | 355 | 442.8 | 732.5 | 131.9 | 43.3 | 5.4 | **2345.3** |
| **2012** | 47.0 | 126.6 | 97.4 | 108.1 | 394.9 | 273.3 | 397.4 | 271.8 | 714.9 | 169.0 | 145.8 | 12.2 | **2758.4** |
| **2013** | 6.6 | 27.4 | 69.8 | 187.6 | 237.2 | 312.7 | 608.3 | 319.8 | 459.5 | 294.3 | 114.2 | 44.8 | **2682.2** |

Note : - no rain

## Monthly TemperatureMinimum (oC)
## SHIHANOUK VILLE
**Longitude:103°29' , Latitude:10°37', Altitude: 13m**

| Month | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec | Average |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Year | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 |
| 2009 | 22.9 | 24.7 | 24.9 | 25.7 | 25.2 | 25.4 | 24.5 | 25.1 | 24.0 | 24.7 | 25.1 | 24.2 | **24.7** |
| 2010 | 23.0 | 24.0 | 25.5 | 25.0 | 24.5 | 23.5 | 23.0 | 20.5 | 20.0 | 22.0 | 20.5 | 22.5 | **22.8** |
| 2011 | 19.5 | 23.0 | 19.5 | 23.5 | 23.5 | 20.5 | 23.0 | 20.0 | 22.0 | 23.0 | 22.0 | 17.5 | **21.4** |
| 2012 | 22.2 | 20.0 | 23.5 | 24.0 | 23.0 | 24.5 | 23.0 | 21.0 | 20.5 | 23.0 | 20.0 | 21.5 | **22.2** |
| 2013 | 22.9 | 23 | 23 | 24 | 22.5 | 23.4 | 19.5 | 22.5 | 22 | 23 | 23.5 | 19.5 | **22.4** |
| 2014 | 22.5 | 24.5 | 25.2 | 26.3 | 26.8 | 25.4 | 24.2 | 24.7 | 24.3 | 25.3 | 24.8 | 23.2 | **24.8** |
| | 22.0 | 22.9 | 23.3 | 24.6 | 24.1 | 23.5 | 22.5 | 21.7 | 21.8 | 23.3 | 22.2 | 20.8 | 22.7 |

## Monthly TemperatureMaximum (oC)
## SHIHANOUK VILLE

| Month | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec | Average |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Year | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 |
| 2009 | 30.1 | 30.9 | 31.8 | 32.3 | 31.1 | 31.3 | 30.5 | 31.4 | 29.3 | 30.5 | 32.1 | 30.2 | **31.0** |
| 2010 | 32.5 | 33.5 | 35.0 | 35.5 | 35.0 | 34.0 | 33.0 | 32.5 | 33.0 | 32.5 | 34.0 | 32.0 | **33.5** |
| 2011 | 34.0 | 35.0 | 32.0 | 33.4 | 33.0 | 34.0 | 32.5 | 32.0 | 32.5 | 33.0 | 33.5 | 32.5 | **33.1** |
| 2012 | 34.5 | 33.0 | 33.0 | 33.5 | 38.5 | 33.0 | 32.5 | 32.0 | 32.8 | 32.5 | 33.5 | 33.0 | **33.5** |
| 2013 | 32.5 | 33 | 35 | 35.5 | 36 | 33.6 | 31.5 | 33 | 33 | 33 | 32.7 | 31.5 | **33.4** |
| 2014 | 29.4 | 29.4 | 30.9 | 32.0 | 32.6 | 31.2 | 30.2 | 31.0 | 30.6 | 31.5 | 31.9 | 31.7 | **31.0** |
| | 32.6 | 32.8 | 33.2 | 34.0 | 35.0 | 33.2 | 31.9 | 32.1 | 32.4 | 32.5 | 33.1 | 32.1 | 32.9 |

## Monthly Average Humidity (%)
## SHIHANOUK VILLE
**Longitude:103°29' , Latitude:10°37', Altitude: 13m**

| Month | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec | Average |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Year | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 |
| 2009 | 75.8 | 84.7 | 84.4 | 82.0 | 83.6 | 83.3 | 86.0 | 83.1 | 88.8 | 86.1 | 80.0 | 79.9 | **83.1** |
| 2010 | 77.5 | 78.8 | 76.8 | 76.8 | 77.4 | 80.5 | 82.1 | 84.7 | 82.6 | 85.0 | 81.4 | 77.9 | **80.1** |
| 2011 | 67.8 | 77.0 | 75.7 | 80.0 | 79.5 | 83.1 | 83.3 | 83.2 | 86.2 | 83.8 | 81.5 | 75.6 | **79.7** |
| 2012 | 77.5 | 81.8 | 87.1 | 82.0 | 81.6 | 83.5 | 84.1 | 86.5 | 90.9 | 85.3 | 86.6 | 79.0 | **83.8** |
| 2013 | 65.2 | 63.5 | 68.4 | 71 | 73.2 | 79.3 | 81.7 | 82 | 81.9 | 80.9 | 73.1 | 64.3 | **73.7** |

Ministry of Water Resours and Meteorology
Department of Meteorology

## Monthly Maximum Wind Speed ( m/s )and Wind Direction
### SHIHANOUK VILLE
**Longitude:103°29' , Latitude:10°37', Altitude: 13m**

| Month / Year | | Jan | Feb | Mar | Apr | May | Jun | Jul | Aug | Sep | Oct | Nov | Dec |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 |
| 2009 | W-dd | NW | NE | SE | NW | NE | NW | NW | NW | NW | NW | NW | NE |
| 2009 | W-ss | 10.0 | 5.0 | 6.0 | 7.0 | 7.0 | 13.0 | 17.0 | 9.0 | 9.0 | 13.0 | 14.0 | 9.0 |
| 2010 | W-dd | NW | S | SE | NW | NW | SW | NW | NW | NW | NW | NE | NE |
| 2010 | W-ss | 9.0 | 7.0 | 6.0 | 5.0 | 21.0 | 8.0 | 7.0 | 16.0 | 17.0 | 7.0 | 8.0 | 7.0 |
| 2011 | W-dd | NE | E | N | SW/SE | N | NW | NW | NW/W | NW | NW/W | NE | NE |
| 2011 | W-ss | 5.0 | 7.0 | 6.0 | 4.0 | 5.0 | 7.0 | 8.0 | 9.0 | 8.0 | 7.0 | 5.0 | 6.0 |
| 2012 | W-dd | NE | NE | W/SE | SW/SE | NW | NW | NW | NW/W | NW | NW/W | NE/N | NE |
| 2012 | W-ss | 6.0 | 9.0 | 5.0 | 4.0 | 8.0 | 10.0 | 6.0 | 10.0 | 9.0 | 12.0 | 8.0 | 6.0 |
| 2013 | W-dd | NE | NNE | SW | WNW | SW | SW | NW | WSW | NW | NNW | NNW | NNW |
| 2013 | W-ss | 3.0 | 5.0 | 6.0 | 9.0 | 5.0 | 5.0 | 12.0 | 10.0 | 12.0 | 8.0 | 7.0 | 9.0 |

# ឧបសម្ព័ន្ធទី០៥

៥.១- លទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីធនធានសត្វ និងព្រៃឈើក្នុងតំបន់អភិវឌ្ឍន៍កោះក្របី

## ៥.១.២. កំណត់ប្រភេទប្លង់ជំរើស

ក្នុងការគណនាចំនួនឡូត៍-អនុឡូត៍គំរូសម្រាប់ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើគឺ ផ្អែកលើគោលការណ៍ណែនាំសម្រាប់ធ្វើសារពើភ័ណ្ឌរបស់រដ្ឋបាលព្រៃឈើ។ ឡូត៍អនុឡូត៍គំរូសម្រាប់ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើនៅលើកោះក្របី ដោយសារផ្ទៃដីមានទំហំត្រឹមតែ 10 ហិកតា ដែលគ្របដណ្តប់ដោយព្រៃស្រោង ដូចនេះក្រុមការងារធ្វើសម្រេចដាក់តាំងឡូត៍អនុឡូត៍គំរូសិក្សាតាមលំដាប់ថ្នាក់អង្កត់ផ្ចិតដូចខាងក្រោម៖

- អង្កត់ផ្ចិតកំពស់(1.30ម) ចាប់ពី 5-14សម សិក្សាចំនួន 10ឡូត៍គំរូ
- អង្កត់ផ្ចិតកំពស់(1.30ម)ចាប់ពី15-30សម សិក្សាចំនួន 10ឡូត៍គំរូ
- អង្កត់ផ្ចិតកំពស់(1.30ម)ធំជាង30សម សិក្សាចំនួន 10ឡូត៍គំរូ

ចំពោះឡូត៍-អនុឡូត៍គំរូដែលបានដាក់តាំងសម្រាប់ការសិក្សាវាយតម្លៃធនធានព្រៃឈើនិងសត្វព្រៃនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អភីប៊ី អ៊ិនវេសមេន ខូអិលធីឌី គឺបានដាក់តាំងលក្ខណៈជាប្រព័ន្ធដែលខ្សែវាស់រាប់មួយទៅខ្សែវាស់រាប់មួយទៀតមានគំលាត 100ម៉ែត្រស្មើៗគ្នា។ ដោយឡែកចន្លោះឡូត៍មួយទៅឡូត៍មួយទៀតមានគំលាត 100 ម៉ែត្រ (ដូចរូបទី1 ក្នុងឧបសម្ព័ន្ធ 1)។ មុននឹងដាក់តាំងឡូត៍-អនុឡូត៍គំរូសិក្សានេះក្រុមការងារធ្វើការជ្រើសរើសទីតាំង សម្របមួយសម្រាប់ដាក់តាំងឡូត៍គំរូសិក្សាវាយតំលៃដោយធ្វើយ៉ាងណាឲ្យឡូត៍-អនុឡូត៍គំរូគ្របដណ្តប់បានគ្រប់ប្រភេទព្រៃដែលមាននៅក្នុងតំបន់ដីសម្បទាន។

- សីតុណ្ហភាពមធ្យមអប្បបរមាប្រចាំឆ្នាំ T =26.00 °C
- សីតុណ្ហភាពមធ្យមប្រចាំឆ្នាំ T = 27.75 °C

(ប្រភពទិន្នន័យៈ ក្រសួងធនធានទឹក និងឧតុនិយម)

៤.២.៣. សំណើម

សំណើមនៅតំបន់នោះមានកំរិតទាបយ៉ាងខ្លាំងនៅរដូវប្រាំងគឺនៅក្នុងខែមករា ខែកុម្ភៈ បន្ទាប់ពីមានខ្យល់មូសុងត្រជាក់បក់ពីទិសខាងជើងឈៀងខាងកើត និងខែមេសាដែលមានកំរិតចន្លោះពី 63.80ភាគរយ ទៅ 67.60ភាគរយ ។

## ៤.៣. ស្ថានភាពដី និង ប្រភេទដី

ស្ថានដី និងប្រភេទដីរបស់ក្រុមហ៊ុនអគីប៊ី អ៊ិនវេសមេន ឌូអិលធីឌី ជាតំបន់កោះដែលមានសណ្ឋានដីជាលក្ខណៈដីខ្ពង់រាប និងកន្លែងខ្លះមានផ្ទៃដីជម្រាលចោទជាមធ្យម។ តាមផែនទីចំណាត់ថ្នាក់ប្រភេទដីរបស់លោក Crocker (1963) មាត្រដ្ឋាន 1:1,000,000 បានបង្ហាញថាកោះក្របីមានប្រភេទដីមួយប្រភេទមួយប្រភេទគឺប្រភេទដី Acid Lithosols ដែលមានទំហំ 12 ហិកតា ។

ដី Acid Lithosols៖ មានកំទេចដុំថ្មស្តើងៗផុសលើដីដែលសំបូរដោយកករជាតិអាស៊ីត និងថ្មដែលពុកផុយ (ថ្មខ្សាច់ ថ្មធ្មូនតដ្ឋ ថ្មក្រួសអាចម៍ផ្កាយ ថ្មជាតិស៊ីលិស និងថ្មធ្មូន) និងថ្មក្នុងតំបន់ជាតិអាស៊ីត ដីស្តើងអាស៊ីតមានជម្រៅពី 5-30 ស.ម ហើយធម្មតាគឺ 15ស.ម ដែលជម្រៅជាមធ្យមអាចដល់ស្រទាប់ថ្ម ដែលនៅទីកន្លែងជាច្រើនបានវិវត្តជាថ្មក្រួសក្រវៀននៅលើផ្ទៃផ្ទាំងថ្មធំ។ ដីកំទេចថ្មស្តើងមានជាតិអាស៊ីត pH 4.5-6.5 ដែលខុសគ្នាពីស្រទាប់ដីល្បាយខ្សាច់ទៅដីឥដ្ឋ ហើយជាធម្មតាភាគច្រើនគឺជាដីឥដ្ឋល្បាយ។ ពណ៌ដីខុសៗគ្នាជាមួយនឹងឥទ្ធិពលពណ៌របស់ថ្មមេ។

## ៤.៤. ផ្លូវដែលអាចចូលដល់តំបន់សិក្សា

តំបន់គម្រោងមេណីយដ្ឋានកោះក្របីរបស់ក្រុមហ៊ុនអគីប៊ី អ៊ិនវេសមេន ឌូអិលធីឌី ស្ថិតនៅក្បែរឆ្នេរសមុទ្រនៃឧទ្យានជាតិរាម ចំងាយប្រមាណជា ៦ គីឡូម៉ែត្រ។ ពេលធ្វើដំណើរពីតាមផ្លូវឧទ្យានជាតិរាម ដល់ឆ្នេរសមុទ្រយើងធ្វើដំណើរតាមទូលដែលចំណាយរយៈពេលប្រមាណជា 30-40នាទី។

# ៥ វិធីសាស្ត្រប៉ាន់ស្មានធនធានព្រៃឈើ

## ៥.១. ប្រភេទប្លង់ជំរើស

### ៥.១.១. ការកំណត់ប្រភេទព្រៃ

តាមការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) បានបង្ហាញថាតំបន់អភិវឌ្ឍកោះក្របីមាន ទំហំផ្ទៃដី 12ហិកតា ។ ក្នុងការសិក្សានេះក្រុមការងារចុះវាយតម្លៃបានប្រើប្រាស់ផែនទីគម្របព្រៃឈើឆ្នាំ 2010 ដើម្បីកំណត់ទំហំប្រភេទព្រៃ និងទំហំផ្ទៃដីទំនេរ សម្រាប់ជាមូលដ្ឋានក្នុងការគណនាចំនួនឡូតិ៍-អនុឡូតិ៍គំរូ។ ប្រព័ន្ធព័ត៌មានភូមិសាស្ត្របានបង្ហាញថាក្នុងតំបន់សិក្សាវាយតម្លៃរួមមានដូចខាងក្រោម៖

- ព្រៃស្រោង ចំនួន 8 ហិកតា
- ដីគ្មានគម្របព្រៃឈើ ចំនួន 2 ហិកតា

**សរុប 10 ហិកតា**

## ៤. ស្ថានភាពទូទៅនៃតំបន់កោះក្របី

### ៤.១ ទីតាំងនៃកោះក្របី

#### ៤.១.១ ទីតាំងរដ្ឋបាល

ទីតាំងសិក្សាវាយតំលៃធនធានព្រៃឈើ សត្វព្រៃ និងសត្វក្នុងទឹកជំហ៊ាននៃក្រុមហ៊ុនអភីប៊ី អ៊ិនវេសមេន ខូអិលធីឌី ស្ថិតនៅក្នុងឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ យោងតាមផែនការមេ ក្រុមហ៊ុនរៀបចំលើទំហំផ្ទៃដី 10ហិកតា សំរាប់អភិវឌ្ឍន៍ដែលរួមមានការសាងសង់រមណីយដ្ឋាន និងប្រតិបត្តិការរាប់បញ្ចូលទាំងការទទួលភ្ញៀវ និងផែរសម្រាប់ដឹកជញ្ជូនបម្រើសេចក្តីត្រូវការទាំងផ្នែកបច្ចេកទេស និងសម្ភារៈ។

#### ៤.១.២ ទីតាំងភូមិសាស្ត្រ

ទីតាំងសិក្សាវាយតំលៃធនធានព្រៃឈើនៃតំបន់អភិវឌ្ឍកោះក្របីរបស់ក្រុមហ៊ុនអភីប៊ី អ៊ិនវេសមេន ខូអិលធីឌី ស្ថិតនៅចន្លោះខ្សែស្របទី 10°30′20″ និង 10°30′35″ នៃរយៈទទឹងខាងជើង និងខ្សែបណ្តោយទី 103°34′02″ និង 103°34′04″ នៃរយៈបណ្តោយខាងកើត។

#### ៤.១.៣ ព្រំប្រទល់

យោងតាមផែនទីដែលមាននៅក្នុងផែនការមេរបស់ក្រុមហ៊ុនអភីប៊ីអ៊ិនវេសមេន ខូអិលធីឌីបង្ហាញថាតំបន់អភិវឌ្ឍនេះស្ថិតនៅចំងាយពីឆ្នេរសមុទ្រនៃឧទ្យានជាតិរាមចំងាយប្រមាណជា 6 គីឡូម៉ែត្រ។ កោះក្របីនេះប៉ែកខាងត្បូងព័ទ្ធជុំវិញដោយកោះឬស្សី និងកោះតាខៀវ និងប៉ែកខាងជើងឈៀងខាងលិចស្ថិតនៅក្បែរកោះព្រះ។

#### ៤.១.៤ ទំហំផ្ទៃដី

គម្រោងអភិវឌ្ឍកោះក្របីរបស់ក្រុមហ៊ុនអភីប៊ី អ៊ិនវេសមេន ខូអិលធីឌី មានទំហំផ្ទៃដី 10 ហិកតា និងត្រូវបានចែកចេញជាបីអនុតំបន់ បើយោងតាមផែនការមេរបស់ក្រុមហ៊ុន។ តាមការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) តំបន់កោះក្របីមានផ្ទៃដីទំហំ 12 ហិកតា ដោយរាប់បញ្ចូលទាំងឆ្នេរខ្សាច់ដែលព័ទ្ធជុំវិញកោះផងដែរ។

### ៤.២. លក្ខខណ្ឌអាកាសធាតុ

#### ៤.២.១. របបទឹកភ្លៀង

របបទឹកភ្លៀងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងរបបខ្យល់មូសុង។ ក្នុងរយៈពេល 6ខែ ក្រោមរបបខ្យល់មូសុងស្សោចាប់ពីខែ ឧសភា ដល់ខែ តុលា ជារដូវដែលសំបូរទៅដោយទឹកភ្លៀងដោតជាំខ្លាំងស្មើគ្រប់ទីកន្លែង។

បើយោងតាមស្ថិតិបរិមាណទឹកភ្លៀងឆ្នាំ2006ខេត្តព្រះសីហនុ(ស្ថានីយ៍ឧតុនិយមខេត្តព្រះសីហនុ)បានបង្ហាញថា៖

- កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ 1988 ម.ម
- កម្ពស់ទឹកភ្លៀង អប្បបរមាប្រចាំឆ្នាំ (2007) 1986 ម.ម
- កម្ពស់ទឹកភ្លៀង អតិបរមាប្រចាំឆ្នាំ (2008) 2070.30 ម.ម

(ប្រភព៖ ស្ថានីយ៍ឧតុនិយមខេត្តព្រះសីហនុ)

#### ៤.២.២ សីតុណ្ហភាព

សីតុណ្ហភាពមានការប្រែប្រួលខុសៗគ្នាទៅតាមទីកន្លែង និងរដូវកាល ដោយឡែកសីតុណ្ហភាពនៅក្នុងតំបន់សិក្សាប្រចាំឆ្នាំ 2006 បានបង្ហាញដូចខាងក្រោម៖

- សីតុណ្ហភាពមធ្យមអតិបរមាប្រចាំឆ្នាំ T = 30.00 °C

# របាយការណ៍ការសិក្សាវាយតម្លៃតំលៃ ប៉ាន់ស្មានធនធានព្រៃឈើ សត្វព្រៃលើគោក និងសត្វក្នុងទឹកនៃតំបន់គម្រោងអភិវឌ្ឍ និងវិនិយោគ កោះក្របី របស់ក្រុមហ៊ុន អគីប៊ី អ៊ិនវេសមេន ខូអិលធីឌី

## ១. សេចក្តីផ្តើម

គម្រោងរមណីយដ្ឋានកោះក្របីគឺជាគម្រោងអភិវឌ្ឍមួយដែលរួមមានការសាងសង់រមណីយដ្ឋាន និងប្រតិបត្តិការនៅលើកោះក្របី ដែលមានទំហំដី 10 ហិកតា នៅក្បែរឆ្នេរសមុទ្រក្រុងព្រះសីហនុ។ គម្រោងកោះក្របីមានបំណងរៀបចំស្តង់ដារថ្មីមួយសម្រាប់តំបន់ ដើម្បីប្រែក្លាយក្រុងព្រះសីហនុឲ្យទៅជាគោលដៅទាក់ទាញ ភ្ញៀវទេសចរណ៍ដែលមកទស្សនារតនសម្បត្តិអង្គរឲ្យស្នាក់នៅកាន់តែយូរថែមទៀតនៅក្នុងប្រទេសនេះ និងស្វែងយល់អំពីឆ្នេរសមុទ្រ សោភ័ណ្ឌភាពទាំងមូលនៃធម្មជាតិ និង បរិស្ថានដែលមានភាពអំណោយផលខាងផ្នែកអេកូឡូស៊ីទាំងឡាយរបស់ប្រទេសកម្ពុជា។

ប៉ុន្តែមុននឹងធ្វើការអភិវឌ្ឍន៍នៅលើកោះនេះ នាយកដ្ឋានអង្កេត ពិនិត្យវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថានតម្រូវឲ្យក្រុមហ៊ុនអគីប៊ី អ៊ិនវេសមេន ខូអិលធីឌី សិក្សាវាយតំលៃធនធានផល-អនុផលព្រៃឈើ សត្វព្រៃ និងសត្វក្នុងទឹកដែលមាននៅក្នុងតំបន់នេះជាមុនសិន។

## ២. គោលបំណង

ការសិក្សាវាយតំលៃប៉ាន់ស្មានធនធានព្រៃឈើ សត្វព្រៃលើគោក និងក្នុងទឹកដែលមានវត្តមាននៅលើកោះក្របីដែលមានផ្ទៃដីចំនួន **10 ហិកតា** ដើម្បីវាយតម្លៃលើចំនុចដូចខាងក្រោម៖

- សិក្សាអំពីបម្រែបម្រួលគម្របព្រៃឈើពីឆ្នាំ 2002-2010 លក្ខណៈព្រៃឈើ និងកំណត់ប្រភេទដើមឈើ (រួមបញ្ចូលចំណាត់ថ្នាក់ប្រភេទឈើដែលរងការបាត់បង់តាមបញ្ជីឧបសម្ព័ន្ធរបស់ IUCN Red List)
- ប៉ាន់ប្រមាណដង់ស៊ីតេ និងមាឌឈើឈរសរុប(មាឌឈើក្នុងមួយហិកតា) និងជីវម៉ាស់នៃមាឌឈើឈរ រួមទាំងប៉ាន់ស្មានតម្លៃឈើឈរ
- សិក្សាអំពីវត្តមានប្រភេទសត្វព្រៃក្នុងតំបន់គម្រោង និងប្រភេទសត្វដែលស្ថិតនៅក្នុងចំណាត់ថ្នាក់កំពុងរងការគំរាមកំហែងតាមបញ្ជីឧបសម្ព័ន្ធរបស់ IUCN Red List)
- សិក្សាអំពីអត្ថប្រយោជន៍នៃព្រៃឈើ និងសត្វព្រៃ និងការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន
- សិក្សាវត្តមានសត្វរស់នៅក្នុងទឹក និងមច្ឆាជាតិនៅក្នុងតំបន់គម្រោងតាមការសម្ភាសន៍ប្រជាពលរដ្ឋ និងការអង្កេត ព្រមទាំងកំណត់ប្រភេទត្រីរងការគំរាមកំហែង។

## ៣. លក្ខខណ្ឌក្នុងការអភិវឌ្ឍន៍

យោងតាមផែនការមេរបស់ក្រុមហ៊ុនអគីប៊ី អ៊ិនវេសមេន ខូអិលធីឌី មុននឹងធ្វើការអភិវឌ្ឍលើកោះក្របី ក្រុមហ៊ុនត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ក្រុមហ៊ុនត្រូវរៀបចំរបាយការណ៍វាយតម្លៃស្តីពីហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង (IESIA) ជាមុនសិនមុននឹងដំណើការសាងសង់។
- ការវិនិយោគនេះ ត្រូវជៀសវាងការកាប់ព្រៃឈើឲ្យបានជាអតិបរមា។ ទោះបីជាប្លង់មេបានកំណត់ទីតាំងសាងសង់រួចហើយសម្រាប់មុខសញ្ញាមួយចំនួនក៏ពិតមែន តែពេលសាងសង់ជាក់ស្តែង ប្រសិនបើប៉ះចំដើមធំ (ចាប់ពីមុខកាត់ 20 ស.ម ឡើងទៅ) ដែលត្រូវរក្សាទុកនោះ សាមីក្រុមហ៊ុនត្រូវបង្វែរទិសដៅសាងសង់វិញ។

រូបភាពទី1 គំនូសតាមឡូតិ៍ អនុតំបន់គំរូ




## ៥.១.៣. ទំហំឡូតិ៍ និង អនុឡូតិ៍គំរូ

| ថ្នាក់អង្កត់ផ្ចិត | ទំហំឡូតិ៍ អនុឡូតិ៍ | ផ្ទៃដី |
|---|---|---|
| 05 ទៅ 14ស.ម | 30ម X 25ម | 0.075 ហិកតា |
| 15 ទៅ 30 ស.ម | 30ម X 50ម | 0.150 ហិកតា |
| ធំជាង 30 ស.ម ឡើងទៅ | 30 X 100ម | 0.300 ហិកតា |




## ៥.១.៤. ការគណនាចំនួនឡូតិ៍គំរូត្រូវដាក់តាំង

ការគណនាចំនួនឡូតិ៍គំរូត្រូវដាក់តាំងក្នុងតំបន់សារពើភ័ណ្ឌ តាមរូបមន្តដូចខាងក្រោម:

$$N = \frac{S \times SI}{s}$$

ដែល: - S : ផ្ទៃដីសរុបតាមស្រទាប់ព្រៃនីមួយៗ គិតជាហិកតា

- SI : កំរិតជម្រើសតាមថ្នាក់អង្កត់ផ្ចិតនីមួយៗ

- s : ទំហំឡូតិ៍ អនុឡូតិ៍គំរូនីមួយៗ គិតជាហិកតា

**៥.១.៥. ការគណនាគំលាតរវាងខ្សែរាប់**

ការគណនាគំលាតរវាងខ្សែវាស់រាប់ តាមរូបមន្តដូចខាងក្រោម:

$$D = \frac{30}{SI} = \frac{30}{0.3} = 100 \text{ ម}$$

ដែល: - D : ចំងាយរវាងខ្សែរាប់ គិតជាម៉ែត្រ

- SI : កំរិតជម្រើស ដែលកំណត់យក 30%

- 30ម : ជាទទឹងឡូតិ៍គំរូ

**៥.១.៦. ការគណនាគំលាតរវាងអនុឡូតិ៍គំរូ**

ការគណនាគំលាតរវាងអនុឡូតិ៍គំរូ (អនុឡូតិ៍គំរូដែលមានទំហំ 30ម៉ែត្រx25ម៉ែត្រ 30ម៉ែត្រx50ម៉ែត្រ)តាមរូបមន្តដូចខាងក្រោម:

$$IG = \sqrt{S/N}$$

ដែល: - IG : ចន្លោះរវាងក្រឡាចក្រត្រង្គ (គិតជាម៉ែត្រ)

- S : ជាផ្ទៃដីសរុបតាមស្រទាប់ព្រៃនីមួយៗ (គិតជាម៉ែត្រការេ)

- N : ចំនួនអនុឡូតិ៍គំរូ

## ៥.២ ការរៀបចំផែនទីប្លង់ជម្រើស

### ៥.២.១. ការកំណត់អត្តសញ្ញាណ

- ខ្សែវាស់រាប់លេខ (ប្លង់លេខរូមាំង I,II,III.......)
- ឡូតិ៍គំរូលេខ (ប្លង់លេខអារ៉ាប់ 1,2,3.......)

### ៥.២.២. ការរៀបចំដាក់តាំងខ្សែវាស់រាប់ និង ឡូតិ៍គំរូ

- ការកំណត់ចំណុចគោល
- ការកំណត់ខ្សែវាស់រាប់និងឡូតិ៍គំរូៈដើម្បីងាយស្រួលស្វែងរកទីតាំងឡូតិ៍គំរូនៅទីវាលដាក់ស្លែងលេខរៀងជាខ្សែវាស់រាប់និយាមការចាប់ផ្តើមនិងបញ្ចប់នៃខ្សែវាស់ រាប់មុំទិសដៅខ្សែវាស់រាប់ និងប្រវែងខ្សែវាស់រាប់នីមួយៗ (មានបង្ហាញក្នុងផែនទីប្លង់ជំរើសភ្ជាប់ក្នុងឧបសម្ព័ន្ធ 1) ។

### ៥.២.៣. ការរៀបចំផែនទីប្លង់ជំរើស

ជ្រើសរើសផែនទីដែលមានមាត្រដ្ឋាន 1:3.000 ចំពោះផែនទីប្លង់ជម្រើសសម្រាប់ធ្វើសារពើភ័ណ្ឌវាយតម្លៃធនធានព្រៃឈើ និងផែនទីប្រភេទដី។

## ៥.៣. ការរៀបចំការងារសារពើភ័ណ្ឌ

- **ការរៀបចំព្រំប្រទល់អនុតំបន់** ៖ លាបថ្នាំពណ៌ក្រហមតាមបណ្តោយព្រំប្រទល់ដែលបានកាប់ឆ្ការ ឬមាន ដោយធម្មជាតិ។

- **ការរៀបចំខ្សែប្រលោះព្រៃ** ៖ ត្រៀយបើកប្រលោះព្រៃដែលមានទទឹងពី 1ម ឬ2ម និងបោះបង្គោលពីមួយទៅមួយប្រវែង 25ម ដោយមានការបាញ់ថ្នាំពណ៌ ក្រហមទៅបង្គោល ឬដើមឈើនៅក្បែរនោះ។ ចំងាយពីខ្សែប្រលោះព្រៃមួយទៅខ្សែមួយទៀតប្រវែង300ម៉ែត្រនិងធ្វើអត្តសញ្ញាណនៅនឹងគល់ខ្សែ ដោយដាក់ជាលេខសំរាប់សំគាល់តាមលំដាប់លំដោយ។

## ៥.៤ វិធីសាស្ត្រវាស់វែង

### ៥.៤.១ កំណត់ប៉ារ៉ាម៉ែត្រវាស់វែង

ប៉ារ៉ាម៉ែត្រត្រូវវាស់វែងក្នុងការងារសារពើភ័ណ្ឌរួមមានៈ អង្កត់ផ្ចិត($D_{1,30ម}$), កំពស់ ($H_{មែកទី1}$), និងរាប់ចំនួនដើមឈើ។

### ៥.៤.២ គោលការណ៍វាស់រាប់

- ប្រភេទឈើ ៖ រាប់ដើមឈើគ្រប់ប្រភេទដែលមានអង្កត់ផ្ចិតកំពស់ទ្រូង (1.30ម) ចាប់ពី5សង់ទីម៉ែត្រឡើងទៅ និងចំណាត់ថ្នាក់ប្រភេទ ត្រូវអនុវត្តន៍តាមប្រកាសលេខ ០៨៩ ប្រក.កសក ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០០៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក្នុងឧបសម្ព័ន្ធ 5) ស្តីពីប្រភេទឈើជាប់ក្នុងលំដាប់ថ្នាក់។
- អង្កត់ផ្ចិត ៖ វាស់ទំហំអង្កត់ផ្ចិតកំពស់ស្មើទ្រូង (1.30ម) ឬលើព្រីង0.65ម ពី នីវ៉ូដីលើសំបកដើមឈើគ្រប់ប្រភេទមានអង្កត់ផ្ចិតចាប់ពី៥សង់ទីម៉ែត្រឡើងទៅ។
- កំពស់ ៖ ប៉ាន់ស្មានកំពស់ដើមឈើត្រឹមមែកទី1 គ្រប់ប្រភេទឈើមានអង្កត់ផ្ចិតចាប់ពី 5ស.ម ឡើងទៅ។

## ៥.៥ ការប្រើប្រាស់ឧបករណ៍វាស់វែង

- វាស់ទំហំអង្កត់ផ្ចិត ៖ ប្រើខ្សែម៉ែត្រវាស់អង្កត់ផ្ចិត (Diameter tap)
- វាស់កំពស់ ៖ ប៉ាន់ស្មានដោយភ្នែកទទេ។

## ៥.៦ ការកំណត់គុណភាពឈើឈរ

ការវាយតំលៃគុណភាពឈើសំរាប់ដើមឈើនីមួយៗ ត្រូវបានផ្តល់ជាចំណាត់ថ្នាក់ដូចខាងក្រោមៈ

គុណភាព A : ដើមឈើដែលអាចផ្តល់ឈើហ៊ុបដោយគ្មានការខូចខាត។

គុណភាព B : ដើមឈើដែលអាចផ្តល់ឈើហ៊ុបមានការខូចខាតតិចតួចដែលអាចយក ទៅប្រើប្រាស់បាន។

គុណភាព C : ដើមឈើមិនអាចផ្តល់ឈើហ៊ុប ដែលប្រើប្រាស់បាននៅក្នុងរោងចក្រ អារឈើ ឬ ឧស្សាហកម្មក្តារបន្ទះពីព្រោះមានការខូចខាតច្រើន។

រូបភាពការវាស់អង្កត់ផ្ចិតដើមឈើ

រូបភាពទី1 ៖ ចំណុចវាស់អង្កត់ផ្ចិតនូវកំពស់ 1.3ម៉ែត្រពីនីវ៉ូដី




រូបភាពទី2 ៖ ករណីដើមឈើដុះនៅលើទីជម្រាលខ្លាំង ចំណុចវាស់អង្កត់ផ្ចិតត្រូវឈរវាស់នូវ



ផ្នែកខាងលើទីទួល

រូបភាពទី3 ៖ ករណីដើមចំពាម




- ករណីដើមចំពាម ប្រសិនបើចំណុចវាស់អង្កត់ផ្ចិតនូវកំពស់ 1.3ម៉ែត្រ ពីនីវូដី ចំពាម ហើយមានទំរង់ដើមធំជាងនោះ ការវាស់វែងអង្កត់ផ្ចិតត្រូវរំកិលចុះក្រោម ប្រមាណ30សង់ទីម៉ែត្រ គឺវាស់ត្រង់ចំណុច1ម៉ែត្រពីនីវូដី និងគិតជាឈើមួយដើម។
- ករណីចំណុចវាស់អង្កត់ផ្ចិតនូវកំពស់ 1.3ម៉ែត្រពីនីវូដីនៅពីលើចំពាមនោះ ចំណុចវាស់អង្កត់ផ្ចិតត្រូវធ្វើការវាស់វែងចំនួន 02លើក និងគិតជាឈើចំនួន 02 ដើម។

រូបភាពទី4៖ ករណីដើមឈើមានព្រឹងចំណុចវាស់អង្កត់ផ្ចិតត្រូវរំកិលទៅផ្នែកខាងលើព្រឹង 65សង់ទីម៉ែត្រ




រូបភាពទី5៖ ករណីចំណុចវាស់អង្កត់ផ្ចិតប៉ះចំពក ប្រហោង ស្នុយ មែក ជាដើម ចំណុចវាស់អង្កត់ផ្ចិតត្រូវអនិយ័ត




រូបភាពទី6៖ ករណីដើមឈើឬសអាកាសចំណុចវាស់អង្កត់ផ្ចិត ត្រូវគិតចាប់ពីចុងឬសទៅផ្នែកខាងលើ 1.3ម៉ែត្រ




រូបភាពទី7៖ ករណីដើមទ្រេត ចំណុចវាស់អង្កត់ផ្ចិត 1.3ម៉ែត្រពីនីវូដីត្រូវវាស់ផ្នែកខាងក្រោមទម្រេតដើម




## ៥.៧ ចាត់តាំងការងារអនុវត្តន៍ជាក់ស្តែងលើទីវាល

### ៥.៧.១ សមាសភាពក្រុមរៀបចំព្រំប្រទល់ និង ប្រឡោះព្រៃសារពើភ័ណ្ឌ

មានសមាជិកចំនួន 5 នាក់ ក្នុងនោះ ៖

- 1នាក់(អ្នកបច្ចេកទេស) ប្រធានក្រុមជាអ្នកប្រើឧបករណ៍ GPS និងកាន់ត្រីវិស័យតំរង់ទិស
- 2នាក់(កម្មករ) ជាអ្នកត្រាយបើកប្រឡោះព្រៃ
- 2នាក់(កម្មករ) ជាអ្នកទាញខ្សែម៉ែត្រវាស់ចំងាយតេបង្គោល វាយផ្លាក និង លាបថ្នាំពណ៌

**៥.៧.២ សមាសភាពក្រុមវាស់រាប់** មានសមាជិកចំនួន 7នាក់ ក្នុងនោះ៖

- 1នាក់(អ្នកបច្ចេកទេស) ប្រធានក្រុមដឹកនាំក្រុម និងកត់ត្រាលទ្ធផលវាស់រាប់
- 2នាក់ (អ្នកបច្ចេកទេស) វាស់អង្កត់ផ្ចិត ប៉ាន់ស្មានកំពស់ កំណត់គុណភាព និង ហៅឈ្មោះឈើ
- 2នាក់(កម្មករ) ត្រាយព្រៃ លាបថ្នាំសំគាល់ ធ្វើព្រំប្រទល់ឡូតិ៍ និង អនុឡូតិ៍គំរូ
- 2នាក់(កម្មករ) ជំនួយការវាស់អង្កត់ផ្ចិត ប៉ាន់ស្មានកំពស់ កំណត់គុណភាព និង ហោះឈ្មោះឈើ(ជាអ្នកស្គាល់ឈ្មោះឈើច្បាស់លាស់)

## ៥.៨ វិធានការកំណត់មាឌឈើ

ការកំណត់មាឌឈើឈរដោយប្រើសមីការមាឌ តាមលំដាប់ថ្នាក់អង្កត់ផ្ចិតតាមប្រភេទព្រៃដូចខាងក្រោម:

- **ប្រភេទព្រៃស្រោង**

ប្រភេទឈើ Dipterocarp

<15ស.ម មាឌ $= 0.022 + 3.4 D^2$

15ស.ម+ មាឌ $= 0.015 + 2.137 D^2 + 0.513 D^2 \cdot L$

ប្រភេទឈើ Non-dipterocarp

<30ស.ម មាឌ $= 0.03 + 2.8 D^2$

30ស.ម+ មាឌ $= -0.0023 + 2.947 D^2 + 0.262 D^2 \cdot L$

## ៥.៩ ការវិភាគទិន្នន័យធនធានឈើ

ទិន្នន័យក្នុងសាលាកប័ត្រសម្រង់ពត៌មានដើមឈើត្រូវបានបញ្ចូលក្នុងកម្មវិធី Microsoft Excel សំរាប់ធ្វើប្រព្រឹត្តិកម្មទិន្នន័យ។ ការវិភាគទិន្នន័យប្រើប្រាស់សមីការមាឌឈើ ខាងលើសំរាប់គណនាមាឌឈើឈរ។

## ៥.១០ ការបង្ហាញលទ្ធផលសារពើភ័ណ្ឌ

ទិន្នន័យធ្វើសារពើភ័ណ្ឌដែលប្រមូលបានពីទីធ្លាជាក់ស្តែងត្រូវបានបញ្ចូល និង វិភាគតាមកម្មវិធី Excel ហើយរៀបចំជាលទ្ធផលដាក់បង្ហាញក្នុងតារាងដូចខាងក្រោម:

- តារាងដង់ស៊ីតេកូនឈើសរុប តាមថ្នាក់អង្កត់ផ្ចិត និងប្រភេទឈើ
- តារាងបរិមាណមាឌឈើគុណភាពCដើមឈើដែលមានអង្កត់ផ្ចិតចាប់ពី5-30ស.ម
- តារាងឈ្មោះឈើ ដង់ស៊ីតេមាឌឈើក្នុង 1ហិកតា តាមថ្នាក់គុណភាពឈើឈរ (A, B, C) ចំពោះដើមឈើមានអង្កត់ផ្ចិតចាប់ពី 20 ទៅ30សង់ទីម៉ែត្រ
- តារាងឈ្មោះឈើ ដង់ស៊ីតេមាឌឈើក្នុង 1ហិកតា តាមថ្នាក់គុណភាពឈើឈរ (A, B, C) ចំពោះដើមឈើមានអង្កត់ផ្ចិតធំជាង 30 សង់ទីម៉ែត្រ
- តារាងឈ្មោះឈើ ដង់ស៊ីតេមាឌឈើ តាមថ្នាក់គុណភាពឈើឈរ (A, B, C) ចំពោះដើមឈើមានអង្កត់ផ្ចិតចាប់ពី 20 ទៅ 30 សង់ទីម៉ែត្រ
- តារាងឈ្មោះឈើ ដង់ស៊ីតេមាឌឈើ តាមថ្នាក់គុណភាពឈើឈរ (A, B, C) ចំពោះដើមឈើមានអង្កត់ផ្ចិតធំជាង 30សង់ទីម៉ែត្រ (បង្ហាញក្នុងឧបសម្ព័ន្ធ2)

### ៥.១១ ការសិក្សាអំពីសត្វ

- ដាក់តាំងឡូត៏សិក្សាលើបន្ទាត់ត្រង់ស៊ិច 30ម គុណ 250ម
- សិក្សាលើដានដែលបានបន្សល់ទុកនៅក្នុងព្រៃ
- ប្រើប្រាស់ព័ត៌មានដែលមានស្រាប់
- ប្រើប្រាស់បញ្ជីសំនួរសម្ភាសន៏សហគមន៏មូលដ្ឋានដែលរស់នៅក្បែរ ក្នុងព្រៃ

### ៥.១២ ការប៉ាន់ស្មានជីវម៉ាស់នៅលើដី និងកាបូនស្តុក

#### *៥.១២.១ ការប៉ាន់ស្មានជីវម៉ាស់*

ការប៉ាន់ស្មានជីវម៉ាស់នៅលើដី (Above Ground Biomass)គឺអនុវត្តតាមរូបមន្តរបស់លោក Brown ឆ្នាំ ១៩៩៧ ដែលបង្ហាញដូចខាងក្រោម៖

$$AGB = VOB \times WD \times BEF$$

ដែល - AGB ជាជីវម៉ាស់លើដី (Above Ground Biomass)

- VOB មាឌឈើគិតទាំងសំបក
- WD ដង់ស៊ីតេឈើ WD = 0,57 (UNFCCC)
- BEF មេគុណពង្រីក

ចំពោះមេគុណពង្រីក មានរបៀបគណនាដូចខាងក្រោម៖

$$BEF = \mathrm{Exp}\{3.213 - 0.506 * \mathrm{Ln}(BV)\} \text{ for } BV < 190 \text{ t/ha}$$

$$= 1.74 \text{ for } BV >= 190 \text{t/ha}$$

(ដែល BV ជាជីវម៉ាស់របស់មាឌឈើ បានមកពីការធ្វើសារពើភ័ណ្ឌព្រៃឈើគិតជា t/ha)

តាមឯកសារបស់លោក Sakasi Nophear បានបង្ហាញថា ជីវម៉ាសក្រោមដី (Bellow Ground Biomass) ស្មើនឹង 30% នៃជីវម៉ាស់លើដី។

#### *៥.១២.២ ការប៉ាន់ស្មានកាបូនស្តុក*

- ការគណនាបរិមាណកាបូនស្តុកនៅលើដើមឈើ ឬកំណើនកាបូននៅក្នុងព្រៃឈើ គេប្រើប្រាស់រូបមន្ត៖

$C_{(above\ ground)} = AGB \times r_c$

- បរិមាណកាបូនស្តុកក្នុងដើមឈើ (ផ្នែកខាងលើដី និងផ្នែកឫស)

$C_{(hold\ tree)} = HTB \times r_c$ (ដែល HTB ជាជីវម៉ាស់ដើមឈើទាំងមូល)

- បរិមាណនៃ $CO_2$ គណនាដោយរូបមន្ត (Kakada K., 2006)៖

$CO_2 = 44/12 \times AGB \times r_c$

## ៦.លទ្ធផលវាយតម្លៃធនធានព្រៃឈើ

### ៦.១ ការប្រើប្រាស់ដី និង ចំណាត់ថ្នាក់ប្រភេទព្រៃ

គម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីរបស់ក្រុមហ៊ុនអភីប៊ី អ៊ិនវេសមេន ខូអិលធីឌី ជាប្រភេទគម្រោងនៃការអភិវឌ្ឍរមណីយដ្ឋានសណ្ឋាគារប្រភេទផ្ទះវីឡាទំនើបចំនួន 29 ផ្ទះវីឡា ដោយមានផ្ទៃក្រឡាប៉ាន់ស្មានសរុបដែលត្រូវ

សាងសង់នៅលើកោះមានទំហំ 8,570 ម៉ែត្រការេ រួមមានផ្ទៃក្រឡាសម្រាប់សាងសង់តំបន់រួមមានទំហំ 6,950 ម៉ែត្រការេ និងផ្ទៃក្រឡាសម្រាប់សាងសង់តំបន់ខាងក្រោយផ្ទះទំហំ 1,620 ម៉ែត្រការេ។

ក្នុងការវិនិយោគនេះ ក្រុមហ៊ុនបានកំណត់ទីតាំងសាងសង់ផ្ទះនៅទីវាលជាក់ស្តែងយោងតាមប្លង់គំរូចជាស្រេចហើយ ដោយការដាក់តាំងប្លង់នេះគឺធ្វើទៅតាមប្លង់មេ និងព្យាយាមជៀសវាងការកាប់ព្រៃឈើជាអតិបរមាតាមរយៈការរំកិលប្លង់ប្រសិនបើនៅពេលដាក់តាំងប៉ះចំដើមឈើធំចាប់ពីមុខកាត់ 20 ស.ម ឡើងទៅដែលត្រូវរក្សាទុកនោះក្រុមហ៊ុនត្រូវបង្វែទិសដៅទីតាំងសាងសង់វិញទោះបីជាប្លង់មេបានកំណត់រួចហើយក៏ដោយ។

**៦.២ ផ្ទៃដីដែលត្រូវធ្វើការវាយតម្លៃធនធានឈើ**

តាមរយៈការចុះដាក់តាំងឡូតិ៍-អនុឡូតិ៍គំរូសម្រាប់ធ្វើសារពើភ័ណ្ឌវាយតម្លៃធនធានព្រៃឈើបង្ហាញថាផ្ទៃដីព្រៃឈើជាក់ស្តែងដែលនឹងធ្វើការវាយតម្លៃមានទំហំត្រឹមតែ 10ហិកតាប៉ុណ្ណោះ សុទ្ធតែជាព្រៃស្រោង ដោយរាប់បញ្ចូលទាំងតំបន់ដែលត្រូវសាងសង់ផងដែរ។

ជាលទ្ធផលនៃការដាក់តាំងឡូតិ៍-អនុឡូតិ៍គំរូសម្រាប់ធ្វើសារពើភ័ណ្ឌវាយតម្លៃ ប៉ាន់ស្មានធនធានព្រៃឈើនៅលើកោះក្របី ក្រុមការងារបានដាក់តាំងឡូតិ៍សិក្សាបានគ្រប់ចំនួនតាមលំដាប់ថ្នាក់អង្កត់ផ្ចិតដូចខាងក្រោម៖

- អង្កត់ផ្ចិតកំពស់(1.30ម) ចាប់ពី 5-14សម សិក្សាចំនួន 11 ឡូតិ៍គំរូ
- អង្កត់ផ្ចិតកំពស់(1.30ម)ចាប់ពី15-30សម សិក្សាចំនួន 11 ឡូតិ៍គំរូ
- អង្កត់ផ្ចិតកំពស់(1.30ម)ធំជាង30សម សិក្សាចំនួន 11 ឡូតិ៍គំរូ

**៦.៣ ស្ថានភាពគម្របព្រៃឈើតំបន់សិក្សា**

ការគណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) តំបន់អភិវឌ្ឍរមណីយដ្ឋានកោះក្របីមានផ្ទៃដីទំហំ 12 ហិកតា ដោយប្រើប្រាស់ផែនទីគម្របព្រៃឈើឆ្នាំ 2002 ឆ្នាំ 2006 និងឆ្នាំ 2010 ដើម្បីពិនិត្យស្ថានភាពគម្របព្រៃឈើបង្ហាញថាព្រៃឈើតំបន់នេះក្នុងរយៈ 10 ឆ្នាំកន្លងមកពុំមានភាពប្រែប្រួលទេ។

តាមការពិនិត្យពីទិដ្ឋភាពជាក់ស្តែងនៃតំបន់អភិវឌ្ឍគម្រោងឃើញថា ស្ថានភាពព្រៃឈើជាព្រៃស្រោងដែលមានដើមឈើធំៗដុះភាគច្រើនមានអង្កត់ផ្ចិតចាប់ពី 30ស.មឡើងទៅ ហើយពុំសូវមានរុក្ខជាតិស្រទាប់ក្រោមនោះទេ។ ភាពមិនសូវមានរុក្ខជាតិស្រទាប់ក្រោមដុះ ដោយសារនៅពេលចុះសិក្សាស្រាវជ្រាវក្រុមហ៊ុនបានចាប់ផ្តើមកំណត់ទីតាំងប្លង់សម្រាប់សាងសង់ផ្ទះវីឡារួចជាស្រេច ដែលការដាក់តាំងនេះទាមទារបោសសំអាតរុក្ខជាតិស្រទាប់ក្រោមជាមុនសិន ។ ដោយឡែកចំពោះភាពមិនប្រែប្រួលគម្របព្រៃឈើនៃតំបន់នេះ មកពីកោះនេះមានទីតាំងស្ថិតនៅឆ្ងាយពីភូមិដែលប្រជាជនរស់នៅ និង ភាគច្រើនពួកគាត់ប្រកបរបរជាអ្នកនេសាទ។

**៦.៤ ធនធានឈើ**

ការប៉ាន់ស្មានធនធានព្រៃឈើដែលមានវត្តមានក្នុងតំបន់គម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របី របស់ក្រុមហ៊ុនអគីប៊ី អ៊ិនវេសមេន ខូអិលធីឌី បានអនុវត្តនតាមលក្ខណៈបច្ចេកទេស និងទទួលបានលទ្ធផលដូចខាងក្រោមៈ

**៦.៤.១ ព័ត៌មានជាមូលដ្ឋាន**

**ក. បរិមាណកូនឈើ៖** (គិតជាដើម)

- ប្រភេទឈើ ៖ គ្រប់ប្រភេទឈើ
- គុណភាពឈើ ៖ កូនឈើដែលមានគុណភាពA+B (គុណភាព C ជាឈើ ខូចគុណភាព)
- ទំហំអង្កត់ផ្ចិត ៖ ដើមឈើដែលមានទំហំអង្កត់ផ្ចិតពី 5ស.ម ទៅ 30ស.ម (លើកលែងប្រភេទឈើប្រណិតដែលមានទំហំអង្កត់ផ្ចិតចាប់ពី15ស.មឡើងទៅ)

- ទំហំផ្ទៃដីជំណុះឈើ ៖ គិតអត្រាពយប៉ាយនៃគំរបព្រៃ និងមិនគិតបញ្ចូលនូវផ្ទៃដីផ្លូវ ប្រព័ន្ធទឹកស្រែ-ចំការ និង តំបន់ភ្នំមានចំណោទខ្ពស់ ។

**ខ. បរិមាណឈើហ៊ុបះ** ( គិតជាដើម និង មាឌ)

- ប្រភេទឈើ ៖ គ្រប់ប្រភេទឈើ
- គុណភាពឈើ ៖ ដើមឈើដែលមានគុណភាព A, B និង C
- ទំហំអង្កត់ផ្ចិត ៖ ដើមឈើដែលមានទំហំអង្កត់ផ្ចិតធំជាង 30ស.ម (ចំពោះដើមឈើមានគុណភាព C គិតជាមាឌចាប់ពីអង្កត់ផ្ចិត 5ស.ម ឡើង និង ដើមឈើប្រភេទប្រណិតដែលមានទំហំអង្កត់ផ្ចិតចាប់ពី 15ស.ម ឡើងទៅ)។
- ទំហំផ្ទៃដីជំណុះឈើ ៖ គិតអត្រាពយប៉ាយនៃគំរបព្រៃ និងមិនគិតបញ្ចូលនូវផ្ទៃដី ផ្លូវ ប្រព័ន្ធទឹកស្រែ-ចំការ និង តំបន់ភ្នំមានចំណោទខ្ពស់។
- បរិមាណមាឌឈើសុទ្ធ៖ អត្រាបំលែងមាឌឈើសរុបមកមាឌឈើសុទ្ធស្មើនិង 80%

### ៦.៤.២ ធនធានឈើ

លទ្ធផលនៃការសិក្សាវាយតម្លៃធនធានព្រៃឈើមានបីកម្រិតផ្សេងៗគ្នាគឺ៖

-ឈើឈរគិតជាកូនឈើ (គ្រប់ប្រភេទឈើដែលមានទំហំអង្កត់ផ្ចិតពី 5-30ស.ម និង មានកំពស់ចាប់ពី៣ម៉ែត្រឡើងទៅ)

- ឈើឈរគុណភាព C (គ្រប់ប្រភេទឈើដែលមានថ្នាក់អង្កត់ផ្ចិតពី5-30សម)

- ឈើឈរគិតជាឈើហ៊ុបមូល (ដើមឈើមានគុណភាព A ,B និង C មានទំហំអង្កត់ផ្ចិតធំជាង30ស.ម និងដើមឈើប្រភេទប្រណិតដែលមានទំហំអង្កត់ផ្ចិតចាប់ពី 15ស.មឡើងទៅ)

ជាលទ្ធផលសារពើភណ្ឌប៉ាន់ស្មានធនធានព្រៃឈើ និង ពត៌មានជាមូលដ្ឋានខាងលើការប៉ាន់ស្មានធនធានព្រៃឈើឈរសរុបមានដូចខាងក្រោម:

តារាងទី ២៖ បរិមាណធនធានឈើឈរប៉ាន់ស្មានសរុបក្នុងផ្ទៃដីធ្វើអាជីវកម្ម

| ថ្នាក់ប្រភេទឈើ | កូនឈើតាមគុណភាព និងអង្កត់ផ្ចិត | | | | មាឌឈើឈរសរុបតាមគុណភាព | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | A + B | | | C | A | | B | | C | |
| | ដើម | ដើម | ដើម | មាឌ (ម៣) | ដើម | មាឌ (ម៣) | ដើម | មាឌ (ម៣) | ដើម | មាឌ (ម៣) |
| | | | | | ដើមឈើមានអង្កត់ផ្ចិតចាប់ពី 15-30ស.ម | | | | | |
| ប្រណីត | | | | | 0 | 0.000 | 0 | 0.000 | 21 | 2.975 |
| | D<15 | D 15-19 | D 20-30 | D5-30 | ដើមឈើមានអង្កត់ផ្ចិតធំជាង 30ស.ម | | | | | |
| ប្រណីត | 0 | 0 | 0 | 1.869 | 0 | 0.000 | 0 | 0.000 | 0 | 0.000 |
| លេខ 1 | 21 | 11 | 0 | 4.351 | 0 | 0.000 | 8 | 4.809 | 16 | 16.519 |
| លេខ 2 | 32 | 0 | 0 | 3.356 | 0 | 0.000 | 13 | 9.538 | 0 | 0.000 |
| លេខ 3 | 0 | 16 | 16 | 17.096 | 0 | 0.000 | 51 | 40.826 | 123 | 89.475 |
| ក្រៅលំដាប់ | 245 | 32 | 91 | 92.370 | 3 | 2.493 | 80 | 68.151 | 205 | 162.199 |
| សរុប | **299** | **59** | **107** | **119.042** | **3** | **2.493** | **152** | **123.324** | **344** | **268.192** |

ក-ឈើឈរគិតជាកូនឈើ (គ្រប់ប្រភេទឈើដែលមានទំហំអង្កត់ផ្ចិតពី 5-30ស.ម និង មានកំពស់ចាប់ពី 3 ម៉ែត្រឡើងទៅ) រួមមាន:

- ប្រភេទប្រណីត

កូនឈើដែលជាប្រភេទឈើប្រណិតដែលមានអង្កត់ផ្ចិតតូចជាង 5 ស.ម ទៅ 30ស.ម ពុំមានវត្តមានក្នុងតំបន់សិក្សាទេ។

- ប្រភេទលេខ1

| | | | |
|---|---|---|---|
| - ទំហំអង្កត់ផ្ចិតតូចជាង 15 សម | ចំនួន | 21 ដើម | (2.13 ដើម/ហ.ត) |
| - ទំហំអង្កត់ផ្ចិតតូចពី 15សម-19សម | ចំនួន | 11 ដើម | (1.07 ដើម/ហ.ត) |
| - ទំហំអង្កត់ផ្ចិតតូចពី 20សម-30សម | ចំនួន | 0 ដើម | (0 ដើម/ហ.ត) |

- ប្រភេទលេខ2

| | | | |
|---|---|---|---|
| - ទំហំអង្កត់ផ្ចិតតូចជាង 15 សម | ចំនួន | 32 ដើម | (3.20 ដើម/ហ.ត) |
| - ទំហំអង្កត់ផ្ចិតតូចពី 15សម-19សម | ចំនួន | 0 ដើម | (0 ដើម/ហ.ត) |
| - ទំហំអង្កត់ផ្ចិតតូចពី 20សម-30សម | ចំនួន | 0 ដើម | (0 ដើម/ហ.ត) |

- ប្រភេទលេខ3

| | | | |
|---|---|---|---|
| - ទំហំអង្កត់ផ្ចិតតូចជាង 15សម | ចំនួន | 0 ដើម | (0 ដើម/ហ.ត) |
| - ទំហំអង្កត់ផ្ចិតតូចពី 15សម-19សម | ចំនួន | 16 ដើម | (1.60 ដើម/ហ.ត) |
| - ទំហំអង្កត់ផ្ចិតតូចពី 20សម-30សម | ចំនួន | 16 ដើម | (1.60 ដើម/ហ.ត) |

- ប្រភេទក្រៅលំដាប់ថ្នាក់

| | | | |
|---|---|---|---|
| - ទំហំអង្កត់ផ្ចិតតូចជាង 15សម | ចំនួន | 245 ដើម | (24.53 ដើម/ហ.ត) |
| - ទំហំអង្កត់ផ្ចិតតូចពី 15សម-19សម | ចំនួន | 32 ដើម | (3.20 ដើម/ហ.ត) |
| - ទំហំអង្កត់ផ្ចិតតូចពី 20សម-30សម | ចំនួន | 91 ដើម | (9.06 ដើម/ហ.ត) |

ខ-ឈើឈរគុណភាព C (គ្រប់ប្រភេទឈើដែលមានថ្នាក់អង្កត់ផ្ចិតពី5-30សម) ចំនួន 119ម$^3$042 (11ម$^3$904/ហ.ត) រួមមាន :

| | | | |
|---|---|---|---|
| • ប្រភេទប្រណីត | ចំនួន | 1ម$^3$869 | (0ម$^3$187/ហ.ត) |
| • ប្រភេទលេខ1 | ចំនួន | 4ម$^3$351 | (0ម$^3$435/ហ.ត) |
| • ប្រភេទលេខ2 | ចំនួន | 3ម$^3$356 | (0ម$^3$335/ហ.ត) |
| • ប្រភេទលេខ3 | ចំនួន | 17ម$^3$096 | (1ម$^3$710/ហ.ត) |
| • ប្រភេទក្រៅលំដាប់ថ្នាក់ | ចំនួន | 92ម$^3$370 | (9ម$^3$237/ហ.ត) |

គ- ឈើឈរគិតជាឈើហ៊ុបមូល (ដើមឈើមានគុណភាព A ,B និង C មានទំហំអង្កត់ផ្ចិតធំជាង 30ស.ម និងដើមឈើប្រភេទប្រណិត ដែលមានទំហំអង្កត់ផ្ចិតចាប់ពី 15ស.ម ឡើងទៅ) រួមមាន:

- ប្រភេទប្រណីត
  - ដើមឈើមានអង្កត់ផ្ចិតចាប់ពី 15សម.-30សម. មានគុណភាព C ចំនួន 2ម$^3$975 (0ម$^3$297/ហ.ត)
  - ដើមឈើមានអង្កត់ផ្ចិតធំជាង 30សម គ្រប់គុណភាពឈើពុំមាននោះទេ។
- ប្រភេទលេខ1 មានគុណភាព B ចំនួន 4ម$^3$809 (0ម$^3$481/ហ.ត) និងគុណភាព C ចំនួន 16ម$^3$519 (1ម$^3$652/ហ.ត)
- ប្រភេទលេខ២ មានគុណភាព B ចំនួន 9ម$^3$538 (0ម$^3$954/ហ.ត)

- ប្រភេទលេខ៣ គុណភាព B ចំនួន 40ម$^3$826 (4ម$^3$083/ហ.ត) និងគុណភាព C ចំនួន 89ម$^3$475 (8ម$^3$948/ហ.ត)
- ប្រភេទក្រៅលំដាប់ថ្នាក់មានគុណភាព A ចំនួន 2ម$^3$493(0ម$^3$249/ហ.ត) គុណភាព B ចំនួន 68ម$^3$151 (6ម$^3$815/ហ.ត) និងគុណភាព C ចំនួន 162ម$^3$199 (16ម$^3$220/ហ.ត)។

### ៦.៤.៣ ការប៉ាន់ស្មានជីវម៉ាស់ និងការបូនស្តុកនៅក្នុងតំបន់គម្រោង

#### ៦.៤.៣.១ ការប៉ាន់ស្មានជីវម៉ាស់

ការប៉ាន់ស្មានជីវម៉ាស់ព្រៃឈើបានអនុវត្តតាមគោលការណ៍ណែនាំរបស់អង្គការស្បៀងអាហារ និងកសិកម្ម (FAO) ដែលជំហ៊ានសំខាន់ៗក្នុងការសិក្សាមានបីដំណាក់កាលគឺការគណនាជីវម៉ាស់នៃមាឌឈើដែលបានមកពីទិន្នន័យធ្វើសារពើភ័ណ្ឌព្រៃឈើ គណនាមេគុណបញ្ចូញជីវម៉ាស់ និងគណនាជីវម៉ាស់លើដី (AGB)។ តារាងខាងក្រោមបង្ហាញអំពីទិន្នន័យនៃការគណនាជីវម៉ាស់លើដីក្នុងផ្ទៃដីមួយហិកតា ក្នុងតំបន់គម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីរបស់ក្រុមហ៊ុនអភីប៊ី អ៊ិនវេសមេន ខូអិលធីឌី។

តារាងទី 3៖ ការប៉ាន់ស្មានជីវម៉ាសលើដីក្នុងផ្ទៃដីមួយហិកតា

| ប្រភេទព្រៃឈើ | មាឌឈើ (VOB ម៣/ហ.ត) | ដង់ស៊ីតេ (WD ត/ម៣) | ជីវម៉ាស់មាឌឈើ (BV ត/ហ.ត) | មេគុណពង្រីក (BEF) | ជីវម៉ាស់លើដី (AGB ត/ហ.ត) |
|---|---|---|---|---|---|
| ព្រៃស្រោង | | | | | |
| កូនឈើ | 9.210 | 0.57* | 5.247 | 10.742 | 56.368 |
| អុស | 19.065 | | 10.867 | 7.432 | 80.766 |
| ឈើហ៊ុប | 12.582 | | 7.172 | 9.172 | 65.775 |
| *សរុប* | 40.853 | | 23.286 | | 202.909 |

ចំណាំ៖ * : តំលៃដង់ស៊ីតេជាមធ្យម ត/ម៣ (Reyes et al. 1992)

តាមតារាងទី 3 បង្ហាញថា បរិមាណជីវម៉ាស់លើដីនៃតំបន់សិក្សាមានប្រហែលជា 202.909 តោន/ហ.ត ដែលបរិមាណនេះប្រហាក់ប្រហែលនឹងទិន្នន័យឧបសម្ព័ន្ធជីវៈម៉ាស់ព្រៃឈើដែលសិក្សាដោយ អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ ។ ជាទូទៅក្នុងការគណនាជីវម៉ាស់ព្រៃឈើ គេគិតទាំងជីវម៉ាស់លើដី និង ជីវម៉ាស់ក្រោមដី ដែលជីវម៉ាស់ក្រោមដីតាមឯកសាររបស់អង្គការ FAO និងលោក Sakasi Nophear គឺយកតំលៃស្មើនឹង 30% នៃចំនួនជីវម៉ាស់លើដី។ ដូច្នេះលទ្ធផលនៃការប៉ាន់ស្មានជីវម៉ាស់ព្រៃឈើក្នុងតំបន់គម្រោងអភិវឌ្ឍន៍កោះក្របីលើផ្ទៃដីចំនួន 10ហិកតា ស្មើនឹង 2,637.817 តោនជីវម៉ាស់ ដែលគិតជាបរិមាណក្នុងមួយហិកតាគឺ 263.781 តោន។

#### ៦.៤.៣.២ ការប៉ាន់ស្មានកាបូនស្តុក

បរិមាណកាបូនស្តុកនៅលើដើមឈើ ឬកំណើនកាបូននៅក្នុងព្រៃឈើនៃតំបន់គម្រោងអភិវឌ្ឍកោះក្របី ស្មើនឹង 50% ($r_c$=50%) នៃបរិមាណជីវម៉ាស់សរុបដែលបានគណនារួចខាងលើ។ ដូចនេះតំបន់សិក្សាមានទំហំ 10ហិកតា ដែលជាប្រភេទព្រៃស្រោងគឺមានបរិមាណកាបូនស្តុកប្រមាណជា 1,318.908តោន បើគិតជាបរិមាណឧស្ម័នកាបូនិច ($CO_2$)គឺ 4,835.997 តោន។

### ៦.៤.៤ ការប៉ាន់ស្មានតំលៃឈើឈរ

ការប៉ាន់ស្មានតំលៃឈើឈរនៅក្នុងតំបន់គម្រោងអភិវឌ្ឍកោះក្របីអនុវត្តទៅតាមប្រកាសលេខ 1276សហវ.ប្រក ចុះថ្ងៃទី25ខែធ្នូឆ្នាំ2009 ស្តីពីការកំណត់ថ្លៃសួយសារលើឈើឈរដើម្បីបង់ចំណូលថវិកាជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ដូចជូនភ្ជាប់ ក្នុងឧបសម្ព័ន្ធ V)។

ជាលទ្ធផលបង្ហាញថាធនធានព្រៃឈើនៃតំបន់គម្រោងអភិវឌ្ឍកោះក្របី ដែលមានផ្ទៃដីព្រៃស្រោងទំហំ 10 ហិកតា រួមមានអុសចំរុះប្រភេទចំនួន 390ម៣210 និងកូនឈើចំរុះប្រភេទចំនួន 465ដើម ដែលគិតជាទឹកប្រាក់សរុបប្រហែលជា 5,679,300រៀល ស្មើនឹង 1,419.841 ដុល្លា។ ដោយឡែកប្រភេទឈើមូលដែលអង្កត់ផ្ចិតធំជាង 30សម. ឡើងទៅមានចំនួន 125ម៣817 គិតជាទឹកប្រាក់ប្រហែលជា 3,986.757ដុល្លា។ ដូច្នេះតំលៃឈើឈរដែលប៉ាន់ស្មានក្នុងតំបន់គម្រោងអភិវឌ្ឍកោះក្របីសរុបគឺ 5,406.598 ដុល្លា។

តារាងទី 4: ការប៉ាន់ស្មានតំលៃឈើឈរក្នុងផ្ទៃដីព្រៃឈើទំហំ 10 ហិកតា

| ល.រ | ការពិពណ៌នា | ប្រភេទឈើ | តំលៃ/ឯកត្តា | បរិមាណ | តំលៃសរុប (រៀល) |
|---|---|---|---|---|---|
| 1 | អុសចំរុះ | - | 6,500 រៀល/ម៣ | 390ម៣210 | 2,536,300 |
| 2 | កូនឈើចំរុះ | ឈើគ្រប់ប្រភេទ(D<15ស.ម) | 2000រៀល/ដើម | 299 ដើម | 598,000 |
| 3 | កូនឈើអង្កត់ផ្ចិត (D=15-30ស.ម) | លេខ 1 | 20,000រៀល/ដើម | 11 ដើម | 220,000 |
| | | លេខ ៣ និង ក្រៅលំដាប់ថ្នាក់ | 15,000រៀល/ដើម | 155 ដើម | 2,325,000 |
| | | | | *សរុប* | 5,679,300 |
| | | | | *គិតជាដុល្លា (អត្រា 1 ដុល្លា = 4000 រៀល)* | ***$ 1,419.841*** |
| | | | *(ដុល្លា/ម៣)* | *(គិតជាម៣)* | *(គិតជាដុល្លា)* |
| 4 | ឈើមូល (D >30សម) | លេខ 1 | 82.5 | 4.809 | $ 396.742 |
| | | លេខ ២ | 55 | 9.538 | $ 524.590 |
| | | លេខ ៣ និងក្រៅលំដាប់ ថ្នាក់ | 27.5 | 111.470 | $ 3065.425 |
| | | | *សរុប* | *125.817* | $ 3,986.757 |
| | | | | *សរុបរួម* | **$ 5,406.598** |

## ៦-៤-៥ ប្រភេទរុក្ខជាតិក្នុង IUCN Red List

លទ្ធផលនៃការធ្វើសារពើភ័ណ្ឌវាយតម្លៃធនធានព្រៃឈើក្នុងតំបន់អនុវត្តគម្រោងអភិវឌ្ឍកោះក្របី បានរកឃើញថាមានប្រភេទរុក្ខជាតិចំនួនតែ 3 ប្រភេទដែលស្ថិតនៅក្នុងបញ្ជី IUCN Red List មានដូចជា អង្កត់ខ្មៅ ផ្ចឹក និងដូនចែម ក្នុងនោះដើមឈើអង្កត់ក៏ជាប្រភេទមានដោយកម្រដែលកំណត់ដោយប្រកាសលេខ 089 ប្រក.កសក ចុះថ្ងៃទី 14 ខែកុម្ភៈ ឆ្នាំ 2005 របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

តារាងទី ៥: ប្រភេទរុក្ខជាតិដែលរងគ្រោះថ្នាក់ រងការគំរាមកំហែង និងមានដោយកម្រ

| ល.រ | ប្រភេទឈើ | ឈ្មោះវិទ្យាសាស្ត្រ | ចំណាត់ថ្នាក់ | មានដោយកម្រ | កម្រិតគំរាមកំហែង | IUCN Red List |
|---|---|---|---|---|---|---|
| 1 | អង្កត់ខ្មៅ | *Diospyros bejaudi*,Loc | LC | ប្រកាសលេខ 089ប្រក.កសក | 4 | |
| 2 | ដូនចែម | Tarrietia javanica, Bl | 1 | | 3 | |
| 3 | ផ្ចឹក | *Anisoptera costata* Korth | 2 | | 2 | EN |

កំណត់សំគាល់៖

- EN : Endangered (ប្រភេទជិតផុតពូជ) VU : Vulnerable (ប្រភេទងាយរងគ្រោះ)
- កម្រិតគំរាមកំហែង (5: ប្រភេទងាយរងគ្រោះថ្នាក់ 4 : ប្រភេទរងគ្រោះថ្នាក់ 1-3 : ប្រភេទរងគំរាមកំហែង)

## ៦-៥-ប្រភេទសត្វព្រៃលើគោក និងសត្វក្នុងទឹក

### ៦.៥.១ ប្រភេទសត្វលើគោក

ការសិក្សាប្រភេទសត្វព្រៃលើគោក និងសត្វក្នុងទឹកនៅតំបន់អនុវត្តគម្រោងអភិវឌ្ឍកោះក្របីធ្វើឡើងដោយការចុះអង្កេត និងសម្ភាសន៍ប្រជាពលរដ្ឋដែលធ្លាប់នេសាទជុំវិញតំបន់នេះ និងចូលចតរីស្នាក់នៅលើកោះ។ ការចុះអង្កេតមានលក្ខណៈងាយស្រួល ដោយសារតំបន់នេះមានទំហំផ្ទៃដីព្រៃឈើត្រឹមតែ 10ហិកតា ប៉ុណ្ណោះដែលធ្វើឲ្យក្រុមការងារវាយតម្លៃបានឆាប់រហ័ស។

តាមការសម្ភាសន៍ប្រជាជនដែលជាអ្នកនេសាទ និងរស់នៅក្បែរតំបន់នោះបានបង្ហាញឲ្យដឹងថាទីតាំងនេះពុំមានសត្វព្រៃធំៗរស់នៅទេគឺមានតែប្រភេទសត្វតូចៗមួយចំនួនដូចជា៖

- **ថនិកសត្វ៖** កណ្ដុរ (*Berylmys berdmorei*) កំប្រុក (*Hylopetes sp*) ប្រម៉ា (*Hystrix brachyuran*) ជ្រូង (*Pteropus sp*) និងប្រចៀវ (*Hipposideros diadema*)។
- **ឧរង្គសត្វ រីល្មូន៖** ត្រកួត (*Varanus bengalensis*) ពស់ព្រៃ (*Pytas korros*) ពស់វែកក្របី (*Naja kaouthia*) ពស់វែកដំបូក (*Naja Siamensis*) តុកកែ (*Gekko gecko*) អន្សង (*Varanus salvator*) ពស់ខ្សែគោ (*Amphiesma Stolata*) និង បង្គួយព្រៃ (*Acanthosaura lepidogaster*)។
- **សត្វស្លាប ៖** ត្រចៀកកាំ (*Hirundo rustica*) ពពិចខ្មៅ (*Hypsipetes leucocephalus*) ញ៉ាង (*Aceros undulatus*) ស្ទាំង (*Accipiter badius*) ចាបពូក (*Ploceus hypoxanthus*) និងកេងកងតូច (*Anthracoceros albirostris*)។

ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយឧបសម្ព័ន្ធ CITES និងបញ្ជីក្រហម IUCN Red List បង្ហាញថាប្រភេទសត្វមួយចំនួនដែលមានវត្តមាននៅតំបន់សិក្សាជាប្រភេទសត្វដែលមានដោយកម្រ រងការគំរាមកំហែង និងជិតផុតពូជផងដែរ។ ចំពោះកម្រិតនៃការគំរាមកំហែង និងជិតផុតពូជនៃប្រភេទសត្វទាំងនោះសូមមើលក្នុងឧបសម្ព័ន្ធទី៤ ។ ដោយឡែកក៏មានប្រភេទសត្វមួយចំនួនពុំមានកំណត់ត្រានៅក្នុងបញ្ជីក្រហម IUCN Red List ទេ ប៉ុន្តែត្រូវបានការពារដោយប្រកាសអនុក្រឹត្យ និងច្បាប់ដូចជា៖

- តុកកែ ត្រូវបានការពារដោយប្រកាសលេខ 020 ប្រក.កសក ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំណាត់ថ្នាក់ និងបញ្ជីប្រភេទសត្វព្រៃ ចុះថ្ងៃទី 25ខែមករាឆ្នាំ 2007។
- ត្រកួត ត្រូវបានការពារក្រោមច្បាប់ស្តីពីព្រៃឈើ ឆ្នាំ 2002 និងអនុក្រឹត្យលេខ 053អនក្រ.បក ចុះថ្ងៃទី 29 ខែឧសភាឆ្នាំ2006 ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់។
- ពស់វែក ពុំមានចុះក្នុងបញ្ជី IUCN ទេ តែក្នុងCITES ស្ថិតក្នុងឧបសម្ព័ន្ធលេខ II និងការពារដោយច្បាប់ស្តីពីព្រៃឈើ ឆ្នាំ 2002។

### ៦.៥.២ ប្រភេទសត្វក្នុងទឹក

តាមការសាកសួរព័ត៌មានពីប្រជាជនដែលជាអ្នកនេសាទនៅក្បែរតំបន់សិក្សា បានបង្ហាញថាជាទូទៅមានផលជលផលប្រមាណជា 36 ប្រភេទដែលត្រូវបានគេនេសាទបានដោយមានភ្ជាប់បញ្ជីរាយនាមនៅក្នុងឧបសម្ព័ន្ធទី៤

នៃរបាយការណ៍។ ប៉ុន្តែប៉ុន្មានឆ្នាំកន្លងមកនេះប្រជានេសាទទាំងនោះពុំអាចដឹងថាតើធនធានជលផលនៅជុំវិញតំបន់កោះក្របីមានការប្រែប្រួលយ៉ាងណានោះទេ ដោយសារក្រុមហ៊ុនពុំអនុញ្ញាតឲ្យនេសាទក្បែរតំបន់កោះឡើយ។ ការនេសាទអាចធ្វើទៅបានយ៉ាងហោចណាស់ស្ថិតនៅចម្ងាយប្រមាណជា 200-250 ម៉ែត្រពីកោះក្របី។ ការដាក់បម្រាមនេះគឺក្នុងគោលបំណងថែរក្សា ការពារ និងអភិរក្សជីវចម្រុះធនធានជលផល ក៏ដូចជាធនធានព្រៃឈើសម្រាប់ជាអេកូ-ទេសចរណ៍ទៅថ្ងៃអនាគត។

តាមការរៀបរាប់របស់ប្រជានេសាទ និងការផ្ទៀងផ្ទាត់ជាមួយ បញ្ជីឧបសម្ព័ន្ធ CITES និងបញ្ជីក្រហម IUCN Red List បង្ហាញថាប្រភេទគ្រុំយក្ស ជាប្រភេទដែលប្រែប្រួលពីរងគ្រោះថ្នាក់តិចតួចទៅងាយរងគ្រោះថ្នាក់។ ហើយប្រភេទដែលកំពុងរងគ្រោះថ្នាក់ដ៏ទៃទៀតដែលកំណត់ដោយអនុក្រឹត្យលេខ123អនក្រ.បក ស្តីពីការកំណត់ប្រភេទផលផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់រួមមាន៖ ផ្កាថ្ម (*Anthozoa spp.*) ខ្យង់កោដ្ឋ (*Trochus nitoticus*) គ្រុំយក្ស (*Tridacna manima* រឺ *Tridacna crocea*) ផ្សោតឥតព្រុយខ្នង (*Neophocaena phocaenoides*) និងផ្សោតក្បាលត្រឡោក (*Orcaella brevirostris*)។ ចំពោះប្រភេទផ្សោតភាគច្រើនរស់នៅតាមឆកកំពង់សោមតាមបណ្តោយឆ្នេរខេត្តកោះកុង និងខេត្តកែប ប៉ុន្តែនៅរដូវប្រាំងតែងតែមកលេងនៅឆ្នេរនៃកោះក្របី។

## ៦.៦ អត្ថប្រយោជន៍នៃធនធានព្រៃឈើ និង ជលផល និងតំលៃរបស់វា

### ក-អត្ថប្រយោជន៍ និងតំលៃនៃការប្រើប្រាស់ធនធានព្រៃឈើ

ព្រៃឈើ និងសត្វព្រៃនៃតំបន់គម្រោងអភិវឌ្ឍកោះក្របី បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ប្រជានេសាទដែលតែងតែទៅនេសាទនៅក្បែរនោះដូចជាផល-អនុផលព្រៃឈើដែលសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃផងដែរ។ តាមការសង្កេតលើទិដ្ឋភាពជាក់ស្តែងនៃតំបន់សិក្សា ឃើញមានគល់ឈើចាស់ៗ ដែលបន្សល់ទុក បង្ហាញថាពីមុនមកប្រហែលជាមានប្រជានេសាទមកកាន់តំបន់នេះ និងកាប់ឈើសម្រាប់សាងសង់លំនៅដ្ឋាន ឈើបង្គោលរបង អុសសំរាប់ដុតចំអិនអាហារជាដើម។ ក្រៅពីនេះផ្តល់នូវអនុផលព្រៃឈើដូចជា បន្លែ ផ្លែឈើព្រៃ វល្លិ៍ ផ្សិត និងរុក្ខជាតិឱសថផងដែរ។

ចំពោះផ្លែឈើព្រៃរួមមាន ផ្លែទម្ពូង ផ្លែដោះប៉ែន និងម៉ាក់ប្រាង។ រុក្ខជាតិឱសថរួមមាន វល្លិ៍អន្ទង់ វល្លិ៍ពាមកញ្ជើបាយដាច ក្របីដល់ដី និងក្របីគ្រោកជាដើម ដែលការប្រើប្រាស់គឺតាមក្បួនខ្មាត រឺ ការចេះតៗគ្នាពីដូនតាមកសម្រាប់ព្យាបាលជំងឺតាមលក្ខណៈប្រពៃណី។ នេះបញ្ជាក់ថាទោះបីជាប្រជាជនពឹងផ្អែកលើរបរនេសាទជាចម្បងយ៉ាងណាក៏ដោយ ក៏នៅតែពឹងផ្អែកលើព្រៃឈើជាសំខាន់ដែលមិនអាចកាត់ថ្លៃបាន ហើយវាក៏បំពេញនាទីយ៉ាងសំខាន់ក្នុងការជួយកែលំអរដីជាតិដី ទប់ទល់ការហូរច្រោះ ជាពិសេសជារបាំងយ៉ាងសំខាន់ដែលជួយការពារខ្យល់ព្យុះដល់ប្រជានេសាទ។

### ខ-ផលជលផល និងប្រាក់ចំណូលរបស់ប្រជានេសាទ

ប្រជាជនភាគច្រើប្រកបរបរនេសាទត្រី ដែលការនេសាទនាពេលបច្ចុប្បន្ននេះគឺស្ថិតនៅចម្ងាយពីកោះក្របីប្រមាណជា 300 ម៉ែត្រ ដែលការនេសាទភាគច្រើនរួមមាននេសាទត្រី មឹក និងបង្គាជាដើម។ ផលនេសាទដើរតួនាទីជាប្រភពផ្តល់ចំណូលយ៉ាងសំខាន់ដល់ប្រជាជនដែលរស់នៅក្បែរតំបន់នេះ និងជាមធ្យោបាយលើកកំពស់ជីវភាពគ្រួសារដ៏ប្រសើរផងដែរ។ ចំពោះផលនេសាទដែលបានមកត្រូវបានឈ្មួញកណ្តាលមកចាំទិញនៅនឹងភូមិ ពេលខ្លះក៏យកទៅលក់នៅផ្សារដោយផ្ទាល់ដែរ។ អ្នកដែលយកទៅលក់ដោយផ្ទាល់ភាគច្រើនមានមធ្យោបាយនេសាទផ្ទាល់ខ្លួន ចំពោះអ្នកដែលយកមធ្យោបាយនេសាទពីឈ្មួញ ផលនេសាទដែលទទួលបានត្រូវលក់ឲ្យគេក្នុងតំលៃទាបជាងទីផ្សារ។

ការលក់ដូរធ្វើឡើងតាមរយៈឈ្មួញកណ្តាលដែលមកពីខាងក្រៅភូមិ និងក្នុងភូមិ ហើយជាទូទៅតំលៃលក់តាមការកំណត់របស់ឈ្មួញកណ្តាលទាំងនោះ ដូចមាននៅក្នុងតារាងខាងក្រោម៖

តារាងទី 5៖ ផលជលផល និងតំលៃរបស់វា

| ល.រ | ផលជលផល | ឯកត្តា | តំលៃ (រៀល) |
|---|---|---|---|
| ១ | ត្រីតឹកកែ | គ.ក្រ | 20,000 រៀល |
| ២ | ត្រីកៅតេ | - | 12,000 រៀល |
| ៣ | ត្រីអាំងកើយ | - | 12,000 រៀល |
| ៤ | ត្រីក្រម៉ុង | - | 2,500 រៀល |
| ៥ | ត្រីដៃខ្លា | - | 10,000 រៀល |
| ៦ | ត្រីដែកគោល | - | 5,000 រៀល |
| ៧ | ខ្យងដូង | - | 5,000 រៀល |
| ៨ | ខ្យងភ្នែកមួយ | - | 10,000 រៀល |
| ៩ | ក្តាមថ្ម | - | 20,000 រៀល |
| ១០ | ក្តាមសេះ | - | 15,000 រៀល |
| ១១ | ក្តាមខ្យល់ | - | 300 រៀល |
| ១២ | មឹកបំពង់ | - | 10,000 រៀល |
| ១៣ | បង្គារ | - | 12,000-28,000 រៀល |

តារាងខាងលើគ្រាន់តែជាតំលៃបង្ហាញផលជលផលដែលប្រជានេសាទធ្លាប់លក់ឲ្យឈ្មួញកណ្តាល និងទីផ្សារ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាសង្កេតឃើញថាការនេសាទរបស់ប្រជានេសាទមានពីគឺការនេសាទជាលក្ខណៈគ្រួសារ និងការនេសាទសម្រាប់ធ្វើជំនួញ។ ដោយឡែកការនេសាទសម្រាប់ធ្វើជំនួញធ្វើឡើងដោយក្រុមធំដែលមួយក្រុមមានគ្នាពី 10-15 នាក់ និងប្រើប្រាស់ទូកធំៗចេញទៅលំហរសមុទ្រឆ្ងាយពីទីតាំងសិក្សាស្រាវជ្រាវ។ ចំពោះការនេសាទជាលក្ខណៈគ្រួសារ ភាគច្រើនស្ថិតនៅក្បែរទីតាំងសិក្សា និងទិន្នផលទទួលបានតិចតួចពេលខ្លះសល់ពីការទុកហូបក្នុងគ្រួសារ គេលក់ដូរសម្រាប់ទិញប្រេង និងសម្ភារៈប្រើប្រាស់ផ្សេងៗ។ ចំពោះប្រាក់ចំណូលគិតជាមធ្យមរបស់ប្រជាជនដែលបានមកពីការនេសាទ អាចចន្លោះពី មួយលានទៅពីរលានរៀលក្នុងមួយខែដោយពុំទាន់ទូទាត់ការចំណាយលើប្រេង ឧបករណ៍នេសាទ និងកំលាំងពលកម្ម។ នៅតំបន់មាត់សមុទ្រកំលាំងពលកម្មថ្លៃ ដោយក្នុងមួយថ្ងៃចន្លោះពី 24,000 រៀល ទៅ 30,000 រៀល គិតជាមធ្យមក្នុងមួយខែគឺ 80ម៉ឺន-មួយលានរៀល ស្មើនឹង 200-250 ដុល្លា។

## ៦.៧ ការអភិវឌ្ឍអេកូឡូស៊ី និងផលប៉ះពាល់ក្នុងតំបន់សិក្សា

គម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របីជាគម្រោងមួយល្អមិនត្រឹមតែអភិវឌ្ឍជាកន្លែងទេសចរណ៍ធម្មជាតិសម្រាប់ទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិនោះទេ ថែមទាំងជួយការពារដល់ជីវចម្រុះក្នុងតំបន់ទៀតផង។ ដោយយោងទៅតាមកិច្ចសន្យា និងផែនការមេ ក្រុមហ៊ុននឹងព្យាយាមធ្វើយ៉ាងណាមិនឲ្យប៉ះពាល់ដល់ដើមឈើធំៗឡើយ ទោះបីជាប្លង់មេបានពង្រាងរួចហើយ ប៉ុន្តែនៅទីវាលជាក់ស្តែងនឹងរំកិលប្រសិនបើប៉ះដើមឈើធំ (អង្កត់ផ្ចិតចាប់ពី 20ស.ម ឡើង)។

ម្យ៉ាងវិញទៀត គម្រោងបានព្យាយាមធ្វើឲ្យកើតឡើងវិញនូវធនធានព្រៃឈើ និងធនធានជលផលដើម្បីជាការទាក់ទាញដល់ភ្ញៀវទេសចរណ៍។

ទន្ទឹមនឹងការអភិវឌ្ឍ ការពារបរិស្ថានគឺជាបញ្ហាចំបង ព្រោះថាប្រសិនបើមានភ្ញៀវទៅកំសាន្តច្រើនកាកសំណល់ក៏អាចកើតមានច្រើនផងដែរ ដូច្នេះគួរមានវិធានការច្បាស់លាស់ដើម្បីទប់ស្កាត់ការបំពុលបរិស្ថាន ដែលជាហេតុធ្វើឲ្យជះឥទ្ធិពលអវិជ្ជមានដល់បរិស្ថានអេកូឡូស៊ី។

**៧-សន្និដ្ឋាន**

ការសិក្សាវាយតម្លៃលើធនធានព្រៃឈើ និងធនធានជលផលនៃតំបន់គម្រោងអភិវឌ្ឍរមណីយដ្ឋានកោះក្របី របស់ក្រុមហ៊ុនអភីប៊ី អ៊ិនវេសមេន ខូអិលធីឌី បានបង្ហាញថាផ្ទៃដីតំបន់អភិវឌ្ឍកោះក្របីមានចំនួន12ហិកតារួមមានព្រៃស្រោងចំនួន 10ហិកតា និងដីតំបន់ឆ្នេរចំនួន 2ហិកតា គណនាតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)។

តំបន់នេះមានធនធានឈើឈដូចជា៖ កូនឈើគុណភាព AនិងB គ្រប់ប្រភេទ (ប្រណិត ឈើលេខ1 លេខ2 លេខ3 និងក្រៅលំដាប់ថ្នាក់) ដែលមានអង្កត់ផ្ចិតតូចជាង 15សម. មានចំនួន 299 ដើម អង្កត់ផ្ចិត(15សម.-19សម.) មានចំនួន 59 ដើម អង្កត់ផ្ចិតពី 20-30សម. មានចំនួន 107 ដើម និងឈើអុស (ឈើដែលមានគុណភាព C) អង្កត់ផ្ចិតពី 5-30សម. មាន 119ម$^3$042 ។ មាឌឈើឈដែលជាឈើប្រណិតអង្កត់ផ្ចិតពី 15-30សម. គុណភាព C មានចំនួន 2ម$^3$975។ ឈើគ្រប់ប្រភេទដែលអង្កត់ផ្ចិតធំជាង 30សម. គុណភាព A មានចំនួន 2ម$^3$493 គុណភាព B មានចំនួន 123ម$^3$324 និង គុណភាព C មានចំនួន 268ម$^3$192 ។ ចំពោះបរិមាណធនធានឈើឈប៉ាន់ស្មានក្នុង 1ហិកតា មានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី ៣ ចំនុច 1.1 1.2 1.3 និងចំនុច 1.4។

លទ្ធផលនៃការគណនាគិតជាថវិកាបង្ហាញថាអុសចំរុះប្រភេទចំនួន 390ម$^{៣}$210 និងកូនឈើចំរុះប្រភេទចំនួន 465ដើម ដែលគិតជាទឹកប្រាក់សរុបប្រហែលជា 5,679,300រៀល ស្មើនឹង 1,419.841ដុល្លា។ ដោយឡែកប្រភេទឈើមូលដែលអង្កត់ផ្ចិតធំជាង 30សម. ឡើងទៅមានចំនួន 125ម$^{៣}$817 គិតជាទឹកប្រាក់ប្រហែលជា 3,986.757ដុល្លា។ ដូច្នេះតំលៃឈើឈដែលប៉ាន់ស្មានក្នុងតំបន់គម្រោងអភិវឌ្ឍកោះក្របីសរុបគឺ 5,406.598 ដុល្លា។ ការគណនាជីវម៉ាស់បានបង្ហាញថាព្រៃស្រោងមានជីវម៉ាស់លើដីចំនួន 202.909តោន/ហ.ត ជីវម៉ាស់ព្រៃឈើ (រាប់បញ្ចូលទាំងជីវម៉ាស់ក្រោមដី) គិតជាមធ្យមក្នុងមួយហិកតា 263.781តោន/ហិកតា ដោយឡែកការប៉ាន់ស្មានក្នុងផ្ទៃដីទំហំ 10ហិកតា មានលើកាបូនស្តុកសរុបជាមធ្យមគឺ 1,318.908តោន បើគិតជាបរិមាណឧស្ម័នកាបូនិច ($CO_2$)គឺ 4,835.997 តោន។

ដោយឡែកប្រភេទសត្វព្រៃលើគោក និងក្នុងទឹកដែលមានវត្តមាននៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចវិញ រួមមានថនិកសត្វ 7ប្រភេទ និងតាមចំណាត់ថ្នាក់នៅប្រទេសកម្ពុជាមានចំនួន 3 ប្រភេទ ដែលមានដោយកម្រ រងការគំរាមកំហែង និងជិតផុតពូជផងដែរ។ ដោយឡែកប្រភេទសត្វមួយចំនួនពុំមានកំណត់ត្រានៅក្នុងបញ្ជីក្រហម IUCN Red List ទេ ប៉ុន្តែត្រូវបានការពារដោយប្រកាស អនុក្រឹត្យ និងច្បាប់ដូចជាតុកកែ ត្រកួត និងពស់វែក។ ចំពោះប្រភេទសត្វក្នុងទឹក ការសិក្សាតាមរយៈការសម្ភាសន៍ និងការផ្ទៀងផ្ទាត់ជាមួយ បញ្ជីឧបសម្ព័ន្ធ CITES និងបញ្ជីក្រហម IUCN Red List រួមមានត្រីយក្ស ផ្កាថ្មរ ផ្សោតឥតព្រុយខ្នង និង ផ្សោតក្បាលត្រឡោក។ ការសិក្សាបង្ហាញថាផលជលផលគឺជាប្រភពចំណូលដ៏សំខាន់សម្រាប់ប្រជាជនដែលរស់នៅតំបន់ឆ្នេរ ដែលក្នុងនោះមានប្រភេទមច្ឆាជាតិរហូតដល់ 37 ប្រភេទដែលត្រូវបាននេសាទជាលក្ខណៈគ្រួសារ។

ជាអនុសាសន៍ដល់ក្រុមហ៊ុនអភីប៊ី អ៊ិនវេសមេន ខូអិលធីឌី ក្នុងដំណើរការអភិវឌ្ឍតំបន់កោះក្របី គួរតែគិតគូរលើចំនុចមួយចំនួនដូចខាងក្រោម៖

- ដោយសារតំបន់អភិវឌ្ឍរមណីយដ្ឋានកោះក្របីមានទំហំត្រឹមតែ 12 ហិកតា ដូចនេះការងារគ្រប់គ្រងកាកសំណល់គឺជាកត្តាចាំបាច់មួយដែលត្រូវគិតគូរជាចំបង

- ក្រុមហ៊ុនអភីប៊ី អ៊ិនវេសមេន ខូអិលធីឌី គួរតែសហការជាមួយមន្ត្រីជំនាញបរិស្ថាន ដោយយកចិត្តទុកដាក់គ្រប់គ្រងដំណើការសាងសង ដោយលៃយ៉ាងណាកាត់បន្ថយផលប៉ះពាល់បរិស្ថានជាអតិបរមា។

## ឯកសារយោង


១ រដ្ឋបាលព្រៃឈើ (2004) សៀវភៅគោលការណ៍ណែនាំធ្វើសារពើភ័ណ្ឌ
២ រដ្ឋបាលព្រៃឈើ (2010) វគ្គបណ្តុះបណ្តាលស្តីពីពិធីការបេច្ចេកទេសសារពើភ័ណ្ឌប៉ាន់ស្មានធនធានព្រៃឈើនៅក្នុងសម្បទានដីសេដ្ឋកិច្ច។
៣ ក្រសួងធនធានទឹក និងឧតុនិយម (2008) ទិន្នន័យសីតុណ្ហភាពខេត្តរតនគិរី
៤ រដ្ឋបាលព្រៃឈើ (2004) សៀវភៅណែនាំស្តីពីការធ្វើផែនការគ្រប់គ្រងព្រៃឈើ
៥ ប្រកាសលេខ ៨៩ ប្រក.កសក ចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០០៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីផល អនុផលព្រៃឈើដែលត្រូវហាមឃាត់ការប្រមូលផល
៦ ប្រកាសលេខ ១២៧៦ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពី ការកំណត់ថ្លៃសួយសារ ឈើ ឈរឡើងវិញ ដើម្បីបង់ចំណូលថវិការដ្ឋ។
៧ អនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រភេទផល ផលិតផល ជលផលដែលកំពុងរងគ្រោះថ្នាក់។
៨ អាស៊ានវែន ឆ្នាំ ២០១២, អត្តសញ្ញាកម្មសត្វព្រៃដែលគេជួញដូរក្នុងតំបន់អាស៊ីអាគ្នេយ៍

# ឧបសម្ព័ន្ធទី០៦

៦.១- ការសិក្សាធនធានជលផល ការនេសាទ និងផ្កាថ្មនៅជុំវិញកោះក្របី

៦.២- ការសិក្សាធនធានផ្កាថ្មនៅឆ្នេរសមុទ្ររាម (ទីតាំងសាងសង់ផែដីគោក)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ស្រាវជ្រាវ

## ស្តីពី

# ការនេសាទនិងធនធានជលផល
# នៅតំបន់ជុំវិញកោះក្របី នៃខេត្តព្រះសីហនុ

សីហា ២០១៣

# មាតិកាអត្ថបទ


**មាតិកាអត្ថបទ**........................................................................................................៣

**១. សេចក្តីផ្តើម**........................................................................................................៥

១.១ លក្ខណៈទូទៅនៃវិស័យជលផល........................................................................៥

១.២ គោលបំណងនៃការស្រាវជ្រាវ............................................................................៧

**២. សំយោគឯកសារ**....................................................................................................៨

១. ទីតាំងភូមិសាស្ត្រ..................................................................................................៨

២. ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងការការពារធនធានជលផលនិងជីវចម្រុះ......................៩

៣. ធនធានជលផលសមុទ្រ.........................................................................................១១

៣.១ ធនធានជលផល...................................................................................................១១

៣.២ ធនធានជលផលដែលកំពុងរងគ្រោះថ្នាក់...............................................................១២

៣.៣ ធនធានជម្រកជលផល..........................................................................................១៥

**៣. វិធីសាស្ត្រនិងសម្ភារៈស្រាវជ្រាវ**.................................................................................១៧

១. វិធីសាស្ត្រវាយតម្លៃសកម្មភាពនេសាទនិងធនធានជលផលក្នុងតំបន់ជុំវិញកោះក្របី.....១៧

១.១ ការសិក្សាអង្កេតពីសកម្មភាពនេសាទនិងធនធានជលផល..........................................១៨

១.២ ដំណើរការនៃការប្រមូលព័ត៌មាន..........................................................................១៨

១.៣ ការវិភាគទិន្នន័យ................................................................................................១៩

២. វិធីសាស្ត្រវាយតម្លៃធនធានជីវចម្រុះស្រទាប់បាត.........................................................១៩

**៤. លទ្ធផលនៃការស្រាវជ្រាវ**........................................................................................២២

១. លទ្ធផលនៃការស្រាវជ្រាវសកម្មភាពនេសាទ.................................................................២២

១.១ លក្ខណៈទូទៅនៃអ្នកនេសាទ.................................................................................២២

១.២ សកម្មភាពនេសាទ...............................................................................................២៤

១.៣ ប្រភេទធនធានជលផលដែលប្រមូលបាន..................................................................២៤

២. លទ្ធផលនៃការស្រាវជ្រាវធនធានជីវចម្រុះនិងប្រភេទស្រទាប់បាត..................................៣០

**៥. ផលប៉ះពាល់និងលទ្ធភាពនៃការកាត់បន្ថយ**...............................................................៤០

៦.ការសន្និដ្ឋាននិងការវាយតម្លៃ..........៤២
បណ្ណាល័យសាស្ត្រ..........៤៤
ឧបសម្ព័ន្ធ..........៤៥

តារាង ក្រាហ្វិក និងរូបភាព

តារាងទី១: ប្រភេទធនធានជលផលសមុទ្រដែលកំពុងរងគ្រោះថ្នាក់ទាំង២៩ប្រភេទ..........១៣
តារាងទី២: ទីតាំងស្រាវជ្រាវប្រព័ន្ធអេកូឡូស៊ី..........១៩
តារាងទី៣: ប្រភេទធនធានជលផលសំខាន់ៗក្នុងតំបន់គម្រោង..........២៤
តារាងទី៤: ប្រភេទធនធានជលផលក្នុងតំបន់គម្រោង..........២៥
តារាងទី៥: លទ្ធផលស្រាវជ្រាវធនធានជលផលស្រទាប់បាត..........៣១
តារាងទី៦: ផលប៉ះពាល់និងវិធានការកាត់បន្ថយ..........៤០

ក្រាហ្វិកទី១: គម្លាតប្រាក់ចំណូលប្រចាំឆ្នាំដែលគ្រួសារអ្នកនេសាទទទួលបាន..........២៣
ក្រាហ្វិកទី២: ប្រភពប្រាក់ចំណូលប្រចាំគ្រួសារ..........២៣
ក្រាហ្វិកទី៣: ផលនេសាទចាប់ជាមធ្យមតាមខែក្នុងមួយៗគ្រួសារ..........២៩
ក្រាហ្វិកទី៤: ផលនេសាទចាប់សរុបតាមខែនៅតាមដងព្រែកទឹកសាប..........២៩

រូបទី១: ផែនទីប្រជុំកោះតាកែវ ខេត្តព្រះសីហនុ..........៨
រូបទី២: រូបភាពកោះក្របីនៅប្រជុំកោះតាគៀវ..........៩
រូបទី៣: ផែនទីទីតាំងស្រាវជ្រាវធនធានជលផលស្រទាប់បាត..........២០
រូបទី៤: ផ្ទាំងគំរូសម្រាប់កំណត់អត្តសញ្ញាណនៃធនធានផ្កាថ្ម និងប្រភេទត្រីផ្កាថ្ម..........២១
រូបទី៥: ផែនទីបង្ហាញពីធនធានជលផលស្រទាប់បាតនៅជុំវិញកោះក្របី..........៣៩

## ១. សេចក្តីផ្តើម

### ១.១ លក្ខណៈទូទៅនៃវិស័យជលផល

ព្រះរាជាណាចក្រកម្ពុជាមានវិសាលភាពប្រព័ន្ធទឹកសាបប្រមាណ២,៧% នៃផ្ទៃប្រទេសដែលសម្បូរ ទៅដោយសារធាតុខនិជ និងសារធាតុចិញ្ចឹមមានផលិតភាពខ្ពស់ក្នុងចំណាត់ថ្នាក់ទី៤ ផ្នែកផលនេសាទ ទឹកសាប បន្ទាប់ពីប្រទេសចិន ឥណ្ឌា និងបង់ក្លាដេស។ ចំណែកឯដែននេសាទសមុទ្រវិញក៏មានផលិតភាព ខ្ពស់ដែរ ហើយសម្បូរទៅដោយសារធាតុចិញ្ចឹមជាច្រើនផងដែរ។

ផ្តើមចេញពីសារសំខាន់របស់វិស័យជលផល ដែលទាក់ទងដោយផ្ទាល់ទៅនឹងជីវភាពប្រជាពលរដ្ឋ ខ្មែរ ក៏ដូចជាសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដែលក្នុងនោះកំណែទម្រង់ វិស័យជលផលជាមុំមួយនៃចតុកោណទី ១សំដៅជម្រុញការសម្របសម្រួលអនុវត្តច្បាប់ រៀបផែនការសកម្មភាព និងការពង្រឹងស្ថាប័នដែលពាក់ព័ន្ធនឹងវិស័យជលផល ដើម្បីធ្វើឲ្យសម្រេចបានគោលដៅថ្នាក់ជាតិក្នុង កិច្ចការពារបរិស្ថានជលផល ការអភិរក្សជីវចម្រុះ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម អភិបាលកិច្ចល្អ និងការកាត់ បន្ថយភាពក្រីក្រ ដូចមានចែងក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីវិស័យជលផល។

ទស្សនៈវិស័យជលផល៖ *គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចំរើននៃសេដ្ឋ- កិច្ចសង្គម និងការអភិវឌ្ឍប្រទេសជាតិ។*

ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាមានប្រវែង៤៣៥គ.ម ហើយតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) មាន ទំហំ៥៥.៦០០គ.ម² (DoF, 2005)។ តំបន់ឆ្នេរសមុទ្រនៃប្រទេសកម្ពុជាស្ថិតនៅក្នុងខេត្តចំនួនបួនគឺ ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប។ តាមទស្សនៈវិស័យនៃមុខងារតំបន់ឆ្នេរសមុទ្រនៃ ប្រទេសកម្ពុជាមានប្រព័ន្ធទាក់ទងគ្នាពីរគឺ ប្រព័ន្ធសេដ្ឋកិច្ចសង្គមនិងប្រព័ន្ធអេកូឡូស៊ី (DoF, 2005)។ ប្រព័ន្ធ អេកូឡូស៊ីរួមមានសមាសភាពជីវសាស្ត្រ គីមី និងរូប ដែលបង្កើតធនធានធម្មជាតិ និងផ្តល់មុខងារទ្រទ្រង់ ជីវិតជាគ្រឹះសំខាន់(ឧទាហរណ៍ ខ្យល់បរិសុទ្ធនិងទឹកស្អាត) សម្រាប់មនុស្សនិងសរីរាង្គមានជីវិតដទៃទៀត។ ឯប្រព័ន្ធសេដ្ឋកិច្ចសង្គម ជាពិសេស ការរស់នៅរបស់មនុស្សជាតិ គឺពឹងផ្អែកលើមុខងារនិងផលិតភាពជា ច្រើននៃប្រព័ន្ធអេកូឡូស៊ី។

ប្រព័ន្ធអេកូឡូស៊ីសមុទ្រសំខាន់ៗរួមមាន ប្រព័ន្ធអេកូឡូស៊ីផ្កាថ្ម ប្រព័ន្ធអេកូឡូស៊ីស្មៅសមុទ្រ ប្រព័ន្ធ អេកូឡូស៊ីព្រៃកោងកាង និងប្រព័ន្ធអេកូឡូស៊ីដទៃទៀតដែលទ្រទ្រង់ឲ្យប្រព័ន្ធអេកូឡូស៊ីទាំងបីនេះ ដូចជាតំបន់ ថ្ម តំបន់ខ្សាច់ តំបន់ភក់។ល។ ដោយឡែក ប្រព័ន្ធអេកូឡូស៊ីផ្កាថ្ម ព្រៃកោងកាង និងស្មៅសមុទ្រ គឺជា ជម្រកដ៏សំខាន់បំផុតដែលបានគាំទ្រដល់ការរស់នៅ កន្លែងរកចំណី កន្លែង

ពងកូន និងកន្លែងផ្សាំរបស់ ប្រភេទសត្វជាច្រើនប្រភេទ ជាពិសេស ប្រភេទសត្វដែលងាយរងការគំរាមកំហែងនិងជិតផុតពូជ។ ជាងនេះទៅទៀត ប្រព័ន្ធទាំងនេះបានជួយរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ី បម្រើឲ្យសេដ្ឋកិច្ចសង្គម និងជាកន្លែងទាក់ ទាញភ្ញៀវទេសចរណ៍មកទស្សនាដ៏មានប្រសិទ្ធភាពបំផុត។

បើប្រៀបធៀបទៅនឹងប្រទេសជិតខាង ប្រព័ន្ធអេកូឡូស៊ីសមុទ្រក្នុងប្រទេសកម្ពុជា និងធនធានជល-ផលទាំងនេះ នៅពុំទាន់មានការប្រែប្រួលខ្លាំងនៅឡើយទេ ដោយបានរួមចំណែកបម្រើឱ្យវិស័យសេដ្ឋកិច្ច គ្រួសារនិងសង្គមជាតិទាំងមូល។

ធនធានជលផលសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា គឺពិតជាសំខាន់មួយផ្អែកលើប្រព័ន្ធអេកូឡូស៊ី ស្មៅសមុទ្រ ផ្កាថ្ម ព្រៃកោងកាង និងតំបន់ពាម។ មច្ឆជាតិដែលរស់នៅក្នុងតំបន់ទាំងនេះ ពិសេស បង្គា ក្តាម ត្រីគឺជាប្រភេទសត្វមានតម្លៃសេដ្ឋកិច្ចខ្ពស់ ទាំងទីផ្សារក្នុងស្រុកនិងទីផ្សារបរទេស។ យោងតាមស្ថិតិរបស់ រដ្ឋបាលជលផលឆ្នាំ២០១២ បានអោយដឹងថា មានត្រីសមុទ្រនិងសត្វឥតឆ្អឹង ខ្នងប្រមាណពី៩២.០០០ ដល់ ៩៥.០០០តោន ត្រូវប្រមូលបានពីដែនសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជារៀងរាល់ឆ្នាំ។

ធនធានជលផល ជាពិសេសត្រី គឺជាអាហារដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជា។ ត្រីដើរតួនាទីយ៉ាងសំខាន់នៅក្នុងសន្តិសុខស្បៀង ហើយតាមការស្រាវជ្រាវរបស់រដ្ឋបាលជលផលក្នុងឆ្នាំ២០០៨ ត្រីបានផ្តល់ប្រូតេអ៊ីនជាង៨១,៥ភាគរយ នៅក្នុងរបបអាហារប្រចាំថ្ងៃរបស់ប្រជាជនយើង។ ត្រីសម្បូរដោយប្រូតេអ៊ីន វីតាមីន និងសារធាតុខនិជផ្សេងៗទៀត ដែលមានសារសំខាន់សម្រាប់សុខភាពមនុស្ស ជាពិសេសស្ត្រីមានផ្ទៃពោះនិងកុមារ។ ជាងនេះទៅទៀត ធនធានជលផលបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងសង្គម និងសេដ្ឋកិច្ចជាតិ ដោយបានផ្តល់ជាមុខរបរដល់ប្រជាជនកម្ពុជាជាង៦លាននាក់ ដែលមានការងារពាក់- ព័ន្ធជាមួយនឹងមុខរបរនេសាទ។ វិស័យជលផលជាប្រភពផ្តល់ប្រាក់ចំណូលយ៉ាងសំខាន់សម្រាប់ទ្រទ្រង់ ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរ ជាពិសេសអ្នករស់នៅតាមជនបទ។ ជាងនេះទៅទៀត ធនធាន ជលផលក៏ជាប្រភពមួយយ៉ាងសំខាន់ក្នុងការទាក់ទាញការចាប់អារម្មណ៍របស់ភ្ញៀវទេសចរណ៍ជាតិនិងអន្តរ ជាតិផងដែរ ដូចជាការនេសាទត្រីកំសាន្ត ការទស្សនាព្រៃកោងកាង និងការមុជទឹកមើលផ្កាថ្មជាដើម ដែល សកម្មភាពទាំងនេះ បានចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជាយើងឱ្យរីកចម្រើន។

ទោះជាយ៉ាងនេះក្តី ប្រព័ន្ធអេកូឡូស៊ីផ្កាថ្ម ស្មៅសមុទ្រ ព្រៃកោងកាង និងតំបន់ឆ្នេរដទៃទៀត ព្រម ទាំងធនធានវារីសត្វជាច្រើនប្រភេទ កំពុងតែស្ថិតក្នុងស្ថានភាពនៃការគំរាមកំហែងដែលបណ្តាលមកពីការ ធ្វើនេសាទដែលមានលក្ខណៈបំផ្លិចបំផ្លាញ ការចាក់ចោលកាកសំណល់ ភាពកករ ការកើនឡើងនៃអ្នក នេសាទ និងការអភិវឌ្ឍតាមតំបន់ឆ្នេរពុំសមស្រប។ ការខូចខាតនិងបាត់

បង់ប្រព័ន្ធអេកូឡូស៊ីទាំងនេះ បាន និងកំពុងបង្កផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាននិងសេដ្ឋកិច្ច ហើយចុងក្រោយនឹងប៉ះពាល់ដល់ភាព ក្រីក្រនិងការរស់នៅរបស់ប្រជាពលរដ្ឋជាច្រើនលាននាក់។

នាពេលបច្ចុប្បន្ននេះ ការអភិវឌ្ឍនៅតាមតំបន់ឆ្នេរ ជាពិសេស ការអភិវឌ្ឍទីក្រុងរណប ការកសាង ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ និងការអភិវឌ្ឍរមណីយដ្ឋាននានា គឺមានសន្ទុះលឿនបំផុតដែលសកម្មភាពទាំង នេះបង្កឲ្យមានការព្រួយបារម្ភពីអ្នកអភិរក្សនិងបរិស្ថានទាំងក្នុងនិងក្រៅប្រទេស។ ដូច្នេះហើយ ដើម្បីឲ្យការ អភិវឌ្ឍទាំងនេះប្រព្រឹត្តទៅប្រកបដោយចីរភាព ជាពិសេសមានការថ្លឹងថ្លែងពីតុល្យភាពរវាងការអភិវឌ្ឍនិង ការអភិរក្ស ការសិក្សាពីផលប៉ះពាល់បរិស្ថាន គឺជាការចាំបាច់បំផុត ដើម្បីកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន ឲ្យបានជាអតិបរមានិងមានវិធានការកាត់បន្ថយជាបន្ទាន់នៅពេលមានហានិភ័យផ្សេងៗកើតឡើងក្នុងពេលកំពុងសាងសង់និងក្នុងពេលដំណើរការពេញលេញ។

## ១.២ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងរួមនៃការសិក្សានេះ គឺដើម្បីវាយតម្លៃពីស្ថានភាពធនធានជលផល ស្ថានភាពស្រទាប់ បាត និងស្ថានភាពនេសាទក្នុងតំបន់ជុំវិញកោះក្របី ដើម្បីចាត់វិធានកាត់បន្ថយផលប៉ះពាល់លើធនធាន ជលផលដែលអាចបណ្តាលមកពីការអភិវឌ្ឍគម្រោងលំហែកាយនៅតំបន់កោះក្របី នៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ របស់ក្រុមហ៊ុន អភីប៊ី អ៊ិនវេសមេន ខូអិលធីឌី (RPB Investment co,. LTd)។

ចំពោះគោលបំណងបន្ទាន់នៃការសិក្សាស្រាវជ្រាវគឺ ៖

- ដកស្រង់ព័ត៌មានដែលមានស្រាប់ពាក់ព័ន្ធធនធានជលផលក្នុងតំបន់គម្រោង
- ពិនិត្យនិងអង្កេតផ្ទាល់ក្នុងតំបន់គម្រោង
- វាយតម្លៃជីវចម្រុះ ជាពិសេសស្ថានភាពប្រព័ន្ធផ្កាថ្មស្រទាប់បាត ទីតាំងជាក់ស្តែង និងធនធាន ជីវចម្រុះដែលមានវត្តមាននៅក្នុងតំបន់ផ្កាថ្មនោះ
- សិក្សានិងវាយតម្លៃពីធនធានជលផលសមុទ្រនិងសកម្មភាពនេសាទនៅជុំវិញកោះ
- កំណត់អំពីផលប៉ះពាល់និងវិធានការកាត់បន្ថយផលប៉ះពាល់
- រៀបចំរបាយការស្រាវជ្រាវ។

ទិន្នន័យដែលប្រមូលបានអាចត្រូវបានចាត់ទុកជាទិន្នន័យគ្រឹះដ៏មានសារសំខាន់បំផុតនៅមុន ពេលដំណើរការសាងសង់គម្រោង ពីព្រោះទិន្នន័យនេះអាចយកធ្វើជាអំណះអំណាងក្នុងការតាមដានបម្រែ បម្រួលធនធានជលផលក្នុងអំឡុងពេលកំពុងសាងសង់និង អំឡុងពេល ដំណើរការគម្រោង (ក្រោយពេល សាងសង់)។ ក្នុងករណីការតាមដានឃើញថាមានការប្រែប្រួល ជាពិសេស ធនធានជលផល ព្រៃកោងកាង និងផ្កាថ្ម នោះយើងត្រូវមានវិធានការជាបន្ទាន់។ ទិន្នន័យ

ដែលនឹងត្រូវប្រមូលរួមមានបីទិដ្ឋភាពសំខាន់ៗគឺ សកម្មភាពនេសាទ ធនធានជលផល និងទីជម្រកជលផល។

## ២. សំយោគឯកសារ

### ២.១- ទីតាំងភូមិសាស្ត្រ

កោះក្របី មានទីតាំងនៅមុខឧទ្យានជាតិរាម ក្នុងឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានទំហំ ប្រមាណ១០ហិកតា និងមានចម្ងាយប្រមាណ៦គីឡូម៉ែត្រពីឆ្នេររាម។ តាមការស្រាវជ្រាវរបស់រដ្ឋបាល ជលផល ដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ីផ្កាថ្មនៅក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា ប្រជុំកោះត្រូវបានបែងចែកជា ៧ប្រជុំកោះ គឺប្រជុំកោះរុង ប្រជុំកោះតាគៀវ ប្រជុំកោះស្ដេច ប្រជុំកោះកុង ប្រជុំកោះតាង ប្រជុំកោះពោធិ៍ និងព្រែកអំពិល។ តាមរយៈការដាក់ជាប្រជុំកោះនេះ កោះក្របីត្រូវបានដាក់ឲ្យស្ថិតនៅក្នុងតំបន់ប្រជុំកោះ តាគៀវ ដែលមានកោះជាច្រើនទៀតនៅជុំវិញ ដូចជាកោះត្រេះ កោះច្រឡុះ កោះឫស្សី កោះតាគៀវ។ល។ តាមការវាយតម្លៃជាបឋមរបស់រដ្ឋបាលជលផល ឆ្នាំ២០០៥ បានបង្ហាញថា នៅក្នុងតំបន់ប្រជុំកោះតាគៀវ មានផ្កាថ្មប្រមាណ ២៩២,៥ហិកតា (DoF, 2005)។




រូបទី១៖ ផែនទីប្រជុំកោះតាគៀវ ខេត្តព្រះសីហនុ




រូបទី២៖ រូបភាពកោះក្របី ក្នុងប្រជុំកោះតាគៀវ ខេត្តព្រះសីហនុ

## ២.២ ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងការការពារធនធានជលផលនិងជីវចម្រុះ

រាល់សកម្មភាពទាំងអស់ដែលធ្វើឱ្យប៉ះពាល់លើធនធានជលផល ជាពិសេស ទីជម្រកវារីជាតិនិង ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ត្រូវហាមឃាត់ដាច់ខាត។ ច្បាប់និងអនុសញ្ញាដែលពាក់ ព័ន្ធទៅនឹងការការពារជីវចម្រុះត្រូវបានតាក់តែងនិងអនុម័តដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីដាក់ឱ្យប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់ទៅលើ ធនធានជីវចម្រុះទាំងនេះ។ លិខិតបទដ្ឋានច្បាប់ជាតិនិងអន្តរជាតិនានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិង អភិរក្សជីវចម្រុះមាន៖

- ផែនការសកម្មភាពជាយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងជីវចម្រុះ
- ផែនការសកម្មភាពថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន
- ផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងតំបន់ឆ្នេរក្រុងព្រះសីហនុ
- អនុសញ្ញា ស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ អនុសញ្ញា ស្តីពីជីវចម្រុះ
- អនុសញ្ញា ស្តីពីការបំពុលបរិស្ថានសមុទ្រ
- អនុសញ្ញាសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២
- អនុក្រឹត្យ ស្តីពីការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- ប្រកាស ស្តីពីវិធានការការពារធនធានជលផលដែលកំពុងរងគ្រោះថ្នាក់។
- ច្បាប់ស្តីពីជលផលត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦។

ច្បាប់ នេះមានឥទ្ធិពលលើការគ្រប់គ្រង អភិរក្ស និង ប្រើប្រាស់ធនធានជលផលឱ្យមាននិរន្តរភាព។ ក្នុងច្បាប់ស្តីពី ជលផលមានមាត្រាមួយចំនួនពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានជលផលសមុទ្រដូចជា ៖

**មាត្រា ៥៖**

ធនធានជលផលមានសរីរាង្គទឹកសាប និងសមុទ្រ ជាសត្វ និងរុក្ខជាតិ មានជីវិតឬគ្មានជីវិត ជាអាទិ៍ មច្ឆជាតិ សិប្បីសត្វ ថលជលិកសត្វ បាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀតដែលបង្ក កំណើតនៅក្នុងទឹក ប្លង់តុង សារាយ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃលិចទឹក ព្រមទាំងព្រៃកោងកាងជាដើម។

**មាត្រា ៦៖**

រដ្ឋបាលជលផល គឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានភារកិច្ចគ្រប់គ្រងជលផលនិងធនធានជលផល ស្របតាមគោលនយោបាយវិស័យជលផលជាតិនិងខ្លឹមសារនៃច្បាប់នេះ។

**មាត្រា ២២៖**

ហាមឃាត់ ការចាក់ចោល ការបោះចោល ការបង្ហូរឬការបាចពង្រាយទៅក្នុងដែននេសាទនូវភាក សំណល់រឹងឬរាវ ឬសារធាតុពុលដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណា ចក្រកម្ពុជា និងអនុសញ្ញាឬសន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តសកម្មភាពដែលធ្វើឱ្យ ពុលឬការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ។

**មាត្រា ៩៦៖**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅដប់ លាន (១០.០០០.០០០) រៀល ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្ត បទល្មើសណាមួយដូចខាងក្រោម ៖

៤-គាស់ កកាយយកថ្ម ដី ខ្សាច់ រ៉ែ ដែលមាននៅក្នុងដែននេសាទដោយគ្មានការអនុញ្ញាត។

៧-ប្រមូលផលធ្វើសន្និធិផ្កាថ្មឬចូលចតនាវា

បោះយុថ្កានៅតំបន់ផ្កាថ្មដោយគ្មានការអនុញ្ញាត។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ(២)ដងឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ។

**មាត្រា ៩៨៖**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី១ ដែលត្រូវដាក់ពន្ធនាគារពីបី (៣) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំនិងវត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋឬបំផ្លាញចោល និងដកហូតកិច្ចព្រមព្រៀងឬលិខិតអនុញ្ញាត ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម ៖

១- កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក និងព្រៃកោងកាងឬហ៊ុមព័ទ្ធកាន់កាប់ព្រៃលិចទឹក និង ព្រៃកោងកាង។

៣- ចាក់ចោល បោះចោល បង្ហូរ បាចពង្រាយសារធាតុពុលឬប្រព្រឹត្តសកម្មភាពធ្វើឱ្យពុលឬបង្ក គ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិនៅក្នុងដែននេសាទ។

១០-បំផ្លាញស្មៅសមុទ្រឬផ្កាថ្មនិងធ្វើឱ្យអន្តរាយដល់អេកូឡូស៊ីស្មៅសមុទ្រឬផ្កាថ្ម។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី១ចាប់ពីពីរ (២) ដងឡើងទៅ ត្រូវផ្តន្ទាទោសទ្វេដងនៃបទ ល្មើសជលផលថ្នាក់ទី១ នៃមាត្រានេះ ។

អនុលោមតាមបណ្តាច្បាប់និងលិខិតបទដ្ឋានទាំងអស់នេះ ការអភិវឌ្ឍផ្សេងៗនៅតាមបណ្តោយព្រែក នេះ ត្រូវគិតគូរទៅលើការថែរក្សាឱ្យបាននូវប្រភេទធនធានជលផលសមុទ្រ ជាពិសេស ផ្កាថ្ម ស្មៅសមុទ្រ ព្រៃកោងកាង ប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ និងប្រពន្ធ័អេកូឡូស៊ី។

## ២.៣- ធនធានជលផលសមុទ្រ

### ២.៣.១ ធនធានជលផល

ត្រី គឺជាពពួកសត្វឆ្អឹងកងដែលសម្បូរជាងគេនៅក្នុងសមុទ្រ ហើយមានប្រមាណជាង៥០០ ប្រភេទ ត្រូវបានរកឃើញនៅក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា (FiA, 2011)។ ត្រីសមុទ្រទាំងនេះភាគ ច្រើនមានតម្លៃសេដ្ឋកិច្ចខ្ពស់ សម្រាប់ជាតម្រូវការស្រស់និងសម្រាប់កែច្នៃ (ផលិតជាចំណីត្រី ទឹកត្រីឬម្សៅ ត្រី)។ ត្រីត្រូវបានចែកជាពីរក្រុមសំខាន់ៗ គឺក្រុមឆ្អឹងទន់ Chondrichthyes (មានពពួកឆ្លាមនិងបបែល) និងក្រុមឆ្អឹងរឹង Osteichthye។

**ឆ្លាមនិងបបែល:** គឺជាក្រុមបុរេសត្វដែលមានតាំងពីជាង៣៥០លានឆ្នាំមុនម្ល៉េះ។ នៅក្នុងព្រះរាជា ណាចក្រកម្ពុជា ពពួកបបែល (Stingrays) ជាប្រភេទដែលជាគោលដៅចាប់ ឯឆ្លាមជាប្រភេទចាប់ដោយ ចៃដន្យ។ ឆ្លាមនិងបបែលមានការលូតលាស់និងការពេញវ័យយឺត ហើយមានកូនតិចតួចប៉ុណ្ណោះ។ ដូច្នេះ ពួកវាត្រូវបានគេគិតថា ងាយរងគ្រោះដោយសារសកម្មភាពមនុស្ស។ ពពួកឈ្មោលមានពងស្វាសមួយគូសម្រាប់បន្តពូជ ប្រភេទខ្លះឱ្យកំណើតមកជាកូនតូចៗ ឯប្រភេទខ្លះទៀតឱ្យកំណើតមកជាកន្សោមពង។ ត្រី ឆ្លាមដែលមាននៅក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រ

កម្ពុជាភាគច្រើនជាប្រភេទតូចៗ។ ប្រភេទឆ្លាមដែល ធំជាងគេគឺ បាឡាន់គីង្កក់ (Whale shark) ដែលចាត់ជាប្រភេទដែលកំពុងរងគ្រោះថ្នាក់។

**ត្រីឆ្អឹងរឹង**:ភាគច្រើនជាប្រភេទត្រីដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់នៅក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។ ប្រភេទជាច្រើនរស់នៅក្នុងតំបន់ផ្កាថ្ម ហើយពួកវាភាគច្រើនត្រូវនេសាទបានដោយឧបករណ៍ខុសច្បាប់ដូចជា ការប្រើគ្រឿងផ្ទុះឬថ្នាំពុល។ ប្រភេទខ្លះកម្រ ហើយរស់នៅក្នុងទីជម្រកនិងស៊ីប្រភេទចំណីជាក់លាក់ ហើយមានប្រភេទខ្លះទៀតហែលជាហ្វូងនៅក្នុងដែនសមុទ្រ។ ប្រភេទខ្លះ មានប្រវែងដងខ្លួន ២-៣ស.ម ប៉ុណ្ណោះពេលពេញវ័យ ប្រភេទខ្លះទៀតលូតលាស់រហូតដល់២-៣គ.ក្រ មុនពេលវាពង ហើយពួក វាមានរូបរាងនិងពណ៌ផ្សេងៗគ្នា។ ត្រីឆ្អឹងរឹងភាគច្រើនផលិតពងបានច្រើន ហើយបង្កកំណើតនៅក្នុងទឹក។ ពពួកត្រីគុកកែ ត្រីឆ្កង់ និងត្រីអាំងកឹយ គឺជាប្រភេទត្រីដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ជាងគេក្នុងចំណោម ប្រភេទផលនេសាទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ២.៣.២ ធនធានជលផលដែលកំពុងរងគ្រោះថ្នាក់

រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរកឃើញថា មានប្រភេទធនធានជលផល ដែលកំពុងរងគ្រោះថ្នាក់ចំនួន៥៨ប្រភេទ ដែលក្នុងនោះ ប្រភេទធនធានជលផលសមុទ្រកំពុង រងគ្រោះថ្នាក់ចំនួន២៩ប្រភេទ និងប្រភេទធនធានជលផលទឹកសាបដែលកំពុងរងគ្រោះថ្នាក់មានចំនួន២៩ ប្រភេទដែរ។ ប្រភេទដែលកំពុងរងគ្រោះថ្នាក់ទាំងនេះ ត្រូវបានចែកជាបីក្រុមធំ គឺប្រភេទដែលជិតផុតពូជ ប្រភេទដែលកំពុងរងគ្រោះនិងប្រភេទងាយរងគ្រោះ។ ការចាត់ថ្នាក់ក្រុមនេះធ្វើឡើងទៅតាមស្ថានភាពរបស់ វានៅក្នុងដែនទឹកធម្មជាតិដូចខាងក្រោម៖

- **ក្រុមប្រភេទជិតផុតពូជ៖** ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរងគ្រោះ ថ្នាក់ដែលចំពោះមុខជលស្តុកក្រុមប្រភេទនេះកំពុងប្រឈមទៅនឹងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ ហើយ អាចវិនាសផុតពូជទាំងស្រុងនៅក្នុងធម្មជាតិនាពេលអនាគតដ៏ខ្លីខាងមុខ ដោយបរិមាណ សរុបបានថយចុះយ៉ាងតិច ៨០(ប៉ែតសិប)ភាគរយ ក្នុងរយៈពេល១០(ដប់)ឆ្នាំចុងក្រោយឬ ក្នុងរយៈពេលបីជំនាន់តំណពូជកន្លងមក តាមរយៈការអង្កេតការប៉ាន់ប្រមាណឬការសន្និដ្ឋាន។
- **ក្រុមប្រភេទកំពុងរងគ្រោះ៖** ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរងគ្រោះថ្នាក់ដែលមានភស្តុតាងបង្ហាញច្បាស់ថា ក្រុមប្រភេទនេះកំពុងប្រឈមនឹងគ្រោះថ្នាក់ដ៏ខ្លាំង ហើយអាចវិនាសផុតពូជនៅក្នុងធម្មជាតិនាពេលអនាគតមិនយូរប៉ុន្មាន ដោយបរិមាណ សរុបបានថយចុះយ៉ាងតិច៥០(ហាសិប)ភាគរយ ក្នុងរយៈពេល១០ (ដប់) ឆ្នាំចុង

ក្រោយឬ ក្នុងរយៈពេលបីជំនាន់តំណពូជកន្លងមកតាមរយៈការអង្កេត ការប៉ាន់ប្រមាណ ការសន្និដ្ឋាន ឬការរំពឹងទុក។

- **ក្រុមប្រភេទងាយរងគ្រោះ៖** ជាប្រភេទធនធានជលផលទាំងឡាយនៅក្នុងធម្មជាតិកំពុងរងគ្រោះដែលងាយប្រឈមនឹងគ្រោះថ្នាក់ដ៏ខ្លាំង ហើយអាចនឹងវិនាសផុតពូជនៅក្នុងធម្មជាតិនាពេលអនាគតខាងមុខ ដោយបរិមាណសរុបបានថយចុះយ៉ាងតិច២០(ម្ភៃ) ភាគរយ ក្នុងរយៈពេល១០(ដប់)ឆ្នាំចុងក្រោយ ឬរយៈពេលបីជំនាន់តំណពូជកន្លងមកតាមរយៈការអង្កេត ការប៉ាន់ប្រមាណ ការសន្និដ្ឋានឬការរំពឹងទុក។

តារាងទី១: ប្រភេទធនធានជលផលសមុទ្រដែលកំពុងរងគ្រោះថ្នាក់ទាំង២៩ប្រភេទ

| លរ | ឈ្មោះជាភាសាខ្មែរ | ឈ្មោះវិទ្យាសាស្រ្ត | ឈ្មោះពាណិជ្ជកម្ម | សាយតេស |
|---|---|---|---|---|
| I. ប្រភេទជិតផុតពូជ | | | | |
| ១ | ក្រពើសមុទ្រ | *Crocodylus porosus* | Estuarine crocodile | I |
| ២ | ជ្រូកទឹកឬពយ៉ុង | *Dugong dugon* | Dugong | I |
| II. ប្រភេទកំពុងរងគ្រោះ | | | | |
| ៣ | ត្រីសេកបូក | *Cheilinus undulates* | Humphead Wrasse | II |
| ៤ | បាឡែនក្របី | *Pseudorca crassidens* | False killer whale | II |
| ៥ | បាឡែនក្បាលធំ | *Globicephala macrorhynchus* | Short-finned pilot whale | II |
| ៦ | ផ្សោតចម្រុះដបចំពុះខ្លី | *Tursiops aduncus* | Indo-Pacific bottlenose dolphin | II |
| ៧ | ផ្សោតក្បាលត្រឡោក | Orcaella brevirostris | Irrawaddy dolphin | I |
| ៨ | ផ្សោតចម្រុះដបចំពុះវែង | *Tursiops truncates* | Common bottlenose dolphin | II |
| ៩ | ផ្សោតឃ្លៀច | *Sousa chinensis* | Indo-Pacific hump-backed dolphin | I |

| | | | | |
|---|---|---|---|---|
| ១០ | ផ្សោតឆ្នូតភ្នែក | *Stenella longirostris roseinventris* | Dwarf spinner dolphin | II |
| ១១ | ផ្សោតអុច | *Stenella attenuate* | Pantropical spotted dolphin | II |
| ១២ | ផ្សោតឥតព្រុយខ្នង | *Neophocaena phocaenoides* | Finless porpoise | I |
| ១៣ | ផ្សោតខ្មៅលឿង | *Dolphinus capensis tropicalis* | Long-beaked common dolphin | I |
| ១៤ | ល្មិច | *Chelonia mydas* | Green turtle | I |
| ១៥ | ក្រាស | *Eretmochelys imbricate* | Hawksbill turtle | I |
| ១៦ | ល្មិចព្រុយបីឬល្មិចស្លឹ | *Dermochelys coriacea* | Leatherback turtle | I |
| ១៧ | ល្មិចក្បាលធំ | *Caretta caretta* | Loggerhead turtle | I |
| ១៨ | ល្មិចប្រជេះ | *Lepidochelys olivacea* | Olive ridley turtle | I |
| ១៩ | គ្រំយក្ស | *Tridacna squamosa* | Fluted giant clam | II |
| ២០ | គ្រំយក្ស | *Tridacna maxima* | Elongate giant clam | II |
| ២១ | គ្រំយក្ស | *Tridacna crocea* | Crocus giant clam | II |
| ២២ | គ្រំយក្ស | *Tridacna gigas* | Giant clam | II |
| ២៣ | ខ្យងកោដ្ឋ | *Trochus niloticus* | Commercial top | |
| ២៤ | ខ្យងគុជឬខ្យងប្រាក់ | *Turbo marmoratus* | Green turbo or green snail | |
| ២៥ | សេះសមុទ្រ | *Hippocampus spp.* | Seahorse | II |
| ២៦ | ផ្កាថ្ម | *Anthozoa spp.* | Corals and sea anemones | |
| ២៧ | ប្រឡាំងកាស | Tachypleus gigas | Traingular-tail horseshoe crab | |

| | | | | |
|---|---|---|---|---|
| ២៨ | កាចរ | *Carcinoscorpius rotundicauda* | Mangrove horseshoe crab | |
| ២៩ | ត្រីបាឡាន់គីង្គក់ | *Rhincodon typus* | Whale shark | II |

ក្នុងឆ្នាំ២០០៩ ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ទាំងនេះ ត្រូវបានកំណត់ជាផ្លូវការ ដោយអនុក្រឹត្យលេខ១២៣ អនក្រ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩។ យោងតាមច្បាប់ស្តីពីជលផល ប្រភេទដែលកំពុងរងគ្រោះថ្នាក់ទាំងនេះ ត្រូវបានហាមឃាត់ការចាប់ ការលក់ ការទិញ ការដឹកជញ្ជូន ការ ប្រមូលផល ការកែច្នៃ និងការធ្វើសន្និធិពីដែនទឹកធម្មជាតិ លើកលែងតែក្នុងគោលបំណងសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្រដែលត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋបាលជលផល។

ប្រភេទទាំងអស់នេះ ភាគច្រើនត្រូវការជម្រកព្រៃកោងកាង ស្មៅសមុទ្រ និងផ្កាថ្មជាសំខាន់ដើម្បី រស់នៅ ធំធាត់ និងបន្តពូជ ដូច្នេះយើងចាំបាច់ត្រូវការពារជម្រកទាំងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ២.៣.៣ ធនធានជម្រកជលផលនិងការគំរាមកំហែង

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយប្រកបដោយធនធានធម្មជាតិយ៉ាងសម្បូរបែប ក្នុងនោះ ផ្កាថ្ម ស្មៅសមុទ្រ និងព្រៃកោងកាង គឺជាធនធានធម្មជាតិដ៏មានសារសំខាន់បំផុតក្នុងការផ្តល់ទីជម្រកពង កូននិងរកចំណីដល់វារិសត្វជាច្រើនប្រភេទ រក្សាលំនឹងប្រព័ន្ធអេកូឡូស៊ី និងបម្រើឲ្យសេដ្ឋកិច្ចសង្គម។ ធនធាន ទាំងអស់នេះ មិនត្រឹមតែបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ត្រីដែលជាអាហារប្រចាំថ្ងៃរបស់ប្រជាជន កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែវាមានសារសំខាន់សម្រាប់ការពារឆ្នេរសមុទ្រ ជីវៈចម្រុះគ្រប់ប្រភេទ និងបម្រើទេស ចរណ៍ធម្មជាតិទៀតផង។

ផ្កាថ្មនៅក្នុងប្រទេសកម្ពុជាចែកចាយនៅទីកន្លែងជាច្រើន ជាទូទៅវាដុះជាប់ទៅនឹងកោះដែលនៅ ឆ្ងាយពីឆ្នេរនិងតំបន់ដែលមានថ្ម។ តំបន់ផ្កាថ្មសរុបត្រូវបានប៉ាន់ស្មានថា មានទំហំប្រមាណ ២៨,០៦៥ គ.ម$^{២}$ ហើយនៅប្រជុំកោះតាគៀវ មានផ្កាថ្មសរុបប្រហែល២៩២,៥ហិកតា។ តាមការវាយតម្លៃពីគម្រោងសមុទ្រ ចិនភាគខាងត្បូងបានឲ្យដឹងថា ផលិតផលជលផលផ្ទាល់ដែលបានទទួលពីផ្កាថ្មក្នុងមួយហិកតាក្នុងមួយឆ្នាំ មានតម្លៃជាប្រាក់ដុល្លាអាមេរិក២.៣០០ដុល្លា។ នេះជាតួលេខដោយផ្ទាល់ដោយពុំបានរាប់បញ្ចូលនូវតួនាទី ដ៏មានសារសំខាន់ក្នុងការបម្រើឲ្យវិស័យទេចរណ៍ ជាជម្រកនិងកន្លែងបន្តពូជរបស់សត្វសមុទ្រជាច្រើន ប្រភេទ ទប់ស្កាត់នឹងរលក ព្រមទាំងមានតួនាទីរក្សាលំនឹងបរិស្ថានជាច្រើនទៀត។ តាមរយៈការសិក្សាពី ជីវៈចម្រុះបានបង្ហាញថា មានផ្កាថ្មចំនួន៧០ប្រភេទ ស្ថិតក្នុង៣៣ពូជ និង១១អំបូរ (Nelson 1999)។ ជា មធ្យមផ្កាថ្មនៅមានជីវិតគ្របដណ្តប់

តំបន់ឆ្នេរប្រមាណពី២៣%ទៅ៥៨%។ ផ្កាថ្មរស់ក្នុងតំបន់ទឹកដែលមាន កំហាប់អំបិលចន្លោះ៣៤-៣៧ភាគ៣ាន់ ជាតំបន់គ្មានល្បាប់ភក់ ទឹកមានសភាពស្អាតនិងថ្លា មានពន្លឺគ្រប់ គ្រាន់ និងជាតំបន់គ្មានការបំពុល។

ប្រព័ន្ធផ្កាថ្មនៅក្នុងប្រទេសកម្ពុជាកំពុងតែទទួលរងនូវការគំរាមកំហែងដ៏គួរឲ្យព្រួយបារម្ភបំផុតដូចជា ៖

- កំណាកនិងសារធាតុចិញ្ចឹម (ចេញពីតំបន់ដីគោក) ការធ្វើកសិកម្មនិងការអភិវឌ្ឍនៅតំបន់ឆ្នេរ បានរួមចំណែកបង្កការបំផ្លាញផ្កាថ្មនៅក្នុងប្រទេសកម្ពុជា ដោយធ្វើឱ្យមានកំណាកនិងភាពកខ្វក់ហូរពីតំបន់ដីគោក។ ដោយគ្មានវិធានការបន្ធូបន្ថយឱ្យទាន់ពេលវេលា បរិមាណដីនិងការហូរច្រោះធ្លាក់ពីតំបន់ខ្ពស់ៗចាក់ទៅតំបន់ផ្កាថ្មក្បែរឆ្នេរជារៀងរាល់ឆ្នាំ។ ការហូរចាក់ដោយ កំណាកករនេះបានរុំព័ទ្ធតួផ្កាថ្ម ហើយទីបំផុតបានធ្វើឲ្យផ្កាថ្មងាប់ ដោយសារពុំអាចធ្វើរស្មីសំយោគបាន។
- វិធីសាស្ត្រនេសាទដែលបង្កឱ្យមានការខូចខាតផ្អែកលើទិន្នន័យ Reef checknig និងការសិក្សាផ្សេងៗបានបង្ហាញថា គ្រឿងផ្ទុះ គឺជាការគំរាម កំហែងដ៏ចម្បងមួយទៅលើផ្កាថ្មនៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះ ការប្រើគ្រឿងផ្ទុះក្នុង ការនេសាទស្ទើរតែពុំមានទៀតទេ។ ជាងនេះទៅទៀត ការនេសាទដោយប្រើថ្នាំបំពុល ដើម្បីចាប់ត្រីផ្កាថ្ម ជាពិសេស ត្រីតុកែបានធ្វើឲ្យបំពុលដល់ផ្កាថ្ម និងការនេសាទដោយអួនអូសនៅក្បែរតំបន់ផ្កាថ្មដែលបង្កជា កករុំព័ទ្ធតួផ្កាថ្ម ហើយធ្វើឲ្យផ្កាថ្មងាប់។
- ការបាក់បែកផ្កាថ្មដោយយុថ្កានិងអួនអូស ព្រមទាំងការបំផ្លាញផ្សេងៗទៀការបាក់បែកផ្កាថ្មដែលបណ្ដាលមកពីយុថ្កាកើតឡើងនៅលើតំបន់ផ្កាថ្មជាច្រើនក្នុងប្រទេសកម្ពុជា។ ការបាក់បែកផ្កាថ្មដែលបណ្ដាលពីយុថ្កាភាគច្រើនមកពីទូកអ្នកនេសាទ ព្រោះគ្មានពោងបណ្ដែតសម្រាប់ឱ្យ ទូកអាចចងភ្ជាប់បាន ហើយកត្តាដែលអ្នកនេសាទពុំមានការយល់ដឹងឬយកចិត្តទុកដាក់ចំពោះការបាក់បែក ដែលបណ្ដាលមកពីការបោះយុថ្កាទៅលើតំបន់ផ្កាថ្ម។ ការទម្លាក់យុថ្ការបស់ទូកទេសចរណ៍នៃអ្នកមុជទឹក និងការដើរជាន់ផ្កាថ្មកំពុងមានការគំរាមកំហែងទៅលើផ្កាថ្មនៅមានកម្រិតទាបបំផុត។ ទោះជាយ៉ាងនេះក្ដី វាក៏អាចជាសក្ដានុពលនៃការគំរាមកំហែងមួយនាពេលអនាគត នៅពេលដែលឧស្សាហកម្មទេសចរណ៍មាន ការកើនឡើង។ការបំផ្លាញផ្កាថ្មដែលកើតឡើងដោយសកម្មភាពនេះ គឺបណ្ដាលពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដូចជា ការដាំសាពាយដោយផ្ទាល់នៅលើតំបន់ផ្កាថ្មដែលបង្កឱ្យមានការបាក់បែក ដោយសារការដើរជាន់ផ្កាថ្មនិង ការបោះចោលកាកសំណល់ឧបករណ៍នេសាទ។
- ការអភិវឌ្ឍដែលធ្វើឱ្យបាក់បែកដល់ផ្កាថ្ម (ផែ ព្រលានយន្តហោះ ការជីកកកាយ)មានសកម្មភាពសាងសង់ជាច្រើននៅលើតំបន់ឆ្នេរ ប៉ុន្តែទំហំនៃផលប៉ះពាល់ទៅលើផ្កាថ្មយ៉ាងណា

នោះមិនទាន់ត្រូវបានគេដឹងនៅឡើយទេ។ សកម្មភាពសាងសង់ រួមមានការពង្រីកកំពង់ផែពាណិជ្ជកម្ម សណ្ឋាគារផ្កាយប្រាំ និងទីលានវាយកូនហ្គោលត្រូវបានគេធ្វើឡើងនៅក្រុងព្រះសីហនុ។ ទោះបីជារដ្ឋាភិបាលមានគោលនយោបាយអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថានក៏ដោយ ប៉ុន្តែផលប៉ះពាល់នៅតែកើត មានដដែល។

- ការបង្កឱ្យផ្កាថ្មងាប់ (ធ្វើឱ្យផ្កាថ្មប្រែជាពណ៌ស bleaching)មានទិន្នន័យជាក់ច្បាស់បង្ហាញថាក្នុងឆ្នាំ២០១០ នៅពេលដែលកំដៅនៃទឹកសមុទ្របានកើនដល់ ៣២ទៅ៣៥អង្សាសេ ផ្កាថ្មប្រមាណ៨០% នៅខេត្តព្រះសីហនុ បានប្រែជាពណ៌ស ហើយនឹងឈានទៅ ងាប់។ ប៉ុន្តែដោយសារមានការសង្គ្រោះបន្ទាន់ ជាពិសេស ក្រុមការងារបានសំអាតបរិស្ថានផ្កាថ្ម ហាមឃាត់ទូកអូសនៅក្បែរតំបន់ផ្កាថ្ម និងជាពិសេសទប់ស្កាត់ការបោះចោលកាកសំណល់លើតំបន់ផ្កាថ្មបានទាន់ ពេលវេលា ទើបយើងអាចស្តារផ្កាថ្មឲ្យរស់មកវិញជាបណ្តើរៗ។
- ការបំផ្លាញផ្កាថ្មតាមរយៈបាតុភូតធម្មជាតិ (ខ្យល់ព្យុះ។ល។) ពុំមានភស្តុតាងជាលក្ខណៈវិទ្យាសាស្ត្រណាដែលបង្ហាញពីការបាក់បែកផ្កាថ្មដោយបាតុភូតធម្មជាតិទេ។ ប៉ុន្តែមានរបាយការណ៍ស្តីពីព្រឹត្តិការណ៍បំផ្លាញផ្កាថ្មធ្ងន់ធ្ងរនៅក្នុងឆ្នាំ១៩៩៨ ដោយបាតុភូតខ្យល់ព្យុះឡិនដានៅតំបន់អាស៊ីអាគ្នេយ៍។

***ការបង្ហាញពីមូលហេតុដែលបង្កឲ្យផ្កាថ្មងាប់នេះ គឺសម្រាប់ឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ផ្សេងៗយល់ដឹង និងមានវិធានការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព។***

## ៣. វិធីសាស្ត្រនិងសម្ភារៈស្រាវជ្រាវ

### ៣.១ វិធីសាស្ត្រវាយតម្លៃសកម្មភាពនេសាទនិងធនធានជលផល

ការវាយតម្លៃពីសកម្មភាពនេសាទនិង ធនធានជលផលដែលប្រមូលបាននៅក្នុងតំបន់អភិវឌ្ឍន៍កោះ ក្របីនេះ គឺមានសារសំខាន់និងជាជំហានដំបូងក្នុងដំណើរការតាមដានការសាងសង់គម្រោង។ ការសិក្សា ទាំងនេះ អាចឲ្យយើងដឹងថាតើប្រជាពលរដ្ឋបានពឹងផ្អែកលើធនធានជលផលក្នុងតំបន់នេះយ៉ាងដូចម្តេច ហើយថាតើត្រូវកាត់បន្ថយផលប៉ះពាល់ទៅលើសកម្មភាពនេសាទនិងធនធានជលផលយ៉ាងណា ព្រមទាំង អាចឲ្យយើងដឹងថាតើអ្នកនេសាទអាចទទួលបានអ្វីខ្លះពីគម្រោងនេះ។ ជារួម ទិដ្ឋភាពទាំងនេះអាចជួយកាត់ បន្ថយជម្លោះរវាងអ្នកនេសាទនិងក្រុមហ៊ុនអភិវឌ្ឍន៍ ព្រមទាំងអាចធានាបានសកម្មភាពនេសាទនិងធនធាន ជលផលនៅក្នុងតំបន់អភិវឌ្ឍន៍ប្រកបដោយចីរភាព។

### ៣.១.១ ការសិក្សាអង្កេតសកម្មភាពនេសាទនិងធនធានជលផលដែលប្រមូលបាន

នៅក្នុងដំណើរការនៃការប្រមូលព័ត៌មាននេះក្រុមជំនាញរបស់នាយកដ្ឋានអភិរក្សជលផល ចំនួន ០៥រូប ត្រូវបានជ្រើសរើសឲ្យចុះសិក្សាវាយតម្លៃពីបស្ថានភាពនេសាទ និងធនធានជលផល ដែលប្រមូលបាន នៅក្នុងតំបន់កោះក្របីនេះ។ តាមគ្រោង ការចុះសិក្សាត្រូវប្រើរយៈពេលត្រឹម៥ថ្ងៃ ប៉ុណ្ណោះ ប៉ុន្តែដោយសារ អាកាសធាតុពុំអំណោយផល (ភ្លៀងធ្លាក់ស្ទើររាល់ថ្ងៃ) ធ្វើឲ្យសកម្មភាព ស្រាវជ្រាវបានពន្យាពេលរហូតដល់ ១០ថ្ងៃ គឺចាប់ពីចាប់ពីថ្ងៃទី០១ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ ២០១៣។ នៅក្នុងដំណើរការប្រមូលព័ត៌មាននេះ ក្រុមការងារបានរៀបចំជាបញ្ជីសំណួរ ដោយបែង ចែកជាជំពូកផ្សេងៗ ជាពិសេសគឺផ្តោតទៅលើមេគ្រួសារ មុខរបរប្រចាំគ្រួសារ ប្រាក់ចំណូល សកម្មភាពនេសាទ ប្រភេទធនធានជលផលដែលចាប់បានឧបករណ៍ នេសាទដែលបានប្រើប្រាស់ និង ចំណូលបានពីការនេសាទ។

### ៣.១.២ ដំណើរការនៃការប្រមូលព័ត៌មាន

នៅក្នុងដំណើរនៃការប្រមូលព័ត៌មាន ក្រុមការងារបានធ្វើការសម្ភាសន៍ជាមួយប្រជាពលរដ្ឋ ដែលជា អ្នកនេសាទចំនួន៣០គ្រួសារ ស្ថិតក្នុងឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ហើយបន្ទាប់មក ក្រុមការងារ បានពិនិត្យស្រង់យកព័ត៌មានពីគ្រួសារអ្នកនេសាទណាដែលបាននិងកំពុងធ្វើនេសាទនៅក្នុងតំបន់ប្រជុំកោះតាគៀវ ជាពិសេសនៅជុំវិញកោះក្របី។ ជាលទ្ធផល គឺក្រុមការងារបាន ចម្រាញ់យកព័ត៌មានពីគ្រួសារអ្នក នេសាទត្រឹម១៧គ្រួសារតែប៉ុណ្ណោះដែលបានធ្វើនេសាទក្នុងតំបន់ នេះ ដើម្បីជៀសវាងនូវភាពលំអៀងច្រើន។

ការប្រមូលព័ត៌មានត្រូវបានធ្វើនៅចន្លោះម៉ោង៣ទៅ៥ល្ងាច ប៉ុណ្ណោះ ពីព្រោះពេលវេលា នេះ គឺពួក អ្នកនេសាទទើបបានត្រឡប់ពីការនេសាទភ្លាមៗ ហើយពេលវេលានេះអាចឲ្យយើង ពិនិត្យមើលប្រភេទត្រី ផលត្រីដែលចាប់បាននិងឧបករណ៍នេសាទដែលពួកគេបានប្រើប្រាស់។ ការ ស្រង់យកព័ត៌មានត្រូវបានធ្វើ តាមរយៈការសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកនេសាទនីមួយៗ ព្រមទាំងបានថតយករូបភាពត្រីនិងធនធាន ជលផលដទៃទៀតដែលពួកគេប្រមូលបានពីក្នុងតំបន់ អភិវឌ្ឍន៍។ ចំពោះប្រភេទត្រីដែលចាប់បានត្រូវបាន កំណត់អត្តសញ្ញាណតាមសៀវភៅអត្តទេសក៍ អំពីប្រភេទធនធានជលផលសមុទ្រក្នុងព្រះរាជាណាចក្រ កម្ពុជាផលិតដោយរដ្ឋបាលជលផលក្នុង ឆ្នាំ២០០៨។

៣.១.៣ ការវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបានត្រូវបានត្រួតពិនិត្យដោយប្រុងប្រយ័ត្ន ហើយបញ្ចូលទៅក្នុងកំព្យូទ័រដោយ ប្រើកម្មវិធី Microsoft Excel ដើម្បីវិភាគនិងវាយតម្លៃ។ លទ្ធផលនៃការវិភាពនេះត្រូវបានយកមកបក ស្រាយតាមរយៈតារាងនិងក្រាហ្វិក។

ចំណែកតម្លៃឬប្រាក់ចំណូលដែលទទួលបានជាប្រាក់រៀល ត្រូវបានគណនាជាប្រាក់ដុល្លាអាមេរិក ដោយគិតក្នុងអត្រា១ដុល្លាស្មើនឹង៤.១០០រៀល។

៣.២ វិធីសាស្ត្រវាយតម្លៃប្រព័ន្ធអេកូឡូស៊ីស្រទាប់បាត

នៅក្នុងសកម្មភាពសិក្សាដើម្បីវាយតម្លៃប្រព័ន្ធអេកូឡូស៊ីស្រទាប់បាតនៅជុំវិញកោះក្របី ត្រូវបានធ្វើ ឡើងដោយមន្ត្រីជំនាញរបស់នាយកដ្ឋានអភិរក្សជលផលចំនួន០៨រូប ដែលមានជំនាញ GIS ជំនាញមុជ ទឹក និងជំនាញកំណត់ពីស្ថានភាពផ្កាថ្ម និងជំនាញកំណត់អត្តសញ្ញាណជីវសាស្ត្រសមុទ្រ។ ការសិក្សានេះ ត្រូវបានធ្វើនៅតាមទីតាំងចំនួន២០ទីតាំង នៅជុំវិញកោះក្របីដែលបានជ្រើសរើសដោយចៃដន្យ និងដោយ គិតទៅលើស្ថានភាពចរន្តទឹក និងសុវត្ថិភាពជាចម្បង។ ខាងក្រោមនេះ ជាចំណុចទាំង២០ទីតាំង ដែលត្រូវ បានកំណត់ក្នុងសកម្មភាពស្រាវជ្រាវ៖

តារាងទី២: ទីតាំងស្រាវជ្រាវប្រព័ន្ធអេកូឡូស៊ីបាតសមុទ្រនៅជុំវិញកោះក្របី

| ទីតាំងស្រាវជ្រាវ | UTM (Y) | 48P (X) | ទីតាំងស្រាវជ្រាវ | UTM (Y) | 48P (X) |
|---|---|---|---|---|---|
| 1 | 1161696 | 0343600 | 11 | 1161633 | 0343176 |
| 2 | 1161573 | 0343589 | 12 | 1161778 | 0343152 |
| 3 | 1161493 | 0343570 | 13 | 1161897 | 0343174 |
| 4 | 1161416 | 0343555 | 14 | 1161929 | 0343194 |
| 5 | 1161479 | 0343684 | 15 | 1162055 | 0343211 |
| 6 | 1161586 | 0343691 | 16 | 1162048 | 0343322 |
| 7 | 1161470 | 0343444 | 17 | 1162015 | 0343436 |
| 8 | 1161492 | 0343325 | 18 | 1161936 | 343538 |
| 9 | 1161547 | 0343242 | 19 | 1161816 | 343593 |

| | | | | | |
|---|---|---|---|---|---|
| 10 | 1161625 | 0343228 | 20 | 1161757 | 343594 |




រូបទី៣៖ ផែនទីទីតាំងស្រាវស្រាវធនធានស្រទាប់បាតនៅជុំវិញកោះក្របី

នៅក្នុងការសិក្សានេះ មានសូចនាករមួយចំនួនត្រូវបានកំណត់ឡើង ដើម្បីទុកជាទិន្នន័យគ្រឹះក្នុង ការតាមដានបម្រែបម្រួលប្រព័ន្ធអេកូឡូស៊ីស្រទាប់បាត ដូចជា៖

- ទីតាំងផ្កាថ្ម ប្រភេទផ្កាថ្ម សុខភាពផ្កាថ្ម និងភាគរយនៃផ្កាថ្មរស់ កំណត់ដោយGPS និង ផ្ទាំងគំរូប្រភេទផ្កាថ្ម (ដូចក្នុងរូបភាពទី៤)
- ប្រភេទត្រីនិងធនធានជលផលដទៃទៀតដែលរស់នៅក្នុងតំបន់ផ្កាថ្ម កំណត់ដោយ ផ្ទាំងគំរូ ប្រភេទត្រីផ្កាថ្ម (ដូចក្នុងរូបទី៤)
- ជម្រៅទឹក កម្រិតថ្លាដែលអាចមើលឃើញ និងប្រភេទស្រទាប់បាត ពិនិត្យដោយខ្សែម៉ែត្រ និងដោយប៉ាន់ស្មានដោយភ្នែកធម្មតា។




រូបទី៨៖ ផ្ទាំងគំរូស្រម្រាប់កំណត់ប្រភេទផ្កាថ្ម ស្ថានភាពផ្កាថ្ម និងប្រភេទត្រីផ្កាថ្ម

នៅក្នុងការស្រាវជ្រាវនេះ មានប្រើវិធីសាស្ត្រខ្សែពំនុះកាត់ទទឹង (Intercept Transect, LIT) គួបផ្សំ នឹងសំភារៈមួយចំនួន ដើម្បីចាប់យករូបភាពច្បាស់លាស់ ដូចជាម៉ាស៊ីនថតនៅក្នុងទឹក (Canon G9, Olympus C5050, Olympus Udigital600 or Olympus U1030SW)។ វិធីសាស្ត្រនេះ ត្រូវបាននិយម ប្រើប្រាស់ក្នុងការវាយតម្លៃធនធានជលផលនៅបាតសមុទ្រ ពីព្រោះថាអាចផ្តល់ឱ្យ យើងនូវសមត្ថភាពក្នុង ការយកសំណាកប្រកបដោយប្រសិទ្ធភាពខ្ពស់ ទាំងគុណភាព និងបរិមាណ និងក្នុងទឹកន្លែងដែលមានទំហំ ធំៗ ហើយមានរយៈពេលស្រាវជ្រាវខ្លី។

ទីតាំងនីមួយៗ ត្រូវបានកំណត់ជាពីរចំណុចតូចៗ គឺចំណុចចាប់ផ្តើមមុជនិងចំណុចចងើប ចេញ។ ជាទូទៅ ចំងាយពីចំណុចចាប់ផ្តើមនិងចំណុចងើបមានប្រមាណពី២០ទៅ១០០ម៉ែត្រ។ ទិស ដៅនៃចំណុច ទាំងពីរនេះ គឺអាស្រ័យទៅតាមស្ថានភាពបាតសមុទ្រ ស្ថានភាពចរន្តទឹក និងស្ថាន ភាពសុវត្ថិភាព។

ការស្រាវជ្រាវនេះ មានក្រុមអ្នកមុជទឹកចំនួន៨នាក់ ហើយបែងចែកជា២ក្រុម គឺក្រុមនីមួយៗ មានគ្នា ២នាក់។ ក្រុមអ្នកមុជទាំងនេះ សុទ្ធសឹងមានសមត្ថភាពខ្ពស់ក្នុងការកំណត់អត្តសញ្ញាណប្រ ភេទដែលបាន ជួបប្រទះនៅទីតាំងនីមួយៗ។ ក្នុងពេលមុជម្តងៗ អ្នកមុជទាំង២រូបត្រូវមុជដំណាល

គ្នារហូតដល់បាតសមុទ្រ ហើយហែលទៅតាមទិសដៅដែលបានកំណត់ ដោយចំណាយរយៈពេលពី១០ទៅ២០នាទី ទើបងើបចេញ ពីទឹក។ សមាជិកក្រុមការងារនីមួយៗអាចជួយគ្នាក្នុងការប្រមូលព័ត៌មានឱ្យបានច្បាស់លាស់ និងអាចជួយ យកអាសារគ្នាក្នុងពេលមានបញ្ហាកើតឡើងជាយថាហេតុ។

## ៤. លទ្ធផលនៃការស្រាវជ្រាវ

### ៤.១ លទ្ធផលនៃការស្រាវជ្រាវសកម្មភាពនេសាទនិងធនធានជលផល

#### ៤.១.១ លក្ខណៈទូទៅនៃគ្រួសារអ្នកនេសាទ

ការស្រាវជ្រាវលើសកម្មភាពទូទៅនៃការនេសាទ ត្រូវបានធ្វើទៅលើគ្រួសារអ្នកនេសាទចំនួន៣០ គ្រួសារប៉ុន្តែលទ្ធផលដែលយកមកវិភាគត្រូវបានធ្វើតែទៅលើតែ១៧គ្រួសារប៉ុណ្ណោះដែលអ្នកទាំងនោះតែង តែធ្វើនេសាទនៅក្នុងតំបន់កោះក្របី ហើយពួកគេទាំងអស់នេះភាគច្រើនមកពីឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះ សីហនុ។

ការធ្វើនេសាទក្នុងតំបន់នេះភាគច្រើន គឺជាបុរសដែលជាមេគ្រួសារ ដែលមានវ័យប្រមាណ១៩ដល់ ៥៥ឆ្នាំ។ ជារួមអ្នកនេសាទទាំងនេះភាគច្រើនពុំមានដីស្រែសម្រាប់ប្រកបរបរកសិកម្មទេ គឺពឹងផ្អែកទាំងស្រុង ទៅលើការនេសាទ។

តាមការវិភាគទិន្នន័យបានបង្ហាញថា ប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំនៃគ្រួសារអ្នកនេសាទគិតជា ដុល្លាគឺ១២.៤៥៦ដុល្លា ហើយមានគ្រួសារខ្លះអាចរកប្រាក់ចំណូលប្រចាំឆ្នាំរហូតដល់២៦.២០០ដុល្លា ប៉ុន្តែ មានមួយចំនួនទៀតទទួលបានតិចតួចត្រឹមតែជិត៣.០០០ដុល្លាប៉ុណ្ណោះ។ ជារួម សមាជិកអ្នកនេសាទក្នុង មួយគ្រួសារជាមធ្យមគឺ៦នាក់ ហើយប្រសិនយើងគិតប្រាក់ចំណូលត្រឹម១ដុល្លាក្នុងម្នាក់ក្នុងមួយថ្ងៃ នោះ ប្រាក់ចំណូលប្រចាំឆ្នាំក្នុងមួយគ្រួសារ គឺ២.១៩០ដុល្លា ប្រសិនគិតប្រាក់ចំណូលក្នុងចន្លោះ១ទៅ២ដុល្លា នោះប្រាក់ចំណូលប្រចាំឆ្នាំគឺ២.១៩០ទៅ៤.៣៨០ ហើយប្រសិនចំណូលច្រើនជាង២ដុល្លា ប្រាក់ចំណូល ប្រចាំឆ្នាំនឹងកើនលើស៤.៣៨០ដុល្លា។ តាមរយៈការវិភាគ និងក្រាហ្វិកទី១ បានបង្ហាញថា ពុំមានគ្រួសារ ណាទទួលបានប្រាក់ចំណូលប្រចាំឆ្នាំតិចជាង២.១៩០ដុល្លាទេ ឯគ្រួសាដែលមានប្រាក់ចំណូលចន្លោះ ២.១៩០ទៅ៤៣៨០ដុល្លាមាន២% ឯគ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំច្រើនជាង៤.៣៨០ដុល្លាមាន រហូតដល់៨៨%ឯណោះ។

បើប្រៀបធៀបនឹងបន្ទាត់ភាពក្រីក្រ ដោយយកចំណូល១ដុល្លាក្នុងម្នាក់ក្នុង០១ថ្ងៃជាគោលនោះប្រាក់ ចំណូលប្រចាំឆ្នាំរបស់គ្រួសារអ្នកនេសាទនីមួយៗនៅក្នុងតំបន់នេះមានជីវភាពសមរម្យបំផុត។




ក្រាហ្វិកទី១៖ គម្លាតប្រាក់ចំណូលប្រចាំឆ្នាំដែលគ្រួសារអ្នកនេសាទទទួលបាន

តាមក្រាហ្វិកទី២បង្ហាញថា ប្រភពប្រាក់ចំណូលរបស់អ្នកនេសាទជាសំខាន់ គឺបានមកពីការលក់ ផលនេសាទរបស់ខ្លួនផ្ទាល់ ដែលមានរហូតដល់៩៨% ហើយក្រៅពីនេះបានមកពីលក់ស្រូវតិចតួចត្រឹម១% និងលក់កម្លាំងពលកម្មត្រឹមតែ១%ប៉ុណ្ណោះ។ នេះសបញ្ជាក់ថា ប្រជាពលរដ្ឋដែលធ្វើនេសាទក្នុងតំបន់នេះពុំ អាចបាត់បង់មុខរបរនេសាទនេះបានឡើយ ហើយធនធានជលផលនៅក្នុងតំបន់នេះមានសារសំខាន់ណាស់ ដែលជាប្រភពចំណូលជាចម្បងបំផុត ដែលនេះចាំបាច់ត្រូវថែរក្សាការពារឲ្យបានគង់វង្សជានិរន្តរ៍។




ក្រាហ្វិកទី២: ប្រភពប្រាក់ចំណូលប្រចាំគ្រួសារ

### ៤.១.២ សកម្មភាពនេសាទ

ជាទូទៅ ការនេសាទក្នុងតំបន់នោះមានសកម្មភាពខ្លាំងក្នុងរយៈពេល១៥ឆ្នាំក្រោយនេះ ប៉ុន្តែមាន អ្នកនេសាទមួយចំនួនបានធ្វើនេសាទនេះចាប់តាំងពីក្រោយរបប ប៉ុល ពត មកម្ល៉េះ គឺមានរយៈពេលរហូត ដល់ជាង៣០ឆ្នាំមកហើយ។

មានប្រភេទឧបករណ៍នេសាទជាច្រើនប្រភេទត្រូវបានប្រើនៅក្នុងតំបន់គម្រោង ប៉ុន្តែប្រភេទសំខាន់ រួមមានមងក្តាម មងត្រី មងបង្គា និងលបក្តាមសេះ ហើយប្រភេទឧបករណ៍នេសាទទាំងអស់នេះត្រូវបាន ប្រើទៅតាមរដូវ ជាពិសេសទៅតាមប្រភេទដែលពួកគេចង់ចាប់និងសម្បូរ។ ទំហំនិងបរិមាណឧបករណ៍ នេសាទដែលប្រើនេះមានការប្រែប្រួលទៅតាមស្ថានភាពអ្នកនេសាទ ប៉ុន្តែជាទូទៅក្នុងមួយគ្រួសារៗមានប្រើ លបក្តាមពី១០០ទៅ៥០០លប មងក្តាមពី៥ទៅ៨០ដៃ (១៥០ដល់ ១.២០០ម៉ែត្រ) មងត្រី២៥ទៅ៣០ដៃ (៦២៥ដល់៧៥០ម៉ែត្រ) និង មងបង្គាពី១០ដល់១០០ដៃ (២៥០ដល់២.៥០០ម៉ែត្រ)។ ក្រៅពីការប្រើប្រាស់ ឧបករណ៍ទាំងនេះ ពួកអ្នកនេសាទបានរាវយកពពួកគ្រំ ខ្យង និងងាវផងដែរ។

តាមការវិភាគនិងពិនិត្យជាក់ស្តែង ជារៀងរាល់ឆ្នាំ មងនិងលបក្តាមត្រូវបានប្រើភាគច្រើនក្នុងចន្លោះ ចាប់ពីខែមីនាដល់ឧសភា មងបង្គាចាប់ពីខែមិថុនាដល់សីហា ឯមងត្រីត្រូវបានប្រើភាគច្រើនក្នុងចន្លោះចាប់ ពីខែកញ្ញាដល់កុម្ភៈ។

### ៤.១.៣ ប្រភេទធនធានជលផលដែលប្រមូលបាន

មានធនធានជលផលចំនួនប្រាំប្រភេទសំខាន់ៗដែលប្រមូលបានក្នុងតំបន់គម្រោង និងជាប្រភពចំណូលយ៉ាងសំខាន់សម្រាប់អ្នកនេសាទ គឺក្តាមសេះ បង្គាស/ខ្លឹង ត្រីកាម៉ុង បបែល និងត្រីប៉ាឡាំង។

តារាងទី៣៖ ប្រភេទធនធានជលផលសំខាន់ៗដែលមានវត្តមាននៅក្នុងតំបន់គម្រោង

| ចំណាត់ថ្នាក់ | ប្រភេទ | ភាគរយ | តំលៃ/គីឡូក្រាម |
|---|---|---|---|
| ១ | ក្តាមសេះ | ៤០% | ៥-៧ដុល្លា |
| ២ | បង្គាស/ខ្លឹង | ២០% | ៥ដុល្លា |
| ៣ | ត្រីកាម៉ុង | ២០% | ០,៣ដុល្លា |
| ៤ | បបែល | ១០% | ១ដុល្លា |
| ៥ | ត្រីប៉ាឡាំង | ១០% | ១,៥ដុល្លា |

តាមរយៈការប្រើឧបករណ៍ខាងលើបានបញ្ជាក់ថា ប្រភេទក្តាមសេះសម្បូរក្នុងចន្លោះខែមីនាដល់ ឧសភា បង្គាសសម្បូរក្នុងចន្លោះខែមិថុនាដល់សីហា និងត្រីកាម៉ុងសម្បូរក្នុងខែមករាដល់មីនា និងត្រីផ្សេងៗ ទៀតអាចចាប់បានគ្រប់រដូវ។

ជារួម ធានធានជលផលនៅក្នុងតំបន់នេះមានប្រមាណជាង៨៦ប្រភេទ ដែលមានវត្តមានក្នុងតំបន់ គម្រោង ដូចក្នុងតារាងទី៨ខាងក្រោម។ ក្នុងចំណោមប្រភេទទាំងអស់នេះ មានប្រភេទខ្លះមានវត្តមានជា អចិន្ត្រៃយ៍ ជាពិសេសពពួកប្រភេទត្រីថ្កាថ្ម ពពួកប្រភេទក្តាមនិងបង្គា ប្រភេទសត្វគ្មានឆ្អឹងខ្នង និងប្រភេទ ខ្យង គ្រំ ងាវ ឯប្រភេទផ្សេងទៀត ជាពិសេសពពួកផ្សោតមានទៅតាមរដូវប៉ុណ្ណោះ។

តារាងទី៨៖ ប្រភេទធនធានជលផលដែលមាននៅក្នុងតំបន់គម្រោង

| លរ | ឈ្មោះខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះពាណិជ្ជកម្ម | សំគាល់ |
|---|---|---|---|---|
| (ប្រភេទដែលពិនិត្យឃើញក្នុងពេលសម្ភាសន៍) | | | | |
| ១ | ត្រីបោះត្រា | *Lutjanusrusselli* | Russell's snapper | Coral reef fish |
| ២ | ត្រីគុកែជ្រូក | *Cromileptesaltivelis* | Humpback grouper | Coral reef fish |
| ៣ | ត្រីគុកែប៉ាក់ | *Epinephelusquoyanus* | Longfin grouper | Coral reef fish |
| ៤ | ត្រីគុកែកៅ | *Epinepheluscoioides* | Orange spotted grouper | Coral reef fish |
| ៥ | ត្រីគុកែអុចខៀវ | *Plectropomusoligocanthus* | Highfin grouper | Coral reef fish |
| ៦ | ត្រីកន្តាំងភ្លើង | *Siganusguttatus* | Orangespottedspinefoot | Coral reef fish |
| ៧ | ត្រីមេអំបៅ | *Chelmonrostratus* | Copperbanded butterfly fish | |
| ៨ | ត្រីសេក | *Cheilinusundulatus* | Humphead Wrasse | Coral reef fish |
| ៩ | ត្រីគ្រាប់ខ្នុរ | *Lethrinuslentjan* | Pinkear emperor | |
| ១០ | ត្រីគ្រាប់ខ្នុរ | *Lethrinusminiatus* | Sweetlip emperor | |
| ១១ | ត្រីគោ | *Pseudotriacanthusstrigilifer* | Longspinedtripodfish | |
| ១២ | ត្រីឆ្លាមឆ្កួត | *Chiloscylliumpunctatum* | Brown banded bamboos shark | |
| ១៣ | ត្រីត្រសក់ | *Petatestheraps* | Largesscaledterapon | |
| ១៤ | ត្រីប្រម៉ា | *Nibeasoldado* | Soldier croaker | |
| ១៥ | ត្រីប្រម៉ាអូច | *Nibea soldado* | Soldier croaker | |
| ១៦ | ត្រីអណ្តាតឆ្កែ | *Paraplagusiabilineata* | Doublelinedtonguesole | |

| | | | | |
|---|---|---|---|---|
| ១៧ | ត្រីកន្តាំងក្រអូប | *Siganuscanaliculatus* | White spotted spinefoot | |
| ១៨ | ត្រីកន្តាំងប្រផេះ | *Siganus argenteus* | Streamlined spinefoot | |
| ១៩ | ត្រីកាម៉ុងខ្លួនខ្លី | *Rastrelligerbrachysoma* | Short mackerel | |
| ២០ | ត្រីប៉ាឡាំង | *Rastrelligerkanagurta* | Indian mackerel | ត្រីកាម៉ុងខ្លួនវែង |
| ២១ | ត្រីកាឡាំង | *Scomberoides commersonianus* | Talang queenfish | |
| ២២ | ត្រីចិន | *Saurida sp.* | Lizardfish | |
| ២៣ | ត្រីស្គង់ក្រហម | *Lutjanusvitta* | Brownstripe snapper | |
| ២៤ | ត្រីបេកាឆ្នូត | *Scomberomoruscommerson* | Narrowbarred | |
| ២៥ | ត្រីកូនគុំ | *Atule mate* | Yellotailscad | |
| ២៦ | ត្រីកុក | *Trichiurus lepturus* | Largehead hairtail | |
| ២៧ | ត្រីកន្ទុយរឹង | *Megalaspis cordyla* | Torpedo scad | |
| ២៨ | ត្រីកាភ៉ាវ | *Polydactylus indicus* | Indian threadfin | |
| ២៩ | ត្រីគូនបារាំង | *Amblygaster sirm* | Spotted sardinella | |
| ៣០ | ត្រីក្អុក | *Arius maculatus* | Spotted catfish | |
| ៣១ | ត្រីកាម៉យ | *Anodontostoma chacunda* | Chacunda gizzard shad | |
| ៣២ | បបែលមាន់ | *Himanturaimbricata* | Scaly whipray | |
| **ប្រភេទក្តាមនិងបង្គា (ប្រភេទដែលពិនិត្យឃើញក្នុងពេលសម្ភាសន៍)** | | | | |
| ៣៣ | ក្តាមសេះ | *Portunuspelagicus* | Flower crab | |
| ៣៤ | ក្តាមអុចបី | *Portunussanguinolentus* | Three spot swimming crab | |
| ៣៥ | ក្តាមថ្ម | *Scylla serrata* | Giant mud crab | |
| ៣៦ | ក្តាមពីងពាងគូថស្រួច | Doclea tetraptera | | |
| ៣៧ | បង្កងកណ្តូប | *Anchisquilla fasciata* | | |
| ៣៨ | បង្គាប៉ាភ៉ា | *Penaeus* | Green tiger shrimp | |

| | | | | |
|---|---|---|---|---|
| | | *semisulcatus* | | |
| ៣៩ | បង្គាខ្លឹង | *Penaeusmonodon* | Giant tiger prawn | |
| ៤០ | បង្គាកុងឡាយ | *Penaeusesculentus* | Tiger Prawn | |
| ៤១ | បង្គាអាងខា | *Penaeuspenicillatus* | | |
| ពពួកខ្យង គ្រំ ងាវ (ប្រភេទដែលពិនិត្យឃើញក្នុងពេលសម្ភាសន៍) | | | | |
| ៤២ | ខ្យងដូង | *Melomelo* | Indian volute | |
| ៤៣ | ខ្យងត្នោត | *Cymbiolanobilis* | Nodle volute | |
| ៤៤ | ខ្យងជើងមួយ | *Strombuscanarium* | Dog conch | |
| ៤៥ | ខ្យងពងគ្រួច | *Babylonia areolata* | Maculated ivory whelk | |
| ៤៦ | គ្រែងឈាម | *Anadara nodifera* | Nodular ark | |
| ៤៧ | ងាវហ្វេល | *Meretrix lusaria* | Poker-chip venus | |
| ៤៨ | ងាវស | *Donax faba* | Pacific bean donax | |
| ៤៩ | គ្រំចំពុះទា | *Pernaviridis* | Green mussel | |
| ៥០ | គ្រំចបជីក | *Atrinavexillum* | Fleg pen shell | |
| ៥១ | គ្រំយក្ស | *Tridacna* sp. | Giant clam | ប្រភេទកំពុងរងគ្រោះ |
| ពពួកមឹក (ប្រភេទដែលពិនិត្យឃើញក្នុងពេលសម្ភាសន៍) | | | | |
| ៥២ | មឹកពីងពាង | *Octopus sp.* | | |
| ៥៣ | មឹកស្នូក | *Sepiellainermis* | Spineless cuttlefish | |
| ៥៤ | មឹកបំពង់ | *Uroteuthisduvaucelii* | | |
| ៥៥ | មឹកដូង | *Sepiola sp.* | | |
| ប្រភេទកំពុងរងគ្រោះថ្នាក់ (ប្រភេទដែលផ្ដល់ព័ត៌មានដោយអ្នកនេសាទនិងមន្ត្រីជលផលខេត្ត) | | | | |
| ៥៦ | ផ្សោតឃ្លៀច | *Sousa chinensis* | Indo-Pacific humpback dolphin | ប្រភេទកំពុងរងគ្រោះ |
| ៥៧ | ផ្សោតឥតព្រុយខ្នង | *Neophocaenaphocaenoides* | Finless porpoise | ប្រភេទកំពុងរងគ្រោះ |
| ៥៨ | ផ្សោតក្បាលត្រ | *Orcaellabrevirostris* | Irrawaddy dolphin | ប្រភេទកំពុងរង |

| | | | | |
|---|---|---|---|---|
| | ទ្បោក | | | គ្រោះ |
| ៥៩ | ល្មិច | *Chelonia* | Green turtle | ប្រភេទកំពុងរងគ្រោះ |
| ៦០ | ក្រាស | *Eretmochelys imbricate* | Hawksbill turtle | ប្រភេទកំពុងរងគ្រោះ |
| ៦១ | ប្រឡាំងកាស | *Tachypleus gigas* | Triangular-tail horseshoe crab | ប្រភេទកំពុងរងគ្រោះ |
| ៦២ | ក្រចាប់ | *Protoreaster nodosus* | Horned sea star | |
| **ប្រភេទសត្វគ្មានឆ្អឹងខ្នង (ប្រភេទដែលពិនិត្យឃើញផ្ទាល់នៅពេលមុជស្រាវជ្រាវ)** | | | | |
| ៦៣ | កាំប្រម៉ា | *Diadema* urchins | Sea urchin | |
| ៦៤ | ឈ្លើងសមុទ្រ | *Holothuraatra* | Black Sea cucumber | |

តាមការស្រាវជ្រាវនិងប្រមូលព័ត៌មានពីអ្នកនេសាទបានបង្ហាញថា មានផ្សោតយ៉ាងហោចណាស់ បីប្រភេទមានវត្តមាននៅក្នុងតំបន់ប្រជុំកោះតាគៀវ (តំបន់កោះក្របី) ជាពិសេសក្នុងចន្លោះខែវិច្ឆិកាដល់ខែ មករា ជារៀងរាល់ឆ្នាំ។ ផ្សោតទាំងនេះហែលជាហ្វូងៗ បម្លាស់ទីពីតំបន់ផ្សេងៗ ពិសេសពីតំបន់ប្រជុំកោះរុង និងកោះតាង មកក្នុងតំបន់នេះដើម្បីចាប់ចំណីជាអាហារ ដូចជាត្រី មឹក និងបង្គា។ ក្រៅពីនេះ ម្តងម្កាល ពួកអ្នកនេសាទបានប្រទះឃើញត្រីបាឡែនក្នុងអំឡុងខែកញ្ញា ដើម្បីស៊ីគីជាអាហារ។

តាមក្រាហ្វិកទី២ ខាងក្រោមបានបង្ហាញថា ផលចាប់ជាមធ្យមក្នុងមួយគ្រួសារក្នុងមួយខែពុំមានការ ប្រែប្រួលទៅតាមខែនោះទេ គឺក្នុងចន្លោះពី៤៣៤ដល់៤៦០គីឡូក្រាម និងប្រមាណ៥.២៨០គីឡូក្រាមក្នុង មួយឆ្នាំក្នុងមួយគ្រួសារ។ មូលហេតុដែលផលដែលចាប់បានមានលក្ខណៈបេរនេះ គឺដោយសារតែការចាប់ មានការប្រែប្រួលទៅតាមរដូវនិងទៅតាមប្រភេទដែលសំបូរ។

តាមរយៈការសម្ភាសន៍ពីអ្នកនេសាទបានឲ្យដឹងថា មានប្រជាពលរដ្ឋប្រមាណ៥០គ្រួសារបាននិង កំពុងធ្វើនេសាទនៅក្នុងតំបន់ប្រជុំកោះតាគៀវ ប៉ុន្តែមានតិចតួច ប្រមាណ២០គ្រួសារបានធ្វើនេសាទនៅ ជុំវិញកោះក្របី។ តាមរយៈតួលេខនេះ យើងអាចគណនាបានថា ផលនេសាទដែលបានដកពីតំបន់កោះ ក្របីនេះមានជាមធ្យម ១០៥.៦តោនក្នុងមួយឆ្នាំ (៥២,៨០តោនX២០គ្រួសារ)។ ប្រសិនយើងយកតម្លៃ ទីផ្សារជាមធ្យម២,៨ដុល្លាក្នុងមួយគីឡូក្រាមផលជលផល នោះយើងអាច

គណនាតម្លៃសរុបដែលទទួលបាន ជារៀងរាល់ឆ្នាំពីតំបន់កោះក្របីប្រហែលជាង១០ម៉ឺនដុល្លាអាមេរិក។

នេះគ្រាន់តែជាការគណនាតម្លៃមួយឲ្យឃើញថា ប្រសិនមានការទប់ស្កាត់ការនេសាទក្នុងតំបន់កោះ ក្របី នោះប្រជាពលរដ្ឋទាំងមូលនឹងបាត់បង់ប្រាក់ចំណូលប្រមាណ ១០ម៉ឺនដុល្លាអាមេរិក ក្នុងមួយឆ្នាំ តាមរយៈការបាត់បង់ដែននេសាទ។ តែទោះជាយ៉ាងនេះក្ដី បើក្រុមហ៊ុនបានកំណត់ទីតាំងដែលហាមឃាត់ការនេសាទច្បាស់លាស់ ហើយមានកន្លែងផ្សេងៗទៀតជាច្រើនដែលប្រជា ពលរដ្ឋអាចធ្វើនេសាទបាននៅក្នុងតំបន់ប្រជុំកោះនេះ (ពីព្រោះពួកគេធ្វើនេសាទចល័តពីទីតាំងមួយទៅទី តាំងមួយទៀត) នោះអាចនឹងមិនបង្កបញ្ហាខ្លាំងដល់ពួកអ្នកនេសាទទេ។




ក្រាហ្វិកទី៣៖ ផលចាប់តាមខែក្នុងមួយគ្រួសារៗក្នុងតំបន់កោះក្របី




ក្រាហ្វិកទី៤៖ ផលចាប់សរុបតាមខែក្នុងតំបន់កោះក្របី

## ៤.២ លទ្ធផលនៃការស្រាវជ្រាវធនធានជីវចម្រុះនិងប្រភេទស្រទាប់បាត

តាមការស្រាវជ្រាវនៅបាតសមុទ្រក្នុងតំបន់ជុំវិញកោះក្របី ទាំង២០ទីតាំងបានបញ្ជាក់ថា ផ្កាថ្មគ្រប ដណ្តប់ពី០ដល់៧០% ហើយក្នុងចំណោមភាគរយនៃផ្កាថ្មនេះ មានប្រមាណ២០ដល់៥០% ភាគរយជា ផ្កាថ្មងាប់ ហើយមូលហេតុនៃការងាប់នេះភាគច្រើនបណ្តាលមកពីការប្រើគ្រឿងផ្ទុះក្នុង អតីតកាល និង ដោយសារកំទិចកំទីព្រមទាំងកករព័ទ្ធផ្កាថ្ម។ តាមការអង្កេតក៏មានផ្កាថ្មមួយចំនួន បានងាប់ដោយបម្រែបម្រួល អាកាសធាតុដែរ ជាពិសេសក្នុងឆ្នាំ២០១០ ហើយពុំបានស្តារឡើងវិញ។ ទោះជាយ៉ាងនេះក្តី គេឃើញមាន ផ្កាថ្មតូចៗមួយចំនួនទើបនឹងដុះឡើងវិញ ហើយអាចនឹងធ្វើឲ្យ តំបន់នេះសម្បូរផ្កាថ្មឡើងវិញបាន ប្រសិន មានការការពារបានត្រឹមត្រូវ។ ជារួម ផ្កាថ្មនៅទីតាំងនេះ ជាប្រភេទផ្កាថ្មរឹង ភាគច្រើនពពួកផ្កាថ្មចង្កេរ ប៉ុន្តែ មានផ្កាថ្មទន់និងរឹងមួយចំនួនទៀតផងដែរ។

ទីតាំងដែលសម្បូរផ្កាថ្ម ហើយដែលត្រូវយកចិត្តទុកដាក់ក្នុងការការពារ គឺទីតាំង ១ ២ ៣ ៧ ៨ ៩ ១០ ១១ ១២ ១៣ ១៧ ១៩ និង២០ ចំណែកទីតាំង ៤ ៥ ៦ ១៤ ១៥ ១៦ និង១៨ មានផ្កាថ្មតិចតួចបំផុត។ រូបទី៥ និងតារាងទី៥ ខាងក្រោមបង្ហាញលំអិតពីធនធានជលផលនិងជីវចម្រុះស្រទាប់ បាតក្នុង ទីតាំងនីមួយៗ។ ចំពោះទីតាំងដែលមានវត្តមានផ្កាថ្ម ភាគច្រើនមានពីមាត់ច្រាំងរហូតដល់ ចម្ងាយ២០០ ម៉ែត្រទៅក្នុងសមុទ្រ ដែលមានជម្រៅទឹកពី១ដល់៦ម៉ែត្រ។

តាមលទ្ធផលនៃការស្រាវជ្រាវបានបញ្ជាក់ច្បាស់ថា ទីតាំងដែលសម្បូរផ្កាថ្ម គឺទីនោះសម្បូរត្រី។ ពពួកត្រីសេកនិងត្រីមេអំបៅមានវត្តមានជាបង្គួរនៅក្នុងតំបន់ផ្កាថ្ម ហើយប្រភេទត្រីទាំងពីរនេះ ជាសូចនាករ បង្ហាញពីវត្តមាននិងសុខភាពផ្កាថ្ម។ ជាក់ស្តែង ក្នុងទីតាំងទី១ ២ ៣ ១០ ១១ ១៣ និង ១៧ នៅពេល ដែលផ្កាថ្មស្ថិតក្នុងស្ថានភាពល្អប្រសើរ វត្តមានហ្វូងត្រីសេក និងហ្វូងត្រីមេអំបៅក៏ មានវត្តមាននៅទីនោះដែរ ដូច្នេះត្រូវមានវិធានការការពារ និងរៀបចំទីតាំងទាំងនេះសម្រាប់ ជាកន្លែងស្រាវជ្រាវ អភិរក្ស និងបម្រើអេកូ ទេសចរណ៍។ ជាងនេះទៅទៀត ការបង្ហូរកាកសំណល់ឬ កករដីពីតំបន់ដីគោក ឬការកាយដីក្នុងទីតាំងលើ គោកក្បែរទីតាំងនេះគួរមានការហាមឃាត់ឬត្រូវ មានការប្រុងប្រយ័ត្នខ្ពស់។

តារាងទី៥៖ លទ្ធផលស្រាវជ្រាវធនធានជលផលស្រទាប់បាតនៅជុំវិញកោះក្របី

| ទីតាំង (A=Area) | ជម្រៅទឹក (m) | កម្រិតថ្លា (m) | ប្រភេទស្រទាប់បាតសំខាន់ៗ និងប្រភេទត្រី | រូបថត |
|---|---|---|---|---|
| A01<br>0343600<br>1161696 | 2,2 | 2,5 | នៅទីតាំងនេះមានផ្កាថ្មគ្របដណ្តប់ប្រមាណ៧០ % ក្នុងនោះងាប់២០% , ៣០%កំទេចកំទីសំបកសិប្បី សត្វ និងខ្សាច់។ មានពពួកកាំប្រម៉ាសមុទ្រ (Sea Urchin), Delicate Whip Coral, Barrel Sponge, មានហ្វូងកូនត្រី Red-striped **Cardinal fish** (Family Apogonidae) និងមានត្រីសេកទំហំ ២០សម ។ ផ្កាថ្មមានចំងាយប្រមាណ១០មពីឆ្នេរ ។ |  |
| A02<br>0343589<br>1161573 | 4,2 | 2,5 | នៅលើទីតាំងនេះមានផ្កាថ្មគ្របដណ្តប់៧០% ក្នុងនោះ ងាប់៣០%។ មានត្រីមេអំបៅ២ក្បាល (Butterfly fish) Seafan, Sponge និងហ្វូងកូនត្រីមេអំបៅ) និងត្រីសេកទំហំក្រោម២០សម ជាច្រើនរស់នៅក្នុង ចំណុចនោះ។ ជាចំណុចមានធនធានជលផលសម្បូរ បែបហើយផ្កាថ្មស្ថិតក្នុងស្ថានភាពល្អប្រសើរ។ |  |

| | | | | |
|---|---|---|---|---|
| | | | |  |
| A03<br>0343570<br>1161493 | 3,3 | 2,5 | មានផ្កាថ្មគ្របដណ្តប់ប្រមាណ៨០% ក្នុងនោះងាប់ ប្រមាណ ២០%។ មានប្រភេទ Sea Fan, Sponge និងមានហ្វូងកូនត្រីក្នុងតំបន់ថ្មនិងត្រីសេកជាច្រើនរស់នៅ ក្នុងចំណុចនោះ។ ជាចំណុចមានធនធាន ជលផលសម្បូរបែបដែលត្រូវការពារ។ |  |
| A04<br>0343555<br>1161416 | 6,3 | 1,5 | បាតសមុទ្រក្នុងទីតាំងនេះសម្បូតទៅដោយកំទេចកំទីសំបកខ្យងខ្ចៅ និងមានប្រភេទSea Fan ដុះមួយៗ។ មានប្រភេទគ្រុំចបតិចតួច តែគ្មានហ្វូងត្រីទេ។ |  |
| A05<br>0343684<br>1161479 | 6,1 | 1 | បាតសមុទ្រក្នុងទីតាំងទី៥នេះសម្បូរទៅដោយកំទេចកំទីសំបកខ្យងខ្ចៅ។<br>មានគ្រុំចបតិចតួនិងពុំមាន ប្រទះឃើញហ្វូងត្រី |  |

| | | | | |
|---|---|---|---|---|
| | | | ទេ។ | |
| A06<br>0343691<br>1161586 | 6,5 | 1 | បាតក្នុងទីតាំងនេះជាប្រភេទខ្សាច់ភក់ មានរន្ធតូចៗ ជាមធ្យម២/១ម² និងពុំមានហ្វូងត្រីទេ។ |  |
| A07<br>0343444<br>1161470 | 5,5 | 1,5 | នៅក្នុងតំបន់នេះមានផ្កាថ្មគ្របដណ្តប់ប្រមាណ៥0% ដែលជាពពួកផ្កាថ្មទន់១០% និងរឹង៩០% ហើយ ប្រហែល៥០% ងាប់។ ក្នុងការមុជនៅទីតាំងនេះមាន ប្រទះឃើញហ្វូងកូនត្រីសេកជាច្រើន និងប្រភេទ កាំប្រម៉ាសមុទ្រ។ មានប្រភេទSea Fan និង Sponge ដុះមួយៗ។ ជារួមទីតាំងនេះមានសក្តានុពល នៃធនធានជលផល។ |  |
| A08<br>0343325<br>1161492 | 5,8 | 1,5 | នៅទីតាំងនេះមានផ្កាថ្មគ្របដណ្តប់៥០% ក្នុងនោះ ងាប់ ៥០%។ ក្នុងការមុជក្នុងទីតាំងនេះ មានជួប ប្រភេទត្រីអាំងកើយ២ក្បាល (លើស២០សម)ធំៗ , ត្រីគុកែធំៗ២ក្បាលផងដែរ។ |  |

| | | | | |
|---|---|---|---|---|
| A09<br>0343242<br>1161547 | 5,77 | 2 | ទីតាំងនេះមានខ្សាច់៦០% ផ្កាថ្ម៤០%ក្នុងនោះងាប់ ៤០% ហើយភាគច្រើនផ្កាថ្មជាប្រភេទCF, ផ្កាថ្មទាំងនេះដុះពីលើផ្ទាំងថ្មធំៗ។ ជាទីតាំងសម្បូរផ្ទាំងថ្ម និង មានផ្កាថ្មដុះពីលើ។ |  |
